សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ
Research and Promotion Khmer Laws Association

# ការសិក្សា ច្បាប់ គ្រប់មាត្រាទាំងអស់

## ក្នុង

# ក្រមរដ្ឋប្បវេណី

## របស់ អេង សុត

## នៅក្រសួងយុត្តិធម៌

## ១៩៦៧

បោះពុម្ពលើកទី១

# អារម្ភកថា

សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ ស្ថិតក្នុងទស្សនវិស័យច្បាស់លាស់មួយ ដែលបាន និងកំពុងបន្តនូវបេសកកម្មរបស់ខ្លួន ក្នុងការចូលរួមចំណែកលើកកម្ពស់តម្លៃប្រព័ន្ធយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការស្រាវជ្រាវ ចងក្រង និងផ្សព្វផ្សាយនូវរាល់អត្ថបទគតិយុត្តជាតិ និងអន្តរជាតិដែលក្នុងនោះរួមមានមិនត្រឹមតែបទដ្ឋានគតិយុត្តិក្នុងសម័យបច្ចុប្បន្នប៉ុណ្ណោះទេ គឺបានផ្តោតផងដែរទៅលើបទដ្ឋានគតិយុត្តដែលមានអត្ថិភាពក្នុងប្រវត្តិគតិយុត្តិខ្មែរ។

ក្រមរដ្ឋប្បវេណីចាស់ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២០ គឺជាក្រមរដ្ឋប្បវេណីដំបូងបំផុតក្នុងមត៌កគតិយុត្តរបស់កម្ពុជា។ ទោះបីជាក្នុងពេលបច្ចុប្បន្ននេះ ក្រមរដ្ឋប្បវេណីចាស់លែងមានអានុភាពអនុវត្តទាំងស្រុងក៏ពិតមែន ប៉ុន្តែច្បាប់នេះនៅតែជាឯកសារពិគ្រោះដ៏ពេញនិយម និងដែលមិនអាចខ្វះបានរបស់បណ្ដាអ្នកស្រាវជ្រាវទាំងឡាយ។ ច្បាប់នេះ ជាមូលដ្ឋានដ៏សំខាន់បំផុតមួយដែលត្រូវបានប្រើប្រាស់ ក្នុងក្របខ័ណ្ឌនៃការប្រៀបធៀបជាមួយនឹងនីតិវិជ្ជមាន ដើម្បីពង្រឹងពុទ្ធិពាក់ព័ន្ធនឹងវិស័យរដ្ឋប្បវេណី និងដើម្បីទទួលបាននូវគន្លឹះក្នុងការដោះស្រាយ ចំពោះបញ្ហាដែលកើតមានឡើងនៅក្នុងសង្គមជាក់ស្តែង។ ដោយយល់ឃើញពីសារសំខាន់ និងភាពចាំបាច់ខាងលើ និងដោយមើលឃើញពីបញ្ហាលំបាកមួយចំនួន ដូចជា សភាពចាស់ទ្រុឌទ្រោម និងភាពលំបាកក្នុងការអានជាដើម ដែលមានលើឯកសារច្បាប់នេះ ទើបសមាគមបានរៀបចំក្រុមការងាររបស់ខ្លួន ដើម្បីធ្វើការវាយឡើងវិញនូវអត្ថបទច្បាប់នេះ ក្នុងគោលបំណងចូលរួមលើកស្ទួយ និងអភិរក្សមត៌កគតិយុត្តិខ្មែរ និងជួយសម្រួលដល់ការស្រាវជ្រាវរបស់អ្នកស្រាវជ្រាវឱ្យកាន់តែមានភាពងាយស្រួល និងឆាប់រហ័ស។

សមាគមសង្ឃឹមថា សមិទ្ធផលដ៏ស្តួចស្តើងនេះនឹងអាចក្លាយជាចំណែកតូចមួយនៃការរីកចម្រើនរបស់លោកអ្នក។

ភ្នំពេញ, ថ្ងៃ២៥ ខែមិថុនា ឆ្នាំ២០១៥

ប្រធាន

សុខ ម៉ុនយៀង

# សមាសភាពក្រុមការងារ

សមិទ្ធផលនេះ លេចចេញជារូបរាងឡើងក្រោមការដឹកនាំដោយ៖


- **លោក សុង ប៊ុនឃៀង** : ប្រធានសមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ
  អ៊ីម៉ែល ៖ songbunkheang@khmerlaws.com
  songbunkheang@gmail.com
- **លោក អាត ច័ន្ទដារា** : អនុប្រធានសមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ
  អ៊ីម៉ែល ៖ ath.chandara@khmerlaws.com
  ath.chandara@yahoo.com


## សមាសភាពអ្នកវាយអត្ថបទ

**លោក ឈិន ដារិត, លោក អ៊ាក ស៊ុងរ័ត្ន, លោក ពេជ្រ សុផានី, លោក គី ដារ៉ូ និង លោក ហ៊ឹម អ៊ុយគាង**

## សមាសភាពអ្នកត្រួតពិនិត្យ និងផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធ

**កញ្ញា ធីម សុភាព, កញ្ញា អេង ស្រីលាប, កញ្ញា ចាន់ សុភារ៉ា, កញ្ញា ខេ កញ្ញា, កញ្ញា អេង ស៊ីវហ៊ា, លោក លី ស្រេង, លោក ហេង សុផារិទ្ធិ, លោក គេង លីណា, និងលោក ខុន ផានិត**

**ឆ្នាំ២០១៥**

# ក្រមរដ្ឋប្បវេណី
# ឆ្នាំ ១៩២០

# ក្រមរដ្ឋប្បវេណី
## មាតិកា ប្រារភ
## អំពីច្បាប់ និងអានុភាពនៃច្បាប់

**មាត្រា ១** ៖ ច្បាប់ជាវិធាន (ជាបន្ទាត់) របស់សង្គមជាតិដែលអាជ្ញាធរមានសមត្ថភាពតាក់តែងឡើង ដើម្បីតម្រូវឱ្យពលរដ្ឋទាំងអស់ឋិតនៅក្រោមអំណាចច្បាប់នោះ ។ ពលរដ្ឋណាមិនគោរពច្បាប់នេះទេ ពលរដ្ឋនោះនឹងត្រូវទទួលទោសពីកងកម្លាំងអាជ្ញាធរសាធារណៈ ។

**មាត្រា ២** ៖ (ក្រម៩១២ នស.៣០-១១-៥៤) សិទ្ធិតែងច្បាប់ជាភារៈរបស់អង្គការដែលមានសមត្ថភាព ។

**មាត្រា ៣** ៖ ច្បាប់ទាំងឡាយត្រូវដាក់ឱ្យប្រតិបត្តិក្នុងដែននៃព្រះរាជាណាចក្រ ក្រោយដែលព្រះករុណាជាអម្ចាស់ជីវិតទ្រង់បានប្រកាសឱ្យប្រើ ។ (ក្រមដូចខាងលើ)

**មាត្រា ៤** ៖ ការប្រកាសឱ្យប្រើនូវច្បាប់នីមួយៗកើតមកពីព្រះរាជក្រមដែលបញ្ជាក់ថាច្បាប់នេះកើតឡើងហើយ ហើយជាច្បាប់ត្រឹមត្រូវ ដែលត្រូវដាក់ឱ្យអាជ្ញាធរ (គឺអ្នករាជការមុខក្រសួង) ផ្សាយដល់សាធារណជន ។ ការប្រកាសឱ្យប្រើនេះញ៉ាំងជនក្នុងដែនព្រះរាជាណាចក្រទាំងមូលឱ្យទទួលប្រតិបត្តិតាម ។ (ក្រ. ដូចខាងលើ)

មាត្រា ៥, ៦, ៧, (ត្រូវនិរាករ, ហើយយកមាត្រា ២០ នៃរដ្ឋធម្មនុញ្ញតទៅនោះមកជំនួសវិញ)

(មាត្រា ២០ ៖ នៃរដ្ឋធម្មនុញ្ញ) ច្បាប់ត្រូវប្រតិបត្តិតាម ៖

- នៅភ្នំពេញកំណត់មួយគុត ក្រោយដែលបានចុះច្បាប់នោះក្នុងរាជកិច្ច ។
- នៅទីឯទៀត គឺក្នុងដែនស្រុកនីមួយៗកំណត់ ប្រាំពីរថ្ងៃគុតក្រោយដែលរាជកិច្ចបានចុះច្បាប់នោះទៅដល់សាលាស្រុក ។

ប៉ុន្តែ បើច្បាប់បានសំដែងថា ជាការប្រញាប់, ច្បាប់នោះត្រូវប្រើភ្លាមៗនៅក្រុងភ្នំពេញ ក្រោយដែលបានយកទៅបិទនៅសាលាក្រុង ហើយនៅក្នុងស្រុកនីមួយៗក្រោយ ដែលបានយកទៅបិទនៅសាលាស្រុក ។

**មាត្រា ៨** ៖ ច្បាប់ទាំងឡាយបញ្ញត្តិដើម្បីទៅអនាគត ច្បាប់ទាំងឡាយនោះគ្មានអនុភាពប្រតិសកម្មទេ ។

**មាត្រា ៩** ៖ ចៅក្រមទាំងឡាយមិនអាចជំរះក្តីដោយអាងលេសថាច្បាប់គ្មានសម្តែង, ច្បាប់មានន័យមិនច្បាស់ ឬមិនគ្រប់គ្រាន់បានឡើយ ។ ចៅក្រមណាអាងលេសយ៉ាងនេះ, ចៅក្រមនោះនឹងត្រូវទោសតាមបញ្ញត្តិនៃមាត្រា ២៥៥ ក្រមព្រហ្មទណ្ឌ ។

**មាត្រា ១០** ៖ បើបទបញ្ញត្តិនៃច្បាប់ មានការខ្វះចន្លោះ, ចៅក្រមត្រូវកាត់សេចក្តីតាមទំនៀមទំលាប់, តាមសមហេតុផល ឬតាមសមនឹងធម៌ ។

**មាត្រា ១១** ៖ ន័យរបស់ច្បាប់ ត្រូវបកស្រាយដោយឥតក្លែង ។

**មាត្រា ១២** ៖ ច្បាប់ជាទីគោរពទូទៅ ។ ច្បាប់បង្ខំប្រជាជនទាំងឡាយ ក្នុងព្រះរាជអាណាចក្រឲ្យប្រតិបត្តិតាម, វៀរលែងតែកាលណា មានការត្រូវអនុវត្ត

តាមវិធាននៃច្បាប់អន្តរជាតិ, នោះទើបត្រូវប្រតិបត្តិ តាមច្បាប់អន្តរជាតិវិញ ។ នៅប្រទេសកម្ពុជា សមភាពនៃវិនិច្ឆ័យ ចំពោះមុខច្បាប់ ជាមូលសាស្ត្រនៃសេចក្ដីរៀបរយសាធារណ ។ (ក្រ. ៩១៣ ដូចខាងលើ)

**មាត្រា ១៣** ៖ រូបកាយ និងទ្រព្យ នៃបុគ្គលម្នាក់ៗមិនត្រូវជនណាមករំលោភលើបានឡើយ ហើយត្រូវឋិតនៅក្រោមការឧបត្ថម្ភ, ក្រោមការការពាររបស់ច្បាប់ទៀតផង ។

**មាត្រា ១៤** ៖ ទាសភាព ត្រូវលុបចោល យ៉ាងដាក់លាក់ ។ ជនណាក៏ដោយក៏មិនអាចចាត់ចែងដោយបំពាននូវរូបបុគ្គលដទៃបានឡើយ ។

**មាត្រា ១៥** ៖ គេមិនអាចព្រមព្រៀងគ្នាជាពិសេស ដើម្បីតាំងបទបញ្ញាផ្ទុយពីច្បាប់ ដែលមានប្រយោជន៍ ដល់សេចក្ដីរៀបរយសាធារណ ឬដល់លោកចរិយាធម៌ឡើយ ។

**មាត្រា ១៦** ៖ ច្បាប់ទាំងឡាយ, បើមិនទាន់និរាករដរាបណា, នឹងនៅតែត្រូវអនុវត្តដរាបនោះ ។

**មាត្រា ១៧** ៖ ច្បាប់នីមួយៗត្រូវនិរាករ (ត្រូវលែងប្រើ) ហើយកាលណាបើអាជ្ញា ធរខាងតែងច្បាប់សម្រេចថាច្បាប់នោះមិនត្រូវយកទៅអនុវត្តទៀតទេ ។

**មាត្រា ១៨** ៖ និរាករណ៍ (ការលែងប្រើ ឬឈប់ប្រើ) អាចចែងដោយច្បាស់ ឬដោយតុណ្ហីភាព ។

និរាករណ៍ដោយច្បាប់ គឺជានិរាករណ៍ដែលមានបទបញ្ញត្តិនៃច្បាប់ថ្មី សំដែងយ៉ាងជាក់លាក់ថាច្បាប់នេះ ឬ ច្បាប់នោះត្រូវនិរាកណ៍ ។

និរាករណ៍ដោយតុណ្ហីភាពក្នុងខនេះ, ច្បាប់ថ្មីពិតមែនតែមិនបានសម្តែងឲ្យច្បាស់ថាច្បាប់នេះ ឬ ច្បាប់នោះត្រូវនិរាករណ៍ដូច្នេះមែន, តែគេអាចដឹងបានថាច្បាប់ថ្មីនិរាកណ៍ច្បាប់ចាស់ នោះអាស្រ័យមកគឺច្បាប់ថ្មី និងច្បាប់ចាស់មានបទបញ្ញត្តិមិនចុះសម្រុងគ្នាគឺថាច្បាប់ចាស់, មានបទបញ្ញត្តិផ្ទុយគ្នាស្រឡះគឺច្បាប់ថ្មី ។

**មាត្រា ១៩** ៖ ច្បាប់អាចត្រូវបន្ថែម, កែប្រែ ឬ និរាករតែដោយសារមានច្បាប់ថ្មី ។

# គន្ថីទី ១
# អំពីបុគ្គល
## មាតិកា ទី១

**មាត្រា ២០** ៖ បុគ្គលទាំងពួងមានសិទ្ធិច្រើនយ៉ាង ដែលកើតមកអំពីសញ្ជាតិ និងអំពីស្ថានភាព ដែលខ្លួនឋិតនៅក្នុងគ្រួសារ ។

សិទ្ធិទាំងអស់នោះ បូករួមមក ហៅថា សិទ្ធិស៊ីវិល (សិទ្ធិបវេណី) ។

## ចំពូកទី ១
## អំពីសញ្ជាតិ

**មាត្រា ២១** ៖ (ក្រ.លេខ ៩១៣ ន.ស ៣០-១១-៥៤) ដែលហៅថា សញ្ជាតិជាខ្មែរគឺជាចំណងមួយខាងសាសនាផង, ខាងនយោបាយផង ដែលចងរូបវន្តបុគ្គល និងនីតិបុគ្គលឲ្យជាប់ទៅនឹងរដ្ឋខ្មែរ ។ មានតែច្បាប់ខ្មែរ ។ ជាពិសេសខ្មែរណាបានសញ្ជាតិបរទេស ដោយបំពាននឹងបញ្ញត្តិទាំងឡាយនៃច្បាប់របស់ខ្មែរ, ខ្មែរនោះពិតជាប្រឆាំងយ៉ាងដាច់ខាត និងអំណាចរបស់ខ្មែរ ។

ច្បាប់មិនទទួលស្គាល់ ជាដាច់ខាតនូវការរើសកញ្ជេក អំពីដូងកែវខាងអម្បូរ ដោយសន្ទតរបស់ពលរដ្ឋ ឬ អំពីមតិខាងទស្សនវិជ្ជា ឬ ខាងសាសនា របស់ពលរដ្ឋដើម្បីឲ្យជននោះបាន ឬ បាត់នូវសញ្ជាតិក៏ទេ, ទាំងដើម្បីឲ្យជននោះ បានប្រើប្រាស់ ឬមិនបានប្រើប្រាស់នូវសិទ្ធិស៊ីវិល និងនយោបាយខ្មែរក៏ទេដែរ ។

សេចក្តីនេះ មានន័យដូច្នេះ ជាដើមថាច្បាប់មិនបានរើសកញ្ជេកឲ្យបានប្រយោជន៍ ឬ ឲ្យខាតប្រយោជន៍ ដល់ខ្មែរ រដ្ឋវាសី ភាគតិចដែលរស់នៅក្នុងដែនដី

នៃព្រះរាជាណាចក្រ ដូចជា ជ្វា, ចាម, ភូមា, លាវ, ខា, គួយ, ព្នង, ព័រ, ស្មៀង ល ... ទេ ព្រមទាំងមិនបានឃោគយល់ ឬ ស្អប់ខ្ពើមដល់ជនខ្មែរដែលមានអម្បូរជាម៉ានីល, ដល់ជនខ្មែរដែលមានដួងកែវជាហ្វីលីពីន ដែលគ្មានសញ្ជាតិឯណាផ្សេងទៀតក្រៅពីសញ្ជាតិជាខ្មែរទេ, ដល់ជនជាតិថៃអាស្រ័យនៅលើដែនដីដែលថៃទើបបង្វិលមកជូនប្រទេសកម្ពុជាតាមសន្ធិសញ្ញាចុះថ្ងៃ ២៣ មីនា ១៩០៧ ទេ ។

**មាត្រា ២២** ៖

១. ត្រូវបានសញ្ជាតិជាខ្មែរ ទោះបីជាកើតនៅទីណាៗក៏ដោយ ៖

ក. កូនមានខាន់ស្លាដែលកើតអំពីឪពុកខ្មែរ

ខ. កូនមានខាន់ស្លាដែលកើតអំពីម្ដាយខ្មែរ

គ. កូនឥតខាន់ស្លា កាលណាបើតុលាការមានភស្តុតាងច្បាស់ជាក់កើតអំពីឪពុក ឬ ម្ដាយដែលមានសញ្ជាតិជាខ្មែរ ។

២. ត្រូវទុកជាខ្មែរ កាលណាបើជននោះកើតក្នុងប្រទេសកម្ពុជា

ក. កូនដែលកើតពីឪពុក ដែលកើតក្នុងប្រទេសកម្ពុជាដែរ

ខ. កូនដែលកើតពីម្ដាយដែលកើតក្នុងប្រទេសកម្ពុជាដែរ

គ. កូនដែលកើតពីឪពុកម្ដាយមិនស្គាល់ឈ្មោះ ។ កូន ដែលទើបនឹងកើតហើយដែលគេរើសបានក្នុងប្រទេសកម្ពុជា ត្រូវទុកថាវាកើតក្នុងប្រទេសកម្ពុជា ។

**មាត្រា ២៣** ៖ ស្ត្រីបរទេស ដែលយកប្តីខ្មែរ មានខាន់ស្លាអាចបានសញ្ជាតិជាខ្មែរពីត្រឹមថ្ងៃរៀបអាពាហពិពាហតទៅ ទោះបីមានច្បាប់ឯណាបញ្ញត្តិផ្ទុយពីនេះក៏ដោយ ។

ស្ត្រីខ្មែរមិនបាត់សញ្ជាតិរបស់ខ្លួនដោយសាររៀបអាពាហពិពាហជាមួយជនបរទេសសោះទេ ។

**មាត្រា ២៤** ៖ វិវាទកម្មអំពីសញ្ជាតិ ត្រូវឡើងទៅតុលាការរដ្ឋប្បវេណី ដែលមានសមត្ថភាពត្រូវជំនុំជម្រះនូវបណ្តឹងទាមទារសញ្ជាតិ បណ្តឹងសុំលះបង់សញ្ជាតិ និងបណ្តឹងជម្លោះសញ្ជាតិជាខ្មែរដូចមានសំដែងខាងក្រោមនេះ ៖

ក្រុមអយ្យការត្រូវតាំងខ្លួនជាភាគីដើមជាដរាប ហើយត្រូវតែធ្វើសេចក្តីសន្និដ្ឋានជាលាយល័ក្ខណ៍អក្សរជាដាច់ខាត បើមិនធ្វើដូចនេះទេសេចក្តីសន្និដ្ឋាននោះត្រូវទុកជាមោឃៈ ។

**មាត្រា ២៤** ស្ទួន ៖ អាចសុំលះបង់សញ្ជាតិ ជាខ្មែរបាន :

១. ប្រពន្ធនៃខ្មែរណាដែលមានដួងកែវកំណើតជាបរទេស ហើយដែលអាពាហពិពាហរបស់នាងត្រូវរលាយដោយសារប្តីស្លាប់ ឬ ដោយសារការលែងលះ ។ មានលក្ខខ័ណ្ឌមួយទៀតថា ស្រីដែលអាចសុំលះបង់សញ្ជាតិជាខ្មែរបានលុះណាតែស្រីនោះបានយកប្តីខ្មែរគ្មានកូនសោះ ហើយម្យ៉ាងទៀត ច្បាប់នៃប្រទេសខ្លួនមិនបានផ្តាច់សញ្ជាតិខ្លួនក្នុងពេលដែលខ្លួនមានប្តីខ្មែរនេះទេ ឬ ក៏ច្បាប់នោះព្រមឲ្យសញ្ជាតិដើមដល់ខ្លួនវិញដោយហេតុមេម៉ាយ ឬ ក៏លែងប្តីហើយ ។

២. ជនដែលកើតក្នុងប្រទេសកម្ពុជាពីម្ដាយដែលកើតក្នុងប្រទេសកម្ពុជាដែរកាលណាបើមានលក្ខខ័ណ្ឌច្បាស់ថា ៖

ក. ឪពុក និងម្ដាយមានសញ្ជាតិជាបរទេស

ខ. ច្បាប់ជាតិរបស់ឪពុក ឬ ម្ដាយឲ្យសញ្ជាតិណាមួយខាងឪពុក ឬ ខាងម្ដាយដល់ជននោះពេញច្បាប់ដោយហេតុមកពីបុត្តភាពរបស់ខ្លួន ឬ ដោយហេតុមកពីខ្លួនសុំលះបង់សញ្ជាតិជាខ្មែរ ។

គ. ឪពុក និងម្ដាយមានសញ្ជាតិជាបរទេស

៣. ជន ដែលកើតក្នុងប្រទេសកម្ពុជាពីឪពុកម្ដាយមិនស្គាល់ឈ្មោះកាលបើថ្ងៃក្រោយហើយជននោះប្ដឹងថាបានស្គាល់ឪពុកម្ដាយវិញហើយ ហើយអាចជនបាននូវភស្តុតាង និងជនដែលកើតក្នុងប្រទេសកម្ពុជាពីម្ដាយដែលកើតក្នុងប្រទេសកម្ពុជាដែរ ។

ក៏ប៉ុន្ដែជននេះ ឬ បើជននេះនៅក្នុងអនីតិភាព, រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលជាអាណាព្យាបាលបើជននោះ ឬ បានរក្សា ជននេះអាចសុំតុលាការឲ្យចេញសាលក្រម គ្រាន់តែកត់សំគាល់ថាឪពុក ឬ ម្ដាយខ្លួនដែលមិនស្គាល់ឈ្មោះពីថ្ងៃមុននោះឥឡូវបានដឹងហើយថាគាត់មានសញ្ជាតិមួយផ្សេងទៀតក្រៅពីសញ្ជាតិខ្មែរបានដោយមិនឲ្យខូចខាតដល់សញ្ជាតិខ្មែរដែលខ្លួនបានហើយនោះទេ ។ នីតិវិធីក្នុងការសុំនេះក៏ដូចជានីតិវិធីដែលមានសំដែងក្នុងមាត្រា ២៦ ថ្មីនៃក្រមរដ្ឋប្បវេណីនេះដែរ ។ តុលាការអាចសម្រេចថាឪពុក ឬ ម្ដាយនៃជននោះដែលមានលិខិតជាផ្លូវការត្រឹមត្រូវតាមច្បាប់នោះមានសញ្ជាតិនេះ ឬ សញ្ជាតិនោះបាន ។

**មាត្រា ២៤** ត្រី ៖ (ក្រ. លេខ ៣៥៧ ន.ស ២៨-១០-៥៤) អាចទាមទារសញ្ជាតិជាខ្មែរបាន ៖

១. ជនដែលមានអម្បូរជាខ្មែរ ដូចដែលមានសំដែងក្នុងមាត្រា ២២ ថ្មី នៃក្រមរដ្ឋប្បវេណីនេះមានលំនៅក្រៅព្រះរាជាណាចក្រកម្ពុជា ហើយត្រឡប់មកប្រទេសកម្ពុជាវិញ ដោយមានប្រាថ្នាថានឹងនៅជាប់តទៅ ។ ក្នុងករណីនេះ, ជននោះអាចសុំទាមទារសញ្ជាតិក្រោយថ្ងៃដែលបានចុះចុងក្រោយបំផុតនូវទិដ្ឋាការឲ្យចូលមកដែនកម្ពុជា បី ឆ្នាំ ។

២. ជនដែលកើតមុនថ្ងៃប្រកាសឲ្យប្រើច្បាប់នេះ ហើយដែលកើតអំពីឪពុក ឬ ម្តាយខ្មែរ ឬ កូនកាត់ខ្មែរ កាលបើច្បាប់ជាធរមានក្នុងខណៈដែលកើតនោះមិនបានឲ្យជននោះបានសញ្ជាតិជាខ្មែរដោយងាយទេ ។

អ្នកទាមទារ សញ្ជាតិត្រូវស្បថដូចអ្នកសុំសញ្ជាតូបនីយកម្មដែលគ្រាន់តែផ្លាះពាក្យក្នុងសំបថនោះពីចូលសញ្ជាតិមកជាទាមទារសញ្ជាតិវិញតែប៉ុណ្ណោះ ។

តុលាការអាចភ្ជាប់ឈ្មោះ សាមីជននេះ, តាមសេចក្តីសុំ របស់ឈ្មោះនេះ, ទៅនឹងឈ្មោះត្រកូល ដែលមានសំឡេងជាខ្មែរ ។ ការសុំទាមទារសញ្ជាតិនេះមានអនុភាពឲ្យបានសញ្ជាតិជាខ្មែរមិនតែសាមីជនប៉ុណ្ណោះទេ គឺបានដល់កូន ដែលនៅជាអនីតិជនក្នុងខណៈដែលទាមទារសញ្ជាតិនេះផង ។

អ្នកទាមទារសញ្ជាតិត្រូវហាមមិនឲ្យបានក្នុងរវាងប្រាំឆ្នាំ :

១. នូវសិទ្ធិ នយោបាយ ដែលជាប់ នឹងគុណភាពនៃខ្លួនជាខ្មែរ

២. នូវសិទ្ធិឲ្យតែងតាំងខ្លួនជាចៅក្រម, ជាសេនានីក្នុងកងទ័ព និងជាអ្នករាជការក្នុងក្របខ័ណ្ឌជាន់ខ្ពស់ខាងរដ្ឋបាល ។

មាត្រា ២៥ ៖ (ក្រ. ៩១៣ ន.ស. ៣១-១១-៤៥) ខ្មែរ ណាបានលាពីសញ្ជាតិឯងដោយរដ្ឋាភិបាលខ្មែរបានអនុញ្ញាតិយល់ព្រម ផងហើយទៅយកសញ្ជាតិជាបរទេស, ខ្មែរនោះត្រូវបាត់សញ្ជាតិខ្លួនជាខ្មែរពីត្រឹមថ្ងៃដែលបានសញ្ជាតិជាបរទេស ។

ក៏ប៉ុន្តែការបាត់សញ្ជាតិនេះគ្មានអានុភាពទៅលើសហព័ទ្ធ និងកូនទាំងឡាយដែលនោះជាខ្មែរនោះទេ ។

**មាត្រា ២៥** ៖ ស្ទួន (ក្រ.លេខ ៣៩៧ ន.ស. ២៦-១០-៥៩)

១. ជនជាតិខ្មែរ ដែលគ្មានអនុញ្ញាតិពីរាជការខ្មែរ ហើយចូលធ្វើជាទាហានដោយស្ម័គ្រចិត្តក្នុងកងទ័ព ដែលមិននៅក្រោមអំណាចរដ្ឋាភិបាលខ្មែរ ។

២. ជនជាតិខ្មែរ ដែលនៅបរទេស ហើយនៅតែធ្វើជាអ្នករាជការបរទេសថ្វីបើរដ្ឋាភិបាលខ្មែរ បានបញ្ជាដាច់ខាតឲ្យលាលែងពីមុខងារនោះក្នុងវេលាមានកំណត់ក៏ដោយ ។

៣. ជនជាតិខ្មែរដែលនៅបរទេស ហើយប្រកែកមិនព្រមចូលមកធ្វើទាហានក្នុងកងទ័ពខ្មែរ, ទាហាន ខ្មែរដែលរត់ទៅបរទេស, ទោះបីក្នុងពេលមានសន្តិភាពក៏ដោយ, និងជនជាតិខ្មែរ, ក្រោយដែលបានប្រព្រឹត្តបទប្រទុស្សរ៉ាយនឹងសេចក្តីសុខសាន្តក្នុងព្រះនគរ និងក្រៅព្រះនគរហើយរត់ទៅជ្រកនឹងបរទេសដើម្បីនឹងបន្តសកម្មភាពវិទ្ធង្សនាតទៅទៀត ។

៤. ជនដែលបានសញ្ជាតិជាខ្មែរដោយសារសញ្ជាតូបនីយកម្មហើយ :

ក. បានទទួលទណ្ឌកម្មជាស្ថាពរពីតុលាការខ្មែរ ឬ តុលាការបរទេស ជាទោសគុកបង្គ្រិមថ្នាក់ទី៣យ៉ាងតិច ។

ខ. បានធ្វើសកម្មភាពវិទ្ធង្សនា ប្រឆាំងនឹងកិច្ចការរដ្ឋាភិបាលនៃប្រទេសនេះយ៉ាងប្រាកដហើយថែមទាំងមានទោសទៀតផង ។

គ. បានបំពេញនូវកិច្ចការ ទាំងឡាយដែលមិនស្របនឹងគុណភាពខ្លួនជាខ្មែរជូនប្រយោជន៍ដល់រដ្ឋបរទេស, ហើយភស្តុតាងនៃការនេះត្រូវបានតុលាការរកឃើញទៀតផង ។

៥. ជនដែលបានសញ្ជាតិជាខ្មែរ ដោយសារការទាមទារសញ្ជាតិ ហើយបានទទួលទណ្ឌកម្មជាស្ថាពរ ដែលផ្តន្ទាទោសគុកយ៉ាងតិចត្រឹមគុកមជ្ឈិមថ្នាក់ទី៣ អំពីបទ ប្រទុស្សរ៉ាយនឹងសេចក្តីសុខសាន្តក្នុងព្រះនគរ និងក្រៅព្រះនគរ ។

៦. ជនដែលបានសញ្ជាតិជាខ្មែរទោះបានដោយសារអ្វីក៏ដោយ, នាកាលគណកម្មការដូចដែលមានសំដែងក្នុងកថាខណ្ឌខាងក្រោមនេះ ដឹងថាជននោះនិយាយភាសាខ្មែរមិនបានស្ទាត់ ឬ កាន់ទំនៀមទំលាប់, ប្រពៃណីខ្មែរមិនបានគ្រប់គ្រាន់ ។

៧. ជនដែលបានសញ្ជាតិជាខ្មែរតោះបានដោយសារអ្វីក៏ដោយ ហើយមិនបានឲ្យកូនទៅរៀននៅសាលារៀនខ្មែរ ។

នេះមិនទាន់និយាយដល់ទោសអាជ្ញាដែលតុលាការនិគ្រោសមានសមត្ថភាពត្រូវកាត់ផងទេ, ទាំងអស់នេះអាចត្រូវជម្លោះខ្លួនជននោះពីសញ្ជាតិជាខ្មែរបាន ។

បណ្ដឹងសុំជម្លោះសញ្ជាតិនេះ ត្រូវព្រះរាជអាជ្ញាខាងលំនៅនៃសាមីជនប្ដឹងតាមបង្គាប់ជាលាយល័ក្ខអក្សររបស់ក្រសួងយុត្តិធម៌ ដែលបានទទួលជាមុននូវយោបល់របស់គណកម្មការមានក្រសួងយុត្តិធម៌, មហាផ្ទៃ, សន្តិសុខជាតិ និងអប់រំជាតិបានសម្រេចរួមគ្នាដើម្បីកំណត់នូវសមាសភាព, មុខការ, និងបែបរបៀបធ្វើការនេះ ។

តុលាការ នឹងកាត់ឲ្យជម្លោះសញ្ជាតិដូចមានសម្ដែងក្នុងកថាខណ្ឌទី៤, ៥, ៦ និង៧ ខាងលើនេះបានតែក្នុងរយៈពេលវេលាដប់ឆ្នាំគិតតាំងពីថ្ងៃដែលជននេះបានជាស្ពាពរនូវសញ្ជាតូបនីយកម្ម ឬ នូវការទាមទារសញ្ជាតិ ។

**មាត្រា ២៦** ៖ (ក្រ.លេខ ៩១៣ នស. ៣០-១១-៥៤) បណ្ដឹងសុំលះបង់សញ្ជាតិ ឬ សុំទាមទារសញ្ជាតិនោះត្រូវសាមីជន ប្ដឹងទៅព្រះរាជអាជ្ញាខាងលំនៅខ្លួន ឬ បើខ្លួននៅបរទេសត្រូវប្ដឹងទៅព្រះរាជអាជ្ញានៅភ្នំពេញដោយធ្វើពាក្យមួយច្បាប់ជាលាយល័ក្ខអក្សរជាតិច្បាស់លាស់ ។

ក្រោយពីបានសើបសួរ តាមសេចក្ដីយល់ឃើញរបស់ខ្លួនថាគួរសមហើយព្រះរាជអាជ្ញាក៏ធ្វើដីការសន្និដ្ឋានមួយជូនសំណុំរឿងនោះទៅតុលាការ, តុលាការត្រូវតែជំរះរឿងនេះក្នុងរយៈពេលកុំឲ្យហួសពីបួនខែគិតពីថ្ងៃដាក់ពាក្យសុំមក ។

តុលាការគ្មានអំណាច នឹងពិនិត្យមើលថាមានពិរុទ្ធធ្ងន់ល្មមគួរឲ្យលះបង់សញ្ជាតិ ឬ ទាមទារសញ្ជាតិសោះទេ ។ តុលាការអាចត្រឹមផ្ទៀងមើលថាតើសាមីជនបានបំពេញល័ក្ខ ខ័ណ្ឌសព្វគ្រប់ល្មម នឹងឲ្យលះបង់សញ្ជាតិ ឬ ទាមទារសញ្ជាតិ ឬក៏បដិសេធពាក្យសុំចោលទាំងស្រុងតែម្ដងបាន ឬ ទេតែប៉ុណ្ណោះ ។

សេចក្តីសម្រេចរបស់តុលាការនេះបើផ្លូវឲ្យឧទ្ធរណ៍ និងសារទុក្ខជាង ហួសហែរតាមច្បាប់ក្រមពិភាក្សារដ្ឋប្បវេណី )

**មាត្រា ២៦** ស្ទួន ៖ (ក្រ. លេខ ៩១៣ ន.ស. ៣០-១១-៥៤) សេចក្តីសម្រេចរបស់តុលាការក្នុងរឿងជម្លោះសញ្ជាតិនេះ ១, សាលក្រមដែលអនុញ្ញាតិឲ្យលះបង់សញ្ជាតិ ឬ ឲ្យទាមទារសញ្ជាតិហើយឲ្យស្បថដូចមានសំដែងក្នុងមាត្រា ២៤ ត្រីខាងលើនេះ ១, ត្រូវយកទៅប្រថាប់ត្រាទទេគឺឥតគិតថ្លៃនៅការិយាល័យប្រថាប់ត្រានៅភ្នំពេញ ។ ម្យ៉ាងទៀតសេចក្តីសម្រេច និងសាលក្រមទាំងអស់ នោះត្រូវយកទៅចុះផ្សាយក្នុងសៀវភៅ "រាជកិច្ចរាជការ" ។ ជាទីបំផុតសេចក្តីសម្រេចនិងសាលក្រមនោះត្រូវយកទៅបិទបីខែនៅសាលាដំបូង និងសាលាខែត្រ ដែលជាទីតាំងនៅនៃសាលាដំបូងនោះ ។

**មាត្រា ២៧** ៖ (ក្រ. លេខ ៩១៣ ន.ស. ៣០-១១-៥៤) ការលះបង់សញ្ជាតិមានអានុភាពតែទៅលើសាមីជន អ្នកសុំប៉ុណ្ណោះទេ ។ ការជម្លោះសញ្ជាតិ មានអានុភាពតែទៅលើអ្នកផ្តស់ខ្លួនតែប៉ុណ្ណោះ ។ ការនេះ មិនបានធ្វើឲ្យសៅហ្មង ដល់គុណភាពជាខ្មែរ របស់សហព័ទ្ធ និងរបស់កូន ទាំងឡាយទេ ។ អ្នកផ្តស់ខ្លួនអាចសុំសញ្ជាតិជាខ្មែរបានទៀតតែត្រូវសុំសញ្ជាតូបនីយកម្មវិញ ។

គេអាចបានសញ្ជាតិជាខ្មែរ ដោយសារសញ្ជាតូបនីយកម្មតាមច្បាប់ជាធរមានបានដែរ ។

# ចំពូក មួយ ស្ទួន
# អំពីសញ្ជាតូបនីយកម្ម (ការសុំចូលសញ្ជាតិ)

(ក្រ. លេខ ៩០៤ ន.ស. ចុះថ្ងៃទី ២៧-៩-៥៤)

**មាត្រា ១** ៖ សញ្ជាតូបនីយកម្មមិនមែនជាសិទ្ធិ គឺជាសេចក្តីយោគយល់ដែលជនម្នាក់ត្រូវបានសុំសញ្ជាតិ ហើយពាក្យសុំនោះអាចត្រូវបដិសេធចោលបាន, ទោះបីអ្នកសុំនោះមានឋានៈដល់ថ្នាក់ណាក៏ដោយ ។

**មាត្រា ២** ៖ ជនបរទេស អាចក្រាបបង្គំទូលសូមព្រះករុណាជាអម្ចាស់ជីវិតធ្វើជាពលរដ្ឋព្រះអង្គបានប៉ុន្តែត្រូវមានល័ក្ខខណ្ឌដូចតទៅ :

១. ជននោះមិនជាអ្នកមានសិទ្ធិសុំទាមទារសញ្ជាតិទេ

២. មានគំនិតមាយាទ និងលោកចរិយាធម៌ល្អ ត្រឹមត្រូវ

៣. (ក្រ.លេខ ៣៥៧ ន.ស. ២-១០-៥៩) ចេះនិយាយភាសាខ្មែរ ហើយមាន ភស្តុតាងច្បាស់ថាជននោះកាន់ទំនៀមទំលាប់ និងប្រពៃណីខ្មែរយ៉ាងគ្រប់គ្រាន់ ។

៤. មានសេចក្តីបញ្ជាក់ថាជននោះមានទីស្នាក់ការអាស្រ័យក្នុងដែនដីនៃព្រះរាជាណាចក្ររវាងប្រាំឆ្នាំ ហើយតាំងពីមុនថ្ងៃដែលដាក់ពាក្យសុំនេះ ។

៥. ក្នុងពេលដែលដាក់ពាក្យសុំនេះក៏មានទីស្នាក់ការអាស្រ័យក្នុងប្រទេសកម្ពុជាដែរ ។

៦. រូបរាងកាយ និងប្រាជ្ញាស្មារតីនៃជននោះមិននាំឲ្យមានគ្រោះថ្នាក់ ឬឲ្យមានបន្ទុកដល់ជាតិឡើយ ។

**មាត្រា ៣** ៖ ការសាកល្បងក្នុងរវាងប្រាំឆ្នាំដូចមានសំដែងក្នុងមាត្រា ២ ត្រូវថយមកត្រឹមពីរឆ្នាំវិញ :

១. ដើម្បីជនបរទេសណាដែលកើតក្នុងប្រទេសកម្ពុជា

២. ដើម្បីឲ្យជនបរទេសណាដែលរៀបការនិងស្ត្រីខ្មែរ ។

**មាត្រា ៤** ៖ (ក្រ. លេខ ៣៥៧ ន.ស. ២៦-១០-៥៧) អ្នកសុំចូលសញ្ជាតិជាខ្មែរមិនត្រូវបានប្រើប្រាស់នូវសិទ្ធិនយោបាយ និងមិនត្រូវបានធ្វើជាអ្នករាជការរដ្ឋបាល ឬ តុលាការក្នុងរយៈពេលដប់ឆ្នាំ, វៀរមួយតែជននោះបានបំរើផលប្រយោជន៍ប្រទេសជាតិយ៉ាងសំខាន់ ដូចជាបាននាំចូលមកក្នុងប្រទេសកម្ពុជានូវឧស្សាហកម្ម ឬ នូវតក្កកម្ម(Invention) និងសង់គ្រឹះស្ថានឧស្សាហកម្មជាដើម, បើនិយាយឲ្យខ្លីទៅទៀតគឺជន ដែលបានបម្រើផលប្រយោជន៍ជាពិសេសដល់ប្រទេសកម្ពុជា ឬ ថាការបានសញ្ជាតិជាខ្មែរនៃជននោះនឹងលើកស្ទួយប្រទេសកម្ពុជាឲ្យបានប្រយោជន៍ច្រើនបំផុតតវ៉ា ។

**មាត្រា ៥** ៖ វៀរមួយទៀត ចំពោះជនបរទេសណាដែល, ក្នុងពេលមានសង្គ្រាម, បានមកធ្វើទាហានក្នុងកងទ័ពខ្មែរដោយស្ម័គ្រចិត្ត ហើយបានទទួលនូវគ្រឿងឥស្សរិយយសយ៉ាងតិចត្រឹមថ្នាក់កងវរសេនាតូចដោយសារសេចក្ដីក្លាហានអង់អាចរបស់ខ្លួននៅមុខបច្ចាមិត្រ, ជនបរទេសនោះអាចសុំចូលសញ្ជាតិជាខ្មែរបានដោយមិនចាំបាច់មានល័ក្ខខ័ណ្ឌអ្វីឡើយ ។

**មាត្រា ៦** ៖ ជនបរទេសណាមានប្រាថ្នាចង់ចូលសញ្ជាតិជាខ្មែរជនបរទេស

នោះត្រូវធ្វើចុតហ្មាយ តាមន័យនេះនាំទៅថ្វាយព្រះករុណាតាមរយៈចៅហ្វាយក្រុង ឬ ខែត្រ ។

ចៅហ្វាយក្រុង ឬ ចៅហ្វាយខែត្រធ្វើអង្កេតរដ្ឋបាលឲ្យដឹងថាអ្នកសុំបាន ប្រកបល័ក្ខខ័ណ្ឌទាំងឡាយ គឺទីស្នាក់អាស្រ័យក្នុងប្រទេសកម្ពុជា និងចរិយាធម៌ គ្រប់សព្វ ហើយឬនៅ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, មហាផ្ទៃ និងសាធារណ សុខាភិបាលត្រូវធ្វើសាវាចររួមគ្នាមួយដើម្បីកំណត់អំពីបែបរបៀប ដែលត្រូវអនុវត្ត មាត្រានេះ ។

**មាត្រា ៧** ៖ ចៅហ្វាយក្រុង, ចៅហ្វាយខែត្រ ត្រូវបញ្ជូនចុតហ្មាយ និង សំណុំរឿង ព្រមទាំងយោបល់របស់ខ្លួនមកជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងអំឡុង ពេល បី ខែ ។ សញ្ជាតូបនីយកម្មនេះត្រូវសម្រេចដោយព្រះរាជក្រឹត្យ ។ ការនេះ បណ្ដាលឲ្យសហព័ទ្ធ និងកូនដែលនៅជាអនីតិជនបានសញ្ជាតិជាខ្មែរដោយពេញ សិទ្ធិដែរ, វៀរលែងតែកាលណាសហព័ទ្ធនោះប្រើសិទ្ធិសុំលះបង់សញ្ជាតិដូចមាន ល័ក្ខខ័ណ្ឌដែលបានកំណត់ទុកក្នុងមាត្រា ២៤ ត្រីនៃក្រមរដ្ឋប្បវេណីនេះ និងម្យ៉ាង វិញទៀត បើសហព័ទ្ធនោះមិនបានភ្ជាប់ពាក្យរបស់ខ្លួនសុំសញ្ជាតូបនីយកម្មមក ជាមួយផងទេ ។

**មាត្រា ៨** ៖ ពាក្យសុំសញ្ជាតូបនីយកម្មអាចត្រូវបដិសេធតាមអំណាចឆន្ទានុ សិទ្ធិបាន ប៉ុន្តែការបដិសេធនេះក៏ត្រូវធ្វើជាព្រះរាជក្រឹត្យដែរ ។

**មាត្រា ៩**៖ ព្រះរាជក្រឹត្យ ដែលឲ្យសញ្ជាតូបនីយកម្មនេះអាចបន្ថែមបទ

បញ្ញត្តិមួយថាឲ្យអ្នកចូលសញ្ជាតិ ថ្មីនេះបានគោត្រកូលដែលមានសម្លេងជាខ្មែរបាន ។

**មាត្រា ១០** ៖ សញ្ជាតិជាខ្មែរត្រូវបានជាស្ថាពរតាំងពីថ្ងៃដែលអ្នកសុំនោះបានទទួលពីព្រះរាជអាជ្ញាខាងលំនៅខ្លួននូវដំណឹងថា ព្រះករុណាជាអម្ចាស់ជីវិតបានទ្រង់ព្រះមេត្តាប្រោសតាមពាក្យរបស់ខ្លួនសុំហើយ និងនូងដីការកោះឲ្យខ្លួនមកកាន់សវនាការ ស៊ីវិលដែលជិតជាងគេ ហើយបានស្បថនៅមុខតុលាការនូវសំបថដូចតទៅនេះ “ ខ្ញុំសូមសន្យាថា ខ្ញុំមានភក្តីភាព, មានសេចក្តីស្នេហា និងស្មោះចំពោះមាតុភូមិខ្មែររបស់ខ្ញុំ, ចំពោះរដ្ឋធម្មនុញ្ញ និងច្បាប់ខ្មែរ, ខ្ញុំសូមសន្យាថានឹងតាំងខ្លួនជាពលរដ្ឋគោរព និងជាអ្នកចំណុះស្មោះត្រង់និង ភក្តីនៃព្រះករុណាជាអម្ចាស់ជីវិត, ថានឹងទទួលផលទាំងអស់ដែលបណ្តាលមកពីការចូលសញ្ជាតិរបស់ខ្ញុំនេះនិងការពាររហូតបាត់បង់ជីវិតនូវបូរណភាព និងកិត្តិយសនៃប្រទេសកម្ពុជា” ។

**មាត្រា ១១** ៖ សំបថនេះត្រូវស្បថតាមទម្រង់ ដូចមានបញ្ញត្តិទុកក្នុងក្រមពិភាក្សាព្រហ្មទណ្ឌ ។ តុលាការមិនអាចប្រកែកមិនឲ្យស្បថដោយអាងលេសណាមួយឡើយ ។ តុលាការត្រូវចេញសាលក្រមឲ្យអ្នកបានសញ្ជាតិសាលក្រមនេះត្រូវយកទៅប្រថាប់ត្រាទទេគឺឥតយកថ្លៃនៅការិយាល័យប្រថាប់ត្រា ដែលតាំងនៅភ្នំពេញហើយសេចក្តីចំឡងនៃសាលក្រមនេះមួយច្បាប់ទៀត ត្រូវបិទបីខែនៅសាលាខែត្រ, សាលាដំបូង, សាលាឃុំខាងទីស្នាក់ការអាស្រ័យនៃអ្នកសុំសញ្ជាតិនេះ ។

## ជំពូក ២
## អំពីអត្រានុកូលដ្ឋាន (ភាពស៊ីវិល)

**មាត្រា ២៨** ៖ អត្រានុកូលដ្ឋាន (ភាពស៊ីវិល) នៃបុគ្គលម្នាក់ៗគឺជាឋានៈដែលបុគ្គលនោះកាន់កាប់ក្នុងគ្រួសារខ្លួនក្ដី, ក្នុងសង្គមជាតិក្ដី និងជាឋានៈដែលជាទីកើតនូវសិទ្ធិនិងករណីកិច្ចទាំងឡាយរបស់បុគ្គលនេះផង ។

**មាត្រា ២៩** ៖អត្រានុកូលដ្ឋានសញ្ញាប័ត្រ (សារលិខិតនៃភាពស៊ីវិល) គឺជាសំបុត្រសម្រាប់កត់រឿងរ៉ាវទាំងឡាយ ដែលទាក់ទងនឹងភាពស៊ីវិលនៃបុគ្គលទាំងឡាយនោះ ។

**មាត្រា ៣០** ៖ តាមមូលសាស្ត្រ, អត្រានុកូលដ្ឋានសញ្ញាប័ត្រនីមួយៗនឹងទុកជាសញ្ញាប័ត្រត្រឹមត្រូវបាន លុះណាតែសញ្ញាប័ត្រនោះបានធ្វើនៅមុខមន្ត្រីអត្រានុកូលដ្ឋាន, នៅមុខភាគី, អ្នកប្ដឹងនឹងនៅមុខសាក្សីទាំងឡាយ ។

**មាត្រា ៣១** ៖ មន្ត្រីអត្រានុកូលដ្ឋាន គឺជាមន្ត្រីដែលមាននាទីខាងទទួលពិនិត្យ, កត់រឿងសំខាន់ៗទាំងឡាយ ដែលទាក់ទងនឹងអត្រានុកូលដ្ឋាននៃបុគ្គល, ខាងតែងសញ្ញាប័ត្រនៃអត្រានុកូលដ្ឋាន, ខាងកាន់បញ្ជីសម្រាប់កត់ត្រាអត្រានុកូលដ្ឋាន, ខាងចេញកំណត់ដៃ(សេចក្ដីស្រង់) នៃសញ្ញាប័ត្រទាំងនោះ ។

**មាត្រា ៣២** ៖ មន្ត្រីអត្រានុកូលដ្ឋាននៃកន្លែងជាទីកើតឡើងនូវរឿងដែលខ្លួនត្រូវកត់ត្រាទើបបានសមត្ថភាពត្រូវពិនិត្យ, កត់រឿងនោះត្រូវតែងសញ្ញាប័ត្រអត្រានុកូលដ្ឋាន, ត្រូវកាន់បញ្ជីដូចមានសំដែងក្នុងមាត្រា៣១ខាងលើនេះ ។

**មាត្រា ៣៣** ៖ ភាគីគឺជនដែលមានភាព ឬ មានរឿងឲ្យគេកត់ក្នុង បញ្ជីអត្រានុកូលដ្ឋាន ។

**មាត្រា ៣៤** ៖ អ្នកប្តឹងគឺជន ដែលចូលទៅកាន់សំណាក់នៃមន្ត្រីអត្រានុកូល ដើម្បីប្តឹងអំពីរឿងដែលមន្ត្រីនេះមានភារៈត្រូវពិនិត្យ, កត់ក្នុងសញ្ញាប័ត្រដែលខ្លួនជាអ្នកធ្វើ ។

**មាត្រា ៣៥** ៖ សាក្សី គឺជន ដែលបញ្ជាក់ថាសេក្តីដែលគេនាំមកប្តឹងមន្ត្រីអត្រានុកូលដ្ឋាននោះពិតជាត្រឹមត្រូវហើយ និងដែលនាំឲ្យចៀសវាងពីការក្លែងបន្លំមិនឲ្យមានក្នុងធ្វើសញ្ញាប័ត្រនោះផង ។

**មាត្រា ៣៦** ៖ (ក្រ.លេខ ៩០៨ ន.ស ២៥-១០-៥៤) ក្នុងឃុំនីមួយៗមានបញ្ជីសំរាប់កត់កំណើត, កត់សេចក្តីប្រកាស អាពាហ៍ពិពាហ៍, កត់អាពាហ៍ពិពាហ៍ និងកត់មរណភាព ។

**មាត្រា ៣៧** ៖ បញ្ជីនោះត្រូវចាងហ្វាងសាលាដំបូងចុះសង្ខេបហត្ថលេខា និងលេខគ្រប់ទំព័រហើយដាក់ឲ្យមេឃុំកាន់រក្សា ឬ បើមេឃុំមានធុរៈ, ឲ្យជំទប់លេខ ១ កាន់រក្សាជួស ។

(ក្រមដូចខាងលើបន្ថែមដូចតទៅនេះ) ក៏ប៉ុន្តែដោយប្រមើលដល់ព្រឹត្តិការណ៍ក្នុងអនាគត, រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងមហាផ្ទៃអាចកែប្រែខ្លះដោយសេចក្តីសម្រេចរួមគ្នាមួយនូវរបៀបកាន់កាប់បញ្ជីអត្រានុកូលដ្ឋាននៃជនបរទេស ។ បទបញ្ញត្តិទាំងឡាយណាដែលមានរួចមកហើយតាមន័យនេះត្រូវទុកជាបានការយ៉ាងពិតទាំងអស់ ។

បទបញ្ញត្តិនោះមានដូច្នេះជាដើម, ឈ្មោះនៃជនបរទេសទាំងឡាយមិនត្រូវចុះតែជាអក្សរខ្មែរប៉ុណ្ណោះទេ គឺត្រូវចុះអក្សរកំណើត នៃជននោះផងដោយគោរពយ៉ាងដាច់ខាតនូវអក្ខរាវិរុទ្ធនៃកាសារនោះ, នោះប្រសិនបើអាចធ្វើបាន ។

**មាត្រា ៣៨** ៖ ក្នុងក្រុងភ្នំពេញចៅសង្កាត់ទាំងឡាយត្រូវកាន់រក្សាបញ្ជីទាំងឡាយនោះ ។

**មាត្រា ៣៩** ៖ បញ្ជីមួយត្រូវធ្វើជាភ្លោះ, ពីរខ, តាមគំរូនិងទម្រង់ដែលដាក់ជាប់នឹងច្បាប់នេះ ។ បញ្ជីនោះមិនត្រូវឲ្យមានកោស, លុប, ច្រៀត, ថែមទេ, បើមានឆូតលុប ត្រូវទុកស័ព្ទដែលលុបនោះឲ្យនៅមើលឃើញបានហើយយោងន័យលក្ខណៈនោះនៅរឹមទំព័រថា "យល់ព្រមលុប" ទើបឲ្យមន្ត្រីអត្រានុកូលដ្ឋាន, អ្នកប្តឹងនិងសាក្សីចុះហត្ថលេខាទាំងអស់គ្នា ។ សញ្ញាប័ត្រទាំងឡាយត្រូវចុះរៀងគ្នាពីមួយទៅមួយ, តៗគ្នាកុំបីចោលទំព័រឲ្យនៅទំនេរឡើយ ។

**មាត្រា ៤០** ៖ នៅថ្ងៃទី១ នៃខែនីមួយៗមន្ត្រីអត្រានុកូលដ្ឋានត្រូវស្រង់សេចក្តីដែលខ្លួនបានកត់ក្នុងបញ្ជីក្នុងខែ ដែលដាច់ទៅហើយធ្វើជាបញ្ជីចុះហត្ថលេខាខ្លួនបញ្ជូនទៅទីសមុហបញ្ជីសាលាដំបូងត្រួតពិនិត្យសេចក្តីនោះ, បើឃើញថាមានសេចក្តីភ្លាត់ភ្លាំងដើម្បីកែតម្រូវ, ត្រូវចេញសាលក្រមបង្គាប់ឲ្យកែតម្រូវតាមគួរ ។

**មាត្រា ៤១** ៖ បញ្ជីនោះត្រូវបញ្ឈប់ផ្តាច់ឆ្នាំ ទៅថ្ងៃទី ៣១ ធ្នូ ក្នុងឆ្នាំនីមួយៗ ។ សៀវភៅ ១ ក្បាល ត្រូវបញ្ជូនទៅសមុហបញ្ជីនៃសាលាដំបូងក្នុងខែ មករា ជាបន្ទាប់, សៀវភៅមួយក្បាលទៀតត្រូវទុកនៅបណ្ណសាដ្ឋានក្នុងឃុំ ឬក្នុងស្រុក, បើអង្គការឃុំមិនគប្បីឲ្យទុកបានទេ, ហើយផ្ញើនឹងមេឃុំ ឬ ស្មៀន,

យោក្ស័ត្រ, ឬ ក្រុមការសាលាស្រុកដែលមាននីតិសម្បទានក្នុងការនេះឲ្យថែរក្សា ។

**មាត្រា ៤២** ៖ អាពាហ៍ពិពាហ៍សញ្ញាប័ត្រ, ជាតិសញ្ញាប័ត្រ, មរណភាពសញ្ញាប័ត្រនៃព្រះរាជវង្សានុវង្ស ត្រូវដាក់ក្នុងបញ្ជីដោយឡែកដែលរក្សាទុកក្នុងទីព្រះរាជាយុត្តកៈនៅក្នុងបង្គាប់ត្រួតត្រានៃឧកញ៉ាវាំង ត្រួតត្រាឲ្យបានត្រឹមត្រូវហើយបញ្ជូនសេចក្ដីចម្លងមួយច្បាប់ ជាចាំបាច់ទៅចៅសង្កាត់ក្នុងរវាង ២៤ ម៉ោងតាមសេចក្ដីបញ្ញត្តិនៃព្រះរាជប្រកាស ចុះថ្ងៃអាទិត្យ ៨ រោជ ខែ ផគុណ ឆ្នាំវកសំរិទ្ធិស័ក ត្រូវនឹងថ្ងៃ ១៤ ខែ មារ្ស ឆ្នាំ ១៩០៩ ។ ចៅសង្កាត់ត្រូវចំឡងសេចក្ដីនេះមួយរំពេចដាក់ក្នុងបញ្ជីអត្រានុកូលដ្ឋានដែលខ្លួនរក្សា ។

**មាត្រា ៤៣** ៖ ព្រះរាជវង្សានុវង្ស នៃព្រះករុណាទ្រង់រាជ្យ និងព្រះករុណាសុវណ្ណកត់ ដែលមានសិទ្ធិត្រូវឲ្យគត់អត្រានុកូលដ្ឋានដោយឡែកដូចនេះបានត្រឹមតែព្រះរាជបុត្រ, ព្រះរាជនត្តា និងព្រះរាជបុត្រ ឬ ព្រះរាជនត្តានៃព្រះមហាក្សត្រយ៍ទ្រង់រាជ្យ ។

**មាត្រា ៤៤** ៖ ជនណា មានកាតព្វកិច្ច ត្រូវប្ដឹងកំណើត និងមរណភាពតាមសេចក្ដីបញ្ញត្តិនៃមាត្រាខាងក្រោមនេះហើយភ្លេច ឬ ធ្វេសប្រហែសមិនបានប្ដឹងដោយឥតហេតុដ៏គួរ, ជននោះនឹងត្រូវទណ្ឌកម្មជាលហុទោស ។

**មាត្រា ៤៥** ៖ ជនណាដោយមានក្លែងយកសេចក្ដីខុស ឬ ក៏បណ្ដោយឲ្យគេយកសេចក្ដីខុសទៅប្ដឹងមន្ត្រីអត្រានុកូលដ្ឋាន ឬ ប្រាប់នូវពត៍មានខ្វះ ឬ មិនពិត, ជននោះនឹងត្រូវទណ្ឌកម្មដាក់គុកពី ១៥ ថ្ងៃទី ៣ខែ ឬ ពិន័យពីដប់រៀលទៅមួយរយ

រៀល, បើចូលក្នុងបទឧក្រិដ្ឋក្លែងលិខិតជាផ្លូវការ ឬ សមគំនិតក្លែងលិខិតជាផ្លូវការ ដែលមានបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌក៏នឹងត្រូវឲ្យមានទោសនោះផងទៀត ។

**មាត្រា ៤៦** ៖ មន្ត្រីអត្រានុកូលដ្ឋានដោយធ្វេសប្រហែសមិនថែរក្សាបណ្ដាលជាយថាហេតុឲ្យខានធ្វើ, ឲ្យអន្តរាយ, ឲ្យខូច ឬ ឲ្យបំផ្លាញនូវសញ្ញាប័ត្រណាមួយ ឬ សៀវភៅណាមួយនឹងត្រូវទោសគុកពី ៦ថ្ងៃ ទៅ៣ខែ និងត្រូវពិន័យជាប្រាក់ពីដប់រៀលទៅមួយរយរៀល ឬ គ្រាន់តែជាប់គុក ឬ គ្រាន់តែពិន័យតែមួយយ៉ាងក៏បាន, តែបើឃើញថាមានទោសក្លែងផងនឹងត្រូវធ្វើទោសតាមបទល្មើសនោះដែរ ។

**មាត្រា ៤៧** ៖ (ព្រះរាជប្រកាស លេខ ៩៥ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ ១៩២៧) ៖ សាក្សី២ នាក់ដែលជានីតិជននោះ, ទោះស្រីក្តី, ប្រុសក្តីអំណេះតទៅត្រូវមិនឲ្យមានក្នុងសំបុត្រកំណើត និងសំបុត្រមរណភាពទេ ។ សាក្សី២នាក់នោះត្រូវឲ្យមានតែក្នុងសំបុត្រអាពាហពិពាហ តាមករណីដូចមានសម្តែងក្នុងបញ្ញត្តិមាត្រា ៦៨នៃក្រមនេះ ។

**មាត្រា ៤៨** ៖ បញ្ជីដែលកាន់រក្សាក្នុងទីសមុហបញ្ជីនៃសាលាដំបូងត្រូវទុកជាបន្ទាល់ក្នុងតុលាការដរាបដល់មានបន្ទាល់ផ្ទុយទើបត្រូវឈប់ ។ មន្ត្រីអត្រានុកូលដ្ឋានអាចចេញកំណត់ដៃ (សេចក្តីស្រង់) សញ្ញាប័ត្រដែលមានក្នុងឆ្នាំដែលកំពុងកាន់ឲ្យអ្នកសុំបាន ។

ឯបញ្ជីនៃឆ្នាំដែលកន្លងទៅហើយមន្ត្រីអត្រានុកូលដ្ឋានក្តី, សមុហបញ្ជីក្នុងសាលាដំបូងក្តីអាចចេញកំណត់ដៃ(សេចក្តីស្រង់) ឲ្យជនណាដែលសុំបានទាំងអស់

គ្នាហើយត្រូវបានខ្វាត់ ៣ រៀល ក្រៅពីថ្លៃតែមផង ។ ឯប្រាក់ខ្វាត់ ៣ រៀល នេះ ត្រូវបានជាប្រយោជន៍នៃមន្ត្រីអត្រានុកូលដ្ឋាន ឬ សមុហបញ្ជី, ស្មៀន, ឃោក្សត្រ, ក្រមការដូចដែលមានសំដែងមកខាងលើនេះ ។

ឯសេចក្តីស្រង់នេះត្រូវមន្ត្រីអត្រានុកូល ឬ សមុហបញ្ជី សាលាដំបូង, ស្មៀន , ឃោក្សត្រ, ក្រមការ ចុះហត្ថលេខា ហើយថ្លៃដែលចេញឲ្យត្រូវសរសេរជាអក្សរពេញអង្គ ។ ហត្ថលេខាមេឃុំ, ស្មៀន, ឃោក្សត្រ, ក្រមការត្រូវឲ្យចៅហ្វាយស្រុកបញ្ជាក់ ។ ឯហត្ថលេខាក្រឡាបញ្ជីត្រូវឲ្យចាងហ្វាងសាលាដំបូងចុះសេចក្តីបញ្ជាក់ផង ។

## ផ្នែកទី ១
## សញ្ញាប័ត្រ កំណើត

**មាត្រា ៤៩** ៖ នាកាលមានទារកកើតក្នុងឃុំ, នោះអ្នកមានកាតព្វកិច្ចត្រូវប្តឹងក្នុងកំណត់ ១៥ ថ្ងៃ ។

**មាត្រា ៥០** ៖ នឹងប្តឹងនូវកំណើតទារកនោះ, បើឪពុកនៅ, ត្រូវឲ្យឪពុកប្តឹង, បើឪពុកមិននៅ ឬ មានធុរៈ ឬ បើម្តាយនៃទារកនោះមិនមានប្តីតាមច្បាប់ទេ, ជនដែលបានទៅជួយធុរៈក្នុងវេលាកើត ឬ ជនដែលនៅជាមួយនឹងស្រីដែលបង្កើតកូននោះត្រូវប្តឹងតាមសេចក្តីបញ្ញត្តិ ។

**មាត្រា ៥១** ៖ ជនដែលបានឃើញទារកទើបនឹងកើត ដែលគេបោះបង់ចោលត្រូវយកទៅប្រគល់ឲមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំព្រមទាំងសំពត់ដែលជាប់នឹងខ្លួនទារកនោះហើយជូនពត៌មានអំពីពេល និងទីកន្លែងដែលខ្លួនបានប្រទះឃើញ

ទារកនោះផង ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវកត់ពត៌មាននោះក្នុងសៀវភៅកំណើត ហើយដាក់អាយុទារកនោះដោយស្មាន, ដាក់ឈ្មោះទារកនោះមួយរំពេច ។

**មាត្រា ៥២** ៖ ក្រមលេខ ៩០៨ នស. ២៥-១០-៥៤ ជាតិសញ្ញាប័ត្រត្រូវប្រាប់ថ្ងៃ ខែ ដែលទារកកើត, ភេទ នៃទារក "គឺជាប្រុស ឬស្រី" ឈ្មោះ ត្រកូល, ឈ្មោះទារក, របរ និងលំនៅដ្ឋាន នៃឪពុកម្ដាយ ។ ទារកដែលកើតក្រៅខាន់ស្លាត្រូវដាក់តែឈ្មោះម្ដាយ, បើឪពុកប្រាកដជាបានសុំឲ្យចុះឈ្មោះខ្លួនជាឪពុកផងទើបដាក់បាន ។

ក្រោយដែលបានតែងសញ្ញាប័ត្រនោះហើយ, មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ទៅអ្នកប្ដឹងដោយឥតយកថ្លៃនូវព្រឹត្តិប័ត្រមួយសន្លឹក ដែលមានចុះឈ្មោះទារកនោះ និងឈ្មោះឪពុកម្ដាយវាព្រមទាំងថ្ងៃ ខែ ឆ្នាំ ដែលកើតទៀតផង ។

ព្រឹត្តិប័ត្រ ដែលបានចេញឲ្យយ៉ាងនេះព្រមទាំងកំណត់ដៃនៃសញ្ញាប័ត្រអត្រានុកូលដ្ឋាន ដែលចេញឲ្យពីនេះទៅមិនត្រូវឲ្យមានចុះសេចក្ដីដូចតទៅនេះទេ, ល្គឹកណាបើចុះ, មន្ត្រីអត្រានុកូលដ្ឋាននឹងត្រូវមានទោសពិន័យជាប្រាក់មួយពាន់រៀលហើយនឹងត្រូវបង់ជម្ងឺចិត្តឲ្យគេទៀតក៏បាន ៖

១. លក្ខណៈនៃកំណើតនោះមានខាន់ស្លា ឬ ឥតខាន់ស្លា ។

២. ថ្នាក់នៃខាន់ស្លារបស់ឪពុកម្ដាយ ។

៣. របរ, អម្បូរ, សាសនា, ឬ សញ្ជាតិរបស់ឪពុកម្ដាយ

៤. ការណ៍ដែលកាលចុះបញ្ជីកំណើតនោះចុះដោយមានគេទៅប្ដឹងឲ្យចុះ ឬចុះតាមសាលក្រមជំនួយសញ្ញាប័ត្រកំណើត ។

ពត៌មានទាំងអស់នេះមានតែអាជ្ញាធរខាងរដ្ឋបាល ឬ ខាងតុលាការប៉ុណ្ណោះទេ ដែលអាចបង្គាប់ឲ្យគេជូនដល់ខ្លួនបានហើយក្នុងការជាអាថ៌កំបាំងទៀតផង ។

**មាត្រា ៥៣** ៖ បណ្ដឹងពីកំណើតទារកដែលកើតចេញអំពីឪពុកខ្មែរខាងក្រៅដែនកម្ពុជា គឺកើតក្នុងស្រុកណាមួយដែលពុំមានបង្កើតអត្រានុកូលដ្ឋានទេ ត្រូវឪពុកឬម្ដាយប្ដឹងមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំដែលខ្លួននៅក្នុងកំណត់៨ថ្ងៃ ក្រោយដែលវិលមកដែនខ្មែរវិញ, មន្ត្រីអត្រានុកូលដ្ឋានត្រូវកត់កំណើតនោះក្នុងបញ្ជីកំណើតក្នុងឆ្នាំនោះ ហើយចុះនិទ្ទេសនៅរឹមទំព័រនៃសញ្ញាប័ត្រកំណើតណាដែលមានថ្ងៃ.ខែ ជិតជាងគេក្នុងសៀវភៅមួយក្បាលៗ ដែលរក្សាទុកក្នុងបណ្ណសាដ្ឋាននៃសាលាឃុំ និងសមុហបញ្ជីនៃសាលដំបូងផង ។

បើទារកនោះកើតក្នុងប្រទេសដែលមានអត្រានុកូលដ្ឋាន ឬ ក្នុងបរទេសណាក៏ដោយឪពុកម្ដាយនៃទារក, កាលបើត្រូវគេដាក់កំហិតឲ្យបង្ហាញភស្តុតាងនូវបណ្ដឹងកំណើតកូនដែលបានប្ដឹងនោះអាចជូនកំណត់ដៃសញ្ញាប័ត្រតាមទម្រង់ដែលមានប្រើនៅប្រទេសនោះក៏បាន, ជូនសេចក្ដីចំឡងនៃសញ្ញាប័ត្រនោះដែលមានសេចក្ដីបញ្ជាក់ជាត្រឹមត្រូវប្រសិនបើឪពុកម្ដាយនោះបានសុំឲ្យចុះកំណើតរបស់កូនខ្លួនក្នុងបញ្ជីដែលភ្នាក់ងារទូត ឬ កុងស៊ុលនៃដែនជាមុខក្រសួងបានកាន់កាប់ ។

**មាត្រា ៥៤** ៖ ខ្មែរ ដែលកើតមុនមានបញ្ជីអត្រានុកូលដ្ឋានអាច នឹងធ្វើបុគ្គភាពរបស់ខ្លួនជាសំបុត្រ “ពង្សាវលី” ដែលមានសាក្សី ៣ នាក់ ជាមនុស្សគួរគេជឿបានមកបញ្ជាក់នៅមុខមេឃុំ តាមបែបដែលត្រូវធ្វើសំបុត្របានសេចក្ដីបញ្ជាក់នោះដែរ ។

បើបញ្ជីនោះគេមិនបានប្រើ ឬ បាត់ ឬ ខូចក៏ត្រូវធ្វើដូច្នេះដែរ ។

ក៏ប៉ុន្តែអ្នករាជការ, ភ្នាក់ងារ ឬ និយោជិតនៃក្រសួងរាជការផ្សេងជាអ្នកត្រូវបានបេឡាសោធន ឥណ្ឌាចិន ឬ សិទ្ធិវន្តនៃជនទាំងនោះធ្វើបញ្ជីជាតិរបស់ខ្លួនដែលមិនទាន់មានដោយហេតុដូចបានពោលទាំងពីរបែបខាងលើនេះឲ្យមានបានដោយសុំដល់ចាងហ្វាងសាលាដំបូងខាងទីកំណើតរបស់ខ្លួន, មិនមែនសុំមេឃុំទេ, ឲ្យចេញ Acte de notoriete tenant lieu d...cte d"haissanceឲ្យ។ ក្នុងលិខិតនេះត្រូវឲ្យមានហត្ថលេខាក្រឡាបញ្ជីព្រមទាំងហត្ថលេខាសាក្សី ៣ នាក់ទៀតផង ។

## ផ្នែកទី ២

## អំពីមរណភាព សញ្ញាប័ត្រ

**មាត្រា ៥៥** ៖ (ព្រះរាជប្រកាសលេខ ៩៥ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ ១៩៣៧) កាលបើមានមរណភាពក្នុងឃុំឯណាមួយអ្នកដែលបានផ្តល់ដំណឹងត្រូវប្តឹង, បើយ៉ាងយឺតណាស់ ៣ ថ្ងៃដល់មន្ត្រីអត្រានុកូលដ្ឋាន ។ មន្ត្រីនេះត្រូវធ្វើកំណត់ហេតុតាមបណ្តឹងនោះ ។ បើមានមរណភាពក្នុងគុក និងក្នុងមន្ទីររាជការសាធារណៈនោះត្រូវឆ្មាំនាយកគុក ឬ ចាងហ្វាងគុក ឬ ចាងហ្វាងទីនោះប្តឹង ។

**មាត្រ ៥៦** ៖ បើមន្ត្រីអត្រានុកូលដ្ឋានមិនបានចេញសំបុត្រធ្វើដោយក្រដាសលាតឥតថ្លៃឲ្យកប់នូវសពនោះទេ, ជនណានឹងយកទៅកប់មិនបាន ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវ អនុញ្ញាត្តិឲ្យកប់សពនោះក្រោយ ១២ ម៉ោងពីមរណៈដែលខ្លួនបានពិនិត្យដោយខ្លួនបាន ពិនិត្យដោយខ្លួនឯងឬជំទប់ពិនិត្យជួស ។

**មាត្រា ៥៧** ៖ អ្នកផងដែលបានប្រទះឃើញនូវសពណាមួយត្រូវប្ដឹងមន្ត្រីអត្រានុកូលដ្ឋានមួយរំពេច ។ មន្ត្រីនេះត្រូវទៅកាន់ទីកន្លែងនៃសពនោះ, សាកសួរពត៌មានឲ្យបានដឹងពីអត្តសញ្ញាណនៃសពហើយកត់ត្រាសេចក្ដីនោះក្នុងបញ្ជីមរណភាព ។

មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ចែងឲ្យកប់នូវសពនោះផង ។ តែប្រសិនបើមានស្លាកស្នាមជាទីនាំឲ្យមានសេចក្ដីសង្ស័យអំពីហេតុដែលស្លាប់នៅ, មន្ត្រីនេះត្រូវប្ដឹងអាជ្ញាធររដ្ឋបាល និងតុលាការឲ្យចេញសំបុត្រអនុញ្ញាតឲ្យកប់ក្រោយដែលបានចាត់ការជាចាំបាច់ គឺឲ្យស៊ើបរកឈ្មោះអ្នកប្រព្រឹត្តនូវឃាតកម្មនោះ ។

**មាត្រា ៥៨** ៖ មរណៈភាពសញ្ញាប័ត្រនោះត្រូវប្រាប់ត្រកូល, ឈ្មោះ, របរ, ទីលំនៅ, ថ្ងៃដែលស្លាប់ ។ ឯថ្ងៃខែ និងទីកើត និងឈ្មោះឪពុកម្ដាយនៃខ្មោចបើដឹងក៏ឲ្យដាក់ផង ។

**មាត្រា ៥៩** ៖ នាកាលខ្មែរម្នាក់ស្លាប់ក្រៅលំនៅខ្លួនដែលធ្លាប់នៅ, មន្ត្រីអត្រានុកូលដ្ឋានដែលធ្វើមរណភាពសញ្ញាប័ត្រនៃជននោះត្រូវបញ្ជូន, កុំឲ្យយឺតយូរ, នូវ សេចក្ដីចំឡងមួយច្បាប់ទៅមន្ត្រីអត្រានុកូលខាងលំនៅសព ។ មន្ត្រីអត្រានុកូលដ្ឋាននេះ ចំឡងសេចក្ដីនោះដាក់ក្នុងបញ្ជីមរណភាពដែលខ្លួនកាន់រក្សា ។ បើមរណភាពបានមានហើយក្នុងដែនដីបរទេស ហើយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនោះបានធ្វើមរណភាពសញ្ញាប័ត្រ ដែលតាមទម្រង់ដែលគេប្រើក្នុងប្រទេសគេ, សញ្ញាប័ត្រនោះត្រូវទុកជាត្រឹមត្រូវដរាបដល់មានភស្តុតាងផ្ទុយ ឬ

ម្យ៉ាងទៀត, បើមានភាគីណាម្នាក់ដែលមានប្រយោជន៍ក្នុងរឿងនេះបានសុំឲ្យចុះមរណភាពនោះក្នុងបញ្ជីមរណភាពសញ្ញាប័ត្រ ដែលមានរក្សាទុកក្នុងអង្គទូត ឬកុងស៊ុលនៃដែនដីមានសមត្ថភាព, សេចក្តីចំឡងនៃសញ្ញាប័ត្រនោះដែលមានសេចក្តីបញ្ជាក់ជាត្រឹមត្រូវទុកជាបន្ទាល់បានដែរ ។

## ផ្នែកទី ៣
## អំពីអាពាហ៍ពិពាហ៍ សញ្ញាប័ត្រ

**មាត្រា ៦០** ៖ នាកាល ការដណ្តឹងបានស្រេចហើយ, មេបាខាងប្រុស ខាងស្រីក៏បានសម្រេចថ្ងៃ. ខែ រៀបអាពាហ៍ពិពាហ៍ ហើយ, ឪពុក ឬម្តាយខាងប្រុស ខាងស្រី ឬ អ្នកដែលជួសឪពុកម្តាយត្រូវទៅប្តឹងមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំខាងស្រីអំពីអាពាហពិពាហនោះ ។

**មាត្រា ៦១** ៖ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើប្រកាសបិទនៅទ្វារសាលាឃុំដើម្បីផ្សាយភ្លាម ។

### ប្រកាសនោះត្រូវមានចុះ

១. ត្រកូល, ឈ្មោះ, អាយុ, របរ និងទីលំនៅនៃអនាគតប្តី, នៃអនាគតប្រពន្ធម្នាក់ៗ ។

២. ត្រកូល, ឈ្មោះ, អាយុ, មុខរបរ និងទីលំនៅនៃឪពុកម្តាយខាងប្រុស ខាងស្រី, បើឪពុកឬម្តាយស្លាប់ឲ្យដាក់ថាស្លាប់ផង

៣. ប្រពន្ធដែលនឹងរៀបការនោះមានខាន់ស្លាទីប៉ុន្មាន ។

ប្រកាសមួយច្បាប់ទៀតត្រូវមន្ត្រីអត្រានុកូលដ្ឋានបញ្ជូនទៅឲ្យមេឃុំខាងលំនៅនៃអនាគតប្តីប្រពន្ធឲ្យយកទៅបិទនៅទ្វារសាលាឃុំនោះភ្លាម ។

**មាត្រា ៦២** ៖ ប្រកាសនេះត្រូវបិទកំណត់ប្រាំបីថ្ងៃ ។ លុះផុតកំណត់នេះហើយទើបសាមីខ្លួនអាចរៀបការបាន ។

**មាត្រា ៦៣** ៖ មន្ត្រីអត្រានុកូលដ្ឋាន នាកាលបានទទួលបណ្តឹងទាស់ពីខាងណាហើយ, ត្រូវចុះសេចក្តីបណ្តឹងទាស់នោះយ៉ាងសង្ខេបលើប្រកាសនោះមួយរំពេច ។

**មាត្រា ៦៤** ៖ មន្ត្រីអត្រានុកូលដ្ឋានត្រូវឲ្យដំណឹងដំណឹងដល់អនាគតប្តីប្រពន្ធនោះអំពីបណ្តឹងទាស់ដែលខ្លួនបានទទួល ។ លុះតុលាការមានសមត្ថកិច្ចបានជំនុំជំរះបណ្តឹងទាស់នេះជ្រះស្រឡះ ហើយទើបមន្ត្រីអត្រានុកូលដ្ឋានអាចនឹងធ្វើអាពាហ៍ពិពាហ៍សញ្ញាប័ត្របាន, បើពុំដូច្នេះនោះទេ, មន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវមានទោសដែលមានសញ្ញាប័ត្រក្នុងមាត្រា ៤៦ នៃក្រមនេះ ។

**មាត្រា ៦៥** ៖ នៅថ្ងៃដែលរៀបការ រួចស្រេចហើយ ប្តីប្រពន្ធថ្មីនេះត្រូវទៅប្តឹងមន្ត្រីអត្រានុកូលដ្ឋានជាថ្មីទៀត, មន្ត្រីនេះបើឥតមានបណ្តឹងទាស់ទៀតទេ, ត្រូវចុះអាពាហ៍ពិពាហ៍នោះ ក្នុងបញ្ជីអាពាហ៍ពិពាហ៍ព្រមទាំងពត៌មានដែលបានជូនហើយពីថ្ងៃមុនផង ។ មន្ត្រីនេះត្រូវឲ្យប្តីប្រពន្ធថ្មី, ឪពុកម្តាយ ឬ ជនណាដែលបានជំនួសឪពុកម្តាយនិងអ្នកមហា ឬ សាក្សី២នាក់ចុះហត្ថលេខា ។ បើអ្នកប្តឹង និងសាក្សីមិនចេះសរសេរ និងចុះហត្ថលេខា មិនកើត, ត្រូវឲ្យផ្តិតមេដៃកត់ថាជននោះ

ចុះហត្ថលេខាមិនកើតទេ ។ ក្នុងលំដាប់នោះ, មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះហត្ថលេខា និងបោះត្រាក្នុងបញ្ជីនោះផង ។

ការដែលប្រុស និងស្រីយកគ្នាជាប្ដីប្រពន្ធមិនបានប្ដឹងប្ដល់តាមច្បាប់នោះ មិនត្រូវឲ្យមានទោសជាបទអាជ្ញាឡើយ តែការដែលយកគ្នាឥតប្ដឹងប្ដល់នេះមិនមានលក្ខណៈជា ធម្មានុរូប ហើយមិនមានអានុភាពខាងផ្លូវច្បាប់ដែលកើតមកពីអាពាហ៍ពិពាហ៍នោះឡើយ។

**មាត្រា ៦៦** ៖ ជនខ្មែរណារៀបការក្រៅដែនកម្ពុជា, ក្នុងប្រទេសដែលពុំមានរបៀបអត្រានុកូលដ្ឋានទេ, ហើយមានប្រាថ្នាចង់ឲ្យសមគ្គសង្វាសនៃខ្លួនមានលក្ខណៈជាធម្មា នុរូប, ជនខ្មែរនោះត្រូវប្ដឹងមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំដែលខ្លួននឹងតាំងទីលំនៅនោះឲ្យចុះអាពាហ៍ពិពាហ៍សញ្ញាប័ត្រឲ្យ ។

បណ្ដឹងនោះត្រូវចុះត្រឹមថ្ងៃដែលប្ដឹងក្នុងបញ្ជីអាពាហ៍ពិពាហ៍ហើយប្ដីដែលប្ដឹង និងប្រពន្ធត្រូវចុះហត្ថលេខាផង ។ បើរៀបការក្នុងប្រទេសដែលមានរបៀបអត្រានុកូលដ្ឋានវិញ, ប្ដីប្រពន្ធមិនចាំបាច់ប្ដឹងដូច្នេះជាថ្មីដើម្បីឲ្យអាពាហ៍ពិពាហ៍របស់ខ្លួនមានលក្ខណៈជា ធម្មានុរូបឡើយ, ប្ដីប្រពន្ធនោះយកតែសេចក្ដីស្រង់នៃអាពាហ៍ពិពាហ៍ដែលបានធ្វើក្នុងប្រទេស នោះមកប្រើក៏គ្រប់គ្រាន់ហើយ ឬ សេចក្ដីចំឡងនៃសញ្ញាប័ត្រដែលបានចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍នៅអគ្គទូត ឬ នៅកុងស៊ុលជាមុខក្រសួងក៏បានដែរ ។

**មាត្រា ៦៧** ៖ ប្ដីប្រពន្ធដែលរៀបការ មុនកើតបញ្ជីអត្រានុកូលដ្ឋាន និងយក

ប័ណ្ណ ឬ សាក្សីជាបន្ទាល់ក៏បាន ។ នាកាលបញ្ជីនោះគឺគេមិនបានប្រើ ឬ បាត់ ឬ ខូចក៏ត្រូវបញ្ជាក់ដូច្នេះបានដូចគ្នាដែរ ។

**មាត្រា ៦៨** ៖ នាកាលនឹងរៀបខាន់ស្លា ផ្សេងទៀតក្រៅពីខាន់ស្លាទី១, អាពាហ៍ពិពាហ៍នោះក៏ត្រូវឲ្យប្ដឹងមន្ត្រីអត្រានុកូលដ្ឋានជាមុខក្រសួងដូចគ្នាដែរ ។

**មាត្រា ៦៩** ៖ ក្នុងពេលវេលាដែលគូស្វាមីជនចូលមកប្ដឹងចូលមកប្ដឹងជាដំបូងអំពីខាន់ស្លារបស់ខ្លួន, មន្ត្រីអត្រានុកូលដ្ឋាន, មុននិងកត់ត្រា, ត្រូវសួរទៅគូស្វាមីជននិងសាក្សីនោះឲ្យដឹងប្ដីនោះមានប្រពន្ធដើមហើយ ឬ ប្រពន្ធថ្មីនេះនៅជាប់អាពាហ៍ពិពាហ៍ពីមុនដែរសិនទើបត្រូវចុះសេចក្ដីនោះក្នុងប្រកាសដែលត្រូវបិទផ្សាយនោះបាន ។

**មាត្រា ៧០** ៖ សាលក្រមដែលកាត់សេចក្ដីឲ្យលែងគ្នា, ត្រូវមន្ត្រីអត្រានុកូលដ្ឋានកត់ដាក់ទៅរឹមទំព័រនៃអាពាហ៍ពិពាហ៍សញ្ញាប័ត្រតាមសេចក្ដីដែលគូក្ដីណាមួយសុំ ឬ ក៏តាមសេចក្ដីសុំអំពីសមុហបញ្ជីក៏បាន ។

## ផ្នែកទី ៤
## បទបញ្ញត្តិពិសេស

**មាត្រា ៧១** ៖ បទល្មើសទាំងឡាយដែលមានបញ្ញត្តិក្នុងមាត្រា៤៥, ៤៦, ៦៤ និងត្រូវជំនុំជម្រះនៅសាលាមជ្ឈិម, ឯបទល្មើសដែលមានបញ្ញត្តិក្នុងមាត្រា ៤៤ នឹងត្រូវជំនុំជម្រះជាបទលហុតាមបណ្ដឹងរបស់ក្រសួងរដ្ឋបាល ឬ របស់សាមីជនទាំងឡាយបាន ។

**មាត្រា ៧២** ៖ ទោសដែលមានបញ្ញត្តិ ខាងលើនេះ នឹងត្រាប្រណីតាមបទបញ្ញត្តិនៃមាត្រា ១៣១ នឹងតទៅនៃក្រមព្រហ្មទណ្ឌ ដែលសំដែងអំពីស្ថានត្រាប្រណីបាន ។ **មាត្រា ៧៣** ៖ អត្រានុកូលដ្ឋានសញ្ញាប័ត្រនឹងកែប្រែ, បំពេញសេចក្តី ឬ កែតម្រូវបានលុះណាតែមានដីការបស់ចាងហ្វាង ឬ សាលក្រមនៃសាលាខាងកន្លែងដែលកត់សេចក្តីនោះបង្គាប់មក ។

កំណើត និងមរណភាពទាំងឡាយឯណា ដែលមិនបានប្តឹងក្នុងកំណត់ច្បាប់ដូចមានបញ្ញត្តិក្នុងមាត្រា ៤៩ និង៥៥នោះទេអាចនឹងសុំឲ្យពិនិត្យកត់នូវកំណើត និងមរណភាពទាំងឡាយ នោះបានដោយមានសាលក្រមនៃសាលាខាងកន្លែង ដែលកើត, ដែលស្លាប់នោះអនុញ្ញាតឲ្យ, សេចក្តីបង្គាប់នៃសាលក្រម ដែលកាត់សេចក្តីរឿងដូច្នេះត្រូវចុះនៅរឹមទំព័រនៃសញ្ញាប័ត្រដែលត្រូវកែប្រែបំពេញ ឬ កែតម្រូវនោះ ។

## មាតិកាទី ២
## អំពី លំនៅ

**មាត្រា ៧៤** ៖ ដែលហៅថា លំនៅ នៃបុគ្គលម្នាក់ៗ គឺទីកន្លែងដែលបុគ្គលនោះបានតាំងជាទីស្នាក់អាស្រ័យជាធម្មតា និងជាមជ្ឈមណ្ឌលដើមនៃកិច្ចការទាំងពួងផង ។

**មាត្រា ៧៥** ៖ ការដែលជនម្នាក់ៗចេញចាកទីមួយទៅនៅទីមួយទៀតព្រមដោយសេចក្តីប្រាថ្នាថានឹងតាំងទីសំណាក់នៃកិច្ចការទាំងពួងក្នុងទីនោះហៅថា ការផ្លាស់ទីលំនៅ ។

**មាត្រា ៧៦** ៖ ជនដែលចង់ផ្លាស់ទីលំនៅត្រូវធ្វើពាក្យឲ្យច្បាស់ ហើយយកទីកប្តឹងមេឃុំនៃឃុំ ដែលខ្លួននឹងចេញចាកទីនិងមេឃុំដែលខ្លួនប្រាថ្នានឹងទៅនៅដើម្បីឲ្យមេឃុំទាំងពីរឃុំនោះកត់ពាក្យនេះក្នុងសៀវភៅ ។

**មាត្រា ៧៧** ៖ ទីលំនៅនៃអ្នករាជការ គឺកន្លែង ដែលខ្លួនធ្វើរាជការ ។

**មាត្រា ៧៨** ៖ ប្រពន្ធ មានខាន់ស្លាមិនមានទីលំនៅឯណាផ្សេងអំពីទីលំនៅនៃប្តីឡើយ ។

**មាត្រា៧៩** ៖ អនីតិជនដែលមិនទាន់មានប្រពន្ធ ឬ ដែលមិនទាន់បានអត្តាធិនត្រូវមានលំនៅនៅផ្ទះឪពុកម្តាយខ្លួន ។ បើគ្មានឪពុកម្តាយទេត្រូវនៅនឹងផ្ទះអាណាព្យាបាល ។

**មាត្រា ៨០** ៖ ទីលំនៅ នៃជនគំហាត់ គឺផ្ទះរបស់ហិតូបត្ថម្ភក ។

**មាត្រា ៨១** ៖ ទីលំនៅនៃបាវព្រាវ និងអ្នកបំរើបញ្ចាំខ្លួន ឬ ស៊ីឈ្នួលនឹងទុកជានៅផ្ទះចៅហ្វាយនាយបានលុះណាតែជននោះនៅនឹងផ្ទះចៅហ្វាយនាយនោះជាធម្មតា ។

**មាត្រា ៨២** ៖ អ្នកជំនួញ ដែលមានផ្ទះជំនួញសាខាច្រើនអាចទុកជាមានលំនៅនៅគ្រប់ផ្ទះសាខាណាដែលបើកបាន, នេះស្តីចំពោះតែកាតព្វកិច្ចខាងជំនួញរបស់ជននោះនឹងចំពោះសេចក្តីត្រូវការក្នុងជំនួញរបស់ខ្លួនតែប៉ុណ្ណោះ ។

**មាត្រា ៨៣** ៖ គូភាគី ទាំងឡាយអាចព្រមព្រៀងគ្នាតាំងលំនៅមួយផ្សេងពីលំនៅខ្លួនពិតដើម្បីសំរេចនូវកាតព្វកិច្ចខ្លួនបាន ។

**មាត្រា ៨៤** ៖ លើកតែករណី ដែលត្រូវយកបទបញ្ញត្តិនៃមាត្រាមុនមកអនុវត្តចេញ, ក្រៅពីនោះ, បណ្ដឹងទាំងឡាយត្រូវតែនាំទៅប្ដឹងនៅសាលាខាងលំនៅនៃចុងចំឡើយនៅ ។

**មាត្រា ៨៥** ៖ បណ្ដឹងទាំងឡាយ ដែលទាក់ទងនឹងមត៌កត្រូវយកទៅជូនសាលាខាងកន្លែងដែលមត៌កនោះកើតឡើង ។

**មាត្រា ៨៦** ៖ បណ្ដឹង ដែលទាមទារកម្មសិទ្ធិ អចលនវត្ថុ ត្រូវប្ដឹងសាលាខាងកន្លែងអចលវត្ថុដែលកើតហេតុនោះនៅ ។

## មាតិកា ទី ៣
## អំពីបាត់ខ្លួន ឬ អវត្តមាន

**មាត្រា ៨៧** ៖ ដែលហៅថា បាត់ខ្លួន នោះគឺបាត់ជនម្នាក់ពីទីលំនៅខ្លួនឥតមានដំណឹងជំនួយអ្វីសោះ, ឥតមាននរណាដឹងថាជននោះរស់ ឬ ស្លាប់ឡើយ ។

**មាត្រា ៨៨** ៖ ជនដែលមានប្រយោជន៍ផងដូចជាឪពុក, ម្ដាយ, ម្ចាស់បំណុលជាដើម អាចធ្វើពាក្យយកទៅប្ដឹងនៅទីសមុហបញ្ជីនៃសាលាខាងលំនៅស្ថាននៃអ្នកបាត់ខ្លួន នោះនៅដើម្បីសុំឲ្យចាត់វិធានការថែរក្សាបេតិបេកភណ្ឌនៃអ្នកដែលបាត់ខ្លួននោះ ។

វិធានការ ដដែលនេះព្រះរាជអាជ្ញា ដែលនៅអមសាលាដំបូងដែលត្រូវសមត្ថកិច្ចក្នុងរឿងនេះក៏អាចផ្ដើមគំនិតសុំបានដែរ ។

**មាត្រា ៨៩** ៖ មាត្រានេះ ត្រូវនិរាករណ៍ដោយអំណាចព្រះរាជក្រមលេខ ១៩៦ ន.ស. ៣០-៥-៥៧ ។

**មាត្រា ៩០** ៖ និរាករណ៍ដូចគ្នាដែរ ។

**មាត្រា ៩១** ៖ តុលាការ ដែលបង្គាប់ឲ្យថែរក្សា បេតិកភណ្ឌរបស់ជនបាត់ខ្លួនតាមការចាំបាច់នោះនឹងចាត់អ្នកណាម្នាក់ឲ្យគ្រប់គ្រងបណ្ដោះអាសន្នបាន, បើត្រូវការ ។

**មាត្រា ៩២** ៖ បឋមភរិយា នៃជនបាត់ខ្លួនត្រូវមានសិទ្ធិគ្រប់គ្រង, ថែរក្សាបេតិកភណ្ឌរបស់ប្ដីដែលបោះបង់នោះបាន ។

**មាត្រា ៩៣** ៖ បេតិភណ្ឌ នេះអាចនឹងប្រគល់ឲ្យតតិយជនណាម្នាក់គ្រប់គ្រងថែរក្សាបានលុះណាតែជននោះគ្មានបឋមភរិយា ឬ លុះណាតែបឋមភរិយាមិនព្រមទទួលគ្រប់គ្រង ។

**មាត្រា ៩៤** ៖ បើការបាត់ខ្លួននោះកន្លងហួសពីមួយឆ្នាំគិតតាំងពីថ្ងៃដែលបាត់ខ្លួននោះមក, ភាគីទាំងឡាយដែលមានប្រយោជន៍ផង ឬ ព្រះរាជអាជ្ញាអាចប្ដឹងឲ្យតុលាការចេញសាលក្រមបញ្ជាក់ថា ជនដែលបាត់ខ្លួននោះបាត់ពិតមែនហើយ ។

**មាត្រា ៩៥** ៖ តុលាការត្រូវចេញដីការបង្គាប់ឲ្យស៊ើសួរដោយយក សេចក្ដីបង្គាប់នោះទៅបិទជាដំណឹងនៅសាលាដំបូង និងនៅសាលាខាងលំនៅរបស់ជនដែលបាត់ខ្លួននោះ ។

**មាត្រា ៩៦** ៖ (ក្រ.លេខ ១៩៦ នស. ៣០-៥-៥៧) ចាងហ្វាងសាលាដំបូងត្រូវប្រញាប់ប្រញាល់ ធ្វើអង្កេតយកពត៌មានដែលមានប្រយោជន៍,ចាងហ្វាងអាចចេញដីការឲ្យប្រើមធ្យោបាយទាំងឡាយមានកេណ្ឌគ្រប់មន្ត្រីក្រុមព្រះនគរបាល,

ចាត់អ្នកជំនាញការ, សួរ ឬ ចាត់ឲ្យសួរសាក្សីជាដើម ។ ចាងហ្វាងអាចចេញដីការប្រគល់អំណាចរបស់ខ្លួនទាំង ឬ ភាគដល់សុភាចារបុរសណាម្នាក់បណ្ដាសុភាចារបុរសទាំងឡាយក្នុងសាលាដំបូង ។

**មាត្រា ៩៧** ៖ (ក្រ.លេខ ១៩៦ នស. ៣០-៥-៥៧) ប្រសិនបើការធ្វើអង្កេតនោះនៅតែមិនបានផលទេហើយអ្នកបាត់ខ្លួននោះក៏នៅតែមិនបានត្រឡប់មកវិញដែរ, ចាងហ្វាង សាលាដំបូង, កាលបានទទួលពាក្យឥតឲ្យបង់តម្លៃពីជនណាម្នាក់បណ្ដាជនទាំងឡាយដែលមានសំដែងក្នុងមាត្រា ៩៤ ខាងលើនេះហើយ, ត្រូវចេញសាលក្រមមួយប្រកាសអំពីការបាត់ខ្លួននោះ ។

ពាក្យណាដែលប្ដឹងសុំឲ្យចេញសាលក្រមប្រកាសអំពីបាត់ខ្លួនមុនផុតកំណត់មួយឆ្នាំរាប់ពីថ្ងៃបិទប្រកាសដូចបានសំដែងក្នុងមាត្រា ៩៨ នោះមក, ពាក្យនោះមិនត្រូវទទួលឡើយ ពីព្រោះរយៈវេលានេះជាបទបញ្ញត្តិដើម្បីសេចក្ដីរៀបរាប់សាធារណៈ ។

**មាត្រា ៩៨** ៖ (ក្រ.លេខ ១៩៦ នស. ៣០-៥-៥៧) សាលក្រមដែលប្រកាសអំពីការបាត់ខ្លួន បើកអំណាចឲ្យទាយាទចែកមត៌កនៃអ្នកបាត់ខ្លួននោះនឹងអនុញ្ញាតឲ្យសហព័ទ្ធរៀបការទៀតដោយសេរី ក្រោយពីថ្ងៃដែលចេញសាលក្រមមួយខែបាន ។ សាលក្រមនោះត្រូវចាត់មន្ត្រីសាធារណណាម្នាក់ឲ្យធ្វើបញ្ជីមត៌កនោះ ។ សេចក្ដីចំឡងនៃបញ្ជីនេះមួយច្បាប់ត្រូវតំកល់ទុកជាមួយនឹងសាលក្រមដើម ។

អង្គសេចក្តីនៃសាលក្រមនោះត្រូវយកទៅចុះនិទ្ទេស នៅរឹមទំព័រនៃជាតិសញ្ញាប័ត្រ និងអាពាហ៍ពិពាហ៍ សញ្ញាប័ត្រនៃអ្នកបាត់ខ្លួនតាមសេចក្តីសុំរបស់ព្រះរាជអាជ្ញា ឬ របស់ជនណាដែលមានប្រយោជន៍ទាក់ទងក្នុងរឿងនេះ ។

សាលក្រមនេះ ត្រូវយកទៅបិទផ្សាយដូចមានសំដែងក្នុងមាត្រា ៩៥ ខាងលើនេះ ។

**មាត្រា ៩៩** ៖ (ក្រ.លេខ ១៩៦ នស. ៣០-៥-៥៧) បើបាត់ខ្លួននោះត្រលប់មកវិញ, បេតិកភណ្ឌនៃអ្នកនោះនៅលើដៃអ្នកណា, អ្នកនោះត្រូវប្រគល់ឲ្យអ្នកបាត់ខ្លួននោះវិញតាមសភាពដែលគង់នៅក្នុងថ្ងៃដែលលេចមុខមកនោះ ។

ទ្រព្យណា ដែលគេបានលក់ហួសទៅហើយ, ទ្រព្យនោះត្រូវសងជាប្រាក់តាមថ្លៃរបស់វាមកវិញ ។

សហព័ទ្ធម្នាក់ ឬ ច្រើននាក់នៃជននេះដែលមិនទាន់រៀបការទៀតទេ ត្រូវមករួមរស់សមគ្គសង្វាសជាមួយនឹងជននេះតទៅ ។

អាពាហ៍ពិពាហ៍របស់សហព័ទ្ធម្នាក់ ឬ ច្រើននាក់ដែលបានរៀបការទៀតក្នុងពេល ដែលជននោះបាត់ខ្លួនមិនអាចត្រូវជននោះប្រកាន់ថាជាប្រការដូចម្តេចដោយសារតែខ្លួន ត្រឡប់មកវិញនោះឡើយ ។

**មាត្រា** ៖ ១០០, ១០១, ១០២, ១០៣, ១០៤, និង ១០៥ ត្រូវនិរាករណ៍ដោយព្រះរាជក្រមលេខ ១៩៦ នស. ចុះថ្ងៃទី ៣០-៥-៥៧ ។

# មាតិកាទី ៤
# អំពីគ្រួសារ
## ចំពូកទី ១
## អំពី កំជាប់ពាក្យ

**មាត្រា ១០៦** ៖ ដែលហៅថា កំជាប់ពាក្យ គឺជាសេចក្ដីសន្យាដែលជនពីនាក់បាន ប្ដេជ្ញាថានឹងយកគ្នាជាប្ដីប្រពន្ធតាមច្បាប់ ។

**មាត្រា ១០៧** ៖ កំជាប់ពាក្យនោះ នឹងទុកជាបានការបានលុះតែការនេះបានធ្វើពិធីជាឧឡារិកមួយដែលហៅថា លើកស្លា ។

**មាត្រា ១០៨** ៖ ប្រុស និងស្រី ដែលនៅក្នុងអនីតិភាពអាចនិងព្រមធ្វើកំជាប់ពាក្យនេះបានក៏លុះណាតែឪពុកម្ដាយ ឬ, បើឥតឪពុកម្ដាយ, អាណាព្យាបាល ឬ ក៏ជនណាដែលត្រូវមុខបានយល់ព្រមផង ។

**មាត្រា ១០៩** ៖ ពាក្យដែលបេជ្ញា ថានឹងរៀបការ ដែលនឹងកើតមកពីកំជាប់ពាក្យនោះអាច នឹងដាច់ដោចទៅវិញបានដោយសារតែកំហុសខាងប្រុស ឬ ខាងស្រី ។ **មាត្រា ១១០** ៖ ការដាច់ដោចនេះនឹងបណ្ដាលឲ្យអ្នកចង់ដាច់ដោយឥតហេតុផល ឬ អ្នកនាំអាទិដាច់ដោយមកពីកំហុសរបស់ខ្លួនជួសជុលសងដំណាច់ដែលគេដាច់បង់ដោយហេតុនោះ ។

**មាត្រា ១១១** ៖ ការជួសជុលដំណាច់ គឺការបង់សំណេូកចិត្តឲ្យសមមូលតាមថ្លៃចំនួន និងភស្តុការបណ្ណាការដែលទិញជូនដើម្បីរៀបការនោះជាដើម ។

**មាត្រា ១១២** ៖ បើកំជាប់ពាក្យនោះដាច់ដោយសារសាមីខ្លួនស្លាប់, នោះសំណងចិត្តមិនត្រូវសងឡើយ, ប៉ុន្តែអ្នកដែលនៅរស់នឹងទារតែជំនូននោះមកវិញបាន ។ បើរបស់នោះ ខូចខាត, បាត់បង់ទៅហើយ, អ្នកនៅរស់នឹងទារតែថ្លៃវិញក៏បាន ។

**មាត្រា ១១៣** ៖ បណ្ដឹង ដែលកើតមកពីកំជាប់ពាក្យនោះត្រូវផុតអាជ្ញាយុកាលក្នុងរយៈវេលាដប់ពីរខែ គិតតាំងពីថ្ងៃដាច់កំជាប់ពាក្យនោះមក ។

## ចំពូកទី ២
## អំពីអាពាហពិពាហ

### ផ្នែកទី ១
### អំពីលក្ខខណ្ឌដែលត្រូវមានដើម្បីរៀបអាពាហពិពាហ

**មាត្រា ១១៤** ៖ ដែលហៅថាអាពាហពិពាហ គឺជាកិច្ចសន្យាយ៉ាងឧឡារិកមួយដែលប្រុសម្នាក់ និងស្រីម្នាក់ប្ដេជ្ញាគ្នាថាខ្លួននិងរួមសមគ្គសង្វាសជាមួយគ្នាតាមច្បាប់ដែលបានបញ្ញត្តិមក ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន ។

**មាត្រា ១១៥** ៖ ពាហពិពាហ អាចរៀបបានតែរវាងបុគ្គលដែលមានភេទផ្សេងគ្នា ។

**មាត្រា ១១៦** ៖ ប្រុសមានអាយុមិនដល់ ១៧ ឆ្នាំ, ស្រីមានអាយុមិនដល់ ១៤ ឆ្នាំមិនអាចរៀបពាហពិពាហបានឡើយ ។

**មាត្រា ១១៧** ៖ មនុស្សវិបល្លាស និងមនុស្សអសមត្ថភាពមិនស្គាល់ខុសត្រូវទាំងអស់នេះមិនអាចរៀបពាហពិពាហបានទេ ។

**មាត្រា ១១៨** ៖ ច្បាប់ហាមមិនឲ្យរៀបពាហពិពាហរវាងបុគ្គលដែលជាប់ចំណងញាតិលោហិត ឬ ញាតិពន្ធនឹងគ្នាក្នុងក្រសែផ្ទាល់ គ្រប់ថ្នាក់, ទោះជាចំណងមានខាន់ស្លាក្ដី, ឥតខាន់ស្លាក្ដី ឬ សាច់ចិញ្ចឹមក្ដី ។

**មាត្រា ១១៩** ៖ ពាហពិពាហរវាងញាតិសាខា, ទោះមានខាន់ស្លាក្ដី, ឥតខាន់ស្លាក្ដី, សាច់ចិញ្ចឹមក្ដី, រួមផ្ទៃក្ដី, រួមលោហិតក្ដី, រួមឪពុកម្ដាយក្ដី, ក្រសែផ្ទាល់ក្ដី, ដោយពន្ធក្ដី, រហូតដល់ថ្នាក់ទី ៣ រាប់ទាំងថ្នាក់ទី៣ នេះផងត្រូវហាមមិនឲ្យរៀបការឡើយ ។

**មាត្រា ១២០** ៖ ថ្នាក់ញាតិត្រូវរាប់ដោយបូកចំនួនជនតាដែលបែកចេញពីគល់តែមួយជាសាខាមួយៗ ។

**មាត្រា ១២១** ៖ ទោះប្រុសស្រី មិនទាន់ដល់កំណត់អាយុ ឬ ជាញាតិនឹងគ្នាមានប្រាថ្នានឹងយកគ្នាជាប្ដីប្រពន្ធ ហើយក៏បានសេចក្ដីក្រាបបង្គំទូលថ្វាយ ឬ, បើជាអនីតិជន, ឪពុកម្ដាយ ឬ អាណាព្យាបាលយកសេចក្ដីក្រាបបង្គមទូលសូមរៀបការ ។ ព្រះករុណាព្រះចៅក្រុងកម្ពុជា នឹងព្រះរាជទានអនុញ្ញាតឲ្យរួចផុតអំពីកំណាត់អាយុ និងអំពីកំរិតញាតិលោហិត ឬ ញាតិពន្ធបានតាមយោបល់គណរដ្ឋមន្ត្រីដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានស្នើរជូនមក ។

**មាត្រា ១២២** ៖ ការដែលឲ្យរួចផុតអំពីកំណាត់អាយុនោះ, បើប្រុសអាយុតិចជាង ១៥ ឆ្នាំ, ស្រីអាយុតិចជាង ១២ ឆ្នាំនឹងអនុញ្ញាតមិនបាន ។

**មាត្រា ១២៣** ៖ ឯសេចក្ដីអនុញ្ញានេះអាចឲ្យញាតិសាខាត្រឹមថ្នាក់ទី ៣ ឬញាតិសាខាពន្ធត្រឹមថ្នាក់ទី២ យកគ្នាបាន ។

**មាត្រា ១២៤** ៖ ប៉ុន្តែ ចំពោះព្រះរាជវង្សានុវង្ស, ព្រះករុណានឹងព្រះរាជទានអនុញ្ញាតឲ្យញាតិសាខាយកគ្នាបាន ។

**មាត្រា ១២៥** ៖ អនីតិជនអាចនឹងរៀបអាពាហពិពាហបានលុះណាតែឪពុកម្ដាយបានអនុញ្ញាតិយល់ព្រមផង ។

**មាត្រា ១២៦** ៖ បើឪពុក និងម្ដាយមិនព្រមព្រៀងគ្នាទេ, ឪពុកព្រមតែម្នាក់ឯងក៏បាន, បើឪពុកស្លាប់ទៅ, ម្ដាយយល់ព្រមក៏បាន ។

**មាត្រា ១២៧** ៖ បើអនីតិជនជាកូន មានខាន់ស្លា, កំព្រាឥតឪពុក, ឥតម្ដាយ, បុព្វញាតិដែលជាញាតិថ្នាក់ជិតជាងគេមានសិទ្ធិឲ្យអនុញ្ញាតិនេះបាន ។

បើមានបុព្វញាតិថ្នាក់ស្មើគ្នាទាំងពីរខាង, ត្រូវបុព្វញាតិខាងឪពុកមានសិទ្ធិឲ្យអនុញ្ញាតិ ។

បើមានការខ្វែងគំនិតគ្នាត្រូវជីតាឲ្យអនុញ្ញាត,បើជីតាស្លាប់, ត្រូវជីដូនឲ្យអនុញ្ញាត។

**មាត្រា ១២៨** ៖ បើបុព្វញាតិ ដែលត្រូវអនុញ្ញាតិឲ្យរៀបអាពាហពិពាហនោះមានសតិបញ្ញាមិនប្រក្រតី, សិទ្ធិឲ្យអនុញ្ញាតនេះត្រូវធ្លាក់ទៅលើបុព្វញាតិម្នាក់ទៀតតាមលំដាប់មាត្រាមុននេះ ។

**មាត្រា ១២៩** ៖ បើឥតបុព្វញាតិណាមួយនៅរស់សោះ, អាណាព្យាបាលនៃអនីតិជននោះត្រូវឲ្យអនុញ្ញាត ។

**មាត្រា ១៣០** ៖ បើអនីតិជននោះគឺគេមិនបានរៀបចំឲ្យមានអាណាព្យាបាលទេ, សេចក្ដីអនុញ្ញាតត្រូវសុំពីក្រុមប្រឹក្សាញាតិ ដែលមេឃុំនៃឃុំខាងលំនៅនៃអនីតិជននោះប្រជុំឲ្យអនុញ្ញាត ។

**មាត្រា ១៣១** ៖ បើអនីតិជនជាមនុស្សកំព្រាឪពុកម្ដាយហើយជាកូនឥតខាន់ស្លាទៀត, សេចក្ដីអនុញ្ញាតត្រូវសុំពីអាណាព្យាបាល ។

**មាត្រា ១៣២** ៖ បើគ្មានអាណាព្យាបាលទេ, អនីតិជននោះត្រូវសុំអនុញ្ញាតពីក្រុមជំនុំនៃឃុំខាងលំនៅឋានខ្លួន ។

**មាត្រា ១៣៣** ៖ ប្រុស និងស្រី, ជានីតិជនហើយចង់រៀបអាពាហពិពាហនឹងគ្នានោះ, ក៏ត្រូវឲ្យបានអនុញ្ញាតពីបុព្វញាតិទាំងឡាយនោះដូចអនីតិជនដែរ ។

**មាត្រា ១៣៤** ៖ ក៏ប៉ុន្តែ បើជនដែលកូនត្រូវសុំអនុញ្ញាតនោះប្រកែកមិនព្រមឲ្យទេ, កូនមានខាន់ស្លាជានីតិជននោះអាចសុំឲ្យមេឃុំខាងលំនៅខ្លួនប្រជុំក្រុមប្រឹក្សាញាតិដើម្បីនឹងផ្សះផ្សាសំរួលឲ្យស្រួលនឹងគ្នាបាន ។ ឯកូនឥតខាន់ស្លាជានីតិជនវិញវាអាចប្ដឹងមេឃុំឲ្យហៅឪពុកម្ដាយទៅកាន់សាលាដំបូង ខាងលំនៅវាជាមួយនឹងវាដើម្បីសុំឲ្យចាងហ្វាងសាលានោះផ្សះផ្សាឲ្យបានដូចគ្នា ។

**មាត្រា ១៣៥** ៖ បើឪពុកម្ដាយនៅតែប្រកែកមិនព្រមទៀត, កូនប្រុស, កូនស្រីអាចរៀបការរំលងសេចក្ដីអនុញ្ញាតនេះបាន, ក្រោយពីថ្ងៃដែលបានផ្សះផ្សានោះមកកំណត់ ៣ ខែ ។

**មាត្រា ១៣៦** ៖ កូនមានខាន់ស្លា ជានីតិជនដែលគ្មានបុព្វញាតិរស់នៅទេនិង កូនឥតខាន់ស្លាជានីតិជនដែលកំព្រាឪពុកម្ដាយហើយចង់រៀបការនោះមិនបាច់សុំអនុញ្ញាតពីនរណាឡើយ ។

**មាត្រា ១៣៧** ៖ អាពាហពិពាហអាចនឹងរៀបបានតែនៅថ្ងៃជាខាងក្រោយនៃការបិទប្រកាសប្រាំបីថ្ងៃ ។

ដែលហៅថា ប្រកាសនោះគឺជាសេចក្ដីដែលឲ្យដំណឹងដល់សាធារណជនឲ្យដឹងអំពីអាពាហពិពាហដែលប្រុងរៀបតាមរបៀបដែលបានបញ្ញត្តិក្នុងចំពូក ៥ មាតិកាទី ១ នៃគន្ថីនេះ ។

**មាត្រា ១៣៨** ៖ ដែលហៅថា អាពាហពិពាហ នោះមិនមែន ការធ្វើបុណ្យតាមច្បាប់សាសនា ឬ តាមបវេណីទេគឺការដែលប្រុសម្នាក់និងស្រីម្នាក់បានប្រកាសក្នុងទីសាធារណថាខ្លួនទាំងពីរនាក់ ព្រមចុះកិច្ចសន្យាយកគ្នាជាប្ដីប្រពន្ធហើយតែប៉ុណ្ណោះ ។

សេចក្ដីប្រកាស នេះត្រូវធ្វើនូវមុខមន្ត្រីអត្រានុកូលដ្ឋាន ខាងលំនៅនៃស្រីហើយចុះបញ្ជីតាមបទបញ្ញត្តិ ដែលមានសំដែងក្នុងចំពូក ៥ មាតិកា មួយនៃគន្ថីស្ដីពីបុគ្គលនេះ ។

**មាត្រា ១៣៩** ៖ អាពាហពិពាហ មាន ២ យ៉ាង គឺអាពាហពិពាហខាន់ស្លាទីមួយ ១ និងអាពាហពិពាហខាន់ស្លាទីពីរ ១ ។

**មាត្រា ១៤០** ៖ ស្រីអាចយកប្ដីបានតែមួយនាក់ ។

**មាត្រា ១៤១** ៖ ប្រុស អាចយកប្រពន្ធបានច្រើននាក់ ។

**មាត្រា ១៤២** ៖ សមគ្គសង្វាសជាធម្មានុរូប ដែលប្រុសរៀបជាដំបូងត្រូវទុកជាខាន់ស្លាទី១ ។

សមគ្គសង្វាសឯទៀតត្រូវទុកជាខាន់ស្លាទីពីរ ។

**មាត្រា ១៤៣** ៖ បើអាពាហពិពាហទីមួយ ដាច់ហើយ, ប្ដីអាចរៀបអាពាហពិពាហខាន់ស្លាទី ១ នឹងប្រពន្ធមួយទៀតបាន ។

**មាត្រា ១៤៤** ៖ ប្ដីអាចលើកប្រពន្ធចុងណាម្នាក់ឲ្យធ្វើជាប្រពន្ធខាន់ស្លាទី ១ បាន ។

**មាត្រា ១៤៥** ៖ ដែលនឹងលើកប្រពន្ធចុងឲ្យធ្វើជាប្រពន្ធដើមបាននោះ, ប្ដីត្រូវនាំសាក្សី ២ នាក់ទៅប្ដឹងឲ្យច្បាស់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដែលបានចុះអាពាហពិពាហខ្លួន និងប្រពន្ធចុងពីមុននោះថា ខ្លួនលើកប្រពន្ធចុងនេះជាទីមួយហើយ ។

**មាត្រា ១៤៦** ៖ ប្ដីត្រូវជូនបន្ទាល់ឲ្យឃើញថាអាពាហពិពាហខាន់ស្លាទី១របស់ខ្លួនមុននោះរលាយហើយដោយបង្ហាញសាលក្រម ឬ អត្រានុកូលដ្ឋានសញ្ញាប័ត្រ ដែលមានសេចក្ដីថាប្រពន្ធខាន់ស្លាទី១នោះបាត់ខ្លួនហើយ, លែងគ្នាហើយ ឬ ស្លាប់ហើយ ។

**មាត្រា ១៤៧** ៖ បណ្ដឹងនោះត្រូវចុះក្នុងសៀវភៅក្នុងឆ្នាំ នោះតាមបទបញ្ញត្តិអំពីអត្រានុកូលដ្ឋានសញ្ញាប័ត្រ ។

និទ្ទេសដែលលើកប្រពន្ធ ខាន់ស្លាទី២ ជាខាន់ស្លាទី១ នោះត្រូវចុះនៅរឹមទំព័រនៃអាពាហពិពាហសញ្ញាប័ត្រមុននោះផង ។

## ផ្នែកទី ៤
## អំពីបណ្ដឹងទាស់ មិនឲ្យរៀបការ

**មាត្រា ១៤៨** ៖ ក្នុងរយៈវេលា ៨ ថ្ងៃគិតពីថ្ងៃដែលបិទប្រកាសឲ្យដំណឹងដល់សាធារណជនពីថ្ងៃរៀបអាពាហពិពាហនោះមក,ញាតិក្តី, អ្នកទាំងពួងដែលមានប្រយោជន៍ក្នុងរឿងនេះក្តីអាចនឹងប្តឹងទោសមិនឲ្យរៀបអាពាហពិពាហបាន ។

**មាត្រា ១៤៩** ៖ បណ្ដឹងទាស់នោះនឹងយកជាការបានលុះណាតែអ្នកប្តឹងទាស់ចុះហត្ថលេខាលើពាក្យខ្លួនដោយដៃឯង ឬ, បើអ្នកប្តឹងទាស់មិនចេះអក្សរ, ឲ្យមានហត្ថលេខានៃសាក្សី២ នាក់ចុះក្នុងបណ្ដឹងនោះផង ។

**មាត្រា ១៥០** ៖ ពាក្យនោះត្រូវអ្នកប្តឹងទាស់ជូនទៅមន្ត្រីអត្រានុកូលដ្ឋានដោយខ្លួនឯងនៅទីដែលរៀបអាពាហពិពាហនោះគឺមេឃុំនៃខាងស្រីនៅ ។

**មាត្រា ១៥១** ៖ បណ្ដឹងនេះត្រូវចង្អុលហេតុដែលទាស់ ។ ហេតុដែលអាចយកមកទាស់នោះគឺ ១. អសមត្ថភាពខាងប្រុស ឬ ខាងស្រី, ២. មានគំហាតណាមួយរបស់ច្បាប់ ។

ការដែលយកលេសថាគ្មានសេចក្តីយល់ព្រមពីជន ដែលត្រូវឲ្យមកជំទាស់បាននោះនឹងធ្វើបានតែជនដែលច្បាប់តម្រូវឲ្យសុំតែប៉ុណ្ណោះទេ ។

**មាត្រា ១៥២** ៖ មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនបណ្ដឹងទាស់នោះមួយរំពេចទៅទីសមុហបញ្ជីនៃសាលាដំបូង ។

តុលាការត្រូវជំនុំជម្រះក្នុងកំណត់ ១០ ថ្ងៃគិតតាំងពីថ្ងៃដែលទទួលពាក្យនោះមក ។

ឯរយៈពេលដែលបើកឲ្យឧទ្ធរណ៍មានតែម្ភៃបួនម៉ោងទេ ។

**មាត្រា ១៥៤** ៖ ថាបើអ្នកប្ដឹងទាស់ នោះមិនបានចូលមកកាន់សវនាការទេ, សាលក្រមនោះត្រូវទុកដូចជាបានជំរះចំពោះមុខគូក្ដីដែរ, ផ្លូវឧទ្ធរណ៍ត្រូវគិតដូចខាងលើ ។

**មាត្រា ១៥៥** ៖ សេចក្ដីដែលតុលាការបានសំរេចនោះត្រូវឲ្យដំណឹងមួយរំពេចទៅមេឃុំដើម្បីឲ្យមេឃុំហៅសាមីខ្លួនប្រុសស្រី និងអ្នកដែលប្ដឹងទាស់នោះមកប្រាប់ឲ្យបានដឹងផង ។

**មាត្រា ១៥៦** ៖ បើតុលាការ ត្រូវបដិសេធបណ្ដឹងទាស់នោះចោល, សាមីខ្លួនប្រុសស្រីអាចរៀបការបានតាមចិត្ត ។ បើតុលាការចាត់ទុកពាក្យដែលប្ដឹងទាស់នោះជាត្រឹមត្រូវ, មេឃុំត្រូវឈប់រៀបការឲ្យសាមីខ្លួនភ្លាម ។

**មាត្រា ១៥៧** ៖ នាកាលមេឃុំ ដឹងថាប្រុស ឬ ស្រីជាមនុស្សអសមត្ថភាព ឬ មានគំហាត់ណាមួយរបស់ច្បាប់ឃាត់មិនឲ្យយកគ្នាទេ, មេឃុំត្រូវជំទាស់ពីចិត្តឯងកុំឲ្យរៀបរយបាន ។

**មាត្រា ១៥៨** ៖ ខណៈនោះមេឃុំត្រូវបកសំបុត្រទៅទីសមុហបញ្ជីនៃសាលាដំបូងជាប្រញាប់ហើយតុលាការត្រូវកាត់សេចក្ដីតាមន័យ ដែលបានពោលហើយអំពីទានពាក្យប្ដឹងទាស់មិនឲ្យរៀបការនោះ ។

## ផ្នែកទី ៣
## អំពីមោឃភាព

**មាត្រា ១៥៩** ៖ អាពាហពិពាហ ដែលឥតបានប្ដឹងមន្ត្រីអត្រានុកូលដ្ឋានឲ្យចុះក្នុងបញ្ជីអាពាហពិពាហទេ, អាពាហពិពាហនោះត្រូវទុកជាមោឃៈ គឺថាគ្មានអាពាហពិពាហទេ ឬ ថាអាពាហពិពាហដែលមិនបានប្ដឹងឲ្យតុលាការបដិសេធឡើយ ។

**មាត្រា ១៦០** ៖ អាពាហពិពាហ ត្រូវទុកជាមោឃៈបានកាលណាបើសហព័ទ្ធណាម្នាក់ឆ្កួតវង្វេង ឬ គ្មានស្គាល់ខុសស្គាល់ត្រូវទេ ។

តែបើសហព័ន្ធនោះបានជាស្រួលឡើងវិញ, ហេតុដែលនាំឲ្យទុកជាមោឃៈនោះត្រូវរលាយទៅវិញដែរ ។

**មាត្រា ១៦១** ៖ បើសាមីខ្លួនដែលរៀបការនោះនៅក្មេងពេក, ពុំទាន់ដល់អាយុគ្រប់ការទេគឺប្រុសអាយុតិចជាង ១៧ ឆ្នាំ ឬ ស្រីអាយុតិចជាង ១៤ ឆ្នាំ, អាពាហពិពាហនោះត្រូវទុកជាមោឃៈបាន ។

អាពាហពិពាហដែលជាមោឃៈ នោះនឹងលែងជាមោឃៈទៅវិញកាលណាបើសាមីខ្លួនប្រុស ឬ ស្រីនោះចំរើនវ័យដល់អាយុគ្រប់ការតាមបញ្ញត្តិច្បាប់វិញហើយ ឬ ក៏ប្រពន្ធនោះមានគភ៌ហើយ ។

**មាត្រា ១៦២** ៖ ពាក្យដែលប្ដឹងឲ្យបដិសេធអាពាហពិពាហដោយហេតុអាយុមិនគ្រប់ការ នោះនឹងអាចធ្វើបានតែប្ដី ឬ ប្រពន្ធនៃជនដែលអាយុមិនទាន់គ្រប់

ការនោះនឹងជនទាំងឡាយដែលបានអនុញ្ញាតឲ្យរៀបការនោះ ឬ អាជ្ញាធរសាធារណៈមានមេឃុំ ឬ ចៅហ្វាយស្រុក ឬ ចៅក្រមជាដើម ។

**មាត្រា ១៦៣** ៖ អាពាហពិពាហ អាចទុកជាមោឃៈបានដែលកាលបើសហព័ទ្ធណាម្នាក់ប្ដឹងថាខ្លួនបានព្រមរៀបអាពាហពិពាហដោយភ័ន្តច្រឡំ ឬ ដោយគេបង្ខំ ។

**មាត្រា ១៦៤** ៖ សេចក្ដីភ័ន្តច្រឡំដែលអាចទុកជាហេតុ គប្បីឲ្យបដិសេធអាពាហពិពាហបាននោះគឺបានតែសេចក្ដីច្រឡំ អំពីបុគ្គលនៃសហព័ទ្ធណាម្នាក់ ឬ ភ័ន្តច្រឡំអំពីថ្នាក់នៃខាន់ស្លា ។

**មាត្រា ១៦៥** ៖ បើសហព័ទ្ធដែលភ័ន្តច្រឡំ ឬ ដែលគេបង្ខំនោះជានីតិជន, សហព័ទ្ធនោះអាចប្ដឹងតែម្នាក់ឯងបាន ។

បើសហព័ទ្ធនោះជាអនីតិជនវិញ, ជនទាំងឡាយដែលបានអនុញ្ញាតឲ្យរៀបការនោះត្រូវចូលទៅប្ដឹងផង ។

**មាត្រា ១៦៦** ៖ បើបណ្ដឹងបដិសេធនេះមិនបានធ្វើក្នុងកំណត់ ៦ ខែ គិតពីថ្ងៃដែលបានដឹងថាមានភ័ន្តច្រឡំ ឬ ពីថ្ងៃដែលគេកំហែងបង្ខំនោះទេ, បណ្ដឹងនោះត្រូវផុតអាជ្ញាយុកាលហើយ ។

**មាត្រា ១៦៧** ៖ អាពាហ៍ពិពាហ៍ ដែលរៀបឥតសុំអនុញ្ញាតឪពុកម្ដាយ, បុព្វញាតិ,អាណាព្យាបាល ឬ ក្រុមប្រឹក្សាញាតិទេត្រូវទុកជាមោឃៈ ។

**មាត្រា ១៦៨** ៖ បណ្ដឹងសុំឲ្យបដិសេធនោះអាចធ្វើបានកាលណាសហព័ទ្ធ,

ដែលត្រូវសុំអនុញ្ញាតពីអ្នកត្រូវមុខអនុញ្ញាត ហើយមិនបានសុំនោះ, នៅក្នុងអនីតិភាព និងកាលណាស្រីជាប្រពន្ធនោះមិនទាន់មានកូន ឬ មិនទាន់មានគក៏ ។

**មាត្រា ១៧០** ៖ បើស្រីនោះ នៅជាប់ចំណងជាបឋមភរិយា ឬ អនុភរិយា គេពេញច្បាប់មិនទាន់ដាច់គ្នាពីប្ដីមុនទេ ហើយរៀបការនិងប្រុសម្នាក់ទៀត, អាពាហពិពាហនោះអាចទុកជាមោឃៈបានដែរ ។

**មាត្រា ១៧១** ៖ បណ្ដឹងសុំមោឃភាពនេះជាភារៈរបស់ប្ដីដើម ។

បណ្ដឹងនេះជារបស់ផ្ទាល់ខ្លួននៃប្ដី, ទាយាទនឹងយកសិទ្ធិប្ដឹងនេះជាមត៌កខ្លួនមិនបានឡើយ ។

**មាត្រា ១៧២** ៖ បើប្រុសមានប្រពន្ធដើមពេញច្បាប់មិនទាន់លែងគ្នា ហើយទៅការប្រពន្ធមួយទៀតធ្វើជាប្រពន្ធដើមតែអាពាហពិពាហ ក្រោយនេះត្រូវទុកជាមោឃៈ ។

**មាត្រា ១៧៣** ៖ ចំពោះមោឃៈភាពត្រង់ខនេះ, ប្រពន្ធខាន់ស្លាទី១, ដែលការមុន, ត្រូវប្ដឹង, បើប្រពន្ធដើមនោះនៅក្នុងអនីតិភាព, ជនទាំងឡាយដែលបានអនុញ្ញាតឲ្យនាងនេះរៀបការនោះអាចនឹងប្ដឹងបានដែរ ។

**មាត្រា ១៧៤** ៖ ប្រពន្ធដែលទើបការក្រោយ ឬ ជនដែលបានអនុញ្ញាតឲ្យនាងនេះ មានប្ដីនោះអាចនឹងសុំឲ្យបដិសេធពីអាពាហពិពាហក្រោយនេះបានដែរ ។

**មាត្រា ១៧៥** ៖ បើប្រពន្ធដែលយកក្រោយនោះសុខចិត្តព្រមផង, តុលាការអាចនឹងកាត់សេចក្ដីបដិសេធនូវខាន់ស្លាទី១ របស់ប្រពន្ធនោះហើយដាក់នាងនោះទៅជាខាន់ស្លាទី២វិញបាន ។

**មាត្រា ១៧៦** ៖ បើប្រពន្ធ ដែលការក្រោយនោះនៅក្នុងអនីតិភាព, ជនទាំងឡាយដែលត្រូវមុខអនុញ្ញាតឲ្យមានប្ដីនោះត្រូវយល់ព្រមឲ្យដាក់ជាខាន់ស្លាទី ២ ផង, បើមិនយល់ព្រមដូច្នោះទេអាពាហពិពាហនោះត្រូវទុកជាមោឃៈ ។

**មាត្រា ១៧៧** ៖ ក្នុងករណី ដែលសាលក្រមកាត់សេចក្ដីបដិសេធអាពាហពិពាហនោះមានសេចក្ដីថា ឲ្យបន្ថយថ្នាក់ខាន់ស្លា ប្រពន្ធដែលទើបការជាន់ក្រោយនោះដែ, សេចក្ដីចម្លងនៃសាលក្រមនោះមួយចប់ ត្រូវបញ្ជូនទៅមន្ត្រីអត្រានុកូលដ្ឋានឲ្យចុះក្នុងរឹមទំព័រនៃ អាពាហពិពាហសញ្ញាប័ត្រ ដែលត្រូវបន្ថយថ្នាក់នោះ ។

**មាត្រា ១៧៨** ៖ អាជ្ញាធរសាធារណៈអាចប្ដឹងឲ្យបដិសេធអាពាហពិពាហនោះបានបើមានហេតុថាស្រីនោះមានប្ដីហើយប្រុសនោះមានប្រពន្ធដើមហើយ ។

**មាត្រា ១៧៩** ៖ បណ្ដឹងសុំមោឃៈភាពដល់អាពាហពិពាហជាន់ក្រោយនេះមិនអាចសុំបានឡើយបើ, តាំងពីថ្ងៃរៀបការជាន់ក្រោយនោះមក, អាពាហពិពាហមុនក៏បានរលាយទៅដែរ ។

**មាត្រា ១៨០** ៖ បើញាតិលោហិត ឬ ញាតិពន្ធក្នុងជាន់ដែលច្បាប់ហាមនោះរៀបការនឹងគ្នា, អាពាហពិពាហនោះត្រូវទុកជាមោឃៈ ។

**មាត្រា ១៨១** ៖ បើសហព័ទ្ធនោះជាញាតិលោហិត ឬ ញាតិពន្ធនឹងគ្នាដែលគប្បីបាននូវព្រះរាជានុញ្ញាត នៃព្រះករុណាឲ្យយកគ្នាបាន, តុលាការត្រូវបង្អង់, កុំអាលជំនុំជំរះ, ចាំស្ដាប់សេចក្ដីដែលព្រះករុណាទ្រង់វិនិច្ឆ័យអំពីព្រះរាជាអនុញ្ញាតនោះសិន ។

ក្រៅពីករណីនេះ អាពាហពិពាហ ដែលយកគ្នាខុសច្បាប់ដូច្នេះត្រូវបដិសេធមួយរំពេច ហើយសហាព័ទ្ធនិងគូកនដែលសមគំនិតទាំងប៉ុន្មាននោះនឹងត្រូវជាប់ចោទតាមបញ្ញតិនៃក្រមព្រហ្មទណ្ឌ ៤៤៧, ៤៤៨ ផង ។

**មាត្រា ១៨២** ៖ អំពីបណ្ដឹងសុំមោឃភាពដោយហេតុមុខស្នន់នោះ, អាជ្ញាធរសាធារណៈព្រមទាំងជនទាំងពួងដែលមានប្រយោជន៍ក្នុងរឿងនេះអាចប្ដឹងវេលាណាក៏បាន ។

**មាត្រា ១៨៣** ៖ អាពាហពិពាហ ដែលរៀបឥតបិទប្រកាសជាមុន តាមបញ្ញតិច្បាប់ទេនឹងបដិសេធមិនបានឡើយ, តែមន្ត្រីអត្រានុកូលដ្ឋានដែលបើកឲ្យរៀបអាពាហពិពាហនោះត្រូវសាលាជំនុំជម្រះពិន័យជាប្រាក់ ពី ២០ រៀល ទៅដល់ ១០០ រៀល ។

**មាត្រា ១៨៤** ៖ កូនដែលកើតអំពីអាពាហពិពាហដែលការបានបដិសេធចោលនោះគង់នៅជាកូនមានខាន់ស្លាដដែល ទោះបីហេតុដែលនាំឲ្យមានមោឃៈភាពនោះយ៉ាងណាក្ដី ។ សិទ្ធិ និងកាតព្វកិច្ចនៃឪពុកម្ដាយ និងកូន ត្រូវមានដូចគ្នានឹងករណី ដែលម្ដាយលែងគ្នា ។

**មាត្រា ១៨៥** ៖ អំពីទ្រព្យសម្បត្តិប្ដីប្រពន្ធដែលតុលាការសម្រេចសេចក្ដីបដិសេធ អាពាហពិពាហនោះក៏ត្រូវសម្រេចដូចក្នុងករណីលែងគ្នាដែរ ។

**មាត្រា ១៨៦** ៖ សាលក្រមនីមួយៗ ដែលកាត់សេចក្ដីបដិសេធអាពាហពិពាហ, ថាបើផុតអំណាចឧទ្ធរណ៍ហើយ, ត្រូវបញ្ជូនទៅឲ្យមន្ត្រីអត្រានុកូលដ្ឋានដែលបានចុះអាពាហពិពាហ នោះឲ្យចុះនិទ្ទេសនៃសាលក្រមនៅរឹមទំព័រនៃអាពាហ

ពិពាហ សញ្ញាប័ត្រដែលបដិសេធ ហើយឲ្យចំឡងសាលក្រមនោះចុះក្នុងសៀវភៅឆ្នាំនោះផង ។

## ផ្នែកទី ៤
## អំពីករណីយកិច្ចនៃប្ដីប្រពន្ធ

**មាត្រា ១៨៧** ៖ ប្ដីប្រពន្ធត្រូវជួយ, សង្គ្រោះគ្នាទៅវិញទៅមក

**មាត្រា ១៨៨** ៖ ប្ដីត្រូវទំនុកបម្រុងប្រពន្ធទាំងឡាយ ។

**មាត្រា ១៨៩** ៖ ប្រពន្ធទាំងឡាយត្រូវទទួលស្គាល់ឱវាទប្ដី, ត្រូវឱនលំទោន ហើយស្លូតត្រង់នឹងប្ដីផង ។

**មាត្រា ១៩០** ៖ ប្រពន្ធចុងទាំងឡាយ ត្រូវស្ដាប់បង្គាប់, កោតខ្លាចប្រពន្ធដើម ។

**មាត្រា ១៩១** ៖ ប្រពន្ធដើមត្រូវមានសិទ្ធិ និងករណីកិច្ចបានលំនៅនៅជាមួយប្ដី ។

**មាត្រា ១៩២** ៖ ប្ដីអាចបង្ខំប្រពន្ធចុងទាំងឡាយឲ្យទៅនៅលំនៅណាមួយដោយឡែកបាន ។

**មាត្រា ១៩៣** ៖ ប្ដីត្រូវទំនុកបំរុងប្រពន្ធទាំងឡាយ ឲ្យចាយវាយតាមសមគួរដល់មុខរបរ និងធនធានដែលខ្លួនមាន ។

**មាត្រា ១៩៤** ៖ ចំពោះដំណើរការណ៍ទាំងពួងដែលកើតមានលើរូបប្រពន្ធណា, ប្ដីត្រូវទទួលដំណាងប្រពន្ធនោះពេញមុខ ។

**មាត្រា ១៩៥** ៖ ប្រពន្ធទាំងឡាយអាចនឹងប្តឹងតុលាការនិងចុះកិច្ចសន្យាផ្សេងៗបានតែកាលណាបើប្តីអនុញ្ញាតផង ។

**មាត្រា ១៩៦** ៖ ប្តីអាចឲ្យដល់ប្រពន្ធទាំងឡាយនូវអំណាចធ្វើអ្វីៗដោយខ្លួនឯងបាន ។

**មាត្រា ១៩៧** ៖ បើប្តីអនុញ្ញាតដូច្នេះហើយ, ប្រពន្ធអាចនឹងធ្វើជំនួញបាន, នូវកិច្ចការអ្វីៗ ដែលគប្បីធ្វើក្នុងជំនួញនោះបានមិនចាំបាច់ឲ្យប្តីអនុញ្ញាតអ្វីផ្សេងៗទៀតឡើយ ។

**មាត្រា ១៩៨** ៖ កិច្ចការទាំងពួងដែលស្ត្រីមានប្តីធ្វើឥតអនុញ្ញាតពីប្តីនឹងត្រូវទុកជាមោឃៈ ។

**មាត្រា ១៩៩** ៖ បើ, ក្រោយមក, ប្តីយល់ព្រមវិញ, ការដែលប្រពន្ធធ្វើពុំបានអនុញ្ញាតជាមុននោះត្រូវយកជាការបាន ។

**មាត្រា ២០០** ៖ ស្រីមានប្តីទោះជាស្រីជំនួញក្តី, បើប្តីមិនបានអនុញ្ញាតឲ្យប្តឹងទេ, មិនអាចនឹងប្តឹងផ្តល់ដល់តុលាការបានឡើយ ។

**មាត្រា ២០១** ៖ បើប្តីមិនអនុញ្ញាតឲ្យប្រព័ន្ធប្តឹងផ្តល់ទេ ឬឲ្យចុះកិច្ចសន្យាអ្វីទេ, ប្រពន្ធអាចនឹងប្តឹងតុលាការសាលារដ្ឋប្បវេណីនៅទីដែលខ្លួននៅនោះសុំអនុញ្ញាតបាន, តុលាការត្រូវសួរប្តី ឬក៏កោះហៅតាមច្បាប់មកជំរះពីដំណើរនោះ។

**មាត្រា ២០២** ៖ ការប្តឹងសុំបដិសេធនូវកិច្ចសន្យាអ្វីមួយដែលស្រីមានប្តីបានធ្វើដោយឥតសុំអនុញ្ញាតិពីប្តីនោះអាចប្តឹងបានតែ ប្តី ឬ ស្រីនោះខ្លួនឯង ឬ ទាយាទនៃប្តីប្រពន្ធនោះ ។

# ជំពូកបី
# អំពីការលែងគ្នា
## ផ្នែកទី២
## បទបញ្ញត្តិទូទៅ

**មាត្រា ២០៣** ៖ ដែលហៅថា ការលែងគ្នា នោះគឺកិរិយាផ្តាច់នូវអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធ ដែលរៀបការពេញច្បាប់ក្នុងពេលរស់នៅទាំងពីរនាក់ ។

**មាត្រា២០៤** ៖ ប្តីប្រពន្ធ អាចនឹងលែងគ្នាបាន លុះណាតែតុលាការកាត់សេចក្តីឲ្យលែងដោយសារតែមានហេតុដូចដែលច្បាប់បានកំណត់ទុកមកផង។

**មាត្រា២០៥** ៖ បណ្តឹងសុំលែងគ្នានោះ អាចប្តឹងបានទាំងប្តីប្រពន្ធព្រមគ្នា ឬប្តឹងតែប្តីក៏បាន ឬ តែប្រពន្ធក៏បាន។

**មាត្រា ២០៦** ៖ ហេតុដែលប្តីអាចនឹងប្តឹងសុំលែងប្រពន្ធបាននោះគឺ ៖

១. ពីព្រោះប្រពន្ធផិតក្បត់ ។

២. ពីព្រោះប្រពន្ធដើរចោល លំនៅសង្វាសរវាងមួយយប់ដោយឥតហេតុអ្វីដ៏គួរសោះ ។

៣. ពីព្រោះប្រពន្ធចុងវាយដំច្រំធាក់ប្រពន្ធដើមដល់មានរបួស, ស្លាកស្នាម ឬ ធ្វើទុក្ខជេរប្រមាថជាទម្ងន់ ។

**មាត្រា ២០៧** ៖ ហេតុដែលប្រពន្ធអាចនឹងប្តឹងសុំលែងប្តីបាននោះគឺ ៖

១. ពីព្រោះប្តីមិនបានចិញ្ចឹម, បីបាច់រក្សាប្រពន្ធ, កូនឲ្យគួរសមតាមកាតព្វកិច្ចនៃខ្លួនជាប្តី ។

២. ពីព្រោះប្ដីនោះបោះបង់លំនៅសង្វាសលើសពីបីខែដោយឥតហេតុអ្វីដ៏គួរ ហើយឥតមានផ្គត់ផ្គង់ស្បៀងអាហារ, ទំនុកបំរុងប្រពន្ធ, កូនសោះ ។

៣. ពីព្រោះប្ដីបណ្ដេញខ្លួនឲ្យចុះចេញពីលំនៅសង្វាសដោយឥតហេតុដ៏គួរ។

**មាត្រា ២០៨** ៖ ហេតុដែលប្ដី ឬ ប្រពន្ធអាចនឹងសុំលែងគ្នាបាននោះទេគឺ ៖

១. ពីព្រោះសហព័ទ្ធវាយ, ដំ, ច្រំ, ធាក់, រំលោភហួសខ្នាត, ធ្វើបាប, ជេរ, ប្រមាថខ្លួនជាទម្ងន់ក្ដី ឬ ប្រព្រឹត្តនូវអំពើទាំងឡាយនោះជាទម្ងន់ដល់បុព្វញាតិនៃខ្លួនក្ដី ។

២. ពីព្រោះសហព័ទ្ធ ត្រូវទណ្ឌកម្មជាទោសឧក្រិដ្ឋ ។

៣. ពីព្រោះសហព័ទ្ធ កាន់កិរិយាមារយាទអនាចារក្រៅធម៌, ក្រៅកល្យាណគតិ ។

៤. ពីព្រោះឃ្លាតគ្នាអស់កាលជាងមួយឆ្នាំឡើងទៅ ។

**មាត្រា ២០៩** ៖ ប្ដីប្រពន្ធ អាចនឹងលែងគ្នា ដោយស្ម័គ្រចិត្តទាំងអស់គ្នាបានដែរតែក្នុងករណីនេះ ត្រូវទុកប្ដីជាខុសនឹងត្រូវឲ្យប្ដីទទួលបង់ខាត។

**មាត្រា ២១០** ៖ ពាក្យប្ដឹងសុំលែងគ្នានេះ ទោះសុំលែងដោយប្រការដូចម្ដេចក្ដី ត្រូវយកទៅប្ដឹងដល់តុលាការខាងលំនៅដែលចុងចម្លើយនៅ។

**មាត្រា ២១១** ៖ ប្រពន្ធអាចនឹងសុំលែងប្ដីបាន ដោយមិនបាច់មានអនុញ្ញាតពីប្ដីឡើយ។

## ផ្នែកទី៤
## អំពីនីតិវិធីនៃការលែងគ្នា

**មាត្រា ២១២** ៖ ពាក្យប្ដឹងសុំលែងគ្នា នោះត្រូវធ្វើជាលាយលក្ខណ៍អក្សរ យកទៅជូនចាងហ្វាងសាលាដំបូងដោយខ្លួនឯង។

**មាត្រា ២១៣** ៖ ពាក្យនោះត្រូវដាក់ហេតុដែលនាំឲ្យលែងគ្នានោះផង។

**មាត្រា ២១៤** ៖ ចាងហ្វាងត្រូវហៅអ្នកដែលប្ដឹងនោះឲ្យចូលមក ហើយ និយាយរំឭកប្រដៅសំរួលតាមដែលយល់ឃើញថាគួរដើម្បីនឹងបញ្ចូលចិត្តអ្នកនោះ ឲ្យលែងប្ដឹងទៅវៀរតែកាលណាចាងហ្វាងយល់ឃើញថា ពាក្យសុំលែងគ្នានោះ មានអាងហេតុជាទម្ងន់ណាស់ ។

**មាត្រា ២១៥** ៖ បើដើមចោទ នៅតែទទូចសុំលែងចាងហ្វាងត្រូវកោះហៅ ប្ដីប្រពន្ធទាំងពីរនាក់ឲ្យចូលមកកាន់សាលាក្នុងរវាង១៥ថ្ងៃ ដើម្បីនឹងផ្សះផ្សាក្រែង បានការ។

**មាត្រា ២១៦** ៖ (ក្រ.លេខ ៥៥ នស.២៩-១១-៥៥) ក្នុងរឿងប្ដឹងលែងគ្នា នេះ ចាងហ្វាងត្រូវកោះភាគីតាមច្បាប់ធម្មតា ។ ការប្រគល់សេចក្ដីសម្រេចដោយ ដាច់ណាត់ក្ដីការបើកផ្លូវឧទ្ធរណ៍ ផ្លូវសារទុក្ខ ល័ក្ខខ័ណ្ឌស្ដីពីទម្រង់ និងរយៈវេលា ប្ដឹងក្ដីក៏ត្រូវគោរពតាមច្បាប់ធម្មតាដែរ ។

**មាត្រា ២១៧** ៖ បើផ្សះផ្សាទៅហើយមិនបានការចាងហ្វាងអាចនឹងបង្គាប់ ឲ្យផ្សះផ្សាជាថ្មីម្ដងទៀតបាន។

**មាត្រា ២១៨** ៖ បើការផ្សះផ្សាជាលើកទី១ ខាងប្ដី ឬ ប្រពន្ធ ដែលតុលាការបានកោះឲ្យមកតាមច្បាប់ ហើយមិនបានមកចាងហ្វាងត្រូវតែផ្សះផ្សាល្បងម្ដងទៀតជាលើកទីពីរ។

**មាត្រា ២១៩** ៖ បើប្ដី ឬ ប្រពន្ធ ជាដើមបណ្ដឹងដែលចៅក្រមបានកោះឲ្យមកតាមច្បាប់ហើយមិនមកទាំងជាន់មុនជាន់ក្រោយនោះ ត្រូវទុកថាដើមបណ្ដឹងសុខចិត្តលែងប្ដឹងវិញហើយ ។

**មាត្រា ២២០** ៖ បើចុងចម្លើយបានទទួលដីកាកោះតាមច្បាប់ហើយ ហើយនៅតែមិនព្រមចូលមកកាន់សាលាទាំងជាន់មុនទាំងជាន់ក្រោយនោះត្រូវទុកថា មិនព្រមសះជាទេ។

**មាត្រា ២២១** ៖ បើអ្នកដែលមិនបានមកក្នុងវេលាកោះលើកមុន មិនមែនជាអ្នកមិនបានមកជាលើកទី២ទេ តុលាការត្រូវកោះមកផ្សះផ្សាមួយលើកទៀតជាលើកទី៣ ។

បើដើមចោទ ឬ ចុងចម្លើយមិនបានចូលមកទៀត, ចាងហ្វាងត្រូវកោះហៅតាមបទបញ្ញត្តិនៃមាត្រាទាំងពីរខាងលើនេះ ។

**មាត្រា ២២២** ៖ សេចក្ដីដែលផ្សះផ្សាទាំងប៉ុន្មានដងនោះត្រូវឲ្យឃ្លាតពីគ្នា ១៥ថ្ងៃយ៉ាងតិចមួយខែយ៉ាងច្រើន។

**មាត្រា ២២៣** ៖ ការដែលផ្សះផ្សាម្ដងៗនោះ ទោះបានការយ៉ាងណាៗក្ដីត្រូវចុះក្នុងកំណត់ហេតុថា បានការ មិនបានការ ឬ គូក្ដីមិនចូលមកទេ ហើយចាងហ្វាងចុះហត្ថលេខាក្នុងកំណត់ហេតុនោះទៅ ។

**មាត្រា ២២៤** ៖ បើល្បងផ្សះផ្សាទៅហើយ មិនបានការសោះចាងហ្វាងត្រូវកោះប្ដីប្រពន្ធនោះឲ្យចូលមកសាលាក្នុងកំណត់មួយខែ ។

**មាត្រា ២២៥** ៖ និរាកណ៍ (ក្រ. លេខ៥៥ ន.ស ២៩-១១-៥៥)

**មាត្រា ២២៦** ៖ បើប្ដី ឬ ប្រពន្ធជាដើមបណ្ដឹងនោះ គឺចៅក្រមបានកោះហៅជាត្រឹមត្រូវហើយមិនចូលមកកាន់សាលា និងមិនបានប្ដឹងដោះសារយ៉ាងណាសោះ ឬ មិនសុំឲ្យបង្អង់សេចក្ដីទៅថ្ងៃក្រោយទេ នោះត្រូវទុកថាឈ្មោះនោះសុខចិត្តលែងក្ដីហើយចៅក្រមត្រូវចំណាយរឿងនោះចោល។

**មាត្រា ២២៧** ៖ បើចុងចម្លើយ មិនបានចូលមកវិញ ដោយឥតគំនាប់ច្បាប់ដូច្នោះដែរ ហើយបើតុលាការយល់ឃើញថាហេតុដែលដើមចោទប្ដឹងមិនសុខចិត្តនោះមានភស្តុតាងពិតតុលាការអាចកាត់សេចក្ដីឲ្យលែងគ្នាត្រឹមនោះតែម្ដង បើបណ្ដឹងនោះមិនទាន់មាន ភស្តុតាងច្បាស់ទេតុលាការត្រូវឲ្យស៊ើបសួរតទៅទៀត។

**មាត្រា ២២៨** ៖ បើប្ដី ឬ ប្រពន្ធជាចុងចម្លើយ ប្រកែកថាសេចក្ដីដែលប្ដឹងពីខ្លួននោះមិនពិតទេតុលាការត្រូវបញ្ជារស៊ើបសួរ ។

**មាត្រា ២២៩** ៖ អំពីក្ដីលែងគ្នានេះ បើមានត្រូវការស៊ើបសួរតុលាការត្រូវស៊ើបសួរឲ្យឆាប់ក្នុងខែនោះឯងត្រូវបង្គាប់ឲ្យជូនសំបុត្រស្នាមដែលត្រូវការឲ្យកោះសាក្សីដែលមានប្រយោជន៍ត្រូវសួរនិងចាត់ចែងវិធានការសព្វសារពើ ដែលយល់ថាគួរចាត់។

**មាត្រា ២៣០** ៖ តុលាការអាចនឹងបញ្ជាឲ្យស៊ើបសួរ ឬ ជំនុំជម្រះដោយសម្ងាត់ក៏បាន ។

**មាត្រា ២៣១** ៖ ការវិនិច្ឆ័យដល់អង្គសេចក្តីត្រូវតែធ្វើក្នុងរវាង១៥ថ្ងៃ គិតតាំងពីថ្ងៃស៊ើបសួរហើយមក ។

**មាត្រា ២៣២** ៖ រយៈវេលាឧទ្ធរណ៍ត្រូវកំណត់៣០ថ្ងៃ បើសេចក្តីដែលតុលាការកាត់ជាសាលក្រមដាច់ណាត់ ត្រូវគិតពីថ្ងៃបានទទួលកំណត់ដៃបើសេចក្តីដែលតុលាការបានកាត់ជាសាលក្រមចំពោះមុខគូភាគីត្រូវគិតពីថ្ងៃកាត់សេចក្តី ។

**មាត្រា ២៣៣** ៖ ការចេញកំណត់ដៃ ឲ្យដំណឹងអំពីសាលក្រមរឿងលែងគ្នាដែលចៅក្រមកាត់សេចក្តីដោយដាច់ណាត់នោះ ត្រូវទីសមុហបញ្ជីចេញឯងក្នុងរវាង១៥ថ្ងៃគិតតាំងពីថ្ងៃដែលកាត់សេចក្តីដាច់ណាត់នោះមក។

**មាត្រា ២៣៤** ៖ រយៈវេលាឧទ្ធរណ៍នេះឃាត់សាលក្រមដែលកាត់ហើយមិនទាន់ឲ្យមានអានុភាពសិន។

**មាត្រា ២៣៥** ៖ សាលាឧទ្ធរណ៍ ដែលបានទទួលបណ្តឹងឧទ្ធរណ៍ ពីរឿងលែងគ្នានោះ ត្រូវសម្រេចក្តីក្នុងខែជាបន្ទាប់គិតពីថ្ងៃទទួលសំណុំរឿងនោះមក ។ ទីសមុហបញ្ជីនៃសាលាដំបូង ក៏ត្រូវបញ្ជូនសំណុំរឿងនោះទៅសាលាឧទ្ធរណ៍កុំឲ្យយឺតយូរដែរ ។

**មាត្រា ២៣៦** ៖ នីតិវិធី និងរយៈវេលា ដែលច្បាប់តម្រូវឲ្យសាលាដំបូងប្រតិបត្តិយ៉ាងណាៗ សាលាឧទ្ធរណ៍ក៏ត្រូវប្រតិបត្តិតាមយ៉ាងនោះៗដែរ ហើយរបៀបប្រគល់សាលាដីកា ប្តឹងសារទុក្ខ ចុះបញ្ជី និងជំនុំជម្រះក៏មានរបៀបដូចគ្នាដែរ។

**មាត្រា ២៣៧** ៖ រយៈវេលានៃបណ្ដឹងសារទុក្ខនេះ ឃាត់សាលដីកាដែលកាត់ហើយមិនទាន់ឲ្យមានអានុភាពសិនដែរ។

**មាត្រា ២៣៨** ៖ បើប្ដីប្រពន្ធសះជានឹងគ្នាវិញ ត្រឡប់មកនៅរួមរស់ជាមួយគ្នាវិញ សេចក្ដីដែលប្ដឹងសុំលែងគ្នានោះ ត្រូវបញ្ចប់ត្រឹមនេះទោះរឿងក្ដីនោះទៅដល់ណាក៏ដោយ។

**មាត្រា ២៣៩** ៖ នាកាលបានទទួលពាក្យប្ដឹងសុំលែងគ្នាហើយចាងហ្វាងអាចនឹងចាត់វិធានការជាបណ្ដោះអាសន្នបាន។

**មាត្រា ២៤០** ៖ ចាងហ្វាង ត្រូវកំណត់ទីកន្លែងឲ្យប្ដីប្រពន្ធម្នាក់ៗនៅក្នុងវេលាដែលកំពុងក្ដីនឹងគ្នា។ ចាងហ្វាងត្រូវសម្រេចជាបណ្ដោះអាសន្នឲ្យប្ដី ឬ ប្រពន្ធថែរក្សាកូនទ្រព្យសម្បត្តិនិងឲ្យចេញប្រាក់ចិញ្ចឹមផងប្រសិនបើគួរសម្រេច។

**មាត្រា ២៤១** ៖ នាកាលសាលក្រម ឬសាលដីកា ដែលកាត់សេចក្ដីឲ្យលែងគ្នាជាស្ថាពរហើយ ចៅក្រមត្រូវឲ្យចម្លងសេចក្ដីវិនិច្ឆ័យនៃសាលក្រម ឬ សាលដីកានោះបិទផ្សាយនៅសាលដំបូងសាលាឃុំក្នុងឃុំដែលប្ដីប្រពន្ធម្នាក់ៗនៅ។

**មាត្រា ២៤២** ៖ មួយទៀត ចាងហ្វាងត្រូវចាត់ចែងឲ្យចម្លងសេចក្ដីវិនិច្ឆ័យនៃសាលក្រម ឬសាលជាស្ថាពរនោះ ចុះនៅរឹមទំព័រនៃអាពាហ៍ពិពាហ៍សញ្ញាប័ត្រដែលត្រូវរលាយ។

## ផ្នែកទី ៣
## អំពីអានុភាពនៃការលែងគ្នា

**មាត្រា ២៤៣** ៖ ការលែងគ្នាបំផ្លាញនូវអានុភាពរបស់អាពាហ៍ពិពាហ៍ឲ្យវិនាសអស់តាំងពីថ្ងៃដែលត្រូវដាច់គ្នាជាស្ថាពរមក ។

**មាត្រា ២៤៤** ៖ ប្រសិនបើអាពាហ៍ពិពាហ៍ដែលដាច់គ្នានោះជាអាពាហ៍ពិពាហ៍ខាន់ស្លាទី១ ប្តីអាចយកប្រពន្ធមួយទៀតជាខាន់ស្លាទី១ដូចគ្នាបាន។

**មាត្រា ២៤៥** ៖ ប្រពន្ធដែលដាច់ប្តីនេះ អាចនឹងយកប្តីមួយទៀតជាខាន់ស្លាទី១ ឬ ជាខាន់ស្លាទី២បាន ប៉ុន្តែប្រពន្ធនេះត្រូវនៅក្នុងវិធវភាពដប់ខែរាប់ពីថ្ងៃដែលសាលក្រមកាត់ឲ្យដាច់នោះទុកជាស្ថាពរមក។

**មាត្រា ២៤៦** ៖ សាលក្រម ដែលកាត់ឲ្យប្តីប្រពន្ធដាច់នោះត្រូវសម្រេចអំពីអំណាចមេបាដែលត្រូវប្រគល់ទៅឲ្យឪពុក ឬ ទៅឲ្យម្តាយ ហើយនិងត្រូវសម្រេចអំពីការប្រាស្រ័យទាក់ទងរវាងឪពុកម្តាយនិងកូននោះផង ។

**មាត្រា ២៤៧** ៖ ឪពុក ឬ ម្តាយណាដែលសាលក្រមមិនបានឲ្យរក្សាកូនទេ ឪពុក ឬ ម្តាយនោះត្រូវជួយចិញ្ចឹមជួយបីបាច់រក្សាជួយចេញសាហ៊ុយអប់រំ និងរៀនសូត្ររបស់កូននោះតាមសមគួរដល់ធនធានរបស់ខ្លួនផង។

**មាត្រា ២៤៨** ៖ បើឪពុកនិងម្តាយមិនស្រុះស្រួលគ្នាក្នុងការទទួលបីបាច់ថែរក្សាកូនទេចៅក្រមត្រូវឲ្យម្តាយរក្សាកូនតូចៗដែលមានអាយុមិនទាន់ដល់៥ឆ្នាំប្រសិនបើគ្មានហេតុអ្វីមកជំទាស់ទេ ។ លុះដល់កូននោះមានអាយុលើសពីប្រាំឆ្នាំទៅកូនស្រីត្រូវនៅជាមួយម្តាយ កូនប្រុសត្រូវនៅជាមួយឪពុក ។

**មាត្រា ២៤៩** ៖ កាលណាកូនទាំងនោះមានអាយុដល់១៦ឆ្នាំហើយ ប្រសិនបើគ្មានហេតុអ្វីមកជំទាស់ទេ កូននោះអាចនៅជាមួយឪពុកក៏បាននៅជាមួយម្ដាយក៏បានតាមចិត្តស្ម័គ្ររបស់វា។

**មាត្រា ២៥០** ៖ ទ្រព្យរបស់ប្ដីប្រពន្ធ ដែលលែងគ្នានោះត្រូវចែកតាមកិច្ចសន្យាមាតិកភណ្ឌដោយឡែក ។

**មាត្រា ២៥១** ៖ ប្រសិនបើគ្មានកិច្ចសន្យាអ្វីដោយឡែកទេ ប្រពន្ធត្រូវយកទ្រព្យដើមរបស់ខ្លួន ដែលខ្លួនបានមកក្នុងពេលអាពាហ៍ពិពាហ៍ព្រមទាំងមត៌កអំណោយ ឬ អច្ច័យទាន ដែលត្រូវបានមកខ្លួនផ្ទាល់ក្នុងពេលដែលខ្លួននៅជាប់នឹងប្ដីនៅឡើយ ។

**មាត្រា ២៥២** ៖ ម្យ៉ាងវិញទៀត ប្រសិនបើស្រីនោះ ជាប្រពន្ធទី១ ប្រពន្ធនោះត្រូវបានចំណែកពាក់កណ្ដាលនៃទ្រព្យដែលរកបានជាមួយគ្នាក្នុងពេលដែលនៅមូលគ្នានៅឡើយគឺទ្រព្យដែលរកបានដោយសារធ្វើការងារ និងគ្រប់គ្រងទ្រព្យសម្បត្តិក្នុងគ្រួសារ ឬ រកបានដោយសារបណ្ដាក់ទុកយកការ យកផលទុនដែលជាទុនរបស់ប្ដី ឬ របស់ប្រពន្ធ ។

(ព្រះរាជប្រកាសលេខ១៨០ចុះថ្ងៃ១១-៨-៣៧ បន្ថែមបទបញ្ញត្តិដូចតទៅនេះ) អចលវត្ថុទាំងឡាយណាដែលបានជាបណ្ដោះអាសន្ន ឬ ជាស្ថាពរក្នុងពេលដែលប្ដីប្រពន្ធនៅក្នុងចំណងអាពាហ៍ពិពាហ៍នឹងគ្នា ហើយទ្រព្យនោះប្រាកដជាបានមកពីសម្បត្តិរបស់រដ្ឋខ្មែរមែនពិតឥតគវាំបាន ទ្រព្យអចលនវត្ថុទាំងឡាយនោះត្រូវទុកជាទ្រព្យផ្ទាល់នៃប្រពន្ធជាស្ត្រីខ្មែរ ដែលរៀបអាពាហ៍ពិពាហ៍នឹងប្ដីបរទេស

លើកមួយតែបរទេសនោះជាពលរដ្ឋ បាំរាំងជាអាណាប្រជានុរាស្ត្របាំរាំង ឬ ជារាស្ត្រដែលនៅក្នុងអាណាព្យាបាលបារាំង។

**មាត្រា ២៥៣** ៖ ក៏ប៉ុន្តែបើសាលក្រម ដែលបានកាត់សេចក្តីឲ្យលែងគ្នានោះ ព្រោះប្រពន្ធផិតប្តី នាងប្រពន្ធនេះត្រូវបានតែទ្រព្យដើមរបស់ខ្លួន ដែលខ្លួនបានមក ក្នុងពេលមុនមានអាពាហ៍ពិពាហ៍ ឬ ទ្រព្យដែលត្រូវបានមកខ្លួន ផ្ទាល់ខ្លួនក្នុងពេល ដែលខ្លួនមានអាពាហ៍ពិពាហ៍ ដូចជា មត៌ក, បណ្តាំ ឬអច្ច័យទាន និងសំលៀក បំពាក់ផ្ទាល់ខ្លួនប៉ុណ្ណោះ។ ទ្រព្យទាំងឡាយណាដែលរកបានជាមួយគ្នាក្នុងពេល មានអាពាហ៍ពិពា ទ្រព្យទាំងអស់នោះត្រូវបានទៅប្តី ។ ម្យ៉ាងវិញទៀត ប្រពន្ធនេះ ត្រូវសងជំនូនទាំងប៉ុន្មានដែលប្តី ឬ ឪពុកម្តាយរបស់ប្តីបានជូនក្នុងពេលកំជាប់ពាក្យ ឬ ក្នុងពេលរៀបការផង។

**មាត្រា ២៥៤** ៖ ប្រពន្ធទី២ ដែលដាច់អាពាហ៍ពិពាហ៍នោះ ត្រូវបានតែទ្រព្យ ដើមរបស់ខ្លួនប៉ុណ្ណោះទេ គឺថាមិនត្រូវបានចំណែកក្នុងសម្បត្តិរួមឡើយ។

**មាត្រា ២៥៥** ៖ ក៏ប៉ុន្តែបើទ្រព្យដើមរបស់នាងនោះត្រូវប្តីចាយវាយអស់ទៅ ហើយ ប្តីនោះត្រូវសងតម្លៃរបស់ទាំងនោះមកប្រពន្ធទី២វិញ លើកមួយតែក្នុង ករណីដែលការលែងគ្នានោះបណ្តាលមកពីហេតុផិតក្បត់។

**មាត្រា ២៥៦** ៖ ប្រពន្ធទាំងនោះ ត្រូវបានសោធនអាហារណើយ តែក្នុង ករណីដែលការលែងនោះមិនមែនជាកំហុសរបស់ខ្លួនទេ ។

**មាត្រា ២៥៧** ៖ ប្រពន្ធទី១ ដែលអស់ទ្រព្យដើមរបស់ខ្លួន ដោយសារប្តីចាយ វាយអស់ទៅនោះ ត្រូវមានសិទ្ធិឲ្យប្តីសងតម្លៃនៃទ្រព្យនោះដែរ ប្រសិនបើទ្រព្យរួម

នោះមិនអាចសងនាងគ្រាន់ទេ នាងនោះត្រូវបានជាម្ចាស់បំណុលរបស់ប្ដី លើកមួយតែក្នុងករណីនៃការលែងគ្នានោះដោយហេតុផិតក្បត់។

**មាត្រា ២៥៨** ៖ ប្រសិនបើទ្រព្យរួម កាលបើចែកគ្នាទៅ មិនអាចចិញ្ចឹមនាងបានទេ ប្រពន្ធទី១ត្រូវបាន សោធនអាហារណើយទៀត ប្រសិនបើការលែងគ្នានោះមិនមែនខុសមកពីខ្លួនទេ។

**មាត្រា ២៥៩** ៖ សោធនអាហារណើយនេះ ត្រូវឈប់ឲ្យ, ឈប់ជំពាក់ហើយកាលណាបើប្រពន្ធ ដែលលែងគ្នានោះ ទោះបើមានខាន់ស្លាទីប៉ុន្មានក៏ដោយមានប្ដីទៀតមានសាហាយ ឬ មានកិរិយាមារយាទមិនត្រឹមត្រូវល្អ។

## ចំពូក៤
## អំពីបុត្តភាព

**មាត្រា ២៦០** ៖ ដែលហៅថា បុត្តភាព គឺជាចំណងញាតិលោហិតផ្ទាល់ដែលចងឪពុក ឬ ម្ដាយ ឲ្យជាប់នឹងកូនដែលកើតអំពីខ្លួន។

**មាត្រា២៦១** ៖ បិតុភាព គឺជាចំណងដែលចងឪពុកឲ្យជាប់នឹងកូន ហើយមាតុភាពគឺជាចំណងដែលចងពីម្ដាយឲ្យជាប់និងកូន ។

**មាត្រា២៦២** ៖ បុត្តភាព ដែលទុកជាមានខាន់ស្លា គឺបុត្តភាពរបស់កូន ដែលកើតអំពីឪពុកម្ដាយ មានអាពាហ៍អាពាហ៍តាមច្បាប់។

**មាត្រា២៦៣** ៖ បុត្តភាព ដែលទុកជាឥតខាន់ស្លា គឺជាបុត្តភាពរបស់ខ្លួនដែលកើតពីឪពុកម្ដាយគ្នាអាណាព្យាល ។

## ផ្នែកទី១
## អំពីបុត្តភាពនៃកូនមានខាន់ស្លា

**មាត្រា ២៦៤** ៖ កូនម្នាក់នឹងទុកជាកូនមានខាន់ស្លាបានលុះណាតែមាតានៃកូននោះមានគត៌ក្នុងវេលាដែលឪពុកម្ដាយនៅជាប់អាពាហ៍ពិពាហ៍នឹងគ្នា ។

**មាត្រា ២៦៥** ៖ គត៌ដែលត្រូវសន្មតថាមានក្នុងពេលអាពាហ៍ពិពាហ៍នោះគឺគត៌ដែលសម្រាលក្នុងរយៈវេលាលើសពី១៨០ថ្ងៃគិតពីថ្ងៃដែលរៀបអាពាហ៍ពិពាហ៍មក ឬ ក្នុងយៈវេលា៣០០ថ្ងៃគិតពីថ្ងៃដែលដាច់អាពាហ៍ពិពាហ៍នោះមក ។

**មាត្រា២៦៦** ៖ កូនដែលកើតក្នុងល័ក្ខខ័ណ្ឌនៃពេលដូចខាងលើនេះត្រូវទុកថាកូននោះមានឪពុក គឺប្ដីនៃម្ដាយ។

**មាត្រា២៦៧** ៖ កូនដែលកើតក្នុងរយៈវេលាតិចជាង១៨០ថ្ងៃគិតពីថ្ងៃដែលរៀបការមកអាចនឹងទុកថាជាកូនរបស់ប្ដីនៃម្ដាយបាន លុះណាតែមានភស្តុតាងច្បាស់ថា ឪពុកនោះបានដឹងថាម្ដាយនេះមានគត៌តាំងពីមុនការមកដែរ ឬ ក៏ឪពុកនេះទទួលស្គាល់ថាខ្លួននេះហើយជាឪពុកនៃកូននោះ បើមិនដូច្នោះទេប្ដីអាចប្រកែកអំពីបិតុភាពនោះបានដោយមិនបាច់រកភស្តុតាងអ្វីថាខ្លួនមិនមែនជាឪពុកនោះទេ ។

**មាត្រា ២៦៨** ៖ កូនដែលកើតក្នុងថ្ងៃទី១៨០ គិតពីថ្ងៃការមក និងកើតក្នុងថ្ងៃទី៣០០គិតពីថ្ងៃដាច់អាពាហ៍ពិពាហ៍មក ជាភស្តុតាងមួយយ៉ាងមាំតម្រូវឲ្យសន្មតថាប្ដីនៃម្ដាយ គឺពិតជាឪពុកនៃកូននោះហើយ ។ ប្ដីនៃម្ដាយនឹងបំផ្លាញអានុភាពនៃភស្តុតាងនេះបាន លុះណាតែប្ដីនោះប្រកែកមិនព្រមទទួលស្គាល់នូវបិតុភាពនេះសោះ ។

**មាត្រា ២៦៩** ៖ ប្ដីនេះត្រូវប្ដឹងពីម្ដាយនិងពីកូនដល់តុលាការខាងលំនៅនៃម្ដាយនោះ។

**មាត្រា ២៧០** ៖ ប្ដីត្រូវដាក់ពាក្យប្ដឹងក្នុងរយៈវេលា២ខែ គិតពីថ្ងៃដែលខ្លួនបានដំណឹងអំពីកំណើតនៃកូននោះមក។

**មាត្រា ២៧១** ៖ ប្ដីត្រូវជូនភស្ដុតាងថា កាលប្រពន្ធខ្លួនមានគភ៌ក្នុងសម័យដែលច្បាប់បានកំណត់មកនោះ គឺថាក្នុងវេលាជាចន្លោះពីថ្ងៃទី៣០០មកទល់នឹងថ្ងៃទី ១៨០ មុនកំណើតនៃកូននោះខ្លួនមានវិបត្ដិខាងកាយមិនអាចរួមដំណេកជាមួយម្ដាយនៃកូននោះបានទេ។

**មាត្រា២៧២** ៖ សេចក្ដីប្រកែកថា ខ្លួនមានវិបត្ដិខាងរូបកាយដែលមិនអាចរួមដំណេកបាននោះអាចកើតមកពីហេតុពីរយ៉ាង៖

១. ប្ដីប្រពន្ធមានលំនៅឆ្ងាយពីគ្នា ។

២. ប្ដីមានកាយវិកលកម្ម បណ្ដាលមកពីគ្រោះថ្នាក់ដែលមិនអាចឲ្យធ្វើសេវនកិច្ចកើត ។

**មាត្រា២៧៣** ៖ បើម្ដាយលាក់កូនដែលសម្រាលមិនឲ្យប្ដីដឹង បើប្ដីមានភស្ដុតាងថាប្រពន្ធផិត បើប្ដីនិងប្រពន្ធមានលំនៅចែកពីគ្នា ទាំងបីយ៉ាងនេះត្រូវទុកថាពាក្យប្រកែករបស់ប្ដីមានភស្ដុតាងគ្រប់គ្រាន់គួរឲ្យយកពាក្យ ដែលប្ដឹងសុំមិនទទួលស្គាល់កូននោះថាជាត្រឹមត្រូវបាន ។

**មាត្រា ២៧៤** ៖ ទាយាទខាងប្ដីអាចនឹងប្ដឹងបដិសេធកូននោះបាន លុះតែប្ដីនោះស្លាប់បាត់ខ្លួន ឬ ក៏ឆ្លួតលេលាមុនផុតកំណត់ពីរដែលមាត្រា២៧០បើកឲ្យនោះ

ហើយលុះតែប្ដីនោះ ក្នុងវេលាដែលខ្លួនមិនទាន់អៀសខ្លួនបាត់ ឬ ដែលមានសតិបញ្ញាជាប្រក្រតីនៅឡើយមិនព្រមទទួលថាកូននោះកើតពីខ្លួនទេ ។

**មាត្រា ២៧៥** ៖ ទាយាទនៃប្ដីត្រូវប្ដឹងក្នុងកំណត់ពីរខែដែរ ។

**មាត្រា ២៧៦** ៖ បើតុលាការកាត់សេចក្ដីទុកពាក្យដែលប្ដឹងបដិសេធនោះជាត្រឹមត្រូវតុលាការត្រូវបង្គាប់ ឲ្យលុបឈ្មោះប្ដីនោះអំពីជាតិសញ្ញាប័ត្រ ឲ្យដកត្រកូលឪពុកនោះចេញអំពីកូន ហើយឲ្យយកត្រកូលម្ដាយមកឲ្យកូនវិញ។

**មាត្រា ២៧៧** ៖ នាកាលសាលក្រមដែលកាត់សេចក្ដីនោះត្រូវដំកល់ជាស្ថាពរហើយ តុលាការត្រូវស្រង់សេចក្ដីវិនិច្ឆ័យនៃសាលក្រម បញ្ជូនទៅមន្ត្រីអត្រានុកូលដ្ឋាន ដែលបានធ្វើនូវវិញ្ញាប័ត្រនោះឲ្យចម្លងដាក់ក្នុងបញ្ជីជាតិនៃឆ្នាំនោះ ហើយចុះនិទ្ទេសនៃ សាលក្រមនោះនៅរឹមទំព័រនៃជាតិសញ្ញាប័ត្រដែលត្រូវកែ។

**មាត្រា ២៧៨** ៖ បណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងសារទុក្ខឃាត់សាលក្រម ឬសាលដីកាមិនទាន់ឲ្យមានអានុភាពសិន។

## ផ្នែកទី២
## អំពីបុត្តភាពនៃកូនឥតខាន់ស្លា

**មាត្រា ២៧៩** ៖ ដែលហៅថា កូនឥតខាន់ស្លា គឺកូនដែលកើតអំពីមាតាបិតាដែលចងព័ន្ធនឹងគ្នាឥតបានរៀបការតាមច្បាប់។

**មាត្រា ២៨០** ៖ នាកាលឪពុកម្ដាយដែលឥតរៀបការតាមច្បាប់ឆ្លើយទទួលនូវទារកណាថាជាកូនខ្លួន ដោយប្រាកដចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានក្នុងវេលាធ្វើជាតិសញ្ញាប័ត្រឪពុកម្ដាយនោះត្រូវទុកជាឪពុកម្ដាយនៃទារកនោះ ។

**មាត្រា ២៨១** ៖ បើម្ដាយ ឬ ឪពុកទទួលតែម្នាក់ឯងទារកឥតខាន់ស្លានោះ ត្រូវទុកជាកូននៃអ្នកដែលទទួលតែប៉ុណ្ណោះ ។

**មាត្រា ២៨២** ៖ ឪពុក ឬ ម្ដាយទទួលស្គាល់កូនឥតខាន់ស្លាក្រោយពេលដែលបានប្ដឹងពីកំណើតនៃទារកនោះក៏បាន ។

**មាត្រា ២៨៣** ៖ នាកាលឪពុក ឬ ម្ដាយឆ្លើយទទួលស្គាល់កូនឥតខាន់ស្លាក្រោយពេលដែលប្ដឹងអំពីកំណើតដូច្នេះ មន្ត្រីអត្រានុកូលដ្ឋានខាងលំនៅឪពុកម្ដាយកត់បណ្ដឹងនោះក្នុងសៀវភៅកំណើតក្នុងឆ្នាំនោះនៅមុខសាក្សីជានីតិជនពីរនាក់។

**មាត្រា ២៨៤** ៖ បើអ្នកដែលប្ដឹងទទួលនៅក្នុងឃុំដែលទារកនោះកើតដែរ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវកត់និទ្ទេសនៃសេចក្ដីទទួលត្រង់រឹមទំព័រនៃជាតិសញ្ញាប័ត្រនៃកុមារនោះ ។

**មាត្រា២៨៥** ៖ បើអ្នកដែលប្ដឹងទទួលមិនមានទីលំនៅក្នុងឃុំដែលទារកនោះកើតទេមន្ត្រីអត្រានុកូល ដ្ឋានត្រូវចម្លងសេចក្ដីទទួលនោះមួយច្បាប់បញ្ជូនទៅចាងហ្វាងសាលាដំបូងជាប្រញាប់ ចាងហ្វាងនេះត្រូវរវេះរវៃចាត់ចែងយ៉ាងណាឲ្យបាននិទ្ទេសនៃសេចក្ដីទទួលនោះចុះត្រង់រឹមទំព័រនៃជាតិសញ្ញាប័ត្រនៃទារកនោះ ។

បើឪពុកម្ដាយណាប្ដឹងសុំទទួលស្គាល់ កូនក្នុងប្រទេសដែលគ្មានអត្រានុកូលដ្ឋាន ឬ ក្នុងបរទេសឪពុកម្ដាយនោះអាចបញ្ជាក់នូវការទទួលស្គាល់នេះតាមទម្រង់ដែលអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនោះធ្លាប់ធ្វើមក គឺជាសេចក្ដីចម្លងនៃសារលិខិតនេះមានសេចក្ដីបញ្ជាក់ជាត្រឹមត្រូវ, ប្រសិនបើឪពុកម្ដាយនៃកូន

នោះបានសុំឲ្យចុះក្នុងបញ្ជីនៃជាតិសញ្ញាប័ត្រដែលរក្សាទុកក្នុងអង្គទូត ឬ ក្នុងកុងស៊ុលនៃប្រទេសមានសមត្ថកិច្ច ។

**មាត្រា ២៨៦** ៖ បើមន្ត្រីអត្រានុកូលដ្ឋានមិនបានប្រតិបត្តិតាមបញ្ញត្តិនៃមាត្រាខាងលើនោះទេមន្ត្រីនោះត្រូវមានទោសតាមមាត្រា៤៦នៃក្រមនេះ។

**មាត្រា ២៨៧** ៖ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវកុំទទួលពាក្យសុំទទួលស្គាល់កូនដែលកើតអំពីឪពុកម្ដាយទាស់នឹងមុខស្នេ់ ឬ កូនដែលកើតអំពីម្ដាយផិតប្ដី ។

**មាត្រា ២៨៨** ៖ ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋាន បានព្រមទទួលពាក្យសុំទទួលស្គាល់កូនដែលកើតអំពីម្ដាយផិតប្ដី ឬ ដែលកើតអំពីសមគ្គសង្វាសទាស់នឹងមុខស្នេ់ ការទទួលស្គាល់នោះត្រូវទុកជាមោឃៈអាសារឥតការ។

## ផ្នែកទី៣

## ធម្មានុរូបកម្មនៃកូនឥតខាន់ស្លា

**មាត្រា ២៨៩** ៖ ដែលហៅថា ធម្មានុរូបកម្ម គឺកិរិយាធ្វើនូវកូនឥតខាន់ស្លាឲ្យមានគុណភាពជាកូនមានខាន់ស្លាឡើងវិញ ។

**មាត្រា ២៩០** ៖ កាលបើឪពុកម្ដាយ ដែលបានទទួលស្គាល់នូវកូនទាំងឡាយរបស់ខ្លួនរួច ហើយទើបនឹងរៀបការតាមច្បាប់ជាក្រោយកូនឥតខាន់ស្លានោះអាចនឹងឡើងជាកូនមានខាន់ស្លាបាន ។

**មាត្រា ២៩១** ៖ ខណៈកូនទាំងនោះត្រូវឡើងជាកូនមានខាន់ស្លាពេញច្បាប់ដោយមិនបាច់ឲ្យឪពុកម្ដាយប្ដឹងទទួលស្គាល់ជាថ្មីទៀតឡើយ ។

**មាត្រា ២៨២** ៖ ប្រសិនបើកាលកូននោះកើតមកគ្មានអ្នកណាបានឆ្លើយទទួលស្គាល់ទេ ប៉ុន្តែថ្ងៃក្រោយមកឪពុកម្ដាយនៃកូននោះរៀបការតាមច្បាប់វិញ កូននោះអាចនឹងឡើងជាកូនមានខាន់ស្លាបាន ឲ្យតែឪពុកម្ដាយឆ្លើយទទួលស្គាល់ក្នុងវេលាដែលរៀបការនោះ។

**មាត្រា ២៨៣** ៖ ក្នុងករណីនេះមន្ត្រីអត្រានុកូលដ្ឋាន ត្រូវកត់ចម្លើយនៃសហព័ទ្ធម្នាក់ៗដែលឆ្លើយទទួលនោះ ក្នុងអាពាហ៍ពិពាហ៍សញ្ញាប័ត្រថា ខ្លួនពិតជាឪពុកម្ដាយនៃកូនទាំងឡាយដែលមានត្រកូល ឈ្មោះ អាយុ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលកូននោះកើតឲ្យច្បាស់លាស់។

**មាត្រា ២៨៤** ៖ និទ្ទេសនៃធម្មានុរូបកម្មនោះ ត្រូវចុះក្នុងរឹមទំព័រនៃជាតិសញ្ញាប័ត្រនៃកូនម្នាក់ៗឲ្យគ្រប់កូន។

**មាត្រា ២៨៥** ៖ បើឃុំដែលរៀបការនៃឪពុកម្ដាយនោះ ជាឃុំទីទៃពីទីដែលកូនធម្មានុរូបកម្មទាំងឡាយនោះកើតទេ មន្ត្រីអត្រានុកូលដ្ឋានដែលបានធ្វើអាពាហ៍ពិពាហ៍សញ្ញា ប័ត្រត្រូវប្រតិបត្តិតាមបទបញ្ញត្តិនៃមាត្រា២៨៥ដែរ បើពុំដូច្នោះទេមន្ត្រីនេះនឹងត្រូវមានទោសដែលមានបញ្ញត្តិក្នុងមាត្រានោះ។

**មាត្រា ២៨៦** ៖ កូនឥតខាន់ស្លាទាំងឡាយ ដែលឪពុកឬម្ដាយមិនបានទទួលស្គាល់ទេ ឪពុកម្ដាយនោះនឹងធ្វើឲ្យកូននោះបានជាកូនមានខាន់ស្លា ដោយធ្វើពាក្យសុំទទួលជាឯក្រោយផ្សេងអំពីអាពាហ៍ពិពាហ៍សញ្ញាប័ត្រ តាមលក្ខខណ្ឌដែលមានបញ្ញត្តិក្នុងមាត្រា២៨២នឹងមាត្រា២៨៣ក៏បាន ។

ប្រសិនបើធម្មានុរូបកម្មដែលទើបនឹងធ្វើក្នុងពេលរៀបអាពាហពិពាហ ឬ ក្រោយរៀបអាពាហពិពាហតាមបញ្ញត្តិនៃមាត្រា២៨៦ នៃក្រមរដ្ឋប្បវេណីដែលសំដែងថា “កូនឥតខាន់ស្លាទាំងឡាយដែលឪពុកម្តាយមិនបានទទួលស្គាល់ទេអាចនឹងធ្វើខ្លួនឲ្យជាកូនមានខាន់ស្លា ដោយធ្វើឪពុកម្តាយពាក្យសុំទទួលជាឯក្រោយផ្សេងអំពីអាពាហពិពាហសញ្ញាប័ត្រ តាមល័ក្ខខ័ណ្ឌដែលមានបញ្ញត្តិក្នុងមាត្រា ២៨២ និងមាត្រា២៨៣ក៏បាន” បានធ្វើក្នុងប្រទេសមានអគ្រានុកូលដ្ឋាន ឬ ក្នុងបរទេសដែលនាំឲ្យពាក្យសុំទទួលស្គាល់កូននោះ ត្រូវធ្វើតាមទម្រង់ ដែលអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនោះធ្លាប់ធ្វើមកសារលិខិតនោះត្រូវយកជាបន្ទាល់បាន ហើយសាមីជនណា ឬ ឪពុកម្តាយអាចបញ្ជាក់នូវការទទួលស្គាល់នេះដោយជូនកំណត់ដៃនៃពាក្យសុំទទួលស្គាល់នោះក៏បាន ដោយជូនសេចក្តីចម្លងនៃសារលិខិតនេះមានសេចក្តីបញ្ជាក់ជាត្រឹមត្រូវក៏បាន ប្រសិនបើសាមីជននោះ ឬ ឪពុកម្តាយនៃកូននោះបានសុំឲ្យចុះក្នុងបញ្ជីនៃអាពាហពិពាហសញ្ញាប័ត្រ ឬ ជានិសញ្ញាប័ត្រដែលរក្សាទុកក្នុងអង្គទូត ឬ កុងស៊ុលនៃប្រទេសមានសមត្ថកិច្ច ។

## ផ្នែកទី៤
## ការស្វែងរកបុត្តភាពឥតខាន់ស្លា

**មាត្រា ២៨៧** ៖ កាលបើគ្មានលិខិតអ្វីទទួលស្គាល់ដោយស្ម័គ្រចិត្តទេ តុលាការអាចតម្រូវឲ្យឪពុកម្តាយ ទទួលស្គាល់នូវកូនឥតខាន់ស្លាបាន។

**មាត្រា ២៨៨**៖ កូនឥតខាន់ស្លាដែលឪពុក មិនបានទទួលស្គាល់អាចប្តឹងឲ្យតុលាការរកឪពុក ឬ រកម្តាយឲ្យបានជាដរាប។

**មាត្រា ២៩៩** ៖ ប៉ុន្តែតុលាការមិនត្រូវទទួលពាក្យដែលប្ដឹងសុំឲ្យរកឪពុកដែលទាស់នឹងមុខស្នេហ៍ ឬ ម្ដាយផិត ឬ ម្ដាយដែលទាស់នឹងមុខស្នេហ៍ឡើយ ។

**មាត្រា ៣០០** ៖ កូនឥតខាន់ស្លា ដែលឪពុកម្ដាយមិនបានទទួលស្គាល់អាចនឹងប្ដឹងឲ្យតុលាការរកឪពុកម្ដាយឲ្យបាន តែក្នុងរវាង២ឆ្នាំរាប់ពីថ្ងៃដែលខ្លួនមាននីតិភាពតទៅប្រសិនបើកូននោះមិនអាចបញ្ជាក់ថា វាទើបនឹងមានភស្តុតាងល្មមឲ្យសន្និដាន ឬ ឲ្យរកឪពុក ឬ ម្ដាយវាក្នុងពេលជាខាងក្រោយទៀតទេ ។

ប្រសិនបើវាបានបញ្ជាក់ដូចខាងលើ នោះវិញ, រយៈវេលាពីរឆ្នាំនោះត្រូវរាប់ពីត្រឹមថ្ងៃដែលវាទើបនឹងបានភស្តុតាងតទៅ ។

**មាត្រា ៣០១** ៖ តុលាការអាចនឹងកាត់សេចក្ដីថា ស្រីនេះជាម្ដាយឥតខាន់ស្លារបស់កូននោះបាន កាលណាបើតុលាការបានភស្តុតាងច្បាស់ អំពីការសម្ភពនៃស្រីនោះ និងបាន ភស្តុតាងច្បាស់អំពីអត្តសញ្ញាណរវាងកូនដែលកើត និងកូនដែលទាមទារមាតុភាពនោះឥតក័ន្តច្រឡំទេ។

**មាត្រា ៣០២** ៖ មធ្យោបាយគ្រប់យ៉ាងអាចទុកជាភស្តុតាងបានទាំងអស់ ។

**មាត្រា ៣០៣** ៖ តុលាការអាចកាត់សេចក្ដីថា បុរសនោះត្រូវជាឪពុកឥតខាន់ស្លារបស់កុមារនោះបាន ។

១. ប្រសិនបើបុរសនោះបាននាំពង្រត់ ឬ បានកំហែងរួមបវេណីដល់ទីជំរៅលើរូបកូនស្ត្រីជាម្ដាយនោះ, កាលណាបើសម័យនាំរត់ ឬសម័យរួមបវេណីនោះត្រូវគ្នានឹងសម័យដែលស្រីនោះមានគក៌ ។

២. ប្រសិនបើប្រុសនោះបានចែចង់ស្រីនោះដោយឧបាយកលបញ្ឆោត, ឬ កំហែង ឬ សន្មតថានឹងរៀបការយកជាប្រពន្ធ ។

៣. បើមានអក្ខរាពីប្រុស ដែលត្រូវប្រកាន់ថាជាឪពុកនោះមានសេចក្តីថា ព្រមទទួលខ្លួនជាឪពុកនោះដោយឥតភ័ន្តច្រឡំទេ ។

៤. បើប្រុសដែលត្រូវប្រកាន់ថាជាឪពុកហើយនឹងម្តាយនៃកូននោះបាន សហាស្មន់នឹងគ្នាក្នុងសម័យដែលស្រីនោះមានផ្ទៃពោះគ្រប់ចំនួនក្នុងថ្ងៃទី ១៨០ ទៅដល់ថ្ងៃទី ៣០០ មុនថ្ងៃដែលកូននោះកើត ។

៥. ប្រសិនបើប្រុសដែលត្រូវប្រកាន់ថាជាឪពុកនោះបានជួយពិភ័ក្តិរក្សា, ជួយអប់រំកូននោះក្នុងឋានៈរបស់ខ្លួនជាឪពុក ។

៦. ប្រសិនបើប្រុសដែលត្រូវប្រកាន់ថាឪពុកនោះបានសែនមេបា ឬ សែនខ្មោច ជាភស្តុតាងថាខ្លួនបានរួមរក្សជាមួយនឹងស្រីដែលជាម្តាយនៃកុមារ នោះក្នុងសម័យនៃថ្ងៃទី ៣០០ និងថ្ងៃទី ១៨០ មុនថ្ងៃដែលកូននោះកើតមែន ។

**មាត្រា ៣០៤** ៖ ពាក្យដែលប្តឹងរកបិតុភាពមិនអាចនឹងទទួលបាន ៖

១. ប្រសិនបើមានភស្តុតាងថាស្រីនោះមានមាយាទអាក្រក់ជាក់ស្តែង ឬ ក៏បានសហាយស្មន់នឹងប្រុសដទៃទៀតដូចដែលមានសំដែងក្នុងមាត្រា ២៧៣ ហើយមានផ្ទៃពោះ, ក្នុងសម័យដូចដែលច្បាប់បានសំដែងថាពីថ្ងៃទី ១៨០ ទៅដល់ថ្ងៃទី ៣០០ នោះ ។

២. ប្រសិនបើបុរស ដែលត្រូវប្រកាន់ថាជាឪពុកនោះមានកាយមិនអាចរួមដំណែកជាមួយនឹងម្តាយនៃកូននោះបាន គឺថាការមិនអាចនេះដោយហេតុឪពុកមាន

លំនៅឆ្ងាយពីគ្នាពេក ឬ មិនអាចដោយហេតុមពីមានគ្រោះថ្នាក់ដូចដែលមានសំដែងក្នុងបទបញ្ញត្តិនៃមាត្រា ២៧២ ។

**មាត្រា ៣០៥** ៖ ក្នុងពេលដែលកូនរបស់ខ្លួននៅក្នុងអនីតិភាពនៅឡើយ ម្តាយអាចប្តឹងសុំឲ្យរកបិតុភាពឲ្យកូនខ្លួនបាន។

**មាត្រា ៣០៦** ៖ ម្តាយអាចប្តឹងរកបិតុភាពបាន រយៈវេលា២ឆ្នាំរាប់ពីត្រឹមថ្ងៃដែលខ្លួនសម្រាលកូននោះមក ។ ក៏ប៉ុន្តែប្រសិនបើមានករណីដូចបានសំដែងក្នុងកថាខ័ណ្ឌទី៤ទី៥នៃមាត្រា៣០៣ ម្តាយនោះអាចប្តឹងក្នុងរយៈ២ឆ្នាំរាប់ពីថ្ងៃដែលបុរសនោះលែងរួមដំណេកជាមួយខ្លួន ឬ ក៏រាប់ពីថ្ងៃដែលបុរសនោះលែងពិភក្តិរក្សានិងអប់រំកូននោះតទៅ។

**មាត្រា ៣០៧** ៖ មធ្យោបាយគ្រប់យ៉ាងអាចទុកជាភស្តុតាងបានទាំងអស់។ ស្រីជាមាតានៃកុមារនោះអាចប្តឹងពីបុរសដែលត្រូវប្រកាន់ថាជាឪពុកក៏បានអាចប្តឹងពីទាយាទនៃបុរសនោះក៏បាន។

**មាត្រា ៣០៨** ៖ សាលក្រមដែលកាត់សេចក្តីឲ្យទទួលស្គាល់នូវបុត្តភាពឥតខាន់ស្លានោះ មានអានុភាព ដូចគ្នានឹងលិខិតដែលទទួលស្គាល់ដោយស្ម័គ្រចិត្តដែរ។

**មាត្រា ៣០៩** ៖ កាលណាបើសាលក្រមនោះត្រូវទុកជាស្ថាពរ ហើយសេចក្តីចំឡងនៃសាលក្រមនេះមួយចប់ត្រូវបញ្ជូនទៅមន្ត្រីអត្រានុកូលដ្ឋាន នៃទីកន្លែងដែលកូននោះកើតដើម្បីឲ្យមន្ត្រីនេះ ចុះនិទ្ទេសអំពីបុត្តភាពនោះត្រង់រឹមទំព័រនៃសញ្ញាប័ត្រកំណើត។ មន្ត្រីអត្រានុកូលដ្ឋាន កាលបើបានចុះរួចហើយត្រូវប្តឹងមក

ចាងហ្វាងសាលាដំបូងអំពីការដែលខ្លួនបានប្រតិបត្តិតាមសេចក្តីនៃសាលក្រមនោះដោយសព្វគ្រប់ហើយ ។

**មាត្រា៣១០** ៖ សាលក្រមដែលកាត់សេចក្តីឲ្យទទួលស្គាល់នូវបិតុភាពឥតខាន់ស្លានោះ អាចនឹងបង្ខំឪពុកនោះឲ្យសងសោហ៊ុយសម្រាលកូន ប្រាក់ចំណាយបីបាច់ថែរក្សាកូនតាំងពីថ្ងៃដែលកូននោះកើតមកដល់ស្រីជាម្តាយនៃកូននោះបាន។

ម្យ៉ាងទៀត តុលាការអាចឲ្យបុរសនោះចេញប្រាក់មួយចំណែកទៀតដល់ស្រីនោះទុកជាសាហ៊ុយជម្ងឺចិត្តកាលបើបុរសនោះបានសន្យាថានឹងរៀបអាពាហពិពាហ ឬ ក៏បុរសនោះបានរំលោភស្រីនោះតាំងពីកាលដែលនាងនៅក្នុងអនីតិភាពនៅឡើយ ។

**មាត្រា ៣១១** ៖ តុលាការអាចបង្គាប់ឲ្យបុរសនោះចេញថ្លៃសោធនអាហារណីយដល់កុមារនោះតាមសមាមាត្រនៃធនធានរបស់ឪពុកនោះបានជាដរាប ។ សោធននេះត្រូវចេញឲ្យមុន តាមការកំណត់របស់សាលក្រមរហូតដល់កូននោះមានអាយុ១៨ឆ្នាំ ប្រសិនបើកូននោះជាកូនប្រុស ប្រសិនបើកូននោះជាកូនស្រីវិញ ឪពុកនេះត្រូវចេញសោធនរហូតដល់កូននោះមានប្តី ឬ រហូតដល់កូននោះមានអាយុ២១ឆ្នាំ ។

**មាត្រា ៣១២** ៖ ឪពុកអាចត្រូវរួចពីកាតព្វកិច្ចនេះបានដែរ ប្រសិនបើឪពុកព្រមទទួលយកកូននោះទៅចិញ្ចឹមដូចជាកូនរបស់ខ្លួនបង្កើត ហើយម្តាយនោះសោតទៀតក៏មិនបានជាជំទាស់នឹងការនេះដែរ ។ ប្រសិនបើឪពុកនិងម្តាយនោះមិនចុះ

សំរុងគ្នាក្នុងការចិញ្ចឹមនេះទេតុលាការត្រូវកាត់សេចក្ដីដោយយោលទៅតាមហេតុ និងគោលច្បាប់ដូចដែលមានបញ្ញត្តិក្នុងមាត្រា២៤៨ និង២៤៩នោះ។

**មាត្រា ៣១៣** ៖ កូនឥតខាន់ស្លាត្រូវយកឈ្មោះរបស់ឪពុកម្ដាយដែលទទួលស្គាល់ខ្លួន ឬ ដែលតុលាការបានបង្ខំឲ្យទទួលស្គាល់ ។ ប្រសិនបើឪពុកនិងម្ដាយបានទទួលស្គាល់កូននោះដោយស្ម័គ្រចិត្ត ឬ ប្រសិនបើតុលាការបានតម្រូវឲ្យឪពុកនិងម្ដាយទទួលស្គាល់ កូនឥតខាន់ស្លានោះត្រូវយកឈ្មោះឪពុកជាត្រកូល ។

**មាត្រា ៣១៤** ៖ កូនដែលមានបុត្តភាពឥតខាន់ស្លា ត្រូវមានករណីយកិច្ចហើយនិងត្រូវបានសិទ្ធិចំពោះម្ដាយ និងឪពុករបស់ខ្លួនដូចជាកូនដែលមានខាន់ស្លាដែរ ។

## ចំពូក៥
## អំពីសុំកូន

**មាត្រា ៣១៥** ៖ សុំកូនគឺជាកិច្ចសន្យាមួយយ៉ាងឧឡារិកដែលចងបុគ្គលពីរគឺម្នាក់ហៅថាឪពុកសុំ ហើយម្នាក់ទៀតហៅថា កូនសុំឲ្យមានចំណងទាក់ទងគ្នាដូចជាបុត្តភាពមានខាន់ស្លាដែរ ។

**មាត្រា ៣១៦** ៖ បុរសត្រូវមានអាយុជាង២៥ឆ្នាំ ត្រូវបងកូនសុំ២០ឆ្នាំយ៉ាងតិច និងត្រូវគ្មានកូនសោះទើបអាចសុំកូនគេចិញ្ចឹមបាន ។

**មាត្រា ៣១៧** ៖ គេអាចសុំបានតែកូនមួយនាក់ប៉ុណ្ណោះ ប្រសិនបើកូនដែលសុំមកនោះវាស្លាប់ ហើយគ្មានកូនទៀតទេ គេអាចសុំកូនមួយនាក់ទៀតបាន ។

**មាត្រា ៣១៨** ៖ កូនសុំនោះ ត្រូវមានអាយុតិចជាង៨ឆ្នាំ ។

**មាត្រា ៣១៩** ៖បុរសដែលមានអាពាហាពិពាហហើយ អាចនឹងសុំកូនគេបាន លុះណាតែប្រពន្ធមានខាន់ស្លាទី១បានយល់ព្រមផង ហើយលុះណាតែតាំងពីការ មក៣ឆ្នាំហើយគ្មានកូនសោះគឺ៣ឆ្នាំដែលក្នុង១ឆ្នាំមាន១២ខែនៃចន្ទគតិ ។

**មាត្រា ៣២០** ៖ ស្រីគ្មានប្ដីអាចសុំកូនគេចិញ្ចឹមបានដែរ ។

**មាត្រា៣២១** ៖ ឪពុកនិងម្ដាយមានខាន់ស្លា ឬឥតខាន់ស្លានៃកូនដែលសុំគេ នោះ ឬ បើគ្មានឪពុកម្ដាយទេ ជនជាអាណាព្យាបាលនៃកូននោះត្រូវឲ្យសេចក្ដីព្រម ព្រៀងរបស់ខ្លួនក្នុងកិច្ចសន្យាសុំកូននោះ។

**មាត្រា ៣២២** ៖ កិច្ចសន្យាសុំកូនត្រូវធ្វើជាលិខិតមានបញ្ជាក់មេឃុំ គឺមេឃុំ ខាងលំនៅនៃអ្នកសុំ។

មេឃុំនេះ ត្រូវចំឡងសេចក្ដីនៃកិច្ចសន្យានោះទាំងមូលដាក់ក្នុងបញ្ជីសម្រាប់ ចុះសំបុត្របញ្ជាក់ ។

អ្នកសុំកូន ព្រមទាំងប្រពន្ធមានខាន់ស្លាទី ១ នៃជននោះ, ម្ដាយឪពុកនៃកូន ដែលគេសុំ ឬ ជនជាអាណាព្យបាលនៃកូននោះត្រូវទៅប្ដឹងនៅចំពោះមុខមន្ត្រី អត្រានុកូលដ្ឋានយ៉ាងច្បាស់លាស់ថាខ្លួនសុខចិត្ត ព្រមចុះកិច្ចសន្យាសុំកូនចិញ្ចឹមនេះ ត្រឹមត្រូវហើយ ហើយចុះហត្ថលេខាលើកិច្ចសន្យានោះ, ប្រសិនបើជនទាំងនោះចេះ អក្សរ ។

**មាត្រា ៣២៣** ៖ មន្ត្រីអត្រានុកូលដ្ឋានត្រូវស្រង់សេចក្ដីក្នុងលិខិតកិច្ចសន្យា នោះ យកមកចុះក្នុងរឹមទំព័រនៃសញ្ញាប័ត្រកំណើតរបស់កូនសុំ ប្រសិនបើកូននោះ កើតក្នុងឃុំនោះ ប្រសិនបើកូននោះមិនមែនកើតក្នុងឃុំដែលធ្វើកិច្ចសន្យានោះទេ

មេឃុំត្រូវចំឡងកិច្ចសន្យានោះចប់ ផ្ញើទៅជូនចាងហ្វាងសាលាដំបូងភ្នាម ។ ចាងហ្វាងនេះត្រូវរវៀររវៃផ្ញើសេចក្តី ចំឡងនោះទៅឲ្យមន្ត្រីអត្រានុកូលដ្ឋានដែលសមត្ថភាពក្នុងរឿងនេះឲ្យចាត់ការតាមច្បាប់ ។

ប្រសិនបើសុំកូនដែលកើតឡើងក្នុងប្រទេសណាមួយដែលមានអត្រានុកូលដ្ឋាន ឬប្រទេសដទៃនាំឲ្យពាក្យសុំកូននោះធ្វើតាមទម្រង់ដែលអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនោះធ្លាប់ធ្វើមក ហើយបើល័ក្ខខ័ណ្ឌដែលមាត្រាពី៣១២ដល់៣២២ (វគ្គទី២) នៃក្រម រដ្ឋប្បវេណីតម្រូវឲ្យមានដើម្បីទុកជាបានការតាមច្បាប់នោះមានគ្រប់សព្វអស់ ហើយសារលិខិតនោះត្រូវយកជាបន្ទាល់បាន ហើយកូនសុំនិងឪពុកម្តាយសុំ ឬ ឪពុកម្តាយឥតខាន់ស្លាអាចជូនកិច្ចសន្យាសុំកូនក៏បានជូនសេចក្តីចម្លងនៃកិច្ចសន្យានោះ ដែលមានសេចក្តីបញ្ជាក់ជាត្រឹមត្រូវក៏បាន ប្រសិនបើភាគីនៃរឿងនេះបានសុំឲ្យចុះក្នុងបញ្ជីអត្រានុកូលដ្ឋានដែលរក្សាទុកក្នុងអគ្គទូត ឬ អគ្គកុងស៊ុលនៃប្រទេសមានសមត្ថកិច្ច ។

**មាត្រា ៣២៤** ៖ កិច្ចសន្យាសុំកូន ត្រូវធ្វើជា៣ច្បាប់ គឺ២ច្បាប់ក្រោយដែលបានបញ្ជាក់មេឃុំរួចហើយ ត្រូវប្រគល់ទៅឲ្យអ្នកសុំមួយច្បាប់ ប្រគល់ទៅឲ្យម្តាយឪពុកបង្កើតនៃកូនសុំ ឬ អាណាព្យាបាលនៃកូននោះមួយច្បាប់ ហើយច្បាប់ទី៣ត្រូវរក្សាទុកក្នុងបណ្ណាសារដ្ឋានអត្រានុកូលដ្ឋាន ។

**មាត្រា ៣២៥** ៖ សុំកូននេះមានអានុភាពឲ្យកូននោះឆ្លងពីភាពជាកូននៃគ្រួសារមានខាន់ស្លា ឬ ឥតខាន់ស្លាមួយទៅជាកូននៃគ្រួសាររបស់អ្នកសុំវិញ ។

**មាត្រា ៣២៦** ៖ កូនសុំត្រូវយកនាមត្រកូលនៃឪពុកសុំ កូនសុំត្រូវមានកាតព្វកិច្ចនិងករណីយកិច្ចចំពោះឪពុកសុំ និងគ្រួសាររបស់ឪពុកសុំដូចជាកូនបង្កើតដែរ ។

**មាត្រា ៣២៧** ៖ ឪពុកសុំត្រូវបីបាច់ថែរក្សាកូនសុំដូចជាកូនខ្លួនបង្កើតដែរ។

**មាត្រា ៣២៨** ៖ កូនសុំ និងបច្ឆាជនរបស់កូនសុំត្រូវមានសិទ្ធិបានមត៌កអំពីឪពុកសុំដូចជាកូនបង្កើតមានខាន់ស្លាដែរ ។

**មាត្រា ៣២៩** ៖ ឪពុកសុំវិញក៏ដូចគ្នាដែរ គឺថាឪពុកសុំត្រូវទទួលមត៌កអំពីកូនសុំដូចគ្នាដូចជាឪពុកបង្កើតនៃកូនសុំដែរ ។

**មាត្រា ៣៣០** ៖ កូនសុំនៅតែរក្សាសិទ្ធិទទួលមត៌កអំពីឪពុកម្ដាយបង្កើតមានខាន់ស្លា ឬ ឥតខាន់ស្លារបស់ខ្លួនដែរ ។ ក៏ប៉ុន្តែឪពុកម្ដាយនៃកូននេះអាចផ្ដាច់មិនឲ្យកូននេះបាននូវមត៌កក៏បាន ដោយមិនបាច់ប្រាប់ហេតុដែលមិនឲ្យនោះថាមកពីកូននោះអកតញ្ញូ ឬ អតីតដូច្នេះឡើយ។

**មាត្រា ៣៣១** ៖ ច្បាប់ដែលហាមមិនឲ្យញាតិលោហិតរៀបអាពាហពិពាហនឹងគ្នានោះក៏ត្រូវហាមមិនឲ្យកូនសុំ, ក្រោយដែលបានប្រគល់មកឲ្យឪពុកសុំរួចហើយ, រៀប អាពាហពិពាហនឹងគ្រួសារខ្លួនដែលមានខាន់ស្លា ឬ ឥតមានខាន់ស្លាដែរ ។

**មាត្រា ៣៣២** ៖ ប្រសិនបើឪពុកសុំបណ្ដោយឲ្យកូនសុំរស់នៅដោយឥតមានពិភក្តិរក្សាសោះឬ បើឪពុកសុំធ្វើទុក្ខបុកម្នេញកូនសុំ, តុលាការត្រូវកាត់សេចក្តី

ដោយឯកឯង ឬ ដោយមានពាក្យបណ្ដឹងរបស់ញាតិនៃកូនសុំឲ្យបដិសេធ សិទ្ធិនៃបិតុភាពសុំ នេះអំពីឪពុកសុំចេញ ។

**មាត្រា ៣៣៣** ៖ សាលក្រមដែលកាត់សេចក្ដីបដិសេធសិទ្ធិបិតុភាពនោះ ត្រូវឆ្លងកាត់ឲ្យប្រគល់កូនសុំដែលនៅក្នុងអនីតិភាពនោះឲ្យបុគ្គលណាម្នាក់រក្សារ ឬ ឲ្យនៅក្នុងអាណាព្យាបាលនៃបុគ្គលណាម្នាក់ផង ។

**មាត្រា ៣៣៤** ៖ សេចក្ដីវិនិច្ឆ័យនៃសាលក្រមនេះត្រូវទៅចុះត្រង់រឹមទំព័រកំណើតរបស់កូនសុំព្រមទាំងចុះលើរឹមទំព័រនៃកិច្ចសន្យាសុំកូនដែលរក្សារទុកក្នុងបណ្ណាសារដ្ឋាននៃឃុំនោះផង ។

## ជំពូក ៦
## អំពីអំណាចមេបា

**មាត្រា ៣៣៥** ៖ ដែលហៅថា អំណាចមេបា នោះគឺសិទ្ធិ អំណាចទាំងអស់ដែលស្របច្បាប់ប្រគល់ដល់ឪពុក និងម្ដាយឲ្យយកសិទ្ធិ និងអំណាចនេះទៅប្រើប្រាស់លើរូបកាយ និងលើទ្រព្យសម្បត្តិរបស់កូនអនីតិជនដើម្បីឲ្យឪពុក និងម្ដាយនោះអាចបំពេញករណីយកិច្ចរបស់ខ្លួន ជាឪពុកម្ដាយបាន ។

**មាត្រា ៣៣៦** ៖ ក្នុងរយៈវេលាដែលឪពុកម្ដាយនៅមានអាពាហពិពាហនៅឡើយ, មានតែឪពុកម្នាក់ប៉ុណ្ណោះទេដែលមានអំណាចមេបា ។

**មាត្រា ៣៣៧** ៖ នាកាលឪពុកស្លាប់ទៅ ឬ ក៏តុលាការបានកាត់សេចក្ដីឲ្យឪពុកនោះផ្ដាស់អំណាចទៅ ឬ ក៏ឪពុកនោះជាប់គំហាត់របស់ច្បាប់, ក្នុងករណីនេះ, ម្ដាយត្រូវទទួលអំណាចមេបានេះឡើង ។

**មាត្រា ៣៣៨** ៖ ក្នុងរយៈវេលាដែលឪពុកបាត់ខ្លួនតែអាពាហពិពាហមិនទាន់រលាយនៅឡើយ អំណាចមេបាត្រូវបានទៅប្រពន្ធខាន់ស្លាទី១ ត្រួតត្រាលើកូនទាំងឡាយដែលកើតអំពីម្ដាយ ហើយដែររស់នៅក្នុងផ្ទះដែលប្រពន្ធនោះត្រួតត្រា។

**មាត្រា ៣៤០** ៖ អំណាចមេបានោះគឺសិទ្ធិឃុំឃាំងកូន, សិទ្ធិប្រៀនប្រដៅកូន និងសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ។

## ផ្នែកទី ១
## អំពីសិទ្ធិ ឃុំឃាំង

**មាត្រា ៣៤១** ៖ ដើម្បីនឹងឃុំឃាំង កូន, អ្នកមានអំណាចមេបាត្រូវធ្វើពាក្យជាលាយល័ក្ខអក្សរសុំទៅចាងហ្វាងសាលាដំបូង, ចាងហ្វាងក៏បញ្ជាឲ្យចាប់កូននោះ ហើយចុះហត្ថលេខា លើដីការឃុំ ។

**មាត្រា ៣៤២** ៖ ចាងហ្វាងសាលាដំបូង, មុននឹងបញ្ជាឲ្យចាប់, អាចកោះអ្នកដែលប្ដឹងសុំឲ្យឃុំឃាំងមកសួររកហេតុផល ដែលខ្លួនយល់ឃើញថាមានប្រយោជន៍សិនបាន, និងឲ្យដំបូន្មានដែលខ្លួនយល់ឃើញថាគួរឲ្យបានជាដរាប ។

បើអ្នកប្ដឹងនៅតែទទូចសុំឲ្យឃុំដដែល ចាងហ្វាងសាលាដំបូងនឹងប្រកែកមិនព្រមទទួលពាក្យនោះពុំបានទេ, តែចាងហ្វាងអាចបន្ថយកំណត់ឃុំនោះឲ្យនៅត្រឹមតែមួយខែមកវិញបាន ។

**មាត្រា ៣៤៣** ៖ កូនអនីតិជនអាយុ ១៦ ឆ្នាំមិនអាចត្រូវជាប់ឃុំលើសពីមួយខែម្ដងៗតៗគ្នាបានទេ ។

អនីតិជនលើសពី ១៦ ឆ្នាំមិនអាចត្រូវជាប់ឃុំលើសពី៦ ខែម្តងៗតៗគ្នាបានដែរ, នីតិភាពរបស់វានាំឲ្យដោះវាចេញពីឃុំមួយរំពេច ។

**មាត្រា ៣៤៤** ៖ ប្រសិនបើឪពុក ប្តឹងសុំឲ្យដាក់កូនដែលកើតពីខ្លួន, ប៉ុន្តែជាកូននឹងប្រពន្ធដើម, ចាងហ្វាងសាលដំបូងអាចប្រកែកមិនឃុំតាមពាក្យសុំបាន ។

ចាងហ្វាងអាចប្រកែកមិនព្រមឃុំតាមពាក្យសុំបានកាលណាបើអ្នកដែលប្តឹង នោះសុំឲ្យដាក់ឃុំកូនដែលខ្លួនមិនមែនជាឪពុកនិងមិនមែនជាម្តាយ ។

**មាត្រា ៣៤៥** ៖ ជនដែលសុំឲ្យឃុំកូនអាចសុំឲ្យដោះវិញភ្លាមមួយរំពេចបាន ។

ជនដែលបានទទួលអំណាចមេបា ជំនួសជនដែលប្តឹងឲ្យឃុំកូននោះមានសិទ្ធិនឹងសុំឲ្យដោះចេញពីឃុំវិញបានតាំងពីថ្ងៃដែលកូននោះជាប់ឃុំមក ។

**មាត្រា ៣៤៦** ៖ ចាងហ្វាងសាលាដំបូងអាចប្រកែកមិនព្រមដាក់ឃុំកូននោះបាន, ប្រសិនបើឃើញថាអ្នកប្តឹងនោះមានសតិបញ្ញាទន់ខ្សោយ ឬក៏មានវ័យជរាហើយ ។ ចាងហ្វាងអាចនឹងប្រកែកយ៉ាងនេះបានលុះណាតែខ្លួនបានកោះអ្នកប្តឹងនោះឲ្យចូលខ្លួនមក, ក្នុងករណីនេះចាងហ្វាងត្រូវអធិប្បាយអំពីហេតុ ដែលខ្លួនប្រកែកមិនព្រមឃុំនេះឲ្យសព្វគ្រប់ដើម្បីជូនសាលាឧទ្ធរណ៍ពិនិត្យតទៅប្រសិនបើគេឧទ្ធរណ៍ ។

**មាត្រា ៣៤៧** ៖ បើកាលណាមានឧទ្ធរណ៍ចាងហ្វាងសាលាឧទ្ធរណ៍ត្រូវជំនុំជំរះ ក្នុងរយៈពេល ១០ថ្ងៃចាប់ពីថ្ងៃដែលបានទទួលបណ្តឹងឧទ្ធរណ៍ដែលក្រឡាបញ្ជីសាលាដំបូងត្រូវបញ្ជូនជាប្រញាប់ ។ សាលាឧទ្ធរណ៍អាចកាត់សេចក្តីឲ្យជម្លោះ

អំណាចមេបាពីជនដែលប្តឹងនោះដោយចិត្តឯងបាន ។ បណ្តឹងសារទុក្ខ អំពីសាលក្រមនេះមិនអាចនាំឲ្យខានប្រតិបត្តិនូវសាលក្រមខាងលើនេះបានទេ ។

**មាត្រា ៣៤៨** ៖ នីតិវិធីដែលស្តីពីដាក់ឃុំកូន ឬពីដោះកូនចេះពីឃុំព្រមទាំងនីតិវិធីស្តីអំពីក្តីជាន់សាលាឧទ្ធរណ៍ទាំងអស់នេះត្រូវឲ្យផុតពីបង់ប្រដាប់ក្តី និងមិនបាច់ឲ្យមានទំរង់ការអ្វីៗទេ ។

## ផ្នែកទី ២
## សិទ្ធិដាក់ទណ្ឌកម្ម

**មាត្រា ៣៤៩** ៖ ឪពុកម្តាយមានសិទ្ធិដាក់ទណ្ឌកម្មលើរូបកាយកូនបានក៏ប៉ុន្តែដោយព្រហ្មវិហារធម៌ ។

**មាត្រា ៣៥០** ៖ ការដែលឪពុកម្តាយធ្វើបាបកូនរហូតដល់របួសស្នាម ឬ ក៏ធ្វើឲ្យខូចសុខភាពរបស់វា ទុកជាទណ្ឌកម្មហួសប្រមាណ ។ ទណ្ឌកម្មហួសប្រមាណនេះនាំឲ្យមានទោសជាបទអាជ្ញា ព្រមទាំងជាពិរុទ្ធនាំឲ្យតុលាការកាត់សេចក្តីឲ្យជម្លោះអំណាចមេបាពីឪពុកនោះដោយចិត្តឯងក៏បាន, ដោយមានពាក្យពីអាជ្ញាធរ ឬ ពីញាតិសន្តានណាមួយក៏បាន ។ ប្រសិនបើកូននោះនៅជាអនីតិជននៅឡើយ ហើយមិនទាន់អាចមានអត្តាធិនភាពបានទេតុលាកាត្រូវរកអាណាព្យាបាលឲ្យកូននោះ ។

## ផ្នែកទី ៣
## សិទ្ធិគ្រប់គ្រង និងប្រើប្រាស់

**មាត្រា ៣៥១** ៖ ទ្រព្យរបស់កូន ត្រូវឪពុកម្តាយគ្រប់គ្រងឲ្យរហូតដល់កូននោះមាននីតិភាព ឬ មានអត្តាធិនភាព ។

**មាត្រា ៣៥២** ៖ ការគ្រប់គ្រង គឺជាកាតព្វកិច្ចដែលតម្រូវឲ្យថែរក្សា និងឲ្យធ្វើសម្បត្តិទ្រព្យនោះឲ្យមានផ្លែផ្កានិងជាសិទ្ធិបរិភោគនូវផ្លែផ្កានោះ ។

**មាត្រា ៣៥៣** ៖ កូនដែលនៅក្នុងអនីតិភាពនៅជាមួយនឹងឪពុកម្ដាយអស់កាលដ៏យូរដរាបណា ផលនៃការងាររបស់កូននោះត្រូវបានមកឪពុកម្ដាយដរាបនោះដែរ ។

កូនដែលនៅក្នុងអនីតិភាពមិនអាច ចេញពីផ្ទះនៃឪពុកមុនពេលដែលខ្លួនមាននីតិភាព ឬ មានអត្តាធិនភាព ដោយឥតសេចក្ដីយល់ព្រមពីជនដែលខ្លួននៅក្នុងអាណាព្យាបាលនោះបានឡើយ ។

**មាត្រា ៣៥៤** ៖ កូនដែលចង់ប្ដឹងទារសម្បត្តិទ្រព្យរបស់ខ្លួន ខ្លះ ឬ ទាំងអស់ពីឪពុកម្ដាយត្រូវតែសុំការអនុញ្ញាតពីចាងហ្វាងសាលាដំបូងជាមុនសិន, បើគ្មានសេចក្ដីអនុញ្ញាតិនេះទេ, កូននោះមិនអាចប្ដឹងពីឪពុកម្ដាយខ្លួនបានឡើយ ។

**មាត្រា ៣៥៥** ៖ ចាងហ្វាងសាលាដំបូង អាចនឹងអនុញ្ញាតិឲ្យប្ដឹងបានលុះណាតែខ្លួនបានកោះហៅឪពុក និងកូននោះឲ្យចូលមកផ្សះផ្សាជាមុនសិន ។

ប្រសិនបើខែនេះចាងហ្វាងផ្សះផ្សាមិនបានផលទេ ចាងហ្វាងអាចនឹងកោះហៅឪពុក និងកូនមកផ្សះផ្សាក្នុងខែក្រោយទៀតបាន ។

**មាត្រា ៣៥៦** ៖ ឪពុកម្ដាយ ត្រូវផ្ដល់អាហារ, ពិភក្តិរក្សា, ចិញ្ចឹមអប់រំ កូនឲ្យបានល្អ, មើលកិរិយាមារយាទ, វាឲ្យបានត្រឹមត្រូវ, ឲ្យដំបូន្មានល្អដល់វា ។ ឪពុកម្ដាយត្រូវបង្រៀនកូន ឬ ឲ្យកូនរៀនសូត្រតាមសតិប្រាជ្ញារបស់វា ។

**មាត្រា ៣៥៧** ៖ ឪពុកម្ដាយដែលផ្ដស់អំណាចមេបា អស់ហើយត្រូវចេញសាហ៊ុយស្បៀងអាហារ ហើយនិងចេញសោហ៊ុយឲ្យកូនរៀនសូត្រទៀតផង ។

# មាតិកា ទី ៥

# អំពីអសមត្ថភាព

## ចំពូកទី១

## អំពីអនីតិភាព

**មាត្រា ៣៥៨** ៖ ដែលហៅថា អនីតិភាព គឺភាពរបស់បុគ្គលដែលមានអាយុមិនទាន់គ្រប់ ២១ ឆ្នាំមែនទែន ។

**មាត្រា ៣៥៩** ៖ អាយុត្រូវរាប់តាមឆ្នាំសុរិយគតិ និងពីឆ្នាំមួយទៅឆ្នាំមួយ ។

**មាត្រា ៣៦០** ៖ ថ្ងៃនៃកំណើត ដែលចុះក្នុងសញ្ញាប័ត្រកំណើតត្រូវទុកជាថ្ងៃទីមួយនៃអាយុ ។ ថ្ងៃនៃកំណើត ដែលប្រព្រឹត្តទៅហើយវិលមកជួបនឹងថ្ងៃកំណើតដើមវិញហៅថា មួយឆ្នាំ ។

**មាត្រា ៣៦១** ៖ ប្រសិនបើកំណើតណាមួយកើតក្នុងខែមួយ ហើយថ្ងៃខែនោះប្រព្រឹត្តទៅរួចវិលមកជួបនឹងថ្ងៃខែកំណើតវិញ, រយៈវេលានេះត្រូវទុកជាមួយឆ្នាំនៃអាយុ ។

**មាត្រា ៣៦២** ៖ នីតិជនមានសេរីភាពនឹងទុកដាក់ខ្លួនប្រាណរបស់ខ្លួនហើយនឹងចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនបាន ។

**មាត្រា ៣៦៣** ៖ អនីតិជន មិនមានសមត្ថភាពនឹងគ្រប់គ្រងទ្រព្យរបស់ខ្លួននិងត្រួតត្រាខ្លួនឯងដោយសេរីបានទេ ។

**មាត្រា ៣៦៤** ៖ នាកាលអនីតិជនណាគ្មានឪពុក ឬ ក៏ឪពុកនោះត្រូវតុលាការជម្លោះអំណាចមេបាអស់ឬក៏ឪពុកនោះជាជនគំហាត់, អនីតិជនត្រូវតែគេរកអាណាព្យាបាលឲ្យ។

**មាត្រា ៣៦៥** ៖ ដែលហៅថា អំណាចព្យាបាល គឺការថែរក្សានូវខ្លួនអនីតិជន និងគ្រប់គ្រងនូវទ្រព្យរបស់អនីតិជននោះ ។

## ផ្នែកទី ១
## អំពីអំណាច ព្យាបាល ពីកំណើត

**មាត្រា ៣៦៦** ៖ កាលណាបើ ឪពុកស្លាប់ទៅ, កូនទាំងប៉ុន្មានដែលកើតអំពីប្ដីនេះ ហើយដែលរស់នៅក្នុងផ្ទះជាមួយនឹងប្រពន្ធខាន់ស្លាទី ១ ត្រូវនៅក្រោមអំណាចព្យាបាលនៃប្រពន្ធខាន់ស្លាទី១ដែលមិនទាន់ស្លាប់ ។

បើអនីតិជន ច្រើននាក់កើតពីម្ដាយផ្សេងៗគ្នា ហើយរស់នៅជាមួយម្ដាយដែលមានលំនៅបែកពីគ្នាដែរ, កូនទាំងឡាយនោះត្រូវនៅក្នុងអំណាចព្យាបាលរបស់ម្ដាយខ្លួនរៀងៗខ្លួន ។

**មាត្រា ៣៦៧** ៖ ស្រីមេម៉ាយទាំងឡាយដែលមានប្ដីទៀត, ដែលមានសហាយទៀត ឬ កិរិយាមារយាទមិនត្រឹមត្រូវ, ត្រូវផ្ដាស់ខ្លួនពីអំណាចព្យាបាលកូនរបស់ខ្លួនទាំងអស់, ប្រសិនបើក្រុមប្រឹក្សាញាតិមិនព្រមឲ្យទុកកូននោះក្នុងអំណាចព្យាបាលនៃស្រីនោះទេ ។

**មាត្រា ៣៦៨** ៖ កាលណាបើប្ដីបាត់ខ្លួនតែមិនទាន់មានសាលក្រមកាត់សេចក្ដីថាប្ដីនោះបាត់ខ្លួន, អំណាចព្យាបាលត្រូវបានមកប្រពន្ធខាន់ស្ដាទី ១ ជាអ្នកត្រួតត្រាលើកូន អនីតិភាពទាំងប៉ុន្មានរបស់ប្ដី ។

កាលណាអ្នកអៀសខ្លួននេះបាត់ជាស្ថាពរហើយ, វិធាននៃការចាត់តាំងអាណាព្យាបាលក្នុងរឿងនេះក៏ដូចជាវិធានចាត់តាំងអាណាព្យាបាលក្នុងរឿងឪពុកស្លាប់នោះដែរ ។

**មាត្រា ៣៦៩** ៖ ក្នុងករណីដែលលែងគ្នា, អំណាចព្យាបាលអាចបានទៅប្ដី ឬ ទៅប្រពន្ធបាន ។

**មាត្រា ៣៧០** ៖ ប្រសិនបើឪពុកថ្កស់ខ្លួនពីអំណាចមេបាហើយ, អំណាចព្យាបាលនៃកុមារអនីតិជននោះអាចឲ្យទៅម្ដាយបានលុះណាតែម្ដាយនោះមិននៅជាមួយឪពុកទេ ។

**មាត្រា ៣៧១** ៖ ម្ដាយអាចប្រកែកមិនព្រមទទួលអំណាចព្យាបាលរបស់ខ្លួនបាន ដែរ ។

## ផ្នែកទី ២
## អំពីការប្រគល់អំណាច ព្យាបាល តាមឪពុក ឬម្ដាយរើសឲ្យ

**មាត្រា ៣៧២** ៖ ឪពុកម្ដាយ ដែលមិនទាន់ស្លាប់ហើយដែលមានអំណាចមេបាគ្រប់គ្រាន់មានសិទ្ធិរើសដោយខ្លួនឯងនូវញាតិ ឬ នូវអ្នកដទៃណាម្នាក់ឲ្យធ្វើជាអាណាព្យាបាលលើកូនរបស់ខ្លួនបាន ។

**មាត្រា ៣៧៣** ៖ សិទ្ធិ នោះអាចនឹងយកទៅប្រើប្រាស់បានលុះណាតែមាន សំបុត្រ បណ្តាំ ឬ សំបុត្របញ្ជាក់មានដាក់សេចក្តីយ៉ាងជាក់លាក់ផង ។

**មាត្រា ៣៧៤** ៖ ម្តាយ, ដែលមានប្តីទៀតហើយ ដែលគេមិនបានលើកឲ្យធ្វើជាអាណាព្យាបាលលើកូនដែលកើតពីប្តីមុនទេ, នឹងរើសអាណាព្យាបាលឲ្យកូននោះមិនបានឡើយ ។

## ផ្នែកទី ៣
## អំពីការប្រគល់ អំណាចព្យាបាលតាមច្បាប់ រើសឲ្យកូនមានខាន់ស្លា

**មាត្រា ៣៧៥** ៖ នាកាលឪពុក ឬ ម្តាយដែលស្លាប់ក្រោយគេមិនបានជ្រើសរើសអាណាព្យាបាលឲ្យកូនទេ, ថាបើកូននោះជាកូនមានខាន់ស្លា, អំណាចព្យាបាលនោះត្រូវបានមកជីតាខាងឪពុក, បើគ្មានជីតាខាងឪពុក, ត្រូវបានមកជីតាខាងម្តាយ, ឲ្យរើសដេញឡើងវិញ ទៅលើដូច្នេះដោយរបៀបយ៉ាងណាឲ្យតែបានសាច់ខាងឪពុកជាងសាច់ខាងម្តាយដែលមានថ្នាក់ស្មើគ្នា ។

**មាត្រា ៣៧៦** ៖ ប្រសិនបើជីតា ខាងឪពុកក៏គ្មាន, ជីតាខាងម្តាយក៏គ្មាន, មានតែបុព្វញាតិទូតពីរនាក់ ខាងឪពុកនៃអនីតិជននោះ, អំណាចព្យាបាលត្រូវបានទៅជីតាខាងឪពុកនៃឪពុករបស់កូននោះ ។

**មាត្រា ៣៧៧** ៖ ប្រសិនបើមានបុព្វញាតិទូតខាងម្តាយវិញហើយជីតាទូតខាងម្តាយនោះនៅទាំងពីរខាង, អំណាចព្យាបាលត្រូវឲ្យទៅជីតាទូតខាងឪពុកនៃម្តាយនៃអនីតិជននោះ ។

**មាត្រា ៣៧៨** ៖ បើឥតខាន់ស្លា បុព្វញាតិទេ, អំណាចព្យាបាលត្រូវឲ្យទៅបងប្រុសបង្កើតរួមឪពុកម្ដាយជាមួយពេញច្បាប់, ប្រសិនបើបងនោះជានីតិជន ។

**ផ្នែកទី ៤**

**អំពីការប្រគល់ អំណាចព្យាបាលតាមក្រុមប្រឹក្សាញាតិរើសឲ្យ**

**មាត្រា ៣៧៩** ៖ បើគ្មានបុព្វញាតិ និងបងប្រុសបង្កើតជានីតិជនរួមឪពុកម្ដាយជាមួយទេ, ក្រុមប្រឹក្សាញាតិត្រូវរើសអាណាព្យាបាលម្នាក់ឲ្យកូនមានខាន់ស្លាដែលនៅជា អនីតិជន ។

**មាត្រា ៣៨០** ៖ ក្រុមប្រឹក្សាញាតិគឺមេឃុំ កោះដោយចិត្តឯងឲ្យមកប្រជុំក្ដី, កោះដោយមានពាក្យពីសាច់ញាតិនៃកូនជាអនីតិជននោះសុំក្ដី ។

**មាត្រា ៣៨១** ៖ ក្រុមប្រឹក្សាញាតិត្រូវប្រជុំនៅសាលាឃុំខាងទីលំនៅនៃកូនអនីតិជននោះនៅ ។

**មាត្រា ៣៨២** ៖ ក្រុមប្រឹក្សាញាតិនោះត្រូវយកបុព្វញាតិដែលរស់នៅ, បងប្រុសនីតិជននៃកូននោះ និងបងប្រុសនីតិជននៃឪពុកកូននោះជសមាជិកក្រោមអធិបតីភាពនៃមេឃុំ ។

**មាត្រា ៣៨៣** ៖ បើគ្មានញាតិទាំងឡាយដូចមាននិយាយក្នុងមាត្រាមុននោះទេ ឬ បើចំនួនញាតិទាំងនេះ ដែលនៅរស់តិច, ថយប្រាំមួយនាក់, មេឃុំត្រូវហៅសាច់ញាតិឯទៀត ឬញាតិពន្ធ ឬបើទាល់ណាស់ទៅទៀត, ត្រូវយកមិត្តសំឡាញ់នៃឪពុកម្ដាយក៏បាន ។

**មាត្រា ៣៨៤** ៖ តមកក្រុមប្រឹក្សាញាតិ បាត់ម្នាក់ជាអាណាព្យាបាល ។

## ផ្នែកទី ៥
## អំពីអំណាចព្យាបាលលើកូនឥតខាន់ស្លា

**មាត្រា ៣៨៥** ៖ បើឪពុកនៃកូន ដែលជាអនីតិជនឥតខាន់ស្លាមិនបានរើសអាណាព្យាបាលឲ្យកូនទេ, អំណាចព្យាបាលនោះត្រូវធ្លាក់ទៅលើបងប្រុសបង្កើតទាំងឡាយនៃកូននោះដែលរួមឪពុកម្ដាយជាមួយគ្នា ហើយដែលជានីតិជនផងដោយយកតាមលំដាប់ពីបងទៅប្អូន ។

**មាត្រា ៣៨៦** ៖ បើគ្មានបងប្រុស ដែលរួមឪពុកម្ដាយមួយជានីតិជនទេ, អំណាចព្យាបាលនោះត្រូវធ្លាក់ទៅលើប្ដីនៃបងស្រីទាំងឡាយ ដែលរួមឪពុកម្ដាយជាមួយដោយរើសយកបងដែលចាស់ជាងគេ ជាជាងបងដែលក្មេងជាងគេ ។

**មាត្រា ៣៨៧** ៖ បើគ្មាបងប្រុសរួមឪពុកម្ដាយមួយ ឬ បងថ្លៃប្រុសទេ, តុលាការត្រូវទម្លាក់អំណាចព្យាបាលនេះទៅលើញាតិណាមួយដោយខំជ្រើសរើសយកញាតិថ្នាកជិតឯណាមួយដែលព្រមទទួលភារៈផង, បើបានច្រើនគប្បីយកបុព្វញាតិជាងញាតិដទៃទៀត ។

**មាត្រា ៣៨៨** ៖ បងប្រុសរួមឪពុកម្ដាយ ជានីតិជន និងប្ដីនៃបងស្រីរួមឪពុកម្ដាយមួយទាំងឡាយប្រកែកមិនទទួលអំណាចព្យាបាល នោះមិនបានទេ ក្រែងតែបណ្ដាបងទាំងនោះមានបងណាម្នាក់ទទួលហើយ ទើបអ្នកឯទៀតប្រកែកបាន ឬលុះតែបងនោះលើកហេតុដ៏គួរឯណាមួយដូចដែលមានបញ្ញត្តិក្នុងមាត្រា ៣៩៤ ខាងមុខនេះមកអាងទើបប្រកែកបាន ។

## ផ្នែកទី ៦
## អំពីអំណាចព្យាបាល លើក្មេងដែលគេបោះបង់

**មាត្រា ៣៨៩** ៖ តុលាការត្រូវផ្តល់អាណាព្យាបាលឲ្យក្មេងដែលគេបោះបង់ចោលទាំងឡាយដោយចិត្តឯងក្តី, ដោយមានពាក្យជនណាប្តឹងក្តីហើយរៀបចំនូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងរឿងនេះផង ។

**មាត្រា ៣៩០** ៖ នាកាលអំណាចបិតុភាពគឺតុលាការបានដកចេញហើយ ឬគេកំពុងប្តឹងនោះ, តុលាការត្រូវផ្តល់អាណាព្យាបាលម្នាក់ឲ្យកូនទាំងឡាយមានកូនសុំជាដើមដោយចិត្តឯងក្តី, ដោយមានពាក្យអាជ្ញារ ឬ ពីញាតិណាម្នាក់ប្តឹងក្តី ។ ក្នុងករណីនៃកូនសុំនេះ, តុលាការគួប្រគល់កូននោះទៅឲ្យឪពុកម្តាយបង្កើតរបស់វាវិញដែលឥតខាន់ស្លាក្តីមានខាន់ស្លាក្តី, ប្រសិនបើប្រគល់ឲ្យបាន ។

**មាត្រា ៣៩១** ៖ បើម្តាយដែលនៅរស់ក្រោយឪពុកមានប្តីទៀតហើយបានទទួល ភារៈពីក្រុមប្រឹក្សាញាតិឲ្យធ្វើជាអាណាព្យាបាលនៃកូនខ្លួនទាំងឡាយ ដែលនៅក្នុងអនីតិភាពនោះ, ប្តីចុងនេះក៏ជាប់ភារៈដូចប្រពន្ធខ្លួនដែលជាម្តាយនៃកូនទាំងនោះដែលគឺថាប្តីចុងត្រូវធ្វើជាអាណាព្យាបាលរួមរបស់កូននៃប្រពន្ធ ។

## ផ្នែកទី ៧
## អំពីហេតុ ដែលគប្បីឲ្យរួចអំពីការទទួលអំណាចព្យាបាល

**មាត្រា ៣៩២** ៖ ជនដែលឪពុក ឬ ម្តាយ រើសឲ្យធ្វើជាអាណាព្យាបាលអាចនឹងប្រកែកបានលុះណាតែជននោះជាអ្នកដទៃពីគ្រួសារនៃកូនអនីតិភាពនោះ ឬ ក៏មានហេតុអ្វីមួយដ៏គប្បីផងទើបប្រកែកបាន ។

**មាត្រា ៣៩៣** ៖ បុព្វញាតិ ឬ បងប្រុសបង្កើតជានីតិជន, ដែលច្បាប់តម្រូវឲ្យព្យាបាលអនីជនហើយ, មិនអាចប្រកែកបានទេ ។

**មាត្រា ៣៩៤** ៖ អាណាព្យាបាលទាំងឡាយ ដែលក្រុមប្រឹក្សាញាតិតាំងអាចនឹងប្រកែកបានលុះណាតែអ្នកនោះមានហេតុគប្បីណាស់ ។

**មាត្រា ៣៩៥** ៖ ហេតុដែលគប្បីដើម្បីប្រកែកពីមុខការជាអាណាព្យាបាលនោះគឺសុខភាព, អាយុ, បន្ទុកនៃគ្រួសាររបស់ខ្លួន ឬ មុខងាររាជាការដែលខ្លួនជាប់រវល់ ។

**មាត្រា ៣៩៦** ៖ សុខភាពនោះត្រូវឲ្យឃើញថាមានជម្ងឺជាទម្ងន់, តគ្រមតត្រយ ឬ ក៏មានពិការជានិច្ច ។

**មាត្រា ៣៩៧** ៖ ឯអាយុ ដែលជាហេតុនាំឲ្យអធ្យាស្រ័យឲ្យបាននោះត្រូវរាប់ពី ៦០ឆ្នាំឡើងទៅ ។ ប៉ុន្តែបើអ្នកនោះត្រូវគេចាត់ឲ្យធ្វើជាអាណាព្យាបាលតាំងពីមុនអាយុ ៦០ ឆ្នាំទៅទៀត, អ្នកនោះត្រូវទទួលរហូតអាយុ ៦៥ ឆ្នាំសិនទើបអាចប្រកែកបាន ។

**មាត្រា ៣៩៨** ៖ ជនដែលមានកូនលើសពីប្រាំនាក់ដែលរស់នៅទាំងអស់ហើយដែលនៅក្នុងអនីតិភាពផង, ជននោះអាចនឹងប្រកែកពីមុខងារអាណាព្យាបាលលើកូនគេបាន ។ ប៉ុន្តែបើអំណាចព្យាបាលនោះត្រូវគេប្រគល់មកឲ្យខ្លួនមុនពេលដែលខ្លួនមានកូនជាគំរប់ប្រាំមួយវិញ, ខ្លួនអាចនឹងប្រគល់មុខងារនោះឲ្យគេវិញបានក្នុងពេលដែលខ្លួនមានកូនជាគំរប់ប្រាំមួយ ។

**មាត្រា ៣៩៩** ៖ មុខងាររាជការទាំងពួងដែលជាហេតុគប្បីឲ្យប្រកែកពីមុខងារអាណាព្យាបាលបានលុះណាតែក្នុងពេលដែលប្រកែកនោះខ្លួនទទួលមុខការរាជការនោះទៅហើយ ។

## ផ្នែកទី ៨
## អំពីលក្ខខ័ណ្ឌនៃសមត្ថភាព ដើម្បីទទួលអំណាចព្យាបាល

**មាត្រា ៤០០** ៖ ជនទាំងឡាយដែលមិនមានភេទជាប្រុស, ក្រៅអំពីម្តាយនៃកូន, មិនអាចធ្វើជាអាណាព្យាបាលបានទេ ។

**មាត្រា ៤០១** ៖ អាណាព្យាបាលត្រូវមាននីតិភាពមានសម្មាអាជីវា, មិនដែលមានទោសឧក្រិដ្ឋ ឬមជ្ឈិមព្រោះលួច, ពាលអនាថា, គៃបំបាត់, ឆបោក, ក្លែង, ធ្វើឲ្យអាស្រូវកាសក្នុងទីសាធារណៈ, បៀតបៀនកេរ្ត៍ខ្មាស ឬ ដឹកនាំអនីតិជនឲ្យស្រើបក្នុងអបាយមុខ ។

**មាត្រា ៤០២** ៖ ប្រសិនបើ, ក្រោយពីបានទទួលទីជាអាណាព្យាបាលមក, ជននោះទើបត្រូវទោសជាឧក្រិដ្ឋទី អាណព្យាបាលនោះត្រូវដកចេញតាមអំណាចនៃមាត្រា ៤៩ និង ៥០ នៃក្រមព្រហ្មទណ្ឌហើយត្រូវដកចេញតាំងអាណាព្យាបាលថ្មីជាជំនួសវិញ ។

ក្នុងករណី ដែលទើបមានទណ្ឌកម្មជាមជ្ឈិមបណ្តាលឲ្យមានអនុទោសត្រង់បញ្ញត្តិនៃមាត្រា ៤៩ កថាខណ្ឌទី ១០ នៃក្រមព្រហ្មទណ្ឌដោយអនុវត្តតាមមាត្រា ៥១ ក្នុងក្រមដដែលនោះអាណាព្យាបាលថ្មីក៏ត្រូវតែងតាំងជាជំនួសដែរ ។

**មាត្រា ៤០៣** ៖ បើទណ្ឌកម្មជាមជ្ឈិមដែលតុលាការទើបផ្តន្ទាលើអាណាព្យាបាលក្នុងកាលជាខាងក្រោយនៃការតែងតាំង ឬ ការចាត់តាំងជាអាណាព្យាបាល, គឺទណ្ឌកម្មព្រោះបទល្មើសណាមួយដែលមានពណ៌នាក្នុងមាត្រា ៤០១, ក្រុមប្រឹក្សាញាតិត្រូវជំនុំគ្នាអំពីការដែលត្រូវឲ្យឈ្មោះនោះនៅជាអាណាព្យាបាលដូចដែល ឬ យ៉ាងណា ។

ចំពោះអាណាព្យាបាល ដែលមានទោសគុកជាមជ្ឈិមកំណត់ ៦ ខែ, ឥតមានព្យួរទោសទេ, ក្រុមប្រឹក្សាញាតិក៏ត្រូវធ្វើដូច្នោះឯងដែរ ។

**មាត្រា ៤០៤** ៖ អាណាព្យាបាលត្រូវទទួលនាទីខ្លួនតាំងពីថ្ងៃដែលគេបានឲ្យដំណឹងថាខ្លួនបានត្រូវតែងតាំងជាអាណាព្យាបាលហើយ, ប្រសិនបើព្រម ។ ថាបើមិនព្រមទេ, ជននេះត្រូវប្តឹងមេឃុំខាងលំនៅនៃអនីតិជនក្នុងកំណត់ដប់ថ្ងៃឲ្យជ្រាបអំពីហេតុដែលខ្លួនមិនព្រមទទួលនោះ ។

**មាត្រា ៤០៥** ៖ អាណាព្យាបាលដែលក្រុមប្រឹក្សាញាតិតែងតាំងក្នុងវេលាជំនុំដែលខ្លួនបានទៅជួបជុំនោះ, បើខ្លួនមិនព្រមទទួលទេ, ត្រូវប្រកែកភ្លាមក្នុងវេលានោះទើបបាន ។

**មាត្រា ៤០៦** ៖ ជនណាដែលច្បាប់តម្រូវឲ្យទទួលភារៈព្យាបាលហើយប្រកែកមិនព្រមទទួលដោយឥតហេតុ, ជននោះនឹងត្រូវសាលាស៊ីវិលខាងលំនៅខ្លួនពិន័យជាប្រាក់ ២០ រៀល ។

## ផ្នែកទី ៩
## អំពីភាតព្វកិច្ច និងសិទ្ធិអាណាព្យាបាល

**មាត្រា ៤០៧** ៖ អាណាព្យាបាល ត្រូវទុក បាលិតដូចជាកូនបង្កើតនៃខ្លួន ។

អ្នកត្រូវមានកាតព្វកិច្ចចំពោះកូននោះបីដូចខ្លួនជាឪពុកក្នុងគ្រួសារដែរ ។

**មាត្រា ៤០៨** ៖ កូនអនីតិជននោះត្រូវគោរព, ប្រតិបត្តិអាណាព្យាបាលខ្លួន, ស្តាប់បង្គាប់អាណាព្យាបាលដូចជាឪពុកខ្លួនបង្កើតដែរ ។

**មាត្រា ៤០៩** ៖ ក្នុងកំណត់ដប់ថ្ងៃគិតពីថ្ងៃដែលខ្លួនចូលកាន់នាទីជាអាណាព្យាបាលមក, អាណាព្យាបាលត្រូវសុំឱ្យមេឃុំខាងកន្លែងដែលមានទ្រព្យសម្បត្តិនៃក្មេងនោះធ្វើបញ្ជីវាយទ្រព្យជាចលនវត្ថុព្រមទាំងវាយតម្លៃទ្រព្យនោះផង ។

បញ្ជីនោះត្រូវធ្វើជាសារលិខិតមានសេចក្តីបញ្ជាក់ជាបីច្បាប់គឺមួយច្បាប់ត្រូវប្រគល់ឱ្យអាណាព្យាបាល, ពីរច្បាប់ទៀតបត្រូវទុកក្នុងបណ្ណសារដ្ឋានដើម្បីនឹងប្រគល់ឱ្យបាលិតនោះមួយច្បាប់ក្នុងវេលាដែលវាដល់នូវនីតិភាព ឬ ដល់នូវអត្តាធិនភាព ។

**មាត្រា ៤១០** ៖ អាណាព្យាបាលត្រូវទទួលទុកដាក់ទ្រព្យសម្បត្តិរបស់អនីតិជនដែលខ្លួនត្រូវគ្រប់គ្រងរក្សានោះក្នុងបន្ទុកខ្លួនទាំងអស់ ។

**មាត្រា ៤១១** ៖ អាណាព្យាបាលមិនអាចទទួលបញ្ចាំ ឬ ទទួលជួលនូវទ្រព្យរបស់ បាលិតបានទេ ។

**មាត្រា ៤១២** ៖ អាណាព្យាបាលមិនអាចលក់ បញ្ចាំ អចលវត្ថុ ឬ ជួលអចលវត្ថុទទួលនូវសេវភាពដោយឥតអនុញ្ញាតពីក្រុមប្រឹក្សាញាត ឬ ពីចាងហ្វាងសាលាដំបូង, ប្រសិនបើបាលិតនោះជាកូនឥតខាន់ស្លា, បានទេ ។

**មាត្រា ៤១៣** ៖ អាណាព្យាបាល ត្រូវចេញមុខតាងអនីតិជននោះក្នុងកិច្ចការស៊ីវិលទាំងអស់ ។

**មាត្រា ៤១៤** ៖ អាណាព្យាបាល មិនអាចអនុញ្ញាតឲ្យអនីតិជននោះធ្វើអំណោយនូវទ្រព្យរបស់វាខ្លះ ឬ ទាំងអស់បានឡើយ ។

**មាត្រា ៤១៥** ៖ អាណាព្យាបាល មិនអាចខ្ចីបុល ឬ ប្ដឹងផ្ដល់ដល់តុលាការជាប្រយោជន៍អនីតិជននោះដោយឥតអនុញ្ញាតពីក្រុមប្រឹក្សាញាតិ, បើបាលិតនោះជាកូនមានខាន់ស្លា, ឬ ពីចាងហ្វាងសាលាដំបូង, បើបាលិតនោះជាកូនឥតខាន់ស្លា, បានឡើយ ។

**មាត្រា ៤១៦** ៖ កិច្ចសន្យាទាំងពួង ដែលអនីតិជនធ្វើតែឯងត្រូវទុកជាមោឃៈ ។ កិច្ចសន្យាដែលអាណាព្យាបាល ធ្វើតែឯងឥតអនុញ្ញាតពីក្រុមប្រឹក្សាញាតិ ឬ ពីចាងហ្វាងសាលាដំបូងទេ, កាលបើកិច្ចសន្យានោះត្រូវតែមានអនុញ្ញាតយ៉ាងនេះខានមិនបាន, ត្រូវអាណាព្យាបាល ទទួលខុសត្រូវតែម្នាក់ឯងចំពោះតតិយជននោះហើយមិនត្រូវឲ្យមានកម្មវិបាកអ្វីមកលើបាលិតសោះឡើយ ។

**មាត្រា ៤១៧** ៖ អាណាព្យាបាល ត្រូវចាត់ចែងនូវផលទុនរបស់អនីតិជននោះដើម្បីអនីតិជននោះ ។

**មាត្រា ៤១៨** ៖ នាកាលអនីតិជនដល់នូវនីតិភាពហើយ ឬ ត្រូវដល់នូវអត្តាធិនភាពហើយ, អាណាព្យាបាលត្រូវវាយការណ៍ដែលខ្លួនបានចាត់ចែងទ្រព្យសម្បត្តិនៃក្មេងនោះប្រាប់វានៅមុខក្រុមប្រឹក្សាញាតិប្រសិនបើក្មេងនោះជាកូនមានខាន់ស្លា ។

បើអនីតិជននោះជាកូនឥតខាន់ស្លាចាងហ្វាងសាលាដំបូង ត្រូវជំរះគណនីរបស់អាណាព្យាបាលនោះ ។

**មាត្រា ៤១៩** ៖ នាកាលអនីតិជននោះដល់នូវនីតិភាពហើយ ឬ ដល់នូវអត្តាធិនភាពហើយ, អាណាព្យាបាល ត្រូវប្រគល់បេតិកភណ្ឌដែលខ្លួនបានទទួលគ្រប់គ្រងរក្សាឲ្យទៅអនីតិជនវិញ ។

**មាត្រា ៤២០** ៖ អាណាព្យាបាល ដែលទទួលគ្រប់គ្រងរបស់ទ្រព្យនោះមិនត្រូវមានឈ្នួលទេ, អាណាព្យាបាលត្រូវវាយការណ៍ប្រាប់ពីចំណាយដែលខ្លួនបានចាយដើម្បីអនីតិជននោះនិងផលទុនដែលខ្លួនបានទទួល ។

**មាត្រា ៤២១** ៖ អាណាព្យាបាល ត្រូវទទួលខុសត្រូវពីព្យាសនកម្មដែលបណ្តាលមកពីខ្លួនដោយចេតនាក្តី, ដោយធ្វេសប្រហែសក្តី, ក្នុងវេលាដែលខ្លួនគ្រប់គ្រងទ្រព្យសម្បត្តិ នោះ ។

**មាត្រា ៤២២** ៖ ទាយាទ នៃអាណាព្យាបាលត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រងរបស់អាណាព្យាបាល ។

**មាត្រា ៤២៣** ៖ ពាក្យដែលប្តឹងពីអាណាព្យាបាល ឬ ពីទាយាទនៃអាណាព្យាបាលឲ្យទទួលខុសត្រូវនោះត្រូវប្តឹងក្នុងកំណត់ពីរឆ្នាំគិតតាំងពីថ្ងៃដែល

ប្រគល់បញ្ជី ។ តែបើហេតុដែលគប្បីឲ្យអាណាព្យាបាលទទួលខុសត្រូវនោះទើបនឹងលេចឡើងជាក្រោយ, រយៈវេលាពីរឆ្នាំនោះត្រូវគិតពីថ្ងៃដែលបានដឹងនូវហេតុនោះវិញ ។

**មាត្រា ៤២៤** ៖ ចំពោះអាណាព្យាបាលដែលមិនស្មោះត្រង់, គ្មានសមត្ថភាព ឬ ក៏មានគំនិតមាយាទអាក្រក់ ឬ ប្រាសចាកលោកចរិយានោះក្រុមប្រឹក្សាញាតិអាចនឹងដកពីទីអាណាព្យាបាលចេញក្រោយ ដែលបានសេចក្ដីយល់ព្រមពីចាង-ហ្វាងសាលាដំបូងក៏បាន ឬ តុលាការអាចនឹងដកចេញដោយចិត្តឯងក៏បាន ។

**មាត្រា ៤២៥** ៖ អាណាព្យាបាលដែលមិនស្មោះត្រង់អាចនឹងត្រូវមានទោសតាមបទបញ្ញត្តិមាត្រា ៥១៥ នៃក្រមព្រហ្មទណ្ឌបាន ។

**មាត្រា ៤២៦** ៖ ញាតិណាម្នាក់នៃអនីតិជននោះក្ដី, សមាជិកណាម្នាក់នៃក្រុមប្រឹក្សាញាតិក្ដី, ជនណាម្នាក់ដែលមានប្រយោជន៍ផងក្ដី, មេឃុំក្ដី, ចាងហ្វាងសាលាដំបូងក្ដី, អាចនឹងនាំអាទិ៍ឲ្យប្រជុំក្រុមប្រឹក្សាញាតិ ដើម្បីត្រួតពិនិត្យគណនីដែលអាណាព្យាបាលកាន់កាប់នោះបាន, បើមានហេតុគប្បីឲ្យដក, អាចនឹងសម្រេចឲ្យដកងារជាអាណាព្យាបាលហើយតាំងមួយថ្មីជាជំនួសបាន ។

**មាត្រា ៤២៧** ៖ បើអាណាព្យាបាលទទួលមរណៈភាព ឬ បាត់ខ្លួន, ច្បាប់តម្រូវឲ្យរើសអ្នកជំនួសតាមវិធានដែលមានសំដែងអំពីតែងតាំងអាណាព្យាបាលនោះ ។

**មាត្រា ៤២៨** ៖ អាណាព្យាបាល មិនអាចនឹងបង្ខិតបង្ខំគេឲ្យរើសឈ្មោះណាជំនួសខ្លួនឡើយ ។

# ចំពូក ២
# អំពីអត្តាធិនភាព

**មាត្រា៤២៩** ៖ អត្តាធិនភាព គឺជាអំពើមួយដែលមានគោលដៅតែមួយគឺ បើកឲ្យ អនីតិជនគ្រប់គ្រងនូវខ្លួនរបស់ខ្លួន និងចាត់ចែងនូវទ្រព្យរបស់ខ្លួនដោយខ្លួនឯង ។

**មាត្រា ៤៣០** ៖ អនីតិជននឹងបាននូវអត្តាធិនភាពបានកាលណាបើខ្លួនអាយុពេញ ១៨ ឆ្នាំហើយ ។

**មាត្រា ៤៣១** ៖ អនីតិជនដែលមានអាពាហ៍ពិពាហ៍ ហើយ, ទោះអាយុប៉ុន្មានក្តី, ត្រូវតែបានអត្តាធិនភាពពេញច្បាប់ ។

**មាត្រា ៤៣២** ៖ ឪពុកអាចបើកឲ្យអនីតិជនបានអត្តាធិនភាពបាន, បើឥតពីឪពុកទៅ, ម្តាយក៏អាចបើកឲ្យបានដែរ ។

**មាត្រា ៤៣៣** ៖ អនីតិជនដែលជាកូនមានខាន់ស្លា, ឥតឪពុកម្តាយនោះ, ត្រូវក្រុមប្រឹក្សាញាតិអនុញ្ញាតឲ្យបានអត្តាធិនភាព, បើកូនឥតខាន់ស្លាវិញ, លុះតែតុលាការអនុញ្ញាតឲ្យទើបបាន ។

**មាត្រា ៤៣៤** ៖ អាណាព្យាបាលអាចនឹងនាំអាទ៏ឲ្យសុំក្រុមប្រឹក្សាញាតិជំនុំអំពីការដែលគួរឲ្យ ឬ មិនគួរឲ្យអនីតិជនជាកូនមានខាន់ស្លាបានអត្តាធិនភាព, បើអនីតិជនជាកូនឥតខាន់ស្លាវិញ, អាណាព្យាបាលអាចនឹងសុំឲ្យតុលាការវិនិច្ឆ័យអំពីអត្តាធិនភាពនៃអនីតិជននោះបាន ។

**មាត្រា ៤៣៥** ៖ បើអាណាព្យាបាលមិនរវល់នឹងគិតគួរឲ្យអនីតិជនជាកូនមានខាន់ស្លាបានអត្តាធិនភាពទេតែមានជនណាម្នាក់ ឬ ច្រើននាក់ដែលជាប់ញាតិលោហិត ឬ ញាតិពន្ធនឹងកូននោះហើយរហួតដល់ថ្នាក់ទី ៤ យល់ថាគួរឲ្យកូននោះមានអត្តាធិនភាពហើយ, ញាតិទាំងឡាយនោះអាចនឹងប្ដឹងមេឃុំឲ្យប្រជុំក្រុមប្រឹក្សាញាតិសម្រេចបើកឲ្យក៏បាន ។

បើអនីតិជនជាកូនឥតខាន់ស្លាវិញ, ញាតិទាំងឡាយនោះនឹងសុំឲ្យតុលាការវិនិច្ឆ័យបើកឲ្យក៏បាន ។ ក្នុងករណីនេះតុលាការនឹងសម្រេចបើកឲ្យបានដោយចិត្តឯងក៏បាន ។

**មាត្រា៤៣៦** ៖ បើម្ដាយជាអាណាព្យាបាលលហើយមានប្ដីទៀត, ជនទាំងអម្បាលនោះក៏នៅតែមានសិទ្ធិធ្វើដូច្នោះបានដែរ ។

**មាត្រា ៤៣៧** ៖ ឪពុកម្ដាយ, ដែលបើឲ្យកូនអនីតិជនបានអត្តាធិនភាព, ត្រូវធ្វើសំបុត្របញ្ជាក់ចុះឲ្យច្បាស់ប្រាកដជូនមេឃុំខាងលំនៅនៃអនីតិភាព ។ សំបុត្រនោះត្រូវធ្វើបីច្បាប់គឺមួយច្បាប់ត្រូវប្រគល់ឲ្យកូនអនីតិភាព ហើយច្បាប់ទីបីត្រូវទុកនៅបណ្ណសារដ្ឋាននៃសាលាឃុំ ។

**មាត្រា ៤៣៨** ៖ បើក្រុមប្រឹក្សាញាតិដែលមានមេឃុំ ជាអធិបតីជំនុំព្រមបើកឲ្យកូនអនីតិភាពបានអត្តាធិនភាពហើយ, កំណត់ហេតុនៃការជំនុំដែលមេឃុំត្រូវចុះហត្ថលេខាដែរនោះមានតម្លៃដូចសំបុត្របញ្ជាក់ដែរ ។

អាស្រ័យហេតុនេះមេឃុំ ត្រូវចម្លងសេចក្ដីជំនុំនោះដាក់ក្នុងសៀវភៅនៃសំបុត្របញ្ជាក់ហើយត្រូវចម្លងជាបីច្បាប់ដូចគ្នា គឺប្រគល់ឲ្យអាណាព្យាបាលមួយ

ច្បាប់ឱ្យកូនអនីតិភាពមួយច្បាប់, ជូនទៅសមុហបញ្ជីសាលាដំបូងមួយច្បាប់ ។ ឯកំណត់ហេតុដើមត្រូវទុកនៅបណ្ណសារដ្ឋាននៃសាលាឃុំ ។

**មាត្រា ៤៣៩** ៖ បញ្ជីគណនីដែលអាណាព្យាបាល បានគ្រប់គ្រងមកត្រូវប្រគល់ឱ្យអនីតិជន ដែលបានអត្តាធិនភាពនោះដូចជាជនបានដល់នូវនីតិភាពដូចដែលបានពោលមកហើយដែរ ។

**មាត្រា ៤៤០** ៖ អនីតិជនដែលបានអត្តាធិនភាព អាចបំពេញតែម្នាក់ឯងបាននូវកិច្ចការណា ដែលអាណាព្យាបាលអាចធ្វើបានដោយមិនបាច់មានអនុញ្ញាតពីក្រុមប្រឹក្សាញាតិនោះដែរ ។

**មាត្រា ៤៤១** ៖ អំពីកិច្ចការទាំងពួងណាដែលកាលពីមុនអាណាព្យាបាលរបស់ខ្លួនត្រូវសុំអនុញ្ញាតពីក្រុមប្រឹក្សាញាតិសិនទើបធ្វើបាននោះ, ឥឡូវនេះអនីតិជននឹងធ្វើនូវកិច្ចការទាំងពួងនោះបាន ក៏លុះតែមាន ហិតូបត្ថម្ភកមួយនាក់អមផងដែរ ។

**មាត្រា ៤៤២** ៖ ទី ហិតូបត្ថម្ភក នៃអនីតិជនដែលបានអត្តាធិនភាពនោះត្រូវទុកជាភារៈឪពុក ឬ, បើឥតឪពុក, ត្រូវជាភារៈម្ដាយ ។

**មាត្រា ៤៤៣** ៖ បើអនីតិជនជាកូនមានខាន់ស្លា តែឥតឪពុកម្ដាយ ឬឪពុកម្ដាយ បាត់ខ្លួនក្ដី, ត្រូវគំហាត់ ឬផ្ដ ស់ខ្លួនពីសិទ្ធិមេបាក្ដី ឬ បើឪពុកប្រកែកដោយមានហេតុដែលគួរប្រកែកបានគឺហេតុព្រោះជរា ឬ សុខភាពមិនល្អ ឬ មួយបើម្ដាយប្រកែកមិនព្រមទទួលហិតូបត្ថម្ភកទេ, ក្រុមប្រឹក្សាញាតិត្រូវចាត់ហិតូបត្ថម្ភកមួយនាក់គឺអាណាព្យាបាលដែលទើបនឹងចេញពីមុខការនោះក៏បាន ។

**មាត្រា ៤៤៤** ៖ បើអនីតិជនជាកូនឥតខាន់ស្លាវិញ , តុលាការត្រូវចាត់តាំងហិតូបត្ថម្ភកឲ្យ។

**មាត្រា ៤៤៥** ៖ បើអនីតិជន ខ្ជះខ្ជាយ, បង្ហិនបេតិកភណ្ឌខ្លួន ឬ ចុះកិច្ចសន្យានឹងគេច្រើនហួសខ្នាតពេក, តុលាការអាចហូតអត្តាធិនភាពនេះដោយចិត្តឯងក៏បាន ឬ ហូតតាមបណ្តឹងពីហិតូបត្ថម្ភកក៏បាន ។ ឯខ្លួនអនីតិជននោះត្រូវដាក់ឲ្យនៅក្នុងអាណាព្យាបាលជាថ្មីវិញទៀត ។

**មាត្រា ៤៤៦** ៖ ឯកិច្ចសន្យា ទាំងឡាយណាដែលត្រូវមានហតូបត្ថម្ភកអមផងទើបធ្វើបាន, ហើយជនដែលបានអត្តាធិនភាពធ្វើតែម្នាក់ឯង, កិច្ចសន្យាទាំងនោះត្រូវតុលាការទុកជាមោឃៈ ឬ នឹងបន្ថយខ្លះក៏បាន ។

## ជំពូក ៣
## អំពីអំណាចព្យាបាល លើជនគំហាត់

**មាត្រា ៤៤៧** ៖ គំហាត់ គឺការដែលតុលាការឃាត់ ឬ ដកពីនីតិជនណាម្នាក់នូវសិទ្ធិគ្រប់គ្រងទ្រព្យរបស់ខ្លួន ។

**មាត្រា ៤៤៨** ៖ គំហាត់នេះអាចចេញមកពីសាលក្រមស៊ីវិលក៏មាន, ចេញមកពីទណ្ឌកម្មជាឱក្រិដ្ឋ ដែលនាំឲ្យមានអនុទោសដូចដែលមានសម្តែងក្នុងមាត្រា ៥៥ ក្រមព្រហ្មទណ្ឌក៏មាន ។

### ផ្នែកទី ១
### អំពីគំហាត់ ស៊ីវិល

**មាត្រា ៤៤៩** ៖ នីតិជនទាំងពួង ដែលមានចរិតវិបត្តិជាខ្លាំងព្រោះល្ងីល្ងើ, ឬ ឆ្កួតវង្វេងអាចនឹងត្រូវដកសិទ្ធិគ្រប់គ្រងនូវទ្រព្យរបស់ខ្លួនបាន ។

**មាត្រា ៤៥០** ៖ ជនដែលឆ្កួត ឬល្ងីល្ងើនោះមានតែសាលក្រមស៊ីវិលទេទើបអាចកាត់សេចក្ដីឲ្យហាមឃាត់បាន ។

**មាត្រា ៤៥១** ៖ ពាក្យសុំឲ្យជាឃាត់ហាម នោះត្រូវយកទៅប្ដឹងសាលដំបូងខាងលំនៅនៃជនដែលថាឆ្កួត ឬ ល្ងីល្ងើនោះ ។

**មាត្រា ៤៥២** ៖ ពាក្យប្ដឹងសុំនោះត្រូវធ្វើជាលាយលក្ខអក្សរ ហើយត្រូវសហព័ទ្ធ ឬ ញាតិណាម្នាក់យកពាក្យនោះទៅប្ដឹងក៏បាន, បើគ្មានជនទាំងឡាយនោះទេ, មេឃុំនៃឃុំខាងលំនៅនៃជនត្រូវឃាត់នោះយកទៅប្ដឹងក៏បាន ។

**មាត្រា ៤៥៣** ៖ មុននឹងសម្រេចសេចក្ដី, តុលាការត្រូវបញ្ជាក់ពីភាពមនុស្សដែលគេប្ដឹងសុំឲ្យឃាត់នោះឲ្យឃើញពិតជាយ៉ាងសិន ។

**មាត្រា ៤៥៤** ៖ អាស្រ័យហេតុនេះ, តុលាការត្រូវស៊ើបសួរឲ្យច្បាស់លាស់, ត្រូវបង្គាប់ឲ្យមនុស្សដែលគេថាឆ្កួត, ល្ងីល្ងើនោះចូលមកដើម្បីសាកសួរមើល, ត្រូវទារសំបុត្រស្នាមគ្រប់ចំពូកមកពិនិត្យ, ត្រូវសួរសាក្សីទាំងអស់ហើយត្រូវឲ្យប្ដឹងតាមយថាហេតុដល់ប្រមុខខេត្តសុំឲ្យពេទ្យពិនិត្យហើយចេញកោសលវិច័យស្ដីពីភាពនៃចរិតរបស់សាម៉ីជន។

**មាត្រា ៤៥៥** ៖ ពាក្យសុំឃាត់នោះត្រូវពិនិត្យពិភាក្សាជាការប្រញាប់ ។ សាលក្រមត្រូវឲ្យស្រេចក្នុងខែជាបន្ទាប់នៃខែដែលបានស៊ើបសួរចប់នោះ ។

**មាត្រា ៤៥៦** ៖ បើតុលាការកាត់សេចក្ដីឃាត់ហាមហើយអង្គសេចក្ដីនៃសាលក្រមនោះត្រូវយកទៅប្រកាសឲ្យដំណឹងដល់សាធារណជននៅសាលាដំបូងនិងនៅសាលាឃុំខាងលំនៅនៃជនគំហាតនោះ។

**មាត្រា ៤៥៧** ៖ ជនគំហាត់ ត្រូវទុកដូចជាក្មេងអនីតិភាព ។

**មាត្រា ៤៥៨** ៖ ត្រូវចាត់ចែងឲ្យមានអាណាព្យាបាលតាមទំនង និងវិធាន ដូចគ្នានឹងអនីតិជនដែរ ។

**មាត្រា ៤៥៩** ៖ ប្រពន្ធខាន់ស្លាទី ១ អាចចាត់តាំងឲ្យធ្វើជាអាណាព្យាបាល ប្ដីដែលត្រូវគំហាត់បានដែរ ។

**មាត្រា ៤៦០** ៖ កូនប្រុសនីតិភាពអាចចាត់តាំងឲ្យធ្វើជាអាណាព្យាបាលនៃ ឪពុកដែលត្រូវគំហាត់បានដែរ ។

អំណាចព្យាបាលនោះត្រូវបានទៅកូនដែលបងៗតាមលំដាប់ជេដ្ឋាភាព ។

**មាត្រា ៤៦១** ៖ កូនប្រសារប្រុស, បងប្អូនប្រុសនៃមនុស្សត្រូវគំហាត់អាច ចាត់តាំងឲ្យធ្វើជាអាណាព្យាបាលបានដែរ ។

**មាត្រា ៤៦២** ៖ សេចក្ដីហាមឃាត់នេះនឹងត្រូវលើកលែងវិញតាមទំនង ដូច កាលដែលដាក់នោះដែរ ។

**មាត្រា ៤៦៣** ៖ អាណាព្យាបាលត្រូវថែរក្សាខ្លួនមនុស្សគំហាតនោះ, ជាអា ទិ៍គឺត្រូវវៃក្នុងការត្រួតពិនិត្យកុំឲ្យភាពវិបត្តិនៃមនុស្សនោះបណ្ដាលឲ្យមានព្យាសនៈ កម្មដល់ជនដទៃ ។

**មាត្រា ៤៦៤** ៖ បើបានព្យាបាលមនុស្សគំហាត់គ្រប់ប្រាំឆ្នាំជាប់ៗគ្នាហើយ អាណាព្យាបាលអាចនឹងសុំឈប់ធ្វើជាអាណាព្យាបាលទៀតបាន, លើកលែងតែ ក្នុងករណីដែលអាណាព្យាបាលនោះត្រូវជាសហព័ទ្ធ, ជាបុព្វញាតិមានខាន់ស្លាក្ដី, ឥតខាន់ស្លាក្ដី, សាច់ចិញ្ចឹមក្ដី ឬ បងប្អូនប្រុសនៃជនគំហាត់ ។

**មាត្រា ៤៦៥** ៖ កិច្ចសន្យាទាំងឡាយ ដែលមនុស្សគំហាត់បានធ្វើក្រោយពេលដែលបានបិទផ្សាយនូវសាលក្រមកាត់សេចក្ដីនោះមកត្រូវទុកជាមោឃៈ ។

**មាត្រា ៤៦៦** ៖ អាណាព្យាបាលនៃមនុស្សគំហាត់ ត្រូវមានកាតព្វកិច្ចដូចគ្នានឹងអាណាព្យាបាលនៃអនីតិជនដែរ ។

**មាត្រា ៤៦៧** ៖ អាណាព្យាបាលអាចនឹងចាយវាយនូវទ្រព្យនៃមនុស្សគំហាត់នោះបានលុះណាតែបានគោរពតាមបទបញ្ញត្តិនៃមាត្រា ៤១២ - ៤១៥ ដែរ ។

## ផ្នែកទី ២
## អំពីគំហាត់ព្រហ្មទណ្ឌ

**មាត្រា ៤៦៨** ៖ ទណ្ឌិតនៃទោសឧក្រិដ្ឋកាលបើមានទោសតាមល័ក្ខខណ្ឌដែលមានបញ្ញត្តិក្នុងមាត្រា ៥៥ នៃក្រមព្រហ្មទណ្ឌនោះហើយត្រូវតែដកសិទ្ធិគ្រប់គ្រងទ្រព្យរបស់ខ្លួនចេញ ។

**មាត្រា ៤៦៩** ៖ ទណ្ឌិតអាចរើសជនណាម្នាក់ដែលខ្លួនចង់ឲ្យធ្វើជាអាណាព្យាបាលលើទ្រព្យរបស់ខ្លួនក្នុងវេលាដែលខ្លួនជាប់ទោសបាន ។

**មាត្រា ៤៧០** ៖ បើទណ្ឌិត ពុំបានរើសអ្នកព្យាបាលទេអាជ្ញាធរឃុំត្រូវចាត់តាំងអាណាព្យាបាលឲ្យ ។

**មាត្រា ៤៧១** ៖ ដើម្បីនឹងតាំងអាណាព្យាបាលឲ្យទណ្ឌិតត្រូវគំហាត់, អាជ្ញាធរឃុំត្រូវគោរពតាមបទបញ្ញត្តិដែលស្ដីអំពីការតម្រូវអំណាចព្យាបាលនោះ ។

**មាត្រា ៤៧២** ៖ អំណាចព្យាបាលត្រូវផុតនៅថ្ងៃដែលទណ្ឌិតបានសេរីភាពឡើងវិញ ។

**មាត្រា ៤៧៣** ៖ វិធានទាំងឡាយដែលបញ្ញត្តិពីកាតព្វកិច្ចរបស់អាណាព្យាបាលនៃ អនីតិជនហើយនិងអំពីការកាន់ការប់បតិកភណ្ឌរបស់អនីតិជនដែលនៅក្នុងអាណាព្យាបាលនោះត្រូវយកមកអនុវត្តិក្នុងរឿង ដែលត្រូវទាក់ទងនឹងអំណាចព្យាបាលលើទណ្ឌិតត្រូវគំហាត់នេះដែរ ។

## ផ្នែកទី ៣
## អំពីមុខការហិតូបត្ថម្ភកលើមនុស្សខ្វះខ្វាយ, លើមនុស្សខ្សោយសតិ,លើមនុស្សពិការនិងលើមនុស្សស្រវឹងខ្ជួប

**មាត្រា ៤៧៤** ៖ នីតិជន ដែលមិនឆ្កួតវង្វេង ឬ ល្ងីល្ងើតែជាមនុស្សចាយវាយខ្ជះខ្ជាយក្រៅតម្រាពេក ឬ មានសតិទន់ខ្សោយ, ថ្លង់, គ, ងងុល, ខ្វិន ឬ ជរា, ឬ ជាអ្នកប្រមឹកអ្នកញៀនអាភានក៏អាចឲ្យតុលាការស៊ីវិល ខាងលំនៅខ្លួនកាត់សេចក្តីឲ្យខ្លួនមានហិតូបត្ថម្ភកបានដែរ ។

**មាត្រា ៤៧៥** ៖ តុលាការត្រូវចាត់តាំងហិតូបត្ថម្ភកតាមវិធានដែលមានសំដែងក្នុងផ្នែកទី ១ ចំពូក៣ មាតិកា ៥ គន្ថីបុគ្គល ។

**មាត្រា ៤៧៦** ៖ ហិតូបត្ថម្ភក របស់អនីតិជនអ្នកបានអត្តាធិនភាពនោះត្រូវទំនុកបំរុងដល់ជននោះដោយប្រការយ៉ាងណា, ហិតូបត្ថម្ភកនៃជនដែលចាយវាយខ្ជះខ្ជាយ, ជនប្រមឹក ឬ ជនពិការក៏ត្រូវទំនុកបំរុងជននោះដោយប្រការយ៉ាងនោះដែរ ។

# មាតិកាទី ៦
# អំពីសិទ្ធិ និងកាតព្វកិច្ច ទាំងឡាយលើបេតិកភណ្ឌក្នុងគ្រួសារ

**មាត្រា ៤៧៧** ៖ ចំណងរវាងសមាជិក ទាំងឡាយក្នុងគ្រួសារមួយជាមួយគ្នាធ្វើឱ្យសមាជិកនោះមានសិទ្ធិ និង កាតព្វកិច្ច លើបេតិកភណ្ឌដល់គ្នានឹងគ្នាទៅវិញទៅមក ។

សិទ្ធិ និង កាតព្វកិច្ចទាំងនោះកកើតឡើងក្នុងពេលដែលជនអ្នកនៅក្រោមសិទ្ធិ និង កាតព្វកិច្ចទាំងឡាយនោះមានជីវិតរស់នៅក៏មាន ក្នុងវេលាដែលជនទាំងនោះស្លាប់ទៅក៏មាន ។

សិទ្ធិ និងកាតព្វកិច្ច លើបេតិកភណ្ឌ ដែលកើតឡើងក្នុងវេលារស់នៅហៅថា អាហារកាតព្វកិច្ច សិទ្ធិ និងកាតព្វកិច្ច ដែលកើតឡើងក្នុងវេលាមរណៈហៅថា សន្តតិកម្ម ឬ មត៌ក ។

## ចំពូក ១ អំពីអាហារកាតព្វកិច្ច

**មាត្រា ៤៧៨** ៖ ដែលហៅថា អាហារកាតព្វកិច្ច នោះគឺ ករណីយកិច្ចដែលជនម្នាក់ត្រូវផ្គត់ផ្គង់ដល់ជនម្នាក់ទៀតនូវជីវព្រឹត្តគឺ ចំណី, អាហារទីស្នាក់អាស្រ័យ និងការថែរទាំ ។

**មាត្រា ៤៧៩** ៖ អាហារកាតព្វកិច្ចរវាងប្ដី និងប្រពន្ធ ទៅវិញទៅមកកើតមកពីបទបញ្ញត្តិនៃមាត្រា១៨៣, អាហារកាតព្វកិច្ចចំពោះអនីតិជនទាំងឡាយកើតមកពីបញ្ញត្តិនៃមាត្រា៣៥៦ ។ ប្ដីប្រពន្ធកាលមិនទាន់បំពេញនូវកាតព្វកិច្ចនោះដល់

គ្នា និងគ្នាទេ ,ក៏នឹងនាំឱ្យរលាយអាពាហ៍ពិពាហ៍ដោយលែងលះឪពុកម្ដាយ , អាណាព្យាបាល, កាលមិនបំពេញនូវកាតព្វកិច្ចខ្លួនដល់អនីតិជនទេ, ក៏នឹងនាំឱ្យផ្ដស់អំណាចមេបាបង់ ។

**មាត្រា ៤៨០** ៖ កូនទាំងឡាយ,នាកាលមានវ័យល្មមធ្វើការចិញ្ចឹមជីវិតបានត្រូវផ្គត់ផ្គង់នូវជីវព្រឹត្តិដល់ឪពុកម្ដាយ ឬ ដល់បុព្វញាតិឯទៀតដែលទ័លក្រ ។

**មាត្រា ៤៨១** ៖ កូនប្រសារប្រុសស្រី ទាំងឡាយក៏ត្រូវផ្គត់ផ្គង់នូវជីវព្រឹត្តិដល់ឪពុកក្មេក និងបុព្វញាតិក្មេកឯទៀតដែរ ។ ប៉ុន្តែបើជនដែលត្រូវទទួលសោធននោះរៀបការជាថ្មីទៀត ឬ បើកូនប្រសារនោះស្លាប់ប្ដី ឬ ប្រពន្ធទាំងកូនអស់ទៅកាតព្វកិច្ចនោះក៏ត្រូវផុតដែរ ។

**មាត្រា ៤៨២** ៖ បើឥតពីឪពុកម្ដាយទៅ ត្រូវបងប្អូនប្រុសស្រី ,បើឥតពីបងប្អូនប្រុសស្រីទៅត្រូវបុព្វញាតិ ,បើឥតពីបុព្វញាតិទៅត្រូវឪពុកក្មេក ម្ដាយក្មេកទាំងឡាយផ្គត់ផ្គង់ជីវព្រឹត្តិដល់បងប្អូន ប្រុសស្រី បច្ឆាញាតិ កូនប្រសារប្រុសស្រីរបស់ខ្លួនប្រសិនបើជនទាំងឡាយនោះពិការ ឬ រកស៊ីចិញ្ចឹមជីវិតខ្លួនឯងពុំកើតមែនទែន ។

**មាត្រា ៤៨៣** ៖ សោធន ត្រូវគិតឱ្យសមគួរតាមសេចក្ដីត្រូវការនៃជនដែលត្រូវការ និងសមគួរដល់ធនធាននៃអ្នកដែលត្រូវផ្ដល់ផង ។

បើជនដែលត្រូវផ្ដល់សោធន នោះប្ដឹងថា ខ្លួនទ័លណាស់ នឹងផ្ដល់ទៀតពុំបានទេ កាលមានបន្ទាល់ច្បាស់ថាទ័លមែន តុលាការអាចនឹងកាត់សេចក្ដីឱ្យជននោះយកមនុស្សដែលខ្លួនត្រូវផ្ដល់សោធននោះទៅចិញ្ចឹមបីបាច់ថែរក្សាបាន ។

**មាត្រា ៤៨៤** ៖ នាកាលជនដែលអាចផ្តល់សោធនបានហើយ ត្រឡប់ជាទ័លផ្តល់លែងបានទាំងអស់ ឬ ភាគខ្វះវិញ ឬ ជនដែលត្រូវទទួលសោធននោះត្រឡប់ជាលែងត្រូវការទាំងអស់ ឬ ខ្វះភាគវិញជនទាំងនេះអាចនឹងសុំឱ្យលើកកាតព្វកិច្ចនេះ ឬ បន្ថយចំនួនខ្វះបាន ។

**មាត្រា ៤៨៥** ៖ នាកាលសោធន នោះគឺជនជាញាតិច្រើននាក់ក្នុងថ្នាក់ជាមួយគ្នាត្រូវផ្តល់ជនជាញាតិទាំងនោះ ត្រូវជួយគ្នាផ្តល់សោធនក្នុងម្នាក់ៗតាមសមាត្រនៃកម្លាំងរៀងខ្លួន។

បើសម្បត្តិនៃជនដែលត្រូវផ្តល់សោធននោះមិនល្មម នឹងផ្តល់ឱ្យខានចង្អៀតចង្អល់ ដល់ខ្លួនឯងខ្លាំងឡើងៗ មិនបានទេ តុលាការអាចនឹងបង្គាប់ឱ្យញាតិឯទៀតបណ្តាញាតិទាំងឡាយដែលមានរាប់នាមក្នុងមាត្រា៤៨០,៤៨១,៤៨២នោះ, ជួយផ្តល់សោធនតាមសមាមាត្រតិចច្រើនជាកំណត់បាន ។

## ចំពូក ២

## បទបញ្ញត្តិទូទៅស្តីពីសន្តតិកម្ម ( មត៌ក )

**មាត្រា ៤៨៦** ៖ ដែលហៅថា សន្តតិកម្ម នោះ គឺការផ្ទេរនូវបេតិភណ្ឌ នៃបុគ្គលណាម្នាក់ដែលស្លាប់ឱ្យទៅជនម្នាក់ ឬ ច្រើននាក់ដែលហៅថា ទាយាទ ឬ សន្តតិជន ។

សន្តតិកម្ម ត្រូវផ្ទេរតាមច្បាប់ ឬ តាមឆន្ទៈរបស់ខ្មោច ។ សន្តតិកម្មដែលផ្ទេរតាមច្បាប់ហៅថា សន្តតិកម្ម ឥតបណ្តាំសន្តតិកម្មដែលផ្ទេរតាមឆន្ទៈខ្មោច ហៅថា សន្តតិកម្មមានបណ្តាំ ។

**មាត្រា ៤៨៧** ៖ សន្តតិកម្មត្រូវចាប់ចែក នៅថ្ងៃដែលខ្មោចនោះស្លាប់ និងនៅទីដែលជាលំនៅក្រោយបង្អស់របស់ខ្មោច ។

**មាត្រា ៤៨៨** ៖ ជនដែលអាចទទួលសន្តតិកម្មបាននោះគឺ មនុស្សដែលមានជីវិតរស់នៅមានសមត្ថភាព និង មិនទាន់កាត់កាលថាជាអភព្វបុគ្គលទេ ។

ទារកដែលនៅក្នុងគ៌ភនៅឡើយ បើកើតក្នុងរវាង ៣០០ថ្ងៃ គិតតាំងពីថ្ងៃដែលខ្មោចនោះស្លាប់មក ហើយរស់អាចទទួលនូវសន្តតិកម្មបាន ។

**មាត្រា ៤៨៩** ៖ ទណ្ឌិតដែលមានទោសត្រូវប្រហារជីវិតបង់ , មានទោសឧក្រិដ្ឋអស់មួយជីវិត , ត្រូវទុកជាជនដែលគ្មានសមត្ថភាព និងទទួលបានឡើយ ។ ឯទណ្ឌិតនេះ បើបានទទួលនូវព្រះរាជអភ័យ ឬ នូវការលើកទោស ឬ ការប្តូរទោសណាមួយហើយ, នឹងមានសមត្ថភាពឡើងវិញ ។

សន្តតិកម្មឥតបណ្តាំ ឯណាដែលត្រូវបានទៅទណ្ឌិតដែលត្រូវទោសប្រហារជីវិតបង់ ឬ ទោសឧក្រិដ្ឋអស់មួយជីវិត ,សន្តតិកម្មនោះត្រូវធ្លាក់ទៅបច្ឆាញាតិនៃជននោះទទួលជួស ។

**មាត្រា ៤៩០** ៖ តុលាការអាចកាត់សេចក្តីទុកជន ទាំងឡាយដូចខាងក្រោមនេះជាអភ័ព្វបុគ្គល ដែលគប្បីឱ្យទទួលនូវសន្តតិកម្ម ( មត៌ក ) ឡើយ ៖

១. ជនដែលបានព្យាបាទដល់ជីវិតនៃខ្មោច កាលនៅរស់, ទោះធ្វើជាមេគេក្តី ,ជាសហចារីក្តី ឬ គ្រាន់តែសមគំនិតក្តី ។

២. ជន, ដែលមានអាយុច្រើនជាង ១៦ ឆ្នាំ បានស្គាល់ឃាតកជនដែលសម្លាប់ខ្មោចហើយ, ព្រងើយកន្តើយពុំប្តឹងតុលាការ ។

៣. ជនដែលប្ដឹងបង្កាច់ទោសពីខ្មោចឱ្យខ្មោចត្រូវឧក្រិដ្ឋទោស ឬ ទោសគុកជាមជ្ឈឹមប្រសិនបើមែន ។

៤. ជនដែលអាចមកបាន ហើយមិនមកថែរក្សា ដុសថ្នាំ ទ្រាំជម្ងឺនៅវេលាដែលខ្មោចនោះមានជម្ងឺឈឺ លើកក្រោយបំផុតដែលខ្លួនបានដឹងដែរ ។

៥. ជន, ដែលនៅជិតខាងដែលខ្មោចនោះស្លាប់ ,អាចមកបានហើយ មិនមកជួយលើកខ្មោចស្រោចផ្អឹងដោយឥតហេតុគប្បីឱ្យមាន ។

៦. មនុស្សដែលខ្មោចបានបណ្ដេញឱ្យចេញពីផ្ទះ ព្រោះអកត្តញ្ញូតា , ព្រោះមិនមានសេចក្ដីគោរព (Irreverence) ព្រោះទុរាចារ ( Inconduite ) ឬព្រោះហេតុដទៃទៀត ហើយមិនបានមកសុំខមាទោសខ្មោចមុនពេលដែលស្លាប់ ។

តុលាការ នឹងកាត់សេចក្ដីឱ្យកាត់កាល់យ៉ាងនេះបានលុះណាដែលមានជនណាម្នាក់ដែលមានប្រយោជន៍ក្នុងរឿងនេះបានប្ដឹងផង ។

**មាត្រា ៤៩១** ៖ ជនអភ័ព្វនេះត្រូវសន្មត់ថា មិនបានទទួលនូវសន្តតិកម្មសោះ ។ សន្តតិកម្មដែលត្រូវបានមកជននោះ ត្រូវធ្លាក់ទៅលើជនទាំងឡាយដែលត្រូវបានសន្តតិកម្មនោះទាំងអស់ ប្រសិនបើជន អភ័ព្វនោះមិនបានរស់នៅក្នុងវេលាដែលខ្មោចធ្វើមរណៈកាលទេ ក៏ប៉ុន្តែ កូនមានខាន់ស្លា ដែលកើតពីជនអភ័ព្វនោះក្នុងរវាង ៣០០ ថ្ងៃក្រោយថ្ងៃស្លាប់នៃជនអភ័ព្វនោះ ហើយរស់ត្រូវស៊ុមត៏កឪពុកវាបាន ។

សន្តតិជនដែលត្រូវកាត់កាល ហើយត្រូវបង្វិលចំណែកសន្តតិកម្មដែលខ្លួន

បានទទួលរួចហើយព្រមទាំងផល និងផលទុនដែលខ្លួនបានរហូតមកតាំងពីថ្ងៃដែលចែកសន្តតិកម្មនោះវិញ ។

**មាត្រា ៤៩២** ៖ ជនអភ័ព្វអាចនឹងកាន់កាប់ថែរក្សានូវសន្តតិកម្មដែលបានទៅកូនដែលនៅក្នុងអនីតិភាពបាន ។

## ចំពូកទី ៣

## អំពីសន្តតិកម្មឥតបណ្តាំ

### ផ្នែកទី ១

### អំពីលំដាប់នៃការផ្ទេរន្តវសន្តតិកម្ម

**មាត្រា ៤៩៣** ៖ សន្តតិកម្មឥតបណ្តាំត្រូវផ្ទេរទៅឱ្យកូននៃខ្មោច កូនទាំងនោះត្រូវចូលមកទទួលចំណែកនៃមត៌កនោះដោយភាគស្មើ ទោះកូននោះមានខាន់ស្លាក្តី កូនដែលទើបនឹងបានធម្មានុរូបភាពក្តី ,កូនសុំក្តី ,កូនឥតខាន់ស្លាក្តីតែតុលាការកាត់ឱ្យទទួលស្គាល់ក្តី , ឬ ដែលទទួលពីចិត្តឯងក្តី ។

បើកូននោះស្លាប់ កូនទាំងឡាយនៃខ្មោចនោះត្រូវចូលមក ទទួលមត៌កជាមួយនឹងមាមីងរបស់ខ្លួនជួសឪពុកម្តាយខ្លួន ហើយចែកភាគនោះដល់បងប្អូនខ្លួនជួសឪពុកម្តាយខ្លួនហើយចែកភាគនោះដល់បងប្អូនខ្លួនស្មើៗគ្នាទៀត ប្រសិនបើកូនទាំងឡាយរស់នៅក្នុងគ្រាដែលចែកសន្តតិកម្ម ។

**មាត្រា ៤៩៤** ៖ បើខ្មោចនោះគ្មានកូនទេ សន្តតិកម្មត្រូវបានទៅឪពុកម្តាយនៃខ្មោច។ បើឪពុកម្តាយនោះ នៅដោយខ្លួនពីគ្នាសន្តតិកម្មត្រូវចែកពាក់កណ្តាលម្នាក់ស្មើគ្នា ។

បណ្តាជនទាំងពីរនាក់នេះបើម្នាក់បានធ្វើកាលកិរិយា ហើយអ្នករស់នៅត្រូវទទួលសន្តតិកម្មទាំងអស់នោះតែម្នាក់ឯង ។

បើឪពុកជាជនបរទេស ហើយទទួលមត៌ក ជាអចលនវត្ថុដែលជាប់នៅលើដីរបស់ខ្មែរ ឪពុកនោះអាចនឹងទទួលមត៌កនោះបានលុះណាតែខ្លួនបានសញ្ជាតិតូបនីយកម្មហើយ ។ បើមិនទាន់បាន សញ្ជាតិតូបនីយកម្មទេ ការផ្ទេរសន្តតិកម្មនេះត្រូវធ្វើតាមបញ្ញត្តិនៃក្រមនេះ ។

**មាត្រា ៤៩៥** ៖ បើខ្មោចនោះឥតកូន ឥតឪពុក ឥតម្តាយទេ សន្តតិកម្មនោះត្រូវចែងជាពីរភាគគឺមួយភាគត្រូវបានទៅបុព្វញាតិខាងម្តាយ ។

បុព្វញាតិណាជិតជាងគេ ត្រូវយកភាគពាក់កណ្តាលដែលត្រូវធ្លាក់ទៅជួរខ្លួនតែបើប្តីប្រពន្ធនៅបែកគ្នាត្រូវចែក តាមសេចក្តីបញ្ញាតិនៃមាត្រាមុនថែមទៀត ។ បើមានបុព្វញាតិម្នាក់ៗត្រូវបានភាគស្មើគ្នាដែរ។

**មាត្រា ៤៩៦** ៖ បើខ្មោចនោះឥតកូនចៅ ឥតបុព្វញាតិទេសន្តតិកម្មត្រូវបានទៅបានទៅបងប្អូនប្រុសស្រី ដោយភាគស្មើ , នេះចំពោះតែបងប្អូន នោះមានឪពុកម្តាយជាមួយគ្នា ។ ប្រសិនបើ ជាបងប្អូន ឪពុក ឬ ម្តាយទីទៃពីគ្នាទេ , បងប្អូនរួមឪពុកម្តាយជាមួយត្រូវបានពីរភាគ , បងប្អូនរួមឪពុកម្តាយមួយ ត្រូវបានពីរភាគ, បងប្អូនរួមតែឪពុក ឬ ម្តាយត្រូវបានមួយភាគម្នាក់ ។ បើបងប្អូន ដែលទទួលនោះស្លាប់ ត្រូវកូនចូលមកទទួលជាមួយនឹងមាមីងរបស់ខ្លួនជួសឪពុកម្តាយខ្លួន ហើយចែកភាគនោះដល់បងប្អូនខ្លួនស្មើៗគ្នាទៀត ប្រសិនបើខ្លួនរស់នៅទាំងអស់ក្នុងគ្រាដែលចែកសន្តតិកម្មនោះ ។

**មាត្រា ៤៩៧** ៖ បើខ្មោចនោះឥតបុព្វញាតិ ឥតបងប្អូន ឥតកូន ឥតបច្ឆាញាតិដែលកើតពីខ្លួនទេ សន្តតិកម្មត្រូវបានទៅប្រពន្ធដើមមានខាន់ស្លា ដែលរស់នៅហើយដែលមិនបានលែងគ្នា ។

**មាត្រា ៤៩៨** ៖ បើប្តីដែលស្លាប់នោះឥតបុព្វញាតិ ឥតបងប្អូនប្រុសស្រី ឥតបច្ឆាញាតិនៃបងប្អូន ឥតប្រពន្ធដើម ឯក្រោយទេ សន្តតិកម្មនៃខ្មោចនោះត្រូវបានទៅប្រពន្ធចុងទាំងឡាយដែលមានខាន់ស្លា ហើយដែលមិនបានលែងគ្នា ដោយភាគស្មើគ្នា ។

**មាត្រា ៤៩៩** ៖ បើប្រពន្ធចុងស្លាប់ឥតកូនចៅ ឥតបុព្វញាតិ ឥតបងប្អូនប្រុសស្រី ឥតបច្ឆាញាតិនៃជនទាំងនេះ សន្តតិកម្មត្រូវបានទៅប្តីដែលមិនបានលែងគ្នា ។

**មាត្រា ៥០០** ៖ បើសហព័ទ្ធណាមុននឹងស្លាប់ បានប្តឹងលែងសហព័ទ្ធដែលនៅរស់ ពាក្យបណ្តឹងនេះត្រូវមានអានុភាពដូចជាបានលែងគ្នាដែរ ប្រសិនបើអ្នកដែលមានប្រយោជន៍ក្នុងរឿងនេះសុំតក្តី ហើយតុលាការ កាលជំនុំជំរះទៅ ក៏បានទុកពាក្យដែលប្តឹង សុំលែងនោះថា ជាត្រូវដែរ ។

**មាត្រា ៥០១** ៖ បើខ្មោចនោះឥតកូនចៅ ឥតបុព្វញាតិ ឥតបងប្អូនប្រុសស្រីឥត បច្ឆាញាតិរបស់បងប្អូន ឥតប្រពន្ធដើម ប្រពន្ធសោះទេ សន្តតិកម្មត្រូវបានទៅមាមីងគឺបងប្អូនមានខាន់ស្លា ឥតខាន់ស្លា ឬ សុំនៃឪពុកម្តាយនៃខ្មោចនោះ ។

ក្នុងករណីនេះបេតិកភ័ណ្ឌត្រូវចែកតាមចំនួនមនុស្សកុំបីចែកតាមសាខាឡើយ ។

**មាត្រា ៥០២** ៖ បើឪពុកម្ដាយ មានបងប្អូនបង្កើតផង បងប្អូនរួមតែឪពុក ឬ តែម្ដាយរួមផង , បងប្អូនរួមតែម្ដាយ ឬ រួមតែឪពុកត្រូវបានក្នុងម្នាក់ៗតែពាក់កណ្ដាល ចំណែកដែលត្រូវបានទៅបងប្អូនបង្កើត ។

បើបងប្អូន នៃឪពុកម្ដាយរបស់ខ្មោច ( គឺមាមីងរបស់ខ្មោច ) នោះស្លាប់ទៅទៀត , កូននៃមាមីង នោះចូលមកទទួលមត៌កជួសឪពុកម្ដាយខ្លួន តាមចំណែកដែលត្រូវបានទៅឪពុកម្ដាយរាល់ខ្លួនប្រសិនបើកូនទាំងនោះមានជីវិតរស់នៅដូចគេដែរ ។

**មាត្រា ៥០៣** ៖ បើខ្មោចនោះស្លាប់ ឥតកូនចៅ ឥតបុព្វញាតិ ឥតបងប្អូនប្រុសស្រី ឥតបច្ឆាញាតិរបស់បងប្អូន ឥតប្រពន្ធដើម ឥតប្រពន្ធចុង ឥតមាមីង ឥតបងប្អូនជីដូនមួយបង្កើត សន្តតិកម្មនោះត្រូវធ្លាក់ទៅលើរដ្ឋ ។

## ផ្នែកទី ២
## អំពីសិទ្ធិនៃសហព័ទ្ធដែលនៅរស់

**មាត្រា ៥០៤** ៖ បើខ្មោចនោះស្លាប់ទៅនៅតែសហព័ទ្ធ មានខាន់ស្លាទីមួយ ដែលឥតបានលែងគ្នាទេ និងកូនម្នាក់ ឬ ច្រើនាក់ ដែលកើតអំពីប្ដី និង ប្រពន្ធនោះនៅនឹងផ្ទះនោះដែរ បេតិកភ័ណ្ឌទាំងប៉ុន្មានត្រូវដាក់ឱ្យសហព័ទ្ធ នោះគ្រប់គ្រងថែរក្សាប្រើប្រាស់ជាប្រយោជន៍គ្រួសារ ។

**មាត្រា ៥០៥** ៖ កូនដែលមានប្ដីប្រពន្ធ ហើយបានសិទ្ធិទារចំណែក នៃសន្តតិកម្មរបស់សហព័ទ្ធ ដែលស្លាប់មុននោះ ឪពុក ឬ ម្ដាយដែលរស់នៅបាន ។

## កថាខណ្ឌទី ១
## សិទ្ធិនៃប្រពន្ធមានខាន់ស្លាទីមួយដែលជាមេផ្ទះ

**មាត្រា ៥០៦** ៖ បើប្ដីស្លាប់មុន, ប្រពន្ធដើមមិនអាចនឹងលក់ដូរ ឬ ចាយវាយដោយប្រាតិភោគប្រត្យ័ក្សនូវអចលនវត្ថុនៃសន្តតិកម្ម ដោយឥតសុំអនុញ្ញាតិពីក្រុមប្រឹក្សាញាតិឱ្យគេពិនិត្យពីសេចក្ដីត្រូវការនៃសន្តតិកម្មនោះបានឡើយ។ ប្រពន្ធដើមបរិភោគផល និងផលទុនបាន។

**មាត្រា ៥០៧** ៖ ប្រពន្ធដើមអាចប្រកែកមិនទទួលសិទ្ធិគ្រប់គ្រង និងបរិភោគនូវបេតិកភណ្ឌរបស់គ្រួសារបាន ។

**មាត្រា ៥០៨** ៖ បើប្រពន្ធដើមនោះមានប្ដីទៀត ,មានប្រុសសាហាយ ឬ មានគំនិតមារយាទអាក្រក់, នោះត្រូវផ្ដស់ខ្លួនបាត់សិទ្ធិនេះ។

**មាត្រា ៥០៩** ៖ អ្នកដែលអាចប្ដឹងសុំឱ្យផ្ដស់សិទ្ធិខាងលើនេះបាន គឺបុព្វញាតិ ឬ បងប្អូននៃប្ដីដែលមាននីតិភាព , កូនប្រុសច្បងដែលមាននីតិភាព, ប្ដីនៃកូនស្រីច្បង, ក្រុមប្រឹក្សាញាតិ។

ឯកូនដែលនៅក្នុងនីតិភាពនោះ ត្រូវតែមានអាណាព្យាបាលតាមបទបញ្ញតិនៃចំពូក ១ ភាគទី ៥ គន្ថីបុគ្គល ។

**មាត្រា ៥១០** ៖ បើប្រពន្ធដើម មានខាន់ស្លា លះបង់សិទ្ធិរបស់ខ្លួន ឬ ត្រូវតុលាការជម្លោះសិទ្ធិគ្រប់គ្រងនោះ,ស្ត្រីនេះត្រូវយកបានតែទ្រព្យដើមរបស់ខ្លួន គឺទ្រព្យដែលខ្លួនមានកាលរៀបការ ឬ ទ្រព្យជាមត៌ក,ជាអំណោយ ឬ ជាអច្ច័យទានដែលបានមកស្ត្រីនោះផ្ទាល់ខ្លួនក្នុងពេលដែលមានអាពាហ៍ពិពាហ៍ ។

ក្នុងករណីដែលទ្រព្យដើមរបស់ខ្លួនបាត់បង់អស់ទៅ, ស្ត្រីនោះត្រូវចាត់យកក្នុង មត៌កត្រឹមតែតម្លៃទ្រព្យខ្លួនវិញ ។

**មាត្រា ៥១១** ៖ បើប្រពន្ធដើមមានខាន់ស្លា ដែលប្រកបព្រមដោយល័ក្ខខ័ណ្ឌដូចដែលមានបញ្ញត្តិក្នុងមាត្រា ៥០៧ នោះទើបគប្បីឱ្យបានអាហារសោធន ។ ថាបើមាន មារយាទស្រីនោះចូលក្នុងល័ក្ខខ័ណ្ឌនៃមាត្រា ៥០៨ ទេ ,ស្ត្រីនោះមិនត្រូវបានអាហារសោធនឡើយ។

## កថាខណ្ឌទី ២
## អំពីសិទ្ធិនៃប្រពន្ធដើមមានខាន់ស្លាដែលអារឥតកូន

**មាត្រា ៥១៣** ៖ ស្ត្រីមេម៉ាយ ជាប្រពន្ធដើមមានខាន់ស្លាដែលនៅរស់តែអារឥតកូននោះមិនមានសិទ្ធិគ្រប់គ្រង និងបរិភោគ នូវបេតិកភណ្ឌរបស់គ្រួសារ ។

**មាត្រា ៥១៤** ៖ ក្នុងករណីនេះ, ប្រពន្ធដើមមានខាន់ស្លាដែលមេម៉ាយ អារឥតកូននោះត្រូវបានមួយភាគបីនៃទ្រព្យសំបាច់ក្រៅពីទ្រព្យដើមរបស់ខ្លួន ។

**មាត្រា ៥១៥** ៖ ទោះប្រពន្ធនោះមានគំនិតមារយាទ អាក្រក់ក្តី ,មានប្តីទៀតក្តីក៏មិនត្រូវខូចសិទ្ធិដែលត្រូវបានចំណែកក្នុងមត៌កដែលខ្លួនត្រូវតែបាននោះឡើយ។

**មាត្រា ៥១៦** ៖ បណ្តឹងដែលប្តីបានប្តឹង សុំលែងប្រពន្ធកាលខ្លួននៅរស់នៅឡើយនោះនឹងនាំ ឱ្យខូចសិទ្ធិនៃស្រីនោះបាន លុះណាតែបណ្តឹងនោះមានអាងហេតុថាប្រពន្ធនោះផិតក្បត់។ ក្នុងករណីនេះ, ទើបស្រីនោះត្រូវបាត់សិទ្ធិដែលត្រូវបានទ្រព្យចាំបាច់ ។

**មាត្រា ៥១៧** ៖ បទបញ្ញត្តិនៃមាត្រា ៥០៧,៥០៨,៥១០,៥១១,៥១២ ត្រូវអនុវត្តលើប្រពន្ធដើមមានខាន់ស្លាដែលមេម៉ាយអារតតកូនដែរ ។

## កថាខណ្ឌទី ៣
## អំពីសិទ្ធិ នៃប្រពន្ធចុងមានខាន់ស្លា

**មាត្រា ៥១៨** ៖ ក្នុងវេលាដែលប្តីស្លាប់ទៅហើយ ប្រពន្ធដើមរស់នៅ, ប្រពន្ធចុងទាំងប៉ុន្មាន ព្រមទាំងកូនរបស់ខ្លួនរៀងៗខ្លួនអាចនៅនឹងផ្ទះនៃគ្រួសារក្រោមអំណាចនៃប្រពន្ធដើមបានប្រសិនបើ ប្រពន្ធចុងក៏សុខចិត្ត ហើយប្រពន្ធដើមក៏ឥតទទឹងទាស់ដែរ។ បើនៅជាមួយគ្នា ដូច្នេះប្រពន្ធចុងទាំងអស់នោះ ត្រូវមានសិទ្ធិនិងករណីយកិច្ចទាំងឡាយដូចកាលប្តីរស់នៅនោះដែរ ។

**មាត្រា ៥១៩** ៖ បើប្រពន្ធមិនឱ្យប្រពន្ធចុង នៅជាមួយផងទេ ឬ បើប្រពន្ធចុងមិនព្រមនៅនឹងផ្ទះក្រោមអំណាចប្រពន្ធដើមទេ ប្រពន្ធចុងត្រូវបានតែគ្រឿងប្រដាប់សម្រាប់ខ្លួន ហើយនឹងទ្រព្យដើមខ្លួនព្រមទាំងបានសោធនរាល់ខែដើម្បីចិញ្ចឹមជីវិតខ្លួន និងកូនអនីតិភាពទាំងឡាយនៃខ្លួនដែលកើតក្នុងអាពាហ៍ពិពាហ៍ជាមួយខ្មោចប្តីនោះ ។

**មាត្រា ៥២០** ៖ ប្រពន្ធចុងណាមានប្តីទៀត ឬ មានសាហាយ ឬ មានគំនិត មាយាទអាក្រក់ប្រពន្ធចុងនោះត្រូវខានបានសោធនចំណែកខ្លួន ហើយសោធនមួយភាគទៀតបានដើម្បីចិញ្ចឹមកូននោះប្រសិនបើគេទុកអំណាចអាណាព្យាបាលនៃកូននោះឱ្យប្រពន្ធចុងនោះតទៅទៀត ។

**មាត្រា ៥២១** ៖ ដែលនឹងប្ដឹងសុំឱ្យលុបសោធន នេះប្រពន្ធដើម ឬ ជនណាមួយ បណ្ដាជនដែលមានសំដែងក្នុងមាត្រា ៥០៩នោះប្ដឹងបានជាដរាប ។

**មាត្រា ៥២២** ៖ បើប្រពន្ធដើមត្រូវបណ្ដេញចេញ ចាកសិទ្ធិគ្រប់គ្រងនិងបរិភោគបេតិកភណ្ឌនៃគ្រួសារ ព្រោះអាឥតកូនក្ដី ព្រោះតុលាការកាត់សេចក្ដីឲ្យប្រាស់ចាកសិទ្ធិនោះក្ដី ឬ មិនព្រមទទួលសិទ្ធិនោះក្ដី ប្រពន្ធចុងមានខាន់ស្លាទាំងឡាយត្រូវដកយកទ្រព្យដើម និងគ្រឿងប្រដាប់ជារបស់ខ្លួនវិញហើយ ត្រូវទទួលព្យាបាលនូវទ្រព្យសម្បត្តិជាចំណែកនៃមត៌កដែលត្រូវបានកូនអនីតិភាពរបស់ខ្លួនរៀងៗខ្លួន ។

## ជំពូក ៤
## អំពីសន្តតិកម្មមានបណ្ដាំ
### ផ្នែកទី ១
### បទបញ្ញត្តិទូទៅ

**មាត្រា ៥២៣** ៖ ដែលហៅថា បណ្ដាំ ឬ មតកសាសន៍គឺសេចក្ដីដែលមនុស្សម្នាក់ ហៅថា ម្ចាស់បណ្ដាំសំដែងនូវឆន្ទៈណាមួយរបស់ខ្លួនដើម្បីឱ្យគេយកទៅប្រតិបត្តិក្រោយពេលខ្លួនស្លាប់ទៅ ។

**មាត្រា ៥២៤** ៖ បណ្ដាំអាចត្រូវបានបដិសេធបានជាដរាប ។

**មាត្រា ៥២៥** ៖ ម្ចាស់បណ្ដាំអាចតាំងអាណាព្យាបាលឱ្យកូនអនីតិភាពរបស់ខ្លួនអាចបង្គាប់ឱ្យធ្វើបុណ្យសពនៃខ្លួន អាចចាត់ចែងនូវទ្រព្យសម្បត្តិរបស់ខ្លួនទាំងអស់ ឬ ខ្លះបាននិងអាច , បើពោលឱ្យវែងឆ្ងាយទៅទៀតជាក់ច្បាប់ ឱ្យដំបូន្មាន

ឬ យោបល់យ៉ាងណាដែលខ្លួនយល់ឃើញថាជាឱសថសក្តិសិទ្ធិអាចធ្វើឱ្យក្រាន របស់ខ្លួនបានសុខដុមរមនា និងបានវឌ្ឍនាកាលដល់គ្រួសារផង ។

**មាត្រា ៥២៦** ៖ សេចក្តីបណ្តាំដែលបានធ្វើជាត្រឹមត្រូវ ត្រូវទុកជាច្បាប់ ដែលត្រូវតែសមាជិកទាំងអស់នៃគ្រួសារគោរពតាម ។

**មាត្រា ៥២៧** ៖ បណ្តាំឯណាដែលផ្តាំឱ្យចែក ទ្រព្យសម្បត្តិបណ្តាំ នោះឱ្យ ហៅថា អច្ច័យទាន ជនដែលត្រូវបានអច្ច័យទាននោះហៅថា អច្ច័យលាភី ។

**មាត្រា ៥២៨** ៖ ដែលហៅថា ភាគបំរុង នោះគឺភាគមួយនៃបេតិកភណ្ឌ ដែលម្ចាស់បណ្តាំខ្លួនឯងក៏មិនអាចនឹងចាត់ចែងយ៉ាងណាៗ ដោយសេរីបានឡើយ ឯភាគដ៏សេសពីភាគបំរុង ហៅថា ភាគទំនេរ ។

ភាគទំនេរនេះ ម្ចាស់បណ្តាំនឹងចង់ឱ្យទៅនរណាក៏បានតាមចិត្ត ។

**មាត្រា ៥២៩** ៖ ភាគបំរុងដែលច្បាប់បង្កើតឡើង នេះគឺប្រយោជន៍ឱ្យ ទាយាទខ្លះដែលមានភ័ព្វជាងគេ បានមត៌កទាំងអស់ ឬ ខ្លះប្រសិនបើម្ចាស់មត៌ក ស្លាប់ទៅមិនបានផ្តាំ ទុកយ៉ាងណាៗទេ ។

**មាត្រា ៥៣០** ៖ ប្រពន្ធដើមមានខាន់ស្លា និងបច្ឆាជន នៃម្ចាស់មត៌កដែលជា ទាយាទ ត្រូវស៊ីភាគបំរុង ។

## ផ្នែកទី ២
## អំពីសមត្ថភាពនៃអ្នកផ្ដាំ

**មាត្រា ៥៣១** ៖ បុគ្គលទាំងពួងណា ដែលជានីតិជន ឬ ដែលបានអត្តាធិនភាពហើយមានសមត្ថភាពចេះពិចារណាស្គាល់ខុសត្រូវ, បុគ្គលទាំងពួងនោះអាចធ្វើបណ្ដាំមានតម្លៃពេញទីបាន ។

**មាត្រា ៥៣២** ៖ ឯមនុស្សអសមត្ថភាព ដូចមានសំដែងក្នុងមាតិកាទី ៥ មិនអាចធ្វើនូវបណ្ដាំដែលត្រូវទុកជាមានតម្លៃពេញទីបានឡើយ ។

**មាត្រា ៥៣៣** ៖ ស្រ្ដីមានប្ដីក្នុងវេលា ដែលមានអាពាហ៍ពិពាហ៍នូវឡើយ អាចនឹងចាត់ចែងដោយបណ្ដាំនូវទ្រព្យដើមរបស់ខ្លួន តែប៉ុណ្ណោះបានឡើយ ។

**មាត្រា ៥៣៤** ៖ ឯព្រះរាជវង្សានុវង្ស និងសាច់ពន្ធ អាចនឹងប្រទានអំណោយ ដោយបណ្ដាំដល់ជនដែលមិនមែនជាទាយាទបាន លុះណាតែព្រះករុណាព្រះចៅក្រុងកម្ពុជា ទ្រង់ព្រះរាជានុញ្ញាតិផងបើពុំនោះទេសេចក្ដីបណ្ដាំនោះត្រូវទុកជាមោឃៈគ្មានផលឡើយ ។

**មាត្រា ៥៣៥** ៖ ជនណាមិនសុខចិត្តនឹងសំបុត្របណ្ដាំឯណា ដោយហេតុថា ម្ចាស់មត៌ក កាលធ្វើនូវបណ្ដាំនោះមានសតិមិនប្រក្រតី ជននោះត្រូវរកបន្ទាល់នៃសំដីរបស់ខ្លួនឱ្យបាន។ ជនដែលមានសំអាងថា ម្ចាស់មត៌ក កាលព្រមធ្វើនូវបណ្ដាំនោះមានគេកំហែងបង្ខំតាមផ្លូវចិត្ត, ដោយបោកប្រាស់ក្ដីក៏ត្រូវរកបន្ទាល់ផងដែរ ។

## ផ្នែកទី ៣
## អំពីភាគបំរុង និង ភាគទំនេរ

**មាត្រា ៥៣៦** ៖ ឪពុកម្តាយ អាចនឹងផ្តាំឱ្យចែក ទ្រព្យដើមរបស់ខ្លួនទៅជនទាំងឡាយ ក្រៅពីបច្ឆាញាតិរបស់ខ្លួនដែលនៅរស់នោះបានតែពាក់កណ្តាលភាគនៃទ្រព្យដើមរបស់ខ្លួន ប្រសិនបើខ្លួនមិនទាន់កាត់កាលបច្ឆាញាតិទាំងអស់គ្នាទេ។ក៏ប៉ុន្តែសហព័ន្ធទី១ អាចនឹងធ្វើបណ្តាំឱ្យតាំងសហព័ន្ធនៃខ្លួនដែលរស់នៅជាផលុបភោគី នៃបេតិកភណ្ឌទាំងអស់បាន ។

ប៉ុន្តែ បើស្ត្រីមេម៉ាយមានខាន់ស្លាទី១ នោះមានប្តីទៀត ឬ មានប្រុសសហាយ ឬ មានកិរិយាអាក្រក់ ស្ត្រីមេម៉ាយនោះត្រូវផ្តាស់ខ្លួនខានបានផលុបភោគទៀត ហើយកាលណាបើមានទាយាទឯណាម្នាក់ប្តឹង ។

**មាត្រា ៥៣៧** ៖ ប្តីមិនអាចផ្តាំឱ្យបន្ថយភាគនៃទ្រព្យសំបាច់ដែលត្រូវបានមកប្រពន្ធឱ្យតិចជាងមួយភាគបីបានទេ, ប្រពន្ធមិនអាចផ្តាំឱ្យបន្ថយភាគនៃទ្រព្យសំបាច់ដែលត្រូវបានទៅប្តីឱ្យតិចជាងពីរភាគបីបានឡើយ ។

**មាត្រា ៥៣៨** ៖ សហព័ន្ធដែលនៅរស់អាចនឹងផ្តែផ្តាំឱ្យចែកទ្រព្យសំបាច់ទៅមនុស្សក្រៅពីបច្ឆាញាតិរបស់សហព័ន្ធ ដែលស្លាប់នោះបានតែពាក់កណ្តាលនៃភាគទ្រព្យសំបាច់ដែលត្រូវបានមកខ្លួន គឺប្រពន្ធបានមួយភាគប្រាំមួយ ប្តី ១ ភាគ ៣ វៀរតែក្នុងករណីដែលមានបញ្ញត្តិក្នុងមាត្រា ៣៣០ ។

**មាត្រា ៥៣៩** ៖ បើប្រពន្ធចុងទាំងឡាយ ដែលមានខាន់ស្លាមិនមានប្តីទៀតមិនមានប្រុសសហាយមិនមានមាយាទអាក្រក់ ដរាបណាទេសេចក្តីក្នុងសំបុត្រ

បណ្តាំនោះក៏មិនត្រូវឱ្យមានន័យអ្វីប៉ះពាល់ដល់សិទ្ធិនៃប្រពន្ធទាំងឡាយ ដែលត្រូវបានសោធនអាហារណើដរាបនោះដែរ ។

**មាត្រា ៥៤០** ៖ បើសំបុត្របណ្តាំណាធ្វើឱ្យខូចសិទ្ធិសហព័ទ្ធទី១ ឬ ខូចសិទ្ធិបច្ឆាញាតិរស់នៅ ដោយធ្វើឱ្យខូចភាគបំរុងដែលច្បាប់តម្រូវឱ្យទុកឱ្យដល់ទាយាទចំពូកនេះ សាម៉ីជនដែលខូចសិទ្ធិនោះអាចនឹងប្តឹងក្នុងកំណត់ ៣ខែ គិតតាំងពីថ្ងៃមរណៈតទៅដើម្បីសុំឱ្យតុលាការបន្ថយសេចក្តីនៃបណ្តាំនោះបាន ។

**មាត្រា ៥៤១** ៖ បើម្ចាស់បណ្តាំឥតមានសហព័ទ្ធទី១ទេ ឥតកូន ឥតចៅជាតំណទេម្ចាស់បណ្តាំនោះនឹងចាត់ចែកទ្រព្យសម្បត្តិរបស់ខ្លួនទាំងអស់បាន , លើកមួយតែក្នុងករណីដែលបានកំណត់ទុកហើយក្នុងមាត្រា ៥៣៤ ។

## ផ្នែកទី ៥
## សេចក្តីកាត់កាល់

**មាត្រា ៥៤២** ៖ ម្ចាស់បណ្តាំអាចកាត់កាល់ទាយាទរបស់ខ្លួនម្នាក់ ឬ ច្រើននាក់បាន ។

**មាត្រា ៥៤៣** ៖ ដែលហៅថា កាត់កាល់គឺដកសិទ្ធិពីទាយាទដែលត្រូវទទួលនូវចំណែកក្នុងមត៌កឱ្យលែងបានមត៌កវិញ ។

**មាត្រា ៥៤៤** ៖ ម្ចាស់បណ្តាំអាចកាត់កាល់ទាយាទដែលមិនត្រូវស៊ីភាគបំរុងដោយគ្រាន់តែដាក់សេចក្តីកាត់កាលនោះក្នុងសំបុត្របណ្តាំបាន ។

**មាត្រា ៥៤៥** ៖ ឯទាយាទ ដែលត្រូវស៊ីភាគបំរុងវិញ បើនឹងត្រូវកាត់កាល់បានលុះណាតែមាន សេចក្តីបណ្តាំដោយឡែកយ៉ាងពិតប្រាកដជាក់ស្តែងហើយឱ្យ

បង្ហាញហេតុផលផងទើបបាន, វៀរលែងតែក្នុងករណីដែលមានបញ្ញត្តិក្នុងមាត្រា ៣៣០ ។

**មាត្រា ៥៤៦** ៖ ទាយាទ ដែលស៊ីភាគបំរុងអាចតវ៉ាអំពីហេតុផលដែលមានក្នុងសេចក្ដីកាត់កាល់នោះបាន ។

ទាយាទនោះ ត្រូវប្ដឹងតវ៉ាក្នុងវេលា ៣ ខែ គិតតាំពីថ្ងៃដែលម្ចាស់មត៌កដល់នូវមរណៈភាព ។

## ផ្នែកទី ៥
## អំពីសមត្ថភាព ដែលនឹងទទួលទ្រព្យបណ្ដាំ

**មាត្រា ៥៤៧** ៖ ដើម្បីនឹងទទួលអច្ច័យទាន បានអច្ច័យលាភីត្រូវតែនៅរស់ក្រោយម្ចាស់បណ្ដាំ ។

អច្ច័យទាន ដែលឱ្យតែចំពោះតែបុគ្គលណាត្រូវបានតែបុគ្គលនោះមិនត្រូវបានទៅទាយាទនៃបុគ្គលនោះឡើយ ប្រសិនបើម្ចាស់បណ្ដាំមិនបានផ្ដាំឱ្យប្រាកដថាត្រូវឱ្យដល់ទាយាទផងទេ ។

**មាត្រា ៥៤៨** ៖ កូនដែលនៅក្នុងគ៌កនៅឡើយ អាចតាំងជាអច្ច័យលាភីបានដែរ ។

**មាត្រា ៥៤៩** ៖ អច្ច័យលាភី ទាំងឡាយត្រូវស្ថិតនៅក្រោមបទបញ្ញត្តិមាត្រា៤៩០ ដែលសំដែងអំពីជនអភ័ព្វនឹងក្រោមបទបញ្ញត្តិនៃមាត្រា ៤៨៩ ដែលសំដែងពីអសមត្ថភាពក្នុងការទទួលមត៌កផង ។

**មាត្រា ៥៥០** ៖ នាកាលអច្ច័យលាភី ដែលទើបនឹងត្រូវទុកជា ជនអភ័ព្វនោះ ពីមុនមកក៏គ្មានសិទ្ធិស៊ីមត៌ករបស់ម្ចាស់បណ្ដាំដែរ ប្រសិនបើម្ចាស់បណ្ដាំនេះស្លាប់ឥតបណ្ដាំ បច្ឆាញាតិនៃអច្ច័យលាភីនោះ នឹងទៅយកអច្ច័យលាភី នោះនឹងទៅយកអច្ច័យទានជំនួសនេះមិនបានឡើយ ។

**មាត្រា ៥៥១** ៖ នាកាលអច្ច័យលាភី ដែលទើបនឹងត្រូវទុកជា ជនអភ័ព្វនោះ ពីមុនមកក៏គ្មានសិទ្ធិស៊ីមត៌ករបស់ម្ចាស់បណ្ដាំដែរ, ប្រសិនបើម្ចាស់បណ្ដាំនេះស្លាប់ឥតបណ្ដាំ, បច្ឆាញាតិនៃអច្ច័យលាភីនោះ នឹងទៅយកអច្ច័យទានជំនួសជននេះមិនបានឡើយ ។

**មាត្រា ៥៥២** ៖ នាកាលអច្ច័យលាភី ដែលទើបនឹងត្រូវទុកជាជនអភ័ព្វនោះជាអ្នកមានសិទ្ធិស៊ីមត៌កឥតបណ្ដាំរបស់ម្ចាស់បណ្ដាំទាំងអស់ ឬ ខ្លះក្នុងគុណភាពនៃខ្លួនជាទាយាទឥតបណ្ដាំ បច្ឆាញាតិនៃអច្ច័យលាភីនោះអាចទទួលមត៌កជួសជននេះបាន តែត្រូវយកតែចំណែកដែលត្រូវបានទៅជននោះ បើជននោះមិនមែនជាជនអភ័ព្វទេ ហើយបើខ្មោចម្ចាស់កេរ្ដិ៍ក៏ស្លាប់ឥតបណ្ដាំដែរ ។

**មាត្រា ៥៥៣** ៖ នាកាលអច្ច័យលាភី ជាទាយាទនៃភាគបំរុងផង ហើយចំណែកនៃភាគទំនេរ ដែលខ្លួនត្រូវបានតាមសំបុត្របណ្ដាំនោះក៏លើសពីចំនួនដែលខ្លួនមានសិទ្ធិត្រូវបានតាមច្បាប់ទៀតផងនោះច្បាប់បញ្ញត្តិថាត្រូវបន្ថយចេញ ។

ការប្ដឹងសុំឱ្យបន្ថយនេះ ជាសិទ្ធិរបស់ទាយាទនៃភាគបំរុងទាំងឡាយដែលបានបង់ប្រយោជន៍។ ទាយាទទាំងនោះត្រូវប្ដឹងក្នុងរវាង ៣ ខែគិតពីថ្ងៃដែលខ្មោចនោះស្លាប់តទៅ ។

**មាត្រា ៥៥៣** ៖ ប្រសិនបើក្នុងសំបុត្របណ្ដាំនោះម្ចាស់បណ្ដាំបានបញ្ជាក់សេចក្ដីយ៉ាងច្បាស់លាស់ អំពីហេតុដែលនាំឱ្យខ្លួនចែកមត៌កដល់ទាយាទនៃភាគបំរុងទាំងឡាយលើសខ្វះគ្នាសព្វគ្រប់អស់ហើយ ការចែកមត៌កមិនស្មើគ្នានេះទុកស្មើសេចក្ដីកាត់កាល់ ដល់អ្នកដែលបានតិច ។ អ្នកបានតិចនេះនឹងប្ដឹងឱ្យបន្ថយសេចក្ដីនៃបណ្ដាំនេះបានក៏បានតែក្នុងលក្ខខណ្ឌដែលមានបញ្ញត្តិក្នុងមាត្រា ៥៤៦ ដែរ ។ ឯករណីដែលមានសម្ដែងក្នុងមាត្រា ៣២០ មិនមានបញ្ញត្តិអ្វីផ្សេងទៀតឡើយ ។

## ផ្នែកទី ៦
## អំពីទម្រង់នៃសំបុត្របណ្ដាំ

**មាត្រា ៥៥៤** ៖ សំបុត្របណ្ដាំទាំងពួង នឹងត្រូវយកជាការបានលុះណាតែសំបុត្របណ្ដាំបានធ្វើជាត្រឹមត្រូវដោយនូវបញ្ញត្តិច្បាប់ ។

**មាត្រា ៥៥៥** ៖ បណ្ដាំអាចធ្វើជាសំបុត្រ មានបញ្ជាក់ក៏បានអាចធ្វើជាសំបុត្រឯកជនក៏បាន។

**មាត្រា ៥៥៦** ៖ បណ្ដាំដែលធ្វើជាសំបុត្រមានបញ្ជាក់នោះត្រូវម្ចាស់បណ្ដាំបង្គាប់សេចក្ដីដោយខ្លួនឯងឱ្យស្មៀនសរសេរនៅចំពោះមុខមេឃុំក្នុងឃុំខ្លួន ហើយមានសាក្សី២ នាក់ជានីតិជនបានដឹងផង ។

សាក្សីនោះត្រូវយកមនុស្សណាក្រៅអំពីអច្ច័យលាភី ឬ ទាយាទ ។

**មាត្រា ៥៥៧** ៖ សំបុត្របណ្ដាំត្រូវចុះថ្ងៃខែឆ្នាំ ចុះនាមត្រកូល នាមកំណើតអាយុនិងលំនៅនៃសាក្សីទៀត ។ មេឃុំត្រូវសូត្រសេចក្ដីបណ្ដាំនោះឱ្យ

ខ្លាំងៗយ៉ាងច្បាស់ៗរួចហើយមេឃុំនឹងម្ចាស់បណ្ដាំព្រមទាំងសាក្សីទាំងឡាយ នោះត្រូវចុះហត្ថលេខាទាំងអស់គ្នា ។

បើម្ចាស់បណ្ដាំនឹងសាក្សីមិនចេះអក្សរមិនចេះអក្សរ មេឃុំត្រូវចារលើសំបុត្របណ្ដាំនោះអំពីរឿងមិនចេះអក្សរនេះជាសំគាល់ផង ។

**មាត្រា ៥៥៨** ៖ សំបុត្របណ្ដាំដែលធ្វើជាសំបុត្រ ឯកជននោះត្រូវម្ចាស់បណ្ដាំសរសេរដោយខ្លួនឯងទាំងអស់ ហើយចុះហត្ថលេខាខ្លួនទៀតផង។

**មាត្រា ៥៥៩** ៖ មនុស្សមិនចេះអក្សរនឹងធ្វើបណ្ដាំបាន តែជាសំបុត្រមានបញ្ជាក់ ។

**មាត្រា ៥៦០** ៖ សំបុត្របណ្ដាំ ដែលគ្មានចុះថ្ងៃខែឆ្នាំ នោះនឹងយកជាការបានលុះណាតែគ្មានសេចក្ដីបណ្ដាំតែមួយមកជំទាស់ ។ បើមានបណ្ដាំច្រើនច្បាប់ឥតចុះថ្ងៃខែឆ្នាំដូចគ្នាហើយមានសេចក្ដីខុសគ្នាទៀត, សំបុត្របណ្ដាំទាំងអស់នោះត្រូវទុកជាឥតបានការទាំងអស់ ។

**មាត្រា ៥៦១** ៖ សំបុត្របណ្ដាំទាំងពួងដែលគ្មានចុះហត្ថលេខាត្រូវទុកជាមោឃ ។

## ផ្នែកទី ៧
## អំពីបដិសេធន៍នៃបណ្ដាំ

**មាត្រា ៥៦២** ៖ ដែលហៅថា បដិសេធបណ្ដាំ នោះគឺការលុបសេចក្ដីបណ្ដាំ ដែលធ្វើត្រឹមត្រូវតាមច្បាប់ចោលដោយហេតុថាម្ចាស់បណ្ដាំប្រែឆន្ទៈ។

**មាត្រា ៥៦៣** ៖ ម្ចាស់បណ្តាំនឹងបដិសេធ បណ្តាំទាំងអស់ក៏បានបដិសេធតែ សេចក្តីខ្លះបាន ។

**មាត្រា ៥៦៤** ៖ បដិសេធន៍បណ្តាំ អាចជាបដិសេធន៍ ដោយជាក់ស្តែងក៏បាន ដោយមិនជាក់ស្តែងក៏បាន។

ដែលហៅថា បដិសេធ ដោយជាក់ស្តែង នោះគឺការធ្វើលិខិតមួយទៀតដែលមានសេចក្តីជាក់លាក់ ហើយទំរង់នៃលិខិតនោះនោះមានការអះអាងជាត្រឹមត្រូវដូចគ្នានឹងសំបុត្របណ្តាំដែរ គឺថាធ្វើនៅមុខមេឃុំមានសាក្សី២នាក់ជួយដឹងឮផង ឬ ក៏ម្ចាស់បណ្តាំធ្វើដោយខ្លួនឯងចុះហត្ថលេខាដៃឯងផង ។

ដែលហៅថា បដិសេធន៍ ដោយមិនជាក់ស្តែង នោះ គឺថាមានលិខិតមួយផ្សេងទៀត ដែលសំដែងឱ្យឃើញច្បាស់ថាម្ចាស់បណ្តាំប្តូរឆន្ទៈខុសពីសំបុត្របណ្តាំមុនហើយ ។

**មាត្រា ៥៦៥** ៖ បើបណ្តាំថ្មីបានសេចក្តីផ្សេងអំពីសេចក្តីបណ្តាំមុន, បណ្តាំថ្មីនេះទុកដូចជាបដិសេធបណ្តាំមុនចោលដោយមិនជាក់ស្តែង ។

**មាត្រា ៥៦៦** ៖ បើម្ចាស់បណ្តាំបានឱ្យដោយសំបុត្របណ្តាំនូវវត្ថុអ្វីមួយទៅឈ្មោះណាម្នាក់លុះកាលជាឯក្រោយមកក៏យកវត្ថុនោះទៅលក់ដូរមកចាយ ទៅវិញក្នុងកាលដែលខ្លួននៅរស់នៅឡើយ អំពើរបស់ម្ចាស់បណ្តាំនេះត្រូវទុកដូចជាបដិសេធន៍បណ្តាំដោយមិនជាក់ស្តែងដែរ។

**មាត្រា ៥៦៧** ៖ បើម្ចាស់បណ្តាំ បំផ្លាញសំបុត្របណ្តាំដើមចោលដោយចេតនា ហើយអំពើនេះត្រូវទុកស្មើបដិសេធន៍សេចក្តីបណ្តាំនោះចោលដែរ ។

**មាត្រា ៥៦៨** ៖ សេចក្ដីដែលតុលាការ កាត់សេចក្ដីទុកអច្ច័យលាភីជាអភ័ព្វបុគ្គល នោះនាំឱ្យបដិសេធ សេចក្ដីបណ្ដាំ ដែលធ្វើចំពោះខ្លួន អច្ច័យលាភនោះដែរ ។

**មាត្រា ៥៦៩** ៖ អច្ច័យលាភី ដែលមិនធ្វើរតាមសេចក្ដីដែលម្ចាស់បណ្ដាំផ្ដាំឱ្យធ្វើក៏នាំឱ្យបដិសេធអច្ច័យទានបង់ដែរ ។

## ផ្នែកទី ៨
## អំពីអច្ច័យទាន

**មាត្រា ៥៧០** ៖ ម្ចាស់បណ្ដាំអាចលើកបេតិកភណ្ឌរបស់ខ្លួនទាំងអស់ឱ្យទៅជាអច្ច័យទានដល់អ្នកឯណាតែម្នាក់ក៏បានអច្ច័យទានបែបនោះហៅថា អច្ច័យទានសាកល ។

ម្ចាស់បណ្ដាំអាចផ្ដាំឱ្យចែកបេតិកភណ្ឌតរបស់ខ្លួនទាំងអស់ ដល់មនុស្សច្រើននាក់ គឺឱ្យមនុស្សម្នាក់ៗបាននូវភាគមួយៗត្រាតែអស់បេតិកភណ្ឌទាំងអស់របស់ខ្លួនទៅក៏បានការឱ្យបែបនេះក៏ហៅថា អច្ច័យទានសាកលដែរ ។

បើម្ចាស់បណ្ដាំឱ្យវត្ថុតែមួយមុខ ឬ ច្រើនមុខមានកំណត់អំណោយបែបនេះហៅថា អច្ច័យទានដោយចំពោះវត្ថុ ។

**មាត្រា ៥៧១** ៖ អច្ច័យលាភីសាកល ត្រូវយកសំបុត្របណ្ដាំដែលម្ចាស់បណ្ដាំបានធ្វើអំណោយមកឱ្យខ្លួននោះទៅចុះក្នុងសៀវភៅ នៅទីសមុហបញ្ជីនៃសាលាខាងទីលំនៅនាំម្ចាស់បណ្ដាំ ដើម្បីឱ្យខ្លួនអាចទទួលមត៌កនើបានដោយត្រឹមត្រូវតាមច្បាប់ ។

**មាត្រា ៥៧២** ៖ អច្ច័យលាភីសាកល បើព្រមទទួលនូវអំណោយនោះ ហើយត្រូវឡើងជាកម្មសិទ្ធិករនៃអំណោយនោះ តាំងពីថ្ងៃដែលម្ចាស់អំណោយធ្វើនូវមរណកាល ។

អច្ច័យលាភីច្រើននាក់ក៏ត្រូវឡើងជាកម្មសិទ្ធិករ ដូច្នេះដែរហើយយកមត៌កនោះមកចែកគ្នាដូចជាទាយាទឥតបណ្តាំដូចច្នោះដែរ ។

**មាត្រា ៥៧៣** ៖ អច្ច័យលាភី ដោយចំពោះវត្ថុ ត្រូវសុំឱ្យអច្ច័យលាភីសាកល ឬ ទាយាទឥតបណ្តាំដែលកាន់យកនូវមត៌កនោះប្រគល់នូវអច្ច័យទានដែលត្រូវបានមកខ្លួនដល់ខ្លួន ។

**មាត្រា ៥៧៤** ៖ អច្ច័យលាភីដោយចំពោះវត្ថុ បើចង់ប្តឹងតុលាការ ដើម្បីទារនូវ អច្ច័យទាន ដែលត្រូវបានមកខ្លួននោះត្រូវតែសងបំណុលម្ចាស់មត៌កនិងធ្វើបុណ្យសពសិនទើបប្តឹងបាន ។

**មាត្រា ៥៧៥** ៖ បើមានភារៈអ្វីតម្រូវឱ្យអច្ច័យលាភី ប្រតិបត្តិហើយជននោះគេចវេះមិនព្រមបំពេញ កាតព្វកិច្ចដែលកើតមក អច្ច័យទាន ដែលខ្លួនទទួលនោះទេ អ្នកដែលត្រូវប្តឹង ឱ្យបដិសេធអច្ច័យទាន នោះអាច ប្តឹងបាន ក្នុងកំណត់ ៣ ខែ គិតតាំងពីថ្ងៃដែលបានប្រាប់ឱ្យអច្ច័យលាភីបំពេញកាតព្វកិច្ចរបស់ខ្លួនហើយមិនព្រមនោះមក ។

**មាត្រា ៥៧៦** ៖ ម្ចាស់បណ្តាំ អាចប្រដាក់ប្រទុក ជនណាម្នាក់ឱ្យធ្វើជាអ្នកចាត់ឱ្យប្រតិបត្តិនូវសំបុត្របណ្តាំនាំខ្លួនបាន ។

**មាត្រា ៥៧៧** ៖ គេអាចរើស អ្នកចាត់តាំងឱ្យប្រតិបត្តិ សំបុត្របណ្តាំនោះក្រៅពីអច្ច័យលាភីស្មោះក៏បានដែរ ជននេះត្រូវប្រមូលមត៌កទាំងអស់មកចែកឱ្យត្រឹមត្រូវតាម សេចក្តីនៃម្ចាស់បណ្តាំប្រគល់នូវអច្ច័យទានដល់អ្នកត្រូវទទួល ហើយដាក់ឱ្យប្រតិបត្តតាម ឆន្ទៈរបស់ម្ចាស់បណ្តាំ ដែលបានសំដែងជាចុងក្រោយបំផុត ។ ជននេះអាចនឹងចាត់ចែងយ៉ាងនេះឱ្យត្រឹមត្រូវពេញលក្ខណៈបាន លុះណាតែយកសំបុត្របណ្តាំដែលតាំងខ្លួនជាអ្នកសម្រេចនោះទៅឱ្យចុះក្នុងសៀវភៅនៅទីសហាមុបញ្ជីនៃសាលាខាងលំនៅនៃម្ចាស់បណ្តាំជាមុនសិន។

## ចំពូក ៥
## អំពីការកាន់យកនូវមត៌ក
### ផ្នែកទី ១
### អំពីវិធានការ ដែលត្រូវចាត់ទុកឱ្យរក្សាទុកនូវបេតិកភណ្ឌ

**មាត្រា ៥៧៨** ៖ តាមគោលការណ៍ វិធានការទាំងឡាយ ដែលត្រូវចាត់ឱ្យទុកដាក់ និងថែរក្សានូវបេតិកភ័ណ្ឌនៃខ្មោចឱ្យគង់វង់នោះនឹងធ្វើទៅបានលុះណាតែមានពាក្យទាយាទពីអច្ច័យលាភីឯណាម្នាក់ ឬ ពីតតិយជនណាដែលមានប្រយោជន៍ក្នុងរឿងនេះដូចយ៉ាងម្ចាស់បំណុល នៃខ្មោចជាដើមប្តឹងសុំជាមុនសិន ។

**មាត្រា ៥៧៩** ៖ ប៉ុន្តែកាលបើមត៌កជារបស់ឪពុក ឬ ម្តាយដែលនៅរស់ក្រោយគេត្រូវបានមកកូនម្នាក់ ឬ ច្រើននាក់នីក្នុងនីតិភាពកាលណាបើមត៌កជារបស់ជនដែលឥតមានទាយាទ ដែលទាយាទបាត់ខ្លួន ឬ គេមិនស្គាល់ឈ្មោះ វិធានការខាងលើនេះត្រូវតែចាត់ដោយឯកឯង។

**មាត្រា ៥៨០** ៖ វិធានការដែលត្រូវចាត់ឱ្យថែរក្សាទុកនោះគឺបិទស្លាកល័ក្សលើទ្រព្យនៃខ្មោចនិងធ្វើបញ្ជីវាយថ្លៃទ្រព្យនោះផង ។

**មាត្រា ៥៨១** ៖ ស្លាកល័ក្ស នោះត្រូវមេឃុំ បិទនៅមុខសាក្សី២នាក់ជានីតិជនជាអ្នកដទៃពីមត៌ក ហើយត្រូវធ្វើកំណត់ហេតុអំពីការបិទនោះដោយសំបុត្រមានសេចក្តីបញ្ជាក់ផង ។

មេឃុំ ត្រូវចម្លងសេចក្តីកត់ហេតុ នោះមួយច្បាប់បញ្ជូនជាប្រញាប់ទៅឱ្យចាហ្វាងសាលាដំបូងៗ ត្រូវទៅកាន់ទីនោះជាមួយសមុហបញ្ជីដើម្បីធ្វើបញ្ជីរបស់ទ្រព្យ ។ ចាងហ្វាងអាចចាត់ចៅក្រមណាម្នាក់ ឬ មេឃុំឱ្យទៅជួយសមុហបញ្ជីធ្វើបញ្ជីវាយថ្លៃរបស់នោះផងបាន ។

**មាត្រា ៥៨២** ៖ បេតិកភណ្ឌ ដែលមានកត់ក្នុងបញ្ជី ជាសម្រេចហើយត្រូវប្រគល់ឱ្យជនណាម្នាក់គ្រប់គ្រងកាន់កាប់រក្សាជាបណ្តោះអាសន្នសិន ។ សហព័ទ្ធមានខាន់ស្លាទី ១ បើមិនប្រកែកទេ ត្រូវតែទទួលមុខការនេះពេញសិទ្ធិ ។

## ផ្នែកទី ២
## អំពីការព្រម និងមិនព្រមទទួលមត៌ក

**មាត្រា ៥៨៣** ៖ ទាយាទ នៃភាគបំរុង មិនអាចប្រកែកថាមិនទទួលនូវមត៌កខ្មោច បុព្វញាតិខ្លួនបានទេ ។ ជននេះត្រូវទទួលសងបំណុលដែលម្ចាស់មត៌កទុកឱ្យខ្លួន ប៉ុន្តែបំណុលទាំងនោះមិនបានត្រូវមានការទេ តាំងពីថ្ងៃដែលកូនបំណុលស្លាប់មក។

ម្ចាស់បំណុល មិនអាចនឹងសុំឱ្យដាក់គុកបង្ខំខ្លួនទាយាទបានទេ។

**មាត្រា ៥៨៤** ៖ ទាយាទទាំងឡាយ ដែលមិនត្រូវបានភាគបំរុង និងអច្ច័យលាភីទាំងឡាយអាចនឹងមិនព្រមយកមត៌កដែលត្រូវបានមកខ្លួននោះបាន ។

**មាត្រា ៥៨៥** ៖ បើមិនព្រមទទួលនូវមត៌កទេ អ្នកប្រកែកនោះត្រូវធ្វើពាក្យយកទៅប្ដឹងដោយខ្លួនឯងនៅទីសមុហបញ្ជី នៃសាលាខាងទីដែលកំពុងចាត់ការមត៌កនោះ។

**មាត្រា ៥៨៦** ៖ បើមិនទទួលមត៌កទេ អ្នកប្រកែកត្រូវប្ដឹងក្នុងរវាង៣ខែ គិតពីត្រឹមក្រោយថ្ងៃដែលខ្មោចស្លាប់មក ។ បើអច្ច័យលាភីនោះ មិនទាន់បានកាន់យកនូវទ្រព្យនោះជាកម្មសិទ្ធិរបស់ខ្លួនទេមិនបានបំបាត់មិនបានលាក់ទុកអ្វីៗទេ អ្នកនោះទើបប្រកែក បាន ។

**មាត្រា ៥៨៧** ៖ ការដែលគ្រាន់តែគ្រប់គ្រងថែរក្សា នោះនឹងមិនអាចឃាត់អច្ច័យលាភី មិនឱ្យប្រកែកថាមិនទទួលយកនូវមត៌កទេ ។

**មាត្រា ៥៨៨** ៖ ការប្រកែកមិនទទួល នូវមត៌កមានអានុភាពនឹងធ្វើឱ្យមត៌កនោះបានទៅទាយាទណា ដែលមត៌កនោះត្រូវតែវិលមករកខ្លួននោះប្រសិនបើអ្នកប្រកែកនោះមិនបានរស់នៅក្រោយខ្មោចម្ចាស់មត៌ក ។

**មាត្រា ៥៨៩** ៖ អ្នកព្យាបាលជនអសមត្ថភាព អាចប្រកែកមិនព្រមទទួលមត៌ក ដែលត្រូវបានទៅបាលិតរបស់ខ្លួនបាន លុះណាតែក្រុមប្រឹក្សាញាតិ ឬ ចាងហ្វាងសាលាដំបូងបើទាយាទជាកូនឥតខាន់ស្លាយល់ព្រមផងជន ដែលមានហិតូបត្ថម្ភកអាចនឹងប្រកែកមិនទទួលនូវមត៌កបានលុះណាតែហិតូបត្ថម្ភកបើកឱ្យប្រកែកផង ។

**មាត្រា ៥៩០** ៖ ទាយាទដែលមិនត្រូវបានភាគបំរុង អច្ច័យលាភីសាកល អាចនឹងសុំឱ្យធ្វើបញ្ជីបញ្ជាក់នូវទ្រព្យសកម្ម និងអកម្មឱ្យដឹងជាមានប៉ុន្មានៗសិន ទើបឆ្លើយទទួល ឬ ប្រកែកក៏បាន ។

**មាត្រា ៥៩១** ៖ សេចក្ដីដែលសុំឱ្យធ្វើបញ្ជីសិនសឹមឆ្លើយទទួល ឬ មិនទទួល ដូច្នេះត្រូវប្ដឹងក្នុងកំណត់ នឹងតាមទំនងដូចបានបញ្ញត្តិក្នុងមាត្រា៥៨៦ ។

**មាត្រា ៥៩២** ៖ ការទទួល ឬ មិនទទួលត្រូវឱ្យឆ្លើយក្នុងកំណត់១៥ថ្ងៃគិតតាំងពីថ្ងៃដែលធ្វើបញ្ជីហើយជាស្រេច។

បើនៅស្ងៀមទុកស្មើព្រមទទួល។

## ផ្នែកទី ៣
## អំពីការជម្រះ និងការចែកមត៌ក

**មាត្រា ៥៩៣** ៖ នាកាលមត៌កត្រូវបានទៅទាយាទច្រើនរូប ឬ ត្រូវបានអច្ច័យលាភីសាកលច្រើនរូប ទ្រព្យមត៌កនោះត្រូវទុកឱ្យទៅមូលមួយដុំជាមួយគ្នារហូតដល់ថ្ងៃ ចែក ។

**មាត្រា ៥៩៤** ៖ ទោះនរណា បានកាន់យកនូវទ្រព្យខ្លះក្នុងវេលាដែលម្ចាស់មត៌កធ្វើនូវមរណៈកាល អ្នកនោះត្រូវថែរក្សាគ្រប់គ្រងនូវទ្រព្យនោះដរាបដល់ថ្ងៃចែកបើបាត់គង់យ៉ាងណាៗអ្នកនោះត្រូវទទួលខុសត្រូវ ចំពោះសហទាយាទផងគ្នា ឬ ចំពោះអច្ច័យលាភី ។

**មាត្រា ៥៩៥** ៖ ទាយាទអច្ច័យលាភី ឬ ម្ចាស់បំណុល នៃខ្មោចអាចនឹងប្ដឹងសុំឱ្យតាំងអ្នកគ្រប់គ្រងមត៌កជាបណ្ដោះអាសន្នសិនទំរាំដល់វេលាចែកក៏បាន ។

**មាត្រា ៥៩៦** ៖ ទាយាទទាំងពួងអាចប្ដឹងសុំឱ្យចែកមត៌កបានវៀលែងតែមានករណីដូចដែលមានបញ្ញត្តិក្នុងមាត្រា៥០៤ ។

**មាត្រា ៥៩៧** ៖ ពាក្យសុំឱ្យចែកនោះអាចនឹងប្ដឹងបានលុះណាតែបានធ្វើបុណ្យសពបាន១ខែហើយសិន។

**មាត្រា ៥៩៨** ៖ បើម្ចាស់មត៌កបានឱ្យទ្រព្យអ្វីទៅទាយាទណាម្នាក់ពីកាលនៅរស់នៅឡើយទាយាទនោះមិនត្រូវគេបង្ខំឱ្យប្រមូលទ្រព្យនោះវិញឡើយក្រែងតែទ្រព្យ ដែលទាយាទបានទទួលនោះបើបូករួមទៅច្រើនលើសពី ១ភាគ៤ នៃមត៌កនោះនោះទើបត្រូវយកចំនួនលើសនោះមកដាក់បញ្ចូលជាមត៌កវិញ។

តែឯប្រាក់ដែលឪពុកម្ដាយ ឱ្យខ្ចីធ្វើជាដើមទុន ឬ ផ្ញើទុកឱ្យរកស៊ីនោះត្រូវយកមកដាក់ក្នុងមត៌កវិញ ។

**មាត្រា ៥៩៩** ៖ ក្នុងករណីនេះ ប្រាក់ដែលជំពាក់នោះ មិនត្រូវមានការឡើយ ឯចំណេញដែលបានមកដោយយកប្រាក់នោះទៅរកស៊ីត្រូវបានជារបស់នៃអ្នកដែលរកស៊ីនោះ ។

**មាត្រា ៦០០** ៖ ប្រាក់ដើម ដែលទាយាទជំពាក់ត្រូវទូទាត់នឹងមត៌ក ។

បើចំណែកមត៌ករបស់ខ្លួន តិចជាងប្រាក់ដែលជំពាក់ ទាយាទត្រូវសងប្រាក់ដែលខ្វះ ខ្លួនត្រូវជំពាក់បំណុលមត៌កវិញ។

**មាត្រា ៦០១** ៖ បើទាយាទណាម្នាក់ បានបំបាត់មត៌កទាំងអស់ ឬ ខ្លះទាយាទនោះ ត្រូវសងទ្រព្យដែលបំបាត់នោះវិញ ឬ បើទ្រព្យនោះបាត់រូបទៅត្រូវសងតម្លៃទ្រព្យនោះ ។

បើទ្រព្យ ឬ តម្លៃទ្រព្យនោះ ត្រូវយកមកចែកសហទាយាទឯទៀត លើកតែជនដែលបំបាត់នោះមិនត្រូវឱ្យបានឡើយ។

**មាត្រា ៦០២** ៖ ឯបំណុលដែលម្ចាស់មត៌កជំពាក់គេត្រូវសងឱ្យស្រេចជាមុនសិន សឹមតាំងចែកមត៌កជាក្រោយ។

**មាត្រា ៦០៣** ៖ ទាយាទបានចេញសោហ៊ុយមើលជម្ងឺខ្មោច ដែលឈឺជាលើក្រោយនេះនឹងចេញសោហ៊ុយធ្វើបុណ្យសពនោះ ទាយាទនោះត្រូវបានសំណងវិញ ។

**មាត្រា ៦០៤** ៖ ទាយាទទាំងឡាយ ត្រូវទទួលសងបំណុលនៃមត៌កត្រឹមតែចំនួនទ្រព្យសកម្មនៃមត៌ក ។ ទាយាទអាចលើកទ្រព្យសកម្ម នៃមត៌កទាំងអស់ប្រគល់ឱ្យម្ចាស់បំណុលដើម្បីឱ្យរួចពីសងបំណុលបាន ។

**មាត្រា ៦០៥** ៖ ក៏ប៉ុន្តែទាយាទ នៃភាគបំរុងត្រូវទទួលសងបំណុលទាំងអស់ឱ្យអស់ ។

**មាត្រា ៦០៦** ៖ នាកាលបំណុលទាំងប៉ុន្មាន បានសងរួចហើយ ទើបគេត្រូវប្រគល់អច្ច័យទានដោយចំពោះវត្ថុនោះទៅអ្នកដែលត្រូវទទួល ។

តមកទាយាទអាចចែកគ្នានូវសកម្មនៃមត៌កនោះបាន ។

**មាត្រា ៦០៧** ៖ មត៌កអាចចែកគ្នា តាមការស្រុះស្រួលគ្នាក៏បាន ឬ ចែកតាមផ្លូវតុលាការក៏បាន ។

បើចែកតាមការស្រុះស្រួលគ្នានោះត្រូវធ្វើជាសំបុត្របានសេចក្ដីបញ្ជាក់ជាដរាប។

**មាត្រា ៦០៨** ៖ បើមានអ្នកស៊ីមត៌កម្នាក់ជាអនីតិជន ឬ អវត្តមាន ( បាត់ខ្លួន ) ការចែកតាមរបៀបស្រុះស្រួលគ្នា នោះត្រូវឱ្យតុលាការចេញសាលក្រមសទិសានុញ្ញាត ( Le partage dl" amiable doit etre homologue par Jugement ) ផង ។

**មាត្រា ៦០៩** ៖ ការវាយចំណែកមត៌ក ត្រូវចែកឱ្យច្រើនផ្នែកតាមចំនួនមនុស្សដែលរួមចំណែកតាមមែក ឬ តាមគល់ដែលត្រូវបាននូវចំណែកនោះ ។

**មាត្រា ៦១០** ៖ ទាយាទទាំងឡាយ ត្រូវព្រមព្រៀងគ្នា ទទួលភាគរបស់ខ្លួនតាមចំណែកដែលចែកឱ្យបើមិនព្រមព្រៀងគ្នាទេត្រូវឱ្យចាប់ឆ្នោត ។

**មាត្រា ៦១១** ៖ បើមានទាស់ទែងខ្វែងគំនិតគ្នាដោយប្រការណាទាយាទណាម្នាក់អាចប្តឹងឱ្យតុលាការ ប្រមូលមត៌កឱ្យមូលមក ហើយចែកដល់ទាយាទទាំងឡាយបាន ។

**មាត្រា ៦១២** ៖ ដើម្បីនឹងប្រមូលទ្រព្យ ទាំងឡាយឱ្យមូលើមកនោះតុលាការត្រូវធ្វើតាមទំនៀមទម្លាប់ក្នុងស្រុក តាមសំណូមពរនៃទាយាទភាគច្រើនតាមស្ថានភាពនៃទ្រព្យនោះ ។

រួចហើយតុលាការ ត្រូវឱ្យចាប់ឆ្នោតយកតាមចំណែករៀងខ្លួន ។

**មាត្រា ៦១៣** ៖ កាលណាចាប់ឆ្នោតរួចហើយ ទាយាទទាំងឡាយអាចនឹងប្តូរចំណែកគ្នាបានតាមចិត្តជាដរាប ។

**មាត្រា ៦១៤** ៖ នាកាលទ្រព្យណាមួយ បើនឹងយកមកចែកទៅមុខជាថយនូវតម្លៃអស់ច្រើនទ្រព្យនោះគប្បីឱ្យទៅអ្នកណាម្នាក់បណ្តាទាយាទទាំងអស់ឱ្យ

ទទួលយក ហើយឱ្យអ្នកនោះចេញប្រាក់ទៅឱ្យអ្នកឯទៀតតាមចំណែកដែកត្រូវបាន ។

**មាត្រា ៦១៥** ៖ ទ្រព្យទាំងឡាយណា ដែលទាយាទមិនព្រមព្រៀងគ្នាអំពីរបៀបចែក ឬ អំពីវត្ថុដែលត្រូវចែកមកឱ្យខ្លួនទ្រព្យទាំងឡាយនោះត្រូវលក់ហើយយកថ្លៃមកចែកគ្នាវិញ ។

**មាត្រា ៦១៦** ៖ អ្នករួមចំណែកម្នាក់ៗ ត្រូវបានប័ណ្ណនៃទ្រព្យទាំងឡាយដែលគេចែកឱ្យនោះ។

**មាត្រា ៦១៧** ៖ ការប្រគល់ទ្រព្យ និងប័ណ្ណនោះនាំឱ្យទាយាទបានឡើងជាកម្មសិទ្ធិករនៃទ្រព្យដែលគេប្រគល់ឱ្យនោះពេញច្បាប់ ។

**មាត្រា ៦១៨** ៖ អ្នករួមចំណែកដែលគេបានប្រគល់ទ្រព្យឱ្យដល់ខ្លួន ហើយខ្លួនត្រូវធ្វើបង្កាន់ដៃឱ្យគេវិញ ។

**មាត្រា ៦១៩** ៖ ការចែកគ្នាដោយស្រុះស្រួល នោះកាលណាបើអ្នករួមចំណែកទាំងអស់គ្នាបានចុះហត្ថលេខាលើសំបុត្រចែក ហើយត្រូវទុកថាការនោះដាច់ស្រេចជាស្ថាពរបាន ។

**មាត្រា ៦២០** ៖ ការចែកដែលមានការស្រុះស្រួលដែលមានសទិសានុញ្ញាតអំពីតុលាការទៀតនោះ នឹងទុកថាជាស្ថាពរបានកាលណាបើសាលក្រមសទិសានុញ្ញាតនោះផុតកំណាត់តវ៉ាហើយ ។

ការចែកដែលតុលាការចាត់ចែងឱ្យនោះនឹងទុកជាស្ថាពរបាន ឬ មិនបានក៏ទាល់តែដូចគ្នាយ៉ាងនេះដែរ ។

**មាត្រា ៦២១** ៖ ការចែកតាមការស្រុះស្រួលតែគ្នាឯង នោះអាចនឹងប្ដឹងឱ្យទុកជាមោឃៈបាន តែក្នុងកំណត់មួយឆ្នាំ គិតតាំងពីថ្ងៃដែលការចែកនោះជាស្ថាពរមក ។

**មាត្រា ៦២២** ៖ ហេតុដែលគប្បីប្ដឹង ឱ្យទុកការចែកជាមោឃៈ នោះគឺអ្នកដែលរួមជាមនុស្សអសមត្ថភាព១ចែកមិនត្រូវតាមទម្រង់ ដែលច្បាប់បញ្ញត្តិមក១ កំហែងបង្ខំឱ្យព្រម ឬ បោកប្រាស់១ ដូចមានសំដែងក្នុងចំពូកនៃកាតព្វកិច្ចដោយបេ្ដជ្ញាស្រាប់ ។

## ផ្នែកទី ៤
## អំពីបណ្ដឹងទារមត៌ក

**មាត្រា ៦២៣** ៖ បណ្ដឹងដែលប្ដឹងទារមត៌ក នោះមានគោលបំណងចង់ឱ្យទាយាទណាម្នាក់បាននូវមត៌កទាំងអស់ ឬ ខ្លះដែលខ្លួនមានសិទ្ធិត្រូវបាន ហើយតែគេមិនឱ្យដោយអយុត្តិធម៌ ។

**មាត្រា ៦២៤** ៖ បណ្ដឹងនេះត្រូវប្ដឹងពីភោគីនៃមត៌ក ។

**មាត្រា ៦២៥** ៖ បណ្ដឹងនេះត្រូវប្ដឹងពីភោគីដោយសុចរិតក្នុងកំណត់៣ឆ្នាំ និងពីភោគីដោយទុច្ចរិតក្នុងកំណត់៥ឆ្នាំគិតតាំងពីថ្ងៃដែលម្ចាស់មត៌កដល់នូវមរណៈកាលមក ។

**មាត្រា ៦២៦** ៖ បើតុលាការសម្រេចថា បណ្ដឹងនោះត្រឹមត្រូវតាមអង្គច្បាប់ ហើយភោគីត្រូវប្រគល់មត៌កនោះទៅឱ្យទាយាទជាធម្មានុរូបនោះវិញ ។ បើភាគីនោះទទួលមត៌កដោយសុចរិតជននោះត្រូវសងផល និងផលទុនដែលខ្លួនបាន

យករួចទៅ ហើយព្រមទាំងមានសិទ្ធិទារឱ្យសងប្រាក់ដែលខ្លួនបានចាយវាយប៉ុន្មានៗទៅក្នុងមត៌កនោះផង និងទារសំណងដែលខ្លួនសងបំណុលម្ចាស់មត៌កនោះទៀតផង ។

បើភោគីនោះទទួលមត៌ក ដោយទុច្ចរិត ជននោះត្រូវប្រគល់ផល និងផលទុនដែលកើតអំពីមត៌កដែលខ្លួនបានយកនោះឱ្យមកអ្នកប្តឹងវិញជននេះគ្មានសិទ្ធិទារសំណាង ដែលខ្លួនបានសងបំណុលមត៌កនោះទេទោះខ្លួនបានចាយវាយទៅក្នុងមត៌កនោះ ឬ ទៅក្នុងការថែរក្សានូវមត៌កនោះប៉ុន្មានៗក្តី ។

# គន្ថីទី២

# អំពីទ្រព្យ

## មាតិកាទី១

## បទបញ្ញត្តិទូទៅ និងអំពីការចែកញែកនូវទ្រព្យ

**មាត្រា ៦២៧** ៖ បេតិកភណ្ឌ នៃបុគ្គលម្នាក់ៗ គឺសារពើអ្វីទាំងអស់ដែលបុគ្គលនោះមាន និងដែលបុគ្គលនោះជំពាក់គេហើយដែលគេអាចកាត់តម្លៃជាប្រាក់បាន ។

អ្វីដែលបុគ្គលនោះមានហៅថា សកម្មនៃបេតិកភណ្ឌ, អ្វីដែលបុគ្គលនោះជំពាក់គេហៅថា អកម្មនៃបេតិកភណ្ឌ ។

**មាត្រា ៦២៨** ៖ សកម្មបានដល់ទ្រព្យទាំងអស់គឺថាបានដល់វត្ថុជាសម្ភារៈទាំងអស់ដែលមានតម្លៃផ្សេងៗ និងដែលបុគ្គលម្នាក់ៗអាចកាន់កាប់ជារបស់ខ្លួនបានព្រមទាំងសិទ្ធិទាំងឡាយ ដែលមានគុណធម៌បើកឲ្យបុគ្គលនោះមានអំណាច

ផ្ទាល់លើវត្ថុណាមួយ ឬ មានអំណាចអាចបង្ខំឲ្យបុគ្គលម្នាក់ទៀតធ្វើនូវកាតព្វកិច្ច ទាំងពួង ជាប្រយោជន៍ផ្ទាល់ដល់ខ្លួនបាន ។

**មាត្រា ៦២៩** ៖ សិទ្ធិដែលបើកឲ្យបុគ្គលម្នាក់ៗមានអំណាចផ្ទាល់លើវត្ថុនីមួយៗហៅថាសិទ្ធិប្រត្យ័ក្ស, សិទ្ធិដែលតាំងបុគ្គលពីរនាក់ឲ្យម្នាក់ជាម្ចាស់បំណុល ហើយម្នាក់ទៀតជាកូនបំណុលហៅថាសិទ្ធិលើបុគ្គល ។

**មាត្រា ៦៣០** ៖ ទ្រព្យទាំងឡាយ នោះចែកជាចលវត្ថុ និងជាអចលវត្ថុ ។

អចលវត្ថុ គឺជាវត្ថុដែលមានឥរិយាបថជាប់នឹងកន្លែងតែមួយ មិនកំរើកតាំងពីកំណើតក្តី, តាំងពីភ័ព្វវាសនានៃវត្ថុនោះក្តី ។ វត្ថុទាំងឡាយខ្លះដែលដឹកនាំបានតាមកំណើតរបស់វាតែច្បាប់រាប់បញ្ចូលជាអចលវត្ថុដែរហៅថា អចលវត្ថុតាមសន្មតរបស់ច្បាប់ ។ សិទ្ធិប្រត្យ័ក្សទាំងឡាយលើអចលវត្ថុក៏ទុកជាអចលវត្ថុដែរ ។

ចលវត្ថុ គឺរបស់ដែលដឹកនាំបាន ពីកំណើត, ដែលគេមិនបានចាត់ ឬមិនបានបញ្ចូលទៅក្នុងកិច្ចការនៃអចលវត្ថុទេ ហើយដែលច្បាប់មិនបានសន្មតទុកជាអចលវត្ថុទេ ។

**មាត្រា ៦៣១** ៖ អចលវត្ថុ ពីកំណើត គឺដីធ្លី, គេហស្ថានដែលសង់លើឫស ឬសង់ដោយបាយអរ និងអិដ្ឋ, សំណង់ទាំងឡាយបើរុះរើនឹងនាំឲ្យខូចខាតអស់តម្លៃក្រៃល ។

**មាត្រា ៦៣២** ៖ អចលវត្ថុពីភ័ព្វវាសនា នោះគឺវត្ថុទាំងពួងទោះបីពីកំណើតមកដឹកនាំបានក៏ត្រូវទុកអចលវត្ថុដែរព្រោះវាជាបរិវារនៃអចលវត្ថុ, វាត្រូវតែនៅជាប់នឹងអចលវត្ថុ, ជួនកាលពីព្រោះវានោះជារបស់ដែលកើតពីអចលវត្ថុ, ដូចយ៉ាង

ផលានុផលនៃរុក្ខជាតិគ្រប់យ៉ាងដែលមិនទាន់ច្រូតកាត់ចាកដើម ឬ មិនទាន់ដាច់ចេញអំពីដី ឬ ដើមឈើដែលកំពុងទ្រង់នូវផ្លែ, ជួនកាលពីព្រោះថានោះជារបស់ចាំបាច់ ឬ មានប្រយោជន៍ក្នុងអាជីវកម្មខាងកសិកម្ម, ខាងឧស្សាហកម្ម, ខាងពាណិជ្ជកម្មនៃមូលនិធិ, ដូចយ៉ាង សត្វចិញ្ចឹមយកផល, ចិញ្ចឹមសំរាប់លក់, សំរាប់អូស, សំរាប់ដឹកនាំ, សំរាប់ប្រណាំង ឬ សំរាប់ភ្ជួរ, រាស់, យន្ត, ឧបករណ៍ប្រដាប់ប្រដារនិងសម្ភារៈទាំងឡាយ, ដី, ពូជ និងកូនឈើ, ជួនកាលពីព្រោះវានោះជារបស់ដែលគេផ្សំចូលគ្នា នឹងអចលវត្ថុពីកំណើតដោយប្រការថាបើគេនឹងបំបែកវាចេញពីអចលវត្ថុឲ្យជាវត្ថុដឹកនាំបានលុះណាតែគេធ្វើឲ្យវាខូចរបៀប ដែលបានរៀបចំហើយ, ខូចប្រយោជន៍, ខូចសេចក្តីស្រួល និងខូចលំអរនៃអចលវត្ថុដែលចលវត្ថុនោះជួយទ្រទ្រង់មកដូចយ៉ាងទរ , ចង្ហូទឹក, កញ្ចក់ធំ, បដិមារ និងកោមព្យួរ ឬភ្ជាប់នឹងជញ្ជាំង, ពិដាន, និងក្តារជាដើម។

**មាត្រា ៦៣៣** ៖ អចលវត្ថុដោយសន្មតរបស់ច្បាប់នោះគឺវត្ថុដែលច្បាប់ដំកល់ឲ្យនៅក្នុងរបៀបជាអចលវត្ថុពីកំណើត, ថ្វីបើវាជាវត្ថុដិតនាំបាន ។ អចលវត្ថុទាំងឡាយនោះគឺទូកដែលមានចំណុះពី ៥០០ហាបឡើងទៅផ្ទះដែលមានចំណុះដូចគ្នានិងសិទ្ធិប្រត្យ័ក្សលើអចលវត្ថុ ។

**មាត្រា ៦៣៤** ៖ សិទ្ធិប្រត្យ័ក្សដែលនឹងទុកជាអចលវត្ថុ ឬ ជាចលវត្ថុនោះក៏អាស្រ័យទៅតាមប្រភេទនៃវត្ថុដែលជាទីតាំងនៃសិទ្ធិនោះជាចលវត្ថុ ឬជាអចលវត្ថុដែរ ។

**មាត្រា ៦៣៥** ៖ ទ្រព្យ ជាអចលវត្ថុ និងសិទ្ធិប្រត្យ័ក្សអចលវត្ថុនោះជួនកាលអាចជារបស់ឯកជននៃជនតែម្នាក់ ឬ ច្រើននាក់មានហ៊ុនរៀងៗខ្លួនក្នុងទ្រព្យតែមួយនោះ ឬ ក្នុសិទ្ធិតែមួយនោះដែលនឹងញែកឲ្យបែកគ្នាមិនបានក៏មាន, ជួនកាលជារបស់សមូហភាពនៃអ្នកស្រុកមួយក្រុម ឬ ជារបស់ប្រជាជនទាំងអស់ក៏មាន ។

ទ្រព្យចំពូកទីមួយ (គឺទ្រព្យឯកជន) ត្រូវទុកជាកម្មសិទ្ធិឯកជនផ្ទាល់ខ្លួនម្នាក់ៗ, ទ្រព្យចំពូកទីពីរ(គឺទ្រព្យសមូហភាព) ត្រូវទុកជាសម្បត្តិសាធារណៈ និងសម្បត្តិឯកជននៃសមូហភាព ។

ក្នុងករណីទាំងឡាយនេះឯកជនក្តី សមូហភាពក្តី ត្រូវមានតែសិទ្ធិ ដូចមានវាយខាងក្រោមនេះលើអចលវត្ថុទាំងនោះ, ឯសិទ្ធិក្រៅពីនេះច្បាប់មិនទទួលស្គាល់សោះទេ ។

១. កម្មសិទ្ធិ

២. ភោគ (កិរិយាមានទ្រព្យ)

៣. ផលុភោគ

៤. សិទ្ធិប្រើប្រាស់ និងអាស្រ័យនៅ

៥. សេវភាព

៦. ការបញ្ចាំអចលវត្ថុ

៧. ហីប៉ូតែក

**មាត្រា ៦៣៦** ៖ ផលុភោគ, សិទ្ធិប្រើប្រាស់ និងអាស្រ័យនៅ, សេវភាព, ទាំងអស់នេះជាគ្រឿងធ្វើឲ្យសៅហ្មងដល់សិទ្ធិរបស់កម្មសិទ្ធិករ ឲ្យខានអាស្រ័យ

នៅដាច់មុខតែម្នាក់ឯងនូវកម្មសិទ្ធិរបស់ខ្លួនដោយខ្លួនព្រមព្រៀងដោយចេតនាផង ឬ ព្រមដោយច្បាប់បង្ខំមកផង ។ សិទ្ធិទាំងអស់នេះមានសំដែងក្នុងមាតិកាទី៣ ស្ដីពី “ អវយវភេទនៃកម្មសិទ្ធិដែលមិនមែនជាប្រតិភោគប្រត្យ័ក្ស” ទេ ។

ឯការបញ្ចាំនូវអចលវត្ថុ និងហីប៉ូតែកទាំងពីរនេះ ទើបត្រូវទុកជាប្រតិភោគប្រត្យ័ក្សសម្រាប់ការពារសេក្ដីប្ដេជ្ញា ដែលកម្មសិទ្ធិករបានដាក់អចលវត្ថុជាគ្រឿងធានាកុំឲ្យគេកែទៅនាបានគឺត្រូវតែប្រតិបត្តិតាមកាតព្វកិច្ចរបស់ខ្លួន ដើម្បីជាប្រយោជន៍ដល់អ្នកទទួលនូវហីប៉ូតែក ឬ ទទួលបញ្ចាំ ។ ហីប៉ូតែក និងការបញ្ចាំអចលវត្ថុនេះមានសំដែងក្នុងផ្នែកទី ២ ចំពូកត និង ៣ នៃមាតិកា ៤ គន្ថី ៣ ។

**មាត្រា ៦៣៧** ៖ ភោគី នៃសិទ្ធិប្រត្យ័ក្សអចលវត្ថុដែលច្បាប់ឲ្យបានផលនៃអចលវត្ថុនោះត្រូវបានកម្មសិទ្ធិនៃផលនោះដោយប្រការយ៉ាងនេះគឺផលនោះជាផលធម្មជាតិ, ភោគីត្រូវចេញបានក្នុងសម័យដែលមានផ្លែ, បើផលនោះជាផលស៊ីវិល, ភោគីត្រូវយកផលនោះមួយថ្ងៃម្ដងៗ ។

ផលធម្មជាតិនោះគឺផលិតផលដែលកើតអំពីដីធ្លី ឬ សត្វស្រុកភោគីត្រូវស៊ីផលនោះតាមរូបកំណើតរបស់វា, ផលស៊ីវិលគឺផលទុន, ធនលាភ និងការប្រាក់, ភោគីត្រូវស៊ីផលនោះដោយយកជាប្រាក់ ។

**មាត្រា ៦៣៨** ៖ សាមញ្ញជនទាំងពួងអាចចាត់ចែងនូវទ្រព្យនិងសិទ្ធិទាំងឡាយដែលខ្លួនមានក្នុងឋានៈជាឯកជន បានដោយសេរីដោយគ្រាន់តែថាមុននឹងធ្វើកិច្ចការទាំងឡាយ, សាមញ្ញជនត្រូវតែគោរពតាមបទបញ្ញត្តិនៃច្បាប់ជាធម្មានុរូបផងតែប៉ុណ្ណោះ ។

**មាត្រា ៦៣៩** ៖ ដើម្បីនឹងគ្រប់គ្រងនូវសម្បត្តិរបស់ខ្លួន, សមូហភាពដែលមានសម្បត្តិត្រូវទុកដូចជាបុគ្គលម្នាក់ដែរហៅថានីតិបុគ្គល ដែលត្រូវមានបុគ្គលភាពមួយដែរ តែដាច់ដោយឡែកផ្សេងពីបុគ្គលភាពនៃសមាជិកម្នាក់ៗរបស់ខ្លួនហើយ ដែលត្រូវជាតំណាងសមាជិកទាំងនោះក្នុងការអាស្រ័យនូវសិទ្ធិទាំងឡាយរបស់ខ្លួនផង ។

ដើម្បីអភិបាល និងដើម្បីលក់ដូរ, ចាយវាយនូវសម្បត្តិខ្លួននោះ, ទោះជាសម្បត្តិសាធារណៈក្តី, ជាសម្បត្តិឯកជនក្តី, សមូហភាពត្រូវប្រព្រឹត្តតាមច្បាប់ដោយឡែកដែលមានចែងក្នុងអត្ថបទច្បាប់ទាំងពួងជាពិសេស ។

**មាត្រា ៦៤០** ៖ ទ្រព្យទាំងពួងណាដែលប្រយោជន៍សង្គមតម្រូវថាត្រូវតែរក្សាទុកតាមរូបមន្តកំណើតរបស់វា ដើម្បីជាគុណប្រយោជន៍ដល់សាធារណៈនៃសមូហភាពរាជការ, ហេតុនេះទ្រព្យទាំងនោះជាសម្បត្តិសាធារណៈនៃសមូហភាពរាជការ, ហេតុនេះទ្រព្យទាំងនោះ, បើនៅតែមានលក្ខណៈដូចពោលហើយនោះដរាបណា, អ្នកណាលក់ដូរចាយវាយទៅណាមិនបានជាដាច់ខាតដរាបនោះ។

**មាត្រា ៦៤១** ៖ ទ្រព្យណា ដែលមិនមានប្រយោជន៍ទូទៅដូចពោលមកនោះទេ ហើយដែលើអ្នកទាំងពួងក៏អាចមានគ្រប់គ្នាបានដែរ, ទ្រព្យនោះត្រូវទុកជាសម្បត្តិឯកជននៃសមូហភាព ។

**មាត្រា ៦៤២** ៖ ទ្រព្យទាំងឡាយនៃសម្បត្តិសាធារណៈ, នាកាលវាលែងមានប្រយោជន៍ដល់សង្គមហើយវា ក៏ត្រឡប់ទៅជាសម្បត្តិឯកជនវិញហើយវាលែងជាសម្បត្តិដែលគេលក់ដូរមិនបានទៀតហើយ ។

**មាត្រា ៦៤៣** ៖ ទ្រព្យដែលទំនេរឥតម្ចាស់និងទ្រព្យនៃជនដែលស្លាប់ឥតទាយាទ ឬ មតក៏ដែលគេបោះបង់ចោលត្រូវបានមកជាសម្បត្តិឯកជននៃរដ្ឋ ។

អចលវត្ថុឥតចុះបញ្ជីដែលភោគីទុកចោលឥតដាំឥតបង្កើតផលក្នុងកំណត់ ៥ ឆ្នាំជាប់គ្នា និងទ្រព្យដែលអ្នកទាំងពួងប្ដឹងថាលែងយកហើយដើម្បីឲ្យផុតអំពីការបង់ពន្ធដីក៏ត្រូវបានជាសម្បត្តិឯកជននៃរដ្ឋដែរ ។

## មាតិកា ទី ២
## អំពី កម្មសិទ្ធិ

**មាត្រា ៦៤៤** ៖ ដែលហៅថា កម្មសិទ្ធិ នោះគឺជាសិទ្ធិដែលច្បាប់ឲ្យអាស្រ័យ , ឲ្យចាត់ចែងនូវទ្រព្យណាមួយយ៉ាងផ្ដាច់ការ និងដាច់មុខតែម្នាក់ឯងដោយគ្រាន់តែឃាត់ថាកុំតែយកវត្ថុនោះទៅប្រើប្រាស់ដោយបទឯណា ដែលខុសនឹងច្បាប់បានហាមហើយ ។

**មាត្រា ៦៤៥** ៖ នរណាបង្ខំគេឲ្យផ្ទេរនូវទ្រព្យជាកម្មសិទ្ធិរបស់គេដល់ខ្លួនមិនបានឡើយ ប្រសិនបើការបង្ខំនោះមិនមែនបង្ខំយកមកធ្វើជារបស់រដ្ឋធ្វើជារបស់សាធារណប្រយោជន៍ទេ ហើយនិងមិនបានបង់សំណងចិត្តឲ្យសំនួនតាមទ្រព្យរបស់គេជាមុនទេ ។

**មាត្រា ៦៤៦** ៖ អ្នកមានកម្មសិទ្ធិនៃទ្រព្យអ្វីមួយរមែងមានសិទ្ធិត្រូវបានអ្វីៗទាំងអស់ដែលកើតពីទ្រព្យនោះនិងអ្វីៗទាំងអស់ ដែលដុះជាបរិវារនៃទ្រព្យនោះពីកំណើតក្ដីពីសិល្បៈនិម្មិត, សិទ្ធិនេះហៅថា សិទ្ធិដំណុះ (ពាក្យបូរាណថា ច្បាប់អាណាប) ។

# ចំពូក ១
# អំពីសិទ្ធិជំណុះ
## ផ្នែកទី ១
## អំពីសិទ្ធិ ជំណុះ ដែលកើតអំពីវត្ថុ

**មាត្រា ៦៤៧** ៖ ផលធម្មជាតិដែលកើត អំពីដី, ផលស៊ីវិល, ផារ ដែលកើតអំពីសត្វត្រូវបានទៅកម្មសិទ្ធិករដោយអំណាចនៃសិទ្ធិជំណុះនេះ ។

**មាត្រា ៦៤៨** ៖ ផលដែលកើតអំពីវត្ថុនឹងបានទៅកម្មសិទ្ធិលុះណាតែជននោះបានសងថ្លៃភ្ជួរ, ថ្លៃការងារ, ថ្លៃពូជដែលតតិយជនបានធ្វើមកនោះ ។

## ផ្នែកទី ២
## អំពីសិទ្ធិជំណុះលើអ្វីដែលជាប់ និងដែលផ្សំគ្នានឹងវត្ថុ

**មាត្រា ៦៤៩** ៖ អ្វីៗ ដែលដុះជាប់ និងដែលផ្សំគ្នា នឹងវត្ថុណាត្រូវបានកម្មសិទ្ធិករនៃវត្ថុនោះតាមវិធានដូចមានខាងក្រោមនេះ ។

### កថាខ័ណ្ឌទី ១

**មាត្រា ៦៥០** ៖ កម្មសិទ្ធិ នៃដីជាកម្មសិទ្ធិទាំងខាលើនិងទាំងខាងក្រោមដី ។

កម្មសិទ្ធិករអាចដាំ ដំណាំ និងសង់សំណង់ នៅលើដីតាមអធ្យាស្រ័យនៃខ្លួនបានវៀរតែការណាដែលមានច្បាប់ និងបទបញ្ជាទាំងឡាយហាមឃាត់ ។

កម្មសិទ្ធិករអាចសង់សំណង់ក្រោមដី និងជីករូងរករបស់អ្វីដែលកើតក្នុងដីតាម សេចក្តីប្រាថ្នានៃខ្លួនបានវៀរតែការណាដែលមានច្បាប់, ដេក្រេ និងបទបញ្ជាដែលទាក់ទងនឹងរ៉ែ ហើយនិងប៉ូលិស, បានហាមឃាត់ហើយ ។

**មាត្រា ៦៥១** ៖ សំណង់, ដំណាំ និងការងារទាំងឡាយដែលធ្វើលើដី ឬ ក្នុងដី បើគ្មានបន្ទាល់អ្វីថាជារបស់អ្នកដទៃទេ ត្រូវសន្មតថាជារបស់កម្មសិទ្ធិករធ្វើដោយធនធានរបស់ ខ្លួន ។

**មាត្រា ៦៥២** ៖ កម្មសិទ្ធិករនៃដីដែលមានសំណង់និងការងារធ្វើដោយសម្ភារៈដែលមិនមែនជារបស់ខ្លួនត្រូវចេញថ្លៃសម្ភារៈទាំងនឡឲ្យម្ចាស់គេវិញ, កម្មសិទ្ធិករអាចត្រូវទណ្ឌកម្មឲ្យសងជម្ងឺចិត្តគេផងក៏បាន, បើគប្បីឲ្យសង, តែម្ចាស់សម្ភារៈមិនមានសិទ្ធិនឹងអូសយករបស់ទាំងនេះវិញឡើយ ។

**មាត្រា ៦៥៣** ៖ នាកាលដំណាំ, សំណង់និងការងារទាំងពួង គឺតតិយជនបានសង់, បានធ្វើដោយសម្ភារះរបស់ខ្លួនកម្មសិទ្ធិករត្រូវមានសិទ្ធិនឹងទុករបស់ទាំងនោះ ឬ នឹងឲ្យអ្នកដទៃនោះរុះរើនាំយកចេញបាន ។

បើកម្មសិទ្ធិករឲ្យយកដំណាំ និងសំណង់ទាំងនោះចេញ, អ្នកដែលបានដាំ, បានសង់នោះត្រូវនាំយកចេញដោយបង់ខាតសោហ៊ុយ លើខ្លួននឹងទារសំណងចិត្តអ្វីមិនបានឡើយ, តតិយជននោះអាចនឹងត្រូវទណ្ឌកម្មឲ្យចេញសោហ៊ុយជម្ងឺចិត្តឲ្យកម្មសិទ្ធិករទៀតផងក៏បាន, ប្រសិនបើកិច្ចការនោះបានបណ្ដាលឲ្យមានព្យសនកម្មដល់កម្មសិទ្ធិករនៃដី ។

បើកម្មសិទ្ធិករចូលចិត្តទុកដំណាំនិងការងារទាំងនោះ, ជននេះត្រូវចេះថ្លៃសម្ភារះ និងថ្លៃការឲ្យគេដោយមិនគិតថាដីនោះអាចនឹងបានដំឡៃកើនឡើងទៀតតិច ឬ ច្រើនយ៉ាងណាឡើយ ។ ប៉ុន្តែ, បើដំណាំ, សំណង់ និងការងារទាំងឡាយដែលតតិយជនធ្វើនោះត្រូវតុលាការបានដកហូតហើយតែមិនដាក់ទណ្ឌកម្មឲ្យតតិយជន

សងផលមកម្ចាស់ដីវិញទេ ព្រោះតតិយជនធ្វើដោយចេតនាសុចរិតនោះ, កម្មសិទ្ធិករនឹងឲ្យគាស់ដំណាំ ឬ រើសំណង់ទាំងនោះចេញមិនបាន, ប៉ុន្តែកម្មសិទ្ធិករអាចនឹងចេញថ្លៃសម្ភារៈ និងថ្លៃការក៏បាន ឬ នឹងឲ្យសងប្រាក់ស្មើនឹងដំលៃដែលដីនោះត្រូវកើនឡើងដំឡៃទៀតក៏បាន ។

**មាត្រា ៦៥៤** ៖ ដីដែលដុះនៅទីមាត់ទន្លេ, មាត់ស្ទឹងបន្តិចម្តងៗ, មើលដឹងហៅថាល្បាប់ ។

ល្បាប់ត្រូវបានជាប្រយោជន៍នៃកម្មសិទ្ធិករដែលមានដីនៅមាត់ទឹកដែលនាវា ឬ ក្បូនចេញចូល, បណ្តែតបាន ឬ មិនបាន, តែបើចេញចូលបាន, បណ្តែតបាន, កម្មសិទ្ធិករត្រូវ ទុកផ្លូវមាត់ទឹក ឬ ផ្លូវសម្រាប់ទាញពួកនាវាឲ្យស្របតាមបទបញ្ជាទាំងឡាយ ។

**មាត្រា ៦៥៥** ៖ ល្បាប់ ដែលដុះ ដោយទឹងហូរ ដាច់ដីពីច្រាំងម្ខាងបន្តិចម្តងៗ មើលមិនដឹងទៅដុះឯច្រាំងម្ខាងត្រូវបានទៅកម្មសិទ្ធិករនៃច្រាំងដែលដុះ ។ ឯកម្មសិទ្ធិករនៃច្រាំងដែលខាតដីដោយទឹកនៅនាំទៅនោះនឹកមកទាមទារយកដីនោះមិនបានទេ ។

បទបញ្ញត្តិនេះមិនតម្រូវឲ្យអនុវត្តលើល្បាប់ក្នុងសមុទ្រ ដែលប្រែប្រួលដោយទឹក សមុទ្រនោះឡើយ ។

**មាត្រា ៦៥៦** ៖ កម្មសិទ្ធិករនៃបឹង ឬ ត្រពាំងត្រូវរក្សាតែដីត្រឹមនាទីទឹកដែលស្រក និងចំនួនទឹកដែលសល់ពីស្រក ។

ផ្ទុយមកវិញកម្មសិទ្ធករនៃបឹង, ត្រពាំងក៏មិនត្រូវមានសិទ្ធិបានដីមាត់ច្រាំងដែលលិចទឹកក្នុងពេលជំនន់ខុសធម្មតាដែរ ។

**មាត្រា ៦៥៧** ៖ ប្រសិនបើទន្លេ ឬស្ទឹង, ព្រែកដែលនាវាចេញចូលបានក្តី,មិនបានក្តី, មានជំនន់ភ្លាមៗឲ្យបាត់ដីមាត់ទឹកមួយកន្លែងធំចំណាំបាន ហើយនាំទៅផ្គាប់នឹងដីខាងក្រោមទឹក ឬ នឹងត្រើយម្ខាង, កម្មសិទ្ធិករដែលបាត់ដីនោះនឹងទារយកដីខ្លួនវិញបានតែត្រូវឲ្យប្តឹងទារក្នុងឆ្នាំនោះបើរំលងមួយឆ្នាំទៅបណ្តឹងទាមទារនោះមិនត្រូវទទួលឡើយ លើកមួយតែកម្មសិទ្ធកម្មនៃដីដែលមានល្បប់ដុះនោះមិនទាន់បានកាន់យកជាភោគរបស់គេនៅឡើយ ។

**មាត្រា ៦៥៨** ៖ កោះធំ, កោះតូចទាំងឡាយ, ដី ដែលដុះក្នុងផ្ទៃទន្លេ ឬស្ទឹង, ព្រែកដែលជាទីអាចដើរ, អាចបណ្តែតនាវា, ក្បូនបានត្រូវបានមករដ្ឋតាមបទបញ្ញាដែលមានជាធរមាន ។

**មាត្រា ៦៥៩** ៖ កោះធំ, កោះតូចទាំងឡាយនិងដីដែលដុះក្នុងស្ទឹង, ព្រែកមិនជាទីដើរ, បណ្តែតនូវក្បូនទេត្រូវបានទៅកម្មសិទ្ធិករដែលមានដីនៅមានស្ទឹង, មាត់ព្រែកខាងទីកោះដុះនោះបើកោះមិនដុះជ្រុលទៅម្ខាងទេ, នោះត្រូវបានទៅកម្មសិទ្ធិករដែលមានដីនៅត្រើយទាំងពីរខាងយកតាមបន្ទាត់ដែលគេសន្មតថាពុះពាក់កណ្តាលស្ទឹងជាប្រមាណ ។

**មាត្រា ៦៦០** ៖ ប្រសិនបើស្ទឹង ឬ ទន្លេណាមួយបែកដៃថ្មីកាត់នឹងឱបដីជារបស់កម្មសិទ្ធិករណាម្នាក់ដែលនៅមាត់ទឹកឲ្យទៅជាកោះ, កម្មសិទ្ធិករនោះនៅតែ

មានកម្មសិទ្ធិលើដីដែលជាប់នោះដដែលទោះបីកោះដែលដុះថ្មីនោះនៅក្នុងទន្លេ, ស្ទឹង, ជាទីដែលនាវាដើរបាន, ក្បូនបណ្តែតបានក្តី ។

**មាត្រា ៦៦១** ៖ ប្រសិនបើទន្លេ, ស្ទឹង ឬ ព្រែកណាមួយជាទីដែលនាវាដើរបាន, ក្បូនបណ្តែតបានហើយបែកមានផ្លូវថ្មីចោលផ្លូវចាស់ទៅ, កម្មសិទ្ធិករនៅមាត់ទឹកទាំងឡាយនោះអាចនឹងយកផ្លូចចាស់ដែលគោកនោះបាន, ម្នាក់ៗត្រូវបានតាមសិទ្ធរបស់ខ្លួនរហូតដល់បន្ទាត់ដែលប្រមាណថាពុះកណ្តាលស្ទឹងនោះ ។ ថ្លៃដីនៃផ្លូវចាស់នោះត្រូវចាងហ្វាងសាលាដំបូងទីនោះតាំងអាជ្ញាកណ្តាលឲ្យទៅពិនិត្យកាត់ថ្លៃតាមសេចក្តីសុំពីរាជការខែត្រ ឬ ពីភាគីនានាដែលមានប្រយោជន៍នឹងទៅនោះ ។

បើកម្មសិទ្ធិករនៅមាត់ទឹកនោះមិនចង់បានដើរនោះតាមថ្លៃ ដែលអាជ្ញាកណ្តាលកាត់ទេ, រាជការត្រូវឡាយឡុងផ្លូវចាស់នោះឲ្យសាធារណជន ។ ថ្លៃដែលបានមកអំពីលក់ដីនោះត្រូវយកទៅចែកឲ្យកម្មសិទ្ធិករ ដែលមានដីជាប់ទៅនោះតាមសមាមាត្រនៃដីដែលខូចខាតរៀងខ្លួនម្នាក់ៗ ។

**មាត្រា ៦៦២** ៖ ព្រាប និងត្រីឯណាដែលចេញចោលកន្លែងចាស់ ហើយចូលក្នុងទ្រុង, ក្នុងត្រពាំង, ក្នុងបៀ គេឯងឯទៀត, បើកម្មសិទ្ធិករនៃទ្រុង, ត្រពាំង, បៀនោះមិនបានល្បួងលួងបញ្ឆោត, ណែនាំយកទៅដោយឧបាយកលយ៉ាងណាទេ, ព្រាបនោះ, ត្រីនោះ ត្រូវបានជារបស់កម្មសិទ្ធិករនៃទ្រុង, ត្រពាំង, បៀរនោះ ។

## កថាខណ្ឌទី ២
## អំពីសិទ្ធិដំណុះជាប់នឹងចលវត្ថុ

**មាត្រា ៦៦៣** ៖ នាកាលវត្ថុឯណាដុះចេញមកពីចលវត្ថុពីរជារបស់កម្មសិទ្ធិករពីរនាក់ផ្សេងគ្នា, សិទ្ធិដំណុះនោះត្រូវចែកគ្នាតាមគន្លងយុត្តិធម៌ជាធម្មតា ។

**មាត្រា ៦៦៤** ៖ ជនទាំងឡាយណាយកសម្ភារៈរបស់អ្នកដទៃទៅប្រើប្រាស់មិនឲ្យម្ចាស់របស់គេដឹង, ជនទាំងឡាយនោះអាចនឹងត្រូវទណ្ឌកម្មឲ្យបង់ជម្ងឺចិត្តឲ្យគេក៏បាន, បើគួរឲ្យបង់, បើឃើញថាមានសេចក្ដីល្មើសជាបទអាជ្ញាផងអាចនឹងត្រូវចោទប្រកាន់ជាបទអាជ្ញាទៀតក៏បាន ។

## ចំពូក ២
## អំពីកម្មសិទ្ធិករ រួមគ្នា ឬសហកម្មសិទ្ធិ

**មាត្រា ៦៦៥** ៖ សហកម្មសិទ្ធិករទាំងឡាយ អាចនឹងប្រើប្រាស់ជាមួយគ្នានូវសិទ្ធិជាកម្មសិទ្ធករលើទ្រព្យណាមួយបានគឺម្នាក់ៗបានមួយហ៊ុនគិតតាមចំនួនតែមិនគិតតាមសម្ភារៈទេ, យ៉ាងនេះអ្នកទាំងនោះឈ្មោះថាមានភាពនៃអវិភាគកម្ម(គឺភាពចែកគ្នាមិនដាច់) ។

**មាត្រា ៦៦៦** ៖ ហ៊ុន នីមួយៗ ត្រូវសន្មតថាស្មើគ្នា ។

សហកម្មសិទ្ធិករម្នាក់ៗមានសិទ្ធិ និងបន្ទុកជាកម្មសិទ្ធិដោយសារហ៊ុនខ្លួនអាចនឹងលក់ដូរ ឬ បញ្ចាំបានហើយបំណុលក៏អាចរឹបអូសយកហ៊ុននោះបានដែរ ។

**មាត្រា ៦៦៧** ៖ សហកម្មសិទ្ធិករ គ្រប់គ្រងនូវរបស់នោះជាមួយគ្នាលើកមួយតែកាលណាមានសេចក្ដីព្រមព្រៀងគ្នាផ្សេងនេះទៅវិញ ។

ប្រសិនបើភាគច្រើនមិនបានសម្រេចផ្សេងពីនេះទេ, បណ្តាសហកម្មសិទ្ធិករទាំង ឡាយនោះ, សហកម្មសិទ្ធិករម្នាក់ៗត្រូវមាននាទីនឹងធ្វើនូវកិច្ចការគ្រប់គ្រងដូចជាជួសជុលថែទាំនិងដាំដំណាំជាដើម ។ ការទាំងឡាយណាដែលសំខាន់ជាងនេះទៅទៀតដូចជាផ្លាស់ដំណាំនិងជួសជុលជាដើម, សហកម្មសិទ្ធិករអាចនឹងសម្រេចបានលុះណាតែភាគច្រើននៃសហកម្មសិទ្ធិករជាអ្នកតំណាងនៃចំណែករៀងខ្លួនបូករួមមកបានជាងពាក់កណ្តាលភាគនៃរបស់នោះព្រមព្រៀងផង ។

**មាត្រា ៦៦៨** ៖ កម្មសិទ្ធិករម្នាក់ៗអាចរំពៃមើល, ថែទាំប្រយោជន៍រួមបាន។ ម្នាក់ៗត្រូវអាស្រ័យ និងប្រើប្រាស់នូវរបស់នោះត្រឹមព្រំដែនដែលស្របនឹងសិទ្ធិឯទៀត ។

ទោះនឹងលក់ដូរ, នឹងបង្កបង្កើននូវសិទ្ធិប្រត្យ័ក្ស ឬនឹងផ្លាស់ប្តូរមុខការដែលត្រូវប្រើប្រាស់របស់នោះយ៉ាងណាៗ, សហកម្មសិទ្ធិករទាំងអស់ត្រូវព្រមព្រៀងគ្នាធ្វើទាំងអស់គ្នាទើបបានលើកមួយតែករណី ដែលអ្នកទាំងអស់គ្នាបានព្រមព្រៀងគ្នាជាឯកច្ឆ័នតាំងច្បាប់ផ្សេងពីរឿងនេះទៅវិញ ។

**មាត្រា ៦៦៩** ៖ សោហ៊ុយបង់ខាតក្នុងការគ្រប់គ្រង, ពន្ធដារ និងបន្ទុកឯទៀតដែលកើតចេញតាមសមាមាត្រ នៃចំណែករៀងៗខ្លួនរៀរតែមានសេចក្តីសម្រេចផ្សេងដែលផ្ទុយនឹងបញ្ញត្តិនេះ ។

ថាបើនរណាមួយបានបង់លើសហួសពីចំណែកខ្លួន អ្នកនោះត្រូវទារពីអ្នកឯទៀតតាមសមាមាត្រដូចគ្នា ។

**មាត្រា ៦៧០** ៖ បើគ្មានកិច្ចសន្យា ថាត្រូវតែនៅក្នុង "អវិភាគកម្មទេ ឬ វត្ថុនោះមិនបំរុងទុកដើម្បីគោលបំណងណាមួយជានិរន្តរ៍ទេ, កម្មសិទ្ធិករម្នាក់ៗមានសិទ្ធិនឹងបង្ខំឲ្យចែកហ៊ុនបាន ។

**មាត្រា ៦៧១** ៖ ជនណាក៏ដោយមិនអាចនឹងបង្ខំឲ្យនរណានៅក្នុង "អវិភាគកម្ម" បានទេ ហើយកម្មសិទ្ធិករម្នាក់ៗអាចនឹងនាំអាទិឲ្យចែកហ៊ុនគ្នាបានជាដរាប។

សហាកម្មសិទ្ធិករ អាចនឹងទុបហ៊ុនទាំងអស់ឲ្យនៅក្នុងភាពអវិភាគកម្មក្នុងមួយកាលបានតែបើនឹងទុបឲ្យហួសពី៥ឆ្នាំទៅមិនបានទេ, ក្រែងតែធ្វើសញ្ញាជាថ្មីទៀតទើប ។

**មាត្រា ៦៧២** ៖ កាលបើវត្ថុនោះត្រូវចែកគ្នាតាមរូបដើម, លក់តាមស្ម័គ្រចិត្តទាំងអស់ ឬ លក់ឡាយឡុងហើយចែកថ្លៃគ្នា ឬ មួយក៏អ្នកណាម្នាក់ ឬ ច្រើននាក់ទទួលយកនូវចំណែកអ្នកឯទៀត លើខ្លួនគ្រានោះសហាកម្មសិទ្ធិត្រូវអស់មានហើយ ។

បើសហាកម្មសិទ្ធិករ មិនព្រមព្រៀងគ្នាអំពីបែបដែលចែកនោះអ្នកទាំងនោះត្រូវប្ដឹងឲ្យតុលាការបង្គាប់ឲ្យចែកវត្ថុគ្នាតាមរូបដើមរបស់វា, ថាបើវត្ថុនោះមិនអាចចែកគ្នាបានទេ ព្រោះវានឹងនាំឲ្យខូចតម្លៃច្រើន, ត្រូវឲ្យតុលាការបង្គាប់ឲ្យលក់ឡាយឡុងក៏បាន, លក់ឲ្យ សហាកម្មសិទ្ធិករផងគ្នាក៏បាន ។

**មាត្រា ៦៧៣** ៖ ជាពិសេស, ភាពអវិភាគកម្មដែលត្រូវនៅអស់កាលជានិច្ចនិងមិនអស់ទៅដោយសារការបែងចែកនោះគឺវត្ថុដូចមានខាងក្រោយ ៖

១. ដី និងគេហស្ថានទាំងឡាយ ដែលឧទ្ទិសចំពោះសាសនា ។

២. ភាគនៃដីដែលជាទីបំរើទ្រព្យទាំងឡាយដូចជា ផ្លូវថ្នល់, ផ្លូវទឹកជាដើម ។ល។

## ចំពូក ៣
## អំពីអន្យសិទ្ធិភាព (របស់ពាក់កណ្តាល)

**មាត្រា ៦៧៤** ៖ សព្ទថា " អវិភាគកម្ម" នេះបើនិយាយពីកំពែង ឬ ជញ្ជាំង ហៅថា អន្យសិទ្ធិភាព ។

### ផ្នែកទី ១
### អំពីជញ្ជាំងអន្យសិទ្ធិ

**មាត្រា ៦៧៥** ៖ ការជួសជុល និងការធ្វើ ជញ្ជាំងអន្យសិទ្ធិណាមួយឡើងវិញ ជាភារៈនៃអ្នកទាំងឡាយដែលមានសិទ្ធិលើរបស់នោះតាមសមាមាត្រនៃសិទ្ធិរបស់ខ្លួនម្នាក់ៗ ។ សហកម្មសិទ្ធិករទាំងពួងកាលបោះបង់ អន្យសិទ្ធិរបស់ខ្លួនហើយ អាចលែងជួយជួសជុល ឬ ធ្វើឡើងវិញនូវជញ្ជាំងនោះបានឲ្យតែជញ្ជាំអន្យសិទ្ធិ នោះលែងទ្រទ្រង់នូវផ្ទះរបស់ខ្លួនហើយ ។

**មាត្រា ៦៧៦** ៖ សហកម្មសិទ្ធិករម្នាក់ៗមិនអាចរូងជញ្ជាំងអន្យសិទ្ធិ ឬ ធ្វើអ្វីផ្ទប់, ប៉ែ្អក នឹងជញ្ជាំងនោះដោយម្ចាស់ម្ខាងមិនបានព្រមផងបានទេ ឬ, ថាបើម្ចាស់ម្ខាងរឹងត ឬ មិនព្រមហើយខ្លួនក៏មិនបានប្តឹងសុំឲ្យអាជ្ញាកណ្តាលទៅពិនិត្យសំរេចចាត់ការជាចាំបាច់សិនដើម្បីកុំឲ្យការរូបរបស់ខ្លួនបង្ខូចសិទ្ធិរបស់គេនោះក៏មិនបានដែរ ។

**មាត្រា ៦៧៧** ៖ កម្មសិទ្ធិករទាំងពួងដែលតជញ្ជាំងណាមួយអាចធ្វើជញ្ជាំងនោះឲ្យជារបស់អន្យសិទ្ធិទាំងអស់ ឬ ខ្លះដោយចេញឲ្យទៅកម្មសិទ្ធិករនៃជញ្ជាំង

នោះនូវថ្លៃជញ្ជាំងពាក់កណ្តាល ឬ ថ្លៃភាគជញ្ជាំងដែលខ្លួនចង់ឲ្យទៅជារបស់អឌ្ឍសិទ្ធិនិងថ្លៃដីដែលសង់ជញ្ជាំងនោះផង ។

**មាត្រា ៦៧៨** ៖ សហកម្មសិទ្ធិករអាចសង់ផ្ទាប់នឹងជញ្ជាំងអឌ្ឍសិទ្ធិបាន ហើយដាក់ធ្នឹម, រត, រនូត, ឲ្យជិតពេញកម្រាស់ជញ្ជាំងដោយទុកឲ្យសល់តែ ៥ សង្ទីម៉ែត្របាន, តែការនេះមិនត្រូវធ្វើឲ្យខូចដល់សិទ្ធិនៃអ្នកម្ខាងឡើយ ប្រសិនបើអ្នកម្ខាងនោះចង់សង់ពីខាងម្ខាងត្រង់កន្លែងជាមួយគ្នានោះមកវិញដែរ, អ្នកម្ខាងនោះនឹងបង្គាប់ឲ្យដាប់ ធ្នឹម, រត, រនូត នោះបន្ថយមកត្រឹមពាក់កណ្តាលជញ្ជាំងនោះវិញក៏បាន ។

**មាត្រា ៦៧៩** ៖ សហកម្មសិទ្ធិករអាចនឹងលើកជញ្ជាំងអឌ្ឍសិទ្ធិឲ្យខ្ពស់ឡើងទៀតបាន, តែអ្នកនោះត្រូវចេញថ្លៃការ្យ និងសាហ៊ុយថ្លៃធ្វើ និងថ្លៃថែទាំជញ្ជាំងដែលហួសពី កំពស់ដើមនោះតែម្នាក់ឯង, មួយទៀតត្រូវឲ្យចេញសំណងចិត្តនៃបន្ទុកដោយហេតុមកពីមានសំណង់ខ្ពស់ហួសទៅលើនោះ, និងឲ្យសមតាមតម្លៃផង ។

**មាត្រា ៦៨០** ៖ បើជញ្ជាំងអឌ្ឍសិទ្ធិមិនមាំ, មិនអាចទ្រទ្រង់នូវទម្ងន់កំពស់ទៅលើនោះបានទេ, អ្នកដែលចង់ធ្វើឲ្យខ្ពស់ឡើងទៅលើទៀតនោះត្រូវរុះរើធ្វើជាថ្មីទាំងអស់ឡើងវិញ ។ ការដាច់បង់ទាំងប៉ុន្មាននៅលើខ្លួន ។ ឯកំរាស់ជញ្ជាំងដែលត្រូវធ្វើលើសពីកំរាស់ដើមនោះត្រូវសង់ដាក់ខាងដីខ្លួន។

**មាត្រា ៦៨១** ៖ អ្នកម្ខាង, ដែលមិនបានជួយសង់ឲ្យខ្ពស់ឡើងទេនោះបើត្រូវការនឹងយកសំណង់នោះទុកជារបស់អឌ្ឍសិទ្ធិនៃខ្លួនដែរ, ត្រូវចេញថ្លៃសំណង់ពាក់

កណ្តាល និងថ្លៃដីដែលចូលទៅក្នុងកម្រាស់ជញ្ជាំងលើសពីកំរាស់ដើមនោះឲ្យគេទៀតបាន ។

## ផ្នែកទី ២
## អំពីស្លាមភ្លោះ, របង, ភ្លឺ អឡ្ឍសិទ្ធិ

**មាត្រា ៦៨២** ៖ កំពែង អឡ្ឍសិទ្ធិទោះជាស្នាមភ្លោះក្តី, ទោះជារបងក្តី, ទោះជាភ្លឺក្តី ត្រូវម្ចាស់កំពែងរួមនោះចេញសាហ៊ុយថែទាំរួមគ្នា, តែបើសហកម្មសិទ្ធិករណាម្នាក់មិនចង់ចេញសាហ៊ុយថែទាំនោះទេ,សហកម្មសិទ្ធិករនោះអាចមិនចេញបានដោយលះបង់អឡ្ឍសិទ្ធិរបស់ខ្លួនចោលតែប៉ុណ្ណោះ ។

ក៏ប៉ុន្តែបើស្នាមភ្លោះ ឬភ្លឺនោះជាទីសំរាប់បង្ហូរទឹកជាធម្មតាទៅ ហើយសហកម្មសិទ្ធិករ នឹងលះបង់អឡ្ឍសិទ្ធិរបស់ខ្លួនមិនបានឡើយ ។

**មាត្រា ៦៨៣** ៖ កម្មសិទ្ធិករ, ដែលមានដី ជាប់នឹងស្នាមភ្លោះ, របង ឬ ភ្លឺក្តីណាមួយដែលមិនជារបស់អឡ្ឍសិទ្ធិទេ, នឹងបង្ខំម្ចាស់ស្នាមភ្លោះ, ម្ចាស់របង, ម្ចាស់ភ្លឺនោះឲ្យព្រមដាក់នូវស្នាមភ្លោះ, របង ឬ ភ្លឺនោះជារបស់អឡ្ឍសិទ្ធិឲ្យខ្លួនពុំបានឡើយ ។

**មាត្រា ៦៨៤** ៖ សហកម្មសិទ្ធិករម្នាក់បណ្តា សហកម្មសិទ្ធិករទាំងឡាយ អាចនឹងរុះរើរបង ត្រឹមព្រំដីខ្លួនចេញបានតែត្រូវធ្វើជញ្ជាំងត្រង់ព្រំដីខ្លួននោះឡើងវិញ ។

បើស្នាមភ្លោះ ឬភ្លឺអឡ្ឍសិទ្ធិនោះគ្រាន់តែជាកំពែងទេសហកម្មសិទ្ធិករនោះ អាចធ្វើដូចគ្នាខាងលើនេះបានដែរ ។

## ចំពូកទី ៤
## អំពីទ្រព្យវត្ត

**មាត្រា ៦៨៥** ៖ ទ្រព្យវត្ត ជាទ្រព្យរបស់ពុទ្ធមាមកៈ ចំណុះជើងវត្តទាំងអស់គ្នា ។ ទ្រព្យនេះនឹងលក់ ដូរ ចាយ វាយ យ៉ាងណាពុំបានឡើយ ហើយមិនមានកំណត់អាជ្ញាយុកាលផង ។

**មាត្រា ៦៨៦** ៖ ទ្រព្យវត្តនឹងជួល ឬ ប្រវាស់បានតែផលទុនដែលបានមកពីការជួល ឬ ប្រវាស់នេះត្រូវទុកសម្រាប់តែកិច្ចការក្នុងសាសនាប៉ុណ្ណោះ ។

**មាត្រា ៦៨៧** ៖ ការគ្រប់គ្រងនូវទ្រព្យវត្តុជាភារៈរបស់សហគមន៍ពុទ្ធមាមកទាំងអស់គ្នា ។ អ្នកទាំងនោះអាចចាត់អាចារ្យ ឬ អ្នកតំណាងណាម្នាក់ឲ្យមានសិទ្ធិក្ដីក្ដាំងដល់តុលាការបាននៅវេលាណាដែលមានរឿងក្ដីពីទ្រព្យនេះ ។

## ចំពូកទី ៥
## អំពីលទ្ធកម្ម នូវកម្មសិទ្ធិ និងអំពីការផ្ទេរនូវកម្មសិទ្ធិ

**មាត្រា ៦៨៨** ៖ ជនម្នាក់អាចបានកម្មសិទ្ធិហើយអាចផ្ទេរកម្មសិទ្ធិនោះឲ្យជនម្នាក់ទៀតតាមសន្តតិកម្ម និងតាមកិច្ចសន្យាបាន ។ ម្យ៉ាងទៀតគេអាចធ្វើភោគៈឲ្យទៅជាកម្មសិទ្ធិបាន ។

### ផ្នែកទី ១
### អំពីលទ្ធកម្ម និងអំពីការផ្ទេរនូវកម្មសិទ្ធិអចលវត្ថុ និងសិទ្ធិប្រត្យ័ក្សអចលវត្ថុ

**មាត្រា ៦៨៩** ៖ លិខិត ដែលផ្ទេរ កម្មសិទ្ធិអចលវត្ថុ និងសិទ្ធិប្រត្យ័ក្សអចលវត្ថុនោះនឹងទុកជាត្រឹមត្រូវចំពោះតតិយជនបាន លុះណាតែលិខិតនោះមានសេចក្ដី

បញ្ជាក់ហើយចម្លងទុកក្នុងបញ្ជីការកម្មសិទ្ធិដី (registres de la propriete fonciere) ទៀតផង ។

**មាត្រា ៦៩០** ៖ សិទ្ធិនៃកម្មសិទ្ធិនឹងកើតឡើងបានលុះណាតែដីនោះមានចុះបញ្ជីការ អ៊ីម្មាទ្រីគុឡាស្យុង (Immatriculation) ឬ ក៏ដីនោះបានដាច់មកជាសម្បទានដោយអនុវត្តតាមព្រះរាជប្រកាសលេខ ៦០ ចុះថ្ងៃ ៣០ កក្កដា ១៩២៩ ។

**មាត្រា ៦៩១** ៖ ភោគៈ ដែលបានកាន់កាប់ជាប់ជាអង្វែង មកនោះនឹងត្រូវបានឡើងជាកម្មសិទ្ធិអចលវត្ថុតាមល័ក្ខខ័ណ្ឌដែលមានបញ្ញត្តិក្នុងមាតិកា ទី ៣ នៃគន្ថីនេះ ។

**មាត្រា ៦៩២** ៖ អចលវត្ថុឯណាដែលគេបោះបង់ចោលរវាងប្រាំឆ្នាំ, អចលវត្ថុនោះត្រូវទុកជារបស់រដ្ឋ វៀរលែងតែក្នុងករណីដែលដីនោះបានចុះក្នុងបញ្ជីអ៊ីម្មាទ្រីគុឡាស្យុង ហើយ ។

## ផ្នែកទី ២

## ព្រះរាជក្រមលេខ ២៥៤ ន.ស ចុះថ្ងៃ ២០-២-៥៨

**មាត្រា ១** ៖ បទបញ្ញត្តិទាំងឡាយដូចតទៅនេះ ត្រូវយកទៅអនុត្តក្នុងការផ្ទេរ ឬ លក់អចលនវត្ថុរវាងរវាងគូភាគីទាំងឡាយដែលមានម្នាក់ ឬ ច្រើននាក់មិនមានសញ្ជាតិជាខ្មែរ, ទោះបីជាភាគីនោះជារូបវន្តបុគ្គលក្តីជានីតិបុគ្គលក្តី, លើកមួយតែកាលណាមានអនុសញ្ញាអន្តរជាតិមានសេចក្តីផ្សេងពីនេះទៅវិញ ។

នីតិបុគ្គលខ្មែរនៃសិទ្ធិឯកជននោះ គឺក្រុមហ៊ុន ស៊ីវិល ឬ ជំនួញ, សមាគម

និងមូលស្ថានទាំងឡាយដែលច្បាប់ ឬ បទបញ្ញាជាធរមានបានកំណត់ន័យឲ្យយ៉ាងដូច្នេះ ។

អសារកម្មសិទ្ធិ ក៏ត្រូវអនុវត្តច្បាប់នេះដូចជាកម្មសិទ្ធិដែរ ។

**មាត្រា ២** ៖ កម្មសិទ្ធិ នៃអចលនវត្ថុ ក្រុង និងជនបទ, មានសំណង់ ឬ គ្មានសំណង់, ដែលជាសម្បត្តិឯកជន នៃសមូហភាព និងគ្រឹះស្ថានសាធារណៈអាចលក់ដូរតាមរបៀបសម្បទាន ឬ តាមរបៀបផ្សេងទៀតបានចំពោះតែរូបវន្តបុគ្គល ឬនីតិបុគ្គលខ្មែរ ។

**មាត្រា ៣** ៖ រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមិនមែនខ្មែរ អាចបង្កោន ឬផ្ទេរដោយមានថ្លៃ ឬ ឥតថ្លៃនូវកម្មសិទ្ធិនៃអចលវត្ថុរបស់ខ្លួនដោយសេរីចំពោះតែរូបវន្តបុគ្គល ឬ នីតិបុគ្គលខ្មែរបាន ។

**មាត្រា ៤** ៖ ក្រៅពីសិទ្ធិជាកម្មសិទ្ធិគេអាចលក់ដូរ ជួលពាក់កណ្ដាលនូវសិទ្ធិប្រត្យ័ក្សអចលវត្ថុទាំងឡាយដូចជាផលុភោគ, សេវភាព, ហីប៉ូតែក, បញ្ចាំ, ជួលល...។ ទោះអចលវត្ថុនេះជាសម្បត្តិឯកជន នៃសមូហភាពនិងគ្រឹះស្ថានសាធារណក្ដី, ទោះជារបស់បុគ្គលឯកជនក្ដីបានដោយសេរីឥតមានវិតត្បិត ព្រោះសញ្ជាតិនៃភាគីទេ ។

ក៏ប៉ុន្តែ រយៈវេលា នៃការព្រមព្រៀងលក់ដូរ, ជួលពាត់ទាំងអស់នេះមិនអាចឲ្យលើសពីកៅសិបប្រាំបួនឆ្នាំឡើយ ។

## ផ្នែកទី ៣
## អំពីលទ្ធកម្ម និងអំពីការផ្ទេរនូវកម្មសិទ្ធិចលវត្ថុ

**មាត្រា ៦៩៣** ៖ លិខិតផ្ទេរ កម្មសិទ្ធិចលវត្ថុត្រូវធ្វើតាមរូបមន្ត នៃលិខិតបញ្ជាក់ដើម្បីទុកជាបន្ទាល់ តនឹងតតិយជន, នេះចំពោះតែការណ៍ដែលច្បាប់តម្រូវឲ្យធ្វើដូចមានបញ្ញត្តិក្នុងមាតិកាដែលសំដែងអំពីសន្តតិកម្ម និងអំពីកិច្ចសន្យាស្រាប់ ។

**មាត្រា ៦៩៤** ៖ សិទ្ធិនៃកម្មសិទ្ធិចលវត្ថុ កើតមកពីភោគៈដោយសុចរិត ។

អ្នកមានចលវត្ថុ នៅដៃត្រូវតែគេសំគាល់ថាមានដោយសុចរិតជាដរាប, បើឈ្មោះណាប្រកាន់ថាមិនមែនទៅវិញ, ឈ្មោះនោះត្រូវរកបន្ទាល់នៃពាក្យរបស់ខ្លួនមកជាទីអាង ។

**មាត្រា ៦៩៥** ៖ អ្នកណាកាន់យកនូវចលវត្ថុអ្វីមួយ ដែលឥតម្ចាស់អ្នកនោះត្រូវបានជាកម្មសិទ្ធិករនៃវត្ថុនោះ ។

ក៏ប៉ុន្តែ បើការកាន់យកដោយបទឯណាដែលច្បាប់និងបទបញ្ជាទាំងឡាយបានហាមហើយ ឬ ដែលជាទីនាំឲ្យខូចសិទ្ធិអ្នកដទៃការកាន់យកនោះមិនត្រូវបាននូវកម្មសិទ្ធិឡើយ ។

**មាត្រា ៦៩៦** ៖ ចលវត្ថុ ឯណាដែលម្ចាស់លះបង់ហើយដោយមានបំណងថានឹងបោះបង់នូវកម្មសិទ្ធិជាប្រាកដ, ចលវត្ថុនោះនឹងនៅជាវត្ថុឥតម្ចាស់ ។

**មាត្រា ៦៩៧** ៖ សត្វព្រៃទាំងឡាយ, ដែលនៅមានសេរីភាពដរាបណា, ត្រូវទុកជាសត្វឥតម្ចាស់ដរាបនោះ ។

សត្វព្រៃណាមួយ (ដែលគេទាក់បាន) រត់រួចទៅ ហើយមានសេរីភាពឡើងវិញ, បើម្ចាស់វាមិនបានខ្វល់ខ្វាយរកភ្លាមៗទេ, ត្រូវទុកវាជាសត្វឥតម្ចាស់ ។

សត្វដែលគេផ្សាំងហើយ, បើរួចទៅជាសត្វព្រៃវិញ,ក៏ត្រូវទុកជាសត្វឥតម្ចាស់ដែរ។

**មាត្រា ៦៩៨** ៖ ត្រីក្នុងត្រពាំង និងក្នុងទីទឹកឯទៀតដែលជារបស់ឯកជនត្រូវទុកជាត្រីមានម្ចាស់ ។

**មាត្រា ៦៩៩** ៖ ឃ្មុំដែលហើរចាកបង្គក, បើម្ចាស់មិនតាមភ្លាមទេ ឬ ក៏លែងតាមហើយ, ក៏ក្លាយទៅជាឃ្មុំឥតម្ចាស់ដែរ ។

**មាត្រា ៧០០** ៖ អ្នកណាឃើញនូវវត្ថុណាមួយដែលគេបាត់ហើយកាន់យកនូវវត្ថុនោះ, អ្នកនោះត្រូវប្រាប់ម្ចាស់គេមួយរំពេច, បើមិនដឹងថាជារបស់នរណាទេ, ត្រូវឲ្យយករបស់នោះទៅប្តឹងអាជ្ញាធរមួយរំពេច ព្រមទាំងប្រាប់នូវកាលៈទេសៈទាំងឡាយដែលគប្បីឲ្យរកម្ចាស់ឃើញផង ។ អ្នកនោះអាចនឹងប្រគល់របស់នោះទៅអាជ្ញាធរក៏បាន ឬ នឹងរក្សាទុកនៅខ្លួនឯងក៏បាន ។ បើរបស់នោះមានតម្លៃមិនហួសពី ៥០ សេនទេអ្នកនោះមិនបាច់ប្តឹងក៏បានដែរ ។

**មាត្រា ៧០១** ៖ អ្នកណាបានរើសនូវរបស់អ្វីមួយ, អ្នកនោះត្រូវរក្សារបស់នោះទុកឲ្យបានល្អ។

បើការថែរក្សាជាទីនាំឲ្យដាច់ប្រាក់កាស ឬ បើទុកទៅវានឹងខូច ឬ វានៅនឹងដៃអាជ្ញាធរជាងមួយឆ្នាំហើយ, អាជ្ញាធរអាចនឹងលក់ឡាយឡុងនូវរបស់នោះបាន ។ ថ្លៃដែលលក់បានមកជាតាងស្នងរបស់ ។

**មាត្រា ៧០២** ៖ ក្នុងកំណត់មួយឆ្នាំគិតចាប់ពីថ្ងៃដែលបានប្តឹងដល់អាជ្ញាធរមក ឬ តាំងពីថ្ងៃដែលរើសបានមក, បើរកម្ចាស់មិនឃើញទេរបស់នោះត្រូវបានទៅអ្នករើស ។

បើរបស់នោះត្រូវប្រគល់ឲ្យម្ចាស់វិញ, អ្នករើសត្រូវបានសំណងសាហ៊ុយដែលខ្លួនបានដាច់បង់ប៉ុន្មានៗមកវិញ ។

**មាត្រា ៧០៣** ៖ អាឃ៏វត្ថុទាំងឡាយដែលមានទំនងឲ្យយល់ច្បាស់នៅពេលដែលឃើញវាថាជារបស់គេកប់ ឬ លាក់ទុកយូរហើយគ្មានម្ចាស់សោះ,ត្រូវទុកជាទ្រព្យកំណប់។

ទ្រព្យកំណប់នេះត្រូវបានជាកម្មសិទ្ធិនៃម្ចាស់អចលវត្ថុ ឬ ចលវត្ថុដែលជាអ្នកឃើញនូវកំណប់នោះ ។

អ្នកដែលឃើញត្រូវបានរង្វាន់ត្រឹមពាក់កណ្តាលតម្លៃនៃទ្រព្យកំណប់ ។

**មាត្រា ៧០៤** ៖ នាកាលជនណាម្នាក់យកវត្ថុធាតុដើមដែលមិនជារបស់ខ្លួនទៅធ្វើជាវត្ថុអ្វីមួយ, ថាបើឧស្សាហកម្មនោះមានតម្លៃច្រើនជាងវត្ថុធាតុដើម, វត្ថុធ្វើថ្មីនោះត្រូវបានទៅសិប្បករជាអ្នកធ្វើ, បើមិនដូច្នោះទេ, វត្ថុធ្វើថ្មីនោះត្រូវបានទៅម្ចាស់វត្ថុធាតុដើម ។ បើសិប្បករនោះមានចេតនាទុច្ចរិត ទោះបីឧស្សាហកម្មនោះមានតម្លៃច្រើនលើសតម្លៃវត្ថុធាតុដើមក្តី, តុលាការអាចនឹងបង្គាប់ឲ្យឲ្យវត្ថុដែលធ្វើនោះទៅម្ចាស់វត្ថុធាតុដើមបាន ។

បណ្តឹងទារសាហ៊ុយជម្ងឺចិត្ត និងបណ្តឹងដែលកើតពីការចម្រើនដោយឥតហេតុក៏នៅតែប្តឹងបានដែរ ។

**មាត្រា ៧០៥** ៖ នាកាលវត្ថុទាំងឡាយជារបស់ម្ចាស់ទីទៃៗពីគ្នាឲ្យចូលគ្នាជាសាច់មួយដល់បំបែកចេញពីគ្នាទៅវាខានខូចច្រើនមិនបាន ឬ ក៏ខានយជួលគេឲ្យអស់ឈ្នួល និងសាហ៊ុយក្រៃលទៅទៀតមិនបាន, ដូច្នេះម្ចាស់ទាំងឡាយនៃរបស់នោះត្រូវបានជាសហកម្មសិទ្ធិករនៃវត្ថុដែលធ្វើថ្មីនេះតាមសមាមាត្រនៃតម្លៃវត្ថុធាតុរៀងខ្លួន ដែលមានក្នុងវេលាលាយគ្នា ឬ បញ្ចូលគ្នានោះ ។

**មាត្រា ៧០៦** ៖ បើក្នុងរបស់ពីរមុខ ដែលយកទៅលាយគ្នា ឬ ផ្សំផ្គុំគ្នានោះរបស់មួយមុខគ្រាន់តែជាបរិវារនៃរបស់មួយមុខទៀតប៉ុណ្ណោះទេ, នោះវត្ថុធ្វើថ្មីទាំងមូលត្រូវបានទៅម្ចាស់វត្ថុធាតុដែលត្រូវយកទៅធ្វើជាគួរប្រធាន ។

**មាត្រា ៧០៧** ៖ សេចក្ដីដែលប្ដឹងសុំជម្ងឺចិត្តនិងសេចក្ដីដែលប្ដឹងសុំសំណងរបស់ជាបរិវារដែលយកទីប្រកនោះនៅជាសិទ្ធិនៃម្ចាស់របស់ដដែល ។

## មាតិកាទី៣
## អំពីភោគៈ (មានខត្ត)

**មាត្រា ៧០៨** ៖ ដែលហៅថា ភោគៈ នោះគឺជាសភាពការមួយដែលមានន័យថាកិរិយាកាន់កាប់នូវវត្ថុអ្វីមួយយ៉ាងដាច់មុខតែឯង និងបំពេញចំពោះវត្ថុនោះនូវកិច្ចការទាំង ឡាយដូចដែលកម្មសិទ្ធិករបានបំពេញហើយដែរ ។

**មាត្រា ៧០៩** ៖ នាកាលភោគីបានកាន់កាប់នូវភោគៈនោះដោយឥតប្រើវិហិង្សាទេ, ព្យាយាមកាន់កាប់ដោយសុចរិត, ឲ្យដឹងឮដល់សាធារណជន, ឥតអាក់ខាន,និងឥតមានព្រលាំទេ, ភោគៈនោះនឹងញ៉ាំងភាគីឲ្យមានអនុភាពចំពោះច្បាប់បាន ។

**មាត្រា ៧១០** ៖ ភោគៈ ដែលគេបានមកដោយវិហិង្សាមិនទុកជាភោគៈត្រឹមត្រូវតាមច្បាប់ឡើយ ។ ក៏ប៉ុន្តែបើកាលណាគេប្រើវិហិង្សាក្នុងពេលដែលមានតតិយជនឥតសិទ្ធិសោះមកដណ្តើមនោះ, វិហិង្សានេះគ្មានឥទ្ធិពលអ្វីទៅលើភោគៈដែលគេបានដោយសន្តិភាពតាំងពីដើមមកនោះទេ ។

**មាត្រា ៧១១** ៖ ភោគីត្រូវកាន់កាប់ដោយសុចរិតគឺថាភោគីមិនបានដឹងជាតតិយជនណាមានសិទ្ធិលើវត្ថុដែលខ្លួនកំពុងកាន់កាប់នោះសោះ ។

**មាត្រា៧១២** ៖ ភោគី ត្រូវកាន់កាប់វត្ថុទាំងនោះក្នុងទីសាធារណៈគឺថាភោគីនោះកាន់កាប់ឥតលាក់បិតបាំងទេ, អ្នកទាំងពួងដែលត្រូវបោះបង់តវ៉ាអំពីសិទ្ធិរបស់ខ្លួនលើវត្ថុនោះ, នឹងបានដឹងឮឃើញផងមិនខាន ។

**មាត្រា ៧១៣** ៖ ចំពោះរឿងអចលវត្ថុ, សេចក្តីដែលទុកជាប្រកាសឲ្យអ្នកផងទាំងពួងដឹងនោះគឺ ៖

១. ភោគីបានប្តឹងដល់មេឃុំជាចៅនាទីនៃអចលវត្ថុនោះ, បើអចលវត្ថុនោះគឺអ្នកប្តឹងមិនទាន់កាន់កាប់នៅឡើយទេ, មេឃុំត្រូវចេញបង្កាន់ដៃឲ្យ ។

២. ភោគីបានបង់ពន្ធដីជាទៀងទាត់ ។

**មាត្រា ៧១៤** ៖ សេចក្តីប្តឹងនោះត្រូវប្រាប់នូវទំហំដី, ប្រភេទដីនិងព្រំប្រទល់ដី ។ មេឃុំត្រូវចម្លងសេចក្តីនោះទាំងអស់ចុះក្នុងសៀវភៅសំរាប់កត់លិខិតបញ្ជាក់ហើយចុះហត្ថលេខាផង ។ បើដៅនោះមានគេចុះក្នុងបញ្ជីការអ៊ីម្មាទ្រីគុឡាស្យុងរួចហើយភោគីមិនអាចនឹងប្តឹងដូច្នោះបានឡើយ ។

**មាត្រា ៧១៥** ៖ ភោគីត្រូវកាន់កាប់ថែរក្សាភោគៈជានិរន្តរគឺថាត្រូវធ្វើនូវកិច្ចការទាំងពួងជាធម្មតាតាមសន្តាប់វាជាដរាបកុំបីបោះបង់ចោលឲ្យមានចន្លោះកាលដែលមិនគួរចោលឡើយហើយដែលផ្អុយនឹងដំណើរការនៃវត្ថុនោះទៅវិញផង ។

**មាត្រា ៧១៦** ៖ ការទុកអចលវត្ថុ ឲ្យនៅទំនេរខ្លះនឹងទុកជាបានកាន់កាប់ជាប់ ឬ មិនជាប់នោះស្រេចលើយោបល់តុលាការ ។ តុលាការត្រូវសង្កេតតាមប្រភេទនៃវត្ថុ, បើយើងយ៉ាងណាត្រូវអធិប្បាយហេតុយ៉ាងនោះក្នុងសាលក្រម ។

**មាត្រា ៧១៧** ៖ ការដែលទុកដីរិលហិល ឲ្យមានជីជាតិនោះនឹងទុកជាបោះបង់ចោលពុំទាន់បាន ។ កិរិយាកាន់កាប់នូវភោគៈតាមកាលសម័យដ៏គប្បីដូច្នេះក៏ឈ្មោះថាបានកាន់កាប់ជានិច្ចហើយ ។

**មាត្រា ៧១៨** ៖ ភោគីត្រូវកុំកាន់កាប់ភោគៈដោយព្រលាំគឺថាភោគី, ទោះកាន់កាប់ដោយខ្លួនឯងក្តី, ទោះឲ្យអ្នកដទៃធ្វើឲ្យក្តី, ត្រូវកាន់កាប់ឲ្យឃើញថាការនោះប្រាកដជាធ្វើដើម្បីខ្លួនក្នុងគុណភាពខ្លួនជាភោគីយ៉ាងដាច់មុខ, កុំឲ្យឃើថាការដែលធ្វើនោះគឺធ្វើដោយសារសិទ្ធិណាមួយផ្សេងទៅវិញ ។

**មាត្រា ៧១៩** ៖ ភោគៈនៅក្នុងដៃអ្នកណា, អ្នកនោះត្រូវតែពិរុទ្ធិថាជាកម្មសិទ្ធិករដោយធម្មានុរូប, ឈ្មោះណាប្រកាន់ថាសិទ្ធិនៃភោគីនោះដោយប្រការយ៉ាងណាៗ, ឈ្មោះនោះត្រូវរកស្មនៃសិទ្ធិរបស់ខ្លួនមកជាបន្ទាល់ ។

**មាត្រា ៧២០** ៖ ភោគៈនៅលើដៃអ្នកណា, អ្នកនោះត្រូវតែពិរុទ្ធិថាជាភោគីដោយសុចរិត, ប៉ុន្តែបើអ្នកដែលតវ៉ាពីភោគៈនោះជាកម្មសិទ្ធិករនៃដីដែលមានក្នុង

បញ្ជីអ៊ីម្មាទ្រីគុឡាស្ស៊ុងហើយ, ភោគីនោះត្រូវរកបន្ទាល់ឲ្យឃើញថាខ្លួនជាម្ចាស់ដីដោយសុចរិតវិញ ។

**មាត្រា ៧២១** ៖ នាកាលតុលាការដកហូតអចលវត្ថុពីភោគីទៅហើយ ឲ្យទៅកម្មសិទ្ធិករនៃដីអ៊ីម្មាទ្រីគុឡាស្ស៊ុង ឬ ឲ្យទៅភោគីដែលគប្បីបាន ឬ ឲ្យទៅសិទ្ធិវន្តនៃភោគីនោះ, បើភោគីចាញ់សេចក្តី, កាលកាន់កាប់នូវអចលវត្ថុនោះ, កាន់កាប់ដោយសុចរិត, តុលាការត្រូវឲ្យភោគីបានផលនៃអចលវត្ថុដែលខ្លួនបានយក ហើយមកទល់នឹងថ្ងៃដែលគេបានប្តឹងដល់តុលាការ, ថាបើអ្នកនោះកាន់កាប់មកដោយទុច្ចរិតទេ, តុលាការត្រូវឲ្យភោគីនោះបង្វិលផលនៃវត្ថុនោះទៅឲ្យគេវិញ ។

**មាត្រា ៧២២** ៖ ភោគីអាចនឹងផ្ទេរនូវសិទ្ធិរបស់ខ្លួនខ្លះ ឬ ទាំងអស់ឲ្យទៅអ្នកដទៃតាមសន្តតិកម្មមានបណ្តាំ ឬឥតបណ្តាំក៏បាន, តាមកិច្ចសន្យាក៏បានដោយគ្មានកែប្រែនូវសិទ្ធិដែលមិនទាន់មាំមួននោះព្រោះតែការផ្ទេរនោះឡើយ ។

លិខិតដែលផ្ទេរនូវភោគៈឲ្យគ្នានោះ, បើភោគៈនោះជាអចលវត្ថុ ឬ ជាសិទ្ធិប្រត្យ័ក្សអចលវត្ថុ, អាចនឹងយកជាសំអាងរវាងភាគីផងគ្នាបានលុះណាតែការផ្ទេរនោះបានធ្វើតាមរូបមន្តយថាភូត (សំបុត្របញ្ជាក់ ឬសំបុត្រសាការី) (ក្រ. ២៩. នស. ១៧-៨-៥៥) ។

**មាត្រា ៧២៣** ៖ ក្នុងរឿងអចលវត្ថុបើភោគីណាមានដីមួយកន្លែងដោយសន្តិភាព, ដោយសុចរិត, មានផ្សាយជាសាធារណៈ, ឥតព្រលាំក្នុងអំឡុង ៥ ឆ្នាំជាប់ៗគ្នាហើយ, ដីនោះជាដីទំនេរគ្មានក្នុងបញ្ជីការអ៊ីម្មាទ្រីគុឡាស្ស៊ុងថាជារបស់អ្នកឯកណាទេ, ភោគីនោះត្រូវឡើងជាកម្មសិទ្ធិនៃដីនោះជាធម្មានុរូប ។

ក្នុងរឿងចលវត្ថុ បើល័ក្ខខ័ណ្ឌទាំងឡាយ, ដែលបានបញ្ញត្តិមកដើម្បីឲ្យភោគៈនោះមានអានុភាពតាមផ្លូវច្បាប់, បានប្រកបព្រមគ្រប់សព្វហើយ, ភោគៈនឹងបានឡើងជាកម្មសិទ្ធិករក្នុងវេលាដែលផុតកំណត់មួយឆ្នាំ, ប៉ុន្តែភោគីត្រូវគោរពតាមបទបញ្ញត្តិមាត្រា ៧០០នៃក្រមនេះផងប្រសិនបើភោគៈនោះចូលក្នុងករណីដែលត្រូវគោរព ។

**មាត្រា ៧២៤** ៖ សិទ្ធិនៃភោគៈអចលវត្ថុនឹងឡើងទៅជាសិទ្ធិនៃកម្មសិទ្ធិនៅពេលដែលអចលវត្ថុនោះបានចុះក្នុងបញ្ជីការអ៊ីម្មាទ្រីគុឡាស្បុងរួចហើយ ។

**មាត្រា ៧២៥** ៖ ដីទាំងឡាយដែលភោគីបោះបង់ចោលក្នុងរវាង ៥ ឆ្នាំត្រូវធ្លាក់ទៅជាសម្បត្តិរដ្ឋ ។

## មាតិកា ទី ៤
## អំពីអវយវភេទនៃកម្មសិទ្ធិដែលមិនមែនជាប្រាតិភោគប្រត្យក្ស

**មាត្រា ៧២៦** ៖ វត្ថុណាជាកម្មសិទ្ធិនៃជនម្នាក់ហើយបានទៅជនម្នាក់ទៀតអាស្រ័យផល, វត្ថុនោះឈ្មោះថាមានអវយវភេទ ។

សិទ្ធិដែលនៅសល់ពីអវយវភេទនោះហើយដែលបានមកកម្មសិទ្ធិករហៅថាអាសារកម្មសិទ្ធិ។

# ចំពូក ទី១
# អំពីផលុភោគ

**មាត្រា ៧២៧** ៖ ផលុភោគ គឺកិរិយាអាស្រ័យនូវផលនៃអចលវត្ថុណាមួយ ដែលជាកម្មសិទ្ធិនៃអ្នកដទៃមានកំណត់កាល ដែលមិនឲ្យលើសពីអាយុនៃអ្នកបានសិទ្ធិអាស្រ័យផលនោះឡើយ ។

**មាត្រា ៧២៨** ៖ ផលុភោគ កើតមកអំពីច្បាប់ក៏មាន, កើតមកអំពីកិច្ចសន្យាក៏មាន ។ ផលុភោគនេះអាចកើតឡើងឥតកំណត់កាលក៏បានមានកំណត់កាលក៏បាន ឬ មានកំណត់ថារហូតដល់ថ្ងៃណាដែលបានសម្រេចនូវល័ក្ខខ័ណ្ឌណាមួយដូច្នេះក៏បាន ។

កិច្ចសន្យាអំពីផលុភោគ នឹងយកជាទីអាងបាន, សូម្បីតែរវាងភាគីផងគ្នាក៏ដោយ, ក៏ត្រូវធ្វើជាលិខិតតាមរូបមន្តយថាភូតដែរ(គឺមានបញ្ជាក់ ឬ ធ្វើនៅសាការី) លិខិតនេះនឹងយកជាទីអាងចំពោះតតិយជនបានតែនៅពេល ដែលលិខិតនេះចុះក្នុងបញ្ជីការអ៊ីម្មាទ្រីគុឡាស្យុងរួចហើយ ។ នេះចំពោះតែកិច្ចសន្យាដែលទាក់ទងនឹងអចលវត្ថុជាកម្មសិទ្ធិ (ក្រ, ២៩ នស. ១៧-៨-៥៥) ។

## ផ្នែកទី ១
## អំពីសិទ្ធិ ផលុភោគី

**មាត្រា ៧២៩** ៖ ផលុភោគីមានសិទ្ធិបរិភោគនូវផល្លានុផលទាំងពួងទោះជាផលធម្មជាតិក្តីនោះជាផលស៊ីវិលក្តីដែលកើតអំពីអចលវត្ថុដែលខ្លួនបានផលុភោគនោះ។

**មាត្រា ៧៣០** ៖ ផល្លានុផលធម្មជាតិ ណាកើតនៅលើដីក្នុងវេលាដែលបើកឲ្យស៊ីផល, ផល្លានោះត្រូវបានទៅផលុភោគី, ផល្លានុផលធម្មជាតិណាកើតឡើងក្នុងវេលាដែលត្រូវអស់សិទ្ធិស៊ីផល, ផល្លានុផលនោះត្រូវបានទៅអាសារកម្មសិទ្ធិករនៃដី ។ ឯការភ្ជួររាស់, សាបព្រោះ, ស្ទូងដាំនោះបើបានជាធ្វើហើយមិនត្រូវឲ្យគិតយកថ្លៃអំពីគ្នាទេ, ប៉ុន្តែបើមានអ្នកណាជួលពាត់ ឬ ប្រវះធ្វើក៏មិនត្រូវឲ្យអ្នកនេះខូចប្រយោជន៍ដែលត្រូវបានក្នុងវេលាដាក់ឲ្យស៊ីផលក្តី, ក្នុងវេលាអស់សិទ្ធិស៊ីផលក្តី ។

**មាត្រា ៧៣១** ៖ ឯផលស៊ីវិលត្រូវបានទៅផលុភោគីតាមសមាមាត្រនៃរយៈវេលាផលុភោគ ។

**មាត្រា ៧៣២** ៖ ផលុភោគី នឹងបរិភោគនូវផលនៃអចលវត្ថុនោះដោយខ្លួនឯង ឬ នឹងជួលពាត់, ប្រវះឲ្យទៅអ្នកដទៃ ឬ ផ្ទេរនូវសិទ្ធិនោះឲ្យទៅអ្នកដទៃដោយយកថ្លៃ ឬ ឥតយកថ្លៃបាន ។

បើជួលពាត់ ឬ ប្រវះឲ្យគេ, កិច្ចសន្យានោះនឹងហួសពី ៣ ឆ្នាំមិនបានទេ, បើផុតកិច្ចសន្យាលើកទីមួយ ហើយនឹងរើធ្វើកិច្ចសន្យាជួលជាថ្មីទៀតក៏កុំឲ្យលើសពីមួយឆ្នាំមុនថ្ងៃអស់សិទ្ធិដែរ ។

**មាត្រា ៧៣៣** ៖ ផលុភោគី ត្រូវអាស្រ័យផលដីដែលចំរើនដោយល្បាប់មកលើដី ខ្លួនបានផលុភោគនោះដែរ ។

**មាត្រា ៧៣៤** ៖ ផលុភោគី ប្រើប្រាស់នូវសេវភាពទាំងឡាយ និងសិទ្ធិទាំងឡាយទូទៅដែលកម្មសិទ្ធិករអាចប្រើប្រាស់បាន, ផលុភោគីប្រើប្រាស់នូវសិទ្ធិទាំងនោះបានដូចជាកម្មសិទ្ធិករដែរ ។

**មាត្រា ៧៣៥** ៖ ផលុភោគី ត្រូវបានសិលាជាតិ ដែលកើតក្នុងដីខ្លួនត្រូវបានផលុភោគនោះដូចជាកម្មសិទ្ធិករដែរ ។

**មាត្រា ៧៣៦** ៖ ផលុភោគី ទារបំណុល ដែលសម្បទានិកជំពាក់កម្មសិទ្ធិករព្រោះជួលអណ្តូងយករ៉ែក្នុងនាទីដីដែលខ្លួនត្រូវបានផលុភោគនោះបាន,ទោះជួលពីកាលណាៗមកដែលនាំឲ្យមានបំណុលនោះក៏ដោយ ។

**មាត្រា ៧៣៧** ៖ អាសារកម្មសិទ្ធិមិនអាចធ្វើឲ្យខូចខាតសិទ្ធិនៃផលុភោគីបាន ឡើយ ។

ខាងផលុភោគីវិញ, លុះដល់វេលាអស់សិទ្ធិស៊ីផលហើយ, ក៏មិនអាចទាមទារសំណងចិត្តអ្វីព្រោះថាខ្លួនបានតុបតែងអចលវត្ថុ ដែលដាក់ផលុភោគរបស់ខ្លួននោះដែរ, ទោះបីអចលវត្ថុនោះបានកើនតម្លៃដោយសារស្នាដៃរបស់ខ្លួនក៏ដោយ ។

ក៏ប៉ុន្តែ, ប្រសិនបើផលុភោគីបានសង់គេងស្ពាននៅទីនោះ, ខ្លួន ឬ ទាយាទខ្លួនអាចនឹងសុំឲ្យគេប្រតិបត្តិតាមបទបញ្ញត្តិនៃមាត្រា ៦៥៣ បាន ។

បើបានតាក់តែងផ្ទះសំបែងដែលមាននៅទីនោះដោយកញ្ចក់ផ្ទុះរូប, នឹងគ្រឿងតែងឯទៀតក្តី, ផលុភោគី ឬ ទាយាទរបស់ខ្លួនអាចនឹងរើយកវិញបាន, តែត្រូវឲ្យរៀបចំទីនោះឲ្យដូចប្រក្រតីដើមវិញ ។

## ផ្នែកទី ២
## អំពីភាតព្វកិច្ច នៃផលុភោគី

**មាត្រា ៧៣៨** ៖ ផលុភោគី ត្រូវទទួលនូវអចលវត្ថុតាមសភាពដែលមានក្នុងពេលនោះ, ក៏ប៉ុន្តែមុននឹងចាប់ផ្ដើមប្រើប្រាស់, ផលុភោគីត្រូវសុំឱ្យមេឃុំត្រួតពិនិត្យនូវស្ថានភាពខាងសម្ភារៈនៃទីកន្លែងនោះក្នុងទីចំពោះមុខអាសារកម្មសិទ្ធិ ឬ ក៏អាសារកម្មសិទ្ធិករនោះមេឃុំបានហៅហើយ ។

**មាត្រា ៧៣៩** ៖ មួយទៀតមុននឹងចាប់ផ្ដើមប្រើប្រាស់, ផលុភោគីត្រូវរកអ្នកមានធនធានសមគួរម្នាក់ឱ្យមកធានាអំពីកិច្ចការ ដែលខ្លួនប្រើប្រាស់នោះគឺត្រូវប្រើប្រាស់ដូចខ្លួននេះជាបិតាដ៏ប្រពៃនៃគ្រួសារ, បានន័យថាផលុភោគី ត្រូវស៊ីផលឱ្យល្អបីដូចខ្លួនឯងនោះជាកម្មសិទ្ធិករ, ហើយយកចិត្តទុកដាក់នឹងផលប្រយោជន៍នៃកម្មសិទ្ធិករផង ។

ចំពោះកាតព្វកិច្ចនេះ, បើកិច្ចសន្យានោះសំដែងថាមិនចាំបាច់មានអ្នកធានាទេក៏គ្មានបានដែរ ។

ឪពុក និងម្ដាយ, ដែលជាផលុភោគីនៃទ្រព្យរបស់កូនអនីតិជននោះ, មិនបាច់ឱ្យមានអ្នកធានាឡើយ, ស្រីមេម៉ាយដែលជាផលុភោគីនៃទ្រព្យរបស់ខ្មោចប្ដីខ្លួនក៏មិនបាច់ឱ្យមានអ្នកធានាដែរ ។

**មាត្រា ៧៤០** ៖ បើផលុភោគីគ្មានអ្នកធានាទេអចលវត្ថុនោះត្រូវយកទៅដាក់ជាឈ្នួល ឬ ត្រូវដាក់ក្នុងវិសណ្ឋាប័ន, ឈ្នួលដី និងឈ្នួលផ្ទះ ឬ ផល ដែល

វិសណ្ឋាបនិកបានទទួលមកនោះ ត្រូវកាត់សាហ៊ុយគ្រប់យ៉ាងឲ្យជ្រះស្រឡះទៅ ហើយប្រគល់តែផលដែលសល់នោះទៅឲ្យផលុភោគី ។

**មាត្រា ៧៤១** ៖ ទោះបីយឺតយូរក្រុរកអ្នកធានាបានក្តី, ផលុភោគីមិនត្រូវខានបាននូវផលដែលខ្លួនមានសិទ្ធិត្រូវបាននោះឡើយ, ផលទាំងឡាយនោះត្រូវបានទៅផលុភោគីតាំងពីថ្ងៃដែលចាប់បើកផលុភោគនោះមក ។

**មាត្រា ៧៤២** ៖ ផលុភោគី ត្រូវទទួលជួសជុលតែការខូចខាតបន្តិចបន្តួច, ឯការជួសជុលធំៗទាំងឡាយត្រូវជាភារៈលើអាសារកម្មសិទ្ធិករ, ប្រសិនបើការខូចខាតនេះមិន បណ្តាលមកពីផលុភោគីមិនបានជួសជុលថែទាំតាំងពីថ្ងៃដែលបើកផលុភោគនោះទេ, បើមិនដូច្នេះទេផលុភោគីត្រូទទួលជួសជុលលើខ្លួនឯងទាំងអស់ ។

**មាត្រា ៧៤៣** ៖ ការជួសជុលធំៗទាំងឡាយ នោះគឺជួសជុលជញ្ជាំធំៗ និងគ្រឿងដំបូលលើ, ផ្លុះធ្នឹម, ផ្លុះរត និងប្រក់ទាំងមូលការជួសជុលទំនប់, ជញ្ជាំងទប់និងរបងកំពែងទាំងមូល ។

ការជួសជុលឯទៀតក្រៅពីនេះជាការជួសជុលតូចតាច ។

**មាត្រា ៧៤៤** ៖ របស់ឯណារលំព្រោះចាស់ទ្រុឌទ្រោម ឬត្រូវអន្តរាយដោយគ្រោះប្រធានស័ក្តិ,អសារកម្មសិទ្ធិករក្តីផលុភោគីក្តី មិនត្រូវគេបង្ខំឲ្យសង់របស់នោះឡើងវិញឡើយ ។

ប៉ុន្តែអសារកម្មសិទ្ធិករ ឬ ផលុភោគីបានយកអចលវត្ថុនោះទៅប៉ោកេអំពីគ្រោះកាចឯណា, បើអចលវត្ថុនោះត្រូវអន្តរាយខ្លះ ឬ ទាំងអស់ព្រោះគ្រោះកាច

នោះមែនអសារកម្មសិទ្ធិករក្តី, ផលុភោគីក្តីនឹងសុំឱ្យយកថ្លៃប៉ោកេដែលបានមកនោះទៅធ្វើ ឬ ជួសជុលឡើងវិញបាន ។

**មាត្រា ៧៤៥** ៖ក្នុងវេលាដែលខ្លួនកំពុងអាស្រ័យផល, ផលុភោគីត្រូវទទួលបន្ទុកប្រចាំឆ្នាំដែលជាប់លើអចលវត្ថុទាំងអស់ដូចជាពន្ធដា, ពន្ធអាករទាំងឡាយ និងរង្វាន់ប៉ោកេដែលទំនៀមធ្លាប់ដាក់លើផលនៃអចលវត្ថុនោះ ។

មួយទៀត ផលុភោគីត្រូវទទួលធ្វើឱ្យបានសម្រេច និងទទួលផ្លាស់ជាថ្មីឱ្យទាន់ពេលនូវកិច្ចសន្យាខាងប៉ោកេនៃអចលវត្ថុ ដែលនៅក្នុងផលុភោគរបស់ខ្លួនគឺកិច្ចសន្យាដែលមានហើយ ក្នុងវេលាដែលបើកផលុភោគនោះក្តី, កិច្ចសន្យាដែលអសារកម្មសិទ្ធិករនឹងតម្រូវឱ្យធ្វើក្នុងកាលជាងក្រោយក្តី ។

**មាត្រា ៧៤៦** ៖ ចំពោះបន្ទុកទាំងឡាយ ដែលផ្ទុកលើកម្មសិទ្ធិក្នុងរយៈវេលានៃផលុភោគនោះ, ផលុភោគី និងអសារកម្មសិទ្ធិត្រូវជួយបង់គ្នាដូចខាងក្រោយ ៖

អសារកម្មសិទ្ធិករត្រូវទទួលបង់បន្ទុកទាំងនោះហើយផលុភោគីត្រូវគិតការប្រាក់ឱ្យអសារកម្មសិទ្ធិករវិញ ។

ផលុភោគីនឹងចេញប្រាក់បង់មុន ហើយដល់វេលាដែលខ្លួនលែងអាស្រ័យផលនោះទៅសឹមទារយកប្រាក់ដើមមកវិញក៏បាន ។

**មាត្រា ៧៤៧** ៖ បើមានកើតក្តីអំពីដំណើរប្រើប្រាស់នូវអចលវត្ថុទាំងឡាយដែលដាក់ជាផលុភោគខ្លួននោះ, ផលុភោគីត្រូវទទួលចេញតែខ្វាត់ក្តីនិងក្រយាពិន័យទេ, ប្រសិនបើមាន ។

**មាត្រា ៧៤៨** ៖ ប្រសិនបើក្នុងរយៈវេលានៃផលុភោគីនោះមានតតិយជនណាមកព្យាបាទសិទ្ធិនៃអសារកម្មសិទ្ធិករ, ផលុភោគីនោះនឹងបណ្ដាលឲ្យមានព្យសនកម្មដល់អសារកម្មសិទ្ធិករ, ផលុភោគីត្រូវទទួលខុសត្រូវលើខ្លួនដូចក្នុងករណីដែលខ្លួនធ្វើនូវវត្ថុគេហើយត្រូវទទួលសងគេដូច្នោះឯង ។

## ផ្នែកទី ៣

## ផលុភោគ ត្រូវចប់ត្រឹមណា

**មាត្រា ៧៤៩** ៖ ផលុភោគត្រូវចប់ ៖

១. ត្រឹមផលុភោគីស្លាប់ ។

២. ត្រឹមដល់កំណត់កាលហើយ ឬ ត្រឹមល័ក្ខខ័ណ្ឌដែលបានកំណត់ទុកជាពេលត្រូវចប់នោះបានសម្រេចហើយ ។

៣. ត្រឹមផលុភោគលែងស៊ីផលទៀតហើយ ។

៤. ត្រឹមអចលវត្ថុដែលត្រូវដាក់ជាផលុភោគនោះអន្តរាយអស់ហើយ ។

**មាត្រា ៧៥០** ៖ មួយទៀតកាលណាបើអសារកម្មសិទ្ធិករប្ដឹងពីផលុភោគីថាប្រើប្រាស់អចលវត្ថុដោយរំលោភមានធ្វើឲ្យខូចអចលវត្ថុ ឬ បណ្ដោយឲ្យអចលវត្ថុខូចពុំថែទាំជាដើម, នោះតុលាការនឹងកាត់ជំលោះសិទ្ធិលែងឲ្យអាស្រ័យផលតទៅទៀតបាន ។

ក្នុងករណីនេះម្ចាស់បំណុល នៃផលុភោគីមានសិទ្ធិនឹងធ្វើអន្តរាគមន៍ក្នុងការណ៍នេះបាន, ម្ចាស់បំណុលអាចសុំជួសជុលការខូចខាតនោះហើយនិងសុំធានាតទៅអនាគតទៀតបាន ។

ដោយយោលទៅតាមគរុភាព នៃកាលៈទេសៈថៅក្រមអាចកាត់សេចក្ដីឲ្យផ្ដាច់ ផលុភោគជាដាច់ខាតក៏បាន ឬ នឹងបញ្ជាឲ្យប្រគល់នូវអចលវត្ថុទៅអសារកម្មសិទ្ធិករវិញតែឲ្យម្ចាស់របស់នេះចេញប្រាក់ប៉ុន្មានៗក្នុង ១ ឆ្នាំៗទៅឲ្យផលុភោគី ឬទីឲ្យសិទ្ធិវន្តរបស់ផលុភោគីនោះដរាបដល់កំណត់វេលាដែលត្រូវចប់ផលុភោគនោះក៏បាន ។

**មាត្រា ៧៥១** ៖ ការដែលអសារកម្មសិទ្ធិករលក់ នូវអចលវត្ថុដែលដាក់ជាផលុភោគនោះមិនជាទីនាំឲ្យផ្លាស់ប្ដូរនូវស្ថានភាពនៃផលុភោគីឡើយ, ផលុភោគីនៅតែមានសិទ្ធិអាស្រ័យផលអចលវត្ថុនេះតទៅទៀត លើកមួយតែផលុភោគីនោះប្រកែកយ៉ាងប្រាកដថាលែងអាស្រ័យផលផលុភោគទៀតហើយ ។

**មាត្រា ៧៥២** ៖ ថាបើផលុភោគីប្រកែកលែងអាស្រ័យផលហើយដោយក្លែងចង់ឲ្យខូចសិទ្ធិនៃម្ចាស់បំណុលខ្លួន, ម្ចាស់បំណុលអាចនឹងប្ដឹងបដិសេធពាក្យប្រកែកនេះបានលើកមួយតែក្នុងរឿងដែលផលុភោគនោះជាមត៌ក ។

**មាត្រា ៧៥៣** ៖ បើអចលវត្ថុត្រូវអន្តរាយទាំងអស់, ទើបផលុភោគត្រូវផុតអំណាចអាស្រ័យផលបាន, បើគ្រាន់តែខូចខ្លះទេ, ផលុភោគត្រូវមានសិទ្ធិអាស្រ័យផលបាន, បើគ្រាន់តែខូចខ្លះទេ, ផលុភោគីត្រូមានសិទ្ធិអាស្រ័យផលត្រង់ដែលនៅល្អ ។

**មាត្រា ៧៥៤** ៖ បើបានដាក់ត្រឹមតែផ្ទះមួយជាផលុភោគទេហើយផ្ទះនោះអន្តរាយដោយគ្រោះកាចអស់ទៅ, ផលុភោគីមិនត្រូវនៅមានសិទ្ធិអាស្រ័យផលលើដី, លើគ្រឿងផ្ទះនោះឡើយ ។

ថាបើបានដាក់សម្បត្តិទាំងមូលមានផ្ទះដែលអន្តរាយនោះជាផលុភោគដែរ, បទបញ្ញត្តិចុងបំផុតនៃមាត្រា ៧៤៤ នៃក្រមនេះតម្រូវឲ្យអនុវត្តក្នុងករណីទាំងពីរនេះ, លើកមួយតែមានការណ៍យ៉ាងណាផ្សេងទៅទៀត ។

## ចំពូកទី២
## អំពីសិទ្ធិ ប្រើប្រាស់ និងអាស្រ័យនៅ

**មាត្រា ៧៥៥** ៖ សិទ្ធិប្រើប្រាស់ អនុញ្ញតិឲ្យអត្ថគាហកហូតយកពីអចលវត្ថុណាមួយនូវផលទាំងឡាយតាមសមគួរដល់សេចក្តីត្រូវការរបស់ខ្លួន និងគ្រួសារខ្លួន ។

ដែលហៅថា សិទ្ធិអាស្រ័យនៅគឺជាសិទ្ធិដែលអនុញ្ញាតិឲ្យអត្ថគាហកបានកន្លែងក្នុងផ្ទះមួយសមគួរល្មមជាទីជ្រកនៅរបស់ខ្លួន និងគ្រួសារខ្លួន ។

នាកាលសិទ្ធិទាំងពីរសិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យនៅបានអនុញ្ញាតិឲ្យអត្ថគាហកយ៉ាងនេះហើយ, ទោះបីជាថ្ងៃក្រោយមកអត្ថគាហកនោះមានប្តីប្រពន្ធក្តី មានកូនក្តីក៏មានសិទ្ធិនៅតែមានដល់អត្ថគាហកដដែល ។

**មាត្រា ៧៥៦** ៖ ផលុភោគ បានកើតឡើង និងបានរលត់ទៅវិញដោយរបៀបយ៉ាងណា សិទ្ធិប្រើប្រាស់ និងអាស្រ័យនៅក៏កើតឡើង ហើយរលត់ទៅវិញដោយរបៀបយ៉ាងនោះដែរ ។

សិទ្ធិទាំងឡាយរបស់អ្នកប្រើប្រាស់ត្រូវតែសម្រេចគ្នាឲ្យដាច់ស្រេចហើយចុះខសន្យាក្នុងសំបុត្របញ្ជាក់ឲ្យសព្វគ្រប់ ឬ បើគ្មានសំបុត្របញ្ជាក់ទេត្រូវគោរពតាមបទបញ្ញត្តិដូចខាងក្រោមនេះ។

**មាត្រា ៧៥៧** ៖ អគ្គគាហកទាំងឡាយដែលបានសិទ្ធិប្រើប្រាស់និងអាស្រ័យនៅនោះត្រូវទទួលគោរពកាតព្វកិច្ចទាំងឡាយដែលមាត្រា ៧៣៨, ៧៣៩, ៧៤១, ៧៤៥, ៧៤៧, ៧៤៨ តម្រូវមក ។

**មាត្រា ៧៥៨** ៖ អគ្គគាហកទាំងឡាយនោះមិនអាចផ្ទេរជួល នូវសិទ្ធិខ្លួនឲ្យអ្នកដទៃ, បានឡើយ ។

**មាត្រា ៧៥៩** ៖ បើអ្នកប្រើប្រាស់ក្រសោបឱបយកផលដីទាំងអស់ ឬ ក៏យកផ្ទះទាំងមូលនៅតែម្នាក់ឯក, អ្នកនេះត្រូវទទួលចេញសោហ៊ុយដាំ, សោហ៊ុយជួសជុល, ថែទាំនិងទទួលបង់ពន្ធដាទាំងពួងនិងរង្វាន់ប៉ោកេដូចផលុភោគីដែរ ។

បើអ្នកនោះយកផលតែមួយភាគទេ ឬ យកកន្លែងតែមួយក្នុងផ្ទះនោះទេ, អ្នកនោះត្រូវជួយចេញតាមសមាមាត្រ នៃចំណែកដែលខ្លួនប្រើប្រាស់ និងអាស្រ័យនៅ ។

## ចំពូក ទី ៣
## អំពីសេវភាព

**មាត្រា ៧៦០** ៖ ដែលហៅថា សេវភាព នៃដីគឺជាបន្ទុកដែលតម្រូវទៅលើអចលវត្ថុមួយហៅថាដីបំរើ ឬ ដីក្រោមដើម្បីឲ្យអចលវត្ថុមួយទៀតដែលហៅថា ដីប្រើ ឬ ដីលើជារបស់កម្មសិទ្ធិករម្នាក់ទៀតប្រើប្រាស់ ។

**មាត្រា ៧៦១** ៖ សេវភាព មានច្រើនបែប គឺសេវភាពកើតមកពីធម្មជាតិ, សេវភាពកើតមកពីច្បាប់ និងសេវភាពកើតមកពីកិច្ចសន្យាតាមដំណើរដែលសេវ

ភាពនោះលេចមកពីស្ថានភាពនៃទីកន្លែង ឬ លេចមកពីច្បាប់បង្កើត ឬ លេចមកពីកម្មសិទ្ធិករទាំងឡាយបានព្រមព្រៀងគ្នាចុះកិច្ចសន្យាយ៉ាងនោះឯង ។

## ផ្នែកទី ១
## អំពីសេវភាពធម្មជាតិ

**មាត្រា ៧៦២** ៖ ដីក្រោម ត្រូវទទួលទឹកដែលហូរតាមធម្មជាតិពីដីខ្ពស់មក។

កម្មសិទ្ធិករនៃដីក្រោមមិនអាចលើកថ្នល់, ភ្លឺ, ធ្វើទំនប់ ឬ ធ្វើការរុងទៀតទប់, ឃាត់ឃាំងទឹកនោះមិនឲ្យហូរបានឡើយ ។

**មាត្រា ៧៦៣** ៖ កម្មសិទ្ធិករនៃដីខាងលើមានសិទ្ធិនឹងទុកទឹកភ្លៀង និងទឹកហូរកាត់ដីខ្លួនប្រើប្រាស់បាន, កុំឲ្យតែល្មើសនឹងអាឃាត់ខាងលើនេះ ។

**មាត្រា ៧៦៤** ៖ កម្មសិទ្ធិករទាំងឡាយ ដែលមានដី នៅប្រប់ទឹកដែលទឹកហូរត្រូវបណ្ដោយទឹកនោះឲ្យហូរទៅលើដីជិតខាងទាំងអស់ ។ ឯម្ចាស់ដីដែលជិតៗទាំងឡាយនោះសោតទៀតក៏ត្រូវតែបណ្ដោយទឹកឲ្យហូរដូចគ្នាទៅកាន់ដីឆ្ងាយៗទៅទៀតតាមសេចក្ដី ដែលត្រូវការរាល់គ្នាក្នុងកសិកម្ម ។

## ផ្នែកទី ២
## អំពីសេវភាពរបស់ច្បាប់

**មាត្រា ៧៦៥** ៖ សេវភាពតាមច្បាប់មានពីរយ៉ាងគឺ : សេវភាពមានកម្មវត្ថុខាងបំរើសាធារណប្រយោជន៍ ១ និងសេវភាពបំរើប្រយោជន៍ឯកជន ១ ។

## កថាខ័ណ្ឌ ទី១
## អំពីសេវភាពរបស់ច្បាប់បំរើសាធារណប្រយោជន៍

**មាត្រា ៧៦៦** ៖ សេវភាព របស់ច្បាប់ដែលបំរើសាធារណប្រយោជន៍ នោះកើតមកអំពីច្បាប់ ឬ អំពីបទបញ្ញត្តិជាពិសេសដែលកម្មសិទ្ធករនៃដីត្រូវតែយំមខ្លួនគោរពតាម ។

## កថាខ័ណ្ឌទី ២
## អំពីសេវភាពរបស់ច្បាប់បំរើប្រយោជន៍ឯកជន

**មាត្រា ៧៦៧** ៖ សេវភាពរបស់ច្បាប់ ដែលបំរើប្រយោជនឯកជននោះគឺជាបទបញ្ញត្តិរបស់ច្បាប់ដែលកំណត់ឲ្យកម្មសិទ្ធិករម្នាក់ៗ អាចធ្វើនូវកិច្ចការផ្សេងៗលើដីរបស់ខ្លួនបាន, ដើម្បីកុំឲ្យប៉ះពាល់ដល់សិទ្ធិរបស់កម្មសិទ្ធករនៃដីជិតខាង ។

**មាត្រា ៧៦៨** ៖ កម្មសិទ្ធិករ ទាំងពួងណាធ្វើនូវការរៀទាំងឡាយណាដែលនាំឲ្យសៅហ្មងដល់ដីជិតខាងដូចយ៉ាងខួងដី, ជីកស្នង់ដី, ជីករូងដី, គរទុកក្នុងដីរបស់ខ្លួននូវវត្ថុប្រកបដោយគ្រោះថ្នាក់, នូវវត្ថុស្អុយ ឬ មានជាតិកាចនាំឲ្យខូចសុខភាពគេ , កម្មសិទ្ធិករទាំងពួងនោះត្រូវប្រតិបត្តិតាមបទបញ្ញត្តិនៃច្បាប់ដោយឡែកដែលកំណត់ចម្ងាយឲ្យប្រយ័ត្នក្តី, ដែលកំណត់ការរៀឲ្យធ្វើសម្រាប់ទប់, ជ្រែងក្តី។

**មាត្រា ៧៦៩** ៖ កម្មសិទ្ធិករម្នាក់ៗមិនអាចនឹងធ្វើប្រហោង, ទ្វារ, បង្អួច, កើយ ឬ យ៉ងទៀតៗ បែបៗគ្នាត្រង់ចំទៅលើដីអ្នកជិតខាងចម្ងាយមិនដល់ពីរម៉ែត្របានទេ ។

**មាត្រា ៧៧១** ៖ កម្មសិទ្ធិករដែលមានដីនៅក្នុងទីបិទមុខឥតច្រកនឹងចេញចូលទៅកាន់ផ្លូវសាធារណៈបាន, ឬ ច្រកនោះតូចពេក, មិនធ្លួនល្មមនឹងធ្វើកសិកម្ម

ឬ ឧស្សាហកម្មខ្លួនទេ, អាចនឹងសុំបើកផ្លូវអ្នកជិតខាងបាន, តែអ្នកនោះត្រូវចេញសោហ៊ុយឲ្យគេតាម សមាមាត្រនៃការខូចខាតដែលបណ្ដាលមកពីការបើផ្លូវនោះ ។

**មាត្រា ៧៧២** ៖ ផ្លូវនោះត្រូវបើកឲ្យទៀងទាត់ដោយយកតែកន្លែងណាដែលត្រង់ពីដីបិទមុខនោះទៅផ្លូវសាធារណៈជាងកន្លែងឯទៀត ។

ប៉ុន្តែការបើកផ្លូវនេះត្រូវកំណត់យកត្រង់កន្លែងណា ដែលមិនសូវខូចខាតដល់ម្ចាស់ដីដែលឲ្យបើកផ្លូវនោះច្រើនពេកផង ។

**មាត្រា ៧៧៣** ៖ បើដីណាមួយបិទមុខដោយហេតុមកពីបែងដីដើម្បីលក់ដូរ, ចែកគ្នា ឬ ដោយចុះកិច្ចសន្យាប្រការឯណាទៀត, ផ្លូវដែលអាចសុំបើកនោះត្រូវបើកតែលើដីដែលសល់ពីការបែងនោះ ឬ លើដីឯទៀតដែលជាកម្មវត្ថុនៃកិច្ចសន្យាបាន ។

ប៉ុន្តែបើផ្លូវដែលបើកលើដីទាំងនោះនៅតែមិនគ្រប់គ្រាន់ទេមាត្រា ៧៧១ នៅតែគួរយកមកអនុវត្តបានទៀត ។

**មាត្រា ៧៧៤** ៖ កម្មសិទ្ធិករទាំងពួងណាត្រូវការយកទឹកដែលខ្លួនមានសិទ្ធិប្រើប្រាស់បានមកដាក់លើដីខ្លួន, កម្មសិទ្ធិករនោះអាចនឹងសុំបើកទីនោះតាមដីដែលនៅខណ្ឌដី ខ្លួនបានតែកម្មសិទ្ធិករនោះត្រូវចេញសោហ៊ុយឲ្យម្ចាស់គេ ។

**មាត្រា ៧៧៥** ៖ កម្មសិទ្ធិករដដែលនោះអាចនឹងសុំបញ្ចេញទឹកដែលខ្លួនបង្ហូរមកស្រោចដីខ្លួននោះតាមទីទាបទាំងឡាយ បានតែថាកម្មសិទ្ធិករនោះត្រូវឲ្យសោហ៊ុយគេជាដរាប ។

**មាត្រា ៧៧៦** ៖ កម្មសិទ្ធិណាមានដីលិចទឹកខ្លះ ឬ ទាំងអស់ត្រូវបង្ហូរទឹកតាមប្រឡាយ ឬ តាមបំពង់បូម ឬ ដោយប្រការឯណាដើម្បីបញ្ចេញទឹកអាក្រក់ចេញពីដីខ្លួនតាមដីជាដំណារពីដីខ្លួនមក, កម្មសិទ្ធិករនោះអាចធ្វើបានដូចគ្នានឹងខាងលើនេះដែរ ។

**មាត្រា ៧៧៧** ៖ កម្មសិទ្ធិករណាម្នាក់ជាប់នឹងមាត់ទឹកត្រើយខាងអាយហើយចង់យកទឹកស្រោចដីខ្លួន, កម្មសិទ្ធិករនោះអាចនឹងសង់ការរៀដែលជាចាំបាច់ក្នុងការបង្ហូរទឹកសង្កត់លើដីត្រើយខាងនាយបានតែត្រូវចេញសោហ៊ុយឲ្យគេជាដរាប ។

**មាត្រា ៧៧៨** ៖ កម្មសិទ្ធិករជាម្ចាស់ដីដែលព្រមឲ្យសង់, ឲ្យធ្វើការរៀអ្វីលើដីខ្លួននោះអាចនឹងសុំប្រើទំនប់នោះជាមួយផងបាន ។ ប៉ុន្តែកម្មសិទ្ធិករនោះត្រូវចេញសោហ៊ុយធ្វើនិងសោហ៊ុយថែទាំពាក់កណ្តាលម្នាក់ស្មើគ្នា ។ ថាបើដូច្នេះកម្មសិទ្ធិករនេះមិនត្រូវទារសោហ៊ុយថ្លៃដីឡើយ, បើបានជាទារទៅហើយត្រូវតែបង្វិលឲ្យគេវិញ ។

## ផ្នែកទី ៣
## អំពីសេវភាព ដែលមនុស្សបង្កើត

**មាត្រា ៧៧៩** ៖ ច្បាប់អនុញ្ញាត ឲ្យកម្មសិទ្ធករទាំងឡាយបង្កើតនូវសេវភាពទាំងឡាយណា ដែលខ្លួនយល់ឃើញថាគួរធ្វើលើដីរបស់ខ្លួនជាគុណប្រយោជន៍ដល់កម្មសិទ្ធិករទាំងឡាយឯទៀតបាន, ឲ្យតែសេវភាពទាំងឡាយនោះពិតជាមាន

ប្រយោជន៍តាមសេចក្ដីត្រូវការប្រើប្រាស់នៃដីប្រើហើយមួយទៀត កុំឲ្យមានអ្វីជាទីទាស់ដល់សេចក្ដីរៀបរយនៃសាធារណជនផង ។

ការប្រើប្រាស់ និងទំហុំនៃសេវភាពដែលកើតឡើងដោយរបៀបយ៉ាងនេះត្រូវតែធ្វើជាប័ណ្ណដើម្បីទុកជាភស្តុតាងនៃការបង្កើតសេវភាពនោះ បើឥតមានប័ណ្ណទេត្រូវព្រមព្រៀងតាមបែបបទដូចមានខាងក្រោយនេះ ។

## កថាខ័ណ្ឌទី១
## សេវភាពទាំងឡាយកើតឡើងយ៉ាងដូចម្ដេច?

**មាត្រា ៧៨០** ៖ សេវភាពទាំងឡាយ ដែលកើតមកពីមនុស្សធ្វើនឹងត្រូវទុកជាកើតដោយត្រឹមត្រូវតាមច្បាប់បាន លុះណាតែភាគីបានធ្វើសំបុត្រមានបញ្ជាក់ ហើយយកទៅចុះក្នុងបញ្ជីការអ៊ីប៉ូតែក្រុកុឡាស្យុងទៀតទើបតតិយជនតវ៉ាមិនបាន ។

នាកាលការទាក់ទងពីដីបំរើទៅដីប្រើបានកើតឡើង ហើយរវាងកម្មសិទ្ធិករនៃដីទាំងពីរយ៉ាងនេះក៏ដោយ, បើកម្មសិទ្ធិករណាលក់ ដូរ ដីរបស់ខ្លួនឲ្យទៅតតិយជនណាម្នាក់ហើយមិនបានចុះ សេចក្ដីឲ្យប្រាកដក្នុងសំបុត្រលក់នោះថាសេវភាពនោះត្រូវនៅជាប្រក្រតីដដែលទេ, ការទាក់ទងនោះក៏ត្រូវលែងមានទៅទៀតដែរ ។

**មាត្រា ៧៨១** ៖ អ្នកណាបានបង្កើតសេវភាពមួយហើយអ្នកនោះត្រូវគេសន្មត់ថាខ្លួនព្រមបើកឲ្យគេធ្វើអ្វីៗតាមចិត្តដែលជាការចាំបាច់ក្នុងការប្រើនូវសេវភាពនោះ ។

សេវភាព បើកឲ្យយកទឹកអំពីម៉ាស៊ីនទឹកណាមួយនឹងបណ្តាលឲ្យអ្នកយកទឹកនោះមានសិទ្ធិដើរកាត់ដីដែលមានម៉ាស៊ីនទឹកជាចាំបាច់ ។

**កថាខណ្ឌទី ២**

**អំពីល័ក្ខខ័ណ្ឌដែលត្រូវប្រើប្រាស់ នូវសេវភាពទាំងឡាយ**

**មាត្រា ៧៨២** ៖ កម្មសិទ្ធិករនៃដីប្រើមានសិទ្ធិនឹងធ្វើនូវការរៀទាំងពួងដែលជាចាំបាច់ដើម្បីប្រើប្រាស់ និងថែរក្សានូវសេវភាពដែលគេព្រមឲ្យខ្លួនប្រើ ។

**មាត្រា ៧៨៣** ៖ ការរៀទាំងឡាយដែលត្រូវធ្វើជាចាំបាច់ដើម្បីប្រើប្រាស់ និងថែរក្សានូវសេវភាពនោះត្រូវជាភារៈនៃម្ចាស់ដីប្រើជាអ្នកចេញសោហ៊ុយ, វៀរតែបានព្រមព្រៀងគ្នាយ៉ាងណាផ្សេងទៅវិញទើបត្រូវប្រតិបត្តិតាមសេចក្តីព្រមព្រៀងនោះបាន ។

**មាត្រា ៧៨៤** ៖ ថាបើឲ្យម្ចាស់ដីបំរើចេញសោហ៊ុយវិញ, អ្នកនេះអាចលះបង់ដីរបស់ខ្លួនត្រង់ ដែលនៅក្នុងសេវភាពនោះឲ្យទៅកម្មសិទ្ធិនៃដីប្រើបានដើម្បីឲ្យផុតពីចេញ សាហ៊ុយ ។

**មាត្រា ៧៨៥** ៖ ប្រសិនបើដីប្រើទើបនឹងត្រូវបែងជាច្រើនភាគ, សេវភាពនោះក៏ត្រូវនៅបំរើដីប្រើតាមភាគដីនីមួយៗតទៅទៀត, កុំឲ្យតែដីបំរើនោះមានល័ក្ខខ័ណ្ឌវិតតែធ្ងន់ថែមឡើងទៀត ។ សេចក្តីនេះមានឧបមា ដោយឧទាហរណ៍ដូច្នេះថាបើសេវភាពនោះ គឺជាផ្លូវដើរកម្មសិទ្ធិករនៃភាគដីផ្សេងៗទាំងឡាយត្រូវដើរតែតាមផ្លូវមួយត្រង់កន្លែងដដែល ដែលមានពីដើមមក ។

**មាត្រា ៧៨៦** ៖ កម្មសិទ្ធិករនៃដីបំរើមិនអាចធ្វើនូវកិច្ចការឯណាដែលជាទីនាំឲ្យការប្រើប្រាស់នូវសេវភាពនោះមានការចង្អៀតចង្អល់ ឬ ឲ្យទៅជាការមិនស្រួលប្រើបានទេ ។

ដូច្នេះកម្មសិទ្ធិករនៃដីបំរើមិនអាចផ្លាស់ប្តូរសេវភាពនៃកន្លែង ឬ លើកយកសេវភាពនោះឲ្យទៅនៅកន្លែងផ្សេងប្រើប្រាស់ខុសពីកន្លែងដើមបានទេ ។

ប៉ុន្តែថាបើទុកស្ថានភាពដើមទៅនឹងនាំឲ្យសេវភាព នោះដាច់បង់ប្រាក់របស់កម្មសិទ្ធិករនៃដីបំរើគឺថានឹងមិនឲ្យម្ចាស់ដីបំរើចំណេញជួសជុលនៅលើដីនោះទេ, អ្នកនេះអាចនឹងសុំដាក់ទីឯទៀតដែលស្រួលដូចគ្នាជាសេវភាពជំនួសវិញបាន, កម្មសិទ្ធិករនៃដីប្រើនឹងប្រកែកពុំបានឡើយ ។

**មាត្រា ៧៨៧** ៖ ឯខាងកម្មសិទ្ធិករនៃដីប្រើវិញក៏ដូច្នេះដែរអ្នកនេះនឹងប្រើប្រាស់នូវសេវភាពតែក្នុងព្រំដែន ដែលមានកំណត់ទុកក្នុងប័ណ្ណដោយមិនអាចផ្លាស់ប្តូរអ្វីនៅលើដីបំរើ ឬ នៅលើដីប្រើឲ្យរិតតែធ្ងន់លើស្ថានភាពមុខនោះបានទេ ។

## កថាខ័ណ្ឌទី ៣
## សេវភាពរលត់ទៅវិញដោយរបៀបណា

**មាត្រា ៧៨៨** ៖ សេវភាពត្រូវរលត់ ៖

១. ដោយហេតុ រលត់សិទ្ធិ ដែលបង្កើតសេវភាពនោះ ។

២. ដោយហេតុដីប្រើ និងដីបំរើទាំងពីរនេះបានធ្លាក់ទៅលើដៃម្ចាស់តែម្នាក់ ។

៣. ដោយហេតុដីដែលមានសេវភាពនោះវិនាសអស់ហើយ ។

# គន្ថីទី៣
# អំពីកាតព្វកិច្ច
## មាតិកាទី ១
## បទបញ្ញត្តិទូទៅ

**មាត្រា ៧៨៩** ៖ កាតព្វកិច្ចជាចំណងនៃសិទ្ធិដែលចង(បង្ខំ) ជនម្នាក់គឺកំដឹង (កូនបំណុល) ឲ្យផ្ទេរនូវកម្មសិទ្ធិនៃវត្ថុណាមួយ ឬ សិទ្ធិណាមួយក្តី, ឲ្យបំពេញនូវកិច្ចការណាមួយក្តី ឬ ឲ្យឈប់បំពេញនូវកិច្ចការណាមួយក្តីដល់ជនម្នាក់ទៀតដែលហៅថាម្ចាស់កំដឹង(ម្ចាស់បំណុល) ។

### ចំពូក ទី ១
### ប្រភព នៃកាតព្វកិច្ចទាំងឡាយ

**មាត្រា ៧៩០** ៖ កាតព្វកិច្ចទាំងឡាយកើតមកពីសេចក្តីប្តេជ្ញា ឬ កិច្ចសន្យា, ពីព្យសនកម្មដោយចេតនា ឬដោយឥតចេតនា, ពីសេចក្តីចម្រើនដោយឥតហេតុ ឬ ពីបទបញ្ញត្តិនៃច្បាប់ ។

#### ផ្នែកទី ១
#### អំពីកាតព្វកិច្ចដោយប្តេជ្ញា

**មាត្រា ៧៩១** ៖ ដែលហៅថាសេចក្តីប្តេជ្ញា ឬ កិច្ចសន្យាគឺកិរិយា ដែលជនពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត, កែប្រែ ឬ រំលត់នូវកាតព្វកិច្ចមួយ ឬ ច្រើនដែលជាបន្ទុកលើខ្លួនម្នាក់ៗ ។

**មាត្រា ៧៩២** ៖ សេចក្តីប្តេជ្ញានោះអាចនឹងចែងពីកាតព្វកិច្ចពិសេសដែលជាបន្ទុកលើភាគីតែម្នាក់ ឬ ច្រើននាក់ឲ្យបំពេញក៏បាន, អាចចែងពីកាតព្វកិច្ចទៅវិញទៅមកដែលជាបន្ទុកលើភាគីទាំងសងខាងឲ្យបំពេញទៅវិញទៅមកក៏បាន ។

## កថាខ័ណ្ឌ ទី៣
## អំពីសុពលភាពនៃសេចក្តីប្តេជ្ញាទាំងឡាយ

**មាត្រា ៧៩៣** ៖ សេចក្តីប្តេជ្ញាទាំងឡាយ នឹងយកជាការបានលុះតែកាតព្វកិច្ចដែលកើតអំពីសេចក្តីប្តេជ្ញានោះ ៖

១. មានវត្ថុមួយដែលមានកំណត់, ដែលអាចធ្វើកើត, ដែលប្រកបនឹងច្បាប់នឹងធម៌ជាទីតាំងផង ។

២. កើតពីសេចក្តីស្ម័គ្រដោយពិតប្រាកដ និងដោយសេរីផង។

៣. កើតពីជនដែលមានសមត្ថភាពគប្បីចុះកិច្ចសន្យាបានផង ។

### ១. អំពីវត្ថុជាទីតាំង

**មាត្រា ៧៩៤** ៖ វត្ថុជាទីតាំង នៃកាតព្វកិច្ចត្រូវចែកឲ្យប្រាកដដោយឡែកពីគ្នាតាមភេទ, តាមធន់, តាមចំនួន, និងតាមគុណភាព ។

**មាត្រា ៧៩៥** ៖ ការដែលមិនអាចធ្វើកើតនោះគឺការដែលពិបាកហួសវិស័យមនុស្សនឹងធ្វើកើត, កុំថាឡើយតែកំដឹងម្នាក់ឯងនោះថ្វី,សូម្បីជនទាំងពួងក៏ធ្វើមិនកើតដែរ ។ ការពិបាកយ៉ាងនេះហៅថាការមិនអាចជាដាច់ខាត់ ។

**មាត្រា ៧៩៦** ៖ អ្វីទាំងពួងដែលទាស់នឹងគតិច្បាប់, ទាស់នឹងសេចក្តីរៀបរយនៃសាធារណជន, ទាស់នឹងលោកចរិយាទាំងអស់នេះហៅថាក្រៅច្បាប់, ក្រៅធម៌ ។

## ២. អំពីសេចក្តីស្ម័គ្រ

**មាត្រា ៧៩៧** ៖ នាកាលមានភ័ន្តច្រឡំអំពីប្រភេទនៃសេចក្តីប្តេជ្ញា, ភ័ន្តច្រឡំអំពីអត្តសញ្ញាណ ឬ អំពីសារជាតិនៃវត្ថុ, សេចក្តីព្រមព្រៀងនោះមិនទុកជាធ្វើស្ម័គ្រទេ ។

**មាត្រា ៧៩៨** ៖ សេចក្តីស្ម័គ្រដែលមិនដោយសេរី នោះគឺស្ម័គ្រដោយគេកំហែង, គំរាម, ឬ ដោយគេបោកប្រាស់មិនឲ្យដឹងខ្លួនជាមុន ។

**មាត្រា ៧៩៩** ៖ អាការកំហែង នោះគឺអំពើទាំងពួងដែលញ៉ាំងគូសញ្ញាឲ្យនឹងខ្លាចក្រែងមានឧបទ្រពយ៉ាងធំណាមួយមកយាយីរូបកាយ, សម្ភារៈផ្លូវចិត្តរបស់ខ្លួនក្តី, របស់ញាតិណាម្នាក់នៃខ្លួនក្តី, របស់អ្នកជិតស្និត ឬ មិត្តសម្លាញ់នៃខ្លួនក្តី ។

**មាត្រា ៨០០** ៖ អាការកំហែងនោះ អាចកើតមកពីអត្តគាហកនៃកាតព្វកិច្ច ឬ តតិយជនណាម្នាក់ដែលមកបង្ខំដល់ផ្លូវចិត្ត ឬ ផ្លូវកាយ ។

**មាត្រា ៨០១** ៖ សេចក្តីបោកប្រាស់នោះ គឺអាការ កិរិយាទាំងឡាយដែលជាកិច្ចកល ឧបាយ កុហក បញ្ឆោត ភូតភរ បន្លំ ជាទីញ៉ាំងគូសន្យាឲ្យព្រមចុះកិច្ចសន្យា ។

**មាត្រា ៨០២** ៖ បំភាន់នោះ អាចបណ្តាលមកពីគូសន្យាផងគ្នាបំភាន់ ឬ ជនដទៃបំភាន់ជាប្រយោជន៍នៃគូសន្យាក៏បាន ។

**មាត្រា ៨០៣** ៖ ជនណាមិនព្រមប្រតិបត្តិតាម ខកាតព្វកិច្ចទាំងឡាយដែលកើតពីកិច្ចសន្យារបស់ខ្លួន ដោយប្រកាន់ថាខ្លួនភាន់ច្រឡំថាគេកំហែង ឬ ថាគេបោកប្រាស់ជននោះត្រូវរកបន្ទាល់នៃសំដីខ្លួនមកជាសំអាង ។

## ៣. អំពីសមត្ថភាព

**មាត្រា ៨០៤** ៖ ជនដែលគ្មានសមត្ថភាព នឹងចុះកិច្ចសន្យាបាននោះគឺ:

១- អនីតិជន

២- មនុស្សដែលត្រូវគំហាត់

៣- ស្ត្រីមានប្ដីហើយ មិនបានទទួលនីតិសម្បទាពីប្ដី ។

**មាត្រា ៨០៥** ៖ គូសន្យានៃជនអសមត្ថភាព មិនអាចនឹងដោះសារដើម្បីគេចកែពីកាតព្វកិច្ចនៃកិច្ចសន្យាដោយសំអាងថារូបជន ដែលចុះកិច្ចសន្យាជាមួយនឹងខ្លួននោះជាជនអសមត្ថជនយ៉ាងនេះបានឡើយ ។

**កថាខ័ណ្ឌទី២**

**អានុភាព និងការបកស្រាយ នៃសេចក្ដីប្ដេជ្ញា**

**មាត្រា ៨០៦** ៖ សេចក្ដីប្ដេជ្ញា ត្រូវទុកជាច្បាប់រវាងគូភាគីទាំងឡាយ ។

**មាត្រា ៨០៧** ៖ សេចក្ដីប្ដេជ្ញានេះ នឹងអាចកែប្រែទៅវិញបាន លុះត្រាតែគូភាគីបានស្ម័គ្រចិត្តព្រមព្រៀងទាំងអស់គ្នាផង ។

**មាត្រា ៨០៨** ៖ សេចក្ដីប្ដេជ្ញានោះ ត្រូវយកទៅប្រតិបត្តិ ដោយសុចរិត និងតាមសេចក្ដីប្រាថ្នា នៃគូភាគីទាំងឡាយ ។

**មាត្រា ៨០៩** ៖ សេចក្ដីប្ដេជ្ញាមានអនុភាព តែទៅលើគូភាគី នៃកិច្ចសន្យានោះតែប៉ុណ្ណោះ ។

**មាត្រា ៨១០** ៖ នាកាលសេចក្ដីប្ដេជ្ញាណា មានសេចក្ដីព្រលាំ មិនច្បាស់យ៉ាងណាប្រាកដសេចក្ដីប្ដេជ្ញានោះត្រូវបកស្រាយវាយសេចក្ដីតាមទំនៀមទំលាប់ទាំងពួងជាសណ្ដាប់ក្នុងទីដែលបានចុះកិច្ចសន្យានោះ ។

**មាត្រា ៨១១** ៖ បើមានមន្ទិលសង្ស័យ ត្រូវឲ្យវាយសេចក្ដីជាប្រយោជន៍នៃកំដឹង(កូនបំណុល)។

## ផ្នែកទី២
## ភាគព្វកិច្ច កើតពីធ្វើឲ្យមានព្យសនកម្ម

**មាត្រា ៨១២** ៖ ជនណាបានប្រព្រឹត្ត នូវអំពើទាំងពួង ជាទីនាំឲ្យខូចខាតដល់ជនដទៃ ជននោះត្រូវជួសជុលសេចក្ដីខូចខាត ដែលកើតពីកំហុសខ្លួនឲ្យគេ ។

**មាត្រា ៨១៣** ៖ ទោះសេចក្ដីខូចខាតនោះ កើតពីអំពើឯណាដែលឥតចេតនាយ៉ាងដូចជាធ្វេសប្រហែស ឬ ពុំបានប្រយ័ត្នត្រួតត្រាក្ដី ក៏ជនអ្នកធ្វើនោះត្រូវតែជួសជុលសេចក្ដីបង់ខាតឲ្យគេដែរ ។

**មាត្រា ៨១៤** ៖ នាយនៃគ្រួសារ ត្រូវទទួលខុសត្រូវចំពោះសេចក្ដីខូចខាតដែលបណ្ដាលមកពីកូនចៅ ជាអនីតិជន ដែលត្រូវនៅក្នុងអំណាចត្រួតត្រានៃខ្លួន ។

**មាត្រា ៨១៥** ៖ ចៅហ្វាយ នាយ ដង្ហៅ ត្រូវទទួលខុសត្រូវចំពោះសេចក្ដីខូចខាតដែលបណ្ដាលមកអំពីបាវព្រាវ កូនឈ្នួល មនុស្សបំរើ ឬ មនុស្សរៀនធ្វើការរបស់ខ្លួនក្នុងវេលា ដែលជននោះធ្វើនូវការ ដែលខ្លួនប្រើឲ្យធ្វើ ។

**មាត្រា ៨១៦** ៖ កាលណាបើនាយនៃគ្រួសារ ចៅហ្វាយនាយ ដង្ហៅទាំងឡាយ មានបន្ទាល់ថា ដើម្បីចៀសវាងមិនឲ្យមានសេចក្ដីខូចខាតនោះ ខ្លួនបានប្រុងប្រយ័ត្នអស់សមត្ថភាព ដែលអាចធ្វើបានហើយ នាយគ្រួសារ ចៅហ្វាយនាយ ដង្ហៅ នោះត្រូវបានរួចផុតពីការទទួលខុសត្រូវដែរ ។

**មាត្រា ៨១៧** ៖ ម្ចាស់សត្វពាហន ឬជនដែលប្រើសត្វនោះ វេលាដែលសត្វនោះនៅក្នុងអំណាចខ្លួន ត្រូវទទួលខុសត្រូវចំពោះអំពើដែលសត្វនោះធ្វើឲ្យខូចខាតរបស់គេ ទោះធ្វើឲ្យខូចខាតក្នុងវេលារត់រួចក្ដីក្នុងវេលា វង្វេង ខ្ចាត់ ភ្លាត់ ក្ដី ។

**មាត្រា ៨១៨** ៖ ម្ចាស់ទ្រព្យ ត្រូវទទួលខុសត្រូវ អំពីសេចក្ដីខូចខាត ដែលកើតអំពីរបស់នៃខ្លួន កាលណាបើសេចក្ដីខូចខាតនោះបណ្ដាលមកអំពីការខានថែទាំ ខានត្រួតត្រា ឬ ក៏ដោយរបស់នោះសង់មិនល្អ ។

## ផ្នែកទី៣
## ភាគព្វកិច្ច កើតអំពីសេចក្ដីចំរើនដោយឥតហេតុ
### កថាខ័ណ្ឌទី១
### អំពី សងប្រាក់ ដែលគ្មានជំពាក់

**មាត្រា ៨១៩** ៖ ជនណាមិនបានជំពាក់គេទេ តែភ័ន្តច្រឡំថាខ្លួនជំពាក់គេហើយក៏បានសងទ្រព្យ ដែលខ្លួនមិនបានជំពាក់នោះទៅគេ ជននោះអាចប្ដឹងទារយកវិញបាន ។

**មាត្រា ៨២០** ៖ ដែលនឹងប្ដឹងទារវិញនោះ គឺប្ដឹងឲ្យបង្វិលរបស់ ដែលលើកទៅឲ្យគេខុសនោះមកវិញក្ដី នឹងប្ដឹងឲ្យសងថ្លៃរបស់នោះក្ដី នឹងប្ដឹងឲ្យសងតម្លៃតាវកាលិកដែលខ្លួនបានបំពេញហើយនោះក្ដី ។

**មាត្រា ៨២១** ៖ ជនណាបានសំណាងនូវរបស់ ដែលគេមិនបានជំពាក់ខ្លួនសោះដោយសត្យសុចរិត ឥតចេតនាក្លែង ជននោះត្រូវបង្វិលរបស់ដែលគេប្រគល់ឲ្យនោះទៅគេវិញ បើរបស់នោះគង់នៅក្នុងដៃរបស់ខ្លួននៅឡើយ ។ ថាបើរបស់នោះមិននៅក្នុងដៃខ្លួនទេ ជននោះត្រូវសងថ្លៃលក់ឲ្យគេ ។

បើតាវកាលិកនោះជាការដែលគេបានធ្វើឲ្យជននោះត្រូវសងតម្លៃនៃការ ។

**មាត្រា៨២២** ៖ បើរបស់នោះបាត់ ឬ ខូចដោយខុសពីខ្លួនជននោះត្រូវទទួលសងគេ ។

**មាត្រា ៨២៣** ៖ ជនណាទទួលដោយចេតនាទុចរិត នូវសំណាងដែលខ្លួនដឹងថាគេមិនបានជំពាក់ខ្លួនទេ ជននោះត្រូវបង្វិលរបស់ដែលគេប្រគល់ឲ្យនោះទៅគេវិញបើជាទទួលប្រាក់វិញត្រូវសងការគេទៀតដោយគិតមួយឆ្នាំ ៥% បើជាទទួលវត្ថុដែលបង្កើតផល ជននោះត្រូវសងផលនោះដល់គេផងមួយទៀតបើនឹងផ្តន្ទាទោសឲ្យសងជម្ងឺចិត្តគេទៀតផង ក៏បាន ។

**មាត្រា ៨២៤** ៖ បើរបស់នោះបាត់ ឬ ខូចខាតជននោះត្រូវទទួលសងគេទោះបាត់ ឬ ខូចខាតដោយករណីប្រធានស័ក្តិក៏ដោយ ។

## កថាខ័ណ្ឌទី២
## អំពី ការគ្រប់គ្រងដោយឈឺឆ្អាល

**មាត្រា ៨២៥** ៖ ជនណាឥតគេពឹងរក ហើយទទួលគ្រប់គ្រងនូវទ្រព្យសម្បត្តិនៃជនដទៃ ដោយឈឺឆ្អាលពីចិត្តឯង ជននោះត្រូវទទួលគ្រប់គ្រង គ្រាតែដល់ម្ចាស់គេមកគ្រប់គ្រងខ្លួនគេវិញ ។ ជននោះត្រូវយកចិត្តទុកដាក់ចាត់ចែងការបីដូចជាឪពុកដ៏ប្រពៃនៃត្រកូលគឺថាទុកខ្លួនដូចជាម្ចាស់របស់ពិត១ និងយកចិត្តទុកដាក់នឹងផលប្រយោជន៍ទ្រព្យនោះផង ។

**មាត្រា ៨២៦** ៖ កម្មសិទ្ធិករ នៃបេតិកភ័ណ្ឌ ដែលគេបានគ្រប់គ្រងឲ្យដោយត្រឹមត្រូវនោះត្រូវសងទៅអ្នក ដែលគ្រប់គ្រងនោះនូវប្រាក់ដែលគេបានចេញ

ចាយវាយក្នុងការជាចាំបាច់ ឬ ក្នុងការមានប្រយោជន៍ទាំងប៉ុន្មាន១ទៅគេវិញមួយទៀតជននោះត្រូវគិតសោហ៊ុយនៃសេចក្ដីលំបាកក្នុងការថែរក្សានោះឲ្យគេផងទៀត ។

## ផ្នែកទី៤
## អំពីភារពូកិច្ច កើតពីច្បាប់

**មាត្រា ៨២៧** ៖ ចៅហ្វាយនាយ និងដង្ហៅ ត្រូវចេញប្រាក់កំជាប់ព្រលឹងឲ្យបាវព្រាវ មនុស្សបំរើ កូនជាង ឈ្នួល និងមនុស្សរៀនធ្វើការរបស់ខ្លួនក្នុងករណីដែលមានគ្រោះថ្នាក់បណ្ដាលមក ក្នុងវេលាបំពេញការងារ ដែលខ្លួនប្រើឲ្យធ្វើ ។

**មាត្រា ៨២៨** ៖ បើគ្រោះនោះ គ្រាន់តែនាំឲ្យអសមត្ថភាពខានធ្វើការមានកំណត់វេលាទេ ចៅហ្វាយនាយ ដង្ហៅ ត្រូវទទួលចេញសោហ៊ុយ ក្នុងការព្យាបាលជម្ងឺនៃមនុស្សនោះ តែទោះយ៉ាងណាក្ដីថ្លៃនៃការថែទាំនោះ មិនត្រូវឲ្យហួសពីចំនួនឈ្នួលឡើយ ។

**មាត្រា ៨២៩** ៖ បើគ្រោះថ្នាក់នោះ បណ្ដាលឲ្យពិការជាប់ជានិច្ច ចៅហ្វាយនាយ ដង្ហៅ ត្រូវចេញប្រាក់ សំណងចិត្តឲ្យមនុស្សទទួលគ្រោះនោះ ។

**មាត្រា ៨៣០** ៖ បើចៅហ្វាយ នាយ ឬ ដង្ហៅ សុំទុកមនុស្សនោះឲ្យនៅនឹងខ្លួន ហើយមនុស្សដែលរងគ្រោះនោះក៏សុខចិត្តផងចៅហ្វាយនាយ ឬ ដង្ហៅនោះមិនត្រូវចេញសំណងចិត្ត ឲ្យអ្នកគ្រោះសោះឡើយ ។

**មាត្រា ៨៣១** ៖ នាកាលគ្រោះថ្នាក់នោះ ជាគ្រោះដល់ស្លាប់ចៅហ្វាយនាយ ដង្ហៅ ត្រូវចេញប្រាក់ធ្វើបុណ្យសព មួយទៀតត្រូវឲ្យចេញប្រាក់សំណងចិត្ត

ឲ្យសមាជិក នៃគ្រួសាររបស់អ្នកស្លាប់ ដែលនៅក្នុងបន្ទុកខ្មោចនោះផង ដោយមិនឲ្យចំនួនប្រាក់នោះលើសពីឈ្នួលទេ ។

**មាត្រា ៨៣២** ៖ បើចៅហ្វាយនាយ ឬដង្ហោ សុខចិត្តចិញ្ចឹមរក្សាមនុស្ស ដែលនៅក្នុងបន្ទុកខ្មោចនោះ ហើយមនុស្សទាំងនោះក៏ព្រមផងដែរ ចៅហ្វាយ ឬដង្ហោ មិនត្រូវចេញប្រាក់សំណងចិត្តឲ្យទៀតឡើយ ។

**មាត្រា ៨៣៣** ៖ ក្នុងករណីទាំងឡាយ ដែលមនុស្សទទួលគ្រោះថ្នាក់ក្នុងការងារនាំ ឬញាតិសារលោហិតនៃមនុស្សនេះ និងចៅហ្វាយនាយ ឬដង្ហោមិនព្រមព្រៀងគ្នាអំពីចំនួនប្រាក់កំជាប់ព្រលឹងនោះទេ តុលាការត្រូវជំនុំជំរះឲ្យ ។

**មាត្រា ៨៣៤** ៖ ដូច្នេះបើអ្នករងគ្រោះនោះ ពិការជានិច្ច តុលាការត្រូវថ្លឹងតាមកម្លាំង កាយដែលថមថយ ដោយគ្រោះនោះ និងតាមចំនួនថ្លៃឈ្នួល ដែលមនុស្សនោះត្រូវបើកក្នុងមួយថ្ងៃ១។ ប្រសិនបើ ជាគ្រោះដល់ស្លាប់ តុលាការត្រូវថ្លឹងតាមថ្នាក់ញាតិជិត ឬឆ្ងាយនៃមនុស្ស ដែលនៅក្នុងបន្ទុកខ្មោច និងលៃឲ្យសមនឹងសេចក្តីត្រូវការនៃជនទាំងនោះផង ។

ក្នុងករណីទាំងឡាយនេះ តុលាការត្រូវពិនិត្យផង ក្រែងគ្រោះនោះកើតដោយសារតែកំហុសរបស់មនុស្សទទួលគ្រោះនោះ ឬ ដោយហេតុល្ងង់មិនប្រសប់ការដើម្បីនឹងបានបន្ថយចំនួនប្រាក់កំជាប់ព្រលឹងនោះខ្លះទៀត ។

# ចំពូកទី២
# អនុភាព នៃ កាតព្វកិច្ច
## ផ្នែកទី១
## សេចក្ដីទូទៅ

**មាត្រា ៨៣៥** ៖ ជនឯណាជាប់កាតព្វកិច្ចផ្ទាល់ខ្លួន ជននោះត្រូវទទួលបំពេញនូវកាតព្វកិច្ច នៃខ្លួនមួយអន្លើដោយចលវត្ថុ និងអចលវត្ថុរបស់ខ្លួនដែលមានក្នុងបច្ចុប្បន្នកាលនិងក្នុងអនាគតកាល ។

បើមិនមានទ្រព្យនឹងសងគេទេ ជននោះអាចនឹងត្រូវដាក់គុកបង្ខំដល់ខ្លួនប្រាណបាន ។

**មាត្រា ៨៣៦** ៖ ការផ្ទេរ នូវកម្មសិទ្ធិ ចលវត្ថុ នឹងផុតពីសេចក្ដីតវ៉ារបស់តតិយជនបាន លុះត្រាតែកម្មសិទ្ធិករ បានប្រគល់វត្ថុនោះដោយប្រត្យ័ក្ស ។

**មាត្រា ៨៣៧** ៖ (ក្រ.២៩៩នស.១៧-៨-៥៥)ការ. ដែលផ្ទេរ នូវកម្មសិទ្ធិអចលវត្ថុ និងសិទ្ធិប្រត្យ័ក្ស អចលវត្ថុនោះ នឹងទុកជាភ័ស្ដុតាងរវាងភាគីបានលុះត្រាតែការនោះបានធ្វើជាសំបុត្រយថាភូតគឺចុះសេចក្ដីបញ្ជាក់ ឬ ធ្វើនៅសាការី ។ បើផ្ទេរអចលវត្ថុអ៊ីម៉្មាទ្រីគុឡាស្បុងផង សំបុត្រយថាភូតនេះត្រូវចុះក្នុងបញ្ជីការអ៊ីម៉្មាទ្រីគុឡាស្យុងទៀត ទើបតតិយជនមានអាចតវ៉ាបាន ។

**មាត្រា ៨៣៨** ៖ ការដែលផ្ទេរនូវកម្មសិទ្ធិចលវត្ថុ និងសត្វពាហនៈឯណាដែលបទបញ្ញាទាំងឡាយតម្រូវឲ្យគោរពតាមរូបមន្តប្រថាប់ត្រាដែរក៏ត្រូវធ្វើដូចគ្នាដែរ ។

**មាត្រា ៨៣៩** ៖ បើកំដឹងម្នាក់ មានកាតព្វកិច្ចត្រូវប្រគល់ចលវត្ថុមួយឲ្យជនច្រើនរូបបន្តបន្ទាប់គ្នាជនណាបានទទួលវត្ថុនោះជាភោគៈប្រាកដ ហើយជននោះត្រូវបានជាកម្មសិទ្ធិករនៃវត្ថុនោះទោះបីប័ណ្ណ ដែលត្រូវប្រគល់ឲ្យដល់ជននោះចុះថ្ងៃក្រោយគេក្ដីឲ្យតែ ភោគៈនោះបានបកដោយសុចរិត ។

**មាត្រា ៨៤០** ៖ ដែលហៅថា ភយន្តរាយ នោះគឺព្រឹត្តិការណ៍ដែលបណ្ដាលឲ្យអន្តរាយ ឬ ឲ្យខូចនូវវត្ថុដែលជាប់ក្នុងកាតព្វកិច្ច ។

**មាត្រា ៨៤១** ៖ បើវត្ថុនោះមិនទាន់បានប្រគល់ឲ្យម្ចាស់បំណុលដរាបណាភយន្តរាយ ដែលកើតឡើងលើវត្ថុនោះត្រូវនៅជាកាៈលើកំដឹងដរាបនោះថាបើវត្ថុនោះបានប្រគល់ឲ្យម្ចាស់បំណុលផុតហើយ ភយន្តរាយនោះត្រូវនៅលើខ្លួនម្ចាស់បំណុលវិញ ។

**មាត្រា ៨៤២** ៖ បើកំដឹង បានប្រាប់ម្ចាស់បំណុល ឲ្យយកវត្ថុហើយ កំដឹងត្រូវរួចខ្លួនស្រលះ ពីការទទួលខុសត្រូវហើយ តែភយន្តរាយទាំងឡាយនោះត្រូវធ្លាក់លើខ្លួនម្ចាស់បំណុល ដូចជាកំដឹងបានប្រគល់វត្ថុនោះ ដល់ម្ចាស់បំណុលដែរ ។

**មាត្រា ៨៤៣** ៖ នាកាលមានករណី ជាមមាញឹក ឬ ជាប្រធានសក្ដិនាំឲ្យភាគីម្ខាងមិនអាចបំពេញនូវកាតព្វកិច្ចរបស់ខ្លួនបានយ៉ាងណា, កាតព្វកិច្ចរបស់ភាគីម្ខាងទៀតក៏ត្រូវរលត់ក្នុងខណៈជាមួយគ្នាយ៉ាងនោះដែរ ។

## ផ្នែកទី២
## សិទ្ធិ នៃម្ចាស់បំណុល

**មាត្រា ៨៤៤** ៖ ម្ចាស់បំណុលទាំងឡាយ អាចប្រើប្រាស់នូវសិទ្ធិរបស់កូនបំណុលខ្លួនបាន និងអំណាចប្ដឹងផ្ដល់តាងកូនបំណុលខ្លួនបានលើកមួយតែសិទ្ធិ និងអំណាចប្ដឹងផ្ដល់ទាំងឡាយណាដែលជាប់ផ្ទាល់នឹងខ្លួនបុគ្គលនេះ មានសិទ្ធិទទួលមត៌កជាដើមតែប៉ុណ្ណោះ ម្ចាស់បំណុល អាចនឹងប្ដឹងឲ្យរឹបអូស លក់ឡាយឡុងល... នូវទ្រព្យនៃកូនបំណុលបាន និងសុំឲ្យដាក់គុកបង្ខំដល់រូបកាយទៀតក៏បានកាលណាបើតុលាការអនុញ្ញាតឲ្យ ។

**មាត្រា ៨៤៥** ៖ ម្ចាស់បំណុល អាចនឹងប្ដឹង សុំឲ្យបដិសេធ នូវកិច្ចសន្យាទាំងឡាយណា ដែលកូនបំណុលបានធ្វើ ដោយលួចលាក់ ជាទីបង្ខូចប្រយោជន៍នៃខ្លួនជាម្ចាស់បំណុលបាន ។

**មាត្រា ៨៤៦** ៖ កិច្ចសន្យាទាំងនោះ អាចនឹងទុកជាមោឃៈ បានកាលណាបើកិច្ចសន្យានោះធ្វើទទេឥតថ្លៃ ឬ បើធ្វើមានថ្លៃក៏ឃើញពិតថាតតិយជនដែលទៅចុះកិច្ចសន្យាជាមួយនឹងកូនបំណុលនោះដោយចេតនាទុច្ចរិតដែរ ។

**មាត្រា ៨៤៧** ៖ ចេតនាទុច្ចរិតរបស់តតិយជននោះ ត្រូវសំគាល់យ៉ាងនេះគឺកាលបើឃើញថាថ្លៃតិចក្រៃពេក ឬ ថាកូនបំណុល និងតតិយជនដែលបានចុះកិច្ចសន្យានឹងគ្នានោះជាប់ជាញាតិ ឬ ជាបាវ ជាចៅហ្វាយនាយនឹងគ្នា ឬ មួយសោតក៏ជាមនុស្សរួមលំនៅនឹងគ្នាដែរ ។

**មាត្រា ៨៤៨** ៖ ក្នុងករណីទាំងឡាយ ដែលមិនបានពិរុទ្ធថាតតិយជននោះមានចេតនាទុច្ចរិតទេម្ចាស់បំណុល ដែលប្ដឹងពីបទទុច្ចរិតនោះត្រូវរកតឹកតាងនៃសំដីខ្លួនជូនតុលាការមកជាទីអាងផង ។

**មាត្រា ៨៤៩** ៖ ដែលហៅថា សោហ៊ុយជម្ងឺចិត្តនោះ គឺចំនួនប្រាក់ជាតម្លៃនៃសេចក្ដីខូចខាត ដែលបណ្ដាលមកពីកិរិយាមិនប្រតិបត្តិតាមកាតព្វកិច្ចណាមួយ ឬ ក៏ប្រតិបត្តិដែរតែយឺតយូរពេក ។

**មាត្រា ៨៥០** ៖ សោហ៊ុយជម្ងឺចិត្តនោះ នឹងត្រូវបានទៅម្ចាស់បំណុល លុះត្រាតែម្ចាស់បំណុលប្រាកដជាបានតឿនកូនបំណុល ឲ្យប្រតិបត្តិតាមកាតព្វកិច្ចហើយ ។

**មាត្រា ៨៥១** ៖ បើកំដឹងមិនបានប្រតិបត្តិនូវកាតព្វកិច្ចដោយសារមានករណីប្រធានសក្ដិទេម្ចាស់បំណុលមិនត្រូវបានជម្ងឺចិត្តឡើយ ។

**មាត្រា ៨៥២** ៖ ម្ចាស់បំណុលមិនត្រូវបានជម្ងឺចិត្តទេ ប្រសិនបើខ្លួនគ្មានព្យសនកម្ម ឬ ខូចខាតអ្វីទេ ។

**មាត្រា ៨៥៣** ៖ ប៉ុន្តែបើមានបទបញ្ញត្តិពិសេស បង្គាប់ឲ្យមានជម្ងឺចិត្តនោះត្រូវតែឲ្យម្ចាស់បំណុលបានជម្ងឺចិត្ត ដោយមិនបាច់ម្ចាស់បំណុលបញ្ជាក់ពីខូចខាតអ្វីទេ និងមិនបាច់ឲ្យម្ចាស់បំណុលបានតឿនទារកូនបំណុលឡើយ ។

**មាត្រា ៨៥៤** ៖ បើគូសន្យា បានចុះចំនួនជម្ងឺចិត្តក្នុងកិច្ចសន្យាហើយតុលាការនឹងកែប្រែចំនួនជម្ងឺចិត្តដែលគូសន្យាបានព្រមព្រៀងគ្នា ហើយនោះពុំបាន

ឡើយ លើកមួយតែក្នុងករណីដែលភាគីម្ខាងប្រតិបត្តិនូវកាតព្វកិច្ចនោះបានភាគខ្លះដែរហើយ ។

**មាត្រា ៨៥៥** ៖ បើកិច្ចសន្យាមិនបានកំណត់នូវចំនួនជម្ងឺចិត្តទេ តុលាការត្រូវសម្រេចចំនួនជម្ងឺចិត្តនោះលៃតាមការខូចខាតផងតាមចំណេញ ដែលម្ចាស់បំណុលខានបានផង ។

**មាត្រា ៨៥៦** ៖ បើអ្នកចាញ់សេចក្ដីដប្អូក់ មិនប្រតិបត្តិតាមសាលក្រមទេ តុលាការនឹងកាត់ឲ្យសងសោហ៊ុយក្រៅពីជម្ងឺចិត្តទៀតក៏បាន ។

**មាត្រា ៨៥៧** ៖ ចំពោះកាតព្វកិច្ចទាំងពួង ដែលប្ដេជ្ញាថា កូនបំណុលត្រូវធ្វើ ឬ មិនត្រូវធ្វើ ហើយកូនបំណុលមិនបានប្រតិបត្តិតាមទេ តុលាការត្រូវសម្រេចឲ្យសងជាជម្ងឺចិត្ត ។

**មាត្រា ៨៥៨** ៖ តុលាការអាចនឹងបង្គាប់ឲ្យបំផ្លាញ នូវការឯណាដែលកូនបំណុលមិនត្រូវធ្វើ ឬ បង្គាប់ឲ្យធ្វើនូវការឯណា ដែលកូនបំណុលមានកាតព្វកិច្ចត្រូវតែធ្វើ ដោយបង់ខាតលើខ្លួនកូនបំណុល ក្រៅពីជម្ងឺចិត្តផងទៀតក៏បាន ។

**មាត្រា ៨៥៩** ៖ ក្នុងករណីដែលកាតព្វកិច្ចនោះ ស្ដីពីការសងប្រាក់ នោះការយឺតយូរក្រសងនេះ នឹងនាំឲ្យម្ចាស់បំណុលមានសិទ្ធិបានការប្រាក់ អំពីប្រាក់ដែលត្រូវសងដោយត្រូវគិតតាមអត្រាច្បាប់ ៥%ក្នុង១ឆ្នាំ ។

# ចំពូក៣
# បែបយ៉ាងនៃកាតព្វកិច្ច
## ផ្នែកទី១
## កាតព្វកិច្ចមានល័ក្ខខ័ណ្ឌ

**មាត្រា ៨៦០** ៖ កាតព្វកិច្ចដែលមានល័ក្ខខ័ណ្ឌនោះ គឺកាតព្វកិច្ចដែលពឹងផ្អែកលើព្រឹត្តិការណ៍ណាមួយ ដែលនៅក្នុងអនាគត និងដែលមិនទៀងទាត់ផង: ល័ក្ខខ័ណ្ឌមានពីរបែបគឺ:

១- ល័ក្ខខ័ណ្ឌថា កាតព្វកិច្ចត្រូវបង្អង់ ប្រតិបត្តិដរាបដល់មានព្រឹត្តិការណ៍ណាមួយកើតឡើង ។

២- ល័ក្ខខ័ណ្ឌថា កាតព្វកិច្ចត្រូវបដិសេធចោល កាលណាបើមានព្រឹត្តិការណ៍ណាមួយកើតឡើង ។

**មាត្រា៨៦១** សិទ្ធិ នៃម្ចាស់បំណុល ឬ កាតព្វកិច្ចនៃកូនបំណុលដែលស្លាប់មុនបានបំពេញល័ក្ខខ័ណ្ឌនោះត្រូវធ្លាក់ទៅលើទាយាទទាំងឡាយនៃអ្នកស្លាប់នោះ ។

**មាត្រា ៨៦២** ៖ កូនបំណុលណាចុះល័ក្ខខ័ណ្ឌ ថាសុំបង្អង់ប្រតិបត្តិកាតព្វកិច្ចនោះសិន លុះដល់មានភយន្តរាយណាមួយកើតឡើងដល់វត្ថុដែលជាប់កាតព្វកិច្ចវេលាណាវេលានោះកូនបំណុលត្រូវទទួលធុរៈខូចខាតលើខ្លួន ។

បើវត្ថុនោះដល់នូវក្តីវិនាស មុនព្រឹត្តិការណ៍ដែលឥតមានកំហុសលើកូនបំណុលទេ កាតព្វកិច្ចនោះត្រូវរលត់ឯង បើវត្ថុនោះខូចម្ចាស់បំណុលរំលាយកាតព្វកិច្ចនោះចោលក៏បាន ឬ តម្រូវឲ្យប្រគល់របស់នោះទាំងខូចខាតឲ្យខ្លួនដោយគ្មានបន្ថយថ្លៃក៏បាន ។

**មាត្រា ៨៦៣** ៖ ក្នុងករណីមានកំហុសពីកូនបំណុល ម្ចាស់បំណុលអាចនឹងរំលាយកាតព្វកិច្ចនោះចោល ហើយត្រូវឲ្យកូនបំណុលសងជម្ងឺចិត្តវិញម្ចាស់បំណុលអាចតម្រូវឲ្យប្រគល់វត្ថុទាំងខូចនោះដល់ខ្លួនផងទៀតក៏បាន ។

**មាត្រា ៨៦៤** ៖ នាកាលបើការបំពេញ នូវល័ក្ខខ័ណ្ឌ នោះមានអនុភាពថាត្រូវលប់កាតព្វកិច្ចនោះចោលទៅវិញ កាតព្វកិច្ចនោះមិនមែនត្រូវបង្អង់ប្រតិបត្តិឡើយ ការបំពេញនូវល័ក្ខខ័ណ្ឌនោះ មានអានុភាពត្រូវបង្ខំម្ចាស់បំណុលឲ្យប្រគល់ទៅកូនបំណុលវិញនូវរបស់អ្វីដែលខ្លួនបានប្រគល់ហើយ ។

## ផ្នែកទី២
## កាតព្វកិច្ចមានកំណត់កាល

**មាត្រា ៨៦៥** ៖ ដែលហៅថាកាតព្វកិច្ចមានកំណត់កាល នោះគឺកាតព្វកិច្ចដែលមិនអាចតម្រូវឲ្យប្រតិបត្តិមុនថ្ងៃកំណត់ដែល ហៅថាថ្ងៃណាត់នោះបានទេ ។

**មាត្រា ៨៦៦** ៖ បើកូនបំណុលបានសងមុខថ្ងៃណាត់ ពីចិត្តឯង ឬ ដោយភ័ន្តច្រឡំកូនបំណុលមិនអាចឲ្យគេបង្វិលប្រាក់នោះទៅខ្លួនវិញ ដោយហេតុថាមិនទាន់ដល់ថ្ងៃសន្យាថាចាំដល់ថ្ងៃសន្យានោះសិនសឹមសងបានទេ ។

**មាត្រា ៨៦៧** ៖ កាលណាបើកូនបំណុលប្រព្រឹត្តិដោយប្រការឯណានាំឲ្យខូចសេចក្ដីនានា ដែលខ្លួនបានជូនដល់ម្ចាស់បំណុលកូនបំណុលនោះត្រូវថ្លស់ខ្លួនលែងបានប្រកាន់តាមថ្ងៃណាត់ហើយ ។

## ផ្នែកទី៣
## កាតព្វកិច្ច អនិយ័ត

**មាត្រា ៨៦៨** ៖ កាតព្វកិច្ចអនិយ័តនោះ គឺកាតព្វកិច្ចដែលមានវត្ថុច្រើនមុខជាទីតាំង ប៉ុន្តែបើភាគីយកវត្ថុមុខណាតែមួយមកប្រតិបត្តិ ហើយសេចក្តីប្រតិបត្តិនោះនឹងរលត់នូវកាតព្វកិច្ចដែលទាក់ទងដល់វត្ថុទាំងឡាយដទៃទៀត ។

**មាត្រា ៨៦៩** ៖ បើមិនមានប្តេជ្ញាថា ឲ្យម្ចាស់បំណុលរើសវត្ថុណាមួយជាប្រាកដទេ ការជ្រើសរើសឲ្យទៅម្ចាស់បំណុលនោះ ស្រេចនៅលើកូនបំណុល ។

**មាត្រា ៨៧០** ៖ បណ្តាវត្ថុទាំងឡាយនោះ បើវត្ថុណាមួយដល់នូវក្តីវិនាសកាតព្វកិច្ចនោះត្រូវតែគង់នៅចំពោះវត្ថុឯទៀតដែរ ។

បើវត្ថុទាំងអស់អន្តរាយទាំងអស់ ទើបកាតព្វកិច្ចត្រូវរលត់ឯង ។

**មាត្រា ៨៧១** ៖ បើបានព្រមព្រៀងឲ្យម្ចាស់បំណុលជ្រើសយកវត្ថុដោយខ្លួនឯងវិញ ហើយបណ្តាវត្ថុទាំងឡាយនោះ វត្ថុឯណាមួយដល់នូវក្តីវិនាសតែឥតមានកំហុសពីកូនបំណុលទេ ម្ចាស់បំណុលត្រូវតែរើសយកវត្ថុឯទៀតបណ្តាវត្ថុទាំងឡាយដែលនៅសល់ ។

បើខុសពីកូនបំណុលវិញ ម្ចាស់បំណុលអាចនឹងទារយកវត្ថុឯណាមួយដែលគង់នៅ ឬ នឹងឲ្យសងថ្លៃវត្ថុ ដែលអន្តរាយនោះក៏បាន

បើវត្ថុទាំងអស់ដល់នូវក្តីវិនាសព្រមគ្នា ដោយហេតុខុសមកពីកូនបំណុល ម្ចាស់បំណុលអាចនឹងតម្រូវឲ្យកូនបំណុល សងថ្លៃវត្ថុឯណាមួយដែលគាប់ចិត្តខ្លួនបាន ។

## ផ្នែកទី៤
## កាតព្វកិច្ចដោយសាមគ្គីភាព

**មាត្រា ៨៧២** ៖ សាមគ្គីភាពរវាងម្ចាស់បំណុលក្តី សាមគ្គីរវាងកូនបំណុលក្តីនឹងយកការស្មាននឹងចិត្តឯងមកប្រមាណមិនបានឡើយ ដែលអាចនឹងទុកជាសាមគ្គីភាពបាននោះ លុះត្រាតែការរួបរួមនោះមានសំដែងច្បាស់ក្នុងសារលិខិតណាមួយប្រសិនបើច្បាប់មិនបានបញ្ញត្តិអំពីសាមគ្គីនេះទេ ។

### កថាខ័ណ្ឌទី១
### សាមគ្គីភាពរវាងម្ចាស់បំណុល

**មាត្រា ៨៧៣** ៖ កាលណាបើម្ចាស់បំណុលតែម្នាក់ បណ្តាម្ចាស់បំណុលទាំងឡាយនោះមានសិទ្ធិទាមទារឲ្យកូនបំណុលបំពេញនូវកាតព្វកិច្ចទាំងអស់ ដើម្បីខ្លួនតែម្នាក់ឯងកាតព្វកិច្ចបែបនេះហៅថា កាតព្វកិច្ចមានសាមគ្គីរវាងម្ចាស់បំណុល ។

**មាត្រា ៨៧៤** ៖ នាកាលកូនបំណុលបានបំពេញកាតព្វកិច្ចឲ្យម្ចាស់បំណុលតែម្នាក់រួចហើយកូនបំណុលនេះត្រូវរួចពីជំពាក់ម្ចាស់បំណុលឯទៀតដែរ ។

**មាត្រា ៨៧៥** ៖ កូនបំណុលមានសេរីភាពនឹងរើសម្ចាស់បំណុល ដែលខ្លួនចូលចិត្តសងបានលើកមួយតែក្នុងករណី ដែលមានម្ចាស់បំណុលណាម្នាក់បណ្តាម្ចាស់ទាំងឡាយនោះបានប្តឹងផ្តល់ ហើយក្នុងករណីនេះកូនបំណុលត្រូវសងទៅអ្នកដែលបានប្តឹង ។

**មាត្រា ៨៧៦** ៖ បណ្ដាម្ចាស់បំណុលសាមគ្គីទាំងឡាយ ម្ចាស់បំណុលណាម្នាក់លើកនូវកាតព្វកិច្ចខ្លួនចោល ហើយកូនបំណុលអាចរួចខ្លួនពីបំណុលបានតែចំពោះចំណែកនៃម្ចាស់បំណុលនោះ ។

**មាត្រា ៨៧៧** ៖ បើម្ចាស់បំណុលណាម្នាក់បណ្ដាម្ចាស់បំណុលសាមគ្គីទាំងឡាយ បញ្ឈប់ដំណើរនៃអាជ្ញាយុកាល ដោយប្រការឯណាប្រការនៃម្ចាស់បំណុលនោះត្រូវមានផលដល់ម្ចាស់បំណុលដទៃទៀតដែរ ។

## កថាខ័ណ្ឌទី២
## សាមគ្គីភាព រវាងកូនបំណុល

**មាត្រា ៨៧៨** ៖ បើម្ចាស់បំណុលមានកូនបំណុលច្រើននាក់ ហើយម្ចាស់បំណុលអាចនឹងទារបំណុលទាំងអស់របស់ខ្លួន ពីកូនបំណុលណាក៏បានតាមចិត្តស្ម័គ្រកាតព្វកិច្ចនេះហៅថា កាតព្វកិច្ចមានសាមគ្គីភាពរវាងកូនបំណុល ។

**មាត្រា ៨៧៩** ៖ បើកូនបំណុលណាម្នាក់បានបំពេញកាតព្វកិច្ចអស់ហើយ កូនបំណុលសាមគ្គីឯទៀតត្រូវបានរួចខ្លួនចាកកាតព្វកិច្ចដែរ ។

**មាត្រា ៨៨០** ៖ បណ្ដឹងនៃម្ចាស់បំណុល នាំឲ្យបញ្ឈប់ដំណើរការនៃអាជ្ញាយុកាលរបស់កូនបំណុលណាម្នាក់ បណ្ដាកូនបំណុលសាមគ្គីទាំងឡាយបណ្ដឹងនៃម្ចាស់បំណុលនោះនឹងនាំឲ្យបញ្ឈប់ដំណើរ នៃអាជ្ញាយុកាលរបស់កូនបំណុលសាមគ្គីឯទៀតដែរ ។

**មាត្រា ៨៨១** ៖ បើម្ចាស់បំណុលសុខចិត្តបែងកាតព្វកិច្ចសាមគ្គី ឲ្យកូនបំណុលណាម្នាក់ ហើយអ្នកឯទៀតត្រូវគង់នៅជាកូនបំណុលសាមគ្គីរបស់ម្ចាស់

បំណុលដដែល ប៉ុន្តែការនេះត្រូវកាត់ចំណែកឲ្យអ្នក ដែលបានផុតពីសាមគ្គីភាពនោះចេញ ។

**មាត្រា ៨៨២** ៖ បណ្ដាកូនបំណុលសាមគ្គីទាំងឡាយ កូនបំណុលណាម្នាក់បានបំពេញកាតព្វកិច្ចតែមួយភាគ ទោះបីម្ចាស់បំណុលបានទទួលហើយក្ដី ក៏ការបំពេញនេះមិននាំឲ្យកូនបំណុលម្នាក់នោះចេញរួចពីសាមគ្គីភាពដែរ ប្រសិនបើគ្មានលិខិតណាចែងឲ្យប្រាកដ ឬ ម្ចាស់បំណុលឆ្លើយឲ្យច្បាស់ជាឲ្យចេញផុតពីបំណុលសាមគ្គីនេះទេ ។

**មាត្រា៨៨៣** ៖ កូនបំណុលសាមគ្គីផងគ្នា ត្រូវទទួលបំពេញកាតព្វកិច្ចតាមចំណែករៀងខ្លួន ។

**មាត្រា៨៨៤** ៖ សេចក្ដីខូចខាតព្រោះកូនបំណុលផងគ្នាម្នាក់ ឬ ច្រើននាក់ជាអសាធនីយ(រកអ្វីសងគ្មាន) នោះតម្រូវឲ្យកូនបំណុលឯទៀត ដែលជាសាធនីយ (អាចសងបាន) ឲ្យទទួលសងតាមសមាមាត្រនៃចំណែករបស់ខ្លួន គឺថាចំណែកនោះ បើគ្មានបទបញ្ញត្តិឯណាកំណត់ថានរណាត្រូវសងប៉ុន្មានៗទេ ត្រូវសន្មតថាឲ្យសងភាគស្មើៗគ្នា ។

## ផ្នែកទី៥
## ភាគព្វកិច្ច អវិភាគីយ (ដែលចែកមិនបាន)

**មាត្រា ៨៨៥** ៖ កាតព្វកិច្ចណាដែលមិនអាចបំបែកចែកគ្នាបំពេញតាមភាគបានទេកាតព្វកិច្ចនោះហៅថា កាតព្វកិច្ចអវិភាគីយ ។

**មាត្រា ៨៨៦** ៖ កូនបំណុលផងគ្នាក្តី ទាយាទនៃកូនបំណុលដែលជាប់កាតព្វកិច្ច អវិភាគីយក្តី ត្រូវទទួលបំពេញកាតព្វកិច្ចនោះរៀងៗខ្លួន ថ្វីបើកាតព្វកិច្ចនោះមិនបានចែង អំពីសាមគ្គីភាពក៏ដោយ ។

## ចំពូកទី៤
## អំពីការរលត់នៃកាតព្វកិច្ច

**មាត្រា ៨៨៧** ៖ កាតព្វកិច្ចត្រូវរលត់:

១- ដោយបានប្រតិបត្តិហើយ ។

២- ដោយមិនអាចប្រតិបត្តិកើត ។

៣- ដោយបានផាត់វត្ថុដទៃ ឲ្យជាសំណងហើយ ។

៤- ដោយបានលើកចោល ដោយចេតនាហើយ ។

៥- ដោយមាននវកម្មហើយ ។

៦- ដោយបានទូទាត់ហើយ ។

៧- ដោយព្យាកុលភាពហើយ ។

៨- ដោយផុតអាជ្ញាយុកាលហើយ ។

### ផ្នែកទី១
### អំពីការប្រតិបត្តិនូវកាតព្វកិច្ច

**មាត្រា ៨៨៨** ៖ កាតព្វកិច្ចឯណា គឺបុគ្គលបានប្រតិបត្តិបរិបូណ៌ហើយ កាតព្វកិច្ចនោះត្រូវរលត់ ។

**មាត្រា ៨៨៩** ៖ ដែលហៅថាប្រតិបត្តិបរិបូណ៌នោះគឺ ការដែលបាន ប្រគល់វត្ថុ ឬធ្វើការងារឲ្យក្ដី ឬ ខានបំពេញការងារអ្វីមួយតាមដែលបានប្ដេជ្ញាគ្នាថាត្រូវខានក្ដី ។

**មាត្រា ៨៩០** ៖ ការប្រតិបត្តិនូវកាតព្វកិច្ចនោះ ត្រូវតែធ្វើឲ្យជាប្រយោជន៍ដល់ម្ចាស់បំណុល។

**មាត្រា ៨៩១** ៖ អំពីការសងវត្ថុជំពាក់នោះ កូនបំណុលរកសងក៏បាន តតិយជនរកសងក៏បាន ។

**មាត្រា ៨៩២** ៖ អំពីសងការងារដែលជំពាក់នោះ ថាបើម្ចាស់បំណុលត្រូវការតែឲ្យកូនបំណុលធ្វើដោយខ្លួនឯង តតិយជននឹងធ្វើសងបំពានចិត្តនៃម្ចាស់បំណុលមិនបានឡើយ ។

**មាត្រា ៨៩៣** ៖ ជនណាក៏ដោយមិនអាចបង្ខំម្ចាស់បំណុល ឲ្យទទួលវត្ថុផ្សេងក្រៅពីវត្ថុដែលជំពាក់នោះបានទេ ទោះវត្ថុដែលប្រគល់ឲ្យនោះមានតម្លៃស្មើនឹងវត្ថុជំពាក់ក្ដីថ្លៃជាងក្ដី ។

**មាត្រា ៨៩៤** ៖ បើមិនបានប្ដេជ្ញាគ្នាដោយចេញវាចាឲ្យច្បាស់ ឬដោយធ្វើសញ្ញាដោយប្រការឯណា ថាត្រូវប្រតិបត្តិនូវកាតព្វកិច្ចនោះ នៅទីណាៗទេ កាតព្វកិច្ចនោះត្រូវប្រតិបត្តិនៅទីលំនៅនៃកូនបំណុល ។

**មាត្រា ៨៩៥** ៖ ជនណាក៏ដោយមិនអាចបង្ខំម្ចាស់បំណុល ឲ្យទទួលព្រមឲ្យកូនបំណុលប្រតិបត្តិនូវកាតព្វកិច្ចតាមភាគបានទេ ។

ប៉ុន្តែដោយយោគយល់ដល់កូនបំណុលឯណា ដែលសុចរិតស្លូតត្រង់ ហើយជាមនុស្សមានស្ថានភាពក្រលំបានផងនោះ តុលាការអាចនឹងកំណត់រយៈវេលាឲ្យ ហើយនឹងបង្គាប់ឲ្យបង្អង់បណ្តឹងជាពិសេសសិនបាន ។

កាលបើបានកាត់សេចក្តីដូច្នេះហើយ តុលាការត្រូវអធិប្បាយហេតុនៃការកាត់នោះឲ្យសព្វគ្រប់ហើយ ចៅក្រមត្រូវប្រើអំណាចនេះដោយសម្ច័យជាទីបំផុត និងឲ្យមានព្រំដែនផង ។

**មាត្រា ៨៩៦** ៖ បើការប្រតិបត្តិកាតព្វកិច្ចនោះ គឺជាកាសងទេ កូនបំណុលដែលជំពាក់ម្ចាស់បំណុលតែម្នាក់នូវកាតព្វកិច្ចច្រើន មានសិទ្ធិនឹងប្រាប់ក្នុងពេលដែលសងថាសំណាងលើកនេះសងបំណុលកាតព្វកិច្ចនេះ ឬ កាតព្វកិច្ចនោះតាមចូលចិត្តរបស់ខ្លួន ។

**មាត្រា ៨៩៧** ៖ បើកូនបំណុលមិនបានប្រាប់យ៉ាងនេះទេ សំណាងនោះត្រូវទុកជាសំណាងបំណុល ដែលមានប្រយោជន៍នឹងសងជាងបំណុលឯទៀត ។

បើបំណុលមានចំនួនស្មើគ្នាទាំងអស់ គេត្រូវពិរុទ្ធថាកូនបំណុលសងបំណុលដែលជំពាក់មកមុនគេបង្អស់ ។

**មាត្រា ៨៩៨** ៖ បើបំណុលមានដើមផង ការផង ហើយកូនបំណុលបានសងខ្លះហើយ ប្រាក់ដែលសងខ្លះនោះត្រូវកាត់ជាការមុន ប្រសិនបើម្ចាស់ប្រាក់មិនបានយល់ព្រមជាប្រាកដថា ប្រាក់សំណាងនោះត្រូវយកទៅកាត់នឹងប្រាក់ដើមទេ ។

**មាត្រា ៨៩៩** ៖ ដែលហៅថា ឧបាទេសកម្ម គឺអំណាចដែលម្ចាស់បំណុលលើកឲ្យទៅតតិយជនណាម្នាក់ ដែលជាអ្នកបានប្រតិបត្តិ នូវកាតព្វកិច្ចរបស់កូនបំណុល ហើយឲ្យប្រើប្រាស់នូវសិទ្ធិរបស់ខ្លួនទាំងប៉ុន្មានចំពោះកូនបំណុល ។

**មាត្រា ៩០០** ៖ ឧបាទេសកម្មដែលកើតពីឆន្ទៈ នៃម្ចាស់បំណុលក្តី កើតពីឆន្ទៈនៃកូនបំណុលក្តី ត្រូវតែធ្វើជាសំបុត្រស្នាមឲ្យប្រាកដដំណាលគ្នា នឹងវេលាដែលបានប្រតិបត្តិនូវកាតព្វកិច្ច ដែលឧបាទេសកម្មនោះត្រូវតែពិនិត្យបញ្ជាក់ទៀត ។

**មាត្រា ៩០១** ៖ ឧបាទេសកម្មនេះ នឹងយកការស្មាននឹងចិត្តឯងមកជាប្រមាណមិនបានឡើយ ។ វាត្រូវកើតពីឆន្ទៈនៃម្ចាស់បំណុល ឬពីឆន្ទៈកូនបំណុល ឬអំពីសេចក្តីបញ្ញត្តិនៃច្បាប់ ។

**មាត្រា ៩០២** ៖ បណ្តាសិទ្ធិដែលច្បាប់ បើឲ្យម្ចាស់បំណុលហើយ ម្ចាស់បំណុលលើកឲ្យទៅតតិយជនតាមឧបាទេសកម្មជាដំណទៀតនេះកាលបើសិទ្ធិនោះជាសិទ្ធិប្រត្យ័ក្ស ឧបាទេសកម្មនោះត្រូវធ្វើជាសំបុត្រមានសេចក្តីបញ្ជាក់ទៀតទើបបាន ។

**មាត្រា ៩០៣** ៖ ម្ចាស់បំណុលឯណាបានដោះ បំណុលម្ចាស់បំណុលដទៃជួសកូនបំណុលខ្លួន ដោយហេតុថាម្ចាស់បំណុលដទៃនោះមានប័ណ្ណប្រសើរជាងប័ណ្ណរបស់ខ្លួន គឺប្រសើរព្រោះប័ណ្ណនោះមានឯកសិទ្ធិ ឬ មួយព្រោះប័ណ្ណនោះមានប្រាតិភោគជាគ្រឿងធានា ម្ចាស់បំណុលនោះត្រូវបានឧបាទេសកម្មពេញសិទ្ធិ ។

**មាត្រា ៩០៤** ៖ ជនណាបានដោយសារទិញដូរក្តី បានទទេក្តីនូវអចលវត្ថុណាមួយដែលជាប់ប្រាតិភោគ ហើយបានសងបំណុលទៅម្ចាស់បំណុលដែលជាអត្តគាហកនៃប្រាតិភោគនោះ ហើយជននោះក៏ត្រូវបានឧបាទេសកម្មដូចគ្នាដែរ ។

**មាត្រា ៩០៥** ៖ កូនបំណុលសាមគ្គីផងគ្នា កូនបំណុលនៃកាតព្វកិច្ចអវិភាគីយផងគ្នា និងអ្នកធានាដែលបានស្ម័គ្ររួម ហើយកូនបំណុលនឹងអ្នកធានាទាំងនោះក៏ត្រូវបាន ឧបាទេសកម្មដែរ ។

**មាត្រា ៩០៦** ៖ ទាយាទដែលបានទទួលមត៌ក ហើយដោះបំណុលនៃមត៌កនោះក៏ត្រូវបានឧបាទេសកម្មដែរ គឺត្រូវបានតែក្នុងព្រំដែននៃសិទ្ធិរបស់ម្ចាស់បំណុលដែលខ្លួនបានដោះនោះ ។

## ផ្នែកទី២
## អំពីកាតព្វកិច្ច ដែលមិនអាចបំពេញកើត

**មាត្រា ៩០៧** ៖ នាកាលវត្ថុ ជាអង្គនៃកាតព្វកិច្ចអន្តរាយ ដោយឥតខុសលើខ្លួនកូនបំណុលទេ ហើយមុនពេលដែលម្ចាស់បំណុលបានប្រាប់ឲ្យធ្វើដូចម្តេចៗផង កាតព្វកិច្ចនោះត្រូវរលត់ឯង ។

## ផ្នែកទី៣
## អំពីផាត់វត្ថុ ដទៃឲ្យជាសំណង

**មាត្រា ៩០៨** ៖ នាកាលកូនបំណុលប្រគល់វត្ថុណាមួយ ដទៃអំពីវត្ថុដែលជាប់ក្នុងកាតព្វកិច្ចឲ្យម្ចាស់បំណុលអំពីនេះហៅថា ផាត់ជាសំណង ។

**មាត្រា ៩០៩** ៖ ដែលផាត់ជាសំណងនេះ បើម្ចាស់បំណុលព្រមផងទើបផាត់បាន ។

## ផ្នែកទី៤
## អំពីលើកកាតព្វកិច្ចចោលដោយចេតនា

**មាត្រា ៩១០** ៖ ដែលហៅថា លើកកាតព្វកិច្ចចោលនោះ គឺម្ចាស់បំណុល លើកសិទ្ធិរបស់ខ្លួនចោលដោយចេតនា ។

**មាត្រា ៩១១** ៖ ការដែលម្ចាស់បំណុលព្រមលើកកាតព្វកិច្ចរបស់ខ្លួន ចោលនោះត្រូវមានភស្តុតាងគឺសំបុត្រ ឬ បង្កាន់ដៃឲ្យរួចជាប្រាកដ ឬ គ្រាន់តែ ប្រគល់ប័ណ្ណបំណុលឲ្យកូនបំណុលវិញក៏បាន ។

**មាត្រា ៩១២** ៖ បើម្ចាស់បំណុល បានប្រគល់ប័ណ្ណបំណុលឲ្យកូនបំណុល ណាម្នាក់ហើយ កូនបំណុលផងគ្នាឯទៀតៗក៏ត្រូវរួចខ្លួនដែរ ។ ឯអ្នកធានាក៏ត្រូវរួច ខ្លួនពីធានាកូនបំណុលដែរ បំណុលក៏ត្រូវរួចស្រឡះពីអ្នកធានាដែរ ។

## ផ្នែកទី៥
## អំពីនវកម្ម

**មាត្រា ៩១៣** ៖ ដែលហៅថានវកម្ម គឺការបង្កើតនូវកាតព្វកិច្ចមួយថ្មីដើម្បី ជាជំនួសកាតព្វកិច្ចចាស់ដែលត្រូវរលត់ជាស្ថាពរ ។

**មាត្រា ៩១៤** ៖ ដើម្បីឲ្យកាតព្វកិច្ចថ្មី កើតឡើងបានត្រូវតែមានការផ្លាស់ ម្ចាស់បំណុល កូនបំណុល ឬក៏ផ្លាស់វត្ថុ ។

**មាត្រា ៩១៥** ៖ នវកម្ម អាចកើតបានពីលិខិតមានរូបមន្តប្រាកដប្រជាបើ កាតព្វកិច្ចរលត់ ឬបើកាតព្វកិច្ចដែលទើបកើតថ្មីប្តេជ្ញាពីអចលវត្ថុ ពីសិទ្ធិប្រត្យ័ក្ស ពី ផ្ទេរកម្មសិទ្ធិ សត្វពាហនៈ ឬ វត្ថុដែលត្រូវគោរពតាមរូបមន្តនៃច្បាប់ប្រថាប់ត្រា នវកម្មនោះត្រូវធ្វើជាសំបុត្របញ្ជាក់ទើបបាន ។

**មាត្រា ៩១៦** ៖ ដែលហៅថាប្រតិភូនោះ គឺសេចក្ដីដែលកូនបំណុលម្នាក់សុំឲ្យ តតិយជនណាម្នាក់ប្រតិបត្តិនូវកាតព្វកិច្ចណាមួយជួសខ្លួន ហើយតតិយជននោះក៏ព្រមទទួលជំនួសផង ។

**មាត្រា ៩១៧** ៖ កូនបំណុលដែលដាក់ឲ្យមានប្រតិភូតាងខ្លួនដូច្នេះ ត្រូវតែឲ្យម្ចាស់បំណុលយល់ព្រមឲ្យប្រាកដផងទើបបាន ។

**មាត្រា ៩១៨** ៖ នវកម្មនេះ ដោះ អ្នកធានា និងកូនបំណុលដែលជាប់កាតព្វកិច្ចចាស់ជាមួយគ្នានោះឲ្យរួចខ្លួនទាំងអស់គ្នា ។

**មាត្រា ៩១៩** ៖ ប្រាតិភោគ នៃកាតព្វកិច្ចចាស់ មិនធានាកាតព្វកិច្ចថ្មីសោះប្រសិនបើគ្មានលិខិតអ្វីចែងច្បាស់លាស់ទេ ។

## ផ្នែកទី៦
## អំពីការទូទាត់

**មាត្រា ៩២០** ៖ ដែលហៅថា ការទូទាត់គ្នានោះ គឺកិរិយារំលត់ដំណាលគ្នានូវកាតព្វកិច្ចដែលខ្លួន ជាកូនបំណុលទៅវិញទៅមក ។

**មាត្រា ៩២១** ៖ កូនបំណុល ត្រូវតែទូទាត់គ្នា កាលណាបើកាតព្វកិច្ចដែលមានទៅវិញទៅមក នោះប្ដេជ្ញា អំពីប្រាក់ ឬអំពីវត្ថុដែលមានប្រភេទដូចគ្នា ។ មួយទៀត កាតព្វកិច្ចនោះ ត្រូវតែមានយ៉ាងពិតប្រាកដ ហើយត្រូវតែសងភ្លាមៗផង ។

**មាត្រា ៩២២** ៖ ការផ្ដល់ទំនិញដែលមានកំណត់តម្លៃ តាមថ្លៃជើង កំពង់នឹងយកទៅទូទាត់ជាមួយនឹងសាច់ប្រាក់បាន ។

**មាត្រា ៩២៣** ៖ ការទូទាត់នឹងមិនអាចធ្វើបានទេកាលណា បើម្ចាស់បំណុលនៃកាតព្វកិច្ចនេះមិនមែនជាកូនបំណុលផ្ទាល់នៃកាតព្វកិច្ចនោះ ហើយម្ចាស់បំណុលនៃកាតព្វកិច្ចនេះ ក៏មិនមែនជាកូនបំណុលផ្ទាល់នៃកាតព្វកិច្ចនោះដែរ ។

**មាត្រា ៩២៤** ៖ អ្នកធានា មិនអាចទទឹង មិនឱ្យទូទាត់បំណុលដែលម្ចាស់បំណុល ជំពាក់កូនបំណុលដែលខ្លួនធានានោះបានទេ ។

កូនបំណុលសាមគ្គី មិនអាចនឹងទទឹងមិនឱ្យទូទាត់បំណុល ដែលម្ចាស់បំណុលជំពាក់កូនបំណុលរួមនោះបានឡើយ ។

**មាត្រា ៩២៥** ៖ កាលបើមានបំណុលច្រើន ដែលអាចនឹងទូទាត់សងបាន នោះការទូទាត់ត្រូវឱ្យសម្រេច តាមបញ្ញត្តិនៃមាត្រា ៨៩៧ ដែលបញ្ញត្តិពីសងបំណុលច្រើន ។

## ផ្នែកទី៧
## អំពីព្យាកុលភាព

**មាត្រា ៩២៦** ៖ ដែលហៅថា ព្យាកុលភាព គឺបែបយ៉ាងមួយនៃការរំលត់នូវកាតព្វកិច្ច ដែលជនម្នាក់ប្រមូលឱ្យមូលមកលើដៃខ្លួនតែម្នាក់ នូវគុណភាពជាម្ចាស់បំណុលផង និងជាកូនបំណុលផង ។

**មាត្រា ៩២៧** ៖ នាកាលកូនបំណុលប្រមូលបំណុល ឱ្យមូលមកលើដៃខ្លួនហើយ អ្នកធានានោះត្រូវបានរួចខ្លួន ។

បើអ្នកធានាប្រមូលបំណុលឱ្យមូលមកលើដៃខ្លួន ហើយកាតព្វកិច្ចគង់នៅដូច ដែល ។

បើកូនបំណុលសាមគ្គី ប្រមូលបំណុលមកលើដៃខ្លួនតែម្នាក់ហើយ កូនបំណុលសាមគ្គីឯទៀត ត្រូវបានចំណោញអំពីប្រមូលនោះត្រឹមតែចំណែកនៃខ្លួនម្នាក់ៗតែប៉ុណ្ណោះ ។

## ផ្នែកទី៨
## អំពីអាជ្ញាយុកាល

**មាត្រា ៩២៨** ៖ បែបយ៉ាងនៃការរំលត់នូវកាតព្វកិច្ច ដែលបណ្ដាលមកពីម្ចាស់បំណុលមិនបានប្ដឹងទារអស់កាលជាអង្វែងពេកហៅថា អាជ្ញាយុកាល ។

**មាត្រា ៩២៩** ៖ បើកូនបំណុល នៅក្នុងឃុំទីទៃ ពីឃុំ ម្ចាស់បំណុលហើយម្ចាស់នេះមិនបានទារក្នុងរវាង៥ឆ្នាំ ចាប់ដើមអំពីថ្ងៃដែលសន្មត់ ថាត្រូវទារនោះមក បំណុលត្រូវអស់អាជ្ញាយុកាល ហើយបើកូនបំណុលនៅក្នុងឃុំជាមួយនឹងម្ចាស់បំណុល ហើយម្ចាស់បំណុលមិនបានទាមទារ ក្នុងរវាង៣ឆ្នាំចាប់ដើមអំពីថ្ងៃដែលដល់សន្មត់ថាត្រូវទារនោះមក បំណុលនោះមកក៏ត្រូវអស់អាជ្ញាយុកាលដែរ ។

**មាត្រា ៩៣០** ៖ បើកូនបំណុលបាត់ខ្លួនពីទីលំនៅហើយ ម្ចាស់បំណុលបានប្ដឹងឱ្យមេឃុំ ឬ ជំទប់ពិនិត្យពីបាត់ខ្លួននេះមានកំណត់ហេតុត្រឹមត្រូវអាជ្ញាយុកាលនោះត្រូវផ្អាកសិនមិនឱ្យអស់ទេ ។

**មាត្រា ៩៣១** ៖ បណ្ដឹងរបស់ម្ចាស់បំណុល ដែលបានប្ដឹងដល់តុលាការក៏ត្រូវផ្អាកអាជ្ញាយុកាលដែរ ។

**មាត្រា ៩៣២** ៖ រយៈវេលា ត្រូវគិត ១២ខែក្នុង១ឆ្នាំ តាមចន្ទគតិ ពីតិថីមួយ ទៅតិថីមួយ ។ ថ្ងៃទី១ ត្រូវរាប់ចាប់ពីថ្ងៃដែលដល់សន្មតត្រូវទារ ។ រយៈវេលា

ដែលត្រូវគ្រប់កំណត់នោះ គឺវេលាដែលផុតថ្ងៃចុងបង្អស់នៃខែគំរប់១២ នៃឆ្នាំទី៣ ឬ ឆ្នាំទី ៤ តាមរៀង ។

**មាត្រា ៩៣៣** ៖ កូនបំណុល ឬអ្នកធានា អាចនឹងយកអាជ្ញាយុកាលនោះ មកតវ៉ា គ្រប់សភាពនៃក្តីបាន ទោះបីក្នុងជាន់សាលាឧទ្ធរណ៍ហើយ សាលានេះបាន ពិភាក្សាដល់អង្គសេចក្តីទៅហើយក៏ដោយ ។

**មាត្រា ៩៣៤** ៖ តុលាការមិនអាចលើកអាជ្ញាយុកាលពីចិត្តឯងមកជា មធ្យោបាយជួសសាមីខ្លួនបានទេ ។

**មាត្រា ៩៣៥** ៖ កូនបំណុលនោះ នឹងទារយកប្រាក់ ឬ តម្លៃនោះមកវិញពុំ បានឡើយ ។

## មាតិកាទី២
## អំពីបន្ទាល់នៃភាតព្វកិច្ច

**មាត្រា ៩៣៦** ៖ ដែលហៅថា បន្ទាល់នោះ គឺវិធីទាំងពួងដែលបង្កើតឡើង សម្រាប់ នឹងបញ្ជាក់អំពីអត្ថិភាពនៃកិច្ចការផ្សេងៗ ដែលជាទីនាំមកនូវសិទ្ធិ ។

**មាត្រា ៩៣៧** ៖ ជនណាសំអាងថាសិទ្ធិ នៃកិច្ចការណាមួយដែលគេតវ៉ា ឬ ដែលគេមិនទាន់មាននោះជាសិទ្ធិរបស់ខ្លួន ជននោះត្រូវរកបន្ទាល់ ។

**មាត្រា ៩៣៨** ៖ ប័ណ្ណ ឬសាក្សី អាចទុកជាបន្ទាល់បាន ការឆ្លើយទទួល ដោយសារភាពសេចក្តីពិនិត្យ កោសលវិច័យ ឬសំបថទាំងអស់នេះ មិនអាចទុកជា បន្ទាល់បានដែរ ។

## ចំពូកទី១
## អំពីបន្ទាល់ ដោយប័ណ្ណ

**មាត្រា ៩៣៩** ៖ ដែលហៅថា ប័ណ្ណនោះ គឺសំបុត្រជាលាយលក្ខអក្សរ ដែលតែងឡើងដើម្បីជាកសិណនៃកិច្ចការទាំងឡាយ ដែលមានកំណត់ប្រាកដប្រជា ។

**មាត្រា ៩៤០** ៖ លិខិតដែលមានសេចក្ដីបញ្ជាក់ និងលិខិតឯកជនអាចទុកជាប័ណ្ណបាន ។

**មាត្រា ៩៤១** ៖ បើកូនបំណុលប្រកាន់ថាខ្លួនបានសងបំណុលគេហើយ តែប័ណ្ណនៅលើដៃម្ចាស់បំណុលនៅឡើយ ចម្លើយនេះនឹងយកជាការបានលុះត្រាតែកូនបំណុលមានបន្ទាល់ឲ្យឃើញជាមុន ថាបានប័ណ្ណនៅលើដៃម្ចាស់បំណុលពីព្រោះមានការភ័ន្តច្រឡំមានការកំហែង រំលោភ ឬមានឧបាយកលទុច្ចរិត ។

**មាត្រា ៩៤២** ៖ ទាយាទក្ដី សិទ្ធិវន្តនៃកូនបំណុលក្ដីប្ដឹងទាស់ថាលិខិតឯកជន ដែលម្ចាស់បំណុលយកមកជាបន្ទាល់នោះមិនត្រឹមត្រូវទេជនទាំងនោះនឹងជាប់ចោទតាមបទបញ្ញត្តិនៃមាត្រា៥១៤ក្រមព្រហ្មទណ្ឌបានលុះត្រាតែតុលាការ ពិនិត្យទៅឃើញថាជននោះឆ្លើយដោយចេតនាចង់ព្យាបាទ ។

**មាត្រា ៩៤៣** ៖ បន្ទាល់ដោយលិខិតទាំងពួង ទោះមានប្រភេទយ៉ាងណាៗក្ដី នឹងជឿយកជាការបាន លុះត្រាតែលិខិតនោះឥតមានសៅហ្មងដោយកោសកែឆ្វតលុបជ្រៀតថែមថយជាហេតុនាំឲ្យមានសេចក្ដីរង្កៀសសង្ស័យ ហើយលុះត្រាតែលិខិតនោះបានធ្វើតាមរូបមន្តនៃបញ្ញត្តិច្បាប់ទៀតផង ។

## ផ្នែកទី១
## អំពីលិខិតបញ្ជាក់

**មាត្រា ៩៤៤** ៖ ដែលហៅថា លិខិតបញ្ជាក់នោះ គឺសំបុត្រដែលគូភាគីបានចុះហត្ថលេខា ក្រោយដែលគេបានអានសេចក្ដីសំបុត្រទាំងអស់យ៉ាងខ្លាំងៗដោយក្បោះក្បាយ ឲ្យគូភាគីស្ដាប់ចំពោះមុខមន្ត្រីរាជការសាធារណៈមន្ត្រីនេះក្រោយដែលបានពិនិត្យអំពីអត្តសញ្ញាណនៃគូភាគី អំពីការចូលខ្លួនៃគូភាគីអំពីការអានលិខិតឲ្យគូភាគីស្ដាប់អំពីហត្ថលេខា ដែលភាគីបានចុះនោះឃើញថាត្រឹមត្រូវហើយ ទើបចុះហត្ថលេខាខ្លួនឯងក្បែរហត្ថលេខានៃគូភាគីព្រមទាំងបោះត្រាផង ។

**មាត្រា ៩៤៥** ៖ មន្ត្រីរាជការសាធារណៈ ដែលមានសមត្ថភាពដើម្បីបញ្ជាក់នូវលិខិតទាំងឡាយក្នុងឃុំនីមួយៗនោះគឺមេឃុំ បើមេឃុំមិននៅ ឬ មានធុរៈត្រូវជំទប់ណាមួយក្នុងឃុំជំនួស កុំឲ្យតែការនេះប៉ះពាល់សិទ្ធិ និងដល់ឯកាធិភាព (ភាពផ្ដាច់មុខ) ដែលបានសំដែងហើយក្នុងមាត្រានេះដើម្បីជាផលប្រយោជន៍ដល់មន្ត្រីរាជការសាធារណដទៃទៀត។

ក៏ប៉ុន្តែក្នុងអាណាខែត្រទាំងឡាយ ដែលស្ថិតនៅក្រោមតំបន់អភិរក្សសុរិយោដីដែលកើតឡើងតាមអារ៉ែតេ គូវែរណើរ យ៉េណេរាល់ ចុះថ្ងៃទី ១៩ កក្កដា ឆ្នាំ ១៩៣៤ និងនៅក្នុងអាណាខែត្រ ដែលរាជការបានបង្កើតឲ្យមានបញ្ជី សម្រាប់ទទួលបណ្ដឹង អចលវត្ថុ ដោយអនុវត្តតាមព្រះរាជប្រកាស លេខ ១៩៩ ចុះថ្ងៃទី៣ វិច្ឆិកា ១៩៣៨ និងអារ៉ែតេ រេស៊ីដង់ សុប៉េរីយ័រ លេខ ៣២៩៨ និង ៣២៩៩ ចុះថ្ងៃទី ២១ តុលា ១៩៣៩នោះ លិខិតទាំងឡាយដែលសម្រេចអំពីអចលវត្ថុហើយធ្វើនៅ

ការិយាល័យភូមិបាល នៃសាលាស្រុកត្រូវឲ្យចៅហ្វាយបញ្ជាក់ ឬ បើគ្មានចៅហ្វាយស្រុកដោយហេតុមន្ត្រីនេះមិននៅ ឬ មានធុរៈត្រូវឲ្យអ្នករាជការណាម្នាក់ក្នុងសាលាស្រុក ដែលចៅហ្វាយស្រុកនោះបានប្រទុកប្រដាក់ជាពិសេសឲ្យធ្វើការនេះកុំឲ្យតែការនេះប៉ះពាល់ដល់សិទ្ធិ និងដល់ឯកាធិភាព (ការផ្តាច់មុខ) នៃសារការីដែលមានសមត្ថភាព ។

(ក្រម ៩១០ នស.៤.១១.៥៤) ក៏ប៉ុន្តែលិខិតទាំងឡាយគ្រប់ប្រភេទ ដែលមានដាក់តម្លៃត្រឹម ឬលើសពី ២០០ ០០០ រៀលឡើងទៅត្រូវតែឲ្យសារការីបញ្ជាក់តាមទម្រង់នៃអាជីវកម្មរបស់គេ ។

ពី៥០ ០០០៛ ដល់ ២០ ០០០៛ ត្រូវចៅហ្វាយស្រុក នៃអាណាខែត្រដែលជាទីតាំង នៃអចលវត្ថុនោះ ឬ ចៅហ្វាយស្រុកនៃអាណាខែត្រខាងលំនៅនៃភាគីខាងណាម្នាក់ បញ្ជាក់ ។

ក្រោមពី ៥០ ០០០៛ ចុះមក ភាគីចង់យកទៅឲ្យមេឃុំ ឬ ចៅហ្វាយស្រុកបញ្ជាក់ក៏បាន ឬ ឲ្យសារការីបញ្ជាក់ក៏បានតាមចិត្ត ។

**មាត្រា ៩៤៦** ៖ នាទីសមត្ថកិច្ចរបស់មេឃុំ ចៅហ្វាយស្រុក មានកំរិតត្រឹមតែព្រំ ឃុំ ព្រំស្រុក ដែលខ្លួនត្រួតត្រា ។

**មាត្រា ៩៤៧** ៖ មេឃុំ នឹងចុះសេចក្តីបញ្ជាក់ក្នុងលិខិត ដែលមានប្តេជ្ញាអំពីកាតព្វកិច្ចលើបុគ្គល ឬ ចលវត្ថុបាន លុះត្រាតែគូភាគីម្នាក់យ៉ាងតិចមានទីលំនៅក្នុងឃុំខ្លួន ។ មេឃុំ អាចបញ្ជាក់សំបុត្រប្តេជ្ញា អំពីអចលវត្ថុបាន លុះត្រាតែអចលវត្ថុនោះឋិតនៅក្នុងនាទីឃុំខ្លួន ។

**មាត្រា ៩៤៨** ៖ បើលិខិត ដែលគេយកមកឲ្យបញ្ជាក់នោះ ជាលិខិតប្ដេជ្ញាអំពីអចលវត្ថុទាំងឡាយ ដែលនៅក្នុងឃុំទីទៃពីគ្នា លិខិតនោះត្រូវជូនទៅមេឃុំ នៃឃុំនីមួយៗបញ្ជាក់ វៀរតែក្នុងករណី ដែលមានសំដែងក្នុងវគ្គទី ២ នៃមាត្រា ៩៤៥ នេះ ទើបត្រូវយកទៅជូនចៅហ្វាយស្រុក ជាចៅនាទី ដែលមានឃុំទាំងឡាយនោះជាចំណុះបញ្ជាក់បាន ។

**មាត្រា ៩៤៩** ៖ លិខិតបញ្ជាក់នីមួយៗ ត្រូវយកទៅប្រថាប់ត្រាភ្លាម គឺប្រថាប់ត្រាក្នុងបញ្ជីដែលហៅថា Carnel denregi strement des certifications ។

ម្យ៉ាងទៀតអំពីលិខិត ទាំងឡាយដែលចៅហ្វាយស្រុកបានបញ្ជាក់ហើយ ចៅហ្វាយស្រុកត្រូវបញ្ជូនទៅឲ្យ មេឃុំ ជាចៅនាទី ដែលជាទីឋិតនៅនៃអចលវត្ថុនោះនូវដំណឹងអំពីការបញ្ជាក់នេះ ដើម្បីឲ្យមេឃុំនោះចុះសេចក្ដីបញ្ជាក់នោះ ក្នុងបញ្ជី Carnel denregi strement des certifications ដូចដែលបានពោលមកហើយក្នុងវគ្គទី១ខាងលើនេះ ។

**មាត្រា ៩៥០** ៖ និទ្ទេសនៃការប្រថាប់ត្រា ត្រូវឲ្យចុះលេខរៀងផងរួចហើយស្រង់លេខរៀងនោះដាក់លើលិខិតដើមគ្រប់តែលិខិតបញ្ជាក់ដែលត្រូវប្រគល់ទៅឲ្យភាគីម្នាក់ៗ។

**មាត្រា ៩៥១** ៖ និទ្ទេសនៃប្រថាប់ត្រានេះ ត្រូវមានចុះថ្ងៃ ខែ ឆ្នាំនៃលិខិត ចុះឈ្មោះព្រមទាំងលំនៅនៃភាគី ចុះប្រភេទលិខិត ចុះកម្មវត្ថុចុះបែបផែន (modolites)នៃលិខិត និងចុះថ្ងៃកំណត់ ដែលត្រូវសងបំណុលផង ។

**មាត្រា៩៥២** ៖ តមកទៀត ប្រសិនបើលិខិតនោះប្តេជ្ញាអំពីអចលវត្ថុ សេចក្តីនៃលិខិតនោះ ត្រូវចម្លងទាំងស្រុង ដាក់ក្នុងបញ្ជីការមួយ ហៅថាបញ្ជីការនៃលិខិតបញ្ជាក់ដែលមានគ្រប់ឃុំ លើកមួយតែឃុំនោះ នៅក្រោមរបបអភិរក្សសុរិយោដីទាំងមូល ឬ ភាគខ្លះ ឬ នៅក្រោមរបបបណ្តឹងអចលវត្ថុ ។

ក្នុងករណី នៃឃុំទាំងពីរបែប គឺឃុំដែលនៅក្រោមអភិរក្សសុរិយោដី និងឃុំដែលនៅក្រោមរបបបណ្តឹងអចលវត្ថុខាងលើនេះ សេចក្តីនៃលិខិតនោះត្រូវយកទៅចុះក្នុងតារាងសុរិយោដី (matrice cadasfrale) ឬ ក្នុងបញ្ជីបណ្តឹងអចលវត្ថុ ហើយលិខិតដដែលនេះមួយច្បាប់ទៀត ត្រូវយកទៅតំកល់នៅបណ្ណសារដ្ឋាននៃមន្ទីរអភិរក្សសុរិយោដី ឬ ការិយាល័យភូមិបាល ។ របៀបចុះតារាង និងរក្សាទុកបែបនេះទុកជាជំនួសការចម្លងលិខិតបញ្ជាក់ដាក់បញ្ជីហើយ ។

**មាត្រា ៩៥៣** ៖ បញ្ជីចុះលិខិតបញ្ជាក់ ដែលបង្កើតឡើងដើម្បីរ៉ាប់រងខាងផ្សាយអចលវត្ថុក្នុងឃុំ ដែលមានដីមិនទាន់ចុះបញ្ជីកា អ៊ីម៉្មាទ្រីគុឡាស្យុង ឬ ចុះមិនទាន់អស់ ឬ មិនទានប្តឹងអស់ ត្រូវដាក់ដៃនាយការិយាល័យភូមិបាលឲ្យកាន់កាប់ ប្រសិនបើមានការិយាល័យភូមិបាលនៅសាលាស្រុក ដែលមានមេឃុំនោះជាចំណុះបើគ្មានទេត្រូវមេឃុំជាអ្នកកាន់កាប់ ។

**មាត្រា ៩៥៤** ៖ បញ្ជីការ ចុះប្រថាប់ត្រា លិខិតបញ្ជាក់ និងបញ្ជីកា នៃលិខិតបញ្ជាក់ប្រសិនបើមានត្រូវសរសេរឲ្យគ្រប់ទំព័រទាំងអស់ កុំរំលងទំព័រទុកក្រដាសឲ្យសល់ស កុំឆ្វតលប់ កុំកោសកែ កុំសរសេរគៀបពីលើឲ្យសោះ ។ ការកែ

កំហុសទាំងប៉ុន្មានត្រូវកែដោយទុកឲ្យគេមើលបាន ហើយមានសេចក្តីយល់ព្រមពីអ្នកបញ្ជាក់ព្រមទាំងស្មៀនទៀតផងប្រសិនបើមានស្មៀន ។

**មាត្រា ៩៥៥** ៖ លិខិតបញ្ជាក់ត្រូវធ្វើឲ្យតាមចំនួនភាគី ដែលមានប្រយោជន៍ដាច់ពីគ្នា គឺថាមានភាគីប៉ុន្មាននាក់ត្រូវធ្វើប៉ុណ្ណោះច្បាប់លិខិតទាំងនោះជាលិខិតដើមទាំងអស់ ។

**មាត្រា ៩៥៦** ៖ មេឃុំ ឬ ចៅហ្វាយស្រុកដែលជាអ្នកបញ្ជាក់ត្រូវទារយកលិខិតដែលខ្លួនបញ្ជាក់នោះមួយច្បាប់ៗជាដរាបដើម្បីរក្សាទុកនៅបណ្ណសារដ្ឋាន ឬបញ្ជូនទៅដំកល់ទុកបន្ថែមលើការចុះបញ្ជី ឬ បញ្ជូនទៅផ្ទៀងផ្ទាត់ហើយចម្លងដាក់សៀវភៅ ឬ ចុះបញ្ជីតាមដំណើរលិខិតដូចបានរៀបរាប់ខាងលើ និងតាមរបបឃុំដូចមានសំដែងក្នុងវគ្គទី ២នៃមាត្រា ៩៥២ ស្រាប់ ។

**មាត្រា ៩៥៧** ៖ បញ្ជីប្រថាប់ត្រា លិខិតបញ្ជាក់ និងបញ្ជីកានៃលិខិតបញ្ជាក់ត្រូវដាក់ជូនចៅហ្វាយខេត្រ ឬ អ្នករាជការណាដែលជំនួសចៅហ្វាយខេត្រក្នុងមុខការនេះឲ្យពិនិត្យ និងចុះទិដ្ឋាការតាមប្រវត្តិកាល(periode) ។

**មាត្រា៩៥៨** ៖ រូបមន្តស្តីពីចុះទិដ្ឋាការ តាមប្រវត្តិកាលនេះត្រូវចៅហ្វាយខេត្រ ឬប្រតិភូរបស់ចៅហ្វាយខេត្រ ដូចមានសម្តែងក្នុងមាត្រាខាងលើនេះធ្វើក្នុងប្រាំមួយខែម្តង ។

**មាត្រា ៩៥៩** ៖ លិខិតបញ្ជាក់ទាំងពួង ដែលមេឃុំ ឬ ចៅហ្វាយស្រុកជាអ្នកបញ្ជាក់មិនបានចុះក្នុងបញ្ជីកាទេត្រូវមេឃុំ ឬ ចៅហ្វាយស្រុកនោះទទួលខុសត្រូវលើខ្លួន ចំពោះភាគី ឬ តតិយជនដែលមានប្រយោជន៍ក្នុងរឿងនេះ ។ ការប្តឹង

តវ៉ាគ្រប់យ៉ាងពីការភ្លេច ឬ ពីការមិនគោរពតាមទម្រង់ការរបស់ច្បាប់ក៏មេឃុំ ឬចៅហ្វាយស្រុកត្រូវទទួលខុសត្រូវលើខ្លួនដែរ ។

**មាត្រា ៩៦០** ៖ បើហត្ថលេខីមិនចេះអក្សរ អ្នកបញ្ជាក់ត្រូវឲ្យអ្នកនោះ ផ្តិតម្រាមដៃក្នុងលិខិតដើមមួយៗនោះនៅចំពោះមុខខ្លួន ។

**មាត្រា ៩៦១** ៖ (ក្រម៩១០ ន.ស.៤.១១.៥៤) ក្រៅអំពីលិខិតដែលបានសម្តែងហើយក្នុងមាត្រា ៩៤៤ និងតទៅនោះ លិខិតទាំងឡាយដូចខាងក្រោមនេះត្រូវទុកជាលិខិតបញ្ជាក់ដែរៈ

១- លិខិតទាំងពួង ដែលកុងស៊ុល ឬ ទូតខ្មែរធ្វើឯបរទេសតាមរូបមន្តយថាភូតនៃសារការីខ្មែរ ក្នុងព្រំដែននៃអំណាចដែលរាជការខ្មែរសម្រេចឲ្យធ្វើបានក្នុងរឿងនេះ ។

២- លិខិតទាំងពួងដែលមន្ត្រីសាធារណៈបានធ្វើតាមរូបមន្តយថាភូត ។ មន្ត្រី សាធារណៈនោះគឺ សារការី ក្រឡាបញ្ជី ដែលរាជការបារាំងបានតែងតាំងឲ្យធ្វើជាសារការីផង ឬ ដែលរាជការបារាំងបានអនុញ្ញាតឲ្យធ្វើជាបណ្តោះអាសន្នក្រោយពីការផ្ទេរសមត្ថកិច្ចមកជូនរដ្ឋាភិបាលខ្មែរពេញផ្ទៃនៃព្រះរាជាណាចក្រទំរាំមានសេចក្តីសម្រេច អំពីរឿងនេះជាថ្មីម្តងទៀត ។

៣- លិខិតយថាភូតទាំងពួង ដែលអាជ្ញាធរបរទេស ជាអ្នកមានសមត្ថកិច្ចបានធ្វើនៅឯបរទេសតាមរូបមន្តដែលច្បាប់ខ្មែរបានបញ្ញត្តិទុកមក ។

៤- លិខិតយថាភូតទាំងពួងធ្វើនៅប្រទេសខ្មែរ ដោយកុងស៊ុល ឬ ទូតបរទេសដែលបានទទួលការតែងតាំងជាត្រឹមត្រូវ ឲ្យនៅអមព្រះរាជរដ្ឋាភិបាលខ្មែរ

កាលណាបើកុងស៊ុល ឬ ទូតនោះប្រព្រឹត្តក្នុងមុខការ ជាសារការីក្នុងព្រំដែនដែលច្បាប់អន្តរជាតិសាធារណៈទទួលស្គាល់ ឬ ដែលអនុសញ្ញាទូត ឬ កុងស៊ុលបានបញ្ជាក់ទុកមក គឺអនុសញ្ញាដែលភ្ជាប់រដ្ឋាភិបាលនៃទូត ឬ កុងស៊ុលនោះនៅនឹងព្រះរាជរដ្ឋាភិបាលខ្មែរ ។

លិខិតដូចបានពោលមក ក្នុងវគ្គទី៣ និងទី៤ នៃមាត្រានេះត្រូវយកទៅសុំឧកាសទាន(exequatur) ពីតុលាការយុត្តិធម៏ខ្មែរ ដើម្បីឲ្យមានរូបមន្តបរិវត្តខ្មែរ ។

**មាត្រា៩៦២** ៖ និរាករហើយ (ដោយតុណ្ហីភាតាំងពីថ្ងៃដែលប្រទេសកម្ពុជាបានឯករាជ្យមក ។

**មាត្រា ៩៦៣** ៖ បើកូនបំណុលណា តវ៉ាថាលិខិតបញ្ជាក់ណាមួយមានសេចក្ដីមិនបរិសុទ្ធ កូនបំណុលនោះត្រូវយកពាក្យដែលប្ដឹងថាក្លែងនោះ ទៅជូនទីក្រឡាបញ្ជីក្នុងរវាងដប់ប្រាំថ្ងៃ ដើម្បីឲ្យគេបញ្ជូនទៅសុភាចារបុរសឲ្យស៊ើបសួរជាប្រញាប់ ។

**មាត្រា ៩៦៤** ៖ បើសុភាចារបុរស ស៊ើបសួរទៅឃើញថា លិខិតបញ្ជាក់នោះពិតជាក្លែងមែន ចារី សហចារី និងអ្នកសមគំនិតក្នុងបទនេះ នឹងត្រូវចោទប្រកាន់ពីបទក្លែងលិខិតយថាភូតតាមបទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៩៦៥** ៖ បើសុភាចារបុរស ស៊ើបសួរទៅឃើញថា ការដែលក្លែងលិខិតនោះមិនជាទីញ៉ាំងអ្នកបញ្ជាក់នោះ ឲ្យដល់នូវកំហុស ជាបទអាជ្ញាទេ ដីការដែលនឹងចេញសម្រេចសេចក្ដីនោះ ត្រូវចុះហេតុឲ្យសព្វគ្រប់ទុកផ្លូវឲ្យដើមចោទ

ប្តឹងជារដ្ឋប្បវេណីពីអ្នកបញ្ជាក់ផងក្រែងមានកំហុសលើអ្នកបញ្ជាក់ក្នុងបទនោះ ហើយ និងប្តឹងជាបទរដ្ឋប្បវេណី ឬ បទអាជ្ញាបីចារីនៃបទក្លែងនោះបានផង ។

**មាត្រា ៩៦៦** ៖ បើសុភាចារបុរស ស៊ើបទៅឃើញថាសេចក្តីសំបុត្រនោះត្រឹមត្រូវទេ ប៉ុន្តែភ្លេច ឬ វិភេទពីរូបមន្តច្បាប់ដែលបានបញ្ញត្តិ អំពីរបៀបធ្វើលិខិតបញ្ជាក់ដីកា ដែលសំរេចលើកលែងចោទប្រកាន់នោះ ត្រូវសំដែងហេតុនោះឲ្យសព្វគ្រប់ទុកផ្លូវឲ្យអ្នករងគ្រោះក្នុងរឿងនេះប្តឹងជាបទរដ្ឋប្បវេណីផង ។

ដើមចោទនឹងត្រូវមានទោស តាមមាត្រា ៥១៤ ក្រមព្រហ្មទណ្ឌ ។

បើកំហុសដែលភ្លេចធ្វើតាមរបៀបច្បាប់ ឬ ដែលធ្វើឲ្យវិភេទនោះធ្លាក់លើអ្នកបញ្ជាក់អ្នកប្តឹងនោះអាចនឹងពីអ្នកបញ្ជាក់ឲ្យទទួលខុសត្រូវពីព្យសនកម្មដែលបណ្តាលមកពីហេតុនោះបាន ។

**មាត្រា ៩៦៧** ៖ បើសុភាចារបុរស ស៊ើបទៅឃើញថាលិខិតនោះរៀបរយតាមច្បាប់ហើយ សេចក្តីក្នុងលិខិតនោះទៀតក៏សុចរិតដែរដើមចោទត្រូវមានទោសតាមមាត្រា ៥១៤ ក្រមព្រហ្មទណ្ឌ ។

**មាត្រា ៩៦៨** ៖ បើនីតិវិធីខាងបទអាជ្ញាគតិ កំពុងពិភាក្សាមិនទាន់ដាច់ស្រាច់ដរាបណា នីតិវិធីខាងរដ្ឋប្បវេណីគតិត្រូវតែបង្អង់ចាំដរាបនោះដែរ ។

## ផ្នែកទី២
## អំពីលិខិតឯកជន

**មាត្រា ៨៦៩** ៖ ដែលហៅថាលិខិតឯកជន នោះគឺ លិខិតដែលធ្វើតែគ្នាឯងឥតមានមន្ត្រីរាជការសាធារណៈណាមួយជួយដឹងឮ ឃើញផងទេមានតែហត្ថលេខានៃគូភាគីប៉ុណ្ណោះ ។

**មាត្រា ៨៧០** ៖ លិខិតឯកជនត្រូវមានចុះហត្ថលេខារបស់ភាគីជាចំណាំ ។

មុននឹងចុះហត្ថលេខា គូភាគីត្រូវសរសេរ ដោយដៃឯងនូវនិទ្ទេសមួយថាបានឃើញហើយយល់ព្រមផង ជាភាសាតែមួយជាមួយគ្នានឹងសេចក្តីក្នុងលិខិតនោះ ។

បើហត្ថលេខីជាអ្នកទទួល បំពេញកាតព្វកិច្ចមិនចេះសរសេរជាភាសានោះទេ ឬ មិនចេះចុះហត្ថលេខាទេ នោះត្រូវធ្វើតាមរបៀបដូចដែលមានប្រាប់ក្នុងមាត្រា ៨៧៤ នេះស្រាប់ ។

**មាត្រា ៨៧១** ៖ (ក្រមលេខ ១៦៦.ន.ស.ចុះថ្ងៃទី ២៨.២.៥៧) លិខិតនោះគឺហត្ថលេខីណាម្នាក់តែងក៏បាន ឬ តតិយជនតែងក៏បាន ។

**មាត្រា ៨៧២** ៖ បើលិខិតនោះគឺតតិយជនតែង លិខិតនោះត្រូវមានឈ្មោះនិងហត្ថលេខា នៃអ្នកតែងផង ។

**មាត្រា ៨៧៣** ៖ បើលិខិតនោះប្តេជ្ញាពីកាតព្វកិច្ច ដែលត្រូវបំពេញទៅវិញទៅមក លិខិតត្រូវធ្វើឲ្យគ្រប់ចំនួនភាគីដែលមានប្រយោជន៍ដាច់ពីគ្នាក្នុងរឿងនេះ ។

ក្នុងលិខិតមួយច្បាប់ៗ ត្រូវដាក់សេចក្តី ឲ្យដឹងអំពីចំនួនលិខិតដែលចេញទាំងអស់ប៉ុន្មានច្បាប់ផង ។

**មាត្រា ៩៧៤** ៖ (ក្រមលេខ ១៦៦ ន.ស ចុះថ្ងៃទី ២៨.២.៥៨) បើគូភាគីជាអ្នកទទួលបំពេញកាតព្វកិច្ចឆ្លើយថាខ្លួនមិនចេះអក្សរទេ ឬ មិនអាចសរសេរបានទេគូភាគីនោះត្រូវផ្តិតមេដៃក្នុងលិខិតនោះតមកលិខិតនោះត្រូវចុះនិទ្ទេសថាឈ្មោះនោះចុះហត្ថលេខាមិនកើត ឬមិនចេះអក្សរទេ ។

មួយទៀតការផ្តិតមេដៃនេះ ត្រូវធ្វើនៅមុខសាក្សីទាំងពីរនាក់យ៉ាងតិចរើសយកសុទ្ធតែនីតិជនជាអ្នកដទៃនឹងគូភាគីជាអ្នកចេះមើលនិងចេះសរសេរ ហើយមានសមត្ថភាពអាចធ្វើសាក្សីបានតាមលក្ខណៈដែលមានសំដែងក្នុងមាត្រា ៩៩១ នឹង ៩៩២ផង ទើបលិខិតនោះយកជាការបាន ។

**មាត្រា ៩៧៥** ៖ ឈ្មោះ និងហត្ថលេខានៃសាក្សី ក៏ត្រូវចុះក្នុងលិខិតដែរ ។

**មាត្រា ៩៧៦** ៖ (ក្រមលេខ ១៦៦ ន.ស.ចុះថ្ងៃ ២៨.២.៥៨) សាក្សីរបស់ភាគីជាអនក្ខរជន មុននឹងចុះហត្ថលេខា ត្រូវសរសេរដោយដៃឯងនូវនិទ្ទេសមួយថាបានអានលិខិតនេះឲ្យ...(ឈ្មោះភាគីអនក្ខរជន) ស្តាប់រួចហើយឈ្មោះនេះបានយល់ព្រមតាមសេចក្តីក្នុងលិខិតនេះទាំងអស់ហើយ ។

ការខ្វះចន្លោះត្រង់រូបមន្តនេះ នឹងបណ្តាលឲ្យមានមោឃភាពដល់លិខិតនោះបាន។

**មាត្រា ៩៧៧** ៖ ប័ណ្ណត្រឹមត្រូវតាមច្បាប់គឺលិខិតបញ្ជាក់ ឬ លិខិតឯកជនថិតនៅក្នុងដៃម្ចាស់បំណុលដរាបណាដរាបនោះប័ណ្ណនោះត្រូវទុកជាបន្ទាល់ថាកូនបំណុលនៅជំពាក់កាតព្វកិច្ចនៃម្ចាស់បំណុលនៅឡើយ ។

**មាត្រា ៩៧៨** ៖ បើកូនបំណុលប្រកែកថាលិខិតនេះជាលិខិតក្លែងទេ គឺក្លែងចុះឈ្មោះខ្លួន ជាអ្នកសរសេរក្តីជាហត្ថលេខាក្តីតុលាការត្រូវបង្គាប់ឲ្យត្រួតពិនិត្យអក្សរនោះមើល ។

**មាត្រា ៩៧៩** ៖ សំបុត្រស្នាមដែលត្រូវយកទៅផ្ទៀបផ្ទួរដើម្បីពិនិត្យអក្សរនោះ ត្រូវយកសំបុត្រជាផ្លូវការក្តី លិខិតបញ្ជាក់ក្តី លិខិតឯកជនដែលគូភាគីព្រមយកផងក្តី ។

**មាត្រា ៩៨០** ៖ សំបុត្រស្នាមដែលត្រូវយកទៅផ្ទៀបផ្ទួរនោះមុននឹងផ្ទៀបត្រូវបង្ហាញឲ្យគូភាគីមើលជាដរាបក្រែងមានទាស់ចំណាំដូចម្តេចៗ នឹងបានប្តឹងទាស់ ។ ឯសេចក្តីដែលគូភាគីប្តឹងដូចម្តេចៗនោះត្រូវកត់ទុកនៅទីក្រឡាបញ្ជី ។

**មាត្រា ៩៨១** ៖ ការពិនិត្យត្រួតនោះត្រូវធ្វើនៅសាលាក្តីចំពោះមុខចៅក្រមណាមួយដែលចាត់ឲ្យធ្វើការនោះ និងចំពោះមុខគូភាគី ដែលត្រូវកោះឲ្យមកតាមច្បាប់ ។

**មាត្រា ៩៨២** ៖ បើគូភាគីមិនព្រមព្រៀងគ្នា អំពីរើសអាជ្ញាកណ្តាលឲ្យពិនិត្យអក្សរទេតុលាការត្រូវចាត់ឯងមួយនាក់ ហើយគូភាគីម្ខាងៗអាចចាត់អាជ្ញាកណ្តាលមួយ ម្នាក់ៗទៀត តាមស្ម័គ្រចិត្តរបស់ខ្លួនក្រៅអំពីអាជ្ញាកណ្តាលដែលតុលាការចាត់ឯងនោះថែមទៀតក៏បាន ។

**មាត្រា ៩៨៣** ៖ បើអាជ្ញាកណ្ដាលត្រួតពិនិត្យទៅឃើញថាអក្សរ ដែលត្រូវចោទថាក្លែងនោះពិតជាក្លែងមែន ឈ្មោះដែលក្លែងនោះត្រូវមានទោសតាមមាត្រា ៥២៣ ក្រមព្រហ្មទណ្ឌ ។

**មាត្រា ៩៨៤** ៖ បើអាជ្ញាកណ្ដាលត្រួតពិនិត្យទៅ ឃើញថាលិខិតដែលត្រូវចោទថាក្លែងនោះ ជាសារលិខិតបរិសុទ្ធទេ អ្នកចោទត្រូវមានទោសតាមមាត្រា ៥១៤ ក្រមព្រហ្មទណ្ឌ ។

**មាត្រា ៩៨៥** ៖ បើកូនបំណុលប្រកាន់ថាលិខិតឯកជននោះមិនត្រឹមត្រូវទេ ព្រោះឥតមានឃើញឈ្មោះខ្លួនជាអ្នកសរសេរ ជាអ្នកចុះហត្ថលេខាសោះកូនបំណុលនោះត្រូវជូនបន្ទាល់នៃសំដីរបស់ខ្លួនជាប័ណ្ណ ឬ មធ្យោបាយទាំងឡាយដែលខ្លួនអាងដោយធ្វើជាពាក្យយកទៅប្ដឹងឯទីក្រឡាបញ្ជីក្នុងរវាង ១៥ថ្ងៃ បើទុកឲ្យហួសពី ១៥ថ្ងៃទៅកូនបំណុលនោះត្រូវផ្ដាស់សិទ្ធិគឺប្ដឹងលែងបានហើយ ។ បើកូនបំណុលបានជូនបន្ទាល់តិកតាង ឲ្យឃើញជាក់ច្បាស់ថា លិខិតឯកជននោះពិតជាក្លែងមែន ចារីដែលក្លែងត្រូវមានទោសតាមមាត្រា ៥១៥ ក្រមព្រហ្មទណ្ឌ ។

**មាត្រា ៩៨៦** ៖ បើលិខិតនោះពិនិត្យទៅ ឃើញថាជាលិខិតបរិសុទ្ធត្រឹមត្រូវវិញទេ កូនបំណុលត្រូវមានទោសតាមមាត្រា ៥១៤ ក្រមព្រហ្មទណ្ឌ ។

**មាត្រា ៩៨៧** ៖ ដរាបណានីតិវិធីខាង បណ្ដឹងអាជ្ញាមិនទាន់បានសម្រេចជាស្ថាពរទេ ដរាបនោះក្ដីរដ្ឋប្បវេណីគតិត្រូវបង្អង់ទុកមួយអន្លើសិន ។

## ផ្នែកទី៣
## អំពីសៀវភៅ ជំនួញ

**មាត្រា ៩៨៨** ៖ សៀវភៅ ជំនួញ ទុកជាបន្ទាល់រវាងអ្នកជំនួញផងគ្នាកាល បើសៀវភៅនោះកត់អំពីការផ្តល់ទំនិញ ។ ដូច្នេះសៀវភៅនេះ មានកម្លាំងក្នុងការធ្វើជា ភស្តុតាងស្មើគ្នានឹងលិខិតឯកជនដែរ ប៉ុន្តែសៀវភៅនោះត្រូវកាន់ឲ្យបាន ត្រឹមត្រូវតាមរបៀបច្បាប់ផងទើបបាន ។

## ចំពូកទី ២
## អំបន្ទាល់ ដោយសាក្សី

**មាត្រា ៩៨៩** ៖ (ក្រម ១៦៦.ន.ស.២៨.៥.៥៨) បន្ទាល់ដោយសាក្សីមិន ត្រូវយកមកប្រឆាំងនឹងសេចក្តីដែលមានចែងក្នុងលិខិតជាលាយល័ក្ខអក្សរទេ ។

កិច្ចសន្យាគ្រប់ប្រភេទដែលប្តេជ្ញាអំពីប្រាក់ ឬ វត្ថុដែលមានចំនួន ឬ តម្លៃ លើសពី ប្រាំពាន់រៀល(៥០០០៛) ឡើងទៅត្រូវធ្វើជាលិខិតលាយល័ក្ខអក្សរ ។

សិទ្ធិប្រត្យ័ក្ស អចលវត្ថុ ត្រូវមានបន្ទាល់ជាលិខិតលាយល័ក្ខអក្សរជា ដរាបទោះបីសិទ្ធិនោះមានតម្លៃប៉ុន្មានក៏ដោយ ។

ច្បាប់អនុញ្ញាតឲ្យយកសាក្សីធ្វើជាបន្ទាល់បាន តែក្នុងកិច្ចសន្យាឬសិទ្ធិ ដែលមាននិយាយផ្សេងអំពីសេចក្តីដែលមានចែងក្នុងលិខិតជាលាយល័ក្ខអក្សរ ។

បទបញ្ញត្តិខាងលើនេះ មិនត្រូវឲ្យមានប៉ះពាល់ដល់បទបញ្ញត្តិនៃមាត្រា ៣៨៩ ក្រមជំនួញឡើយ ។

**មាត្រា ៩៩០** ៖ (ក្រម ១៦៦ នស.២៨.២.៥៧) វិធានខាងលើនេះមាន អញ្ញត្រកម្មដូចតទៅនេះ។

ក) កាលបើម្ចាស់បំណុលដោះសារថា ការមិនអាចរកបន្ទាល់ជាលាយលក្ខណ៍អក្សរនៃកាតព្វកិច្ច ដែលមានប្ដេជ្ញាជាមួយនឹងខ្លួនបាននោះបណ្ដាលមកពីករណីប្រធានស័ក្ដិណាមួយ ។

ខ) បើម្ចាស់បំណុលអាចនឹងជូនលិខិតដើមនៃបន្ទាល់ជាលាយលក្ខណ៍អក្សរ ដែលបានពីកូនបំណុល ដែលនាំឱ្យយល់ថាកាតព្វកិច្ចដែលម្ចាស់បំណុលសុំឱ្យបំពេញនេះបំពេញនេះប្រហែលជាមិនមែន ។

**មាត្រា ៩៩១** ៖ ជនទាំងពួង ប្រុសក្ដី ស្រីក្ដី អាយុយ៉ាងតិច ១៨ឆ្នាំ មានសតិប្រាជ្ញាបរិបូណ៌ អាចនឹងធ្វើសាក្សីឱ្យគេបានរៀវលែងតែមនុស្សនោះជាមនុស្សផ្ដាស់សិទ្ធិដោយហេតុមានទោសតែប៉ុណ្ណោះ ។

**មាត្រា ៩៩២** ៖ ញាតិ ក្រសែផ្ទាល់ ឪពុកម្ដាយក្មេក ឪពុកម្ដាយឥតខាន់ស្លា ឬ ញាតិសាខាដល់ថ្នាក់ទី៨ បាវព្រាវ កូនឈ្នួល អ្នកជួលវត្ថុ កូនបំណុលទាំងអស់នេះមិនអាចនឹងយកជាសាក្សីបានឡើយ ។

**មាត្រា ៩៩៣** ៖ ភាគីម្ខាង អាចជិតចិត្ត សាក្សី ដែលគូភាគីម្ខាងយកមកផ្ដាញ់ខ្លួនបាន ប៉ុន្តែត្រូវចង្អុលហេតុដែលជិតចិត្តនោះឱ្យច្បាស់ ។ ចៅក្រមត្រូវពិនិត្យពាក្យដែលជិតចិត្តនោះហើយសម្រេចថាគួរយកក៏បានគួរចោលក៏បាន ។

**មាត្រា ៩៩៤** ៖ បញ្ជីសាក្សី ត្រូវឱ្យយកទៅជូន នៅទីក្រឡាបញ្ជីក្នុងកំណត់ ១៥ថ្ងៃ គិតតាំងពីថ្ងៃ ដែលបើកឱ្យជូនសាក្សី ។ បើឈ្មោះដែលអាងសាក្សីមិនបានជូនសាក្សី ក្នុងកំណត់នេះទេនោះត្រូវផ្ដាស់សិទ្ធិ គឺលើកលែងឱ្យជូនសាក្សីទៀតហើយ ។

**មាត្រា ៩៩៥** ៖ ចៅក្រមណាម្នាក់ដែលត្រូវចាត់ហើយមកនោះត្រូវសួរយកចម្លើយសាក្សី នៅក្នុងសវនាការនៃតុលាការ ។ ក្រឡាបញ្ជីជាអ្នកកត់ចៅក្រមជាអ្នកសួរហើយប្រាប់ឲ្យកត់ ។ សាក្សីដែលចេះអក្សរត្រូវចុះហត្ថលេខាក្រោយដែលបាន ឮ សូត្រ សេចក្ដីចម្លើយនោះឲ្យស្ដាប់ ។ គូភាគីត្រូវតែចូលមកតាមដីកាកោះ ឬ ក៏ចៅក្រមបានកោះហៅ ឲ្យមកតាមច្បាប់ហើយ ។

**មាត្រា ៩៩៦** ៖ សាក្សីតែម្នាក់នឹងយក ជាភ័ស្ដុតាងពុំបាន ។

**មាត្រា ៩៩៧** ៖ នាកាលតុលាការអនុញ្ញាតឲ្យភាគីណាម្នាក់ រកបន្ទាល់នៃកិច្ចការរបស់ខ្លួនដែលបានធ្វើមក ហើយភាគីម្ខាងទៀតក៏ត្រូវអនុញ្ញាតឲ្យរកបន្ទាល់ដូចគ្នាប្រឆាំងនឹងខ្លួនដែរ ។

## ចំពូកទី ៣
## អំពីបែបផ្សេងៗទៀត នៃបន្ទាល់របស់ភាគពូកិច្ច
### ផ្នែកទី ១
### អំពីចម្លើយ សារភាព

**មាត្រា ៩៩៨** ៖ ចម្លើយ ដែលភាគីណាម្នាក់ឆ្លើយទទួលសារភាពអាចទុកជាបន្ទាល់បានដែរ ។

**មាត្រា ៩៩៩** ៖ ដែលហៅថា ចម្លើយសារភាព នោះ គឺកិរិយាដែលភាគីណាម្នាក់ទទួលស្គាល់នូវសេចក្ដីដែលអ្នកម្ខាងប្ដឹងប្រកាន់ខ្លួននោះថាជាសេចក្ដីត្រឹមត្រូវមែន ។

**មាត្រា ១000** ៖ ចម្លើយសារភាពនេះ នឹងយកជាបន្ទាល់បានលុះត្រាតែចម្លើយនោះឆ្លើយទទួលប្រកដប្រជា ចំពោះមុខតុលាការ ។

**មាត្រា ១០០១** ៖ កាលណាបើតុលាការ សួរទៅហើយភាគីមិនព្រមឆ្លើយសោះការនៅស្ងៀមនេះត្រូវទុកស្មើទទួលសារភាពដែរ ។

**មាត្រា ១០០២** ៖ ជនណា បានទទួលសារភាពហើយ នឹងប្រកែកដោះសារដោយប្រការឯណាវិញមិនបានទេ, បើបាន, លុះណាតែជននោះពន្យល់ឲ្យឃើញជាខ្លួនឆ្លើយទទួលនោះព្រោះមានភ័ន្តច្រឡំអង្គហេតុដូច្នេះជាដើម ។

## ផ្នែកទី ២
## អំពីសបថ

**មាត្រា ១០០៣** ៖ កាលណាតុលាការ ឃើញថាសេចក្ដីនៃបណ្ដឹងនោះមានការពិតច្រើន តែមិនមានបន្ទាល់តិកតាងឲ្យធួនល្មមសោះ, តុលាការអាចនឹងឲ្យភាគីម្ខាងនេះ ឬម្ខាងនោះស្បថបញ្ជាក់បាន ។

**មាត្រា ១០០៤** ៖ ក្នុងករណីនេះ ភាគីម្ខាងនឹងតម្រូវឲ្យភាគីម្ខាងស្បថក៏បាន ។

**មាត្រា ១០០៥** ៖ ភាគី ណាដែលតុលាការតម្រូវឲ្យស្បថហើយ, ភាគីនោះមិនអាចនឹងប្រកែកពុំព្រមស្បថបានទេ ។

ភាគី ដែលអ្នកម្ខាងតម្រូវឲ្យស្បថហើយអាចមិនស្បថខ្លួនឯងក៏បានបើខ្លួនបញ្ជូនទៅឲ្យម្ខាងនោះស្បថវិញ ។

**មាត្រា ១០០៦** ៖ សំបថ នោះត្រូវធ្វើតាមលទ្ធិសាសនានៃអ្នកដែលត្រូវស្បថ, តែឯកន្លែងស្បថនោះត្រូវតុលាការ ឬ ត្រូវអ្នកដែលដែលតម្រូវឲ្យគេស្បថនោះរើស ។

**មាត្រា ១០០៧** ៖ សំបថ នោះត្រូវធ្វើនៅមុខភាគីម្ខាង ឬ កំបាំងមុខភាគីដែលគេ បានហៅតែមិនមក, ដោយមានចៅក្រម ឬ អ្នកជំនួសចៅក្រមម្នាក់ដែលចាត់មកជាអាជ្ញាកណ្តាលបានឃើញផង ។

អាជ្ញាកណ្តាលត្រូវធ្វើកំណត់ហេតុ ដែលបានស្បថនោះបញ្ជាក់ថាបានធ្វើត្រឹមត្រូវតាមលទ្ធិសាសនាហើយ ។ សេចក្តីដែលបានចេញវាចាឲ្យស្បថយ៉ាងណាត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង ។

## ផ្នែកទី ៣
## អំពីការពិនិត្យ ដល់ទីកន្លែង និងអំពីកោសលវិច្ច័យ

**មាត្រា ១០០៨** ៖ ការពិនិត្យ សម្ភារៈក៏អាចទុកជាបន្ទាល់បានដែរ ។

**មាត្រា ១០០៩** ៖ តុលាការចុះទៅកាន់ទីកន្លែង ឬ នឹងចាត់ចៅក្រមណាម្នាក់ជាអាជ្ញាកណ្តាលឲ្យទៅពិនិត្យការដែលគូភាគីអះអាង ឬ ការដែលគប្បីពិនិត្យឯទីកន្លែងនោះក៏បាន, គូភាគីត្រូវតែចូលមក ឬ ក៏គេបានហៅឲ្យចូលមកតាមច្បាប់ហើយ ។

**មាត្រា ១០១០** ៖ តុលាការអាចចាត់អ្នកជំនាញឲ្យទៅពិនិត្យក៏បាន ។

**មាត្រា ១០១១** ៖ ដែលហៅថា អ្នកជំនាញនោះគឺជនដែលមានសមត្ថភាពបច្ចេកទេសអាចពិនិត្យរកហេតុ, រកបច្ច័យយ៉ាងជាក់ច្បាស់ជូនតុលាការពិនិត្យ, ពិចារណាបាន ។

**មាត្រា ១០១២** ៖ តុលាការ អាចតាំងអ្នកជំនាញតាមសេចក្តីយល់ព្រមរបស់គូភាគីក៏បាន ឬ តាំងតាមចិត្តខ្លួនក៏បាន ។

**មាត្រា ១០១៣** ៖ តុលាការអាចតាំងអ្នកជំនាញតែមួយនាក់ក៏បាន, ឬច្រើននាក់ក៏ បាន។

បើតាំងច្រើននាក់ចំនួននៃអ្នកជំនាញត្រូវឲ្យសេសជានិច្ច ។

អ្នកជំនាញការត្រូវធ្វើសេចក្ដីវាយការណ៍តែមួយជូនទៅតុលាការ ។

**មាត្រា ១០១៤** ៖ សោយហ៊ុយបំណាច់ជូនអ្នកជំនាញការត្រូវឲ្យភាគីដែលសុំឲ្យ ពិនិត្យការ ហើយដែលជាអ្នកត្រូវជូនបន្ទាល់នោះបង់ជាមុននៅឯទីក្រឡាបញ្ជី, បើភាគីនេះឈ្នះសេចក្ដី, ភាគីខាងចាញ់ត្រូវសងសោហ៊ុយបំណាច់នោះវិញ ។

**មាត្រា ១០១៥** ៖ ប៉ុន្តែអំពីការបោះគោលចរឹកដីវិញ, តុលាការអាចតម្រូវឲ្យគូវិវាទទាំងពីរខាងបង់ប្រាក់បំណាច់នោះទាំងអស់គ្នាបាន ។

**មាត្រា ១០១៦** ៖ (ក្រ.២៩ នស. ១៧.៨.៥៥) ដោយយោលទៅតាមច្បាប់ធម្មតា នៃកោសលវិច្ឆ័យអ្នកជំនាញការមានភេទជាប្រុសក៏បាន, ស្រីក៏បាន, មានសញ្ជាតិជាអ្វីក៏បានឥតមានលក្ខខណ្ឌទេ ។

# មាតិកា ទី៣
# អំពីកិច្ចសន្យា ផ្សេងៗ ដែលតែងធ្វើជាហូរហែរ
## ចំពូក ទី១
## អំពីការលក់
### ផ្នែក ទី១
### បទបញ្ញត្តិ ទូទៅ

**មាត្រា ១០១៧** ៖ ដែលហៅថា ការលក់ គឺជាកិច្ចសន្យាមួយដែលជនម្នាក់ហៅថាអ្នកលក់ត្រូវផ្ទេរនូវសិទ្ធិនៃវត្ថុណាមួយ ឬ សិទ្ធិណាមួយជារបស់ខ្លួនឲ្យទៅជនម្នាក់ទៀតហៅថាអ្នកទិញ ដែលជាអ្នកត្រូវចេញថ្លៃជាប្រាក់តាមតម្លៃនៃវត្ថុនោះឲ្យអ្នកលក់ ។

**មាត្រា ១០១៨** ៖ កម្មសិទ្ធិករ ទាំងពួង អាចលក់វត្ថុ ឬ សិទ្ធិទាំងឡាយរបស់ខ្លួនបាន, វៀរតែក្នុងករណីដែលមានច្បាប់ឬបទបញ្ជាឯណាហាមឃាត់តែប៉ុណ្ណោះ ។

**មាត្រា ១០១៩** ៖ ការលក់វត្ថុអ្នកដទៃត្រូវទុកជាមោឃៈ ។

**មាត្រា ១០២០** ៖ គេអាចលក់វត្ថុដែលនឹងមាននាអនាគតបាន, វៀរលែងតែមតិកដែលមានម្ចាស់ នៅរស់នៅឡើយ ទោះបីជាម្ចាស់មតិកនោះយល់ព្រមផងក៏ដោយ ។

**មាត្រា ១០២១** ៖ ឯថ្លៃត្រូវទុកជាប្រមាណនៃតម្លៃវត្ថុ ឬ សិទ្ធិដែលលក់ជាប្រាក់ដែលច្បាប់បើកឲ្យចាយ ។

អ្នកលក់, អ្នកទិញត្រូវសម្រេចថ្លៃនោះខ្លួនឯង ។ ថ្លៃត្រូវកាត់តាមទម្ងន់, តាមចំនួន ឬ តាមរង្វាស់រង្វាល់នៃវត្ថុ ។

**មាត្រា ១០២២** ៖ នាកាលអ្នកលក់ និងអ្នកទិញ ព្រមព្រៀងគ្នាអំពីវត្ថុដែលលក់ និងថ្លៃហើយ, ការលក់នោះត្រូវទុកជាត្រឹមត្រូវដោយបរិបូរណ៍ ។

(ក្រម ២៩ នស. ១៧.៨.៥៥) ក៏ប៉ុន្តែការលក់ នូវសិទ្ធិប្រត្យ័ក្ស អចលនវត្ថុនឹងត្រូវទុកថាជាមានបន្ទាល់ រវាងភាគី ផងគ្នា ឬរវាងតតិយជនបាន, ក៏លុះណាតែការលក់នោះបានធ្វើជាលាយល័ក្សអក្សរតាមរូបមន្តយថាភូត គឺមានបញ្ជាក់ ឬ ធ្វើនៅសារការី ។

**មាត្រា ១០២៣** ៖ ជនទាំងពួង, ដែលប្រកបដោយសមត្ថភាពល្មមចុះកិច្ចសន្យាបាន, អាចនឹងលក់ ឬ នឹងទិញបាន ។ ប៉ុន្តែជនចំពូកដូចខាងក្រោមមិនអាចលក់បានទេគឺ ៖

ជនដែលមិនមែនជាកម្មសិទ្ធករនៃវត្ថុ ៖

សហកម្មសិទ្ធិករលក់វត្ថុអវិភាគីយ(ដែលចែកគ្នាមិនបាន) ដោយគ្មានសេចក្ដីព្រមព្រៀងពីសហកម្មសិទ្ធិឯទៀត ។

ជនអ្នកជាប់អំណូស នឹងលក់វត្ថុ ដែលច្បាប់ឲ្យអូសរួចទៅហើយ ។

ជនដែលមិនអាចទិញបាននោះគឺ ៖

អាណាព្យាបាល ទិញវត្ថុ ជារបស់បាលិតខ្លួន ។

ហិតូបត្ថម្ភក ទិញទ្រព្យដែលខ្លួនបានរក្សា ។

ចៅក្រម និងមន្ត្រី ឬ ភ្នាក់ងាររាជការ ទិញវត្ថុ ដែលតុលាការរបស់ខ្លួន ឬ ដែលខ្លួនឯងមានបេសកកម្មត្រូវលក់ ។

ជនអ្នកជាប់អំណូសទិញ របស់ដែលច្បាប់អូស ហើយដាក់លក់ ។

**មាត្រា ១០២៤** ៖ ប្តីប្រពន្ធ លក់ឲ្យគ្នាទៅវិញទៅមកមិនបាន, ការលក់នោះត្រូវទុកជាមោឃៈ ។

## ផ្នែកទី ២
## អំពីភាតព្វកិច្ច នៃអ្នកលក់

**មាត្រា ១០២៥** ៖ អ្នកលក់ត្រូវ :

១. ថែររក្សា វត្ថុដែលកលក់ឲ្យគង់ ។

២. ប្រគល់វត្ថុដែលលក់

៣. ផ្ទេរសិទ្ធិ នៃកម្មសិទ្ធិ ខ្លួនលើវត្ថុនោះឲ្យអ្នកទិញ ។

៤. ទទួលធានាជូនអ្នកទិញអំពីវិការៈ នៃវត្ថុ, អំពីការរំខាន មិនឲ្យប្រើប្រាស់វត្ថុនោះបាន និងអំពីការដកហូតវត្ថុវិញ តាមសេចក្តីសម្រេចរបស់តុលាការ ។

### កថាខណ្ឌទី ១
### អំពីការដែលអ្នកលក់ត្រូវថែររក្សាវត្ថុទុក

**មាត្រា ១០២៦** ៖ អ្នកលក់ត្រូវថែររក្សានូវវត្ថុដែលក់ឲ្យគង់ រហូតដល់ថ្ងៃ ខែ ដែលណាត់ថានឹងប្រគល់វត្ថុឲ្យអ្នកទិញ តាមកាតព្វកិច្ចរបស់ខ្លួន ។

**មាត្រា ១០២៧** ៖ អ្នកលក់ ត្រូវវៀរកុំបីផ្លាស់ប្តូរ, កែប្រែវត្ថុដោយប្រការឯណាៗ ក្នុងរយៈវេលាចាប់តាំងពីថ្ងៃលក់រហូតដល់ថ្ងៃប្រគល់វត្ថុឡើយ ។

**មាត្រា ១០២៨** ៖ អ្នកលក់ ត្រូវទទួលខុសត្រូវ អំពីសេចក្ដីអន្តរាយដែលបណ្ដាលឡើងដល់វត្ថុនោះដរាបដល់ថ្ងៃដែលត្រូវប្រគល់ ។

**មាត្រា ១០២៩** ៖ ការលក់ ត្រូវរំលាយចោល បើវត្ថុដែលលក់ដល់នូវក្ដីអន្តរាយ ឬ ខូចជាខ្លាំងមុនពេលប្រគល់ ។ មួយទៀតបើសេចក្ដីអន្តរាយ ឬ ការខូចនោះកើតមកអំពីកំហុកអ្នកលក់, អ្នកលក់ត្រូវចេញសោហ៊ុយជម្ងឺចិត្តឲ្យអ្នកទិញ ។

**កថាខណ្ឌទី ២**
**អំពីការប្រគល់វត្ថុ**

**មាត្រា ១០៣០** ៖ ដែលហៅថា ការប្រគលើវត្ថុនោះ គឺកិរិយាលើកវត្ថុដែលលក់ឲ្យអ្នកទិញ ។

**មាត្រា ១០៣១** ៖ ការប្រគល់ នោះត្រូវប្រគល់តាមចិត្តភាគីទាំងសងខាង, បើតាមមូលសាស្ត្រ, វត្ថុលក់ត្រូវប្រគល់នៅទីដែលវត្ថុនោះស្ថិតនៅក្នុងវេលាដែលលក់, តែបើអ្នកលក់អាចយកទៅប្រគល់ដល់លំនៅអ្នកទិញក៏បាន ។ ឯអ្នកទិញសោទ នឹងទៅយកវត្ថុដល់ផ្ទះអ្នកលក់ក៏បានដែរ ។

**មាត្រា ១០៣២** ៖ អ្នកលក់ មិនត្រូវប្រគល់ត្រឹមតែតួប្រធាន នៃវត្ថុនោះឡើយ គឺត្រូវប្រគល់ទាំងផល ឬ ទាំងគ្រឿងបរិវារ ដែលត្រូវជាប់នឹងវត្ថុនោះផង ។

**មាត្រា ១០៣៣** ៖ ក្នុងរឿងលក់ អចលនវត្ថុ, ការប្រគល់ប័ណ្ណនៃអចលនវត្ថុនោះ ឬកូនសោជាដើម ត្រូវទុកថាជាបានប្រគល់អចលវត្ថុដោយត្រឹមត្រូវហើយ ។

**មាត្រា ១០៣៤** ៖ អំពីចលនវត្ថុ និងសត្វពាហនៈដែលកម្មសិទ្ធិរបស់វាត្រូវចុះបញ្ជីដែរ, ការប្រគល់ប័ណ្ណ ឬ កាត្រនៃចលនវត្ថុ ឬ សត្វពាហនៈនោះត្រូវទុកជាបានប្រគល់វត្ថុ ឬ សត្វនោះហើយ ។

**មាត្រា ១០៣៥** ៖ វត្ថុលក់ ត្រូវប្រគល់នៅថ្ងៃដែលណាត់ក្នុងកិច្ចសន្យា, បើកិច្ចសន្យា នោះមិនបានណាត់ថ្ងៃទេ, ចៅក្រមគប្បីសន្និដ្ឋានថាអ្នកលក់ត្រូវប្រគល់វត្ថុដែលលក់នោះមួយរំពេច, វៀរតែបើអ្នកទិញមិនទាន់ចេញថ្ងៃទេ, នោះទើបត្រូវបើកសិទ្ធិឲ្យអ្នកលក់ឃាត់វត្ថុនោះទុកសិន ។

**មាត្រា ១០៣៦** ៖ សោហ៊ុយ នៃការប្រគល់វត្ថុនោះត្រូវអ្នកលក់ចេញ, លើកមួយតែកាលណាមានសេចក្ដីព្រមព្រៀងគ្នាផ្សេងពីនេះទៅវិញ ។

**មាត្រា ១០៣៧** ៖ បើអ្នកទិញ, ថ្វីបើបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួនហើយ, នៅតែមិនទាន់បានវត្ថុនោះទេដោយអ្នកលក់មិនព្រមប្រគល់ក្ដី, ដោយថ្ងៃសន្មតកន្លងហួសទៅក្ដី, អ្នកទិញអាចនឹងទារឲ្យប្រគល់វត្ថុដែលលក់នោះឲ្យទាល់តែបានដោយសុំឲ្យកងកម្លាំងអាជ្ញាសាធារណៈជួយក៏បាន ឬ រំលាយនូវកិច្ចសន្យានោះក៏បាន, មិនតែប៉ុណ្ណោះសោតអ្នកទិញមានសិទ្ធិទារសោហ៊ុយជម្ងឺចិត្តថែមទៀតផង ។

**កថាខណ្ឌទី ៣**
**អំពីការផ្ទេរនូវកម្មសិទ្ធិ**

**មាត្រា ១០៣៨** ៖ ក្នុងរឿងអចលវត្ថុ, ការផ្ទេរនូវកម្មសិទ្ធិរបស់អ្នកលក់ឲ្យទៅអ្នកទិញនោះទុកជាត្រឹមត្រូវ, តតិយជនតវ៉ាលែងបាន, តាំងពីថ្ងៃដែលសំបុត្រ

លក់នោះមាន សេចក្តីបញ្ជាក់, មានប្រថាប់ត្រា និងមានចុះបញ្ជីការអ៊ីម៉្មាទ្រីគូឡា ស្ស៊ុង ឬ ក្នុងសៀវភៅភូមិបាលផងទៀត ។

**មាត្រា ១០៣៩** ៖ អំពីលក់ដូរ នូវចលនវត្ថុ និងសត្វដែលច្បាប់តម្រូវឲ្យចុះក្នុងបញ្ជីតាមបទបញ្ញាជាធរមាន ដែលនោះក៏ត្រូវទុកជាត្រឹមត្រូវផុតតវ៉ាអំពីតតិយជនតាំងពីថ្ងៃដែលសំបុត្រលក់នោះបានទទួលសេចក្តីបញ្ជាក់ និងប្រថាប់ត្រាហើយដែរ ។

**មាត្រា ១០៤០** ៖ ចំពោះចលនវត្ថុឯទៀតវិញ, ការផ្ទេរសិទ្ធិរបស់វាអាចនឹងទុកជាបានការមែនទែនផុតតវ៉ាអំពីតតីយជនបានពីត្រឹមពេលដែលប្រគល់វត្ថុនោះដល់ដៃអ្នកទិញ, លើកលែងតែការលក់ដែលត្រូវតែធ្វើសំបុត្របញ្ជាក់ និងប្រថាប់ត្រាផងតែប៉ុណ្ណោះ ។

**កថាខណ្ឌទី ៤**
**អំពីការធានា ចំពោះវិការៈនៃវត្ថុ**

**មាត្រា ១០៤១** ៖ ដែលហៅថា វិការៈ នោះគឺការសៅហ្មងផ្សេងៗ ដែលធ្វើឲ្យវត្ថុនោះប្រើការក្នុងមុខងាររបស់វាមិនកើត ឬ ឲ្យតម្លៃ ឬ ឲ្យថយប្រយោជន៏ច្រើនប្រើការមិនបាន ។

**មាត្រា ១០៤២** ៖ អ្នកលក់មិនត្រូវរ៉ាប់រងអំពីវិការៈដែលសើរៗខាងក្រៅទេ គឺត្រូវរ៉ាប់រងអំពីវិការៈដែលកំបាំង (vices caches)

**មាត្រា ១០៤៣** ៖ បើវិការៈនោះទើបនឹងបណ្តាលឡើងក្រោយពេលលក់, អ្នកលក់ក៏មិនត្រូវរ៉ាប់រងដែរ ។

**មាត្រា ១០៤៤** ៖ បើអ្នកទិញ មានបន្ទាល់ថាវិការៈនោះមានមុនពេលលក់, អ្នកទិញអាចសុំរំលាយការលក់នោះចោល ឬ ក៏បន្ថយថ្លៃខ្លះបានតាមចិត្ត ។ ទោះនឹងលែងទិញក្តី, ទោះនឹងសុំឲ្យបន្ថយថ្លៃក្តី, អ្នកទិញត្រូវនិយាយក្នុងឆ្នាំបន្ទាប់ពីឆ្នាំដែលប្រគល់វត្ថុ, បើពុំនិយាយក្នុងឆ្នាំនោះទេ, ការនៅស្ងៀមនេះត្រូវទុកជាអ្នកទិញសុខចិត្តព្រមយកហើយ ។

**មាត្រា ១០៤៥** ៖ បើបានខសន្យា ជាពិសេសហើយ, អ្នកលក់ត្រូវផុតចាកការរ៉ាប់រងអំពីវិការៈបាន ។ បើអ្នកទិញថាអ្នកលក់ត្រូវរ៉ាបរងតែក្នុងកំណត់កាលប៉ុណ្ណោះៗទេ លុះផុតកំណត់កាលនោះហើយអ្នកលក់ត្រូវរួចពីការរ៉ាប់រងចំពោះវិការៈនោះហើយ ។

តែបើអ្នកលក់មានគំនិតអាក្រក់, លាក់, បិទបាំងវិការៈនោះខសន្យាដូចខាងលើនេះក៏ត្រូវទុកជាមោឃៈដែរ ។

**មាត្រា ១០៤៦** ៖ គេអាចព្រមឲ្យសាកវត្ថុលក់បានដែរ ។ ដែលហៅថាសាកនោះគឺត្រូវប្រគល់វត្ថុទៅអ្នក ដែលចង់ទិញឲ្យយកទៅប្រើមើលឲ្យដឹងថាវត្ថុនោះត្រឹមត្រូវតាមនិស្ស័យវាហើយ ឬ នៅ ។

**មាត្រា ១០៤៧** ៖ ការលក់សាក នេះមិនគប្បីប្រមាណនឹងចិត្តឯងបានឡើយ ។

**មាត្រា ១០៤៨** ៖ កិច្ចសន្យា ត្រូវតែកំណត់អំពីរយៈវេលាដែលត្រូវសាកនោះ, ថាបើផុតរយៈវេលានោះហើយ, អ្នកទិញនៅតែស្ងៀមនេះ ត្រូវទុកថាអ្នកទិញទទួលទិញហើយ ។

**មាត្រា ១០៤៩** ៖ បើកិច្ចសន្យា មិនបានកំណត់រយៈវេលានៃការសាកទេ, តុលាការថ្លឹងតាមជាតិនៃវត្ថុ និងទម្លាប់ដែលធ្លាប់ប្រើក្នុងស្រុកជាប្រមាណតាមសមគួរដល់យោបល់ខ្លួនចុះ ។

**មាត្រា ១០៥០** ៖ ក្នុងករណីលក់សាក នេះ, អ្នកទិញមិនត្រូវយកវិការៈណាមួយនៃវត្ថុមកជាសំអាងដើម្បីនឹងរំលាយការលក់នោះបានឡើយ ។

បើអ្នកទិញព្រមយកហើយ, សេចក្ដីក្នុងកិច្ចសន្យាដែលបានល័ក្ខខណ្ឌអំពីការសាកនោះក៏ត្រូវអស់ន័យដែរ ។ បើអ្នកទិញប្រកែកមិនយកវិញ, សេចក្ដីប្រកែកនេះឃាត់មិនឲ្យកិច្ចសន្យាលក់នោះកើតឡើងបានទេ ។

## កថាខ័ណ្ឌទី ៥
## អំពីការរ៉ាប់រង ចំពោះការរំខាន និងចំពោះការដកហូត

**មាត្រា ១០៥១** ៖ អ្នកលក់ មិនត្រូវប្រព្រឹត្តដោយប្រការឯណាឲ្យអ្នកទិញខានប្រើប្រាស់វត្ថុនោះឡើយ ។

ប្ដេជ្ញា ទាំងពួង ដែលអនុញ្ញាតឲ្យអ្នកលក់រួច អំពីកាតព្វកិច្ចនេះត្រូវទុកជាអសាឥតការ ។

**មាត្រា ១០៥២** ៖ ដែលហៅថា ការរំខាន នោះគឺកិច្ចការទាំងពួងដែលបង្អាក់បង្ខាន អ្នកទិញមិនឲ្យប្រើប្រាស់នូវវត្ថុ ដែលទិញដោយសន្តិភាពបាន ។

**មាត្រា ១០៥៣** ៖ សេចក្ដី ដែលតុលាការ កាត់សេចក្ដីដកសិទ្ធិដែលអ្នកលក់បានផ្ទេរ ឲ្យទៅអ្នកទិញនោះដើម្បីយកមកឲ្យតតិយជនវិញហៅថាការដកហូត ។

**មាត្រា ១០៥៤** ៖ តុលាការ អាចដកហូតសិទ្ធិទាំងអស់ក៏បាន, ដកភាគខ្លះក៏បានតាមតែតតិយជន ដែលមានសិទ្ធិដ៏ត្រឹមត្រូវប្ដឹងទារសិទ្ធិដែលអ្នកលក់ផ្ទេរទៅឲ្យអ្នកទិញទាំងអស់ ឬ ភាគខ្លះ ។

**មាត្រា ១០៥៥** ៖ អ្នកលក់ មិនត្រូវទទួលរ៉ាប់រង ជូនអ្នកទិញអំពីការរំខានដែលបណ្ដាលមកពីតតិយជន ជាអ្នកគ្មានសិទ្ធិលើវត្ថុនោះបន្ដិសោះមកកំហែងកំហល់វាយដំនោះទេ ។

**មាត្រា ១០៥៦** ៖ អ្នកលក់ ត្រូវរ៉ាប់រងជូនអ្នកទិញអំពីការរំខានណាដែលតតិយជនគំរាមថានឹងប្ដឹងឲ្យដកហូតវត្ថុនោះទាំងអស់ ឬ ភាគខ្លះ ។

**មាត្រា ១០៥៧** ៖ សេចក្ដីគំរាម ថានឹងដកហូតនោះកើតឡើងក្នុងគ្រា ដែលតតិយជនទាមទារឲ្យអ្នកទិញទទួលស្គាល់នូវសិទ្ធិ ដែលគេអួតថាមានលើវត្ថុទាំងអស់ ឬ ភាគខ្លះ។

**មាត្រា ១០៥៨** ៖ នាកាលតតិយជន ថានឹងប្ដឹងឲ្យដកហូតហើយ, អ្នកទិញអាចទៅហៅអ្នកលក់ឲ្យមករ៉ាប់រងភ្លាមបាន ។

**មាត្រា ១០៥៩** ៖ ខណៈនោះអ្នកលក់ត្រូវបញ្ចេញប័ណ្ណរបស់ខ្លួន, ប្រើគ្រប់មធ្យោបាយទាំងពួងឲ្យតតិយជននោះលែងប្ដឹងទៅវិញក្ដី, ឲ្យបានឈ្នះតតិយជននោះតាមអំណាចសាលក្រមក្ដី ។

**មាត្រា ១០៦០** ៖ បើអ្នកទិញ បានហៅអ្នកលក់ឲ្យមករ៉ាប់រងជួសខ្លួនហើយ, អ្នកទិញមិនត្រូវបានសោហ៊ុយជួសជុលអ្វីឡើយ ។

**មាត្រា ១០៦១** ៖ បើអ្នកលក់រម្ងាប់សេចក្ដីរំខាន នោះមិនបានទេ, ការប្ដឹងផ្ដល់ក៏ប្រព្រឹត្តទៅតាមដំណើររបស់វា ។

**មាត្រា ១០៦២** ៖ បើតុលាការកាត់សេចក្ដីដកហូតទាំងអស់, អ្នកលក់ត្រូវបង្វិលថ្លៃទាំងអស់ដែលខ្លួនទទួលបានហើយឲ្យគេវិញ, មួយវិញទៀតអ្នកលក់ត្រូវចេញសោហ៊ុយជម្ងឺចិត្តផង, នៅក្នុងជម្ងឺចិត្តនោះត្រូវគិតដំណាច់បង់ខាតក្នុងការធ្វើកិច្ចសន្យាផង,ប្រសិនបើកាលធ្វើនោះអ្នកទិញបង់ប្រាក់ដំណាច់នេះដែរ, ប្រាក់ប្រដាប់ក្ដីផង, បើអ្នកទិញបានចេញមុន, ផលនិងផលទុនដែលតុលាការត្រូវកាត់ឲ្យបានទៅតតិយជនផងអធិលាភផង, ប្រសិនបើវត្ថុនោះបានកើនឡើងតាំងពីថ្ងៃដែលលក់មក, ប្រាក់ចំណាយផងទោះជាចំណាយ នោះច្រើនហួសខ្នាតក្ដីឲ្យតែអ្នកទិញគិតបញ្ចូលទៅក្នុងវត្ថុនោះតាំងពីថ្ងៃលក់មក ។

**មាត្រា ១០៦៣** ៖ បើតុលាការកាត់សេចក្ដីឲ្យដកហូតតែភាគខ្លះ, អ្នកទិញអាចសុំឲ្យរំលាយការលក់វិញបានហើយ បង្វិលវត្ថុដែលសល់នៅនឹងខ្លួនឲ្យទៅអ្នកលក់វិញ ។ ឯជម្ងឺចិត្តដែលអ្នកទិញត្រូវបាននោះត្រូវគិតដូចក្នុងករណីដែលដកហូតទាំងអស់ដែរ ។

បើអ្នកទិញព្រមទទួលយកវត្ថុដែលនៅសល់នោះ, ជម្ងឺចិត្តត្រូវគិតតាមភាគដែលបាត់បង់ដោយការដកហូតនោះ ។

**មាត្រា ១០៦៤** ៖ បើវត្ថុនោះឲ្យអធិលាភ, តម្លៃនៃវត្ថុនោះត្រូវគិតតាមតម្លៃក្នុងខណៈដែលដកហូត, មិនត្រូវគិតតាមតម្លៃក្នុងវេលាទិញទេ, ក្នុងករណីផ្ទុយទៅ

វិញ, តម្លៃនៃវត្ថុនោះត្រូវគិតតាមតម្លៃក្នុងវេលាលក់ កុំឲ្យគិតតាមតម្លៃក្នុងវេលាដកហូតឡើយ ។

**មាត្រា ១០៦៥** ៖ ភាគីទាំងសងខាង អាចនឹងបន្ថយទំហំនៃការរ៉ាប់រងចំពោះសេចក្ដីរំខានដែលមានហេតុគឺដកហូតនោះបាន ។

ភាគីទាំងសងខាង អាចនឹងព្រមព្រៀងគ្នាថាឲ្យអ្នកលក់រួចអំពីការរ៉ាប់រងទាំងអស់ក៏បាន ។

**មាត្រា ១០៦៦** ៖ កាតព្វកិច្ចនៃការទទួលរ៉ាប់រងនេះ, បើអ្នកលក់ស្លាប់, ត្រូវធ្លាក់ទៅលើទាយាទនៃអ្នកនេះទាំងអស់ ។

**មាត្រា ១០៦៧** ៖ បើវត្ថុដែលលក់នោះបានមកដោយអំពីល្មើសជាឧក្រិដ្ឋ ឬជាមជ្ឈិម, អ្នកទិញ, កាលបើបានដឹងហើយ, អាចនឹងសុំរលាយការលក់នោះវិញបានទោះមិនមានក្រែកគេដកហូតវិញក៏ដោយ ។

សេចក្ដីប្ដេជ្ញា ដែលផ្ទុយពីសេចក្ដីនេះត្រូវទុកជាមោឃៈ ។

**មាត្រា ១០៦៨** ៖ ប្រសិនបើវត្ថុតែងដែល ហើយលក់ឲ្យច្រើននាក់តៗគ្នា, អ្នកទិញក្រោយបង្អស់ត្រូវហៅអ្នកដែលលក់ឲ្យខ្លួនមករ៉ាប់រង ។ អ្នកលក់នេះនឹងប្រកាន់អ្នកដែលលក់ឲ្យខ្លួនតៗទៅទៀតតាមត្រូវការ ។

## ផ្នែក ទី៣

## អំពីភាតព្វកិច្ច នៃអ្នកទិញ

**មាត្រា ១០៦៩** ៖ អ្នកទិញ ត្រូវបង់ថ្លៃដែលព្រមព្រៀងគ្នានៅថ្ងៃនិងនៅទីកន្លែងដែលបានណាត់ហើយ ។

**មាត្រា ១០៧០** ៖ បើកិច្ចសន្យាមិនបានចង្អុលទីកន្លែងនិងថ្ងៃដែលត្រូវបង់ថ្លៃទេ, ការនេះគប្បីសន្និដ្ឋានថាត្រូវបង់នៅទីនិងវេលាដែលប្រគល់វត្ថុ ។

**មាត្រា ១០៧១** ៖ កិច្ចសន្យាអាចបង្ខំថាបើអ្នកទិញក្របង់ ថ្លៃវត្ថុពេក, ប្រាក់ថ្លៃវត្ថុនោះត្រូវមានការទៀតក៏បាន ។ ឯការនោះមិនអាចគិតឲ្យច្រើនលើសពីអត្រា ៥ % ក្នុងមួយឆ្នាំបានទេ ។

**មាត្រា ១០៧២** ៖ បើកិច្ចសន្យាមិននិយាយពីការប្រាក់ទេ, អ្នកទិញត្រូវចេញតែថ្លៃ ដើម ។ តែក្នុងករណីដែលវត្ថុនោះបង្កើតជាផល ឬផលទុន, ការប្រាក់ ៥% ក្នុង១ ឆ្នាំត្រូវតែគិត ។

**មាត្រា ១០៧៣** ៖ បើអ្នកទិញបានបានទទួលនូវវត្ថុហើយ, ហើយមានគេប្រកាន់ថានឹងប្ដឹងឲ្យដកហូតវត្ថុនោះវិញ, អ្នកទិញអាចមិនទាន់បង់ថ្លៃវត្ថុនោះដោយទុកប្រាក់នឹងខ្លួនសិនបាន, លុះហេតុនោះរម្ងាប់ហើយសឹមប្រគល់ឲ្យចុះ ។

**មាត្រា ១០៧៤** ៖ បើអ្នកទិញមិនទាន់ចេញថ្លៃឲ្យដរាបណាអ្នកលក់មានសិទ្ធិនឹងផ្អាកវត្ថុនោះទុកដរាបនោះដែរ ។

**មាត្រា ១០៧៥** ៖ បើអ្នកលក់មិនព្រមពន្យាពេលបង់ថ្លៃឲ្យអ្នកទិញ, អ្នកលក់ត្រូវមានសិទ្ធិផ្អាកវត្ថុនោះជាដរាប ។

**មាត្រា ១០៧៦** ៖ ក៏ប៉ុន្តែ, បើតាំងពីថ្ងៃនោះមក, អ្នកទិញធ្លាក់ខ្លួនជាអ្នកក្ស័យទុន ឬ ក៏ត្រូវច្បាប់ឲ្យអូសរបស់ទ្រព្យ, អ្នកលក់, ទោះបីបានពន្យាពេលឲ្យអ្នកទិញក៏ដោយ, ក៏អាចប្រសើសិទ្ធិផ្អាកវត្ថុនោះបានដែរ ។

**មាត្រា ១០៧៧** ៖ បើដល់សន្មតហើយ, អ្នកទិញមិនបានបង់ថ្លៃគ្រប់ទេ, អ្នកលក់អាចសុំរំលាយការលក់នេះវិញបាន, ប្រសិនបើអ្នកលក់មិនចូលចិត្តប្ដឹងទារថ្លៃទេ ។

បើភាគខ្លះនៃថ្លៃសងមិនទាន់អស់ដរាបណា, អ្នកលក់នឹងសុំរំលាយការលក់បានដរាបនោះ ។

**មាត្រា ១០៧៨** ៖ បើរំលាយការរលក់វិញហើយ, ភាគីទាំងសងខាងនៃកាតព្វកិច្ចត្រូវបង្វិលរបស់ដែលខ្លួនបានទទួលឲ្យគ្នាវិញ ។

អ្នកទិញត្រូវបង្វិលវត្ថុព្រមទាំងផល និងផលទុនដែលខ្លួនបានយកអ្នកលក់ត្រូវសងទៅអ្នកទិញនូវប្រាក់ដែលអ្នកទិញបានបានចេញក្នុងថ្លៃប៉ុន្មានៗ ហើយត្រូវគិតការ ៥ % ក្នុងមួយឆ្នាំតាំងពីថ្ងៃដែលបានសងថ្លៃលើកទីមួយលើកៗ ។

**មាត្រា ១០៧៩** ៖ ការរំលាយនូវការលក់ ដែលត្រូវមានរូបមន្តគឺសេចក្ដីបញ្ជាក់ និងប្រថាប់ត្រានោះ, ទោះរំលាយដោយអំណាចសាលក្រមក្ដី, ដោយភាគីព្រមព្រៀងគ្នាក្ដី, ត្រូវចម្លងដាក់ក្នុងបញ្ជីនៃលិខិតបញ្ជាក់តាមពាក្យសុំរបស់ក្រឡាបញ្ជី, ប្រសិនបើរលាយដោយអំណាចសាលក្រម ឬ តាមពាក្យសុំរបស់ភាគីប្រសិនបើរលាយភាគីព្រមព្រៀងគ្នាដោយស្រួល ។

សាលក្រម ឬ សំបុត្ររំលាយការលក់ ដែលធ្វើដោយព្រមព្រៀងស្រួល នឹងគ្នានោះត្រូវចម្លង ដាក់ក្នុងបញ្ជីការនៃឃុំដែលបានបញ្ជាក់ការលក់ដែលត្រូវរលាយនោះ ។

មួយទៀត, មេឃុំត្រូវនិទ្ទេសនៃការរលាយនោះក្នុងរឹមទំព័រនៃសំបុត្រលក់ដែលត្រូវរលាយនោះផង ។

## ចំពូក ទី២
## អំពីការលក់បញ្ចាំ (ឬការលក់លោះទិញ)

**មាត្រា ១០៨០** ៖ ដែលហៅថា ការលក់បញ្ចាំ នោះគឺជាកិច្ចសន្យាលក់សុំរក្សាទុកនូវសិទ្ធិលោះវត្ថុដែលខ្លួនបានលក់ហើយមកវិញដោយចេញថ្លៃ និងសោហ៊ុយទាំងឡាយឲ្យអ្នកទិញទាំងអស់ក្នុងរយៈវេលាណាមួយ ដែលបានព្រមព្រៀងគ្នា ។

**មាត្រា ១០៨១** ៖ ការលក់បញ្ចាំវត្ថុទាំងពួងត្រូវមានលិខិតបញ្ជាក់ ។

**មាត្រា ១០៨២** ៖ រយៈវេលា ដែលត្រូវលោះវត្ថុវិញនោះមិនអាចកំណត់ឲ្យហួសពី ៥ ឆ្នាំបានឡើយ ។

បើទុកជាកំណត់ឲ្យហួសពីនោះក៏ត្រូវបន្ថយមកត្រឹមតែកំណត់ ៥ ឆ្នាំវិញដែរ ។

**មាត្រា ១០៨៣** ៖ ភាគីទាំងឡាយ អាចកំណត់ឲ្យតិចមកទៀតក៏បាន ។

បើថារយៈវេលាមិនបានកំណត់ក្នុងកិច្ចសន្យាទេ, ភាគីត្រូវពិរុទ្ធថាយកតាមរយៈវេលារបស់ច្បាប់ ។

**មាត្រា ១០៨៤** ៖ បើអ្នកលក់មិនបានលោះវត្ថុក្នុងកំណត់រយៈវេលានេះទេ, វត្ថុនោះត្រូវដាច់, អ្នកទិញត្រូវឡើងជាកម្មសិទ្ធិករពេញច្បាប់ ។

**មាត្រា ១០៨៥** ៖ បើនៅក្នុងរយៈវេលា វិញ, អ្នកទិញអាចធ្វើនូវកិច្ចទាំងពួង ដូចជាកម្មសិទ្ធិករនៃវត្ថុនោះដែរ គឺដូចជាលក់វត្ថុនោះឲ្យទៅតតិយជនណាម្នាក់ជាដើមបាន ។

ក្នុងករណីនេះ កម្មសិទ្ធករដើមអាចនឹងលោះដោះសារវត្ថុនោះពីអ្នកទិញក្រោយនេះបាន, ទោះបីលិខិតលក់លើកក្រោយនេះមិនមានសន្យាឲ្យលោះក៏ដោយ ។

**មាត្រា ១០៨៦** ៖ បើអ្នកទិញមានការទាក់ទងតែនឹងភោគីទេអ្នកទិញអាចតតាំងនឹងកម្មសិទ្ធិករមែនទែននៃវត្ថុនោះបាន ។

**មាត្រា ១០៨៧** ៖ សិទ្ធិលោះវត្ថុជាសិទ្ធិរបស់អ្នកលក់, របស់ទាយាទ និងរបស់ម្ចាស់បំណុលនៃអ្នកលក់ ។

**មាត្រា ១០៨៨** ៖ ការលោះវត្ថុអាចកើតមកពីឆន្ទៈដ៏ពិតប្រាកដរបស់អ្នកលក់បាន ។

**មាត្រា ១០៨៩** ៖ ប្រសិនបើអ្នកទិញមិនព្រមបើកឲ្យលោះទេ, អ្នកលក់ត្រូវប្ដឹងមេឃុំ, មេឃុំ, ត្រូវធ្វើកំណាត់ហេតុនៃបណ្ដឹងនេះ ។

**មាត្រា ១០៩០** ៖ នាកាលអ្នកលក់ សុំលោះក្នុងរយៈវេលាត្រឹមត្រូវហើយ, ការលក់នោះត្រូវរលាយ ហើយការផ្ទេរកម្មសិទ្ធិនៃវត្ថុដែលបានផ្ទេរពីថ្ងៃមុនទៅឲ្យអ្នកទិញក៏ត្រូវសូន្យដែរ ។

អ្នកលក់ត្រូវនៅជាកម្មសិទ្ធិករ នៃរបស់នោះជានិច្ច, អ្នកទិញទុកដូចជាមិនបានទិញដែរ, ហេតុដូច្នេះសិទ្ធិប្រត្យ័ក្សទាំងឡាយដែលអ្នកទិញបានបង្កើនឲ្យទៅនរណាក៏បំពានក៏ទៅជាអសាសូន្យអស់ដែរ ។

**មាត្រា ១០៩១** ៖ បើអ្នកទិញមិនអាចដោះសារព្យាសនកម្មដែលបំផ្លាញសិទ្ធិវន្តខ្លួនដោយសារកម្មសិទ្ធិករ មកលោះវត្ថុគេទៅវិញនោះទេ, ម្យ៉ាងវិញទៀត, បើអ្នកទិញលាក់មិនឲ្យសិទ្ធិវន្តដឹងថាវត្ថុនោះគេមិនបានលក់ដាច់ឲ្យខ្លួនទេ, អ្នកទិញត្រូវមានទោសដែលមានបញ្ញត្តិក្នុងមាត្រា ៥១៥១ ក្រមព្រហ្មទណ្ឌ ។

**មាត្រា ១០៩២** ៖ នាកាលអ្នកលក់ ចង់លោះវត្ថុខ្លួនវិញ, ខ្លួនត្រូវសងថ្លៃដើមទៅអ្នកទិញវិញដោយឥតឲ្យការប្រាក់ទេ, បើវត្ថុនោះបង្កើនផល និងផលទុន, បើវត្ថុនោះមិនបង្កើនផល និងផលទុនទេ, ប្រាក់នោះត្រូវមានការ, តែការនោះមិនត្រូវឲ្យហួសពី ៥% ក្នុងមួយឆ្នាំទេ ។

**មាត្រា ១០៩៣** ៖ អ្នកលក់បញ្ចាំអាចនឹងប្តឹងសុំឲ្យតុលាការបដិសេធការលក់នោះបានជាដរាប, ទោះក្នុងវេលាណាក៏ដោយ, ទោះមានការណ៍យ៉ាងណាក៏ដោយ បើក្នុងពេលលក់នោះតម្លៃពិតនៃវត្ថុនោះថ្លៃច្រើនជាងថ្លៃលក់ ៥០ ភាគ ១០០យ៉ាងតិច ។

**មាត្រា ១០៩៤** ៖ អ្នកលក់ ត្រូវសងថ្លៃជួសជុលដែលអ្នកទិញបានចេញក្នុងការជួសជុលជាចាំបាច់ផងតែឯថ្លៃថែទាំវត្ថុនោះមិនត្រូវឲ្យអ្នកលក់សងទេ ។

# ចំពូក ពីរ ស្ទួន
# ព្រះរាជប្រកាសលេខ ១០៥ ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ១៩៣៩
# កតិកាភេទ នៃការលក់

**មាត្រា ទី១** ៖ បើអ្នកលក់ លក់អចលនវត្ថុថោក ជាងពាក់កណ្ដាលថ្លៃដែលខ្លួនត្រូវលក់, ខ្លួនអាចនឹងសុំកតិកាភេទនៃការលក់បាន, គឺតុលាការ, នាកាលបានទទួលពាក្យពីអ្នកលក់ ឬ ពីទាយាទ ឬ សិទ្ធិវន្តនៃអ្នកលក់ហើយ, ត្រូវកាត់សេចក្ដីឲ្យទុកការលក់នោះ, ជាមោឃៈភ្លាមទោះបីក្នុងកិច្ចសន្យាលក់នោះ, អ្នកលក់បានដាក់សេចក្ដីច្បាស់ថាខ្លួនមិនប្ដឹងសុំកតិកាភេទទេ ប្រសិនបើអាចប្ដឹងបានក៏ដោយ ឬក៏បានថែងច្បាស់ថាខ្លួនធ្វើអំណោយដល់អ្នកទិញនូវថ្លៃលើសពីនេះទៅទៀតយ៉ាងនេះក៏ដោយ ។

**មាត្រា ២** ៖ ដើម្បីឲ្យដឹងថាអ្នកលក់វិបរិតប្រយោជន៍ដោយលក់ថោកជាងពាក់កណ្ដាលថ្លៃមែន ឬ មិនមែន, តុលាការត្រូវប៉ាន់តម្លៃអចលនវត្ថុនោះតាមសភាព និងតាមតម្លៃវាក្នុងពេលដែលលក់ ។

**មាត្រា ៣** ៖ បើការលក់នេះ កន្លងមកបីឆ្នាំ ហើយគិតតាំងពីថ្ងៃដែលលក់មក, តុលាការមិនគប្បីទទួលពាក្យសុំកតិកាភេទនោះឡើយ ។ អ្នកប្ដឹងនោះទោះស្រីមានប្ដីក្ដី, អ្នកភៀសខ្លួនក្ដី, អ្នកមានគំហាត់ក្ដី, អនីតិជនណាម្នាក់យកអចលនវត្ថុទៅលក់ក្ដីត្រូវគិតរយៈវេលាបីឆ្នាំដូចគ្នាទាំងអស់ ។

រយៈវេលានេះមិនត្រូវយកទៅគិតក្នុងកិច្ចសន្យាលក់បញ្ចាំនោះទេព្រោះកិច្ចសន្យានេះមិនឋិតនៅក្រោមអាជ្ញាយុកាលនៃមាត្រា ១០៨០ និងតទៅនៃក្រមរដ្ឋប្បវេណីជានិច្ចហើយ។

**មាត្រា ៤** ៖ ដើម្បីសុំឲ្យពិនិត្យពីវិបរិត, ព្រោះលក់ថោកនោះ, អ្នកលក់ត្រូវប្ដឹងទៅតុលាការជាកាតព្វកិច្ច ។ ដើម្បីនឹងសន្និដ្ឋានអំពីវិបរិតនោះ, តុលាការត្រូវពិនិត្យពាក្យដោយបរិមាណភាព ថារឿងដែលគេប្ដឹងមកនោះសមរមគ្រប់គ្រាន់ហើយឬនៅ, ជារឿងធំដុំ ឬ ទេ ។

**មាត្រា ៥** ៖ បន្ទាល់នៃវិបរិតនេះ ត្រូវមានចែងក្នុងសេចក្ដីរាយការណ៍ មួយរបស់អ្នកជំនាញការអំពីអ្នកជំនាញការនេះ បើតាមគោលការ, ភាគីទាំងអស់គប្បីព្រមព្រៀងគ្នារើសតែម្នាក់បានហើយ ។

បើភាគីមិនអាចព្រមព្រៀងគ្នាក្នុងការរើសតែម្នាកនោះទេ តុលាការត្រូវចាត់បីនាក់គឺឲ្យដើមចោទរើសម្នាក់, ឲ្យចុងចម្លើយរើសម្នាក់ និងឲ្យតុលាការរើសម្នាក់ ។

ក៏ប៉ុន្តែអ្នកជំនាញការទាំងបីនាក់នោះ ត្រូវឲ្យព្រមព្រៀងគ្នាធ្វើសេចក្ដីរាយការណ៍ហើយឲ្យមូលមាត់គ្នាដាក់យោបល់តែមួយ ហើយដូចគ្នាទៀត ។

**មាត្រា ៦** ៖ ប្រសិនបើតុលាការទុកបណ្ដឹង សុំកតិកាភេទជាត្រឹមត្រូវហើយ, អ្នកទិញអាចរើសយកចំណុចណាមួយបណ្ដាចំណុចទាំងពីរនេះ គឺប្រគល់អចលនវត្ថុឲ្យម្ចាស់វា ហើយដកយកថ្លៃដែលបានបង់ហើយមកវិញក៏បាន ឬ ទុកអចលន

វត្ថុនោះហើយថែមប្រាក់ឲ្យគ្រប់ទៀតតាមថ្លៃដែលអ្នកជំនាញការបានកំណត់មកក៏បាន ។

តតិយជនដែលបានទិញ ត ពីអ្នកទិញផ្ទាល់ក៏មានសិទ្ធិនេះដូចគ្នា, លើកមួយតែបើអ្នកទិញផ្ទាល់រ៉ាប់ថានឹងតវ៉ានឹងលក់ជួស ។

**មាត្រា ៧** ៖ ថាបើអ្នកទិញពេញចិត្តនឹងទុក អចលនវត្ថុជាងហើយថែមថ្លៃឲ្យទៀតដូចមានសំដែងក្នុងមាត្រាមុន, ខ្លួនត្រូវចេញការនៃថ្លៃដែលឲ្យខ្វះនោះតាំងពីថ្ងៃដែលអ្នកលក់ប្តឹងមក ។

ថាបើអ្នកទិញពេញចិត្តនឹងប្រគល់អចលនវត្ថុ នោះជាងហើយដកយកប្រាក់ខ្លួនមកវិញត្រូវប្រគល់ផលនៃអចលនវត្ថុនោះតាំងពីថ្ងៃដែលគេប្តឹងមក ។

បើអ្នកទិញមិនដែលបានទទួលផលពីអចលនវត្ថុសោះទេ, អ្នកនេះត្រូវបានការនៃប្រាក់ថ្លៃទិញដែលខ្លួនបានបង់ហើយដោយគិតពីត្រឹមថ្ងៃគេប្តឹងមក ឬគិតតាំងពីថ្ងៃទិញមក។

**មាត្រា ៨** ៖ អ្នកទិញ ប្តឹងសុំកតិកាភេទព្រោះវិបរិតប្រយោជន៍ខ្លួននោះមិនបានទេ ។

ការលក់ឯណា ដែលអាជ្ញាធរខាងតុលាការជាអ្នកលក់, ដូចជាអចលនវត្ថុដែលគេទិញបានពីការលក់ឡាយឡុងជាឧទាហរណ៍, ជនណានឹងប្តឹងសុំកតិកាភេទក៏មិនបានដែរ ។

## ចំពូកទី៣
## អំពីការដូរ

**មាត្រា ១០៩៥** ៖ ដែលហៅថា ការដូរ នោះគឺជាកិច្ចសន្យា ដែលភាគីទាំងឡាយព្រមព្រៀងនឹងឲ្យវត្ថុគ្នាទៅវិញទៅមក ។

**មាត្រា ១០៩៦** ៖ ការដូរនេះត្រូវប្រព្រឹត្តទៅតាមច្បាប់ និងតាមរូបមន្តនៃការលក់ ដែរ ។

**មាត្រា ១០៩៧** ៖ បើដូរវត្ថុ ដែលមិនមែនជារបស់ខ្លួនការដូរនោះត្រូវទុកជាមោឃៈ ។

បើភាគីម្ខាងបានទទួលនូវវត្ថុ ហើយ ហើយដឹងថាអ្នកម្ខាងទៀតមិនមែនជាកម្មសិទ្ធិករនៃវត្ថុនោះទេ, ខ្លួក៏មិនត្រូវគេបង្ខំឲ្យប្រគល់វត្ថុថ្នូរនោះទៅឲ្យអ្នកម្ខាងនោះទេ តែខ្លួនត្រូវបង្វិលវត្ថុដែលខ្លួនបានទទួលនោះទៅឲ្យគេវិញ ។

**មាត្រា ១០៩៨** ៖ អ្នកដូរ, ដែលចាញ់បញ្ឆោតគេ, អាចប្ដឹងសុំឲ្យសងវត្ថុដែលខ្លួនបានប្រគល់ឲ្យនោះវិញក៏បាន ឬ ឲ្យសងជម្ងឺចិត្តក៏បាន ។

## ចំពូកទី ៤
## អំពីកិច្ចសន្យានៃការជួល

**មាត្រា ១០៩៩** ៖ ដែលហៅថា ការជួល គឺកិច្ចសន្យាដែលជនណាម្នាក់សន្យាថានឹង ផ្ដល់ទៅឲ្យជនណាម្នាក់ទៀតនូវវត្ថុណាមួយ ដើម្បីប្រើប្រាស់ក្នុងពេលមានកំណត់ដោយឲ្យថ្លៃតាមសមាមាត្រនៃពេល ។

**មាត្រា ១១០០** ៖ ច្បាប់នៃការជួល នេះរេទៅតាមប្រភេទនៃវត្ថុដែលការប្រើប្រាស់តម្រូវឲ្យជួល ។

**មាត្រា ១១០១** ៖ វត្ថុដែលជួល នោះអាចជាវត្ថុ សម្ភារៈ ក៏បាន, ថ្លៃនៃការជួលនេះហៅថា ឈ្នួល វត្ថុ, អាចជាកម្លាំងមនុស្សធ្វើការក៏បាន, ថ្លៃជួលកម្លាំងយ៉ាងនេះហៅថាឈ្នួលការ និងអាចជាដើមទុនក៏បាន, ថ្លៃជួលទុននេះហៅថាការប្រាក់ ។

## ផ្នែកទី ១
## អំពីការជួលវត្ថុ

**មាត្រា ១១០២** ៖ វត្ថុដែលអាចជួលបាននោះគឺវត្ថុជាអចលនវត្ថុ ឬចលវត្ថុ ។

### កថាខណ្ឌទី ១
### ការជួល នូវអចលវត្ថុ

**មាត្រា ១១០៣** ៖ កិច្ចសន្យា ដែលប្តេជ្ញាអំពីការជួលអចលវត្ថុ ហៅថា ភតិសន្យា ។

ម្ចាស់វត្ថុ ដែលជួលវត្ថុទៅឲ្យគេហៅថា ភតិបតី ។ អ្នកដែលជួលវត្ថុគេប្រើហៅថា អ្នកជួល ឬ ភតិក ។

បើអចលវត្ថុដែលជួលនោះជាផ្ទះ, ថ្លៃជួលផ្ទះឲ្យហៅថា ឈ្នួលផ្ទះ ។ បើជាថ្លៃឈ្នួលស្រែចំការ ឲ្យហៅថាឈ្នួលដី ។

អ្នកដែលជួលផ្ទះគេហៅថា អ្នកជួលផ្ទះ ។ អ្នកជួលស្រែចំការហៅថា អ្នកជួលដី ។

**មាត្រា ១១០៤** ៖ ឈ្នួលផ្ទះ ឬឈ្នួលដី អាចគិតជាប្រាក់ ឬជាផលនៃដីក៏បាន ។

**មាត្រា ១១០៥** ៖ ភតិសន្យាទាំងឡាយមិនអាចកំណត់ថាព្រមជួលអស់កាលគ្មានទីបំផុតបានទេ ។ នាកាលបើភតិតសន្យាមិនបានបញ្ជាក់អំពីរយៈវេលាទេ, ភតិសន្យាត្រូវសន្និដ្ឋានថាកំណត់ត្រឹមតែបីឆ្នាំប៉ុណ្ណោះ ។

(ក្រម២២៤ ន.ស ១៨.៩.៥៧) ទោះបីម្ដេចម្ដា ភតិសន្យាមិនអាចកំណត់ថាព្រមជួលលើសពី ៩៩ ឆ្នាំបានទេ ។

**មាត្រា ១១០៦** ៖ ភតិសន្យាដែលជួល លើសពីកំណត់មួយឆ្នាំឡើងទៅត្រូវធ្វើជាលាយល័ក្សអក្សរដរាប ។

បើភតិសន្យាបានកំណត់រយៈវេលាលើសពីបីឆ្នាំ, កិច្ចនោះត្រូវតែធ្វើជាលិខិតបញ្ជាក់ ឬ ធ្វើនៅមន្ទីរសារការី ។

ភតិសន្យា, ដែលធ្វើតាមរូបមន្តយថាភូតនៅមន្ទីរសារការី ឬ មានបញ្ជាក់ហើយចុះក្នុងបញ្ជីភូមិបាលទៀត, ត្រូវទុកជាត្រឹមត្រូវ, តតិយជនមិនអាចតវ៉ាបានឡើយ ។

**មាត្រា ១១០៧** ៖ នាកាលភតិសន្យាធ្វើតែមាត់ទទេ, ឥតសំបុត្រស្នាមទេ ហើយបញ្ជាក់បានលុះណាតែភតិសន្យានោះមានកំណត់ត្រឹមតែមួយឆ្នាំប៉ុណ្ណោះ ។

**មាត្រា ១១០៨** ៖ ភតិបតីត្រូវផ្ដល់ទីស្ថានដែលជួលនោះឲ្យអ្នកជួលអាស្រ័យផលក្នុងអំឡុងពេលដែលជួល ។

**មាត្រា ១១០៩** ៖ អាស្រ័យហេតុនេះ ភតិបតីត្រូវប្រគល់អចលនវត្ថុឲ្យអ្នកជួល, ត្រូវរៀបចំឲ្យគង់ល្អក្នុងរយៈវេលានៃភតិសន្យា, ត្រូវវៀរនូវអំពើទាំងពួងដែលនាំឲ្យរំខានដល់អ្នកជួល, បើមានតតិយជនមកប្រកាន់ថាគេមានសិទ្ធិឯណា

មួយ, ភតិបតីត្រូវទទួលរ៉ាប់រងការពារសេចក្ដីរំខាននោះ, ត្រូវទទួលខុសត្រូវចំពោះវិការភាពដែលកំបាំង ។

**មាត្រា ១១១០** ៖ ការប្រគល់នោះត្រូវធ្វើនៅថ្ងៃដែលបានណាត់ក្នុងកិច្ចសន្យា, បើកិច្ចសន្យាមិនបានណាត់ថ្ងៃប្រគល់ទេការប្រគល់ ត្រូវយកថ្ងៃតាមទំនៀមដែលគេធ្លាប់ជួលមក។

**មាត្រា ១១១១** ៖ ភតិបតីត្រូវចាត់ចែងឲ្យជួសជុលការគ្រប់ចំពូកដែលគួរជួសជុលដើម្បីឲ្យអចលវត្ថុនោះបានគង់នៅល្អ, អ្នកនេះត្រូវឲ្យជួសជុលអ្វី ដែលខូចមុនថ្ងៃប្រគល់ដូច្នេះជាដើម ។

**មាត្រា ១១១២** ៖ ភតិបតីត្រូវថែទាំអចលវត្ថុឲ្យល្អដើម្បីឲ្យអ្នកជួលប្រើប្រាស់អចលវត្ថុនោះតាមនិស្ស័យរបស់វាក្នុងវេលាដែលជួលនោះ ។ ប៉ុន្តែចំពោះការជួសជុលបន្តិចបន្តួចនោះ, ភតិបតីមិនបាច់ធ្វើអ្វីឡើយ ។

**មាត្រា ១១១៣** ៖ ភតិបតី មិនអាចធ្វើអ្វីៗដែលជាហេតុនាំឲ្យទីដែលជួលឲ្យគេនោះថយប្រយោជន៍ ឬ មិនគាប់ចិត្តគេបានទេ ។

ប៉ុន្តែភតបតី អាចចាត់ឲ្យជួសជុលអ្វីជាប្រញាប់និងជាចាំបាច់ ។

បើការជួសជុលនោះត្រូវត្រូវធ្វើយូរជាងមួយខែ ឬ ធ្វើឲ្យទីនោះមិនជាទីអាស្រ័យនៅបានទេ, អ្នកជួលអាចសុំឲ្យបន្ថយឈ្នួល ឬ សុំឲ្យបដិសេធកិច្ចសន្យាចោលបាន ។

**មាត្រា ១១១៤** ៖ ភតិបតី ត្រូវរ៉ាប់រងជូន អ្នកជួល អំពីសេចក្ដីរំខានទាំងឡាយ ដែល បណ្ដាលមកពីតតិយជនអួតអាងថា ខ្លួនគេមានសិទ្ធិណាមួយលើអចលវត្ថុជួលនោះ ដូចជាសេវភាព, ផលុភោគ, កម្មសិទ្ធិ, ការបញ្ចាំជាដើម ។

**មាត្រា ១១១៥** ៖ ភតិបតីត្រូវទទួលរ៉ាប់រងតែអំពីវិការភាពណាដែលមើលមិនឃើញហើយធំដុំផង, ហើយមួយទៀត, បើមានវិការភាពនោះទៅវានឹងនាំឱ្យប្រើវត្ថុនោះមិន កើត ។

**មាត្រា ១១១៦** ៖ អ្នកជួល ត្រូវប្រើប្រាស់វត្ថុនោះតាមសេចក្ដីព្រមព្រៀងគ្នាគឺប្រើប្រាសក្នុងឋានៈនៃខ្លួនជាបិតាដ៏ប្រពៃនៃគ្រួសារត្រូវចេញឈ្នួលតាមពេលវេលាដែលបានកំណត់, ដល់ផុតភតិសន្យាហើយត្រូវបង្វិលវត្ថុឱ្យគេវិញ ។

**មាត្រា ១១១៧** ៖ ថាបើភតិសន្យាមិនបាននិយាយអំពីបែបបទដែលត្រូវប្រើវត្ថុនោះយ៉ាងណាៗទេ, វត្ថុនោះមាននិស្ស័យត្រូវប្រើបែបណាត្រូវប្រើបែបនោះតាមកាលៈទេសៈ ។

**មាត្រា ១១១៨** ៖ អ្នកជួលត្រូវប្រើប្រាស់នូវវត្ថុនោះក្នុងឋានៈជាបិតាដ៏ប្រពៃនៃគ្រួសារគឺថាត្រូវថែទាំវត្ថុនោះឱ្យបានគង់ល្អ, ត្រូវចាត់ចែងឱ្យរក្សាដោយផ្ចិតផ្ចង់និងដោយប្រយ័ត្នបីដូចជារបស់នៃខ្លួន ។ អ្នកជួល ត្រូវជួសជុលអ្វីៗដែលខ្លួនជាអ្នកជួលត្រូវធ្វើដោយបង់ខាតលើខ្លួនជាដើម ។

**មាត្រា ១១១៩** ៖ អ្នកជួល ត្រូវចេញឈ្នួល ក្នុងថ្ងៃដែលមានណាត់ក្នុងកិច្ចសន្យា, បើមិនបានណាត់ថ្ងៃទេ, អ្នកជួលត្រូវយកតាមទំនៀមក្នុងស្រុក ។ បើមិន

ជាក់ច្បាស់ពីទំនៀមទេគប្បីសនិដ្ឋានថាត្រូវចេញឈ្នួលក្នុងវេលាផុតកំណត់ជួលគឺថាមិនត្រូវចេញមុនទេ ។

**មាត្រា ១១២០** ៖ ឈ្នួលផ្ទះ និងឈ្នួលដី នឹងប្ដេជ្ញាគ្នាថាអ្នកជួលត្រូវយកឈ្នួលទៅឲ្យដល់ផ្ទះភតបតីក៏បាន ឬ ភតិបតីត្រូវតែទៅយកឯផ្ទះអ្នកជួលក៏បាន ។ បើគ្មានប្ដេជ្ញាយ៉ាងនេះទេ, ភតិបតីត្រូវយកទៅយកឈ្នួលឯផ្ទះអ្នកជួល ។

**មាត្រា ១១២១** ៖ ដល់ផុតភតិសន្យា ហើយអ្នកជួលត្រូវបង្វិលអចលវត្ថុដល់ភតិបតីវិញ ដោយទុកវត្ថុនោះឲ្យគង់នៅល្អដូចដើម គឺថាកុំឲ្យមានបាក់បែក, ខូចខាតណាដែល បណ្ដាលមកពីខ្លួន ។ ឯការបាក់បែកខូចខាតណាដែលបណ្ដាលមកពីការប្រើប្រាស់ជាធម្មតានូវអចលវត្ថុនោះ, អ្នកជួលមិនត្រូវទទួលខុសត្រូវឡើយ ។

**មាត្រា ១១២២** ៖ ក្នុងរយៈពេលកំពុងជួល បើអ្នកជួលមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនទេ, ភតិបតីមានសិទ្ធិសុំឲ្យបដិសេធភតិសន្យានោះចោលហើយដេញអ្នកជួលនោះចេញ ។

**មាត្រា ១១២៣** ៖ អ្នកជួលមិនអាចជួលអចលវត្ថុនោះតទៅអ្នកដទៃដោយឥតសុំអនុញ្ញាតពីភតិបតីបានទេ, វៀរតែបើមានខសន្យាគ្នាថាបើកឲ្យជួសបាន, ទើបបាន ។

**មាត្រា ១១២៤** ៖ អ្នកជួល ដែលបានជួលវត្ថុឲ្យគេតទៅទៀតនោះត្រូវនៅជាប់កាតព្វកិច្ចជាមួយនឹងភតិបតីដដែល, អ្នកជួលត្រូវទទួលខុសត្រូវរបស់អ្នកជួលត លើខ្លួនមានការខូចខាត,បែកបាក់ទាំងឡាយដែលបណ្ដាលពីអ្នកជួលតជាដើម ។

**មាត្រា១១២៥** ៖ ប្រសិនបើអចលវត្ថុ ត្រូវភ្លើងឆេះ ត្រូវពិរុទ្ធថាខុស លើអ្នកជួល, អ្នកជួលអាចនឹងផុតពីពិរុទ្ធនេះបានលុះណាតែអ្នកជួលនោះមានបន្ទាល់ថាភ្លើង នោះបណ្ដាលមកពីករណីប្រធានសក្តិ ឬពីវិការភាពនៃសំណង់ ឬក៏រាលមកពីផ្ទះអ្នកជិតខាង ។

**មាត្រា ១១២៦** ៖ នាកាលភតិបតីត្រូវគេដកហូតសិទ្ធិកម្មលើវត្ថុ នោះហើយ, ភតិសន្យាក៏ត្រូវផុតអនុវត្តិដែរ ។ ប៉ុន្តែបើភតិសន្យា កាលប្ដេជ្ញានឹងគ្នានោះជាលិខិតបញ្ជាក់, ទោះបីម្ចាស់បំណុលរបស់ភតិបតីនេះបានដកហូតអចលវត្ថុនោះក៏ដោយក៏ភតិសន្យានោះនៅតែបានការដដែល, ខណៈនេះភតិសន្យានោះត្រូវឲ្យផលមកម្ចាស់បំណុលនៃភតិបតីវិញ។

**មាត្រា ១១២៧** ៖ ពន្ធដី ត្រូវនៅលើភតិសន្យានេះបានប្ដេជ្ញាផ្ទុយពីនេះទៅវិញ ។

**មាត្រា ១១២៨** ៖ ភតិបតីត្រូវបណ្ដោយឲ្យអ្នកជួលប្រើប្រាស់នូវវត្ថុដែលជួលនោះក្នុងរយៈវេលានៃកិច្ចសន្យា ។

**មាត្រា ១១២៩** ៖ អ្នកជួល ត្រូវទទួលចេញ ឈ្នួលឲ្យភតិបតីក្នុងវេលាដែលជួល ។

**មាត្រា ១១៣០** ៖ ទោះភតិបតីស្លាប់ទីក្តី ក៏ភតិសន្យាត្រូវតែនៅប្រតិបត្តិបានតទៅ ទៀត ។ បើអ្នកជួលស្លាប់វិញ ភតិសន្យានឹងលែងយកមកប្រតិបត្តិបានលុះណាតែទាយាទ ឬ សន្តិជនលែងចង់ជួលតទៅ ។

**មាត្រា ១១៣១** ៖ បើអ្នកជួល មិនបានប្រតិបត្តិតាមកាតព្វកិច្ចរបស់ខ្លួនទេ ឬ ក៏អ្នកជួលយកអចលវត្ថុនោះទៅប្រើប្រាស់ជាការផ្សេង អំពីការដែលត្រូវប្រើ ឬ ក៏ ប្រើក្នុងការដែលនាំឲ្យអន្តរាយដល់អចលវត្ថុ, ភតិបតីអាចសុំឲ្យរំលាយនូវភតិសន្យានោះបាន ។

**មាត្រា ១១៣២** ៖ បើអចលវត្ថុនោះមានភាគមួយវិនាសទៅដោយករណីប្រធាសក្តិ, អ្នកជួលអាចសុំបដិសេធនូវភតិសន្យានោះចោល ឬសុំបន្ថយឈ្នួលបាន ។

**មាត្រា ១១៣៣** ៖ បើដល់ពេលកំណត់សន្យា ហើយមិនចង់ជួលតទៅទៀត, ភតិ បតី និងអ្នកជួលត្រូវប្រាប់គ្នាទៅវិញទៅមកឲ្យដឹង ។ សេចក្តីដែលឲ្យដំណឹងដូច្នេះហៅថាដំណឹងឈប់ជួល (conge)។

**មាត្រា ១១៣៤** ៖ ដំណឹង ឈប់ជួលនេះត្រូវឲ្យក្នុងរយៈវេលាតាមទំនៀមនៃកន្លែងនោះ ។

**មាត្រា ១១៣៥** ៖ បើអចលវត្ថុដែលជួល ជាដី, ភតិបតីអាចឃាត់អ្នកជួលមិនឲ្យយកផលចម្រូតនៃដីចេញពីនោះមុនចេញឈ្នួលបាន, បើអចលវត្ថុជួលជាគេហស្ថានវិញ ភតិបតីអាចឃាត់មិនឲ្យយកគ្រឿងប្រដាប់, តុតាំងចេញពីផ្ទះមិនចេញឈ្នួលបាន ។

**មាត្រា ១១៣៦** ៖ កិច្ចសន្យាដែលកម្មសិទ្ធករឲ្យដីទៅកសិករធ្វើយកផលចែកគ្នាហៅថា ការប្រវាស់ (metayage) ។

**មាត្រា ១១៣៧** ៖ ការចែកនោះត្រូវធ្វើតាមចិត្តនៃគូភាគី ។

បើភាគីមិនបានសន្យាថា ត្រូវចែកគ្នាយ៉ាងណាទេ, ការចែកនោះគប្បីសន្និដ្ឋានថាត្រូវចែកស្មើភាគគ្នា ។

**មាត្រា ១១៣៨** ៖ ការប្រវាស់ ត្រូវប្រតិបត្តិតាមគោលច្បាប់ដែលបញ្ញត្តិអំពីជួលអចលវត្ថុដែរ ។

**មាត្រា ១១៣៩** ៖ អ្នកប្រវាស់, លុះបានគិតគូរចែកគ្នានឹងភតិបតីស្រេចហើយ, ទើបខ្លួនត្រូវយកផលនឹងផលចម្រូតដែលធ្វើបាននោះជារបស់ខ្លួនបាន ។

**កថាខណ្ឌទី ២**

**អំពីការជួលចលវត្ថុ**

**មាត្រា ១១៤០** ៖ ការជួលពាត់ ចលវត្ថុ នោះត្រូវប្រតិបត្តិតាមគោលច្បាប់ដែលស្ដីអំពីការជួលអចលវត្ថុដែរ ។

**មាត្រា ១១៤១** ៖ ជួលចលវត្ថុ នេះបើមិនបានសន្យាគ្នាដោយសំបុត្រស្នាមទេ, ត្រូវសន្និដ្ឋានថាជួលកំណត់ត្រឹមតែមួយឆ្នាំ ។

**មាត្រា ១១៤២** ៖ អ្នកផងជួលសត្វគេប្រើជិះ, ដឹកនាំ ឬ ភ្ជួររាស់ត្រូវសងគេ, បើសត្វនោះស្លាប់ ឬ បាត់វេលាដែលជួល, វៀរតែ, បើមានសេចក្ដីសន្យាគ្នាផ្ទុយពីនេះទៅវិញ ។

**មាត្រា ១១៤៣** ៖ អ្នកផង ជួលសំពៅ, សំប៉ាន, ទូក្តារបស់គេប្រើ, បើបាត់, លិច, ត្រូវសងគេ, វៀរតែ, បើមានសេចក្ដីសន្យាគ្នាផ្ទុយពីនេះទៅវិញ ។

**មាត្រា ១១៤៤** ៖ អ្នកផងជួលរទេះសាឡី នូវសារពើគ្រឿងប្រដាប់ធ្វើកសិកម្ម ឬ ឧស្សាហកម្មមាននង្គ័ល, រនាស់, ត្បាលកិន, កីត្បាញជាដើមបើខូច,

បាត់ត្រូវសងគេ, អ្នកជួលត្រូវថែទាំរបស់ទាំងនោះឲ្យល្អបើគួរជួសជុលក៏ជួសជុលផង ។

**មាត្រា ១១៤៥** ៖ ដែលហៅថា ជួលការងារនោះគឺកិច្ចសន្យាដែលជនម្នាក់ហៅថា ជាង, នយោជិត, អ្នកការ ឬកូនឈ្នួលសន្យាថានឹងធ្វើការក្នុងពេលមានកំណត់ប៉ុណ្ណោះៗឲ្យជនម្នាក់ទៀតហៅថា នាយ, ម្ចាស់ការ ឬ នយោជកដោយយកថ្លៃតាមសមាមាត្រ នៃកាលដែលបានព្រមព្រៀងគ្នា, ថ្លៃនោះហៅថា ប្រាក់ឈ្នួលការ salarires ou gages ។

**មាត្រា ១១៤៦** ៖ គេអាចជួលបានតែការងារផ្ទាល់ខ្លួន ។

**មាត្រា ១១៤៧** ៖ ការជួលការងារ ត្រូវមានកំណត់កាល ។

**មាត្រា ១១៤៨** ៖ ទោះរយៈវេលាដែលចុះក្នុងកិច្ចសន្យានោះប៉ុន្មានៗក្ដី, អ្នកការ ឬម្ចាស់ការអាចនឹងបន្ថយឲ្យតិចមកបានតាមចិត្តស្ម័គ្រ គ្រាន់តែត្រូវកុំខានឲ្យដំណឹងឈប់ជួលប្រាំបីមុនប៉ុណ្ណោះ ។

**មាត្រា ១១៤៩** ៖ ដំណឹង ឈប់ជួលនោះត្រូវឲ្យនៅមុខមេឃុំ ខាងលំនៅនៃអ្នកចុះកិច្ចសន្យាទើបយកជាការបាន ។

**មាត្រា ១១៥០** ៖ ឯប្រាក់ឈ្នួលត្រូវកំណត់ក្នុងសន្យា, បើពុំបានកំណត់ក្នុងកិច្ចសន្យាទេ, ត្រូវយកតាមទំនៀម ។

**មាត្រា ១១៥១** ៖ ប្រាក់ឈ្នួលត្រូវកំណត់ក្នុងសន្យា, បើពុំបានកំណត់ជួល ឬមុនកំណត់ជួលក៏បានតាមចិត្តស្ម្រគ្រនៃគូភាគី ។

ឈ្នួលនោះគប្បីសន្និដ្ឋានថាត្រូវបើកនូវវេលាផុតកំណត់ជួល ។

**មាត្រា ១១៥២** ៖ ថាបើរយៈវេលាដែលត្រូវបើកឈ្នួលនោះគប្បីសន្និដ្ឋានថា ត្រូវបើករាល់ខែឲ្យកូនឈ្នួលនិងនិយោជិតហើយបើករាល់ថ្ងៃឲ្យជាង ។

**មាត្រា ១១៥៣** ៖ នាកាលកិច្ចសន្យានោះត្រូវរលាយមុនដល់ការសន្មត ហើយប្រាក់ឈ្នួលបានបើកយកមុនទៅហើយ, អ្នកការត្រូវបង្វិលភាគដែលលើស ពីចំនួន ដែលខ្លួនត្រូវបាននោះឲ្យនាយការវិញ ។

**មាត្រា ១១៥៤** ៖ បើនាយការឲ្យកូនឈ្នួលលែងធ្វើការ, នាយនោះអាចឲ្យ ឈប់ការភ្លាមបាន, បើត្រូវការឲ្យចេញពីផ្ទះផង, ក៏ឲ្យចេញបាន តែត្រូវគិតប្រាក់ ឈ្នួលដែលត្រូវបើកនោះថែមប្រាក់ប្រាំបីថ្ងៃឲ្យទៀត ។

**មាត្រា ១១៥៥** ៖ បើនាយការប្រើវិហិង្សា ឬ វាយដំកូនឈ្នួល ឬ ប្រើកូន ឈ្នួលឲ្យធ្វើការផ្សេងពីការដែល ខ សន្យាគ្នា ឬបង្ខំឲ្យធ្វើការណាមួយពិបាកពេក លើសកម្លាំង, អ្នកការអាចផ្តាច់កិច្ចសន្យានោះបានដោយមិនចាំបាច់ឲ្យដំណឹងមុន ប្រាំបីថ្ងៃដូចដែលមានបញ្ញត្តិក្នុងមាត្រា ១១៤៨ នោះឡើយ ។

**មាត្រា ១១៥៦** ៖ បើកូនឈ្នួលមិនស្តាប់បង្គាប់ នាយ ឬ ធ្វើការអាក្រក់ ដោយចេតនាក្លែង ឬ មិនធ្វើការដែលខ្លួនទទួលធ្វើនោះ, នាយអាចនឹងផ្តាច់ខ សន្យា នោះបានដោយមិនចាំបាច់ឲ្យដំណឹងមុនប្រាំបីថ្ងៃបានដូចគ្នា ។

**មាត្រា ១១៥៧** ៖ កូនឈ្នួលមិនត្រូវទទួលខុសត្រូវអំពីពស្សនកម្មដែល បណ្តាលឡើងក្នុងវេលាដែលខ្លួនធ្វើការនោះឡើយ ។ វៀរតែបើនាយការមាន បន្ទាល់ថាកូនឈ្នួលនោះធ្វើឲ្យអន្តរាយ ដោយចេតនាចង់ព្យាបាទទើបត្រូវឲ្យកូន ឈ្នួលទទួលខុសត្រូវ ។

**មាត្រា ១១៥៨** ៖ បំរាមមិនឲ្យនាយការពិន័យ ឬកាត់ប្រាក់ឈ្នួលរបស់កូនឈ្នួលដោយហេតុថាកូនឈ្នួលធ្វើខុសដោយឥតចេតនាក្លែងក្នុងវេលាធ្វើការនោះឡើយ ។

**មាត្រា ១១៥៩** ៖ អនីតិជន មិនអាចស៊ីឈ្នួលធ្វើការឥតឪពុកម្ដាយ ឬអាណាព្យាបាល ដែលក្មេងនោះត្រូវនៅក្នុងអំណាចតាមច្បាប់យល់ព្រមផងបានទេ ។

**មាត្រា ១១៦០** ៖ គេអាចជួល អនីតិជនអាយុដប់ប្រាំមួយឆ្នាំឲ្យធ្វើការបាន, តែឲ្យធ្វើការណាដែលមិនពិបាក ហើយល្មមនឹងកំលាំងវាផង ។

**មាត្រា ១១៦១** ៖ បើនាយការប្រើកូនឈ្នួលជាអនីតិជនអាយុដប់ប្រាំមួយឆ្នាំឲ្យធ្វើការណាដែលជាទីនាំឲ្យខូចសុខភាព, ខូចវ័យនៃក្មេងនោះ, ឪពុកម្ដាយ ឬជនដែលជំនួសឪពុកម្ដាយ និងអាជ្ញាធរសាធារណៈអាចបង្ខំឲ្យផ្ដាច់ ខ សន្យានោះបង់បានជាដរាបមិនចាំបាច់ឲ្យដំណឹងមុនឡើយ ។

**មាត្រា ១១៦២** ៖ អនីតិជន អាយុដប់ប្រាំមួយឆ្នាំ អាចផ្ដាច់កិច្ចសន្យាជួលការងារ ដែលវាបានចុះជាមួយគេដោយឥតហេតុបានដរាប ដោយមិនចាំបាច់ប្រាំមុនប្រាំបីថ្ងៃឡើយ ។

**មាត្រា ១១៦៣** ៖ ឪពុកម្ដាយ ឬជនដែលទទួលជួសឪពុកម្ដាយ, ថាបើបានទទួលប្រាក់ឈ្នួលមុនហើយ, ត្រូវបង្វិលឲ្យគេវិញ ។

បើអនីតិជនអាយុ ដប់ប្រាំមួយឆ្នាំ ត្រូវរកប្រាក់ដោយខ្លួនឯងដើម្បីបង្វិលឲ្យគេវិញហើយរកមិនបានទេ, ច្បាប់ថាមិនបើកឲ្យដាក់គុកបង្ខំដល់រូបកាយវាឡើយ ។

**មាត្រា ១១៦៤** ៖ អ្នកការអាចស៊ីឈ្នួល ធ្វើការដើម្បីដោះបំណុលដែលខ្លួនជំពាក់នាយការបាន ។ ក្នុងករណីនេះកិច្ចសន្យានោះត្រូវធ្វើនៅមុខមេឃុំជាលិខិតបញ្ជាក់, ទើបយកជាការបាន ។

**មាត្រា ១១៦៥** ៖ កូនបំណុលអាចជួលបានតែការងាររបស់ខ្លួនផ្ទាល់ខ្លួន ។

**មាត្រា ១១៦៦** ៖ កិច្ចសន្យាត្រូវដាក់ចំនួនប្រាក់ ឈ្នួលដែលព្រមយក, ដាក់ចំនួនប្រាក់ដើមដែលជំពាក់, ដាក់ប្រាក់ការ, ប្រសិនបើត្រូវយកត្រឹមតែអត្រា ៥% ក្នុងមួយឆ្នាំ ។

**មាត្រា ១១៦៧** ៖ ស៊ីឈ្នួលធ្វើការងារដើម្បីដោះបំណុលនេះនឹងជួលឲ្យហួសពីកំណត់មួយឆ្នាំមិនបាន ។

**មាត្រា ១១៦៨** ៖ ប្រាក់ដើម ត្រូវលែងមានការតាំងពីថ្ងៃដែលកូនបំណុលចូលបំរើម្ចាស់ប្រាក់ ។

**មាត្រា ១១៦៩** ៖ លុះដល់កំណត់សន្យាហើយបើកូនបំណុលកាត់ប្រាក់ជំពាក់នោះមិនទាន់អស់ទេ, កូនបំណុលអាចនឹងធ្វើកិច្ចសន្យាជាថ្មីទៀតបានតែកិច្ចសន្យានេះមិនត្រូវហួសពីមួយឆ្នាំឡើយ ។

**មាត្រា ១១៧០** ៖ កិច្ចសន្យាថ្មី នេះត្រូវធ្វើជាសំបុត្របញ្ជាក់ជាថ្មីទៀត ឬជាសេចក្ដីបន្ថែមលើសំបុត្រចាស់នោះនៅមុខមេឃុំទើបទុកជាត្រឹមត្រូវបាន ។

**មាត្រា ១១៧១** ៖ ក្នុងកិច្ចសន្យាថ្មីនោះត្រូវមានចុះចំនួនប្រាក់ដើម និងចុងការដែលបានកាត់ហើយ, ចំនួនប្រាក់ដែលនៅជំពាក់, បើមានសេចក្ដីកែប្រែយ៉ាងណាក៏ឲ្យដាក់ផង។

**មាត្រា ១១៧២** ៖ កូនបំណុលដែលស៊ីឈ្នួលដោះបំណុលនេះអាចលែងជួលការងារ, ហើយចេញពីម្ចាស់ប្រាក់បានតែត្រូវឲ្យប្រតិបត្តិតាមសេចក្ដីបញ្ញត្តិស្ដីពីឲ្យដំណឹងមុនប្រាំបីថ្ងៃនោះផង ។

**មាត្រា ១១៧៣** ៖ បើកូនបំណុល ផ្ដាច់កិច្ចសន្យាហើយជននេះត្រូវនៅជំពាក់ប្រាក់ដែលសល់អំពីកាត់ទៀត, ប្រាក់នេះត្រូវមានការតទៅទៀត ។

**មាត្រា ១១៧៤** ៖ បើកូនបំណុលផ្ដាច់កិច្ចសន្យាដោយមិនបានឲ្យដំណឹងដល់ម្ចាស់ប្រាក់ទេ, អ្នកនេះត្រូវទៅប្ដឹងមេឃុំឲ្យកត់ថ្ងៃខែ ក្នុងសំបុត្រដើម្បីនឹងកំណត់ថ្ងៃដែលត្រូវគិតការប្រាក់តទៅ ។

**មាត្រា ១១៧៥** ៖ ថាបើប្រាក់ឈ្នួលរបស់កូនឈ្នួលដោះប្រាក់ដើមរួចហើយ, កូនឈ្នួលត្រូវនៅជំពាក់ប្រាក់ការទៀតតែប្រាក់ការនេះមិនត្រូវលើកមកធ្វើជាប្រាក់ដើមឡើយ។

**មាត្រា ១១៧៦** ៖ បើកូនឈ្នួលមានគ្រោះថ្នាក់ក្នុងវេលាធ្វើការ ឬឱកាសធ្វើការ, គ្រោះថ្នាក់នោះត្រូវសម្រេចតាមមាត្រា ពី ៨២៨ ទៅ ៨៣៤ នៃក្រមនេះ ។

## ព្រះរាជក្រមលេខ ១២៣ ន.ស ចំថ្ងៃទី ២១ មីនា ១៩៤៤

**មាត្រា ទី ១** ៖ ការស៊ីឈ្នួលដើម្បីដោះបំណុលដូចដែលបានសំដែងហើយក្នុងមាត្រា ពី ១១៦៤ ដល់ ១១៧៥ នៃក្រមរដ្ឋប្បវេណីនេះត្រូវនៅក្រោមល័ក្ខខណ្ឌទាំងឡាយដូចតទៅ នេះ

**មាត្រា ២** ៖ ជនដែលមានអាយុលើសពីហាសិបឆ្នាំមិនអាចស៊ីឈ្នួលនៅបំរើគេដើម្បីដោះបំណុលគេបានឡើយ ។

**មាត្រា ៣** ៖ បំរាមជាដាច់ខាតគ្រប់បិតា នៃគ្រួសារទាំងអស់មិនឲ្យយកប្រពន្ធទី១ ឬទី២ ឬកូនដែលមិនទាន់បានអាយុដប់ប្រាំបីឆ្នាំទៅស៊ីឈ្នួលធ្វើការឲ្យគេឡើយ ។

**មាត្រា ៤** ៖ ក៏ប៉ុន្តែច្បាប់សន្តោសដល់ប្រពន្ធទី ១ និងទី២នៃកំដឹងឲ្យចូលស៊ីឈ្នួលដោះបំណុលដែលប្តីកំពុងតែដោះនោះបាន ។ ការស៊ីឈ្នួលនេះត្រូវធ្វើតាមល័ក្ខខណ្ឌដូចមានសំដែងហើយក្នុងច្បាប់ ។ កូនអនីតិជន នៃប្រពន្ធទាំងពីរដែលនៅបំរើម្ចាស់បំណុលជាមួយគ្នាត្រូវនៅក្នុងបន្ទុកនៃម្ចាស់បំណុល ។ ប៉ុន្តែអ្នកនេះមិនអាចបង្ខំកូនក្មេងទាំងនោះឲ្យធ្វើការអ្វីឲ្យខ្លួនបានឡើយ ។

**មាត្រា ៥** ៖ អ្នកស៊ីឈ្នួលបំរើគេដើម្បីដោះបំណុល, កាលណាបើបំរើបានគ្រប់ពីរឆ្នាំហើយ, មិនអាចធ្វើកិច្ចសន្យាថ្មីដោយរបៀបណា ឬដោយហេតុណាទៀតបានឡើយ ។

**មាត្រា ៦** ៖ តាំងពីថ្ងៃ ១ កក្កដា ១៩៤៤ នេះតទៅ ជនទាំងពីរភេទ, ដែលក្រជំពាក់បំណុលគេ គ្មានប្រាក់សងហើយស្ម័គ្រចិត្តស៊ីឈ្នួលម្ចាស់បំណុល, ត្រូវឲ្យ

កាត់ប្រាក់បំណុលក្នុងមួយខែប្រាំមួយរៀលចេញ, ប្រសិនបើជននោះស្ពៀកពាក់, ស៊ីចុក, លើអ្នកប្រើ, និងត្រូវឲ្យកាត់ក្នុងមួយខែដប់ប្រាំរៀល, ប្រសិនបើជននោះមិនស្ពៀកពាក់, ស៊ីចុកលើអ្នកប្រើទេ ។

**មាត្រា ៧** ៖ អ្នកស៊ីឈ្នួលនេះមានសេរីភាព នឹងឈប់ធ្វើការឲ្យម្ចាស់បំណុលថ្ងៃណាក៏បានឲ្យតែខ្លួនបានសងបំណុលដែលនៅសល់ដូចមានក្នុងសំបុត្របំណុលដែលខ្លួនបានចុះហត្ថលេខានោះ ។

កូនក្មេងដែលឪពុកម្ដាយយកទៅស៊ីឈ្នួលគេ, កាលណាបើបានអាយុដល់នីតិភាពហើយ,ក៏មានសេរីភាពដើរចេញពីអ្នកប្រើដូច្នេះដែរ ។ តែក្នុងករណីនេះ, ម្ចាស់បំណុល មានសិទ្ធិនឹងប្ដឹងពីឪពុកម្ដាយនៃក្មេងនោះឲ្យសងប្រាក់ជំពាក់នោះបាន ។

**មាត្រា ៨** ៖ ប្រាក់ដែលថែមទាំងបំណុលនោះនឹងទុកជាត្រឹមត្រូវបានលុះណាតែការខ្ចីនោះបានចុះសេចក្ដីសព្វគ្រប់លើខ្នងកិច្ចសន្យា ហើយមានហត្ថលេខាមេឃុំ និងភាគីទាំងសងខាងចុះក្នុងសំបុត្រនោះផង ។

**មាត្រា ៩** ៖ ការធ្វើកិច្ចសន្យាថ្មីដូចដែលមានសំដែងក្នុងមាត្រា ១១៧៦ នៃក្រមរដ្ឋប្បវេណីនេះ នឹងទុកជាត្រឹមត្រូវបានលុះណាតែសេចក្ដីនោះបានទទួលសទិសានុញ្ញាតិពីសាលាដំបូងក្នុងខែត្រខាងលំនៅនៃម្ចាស់បំណុលក្នុងរវាងពីរខែ ។

**មាត្រា ១០** ៖ កិច្ចសន្យា, ដែលប្ដេជ្ញាថានឹងរលត់បំណុលណាមួយចោលនឹងទុកជាត្រឹមត្រូវបានលុះណាតែអ្នកប្រើ, ក្រោយដែលបានសេចក្ដីបញ្ជាក់នឹងបានស

ទិសានុញ្ញាតិរួចហើយ, ហើយបង់ពន្ធមួយរៀលទៀតដើម្បីជាប្រយោជន៍ដល់ថវិការខែត្រផង ។

**មាត្រា ១១** ៖ អំពើទាំងពួងដែលល្មើសនឹងបទបញ្ញត្តិទាំងឡាយនៃព្រះរាជក្រមនេះនឹងត្រូវផ្តន្ទាទោសជាមជ្ឈិមថ្នាក់ទីពីរ ។

**មាត្រា ១២** ៖ ព្រះរាជប្រកាសចុះថ្ងៃ ២៩ ធ្នូ ១៨៩៧ និង ១៩ សីហា ១៩៣៦ ត្រូវនិរាករហើយព្រមទាំងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រមនេះក៏ត្រូវនិរាករដែរ។

## ផ្នែកទី ៣

## អំពីការជួលទុន(ចងការ)

**មាត្រា ១១៧៧** ៖ ដែលហៅថា ចងការ នោះគឺជាកិច្ចសន្យាដែលជនម្នាក់ប្រគល់ប្រាក់មានចំនួនឲ្យទៅជនម្នាក់ទៀត ដែលមានភារៈត្រូវសងវិញមួយអន្លើដោយប្រាក់ការតាមសមាត្រនៃរយៈកាលនៃក្នុងកិច្ចសន្យា ។

**មាត្រា ១១៧៨ ៖** អ្នកចងការគឺជាអ្នកឲ្យប្រាក់, អ្នកខ្ចីគឺជាអ្នកទទួលប្រាក់ ។

**មាត្រា ១១៧៩** ៖ ដែលហៅថា ប្រាក់ដើម ឬទុនគឺប្រាក់ដែលគេចងការ ។ ការប្រាក់គឺជាឈ្នួលនៃប្រាក់ដើម ។ ការប្រាក់ត្រូវកំណត់តាមលេខ ឬ តាមអត្រានៃប្រាក់ដើម ។ ការប្រាក់ត្រូវកំណត់តាមលេខ ឬ តាមអត្រាដែលបានព្រមព្រៀងគ្នា ។

**មាត្រា ១១៨០** ៖ នីតិជន, ដែលមានសេរីភាពនឹងចាត់ចែងទ្រព្យរបស់ខ្លួនបាន, ទើបអាចឲ្យគេខ្ចី ឬ ខ្ចីគេបានត្រឹមត្រូវតាមច្បាប់ ។

**មាត្រា ១១៨១** ៖ កិច្ចសន្យានេះត្រូវប្ដេជ្ញាគ្នាជាលាយលក្ខណ៍អក្សរ ។ ក្នុងលិខិតនោះត្រូវឲ្យដាក់ត្រកូល, ឈ្មោះ, លំនៅនៃភាគីទាំងពីរខាង, ចំនួនប្រាក់ដើមដែលខ្ចី, អត្រានៃការប្រាក់ដែលព្រមព្រៀងគ្នា, ថ្ងៃ ខែ ឆ្នាំដែលចងការនិងថ្ងៃកំណត់ដែលត្រូវសង ។ កូនបំណុលត្រូវចុះហត្ថលេខាក្នុងសំបុត្រនោះ ។

**មាត្រា ១១៨២** ៖ បើមិនចេះអក្សរទេកូនបំណុលត្រូវចុះផ្ដិតមេដៃនៅមុខសាក្សីពីរនាក់ដែលមិនមែនជាញាតិ និងភាគីទាំងសងខាងដូចមានលក្ខខណ្ឌក្នុងមាត្រា ៩៩១ និង ៩៩២ ស្រាប់ ។

**មាត្រា ១១៨៣** ៖ បើកិច្ចសន្យានោះភ្លេចដាក់ថ្ងៃកំណត់ដែលត្រូវសង ឬគ្មានដាក់ អត្រានៃការប្រាក់ទេភាគីទាំងសងខាងត្រូវពិរុទ្ធថាខ្ចីគ្នាមួយឆ្នាំឥតការរហូតដល់ថ្ងៃកំណត់នោះ ។

**មាត្រា ១១៨៤** ៖ ការប្រាក់ត្រូវចេញឲ្យម្ចាស់ប្រាក់នៅថ្ងៃដែលមានសន្មតក្នុងកិច្ចសន្យាលើកតែមានបញ្ញត្តិផ្សេងពីនេះ ។

**មាត្រា ១១៨៥** ៖ ប្រាក់ដែលបានឲ្យខ្ចីថែមលើប្រាក់ដើមទៀតក្ដី, ប្រាក់ដែលសងខ្លះក្ដី, ប្រាក់ការដែលគេទារក្នុងវេលាជំពាក់ហើយបានឲ្យគេក្ដី, ទាំងអស់នេះត្រូវកត់ត្រានៅលើខ្នងសំបុត្រហើយត្រូវមានហត្ថលេខានៃម្ចាស់ប្រាក់ ឬហត្ថលេខានៃកូនបំណុលតាមការណ៍ បើភាគីមិនចេះអក្សរទេភាគីត្រូវធ្វើតាមសេចក្ដីបញ្ញត្តិដែលបានសំដែង ហើយក្នុងមាត្រា ១១៨២ ខាងលើនេះ ។

**មាត្រា ១១៨៦** ៖ បើម្ចាស់ប្រាក់បានប្រគល់សំបុត្រជំពាក់ឱ្យកូនបំណុលហើយ, បំណុលនោះត្រូវទុកជាបានសងហើយ ។

**មាត្រា ១១៨៧** ៖ (ក្រម, ១៣០ ចរ ៧.៦.៦៣) គូភាគីមិនអាចព្រមព្រៀងគ្នាយកការឱ្យហួសពី ៨ %ក្នុងមួយឆ្នាំឡើយ ។

**មាត្រា ១១៨៨** ៖ បើម្ចាស់ប្រាក់យកការប្រាក់ហួសពីអត្រាច្បាប់នេះ, ម្ចាស់នោះត្រូវមានទោសតាមបញ្ញត្តិមាត្រា ៤១៣ នៃក្រមព្រហ្មទណ្ឌ ។

ឯការប្រាក់ដែលម្ចាស់ប្រាក់ យកលើសរហូតមកក្នុងពេលដែលជំពាក់ត្រូវកាច់ដាក់ជាសំណងប្រាក់ដើម ។

បើបំណុលនោះសងទាំងដើមទាំងការអស់ហើយតែនៅសល់ប្រាក់ ដែលយកលើសទៀត, ម្ចាស់ប្រាក់នឹងត្រូវទណ្ឌកម្មឱ្យបង្វិលប្រាក់ដែលយកលើសហួសច្បាប់ឱ្យទៅគេវិញ, ហើយគិតការ ៨ %ក្នុងមួយឆ្នាំតាំងពីថ្ងៃដែលយកពីគេនោះទៀតផង ។

**មាត្រា១១៨៩** ៖ ការប្ដឹងឱ្យទារប្រាក់មុនកំណត់សន្យាមិនបាន ។ ប៉ុន្តែបើអ្នកជំពាក់ស្លាប់, ប្រាក់ដែលជំពាក់ត្រូវឱ្យទារមួយរំពេចបានហើយទាយាទត្រូវតែកាត់យកក្នុងមត៌ក មកសងមុនសិនរួចសឹមចែកមត៌កក្រោយ ។

**មាត្រា ១១៩០** ៖ បុព្វញាតិ និងបច្ឆាញាតិ បងប្អូនប្រុសស្រីខ្ចីប្រាក់កាសគ្នាទៅមកមិនត្រូវមានការឡើយ, ម្ចាស់ប្រាក់ត្រូវបានតែប្រាក់ដើមវិញប៉ុណ្ណោះ ។

**មាត្រា ១១៩១** ៖ បុព្វញាតិ និងបច្ឆាញាតិដែលជំពាក់ប្រាក់គ្នា និងប្ដឹងផ្ដល់ដល់តុលាការឱ្យទារប្រាក់ពីគ្នាពុំបានឡើយ ។

**មាត្រា ១១៩២** ៖ ការខ្ចីបុលស្រូវអង្ករព្រមទាំងសារពើវត្ថុដទៃទៀត ដែលជាគ្រឿងស្រវឹងបរិភោគនិងឧបភោគក៏ត្រូវឋិតនៅក្រោមបទបញ្ញត្តិស្ដីពីការចងការប្រាក់ដែរ ។

## ចំពូកទី ៥
## អំពីការឲ្យខ្ចី

**មាត្រា ១១៩៣** ៖ ដែលហៅថា ការឲ្យខ្ចីនោះគឺជាកិច្ចសន្យាដែលជនម្នាក់ប្រគល់វត្ថុណាមួយឲ្យទៅជនម្នាក់ទៀតប្រើប្រាស់តាមសេចក្ដីដែលព្រមព្រៀងគ្នាឬតាមនិស្ស័យនៃវត្ថុនោះ ។

**មាត្រា ១១៩៤** ៖ អ្នកឲ្យខ្ចីគឺម្ចាស់វត្ថុដែលប្រគល់វត្ថុនោះឲ្យទៅគេ, អ្នកខ្ចីគឺជនដែលទទួលវត្ថុនោះពីគេ ។

**មាត្រា ១១៩៥** ៖ ឲ្យខ្ចីគឺឥតយកការទេ ។

**មាត្រា ១១៩៦** ៖ ការលើកវត្ថុអ្នកដទៃឲ្យទៅគេខ្ចីមិនមានអនុភាពអ្វីមកលើកម្មសិទ្ធិករនៃវត្ថុ, លើសិទ្ធិវន្ត និងលើម្ចាស់បំណុលនៃកម្មសិទ្ធិករឡើយ ។

**មាត្រា ១១៩៧** ៖ បើឲ្យខ្ចីវត្ថុដែលមិនវិនាសដោយសារប្រើហៅថា ការឲ្យខ្ចីប្រើ, បើឲ្យខ្ចីវត្ថុដែលអស់ដោយសារប្រើហៅថា ឲ្យខ្ចីវិភោគ ។

### ផ្នែកទី ១
### អំពីការឲ្យខ្ចីប្រើ

**មាត្រា ១១៩៨** ៖ អ្នកដែលឲ្យវត្ថុណាមួយទៅគេខ្ចីប្រើនៅតែជាកម្មសិទ្ធិករនៃវត្ថុនោះដដែល ។

**មាត្រា ១១៩៩** ៖ អ្នកខ្ចីមិនអាចលក់ដូរផ្ទេរសិទ្ធិឲ្យវត្ថុខ្ចីទៅតតិយជនប្រើដោយគ្មានសេចក្តីព្រមព្រៀងពីអ្នកឲ្យខ្ចីបានឡើយ ។

**មាត្រា ១២០០** ៖ អ្នកខ្ចីត្រូវប្រើប្រាស់នូវវត្ថុនោះឲ្យល្អ, ថែទាំបីដូចខ្លួនជាម្ចាស់វត្ថុគឺប្រើឲ្យត្រឹមត្រូវតាមនិស្ស័យរបស់វា ។

**មាត្រា ១២០១** ៖ អ្នកខ្ចី ត្រូវទទួលដាច់បង់ សោហ៊ុយក្នុងការថែទាំវត្ថុនោះលើខ្លួន ។

**មាត្រា ១២០២** ៖ បើវត្ថុនោះបែកបាក់, ដាច់ដាច, ខូចបាត់ដោយករណីប្រធានស័ក្តិ, អ្នកខ្ចីមិនត្រូវទទួលសងឡើយ, តែបើបែកបាក់, ដាច់ដោច, ខូត, បាត់, មកពីកំហុសខ្លួន, ខ្លួនត្រូវទទួលសងគេ ។ ឯខូចដោយប្រើការជាធម្មតាក៏មិនត្រូវសងដែរ ។

**មាត្រា ១២០៣** ៖ អ្នកខ្ចីត្រូវបង្វិលវត្ថុឲ្យគេវិញនៅវេលាដែលដល់សន្មត, បើកិច្ចសន្យានេះគ្មានសន្មតគ្នាយ៉ាងណាទេ, អ្នកឲ្យខ្ចីអាចទារយកវត្ថុខ្លួនវិញក្នុងវេលាណាក៏បាន ។

**មាត្រា ១២០៤** ៖ បើអ្នកខ្ចីយកវត្ថុទៅប្រើការក្រៅពីនិស្ស័យរបស់វា, អ្នខ្ចីអាចទារវត្ថុខ្លួនមួយរំពេចវិញបាន, ថ្វីបើមិនទាន់ដល់រយៈវេលាដែលសន្មតគ្នា ។

**មាត្រា ១២០៥** ៖ បើដល់វេលាស្មតហើយអ្នកខ្ចីចង់ទុករបស់នោះតទៅទៀត, អ្នកឲ្យខ្ចីអាចទារឈ្នួលតទៅបាន,បើដូច្នេះការខ្ចីនេះប្រែទៅជាការជួលវិញ ។

## ផ្នែកទី ២
## អំពីការឲ្យខ្ចី បរិភោគវត្ថុ

**មាត្រា ១២០៦** ៖ នាកាលវត្ថុដែលខ្ចីជារបស់ដែលគេបរិភោគបាន, អ្នកដែលខ្ចីរបស់គេត្រូវឡើងជាម្ចាស់នៃវត្ថុខ្ចីនោះ, អ្នកខ្ចីអាចប្រើប្រាស់នូវវត្ថុនោះតាមទំនើងចិត្តបាន, អ្នកនោះត្រូវរកវត្ថុ ដែលមានផុនដូចគ្នាមានគុណភាពនិងមានចំនួនស្មើគ្នាសងគេវិញតែប៉ុណ្ណោះ ។

**មាត្រា ១២០៧** ៖ អ្នកឲ្យខ្ចីនឹងទារយកវត្ថុនោះវិញមុនថ្ងៃសន្មតគ្នាពុំបានឡើយ ។

**មាត្រា ១២០៨** ៖ បើភាគីមិនបានកំណត់កាលត្រូវសងទេ, តុលាការអាចកំណត់រយៈវេលាឲ្យរកវត្ថុសងគេបាន ។

**មាត្រា ១២០៩** ៖ នាកាលអ្នកខ្ចីមិនបានសងវត្ថុទៅគេវិញនៅទីបំផុតកាលដែលសន្មតទេ, អ្នកខ្ចីត្រូវចេញការឲ្យគេតាមច្បាប់គិតតាំងពីថ្ងៃដែលម្ចាស់បំណុលបានទារ ឬ តាំងពីថ្ងៃដែលម្ចាស់បំណុលបានប្ដឹងដល់តុលាការ, បើដូច្នេះការខ្ចីនេះប្រែទៅជាជួលប្រាក់ ឬវត្ថុដែលគេបរិភោគទៅវិញ ។

**មាត្រា ១២១០** ៖ បើវត្ថុដែលគេឲ្យខ្ចីនោះប្រែថ្លៃតាំងពីថ្ងៃដែលចុះកិច្ចសន្យាមក, អ្នកខ្ចីត្រូវរករបស់គ្រប់ចំនួនដែលខ្លួនបានខ្ចីគេមកសងទៅគេវិញ ។

**មាត្រា ១២១១** ៖ បើអ្នកខ្ចីរកវត្ថុដែលមានគុណភាពដូចគ្នាគ្រប់ចំនួនឲ្យគេមិនបានទេ, អ្នកខ្ចីត្រូវចេញថ្លៃឲ្យគេតាមតម្លៃដើងកំពស់ក្នុងថ្ងៃដែលដល់សន្មតសង ។

# ចំពូកទី ៦
# អំពីកិច្ចសន្យានៃការដឹកនាំ

**មាត្រា ១២១២** ៖ ដែលហៅថា កិច្ចសន្យានៃការដឹកនាំ នោះគឺជាកិច្ចសន្យាដែលជនម្នាក់សន្យាថានឹងនាំជនម្នាក់ទៀត ឬ ទំនិញទាំងឡាយជារបស់ជននោះពីកន្លែងមួយទៅកន្លែងមួយទៀតដោយយកឈ្នួលតាមការព្រមព្រៀង ។

**មាត្រា ១២១៣** ៖ គេអាចដឹកនាំដោយយាន ឯណាមួយក៏បាន ។

**មាត្រា ១២១៤** ៖ អ្នកដឹកនាំ ត្រូវទទួលខុសត្រូវអំពីការបាត់ ឬ ខូចរបស់ដែលគេប្រគល់ឲ្យខ្លួនដឹកនាំ, ត្រូវទទួលខុសត្រូវអំពីគ្រោះថ្នាក់ដែលបណ្តាលឡើងដល់អ្នកដំណើរក្នុងវេលាដែលខ្លួនដឹកនាំ, លើកមួយតែក្នុងករណីប្រធានស័ក្តិ, ឬគ្រោះថ្នាក់នោះកើតមកពីសេចក្តីប្រហែសឥតគំនិត ឬ ពីមិនប៊ិនប្រសប់នៃអ្នកដំណើរខ្លួនឯង ។

**មាត្រា ១២១៥** ៖ បើទំនិញដែលគេប្រគល់ឲ្យដឹកនាំនោះអន្តរាយដោយចោរកម្មអ្នកទទួលដឹកនាំត្រូវទទួលសងគេដែរ ។

**មាត្រា ១២១៦** ៖ បើការខូចខាតនោះមិនបណ្តាលមកពីវិការៈនៃវត្ថុនោះទេ ឬ ពីករណីនៃប្រធានស័ក្តិទេ, អ្នកទទួលដឹកនាំត្រូវសងគេ, ត្រូវទទួលខុសត្រូវទាំងអស់ ។ ការខូចខាតដោយហេតុទាំងឡាយមានខូចព្រោះយឺតយូរដោយឥតចូលក្នុងករណីនៃប្រធានស័ក្តិជាដើមទេ , អ្នកដឹកនាំត្រូទទួលសងទាំងអស់ដែរ ។

**មាត្រា ១២១៧** ៖ ការប្ដឹងផ្ដល់ឲ្យអ្នកដឹកនាំទទួលខុសត្រូវនោះត្រូវប្ដឹងក្នុងឆ្នាំនោះចាប់ពីដើមអំពីថ្ងៃដែលម្ចាស់របស់បានដឹងថាបាត់ ឬ ខូច, ឬ ចាប់ផ្ដើមអំពីថ្ងៃដែលអ្នកដំណើរបានទទួលរងគ្រោះ ។

**មាត្រា ១២១៨** ៖ បើនាវាពីរដើរតាមផ្លូវមួយបណ្ដោយគ្នាមុនក្រោយហើយប៉ះទង្គិចទង្គុកគ្នា, ម្ចាស់នាវាក្រោយត្រូវទទួលខុសត្រូវអំពីសេចក្ដីខូចខាតដែលបណ្ដាលដល់នាវាមុខ, ដល់បន្ទុកនៃនាវាមុខ, លើកមួយតែបើម្ចាស់នាវាក្រោយមានបន្ទាល់ថាការប៉ះគ្នានេះឥតមានកំហុសពីខ្លួនទេ, ដូច្នេះទើបរួចខ្លួនបាន ។

**មាត្រា ១២១៩** ៖ ប្រសិនបើនាវាមួយចងស្ងៀមនៅនឹងកំពង់, ទូកមួយទៀតឡើង ឬចុះហើយប៉ះគ្នា, ទូកដែលដើរនោះត្រូវទទួលខុសត្រូវអំពីសេចក្ដីអន្តរាយនោះ ។

**មាត្រា ១២២០** ៖ ប្រសិនបើនាវាពីរដើរទន្ទឹមគ្នាហើយប៉ះគ្នា បើមិនឃើញថាខុសពីនរណាៗទេ មិនត្រូវឲ្យម្នាក់ៗទទួលខុសត្រូវឡើយ ។

**មាត្រា ១២២១** ៖ បើទូកមួយចុះតាមខ្សែទឹកព្រមានដល់ទូកឡើងថាខ្លួននឹងចូលចត, នោះទូកឡើងត្រូវចៀសឲ្យទូកចុះងាយនឹងរៀបចំចត ។ ប្រសិនបើទូកឡើងដែលគេបានប្រាប់ហើយមិនបានចៀសហើយប៉ះគ្នាបណ្ដាលឲ្យមានអន្តរាយ, ខូចខាតដល់ទូកចុះ ឬ ដល់បន្ទុកក្នុងទូកចុះ, ទូកឡើងត្រូវទទួលខុសត្រូវ ។ ថាបើទូកឡើងលិច ឬ ខូចដោយប៉ះពាល់នឹងទូកចុះ, ទូកឡើងមិនត្រូវបានសំណងចិត្តឡើង ។

**មាត្រា ១២២២** ៖ បើទូកឡើង បានចៀសហើយ ហើយនៅតែប៉ះគ្នាទៀត, នោះទូកឡើងត្រូវបានសំណងចិត្តវិញ ។

**មាត្រា ១២២៣** ៖ បើទូកពីរចង់ចូលចតនៅកំពង់តែមិនបានប្រាប់គ្នាឲ្យដឹងជាមុន ហើយប៉ះគ្នា,បណ្ដាទូកទាំងពីរនោះ,ទូកណាមកដោយមិនត្រូវបានប្រាក់សំណងចិត្តឡើយ។

**មាត្រា ១២២៤** ៖ ប្រសិបើទូកមួយគ្មានបន្ទុក, ទូកមួយទៀតផ្ទុក, ប៉ះទង្គិចគ្នាបណ្ដាលឲ្យបែកបាក់, អន្តរាយទូកមានបន្ទុក ឬ អន្តរាយឥវ៉ាន់ដែលផ្ទុក, នោះទូកទទេត្រូវទទួលខុសត្រូវវៀរ តែបើទូកទទេនោះមានបន្ទាល់ថាការប៉ះទង្គិចគ្នានេះមិនបណ្ដាលមកពីកំហុសខ្លួនឡើយ, ដូច្នេះទើបរួចខ្លួនបាន ។

**មាត្រា ១២២៥** ៖ តាមធម្មតា, ទូកឡើងត្រូវឯបមាត់ទឹកហើយទូកចុះត្រូវដើរកណ្ដាលខ្សែទឹក ។

**មាត្រា ១២២៦** ៖ បើមានទង្កុកទង្គិចគ្នានៅតាមបណ្ដោយមាត់ទឹកហើយមានអន្តរាយ, ខូចខាត, ទូកចុះត្រូវទទួលខុសត្រូវជាធម្មតា ។ បើទូកចុះនោះលិច ឬ បែកបាក់, ខូចដោយប៉ះនឹងទូកឡើងទូកចុះត្រូវទុកជាអភ័ព្វរបស់ខ្លួនឥតត្រូវបានសំណងចិត្តឡើយ ។

**មាត្រា ១២២៧** ៖ បើមានប៉ះទង្គិចគ្នាត្រង់ខ្សែកណ្ដាល ទឹកវិញទូកឡើងត្រូវទទួលខុសត្រូវពីសេចក្ដីខូចខាតដោយន័យដូចមានពោលហើយ ។

**មាត្រា ១២២៨** ៖ ប្រសិនបើមានមនុស្សម្នាក់ឬច្រើននាក់ក្នុងនាវាណាមួយស្លាប់ ឬ របួស, ម្ចាស់ទូកស្លាប់ ឬ របួស, ម្ចាស់ទូកអ្នកបណ្តាលឲ្យមានគ្រោះថ្នាក់នេះត្រូវទទួលខុសត្រូវ ។

**មាត្រា ១២២៩** ៖ បើមានមនុស្សម្នាក់ ឬ ច្រើននាក់ក្នុងនាវាណាមួយស្លាប់ ឬ របួស, ម្ចាស់ទូកអ្នកបណ្តាលឲ្យមានគ្រោះថ្នាក់នេះត្រូវទទួលខុសត្រូវ ។

**មាត្រា ១២៣០** ៖ បើខុសលើនាវាទាំងពីរ, ម្ចាស់នាវាទាំងពីរត្រូវទទួលខុសត្រូវអំពីគ្រោះថ្នាក់ដែលបណ្តាលដល់មនុស្សចំណុះនាវាខ្លួនរៀងខ្លួន ។

## ចំពូកទី ៧
## អំពីកិច្ចសន្យានៃសហគ្រាស

**មាត្រា ១២៣១** ៖ ដែលហៅថា កិច្ចសន្យានៃសហគ្រាស នោះគឺជាកិច្ចសន្យា ដែលជនម្នាក់ទទួលធ្វើការឯណាមួយឲ្យជនម្នាក់ទៀតដោយយកថ្លៃឲ្យសមាមាត្រនឹងទំហំនៃការងារ ។

**មាត្រា ១២៣២** ៖ បើថ្លៃមិនបានកំណត់ក្នុងសេចក្តីប្តេជ្ញាគ្នាទេ, តុលាការត្រូវវិនិច្ឆ័យតម្លៃដោយយកតាមថ្លៃដែលគេធ្លាប់ឲ្យក្នុងស្រុក ។

**មាត្រា ១២៣៤** ៖ បើការងារ ដែលបានធ្វើរួចហើយនោះមិនត្រឹមត្រូវតាមកិច្ចសន្យាទេ, ម្ចាស់ការមិនព្រមទទួលក៏បាន, ឲ្យកែការងារនោះឲ្យត្រូវតាមកិច្ចសន្យាក៏បាន, ព្រមទទួលយកការងារនោះទាំងយ៉ាងនោះហើយបន្ថយថ្លៃចុះមកក៏បាន ។

**មាត្រា ១២៣៥** ៖ បើកិច្ចសន្យា បានកំណត់ថាឲ្យធ្វើការនោះឲ្យហើយក្នុងពេលណាមួយហើយការងារនោះធ្វើមិនហើយតាមពេលដែលសន្យាគ្នា, អ្នកបញ្ជាឲ្យធ្វើអាចនឹងទំលាយកិច្ចសន្យានោះបាន ហើយនឹងបានជម្ងឺចិត្តព្រោះអ្នកទទួលការធ្វើឲ្យមានព្យសនកម្មដោយហេតុនោះផងក៏បាន ។

**មាត្រា ១២៣៦** ៖ ប៉ុន្តែបើការយឺតយូរនោះបណ្តាលមកពីករណីប្រធានស័ក្តិ អ្នកបញ្ជាឲ្យធ្វើមិនត្រូវបានជម្ងឺចិត្តឡើយ ។

**មាត្រា ១២៣៧** ៖ ពេលវេលាដែលត្រូវធ្វើការឲ្យហើយ ហើយប្រគល់ឲ្យម្ចាស់របស់នោះ បើទុកជាមិនមានកំណត់ជាប្រាកដយ៉ាងណាក្នុងកិច្ចសន្យាក្តី, តុលាការអាចនឹងវិនិច្ឆ័យយកតាមមុខការ, តាមប្រភេទនិងតាមគោលបំណងនៃការដែលគេជួលធ្វើនោះបាន។

**មាត្រា ១២៣៨** ៖ បើអ្នកបញ្ជាឲ្យធ្វើសន្យាថានឹងបើកប្រាក់ឲ្យមុនខ្លះ ឬទទួលផ្តល់វត្ថុធាតុដើមខ្លះឲ្យធ្វើការនោះហើយមិនបានបើកប្រាក់ឲ្យ, មិនបានផ្តល់វត្ថុធាតុដើមឲ្យទាន់ពេលវេលាទេ, អ្នកបញ្ជានោះមិនអាចអាចសុំផ្តាច់កិច្ចសន្យាដោយអាងហេតុយឺតយូរនោះបានទេ ។

**មាត្រា ១២៣៩** ៖ អ្នកបញ្ជាឲ្យធ្វើអាចបញ្ឈប់ការដែលខ្លួនជួលឲ្យធ្វើនោះមុនវេលា ដែលគេធ្វើហើយជាស្ថាពរបានជាដរាប, តែត្រូវឲ្យគិតថ្លៃការដែលបានធ្វើនោះ, ឲ្យគិតចំណាយនិងឲ្យគិតចំណេញដែលគេខានបាននោះឲ្យគេផង ។

**មាត្រា ១២៤០** ៖ ប្រសិនបើអ្នកបញ្ជាឲ្យធ្វើ បានបើកប្រាក់ឲ្យមុនខ្លះ, បានផ្តល់វត្ថុធាតុដើមឲ្យ, ហើយបើការនោះអន្តរាយមុនព្រោះអ្នកធ្វើ អ្នកបញ្ជាឲ្យធ្វើ

ត្រូវបានជម្ងឺចិត្តឲ្យស្មើនឹងការជួសជុលនៃព្យសនកម្ម ដែលបណ្ដាលមកពីការបាត់វត្ថុ ហើយនិងឲ្យសងប្រាក់ចំណាយដែលខ្លួនបានចាយនោះវិញ ។

តែបើអន្តរាយនោះបណ្ដាលមកពីករណីប្រធានស័ក្តិ, គូភាគីទាំងសងខាងត្រូវទទួលខូចខាតរៀងខ្លួនដោយគ្មាននរណាប្ដឹងផ្ដល់ពីនរណាបានឡើយ ។

**មាត្រា ១២៤១** ៖ អ្នកទទួលការត្រូវទទួលខុសត្រូវរបស់មនុស្សដែលខ្លួនយកមកប្រើក្នុងការនោះ ។

**មាត្រា១២៤២** ៖ នាកាលបើការនោះធ្វើរួចហើយ, អ្នកទទួលធ្វើអាចទារថ្លៃក្នុងវេលាប្រគល់ការបាន ។

**មាត្រា ១២៤៣** ៖ បើអ្នកបញ្ជាឲ្យធ្វើបានឲ្យថ្លៃហើយ, អ្នកបញ្ជានោះត្រូវទុកជាព្រមទទួលការនោះហើយ ។

**មាត្រា ១២៤៤** ៖ (ក្រម. ១៤០ បរ ៣១.៧.៦៣) ១. កាលបើក្រោយពីបានប្រគល់ការរួមក, គុណវិបត្តិ ឬ វិការៈដ៏កំបាំងណាមួយបានផ្ទុះឡើង, មកពីមានកំហុសក្នុងពេលដែលធ្វើការងារនោះ, កិច្ចសន្យានោះត្រូវរំលាយចោល, ថ្លៃត្រូវបង្វិលឲ្យមកគេវិញខ្លះ ឬ ក៏ការរួនោះត្រូវជួសជុលដោយបង់ខាតលើអ្នកទទួលខុសត្រូវ ។ អ្នកដែលមានសិទ្ធិប្ដឹងសុំឲ្យទទួលក្នុងវេលាបីឆ្នាំ រាប់ពីថ្ងៃដែលបានព្រមទទួលការរួនោះមក ។

២. ប្រសិនបើការនោះគឺជាសំណង់គ្រឹះស្ថានណាមួយ, បទបញ្ញត្តិនៃវគ្គខាងលើនេះត្រូវទទួលយកទៅអនុវត្តលើនិម្មាបនិក ឬលើសហគ្រិនដែលមានកំហុសក្នុងការងាររបុិចរបុីបណ្ដាលឲ្យមានគុណវិបត្តិ ឬវិការៈដ៏កំបាំងនោះ ។ ដែលហៅថា

ការងាររបេ៉ចរប៉ឹសនោះគឺការងារដែលត្រូវបង្ហើយចុងដៃ និងកិច្ចការៀបចំផ្សេងៗ ដែលជាការងារឬកិច្ចការ, បើទុកណាជាធ្វើមិនល្អទៅ, ក៏មិននាំឲ្យខូចដល់ភាពមាំមួននៃគ្រឹះស្ថាននោះដែរ ។

អ្នកដែលប្ដឹងសុំឲ្យគេទទួលខុសត្រូវតាម ខ សន្យាកិច្ចសន្យាអាចប្ដឹងបានតែក្នុងករណីដែលវិការនោះលេចឡើងក្នុងសម័យដែលគេរ៉ាប់ទទួលខុសត្រូវដូចមាន ខ បេ្តជ្ញាក្នុងកិច្ចសន្យាតែប៉ុណ្ណោះ

បើគ្មានរ៉ាបទទួលខុសត្រូវក្នុងកិច្ចសន្យាទេ, អ្នកនោះអាចប្ដឹងបានក្នុងវេលាបី ឆ្នាំរាប់ពីថ្ងៃដែលទទួលមក ។ ក្នុងកថាខ័ណ្ឌនេះ និងកថាខ័ណ្ឌតទៅ, ពាក្យថា “ទទួល” នេះមានន័យថា “ទទួលបណ្ដោះអាសន្ន ឬ ទទួលកាន់កាប់អចលវត្ថុនោះមួយសំនើសិន” ។

៣. ចំណែកឯនិម្មាបនិក និងសហាគ្រិនវិញ, អ្នកទាំងពីរនេះត្រូវរួបរួមគ្នារ៉ាប់ទទួលខុសត្រូវ, ក្នុងវេលាដប់ឆ្នាំរាប់ពីថ្ងៃដែលព្រមទទួលការ្យនោះមក, អំពីភាពមាំមួននៃគ្រិះស្ថានទាំងមូល ឬ ភាគខ្លះៗអ្នកទាំងពីនេះត្រូវពិរុទ្ធ ថាជាអ្នកទទួលខុសត្រូវអំពើរលំ, អន្តរាយនៃគ្រឹះស្ថានទាំងមូល ឬ ភាគខ្លះ និងអំពីវិការៈនៃព្រះធរណីក្នុងវេលាដប់ឆ្នាំដែរ។

តុលាការ ត្រូវតែបញ្ចូលអ្នកទាំងពីរនោះមកជាចុងចម្លើយដោយចិត្តឯងឲ្យមករួបរួមគ្នាការពារចំពោះបណ្ដឹង ដែលប្ដឹងសុំឲ្យអ្នកទាំងពីរនាក់នោះទទួលខុសត្រូវអំពីរឿងដូចដែលមានសំដែងក្នុងវគ្គទី៣នៃមាត្រានេះ ។

ភាគនៃកំហុស ដែលត្រូវចែកទៅឱ្យម្នាក់ៗបានចែកគ្នាផ្ទាល់ខ្លួនរៀងខ្លួនក្នុងគំរោងការនោះរួចហើយក្នុងការដែលបានធ្វើគ្រឹះស្ថាននោះ ។

៤. អញ្ញត្រកម្ម ដែលចេញមកពីការអស់រយៈវេលាប្ដឹងដូចដែលមានសំដែងក្នុងមាត្រានេះ ត្រូវតែភាគីលើកមកតវ៉ាឱ្យជាក់ស្ដែងដោយខ្លួនឯងនៅមុខចៅក្រមជាន់សាលាដំបូង,បើមិនលើកមកតវ៉ាទេ, ភាគីនោះត្រូវពិរុទ្ធថាខ្លួនបោះបង់មធ្យោបាយនេះចោលហើយ ។ ចៅក្រមសាលាឧទ្ធរណ៍និងសាលាវិនិច្ឆ័យមិនអាចលើកអញ្ញត្រកម្មនោះពីចិត្តឯងមកតវ៉ាជួសភាគីបានទេ ។

**មាត្រា ១២៤៥** ៖ បើអ្នកទទួលការស្លាប់, កិច្ចសន្យានោះត្រូវរលាយ ។

## ចំពូកទី ៨
## អំពីការផ្ញើ

**មាត្រា ១២៤៦** ៖ ដែលហៅថា ការផ្ញើ នោះគឺជាកិច្ចសន្យាដែលជនម្នាក់ផ្ញើចលវត្ថុណាមួយនឹងជនម្នាក់ទៀតឱ្យរក្សាទុកឥតឈ្នួល ឬមានឈ្នួល ហើយឱ្យបង្វិលវត្ថុនោះទៅអ្នកដែលយកមកផ្ញើនោះវិញ ឬប្រគល់ឱ្យនរណាមួយដែលគេប្រាប់ឈ្មោះមកយ៉ាងច្បាស់វេលាដែលបានសន្មតគ្នា ឬនៅវេលាដែលទារវិញ ។

**មាត្រា ១២៤៧** ៖ អ្នកដែលយកចលវត្ថុមកផ្ញើឱ្យរក្សាហៅថាអ្នកផ្ញើ, អ្នកដែលគេផ្ញើចលវត្ថុហៅថាអ្នកទទួលបញ្ញើ ។

**មាត្រា ១២៤៨** ៖តាមគោលច្បាប់, កិច្ចសន្យានៃការផ្ញើទុកជាបានការមួយឥតឈ្នួលទេ, ហេតុនេះបើកិច្ចសន្យាមិនបាននិយាយពីឈ្នួលទេ, អ្នកទទួលបញ្ញើមិនត្រូវទទួលឈ្នួលឡើយ ។

**មាត្រា ១២៤៩** ៖ អ្នកទទួលបញ្ញើត្រូវរក្សាវត្ថុដែលគេផ្ញើនោះឲ្យគង់ហើយត្រូវប្រគល់ឲ្យវិញនៅវេលា ដែលបានសន្មតគ្នាឬនៅវេលាដែលអ្នកផ្ញើមកយកជាលើកទី១ ។

**មាត្រា ១២៥០** ៖ អ្នកទទួលបញ្ញើត្រូវប្រគល់ឲ្យតែអ្នកមកផ្ញើ, ទោះអ្នកនោះមិនមែនជាកម្មសិទ្ធិករក៏ដោយ, ក្រៅពីអ្នកមកផ្ញើ, ទោះកម្មសិទ្ធិករពិតមកទារយកក៏ដោយ, ក៏មិនត្រូវឲ្យដែរ ។

**មាត្រា ១២៥១** ៖ អ្នកទទួលបញ្ញើគ្មានសិទ្ធិនឹងយកបញ្ញើនោះទៅប្រើប្រាស់ទេ បើគ្មានការអនុញ្ញាតឲ្យប្រើទេ ។

**មាត្រា ១២៥២** ៖ បើផ្ញើឥតឈ្នួល, គេអាចសន្និដ្ឋានថាអ្នកផ្ញើបើកឲ្យអ្នកទទួលបញ្ញើប្រើប្រាស់នូវវត្ថុដែលផ្ញើនោះបានតែបើផ្ញើមានឈ្នួល, គេមិនគប្បីសន្និដ្ឋានដូច្នេះ ឡើយ ។

**មាត្រា ១២៥៣** ៖ បើបញ្ញើខូច, អន្តរាយ, បាត់ពីព្រោះកំហុសខ្លួន, អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវ ។ បើបញ្ញើដែលបើកឲ្យប្រើហើយតាមធម្មតាទៅ, វាខូច, នោះអ្នកទទួលបញ្ញើមិនត្រូវសងឡើយ ។

**មាត្រា ១២៥៤** ៖ បើរបស់នេះអន្តរាយ, បាត់ដោយហេតុមកពីករណីនៃប្រធានស័ក្តិ, អ្នកទទួលបញ្ញើមិនត្រូវសងទេ ។ បើផ្ញើមានឈ្នួល ហើយបញ្ញើនោះអន្តរាយដោយចោរកម្មអ្នកទទួលបញ្ញើត្រូវសងគេ, បើផ្ញើឥតឈ្នួលហើយទទួលបញ្ញើមានបន្ទាល់ថាវត្ថុនោះបាត់ក្នុងការប្រយ័ត្នដែរ, អ្នកទទួលបញ្ញើមិនត្រូវសងឡើយ ។

**មាត្រា ១២៥៥** ៖ ក៏ប៉ុន្តែម្ចាស់សណ្ឋាគា(hoteliers), ម្ចាស់ទាម (aubergistes), ម្ចាស់សយនដ្ឋាន (proprietaire de dortoirs)ម្ចាស់ភោជនាគា (restaurants) ត្រូវទទួលសងទ្រព្យនៃជនទាំងឡាយដែលមកស្នាក់អាស្រ័យក្នុងផ្ទះខ្លួន, បានផ្ញើនឹងខ្លួនហើយអន្តរាយទៅដោយចោរកម្ម ។

**មាត្រា១២៥៦** ៖ នាកាលអ្នកផ្ញើបានប្រាប់ថាបញ្ញើនោះត្រូវប្រគល់ឲ្យជនណាម្នាក់ក្នុងវេលាណាមួយ, អ្នកទទួលត្រូវទុកបញ្ញើនោះឲ្យជនដែលគេឲ្យប្រគល់នោះក្នុងវេលានោះ, បើអ្នកផ្ញើមិនបានប្រាប់វេលាប្រគល់ទេ, អ្នកទទួលត្រូវប្រគល់ឲ្យគេក្នុងខណៈដែលគេមកទាជាដំបូង ។

**មាត្រា ១២៥៧** ៖ អ្នកផ្ញើអាចទារឲ្យអ្នកទទួលប្រគល់បញ្ញើនោះដល់ខ្លួនអ្នកផ្ញើមុនជនដែលខ្លួនបានផ្តាំឲ្យប្រគល់ឲ្យនោះបាន ។

## ចំពូកទី ៩
## អំពីវិសុណ្ណាបនិក

**មាត្រា ១២៥៨** ៖ នាកាលបុគ្គល ច្រើននាក់ទាមទារភោគៈ ឬកម្មសិទ្ធិនៃវត្ថុណាមួយ, បុគ្គលនោះអាចនឹងព្រមព្រៀងគ្នាថាវត្ថុនោះត្រូវឲ្យទៅតតិយជនម្នាក់រក្សាទុកឲ្យទំរាំដល់តុលាការវិនិច្ឆ័យសេចក្តីជាស្រេចឲ្យបាន ។

**មាត្រា ១២៥៩** ៖ ការដែលប្រគល់វត្ថុកើតដំណើរឲ្យតតិយជនម្នាក់រក្សាយ៉ាងនេះហៅថាវិសុណ្ណាបនិក ឬ កំណោះ ។

**មាត្រា ១២៦០** ៖ វិសុណ្ណាបនិក នឹងទុកជាត្រឹមត្រូវបានលុះណាតែគូវិវាទទាំងអស់មូលមាត់គ្នាព្រមផង ។

**មាត្រា ១២៦១** ៖ វិសុណ្ឋានិក មានឈ្នួលក៏មាន, ឥតឈ្នួលក៏មាន ។ បើគេមិនបាននិយាយគ្នាពីឈ្នួលទេ , វិសុណ្ឋាបនិកនោះត្រូវសន្និដ្ឋានថាឥតឈ្នួល ។

**មាត្រា ១២៦២** ៖ វិសុណ្ឋាបនិកអាចនឹងទទួលចលវត្ថុក៏បាន អចលវត្ថុក៏បាន ។

**មាត្រា ១២៦៣** ៖ អ្នកដែលអាចទារយកវត្ថុនោះគឺអ្នកដែលតុលាការបានកាត់សេចក្ដីឲ្យបានវត្ថុនោះ ។

**មាត្រា ១២៦៤** ៖ តុលាការអាចនឹងបង្គាប់ឲ្យធ្វើវិសុណ្ឋាបនិកដោយឯកឯងបាន, សេចក្ដីសម្រេចរបស់តុលាការជំនួសសេចក្ដីព្រមព្រៀងរបស់គូភាគី ។

**មាត្រា ១២៦៥** ៖ ទោះតុលាការបង្គាប់ឲ្យតំកល់ក្ដី, គូវិវាទព្រមព្រៀងគ្នាក្ដី, អ្នកទទួលវត្ថុតំកល់នោះត្រូវមានកាតព្វកិច្ចតែដដែល ។ គោលច្បាប់ដែលស្ដីពីវិសុណ្ឋាបនិកដូចគ្នានឹងគោលច្បាប់ដែលស្ដីពីការផ្ញើដែរ ។

**មាត្រា ១២៦៦** ៖ បើវិសុណ្ឋាបនិកនោះគឺតុលាការបង្គាប់ឲ្យធ្វើ, តុលាការត្រូវសម្រេចពីឈ្នួលឲ្យអ្នករក្សាផង ។

**មាត្រា ១២៦៧** ៖ បើវត្ថុដែលដាក់វិសណ្ឋាបនិកនោះជាអចលវត្ថុ, អ្នករក្សាត្រូវគ្រប់គ្រងទាំងអស់, អ្នកនេះត្រូវ, ទារយកផលនិងផលទុនហើយធ្វើខ្លួនជាគណនេយ្យករនៃអចលវត្ថុនោះ។ នៅវេលាដែលខ្លួនត្រូវប្រគល់វត្ថុនោះឲ្យម្ចាស់គេវិញ, ខ្លួនត្រូវជូនទាំងគណនីខាងការចាត់ចែងផង ។

បើតុលាការជាអ្នកឲ្យដំកល់វត្ថុនោះគណនីនោះ ត្រូវតុលាការជាអ្នកត្រួតត្រា ។

# ជំពូកទី ៣០
# អំពីអាណត្តិ

**មាត្រា ១២៦៨** ៖ អាណត្តិ គឺជាកិច្ចសន្យា ដែលជនម្នាក់ឲ្យអំណាចទៅជនម្នាក់ទៀតឲ្យយក ទៅបំពេញកិច្ចខ្លះខាងតុលាការក្នុងនាមខ្លួន និងតាងខ្លួន ។

**មាត្រា ១២៦៩** ៖ អ្នកដែលឲ្យអំណាចទៅគេហៅថាអាណត្តិទាយក, អ្នកដែលទទួលអំណាចនោះហៅថាអាណត្តិគាហក ឬ អ្នកដំណាង ។

**មាត្រា ១២៧០** ៖ ភាគី អាចព្រមព្រៀងគ្នាអំពីអាណត្តិដោយឥតឈ្នួល ឬ មានឈ្នួលបាន ។ បើកិច្ចសន្យាមិនបាននិយាយត្រង់ខនោះ, អាណត្តិនោះគប្បីសន្និដ្ឋានថាឥតមានឈ្នួលទេ ។

**មាត្រា ១២៧១** ៖ អាណត្តិនោះនឹងយកជាការបានលុះណាតែធ្វើជាលាយល័ក្សអក្សរ, លិខិតប្រគល់អំណាចនេះហៅថាសំបុត្រប្រគល់អំណាច ឬ សិទ្ធិប្រទាន ។

**មាត្រា ១២៧២** ៖ ជនទាំងឡាយច្រើននាក់ អាចឲ្យអំណាចខ្លួនទៅដំណាងតែម្នាក់ចេញតាងក្នុងអង្គសេចក្ដីតែមួយជាមួយគ្នាបាន ។ បើអាណត្តិនោះមានឈ្នួលដែរ, អាណត្តិទាយកទាំងអស់ត្រូវរួបរួមគ្នាចេញ ។

**មាត្រា ១២៧៣** ៖ អាណត្តិនោះអាចជាអាណត្តិពិសេសក៏បានជាអាណត្តិទូទៅក៏បាន, សេចក្ដីក្នុងសិទ្ធិប្រទាននោះត្រូវបញ្ជាក់ពីវិសាលភាពនៃអាណត្តិនោះផង ។

**មាត្រា ១២៧៤** ៖ អាណត្តិទាយកមិនអាចឲ្យអំណាចខ្លួនហួសពីខ្លួនមានបានទេ ។

**មាត្រា ១២៧៥** ៖ ជនទាំងពួងអាចធ្វើជាតំណាងនៅមុខតុលាការតាមអំណាច សិទ្ធិប្រទានតាងបុព្វញាតិ, បច្ឆាញាតិខ្លួនដែលមានខាន់ស្លា, ឥតខាន់ស្លា, ឬសាច់ចិញ្ចឹម, តាងសហព័ទ្ធខ្លួនដែលមានខាន់ស្លា, តាងញាតិសាខាបង្កើត, រួមឪពុកឬរួមម្ដាយដែលមានខាន់ស្លា, ឥតខាន់ស្លា ឬសាច់ចិញ្ចឹមត្រឹមថ្នាក់ទី ៤ និងញាតិពន្ធនៃខ្លួនត្រឹមថ្នាក់ទី ៤ ដែរ។

**មាត្រា ១២៧៦** ៖ បើអ្នកតំណាងមិនមែនជាញាតិតាមល័ក្ខខ័ណ្ឌដូចមានអធិប្បាយខាងលើនេះទេ, តុលាការអាចមិនព្រមទទួលអ្នកតំណាងនោះដោយមិនបាច់ប្រាប់ហេតុបាន ។

**មាត្រា ១២៧៧** ៖ អ្នកតំណាងត្រូវឲ្យដល់អាណត្តិទាយកនូវព័ត៌មានគ្រប់ប្រការ ដែលអាណត្តិទាយកដណ្ដឹងសួរអំពីស្ថានភាពនៃរឿងដែលគេពឹងពាក់ខ្លួន ។

**មាត្រា ១២៧៨** ៖ អ្នកតំណាងត្រូវរាយរាប់ការក្រោយដែលខ្លួនបានប្រតិបត្តិតាមអាណត្តិរួចហើយ ។ ខ្លួនត្រូវទទួលខុសត្រូវអំពីកំហុសរបស់ខ្លួនផង ។

**មាត្រា ១២៧៩** ៖ នាកាលមានអាណត្តិទាយកប្ដឹងពីអ្នកតំណាងខ្លួន, តុលាការត្រូវរកកំហុសតំណាងមានឈ្នួលឲ្យតឹងរឹងជាងតំណាងឥតឈ្នួល ។

**មាត្រា ១២៨០** ៖ អ្នកដំណាងត្រូវយកចិត្តទុកដាក់បំពេញនូវអាណត្តិខ្លួនឲ្យហ្មត់ចត់ និងឲ្យរវាសរវៃផង ។

**មាត្រា ១២៨១** ៖ អាណត្តិទាយកត្រូវចេញសោហ៊ុយដាច់ខាតក្នុងការដែលខ្លួនឲ្យអាណត្តិទៅគេធ្វើនោះ ។

**មាត្រា១២៨២** ៖ ខសន្យា ទាំងឡាយ ដែលអ្នកតំណាងបានធ្វើក្នុងនាមអាណត្តិទាយកក្នុងព្រំដែននៃអំណាចដែលអាណត្តិទាយកឲ្យមកនោះត្រូវទុកជាបានការទាំងអស់។

**មាត្រា ១២៨៣** ៖ អំណាចដែលអាណត្តិទាយកបានឲ្យនោះនឹងដលវិញបានមិនបាច់ប្រាប់ហេតុឡើយ ។

**មាត្រា ១២៨៤** ៖ កិច្ចការទាំងឡាយ, ទាំងពួង ដែលអ្នកតំណាងបានធ្វើក្រោយដែលអាណត្តិទាយកបានដកអំណាចហើយត្រូវទុកជាមោឃៈ ។

**មាត្រា ១២៨៥** ៖ បើអាណត្តិទាយក ឬ អ្នកតំណាងស្លាប់, អំណាចដែលឲ្យនោះត្រូវរលាយ ។

**មាត្រា ១២៨៦** ៖ អ្នកដែលកាន់កាប់ គ្មានសិទ្ធិប្រទាននូវការងាររបស់ជនដទៃដើម្បីកុំឲ្យគេមានព្យសនកម្ម, ត្រូវមានកាតព្វកិច្ចដូចខ្លួនជាអ្នកតំណាងដែរ, សិទ្ធិនៃអ្នកដែលធ្វើការជួសជនដទៃនេះត្រូវគិតដូចមានចែងក្នុងមាត្រា ៨២៥-៨២៦ នោះ ។

# ជំពូកទី ១១
# អំពីក្រុមហ៊ុន

**មាត្រា ១២៨៧** ៖ ដែលហៅថា ក្រុមហ៊ុន នោះគឺកិច្ចសន្យាដែលមនុស្ស ទាំងឡាយព្រមព្រៀងគ្នាយកធនធានរបស់ខ្លួនទៅដាក់រួមគ្នាក្នុងគោលបំណងណា មួយ ដើម្បីនឹងចែកចំណេញ ឬ ចែកខាតដែលអាចកើតឡើងពីការនោះ ។

កិច្ចសន្យាក្រុមហ៊ុន ត្រូវធ្វើលិខិតជាលាយល័ក្សអក្សរមានសេចក្ដីបញ្ជាក់ ផងបើកិច្ចសន្យានោះប្ដេជ្ញាអំពីអចលវត្ថុ ។

**មាត្រា ១២៨៨** ៖ ឯប្ដីប្រពន្ធ នឹងចូលហ៊ុនគ្នាពុំបានឡើយ ។

**មាត្រា ១២៨៩** ៖ ចំណែកហ៊ុននោះស្មើគ្នាក៏បាន, មិនស្មើគ្នាក៏បាន ។

**មាត្រា ១២៩០** ៖ សមាជិកទាំងឡាយ អាចយកទុនមករួមក៏បាន, យក ប្រាជ្ញា, សកម្មភាព, ចំណេះ ឬការពិសោធន៍មកដាក់ក្នុងមូលនិធិរួមក៏បាន ។

**មាត្រា ១២៩១** ៖ មូលនិធិរួមរបស់ក្រុមហ៊ុនគឺជាដើមទុននៃក្រុមហ៊ុន, ដើម ទុននោះជារបស់សមាជិកទាំងអស់គ្នា ។

អ្វីដែលសមាជិកម្នាក់ៗមានក្រៅពីវត្ថុ ដែលយកទៅចូលក្នុងក្រុមហ៊ុននោះ មិនមែនជារបស់ក្រុមហ៊ុនឡើយគឺជារបស់កម្មសិទ្ធិផ្ទាល់ខ្លួនម្នាក់ៗ ។

**មាត្រា ១២៩២** ៖ សមាជិកម្នាក់ៗត្រូវបានចំណេញតាមសមាមាត្រនៃហ៊ុន ដែលខ្លួនយកមកចូល ។ កិច្ចសន្យាត្រូវចែងឲ្យច្បាស់ពីតម្លៃនៃហ៊ុនរបស់សមាជិក ដែលពុំបានចេញប្រាក់ដើម, ពុំបានចេញទ្រព្យជាសម្ភារៈនោះ ។

បើកិច្ចសន្យាគ្មានចែងអំពីខនេះទេ, ហ៊ុនដែលយកមកចូលនោះត្រូវទុកជាស្មើភាគគ្នាទាំងអស់ ។

**មាត្រា ១២៩៣** ៖ សមាជិកណាក៏ដោយមិនអាចបង្ខំសមាជិកផងគ្នាឲ្យបញ្ចូល តតិយជនក្នុងក្រុមហ៊ុនបានទេ, បើសមាជិកទាំងអស់ព្រមទាំងអស់គ្នាជាឯកច្ឆ័ន្ទ, ទើបអ្នកថ្មីអាចចូលបាន ។

**មាត្រា ១២៩៤** ៖ កាតព្វកិច្ចនៃសមាជិកទាំងឡាយត្រូវចែងក្នុងកិច្ចសន្យាឲ្យច្បាស់លាស់ ។

## ចំពូកទី ១២
## អំពីប្រទានកម្ម ឬការឱ្យ

**មាត្រា ១២៩៥** ៖ ដែលហៅថាប្រទានកម្ម ឬការឱ្យ នោះគឺជាកិច្ចសន្យាមួយដែលជនម្នាក់ហៅថា អ្នកឱ្យ ឬទាយក ឱ្យនូវវត្ថុអ្វីមួយដាច់ឥតរើរុសទៅជនម្នាក់ទៀតហៅថាអ្នកទទួលឬ បដិគាហក ដែលព្រមយកវត្ថុនោះ ។

**មាត្រា ១២៩៦** ៖ ប្រទានកម្មនេះគឺបុគ្គលឲ្យទៅដើម្បីកុសលក៏មាន, ឲ្យជាសំណងថ្លៃការ ឬជារង្វាន់ ឬដើម្បីដាក់ធុរៈអ្វីមួយទៅអ្នកទទួលក៏មាន ។

### ផ្នែកទី ១
### អំពីអំណោយ, ជំនូន ឬបណ្ណាការ

**មាត្រា ១២៩៧** ៖ ប្រទានកម្ម ជាប្រាក់ ឬជាចលវត្ថុនោះមិនមានរូបមន្តយ៉ាងណាៗ ឡើយ, ប្រទានកម្មនេះគឺអំណោយ, ជំនូន ឬបណ្ណាការដែលអ្នកឲ្យប្រគល់ខ្លួនឯង ឬឲ្យគេប្រគល់ក្នុងនាមខ្លួនទៅអ្នកទទួល ។ ប្រទានកម្មបែបនេះបើ

ឲ្យហើយត្រូវទុកជាការស្រេចនឹងរើរុសវិញមិនបានទេ, ទោះអ្នកទទួលនោះត្រឡប់ជាជនអកត្តញ្ញូ ឬ ជាអភ័ព្វបុគ្គលក៏ដោយ ។ មានស្ថានភាពមួយទេ គឺស្ថានដែលអ្នកទទួលប្រទានកម្មមិនព្រមបំពេញនូវបន្ទុកដែលអ្នកឲ្យផ្តាំទើបដកហូតប្រទានកម្មវិញបាន ។

## ផ្នែកទី ២
## អំពីប្រទានកម្មដទៃទៀត

**មាត្រា ១២៩៨** ៖ នាកាលប្រទានកម្ម ប្តេជ្ញាថាឲ្យបេតិកភ័ណ្ឌសាកល ឬឲ្យតែអចលវត្ថុណាមួយ, ប្រទានកម្មនោះត្រូវឲ្យដោយសំបុត្រ បញ្ជាក់នីមុខអ្នកទទួលដែលព្រមទទួលផង ។

**មាត្រា ១២៩៩** ៖ ប្រទានកម្មដែលឲ្យ អចលវត្ថុ,នាកាលបានចុះបញ្ជីការភូមិបាល តាមអចលវត្ថុនីមួយៗរួចហើយ និងក្រោយដែលបានចុះក្នុងបញ្ជីការអ៊ីម្ម៉ាទ្រីគុឡាស្យុងហើយ, ប្រសិនបើអំណោយនោះជាដីអ៊ីម្ម៉ាទ្រីគុឡាស្យុង, ទើបទុកជាស្រេច, តតិយជននឹងតវ៉ាមិនបានឡើយ ។

**មាត្រា ១៣០០** ៖ ភាគនៃបេតិភណ្ឌដែលអ្នកឲ្យអាចធ្វើប្រទានកម្មតាមកិច្ចសន្យាសបាននោះក៏ដូចជាភាគនៃមត៌កដែលម្ចាស់មត៌កអាចនឹងចាត់ចែងដោយសំបុត្របណ្តាំបានដូចចែងទុកហើយក្នុងមាតិកាស្តីពីសន្តិកម្មនោះដែរ ។

**មាត្រា ១៣០១** ៖ ប្រទានកម្មដែលធ្វើដោយហេតុមរណៈហៅថា អច្ច័យទាន ។

ប្រទានកម្មដែលឲ្យដល់គ្នាទៅវិញទៅមកហៅថា ការដូរ ។

**មាត្រា ១៣០២** ៖ នាកាលអ្នកទទួលប្រទានកម្មមានសមត្ថភាពអាចនឹងចុះកិច្ចសន្យាបានហើយ, អ្នកនោះអាចប្រកែកមិនព្រមយកសប្បុរិសទាននេះបានជាដរាប ។

ម្ចាស់បំណុលនៃជននោះមិនអាចធ្វើអន្តរាគមន៍ដើម្បីបង្ខំជននេះឲ្យទទួលប្រទានកម្មបានឡើយ ។

**មាត្រា ១៣០៣** ៖ ប្រទានកម្មដែលអ្នកឲ្យនឹងមានក្នុងអនាគតនោះមិនបានទេ, ប្រទានកម្មដែលធ្វើដើម្បីឲ្យអ្នកទទួលនោះព្រមសងបំណុលខ្លួន ដែលនឹងមានក្នុងអនាគតក៏មិនបានដែរនិងប្រទានកម្មដែលបើកឲ្យអ្នកមានសិទ្ធិយកទ្រព្យដែលបានហើយទៅចាត់ចែងតាមចិត្តខ្លួនក៏មិនបានដែរ ។

**មាត្រា ១៣០៤** ៖ អ្នកឲ្យសំចៃទុកដើម្បីខ្លួននូវផលលុបភោគ, សិទ្ធិប្រើប្រាស់ និងអាស្រ័យនៅ ឬសិទ្ធិប្រើចលវត្ថុសិនក៏បានដែរ ។

**មាត្រា ១៣០៥** ៖ គូភាគីអាចព្រមព្រៀងគ្នាថាវត្ថុដែលបានឲ្យហើយនឹងវិលមករកអ្នកឲ្យវិញតាមល័ក្ខខណ្ឌណាមួយបាន កុំឲ្យតែការធ្វើការធ្វើឲ្យសម្រេចនូវល័ក្ខខណ្ឌនោះពឹងផ្អែកលើឆន្ទៈនៃអ្នកឲ្យនោះឡើយ, បើមិនដូច្នោះទេ, កិច្ចសន្យានោះត្រូវទុកជាមោឃៈ ។

**មាត្រា ១៣០៦** ៖ ប្រទានកម្មឯណាដែលអ្នកទទួលបានព្រមទទួលហើយ, ប្រទានកម្មនោះត្រូវទុកជាស្រេចឥតរើសរុសដោយប្រការឯណាបានឡើយ, វៀរតែក្នុងស្ថានដូចមានខាងក្រោម ។

**មាត្រា ១៣០៧** ៖ អ្នកឲ្យ ឬសិទ្ធិវន្តរបស់អ្នកឲ្យអាចនឹងប្ដឹងសុំឲ្យបដិសេធវិញបានដោយមានហេតុដូចតទៅ ៖

១. បើអ្នកទទលមិនបានបំពេញនូវការៈដែលខ្លួនមានកាតព្វកិច្ចត្រូវបំពេញ។

២. បើអ្នកទទួលប្រព្រឹត្តនូវអំពើអកត្តញ្ញូ ឬធ្វើខ្លួនឲ្យអភព្វបុគ្គលគ្រប់ល័ក្ខខណ្ឌដូចមានសម្ដែងហើយក្នុងមាតិកានៃសន្តិកម្ម

៣. បើអ្នកទទួលមិនចិញ្ចឹមអ្នកឲ្យក្នុងពេលដែលទ័លក្រ

**មាត្រា ១៣០៨** ៖ ជនណាមិនទាន់មានកូនហើយធ្វើប្រទានកម្មដល់អ្នកដទៃ, បើថ្ងៃក្រោយមកខ្លួនត្រឡប់ជាមានកូនម្នាក់មានខាន់ស្លា ឬឥតខាន់ស្លា, ជននោះអាចបដិសេធប្រទានកម្មនោះវិញបាន ។ តែបើកូននោះជាកូនសុំទេ, អ្នកឲ្យមិនអាចសុំបដិសេធប្រទានកម្មបានឡើយ ។

**មាត្រា ១៣០៩** ៖ ការសុំបដិសេធប្រទានកម្មនោះជាភារៈរបស់អ្នកឲ្យ ឬរបស់សិទ្ធិវន្តអ្នកឲ្យ ។

**មាត្រា១៣១០** ៖ ការបដិសេធនោះបណ្ដាលឲ្យរលាយកម្មសិទ្ធិនៃអ្នកទទួលទាន, ការនេះមានអានុភាពខាងរំលាយជាល័ក្ខខ័ណ្ឌ, ទ្រព្យដែលបានឲ្យហើយនោះត្រូវបានទៅអ្នកឲ្យវិញដោយលែងឲ្យអ្នកទទួលមានបំណុលនឹងបន្ទុកទាំងពួង ដែលបានភ្ជាក់វេរលើអ្នកនេះពីថ្ងៃមុននោះ ។

# មាតិកា ទី ៤
# អំពីកិច្ចសន្យាធានា

**មាត្រា ១៣១១** ៖ ដែលហៅថាកិច្ចសន្យាធានា គឺជាកិច្ចសន្យាដែលធ្វើដើម្បីឃុំគ្រងម្ចាស់បំណុលទាំងឡាយមិនឲ្យអន្តរាយទ្រព្យ ដោយសារកូនបំណុលរកប្រាក់សងមិនបាន។ កិច្ចធានានោះត្រូវធ្វើជាលាយល័ក្សអក្សរ ។

**មាត្រា ១៣១២** ៖ កិច្ចធានា នេះមានពីរបែប គឺបែបទីមួយ អ្នកធានាប្ដេជ្ញានឹងម្ចាស់បំណុលថាខ្លួនទទួលសងជួសកូនបំណុល កាលណាអ្នកនេះរកប្រាក់សងម្ចាស់បំណុលមិនបានទេ, មួយបែបទៀតកូនបំណុលយកទ្រព្យអ្វីមួយ ឬច្រើនរបស់ខ្លួនទៅដាក់សម្រាប់សងបំណុលម្ចាស់បំណុល ណាម្នាក់ដោយមិនឲ្យម្ចាស់បំណុលទាំងឡាយឯទៀតមានសិទ្ធិលើទ្រព្យនោះឡើយ ។

ការដែរយកមនុស្សមកធានា បំណុលហៅថា កំជាប់ដោយបុគ្គល ឬ ប្រាតិភោគបុគ្គល, ការដែលយកទ្រព្យមកធានាហៅធាជាប់ដោយវត្ថុ ឬ ប្រតិភោគប្រត្យ័ក្ស ។

**មាត្រា ១៣១៣** ៖ កិច្ចសន្យាធានា មានបី ប្រការដូច្នោះ

១. ធានាដោយបុគ្គលដែលហៅថាប្រតិភោគដោយបុគ្គល

២. បញ្ចាំ

៣. ហ៊ីប៉ូតែក

បញ្ចាំ និងហ៊ីប៉ូតែកជាប្រាតិភោគប្រត្យ័ក្ស ។

## ចំពូកទី ១
## អំពីកិច្ចធានាដោយបុគ្គល

**មាត្រា ១៣១៤** ៖ ដែលហៅថា កិច្ចធានា ដោយបុគ្គល គឺជាសេចក្ដីសន្យាមួយដែលតតិយជនម្នាក់ ហៅថាអ្នកធានាសន្យា នឹងម្ចាស់បំណុលថាខ្លួនទទួលបំពេញនូវកាតព្វកិច្ចរបស់កូនបំណុលជំនួសកូនបំណុល ប្រសិនបើកូនបំណុលមិនបានបំពេញកាតព្វកិច្ចនោះដោយខ្លួនឯងទេ ។ កិច្ចសន្យានេះអាចនឹងធ្វើជាសំបុត្របញ្ជាក់ក៏បាន, នឹងធ្វើជាសំបុត្រឯកជនក៏បាន ។

**មាត្រា ១៣១៥** ៖ អ្នកធានា មិនត្រូវបានអ្វីពីម្ចាស់បំណុលជាសគុណ ដល់ខ្លួនជាអ្នកធានាឡើយ ។

**មាត្រា ១៣១៦** ៖ បំណុលតែមួយ អាចមានអ្នកធានាច្រើននាក់បាន ។

**មាត្រា ១៣១៧** ៖ កិច្ចធានា ដោយបុគ្គលមានកំណត់កាតព្វកិច្ចណាមួយជាប្រធាន ។ បានសេចក្ដីថា កិច្ចធានា ដោយបុគ្គលនេះមិនអាចធានាវត្ថុឯណាផ្សេងឬ ធំហួសវត្ថុនៃកាតព្វកិច្ចដែលជាប្រធាននោះបានឡើយ ។

**មាត្រា ១៣១៨** ៖ កិច្ចធានា ដោយបុគ្គលអាចប្ដេជ្ញាអំពីកាតព្វកិច្ចគ្រប់ចំពូកបាន, ទោះកាតព្វកិច្ចនោះមានវត្ថុយ៉ាងណាៗក្ដី, កិច្ចធានាដោយបុគ្គលនេះអាចប្ដេជ្ញាអំពីកាតព្វកិច្ចដែលមានហើយក្នុងកាលពីមុនមកក៏បាន, ប្ដេជ្ញាអំពីកាតូកិច្ចដែលនឹងមានក្នុងអនាគតក៏បាន ។

ក្នុងករណីខាងក្រោមនេះបើកាតព្វកិច្ច ជាប្រធានកើតឡើងវេលាណាទើបកិច្ចធានានោះក៏មានអានុភាពក្នុងវេលានោះដែរ ។

**មាត្រា ១៣១៩** ៖ កិច្ចធានាឯណាប្ដេជ្ញាអំពីកាតព្វកិច្ចដែលច្បាប់ទុកជាមោឃៈ, កិច្ចធានានោះទុកជាអសារសូន្យ, គ្មានអានុភាពទេ, ប៉ុន្ដែបើមោឃៈនោះរហូតមកពីកូនបំណុលជាជនអសមត្ថភាព, កិច្ចធានានោះនៅតែទុកជាបានការដដែល ។

**មាត្រា ១៣២០** ៖ ម្ចាស់បំណុលមិនអាចឲ្យអ្នកធានាសងមុនថ្ងៃកំណត់ ក្នុងកិច្ចសន្យានោះបានទេ, កិច្ចសន្យានោះបានកំណត់ពេលសងនៅថ្ងៃណា, អ្នកធានានៅតែប្រកាន់ថ្ងៃនោះបាន, ទោះបីកូនបំណុលផ្ដាស់សិទ្ធិគ្មានអំណាចប្រកាន់តាមកិច្ចសន្យានោះក៏ដោយ ។

**មាត្រា ១៣២១** ៖ ម្ចាស់បំណុលអាចប្ដឹងពីអ្នកធានាដំណាលនឹងកូនបំណុល ឬប្ដឹងក្រោយក៏បាន ។

**មាត្រា ១៣២២** ៖ លុះក្រោយពីមានសាលក្រមមក, អ្នកធានាអាចបញ្ជូនម្ចាស់បំណុលឲ្យអូសទ្រព្យកូនបំណុលលក់មុនសិនសឹមសម្រេចអូសរបស់ខ្លួនជាក្រោយបាន ។ តែអ្នកធានាមិនអាចសុំឲ្យបង្ខំដល់រូបកាយកូនបំណុលមុនសម្រេចលក់ទ្រព្យខ្លួនជាអ្នកធានាបានឡើយ ។

**មាត្រា ១៣២៣** ៖ ក្នុងករណីមានអ្នកធានាច្រើននាក់នោះ, អ្នកធានាម្នាក់ៗត្រូវជាប់ធានាបំណុលទាំងមូលហាក់ដូចជាអ្នកធានាមានតែម្នាក់ ។ អ្នកធានាទាំងអស់ត្រូវរួបរួមគ្នាសងបំណុលនោះ ។

**មាត្រា ១៣២៥** ៖ បើអ្នកធានាបានសងប្រាក់ជួសកូនបំណុលដែលខ្លួនធានាហើយ, សិទ្ធិម្ចាស់បំណុលទាំងប៉ុន្មានត្រូវបានទៅអ្នកធានាទាំងអស់, ជាអាទិ៍, អ្នកធានាត្រូវបាន ប្រាតិភោគប្រត្យ័ក្សដែលធានានូវបំណុលនោះជាដើម ។

**មាត្រា ១៣២៦** ៖ អ្នកធានាមានសិទ្ធិទារឲ្យកូនបំណុលសងប្រាក់ដែលខ្លួនបានសងជួសមកវិញព្រមទាំងការប្រាក់តាំងពីថ្ងៃដែលខ្លួនបានសងនិងសោហ៊ុយដែលដាច់បង់ផង ។

**មាត្រា ១៣២៧** ៖ អំពីសេចក្តី ដែលអ្នកធានាត្រូវទារពីអ្នកធានាដូចគ្នានោះ, នាកាលមានម្នាក់ចេញសងហើយ អ្នកនោះត្រូវប្តឹងទារពីអ្នកធានាឯទៀតតាមបញ្ញត្តិដែលស្តីពីសាមគ្គីភាព ។

## ចំពូក ទី ២
## អំពីការបញ្ចាំ

**មាត្រា ១៣២៨** ៖ ការបញ្ចាំ គឺជា ការដែលកូនបំណុលឯងក្តី តតិយជនណាម្នាក់ដាក់ទ្រព្យអ្វីមួយនៅដៃម្ចាស់បំណុលសម្រាប់រ៉ាបរងសងបំណុលណាមួយដោយឲ្យម្ចាស់បំណុលនេះមានសិទ្ធិយកថ្លៃនៃទ្រព្យដែលបញ្ចាំនោះជាសំណងប្រាក់ខ្លួនមុនម្ចាស់បំណុលឯទៀត ។

**មាត្រា ១៣២៩** ៖ បញ្ចាំមានពីរយ៉ាង គឺបញ្ចាំចលវត្ថុមួយ, បញ្ចាំអចលវត្ថុមួយតាមប្រភេទនៃទ្រព្យដែលបញ្ចាំ ។

## ផ្នែកទី ១
## អំពីបញ្ញាំចលវត្ថុ

**មាត្រា១៣៣០** ៖ កិច្ចសន្យាបញ្ញាំចលវត្ថុត្រូវមានសំបុត្រជាលាយល័ក្ខអក្សរ ។

**មាត្រា ១៣៣១** ៖ ទ្រព្យដែលបញ្ញាំនោះត្រូវប្រគល់ទៅម្ចាស់បំណុលទើបកិច្ចសន្យានោះត្រូវទុកជាត្រឹមត្រូវបាន ។

**មាត្រា ១៣៣២** ៖ កិច្ចសន្យាត្រូវដាក់ចំនួនប្រាក់ដែលជំពាក់និងវត្ថុដែលបញ្ញាំឲ្យច្បាស់ប្រាកដ ។

**មាត្រា ១៣៣៣** ៖ បើកិច្ចសន្យាមិនដាក់ថាត្រូវមានការប្រាក់ប៉ុន្មានៗទេ, មិនដាក់កំណត់កាលដែលត្រូវសងទេ, បំណុលនោះត្រូវទុកជាឲ្យគ្នាខ្ចីទទេ ឥតការក្នុងកំណត់មួយឆ្នាំគិតតាំងពីថ្ងៃដែលចុះកិច្ចសន្យានោះមក ។

**មាត្រា ១៣៣៤** ៖ ម្ចាស់បំណុលដែលគេបញ្ញាំទ្រព្យផងនោះ, គ្មានសិទ្ធិនឹងប្រើវត្ថុដែលបញ្ញាំនោះទេ, វៀរតែបើបានសន្យាគ្នាថាឲ្យប្រើចុះទើបប្រើបាន ។

**មាត្រា ១៣៣៥** ៖ ម្ចាស់បំណុលមិនអាចចាត់ចែងនូវទ្រព្យដែលគេបញ្ញាំតាមអំពើចិត្តខ្លួនបានទេ, ខ្លួនត្រូវទុកទ្រព្យនោះឲ្យគង់នៅនឹងដៃខ្លួនហើយថែទាំឲ្យល្អ , បើបាត់, ខូចទ្រព្យនោះពីព្រោះខ្លួនធ្វេសប្រហេស ឬពីព្រោះខុសពីគំនិតខ្លួន, ខ្លួនជាម្ចាស់បំណុលត្រូវសងគេ។ ឯខាងកូនបំណុលវិញ, បើម្ចាស់បំណុលបានចេញចាយ , ដាច់ខាតដើម្បីថែរក្សាទ្រព្យដែលបញ្ញាំនោះប៉ុន្មានៗខ្លួនត្រូវទទួលសងទៅម្ចាស់បំណុលប៉ុណ្ណោះៗវិញ ។

**មាត្រា ១៣៣៦** ៖ បើម្ចាស់បំណុលប្រើប្រាស់វត្ថុដែលគេបញ្ចាំហួសខ្នាតពេក, កូនបំណុលអាចសុំដកវត្ថុនោះវិញបាន ។

**មាត្រា ១៣៣៧** ៖ បើដល់កំណត់សន្យាហើយ, ម្ចាស់បំណុលបានទទួលសំណងជាទ្រព្យដែលគេជំពាក់ហើយ, ម្ចាស់បំណុលត្រូវប្រគល់របស់ដែលគេបញ្ចាំឲ្យទៅគេវិញ ។ បើកូនបំណុលមិនទាន់សងគ្រប់ចំនួនទេ, ម្ចាស់បំណុលនឹងឃាត់របស់ដែលបញ្ចាំនោះសិនបាន ។

**មាត្រា ១៣៣៨** ៖ បើបំណុលរលត់ដោយបែបបទយ៉ាងណាក្រៅពីសងប្រាក់ក្តី, ការបញ្ចាំក៏ត្រូវរលត់ដូចគ្នាដែរ ។

**មាត្រា ១៣៣៩** ៖ ទោះបីបំណុលដែលបានបញ្ចាំវត្ថុផងនោះរលត់ហើយក្តី, ថាបើកូនបំណុលនៅជំពាក់បំណុលមួយផ្សេងទៀតដែលត្រូវទារបាន,ម្ចាស់បំណុលអាចឃាត់វត្ថុបញ្ចាំនោះទុកតទៅទៀតបាន ។

**មាត្រា១៣៤០** ៖ បើដល់កំណត់លោះហើយ, កូនបំណុលមិនលោះ, ម្ចាស់បំណុលអាចប្តឹងតុលាការសុំឲ្យលក់វត្ថុបញ្ចាំថ្លៃបាន ។ ប៉ុន្តែ បើបានសន្យាគ្នាថាដល់កំណត់លោះហើយ, កូនបំណុលមិនលោះទេ, វត្ថុនោះត្រូវបានទៅម្ចាស់បំណុល, នោះបើដល់កំណត់ហើយកូនបំណុលមិនបានលោះមែន, ម្ចាស់បំណុលត្រូវបានឡើងជាកម្មសិទ្ធិករពេញច្បាប់នៃវត្ថុនោះ ។

តែបើតម្លៃវត្ថុដែលបញ្ចាំនោះថ្លៃច្រើនជាងមួយរយរៀល, សេចក្តីសន្យាដូច្នេះត្រូវទុកជាមោឃៈអសារឥតការ ។

**មាត្រា ១៣៤១** ៖ ប្រាក់ដែលបានមកអំពីលក់របស់នោះត្រូវសងម្ចាស់បំណុល, បើសល់ពីនោះ, ត្រូវប្រគល់ទៅកូនបំណុលវិញឬ, បើកូនបំណុលមានជំពាក់ជនដទៃទៀតហើយម្ចាស់បំណុលដទៃទាំងឡាយនេះបានចេញខ្លួនមកប្ដឹង, កូនបំណុលក៏ទទួលថាជំពាក់មែនហើយបំណុលនោះក៏ដល់កំណត់ត្រូវទារដែរ, ត្រូវប្រគល់ទៅឲ្យម្ចាស់បំណុលទាំងឡាយនោះ ។ ការចែកសំណាងឲ្យម្ចាស់បំណុលទាំងឡាយដែលគ្មានវត្ថុបញ្ចាំផងនោះត្រូវលៃតាមសមាមាត្រនៃបំណុល ដែលជំពាល់រៀងខ្លួន ។

**មាត្រា ១៣៤២** ៖ បើប្រាក់ថ្លៃលក់វត្ថុនោះមិនគ្រប់គ្រាន់នឹងសងបំណុលដែលបញ្ចាំវត្ថុនោះទេ, កូនបំណុលត្រូវនៅជំពាក់បំណុលដែលនៅសល់តទៅទៀត ។

**មាត្រា ១៣៤៣** ៖ សោហ៊ុយដាច់ខាតក្នុងការលក់ដូរនឹងសោហ៊ុយប្ដឹងផ្ដល់ទាំងប៉ុន្មានត្រូវទុកជាបន្ទុកលើកូនបំណុល ។

## ផ្នែកទី ២
## អំពីការបញ្ចាំអចលវត្ថុ

**មាត្រា ១៣៤៤** ៖ ការបញ្ចាំអចលវត្ថុត្រូវតែមានកិច្ចសន្យាតាមរូបមន្តនៃលិខិតបញ្ជាក់ទើបបាន ។

**មាត្រា ១៣៤៥** ៖ តាមមូលសាស្ត្រកិច្ចសន្យានេះត្រូវសុំឲ្យមេឃុំ ជាចៅនាទីនៃអចលវត្ថុនោះបញ្ជាក់ឲ្យ, ថាបើអចលវត្ថុច្រើនផានាតែបំណុលមួយ, កិច្ចសន្យានោះត្រូវសុំឲ្យមេឃុំម្នាក់ៗ ដែលមានអចលវត្ថុទាំងឡាយនោះនៅក្នុងឃុំផ្សេងៗ

នោះបញ្ជាក់ឲ្យ ។ ក៏ប៉ុន្តែកិច្ចសន្យាដែលចូលក្នុងករណីដូចមានសំដែងក្នុងមាត្រា ៩៤៥ (វគ្គទី២) នៃក្រមនេះត្រូវសុំសេចក្តីបញ្ជាក់ពីចៅហ្វាយស្រុក ។

មិនតែប៉ុណ្ណោះសោត, កាលបើបំណុលនោះជាបំណុលខ្ចីប្រាក់មានប្រតិភោគប្រត្យ័ក្សផង, កិច្ចសន្យានោះត្រូវធ្វើតាមរូបមន្តដូចមានសំដែងក្នុងព្រះរាជប្រកាសលេខ ១៤ ចុះថ្ងៃទី២៩មករា ១៩៣៨ គឺថាត្រូវឲ្យអ្នករាជការ ឬភ្នាក់ងារដែលជាអ្នកត្រូវមុខខាងធ្វើការនេះដូចមានសំដែងក្នុងព្រះរាជប្រកាសនោះចុះទិដ្ឋាការឲ្យ, បើមិនដូច្នោះទេកិច្ចសន្យានោះត្រូវមានមោឃៈភាពយ៉ាងដាច់ខាត ។

**មាត្រា១៣៩៦** ៖ ការបញ្ចាំអចលវត្ថុ នឹងត្រូវទុកជាការប្តេជ្ញាត្រឹមត្រូវតាមច្បាប់ហើយ តតិយជនមិនអាចមកតវ៉ាបាននោះ, គឺលុះណាតែលិខិតជាទីប្តេជ្ញានោះបានគោរពតាមប្រកាសនៈភូមិបាល, ដូចដែលមានបញ្ញត្តិក្នុងមាត្រា ៩៥២ ខាងលើនេះដែលត្រូវធ្វើឲ្យស្របតាមស្ថានភាពនៃអចលវត្ថុបញ្ចាំនោះផង ។

ការមិនបានធ្វើប្រកាសនេះនឹងបណ្តាលឲ្យម្ចាស់បំណុលផ្តស់សិទ្ធិ ចាកប្រាតិភោគប្រត្យ័ក្សអស់ហើយ បន្សល់ទុកឲ្យអ្នកនោះត្រឹមតែសិទ្ធិឲ្យសងប្រាក់ដែលខ្ចីទៅតែប៉ុណ្ណោះ ។ សិទ្ធិប្តឹងនេះក៏ដូចជាសិទ្ធិដែលបើកឲ្យប្តឹងទារប្រាក់ចងការដែរគឺសុទ្ធតែជាសិទ្ធិមានអាជ្ញាយុកាលដូចមានកំណត់ទុកក្នុងបទបញ្ញត្តិនៃមាត្រា ៩២៨ តទៅនៃក្រមនេះស្រាប់ ។

លិខិតបញ្ចាំទាំងឡាយ, ដែលបានធ្វើមុនថ្ងៃប្រកាសឲ្យប្រើព្រះរាជប្រកាសនេះត្រូវយកទៅធ្វើតាមរូបមន្តដូចបានបញ្ញត្តិមកខាងលើនេះក្នុងវេលាប្រាំមួយខែ

រាប់ពីថ្ងៃប្រកាសឲ្យប្រើព្រះរាជប្រកាសនេះតទៅ, បើមិនធ្វើតាមបញ្ញត្តិនេះទេ, ម្ចាស់បំណុលនឹងត្រូវផ្តស់សិទ្ធិចាកប្រាតិភោគប្រត្យ័ក្សហើយ ។

**មាត្រា ១៣៤៧** ៖ អចលវត្ថុតែមួយអាចបញ្ចាំបានតែនឹងម្ចាស់បំណុលម្នាក់ ឬ ច្រើននាក់ដែលសាមគ្គីគ្នា ។

**មាត្រា ១៣៤៨** ៖ អចលវត្ថុដែលដាក់បញ្ចាំនឹប្រគល់ឲ្យម្ចាស់បំណុលក៏បាន, មិនប្រគល់ឲ្យក៏បាន, មិនបង្ខំទេ ។ គេអាចបញ្ចាំដោយប្រគល់តែប័ណ្ណនៃអចលវត្ថុនោះប៉ុណ្ណោះក៏បាន ។

**មាត្រា ១៣៤៩** ៖ ដូច្នេះបើប្រគល់ ឬមិនប្រគល់នូវអចលវត្ថុដល់ម្ចាស់បំណុលទេ, និទ្ទេសនៃការនោះត្រូវចុះឲ្យច្បាស់ក្នុងកិច្ចសន្យាបញ្ចាំនោះ ។

បើមុនដំបូងប្រគល់ហើយក្រោយមកមិនប្រគល់វិញ ឬមុនមិនប្រគល់ហើយក្រោយមកប្រគល់វិញ, និទ្ទេសនៃការផ្លាស់ប្តូរនេះត្រូវកត់លើខ្នងនៃកិច្ចសន្យានោះដែរ ។

**មាត្រា ១៣៥០** ៖ បើប្រគល់ដីឲ្យដោយជាក់លាក់ផង, ម្ចាស់បំណុលត្រូវតែប្រគល់ទ្រព្យបញ្ចាំនោះឲ្យកូនបំណុលវិញជាកំហិតក្នុងពេលដែលជននេះបានសងបំណុលអស់ហើយ ។

ក្នុងរយៈវេលាដប់ឆ្នាំរាប់ពីថ្ងៃធ្វើកិច្ចសន្យាមក, បើកិច្ចសន្យានោះមិនបានកំណត់ថ្ងៃឲ្យសង, ប្រសិនបើម្ចាស់បំណុលមិនបានប្តឹងដល់តុលាការទារបំណុលនោះទេ, ម្ចាស់បំណុលត្រូវផ្តស់សិទ្ធិនេះទទេគឺប្តឹងលែងបានសោះ ។

ការផ្តស់សិទ្ធិនេះមិនត្រឹមតែ តម្រូវឲ្យម្ចាស់បំណុលប្រគល់ដីឲ្យកូនបំណុលវិញប៉ុណ្ណោះទេ គឺតម្រូវឲ្យកូនបំណុលបានរួចស្រឡះចាកបំណុលដោយអហោសិកម្មផង ។ និទ្ទេសស្តីពីការបញ្ចាំដែលចុះក្នុងបញ្ជីការនៃប្រកាសនៈភូមិបាល(register de publicite fonerere) ពីថ្ងៃមុននោះត្រូវលុបចោលតាមពាក្យសុំរបស់កូនបំណុលឬចៅហ្វាយខែត្រត្រូវលុបចោលឯងដោយគ្រាន់តែបានពិនិត្យ ឃើញថាមានខ័យសក្កហើយ (គឺអស់សិទ្ធិ នឹងប្តឹងផ្តល់ហើយដោយហេតុថារយៈវេលាដែលច្បាប់បើកឲ្យប្តឹងនោះកន្លងហួសអស់ទៅហើយ(forclusion), ដោយបានឃើញកិច្ចសន្យាបញ្ចាំមួយច្បាប់ ឬក៏ដោយបានឃើញចំណារនៅលើតារាងភូមិបាល (martrice cadastrale) ប្រសិនបើដីនោះជាដីអ៊ីម៉្មាទ្រីគុឡាស្យុង, ហើយក្រឡាបញ្ជីនៃតុលាការ ដែលមានសមត្ថកិច្ចនោះក៏បានបញ្ជាក់ថាចំពោះកិច្ចសន្យាដែលមានគេប្តឹងសុំឲ្យទុកជាខ័យសក្កនោះ, ម្ចាស់បំណុលមិនបានប្តឹងផ្តល់អ្វីដល់តុលាការទេ ។

**មាត្រា ១៣៥១** ៖ប្រសិនបើដីបញ្ចាំនៅនឹងដៃកូនបំណុលព្រោះកាលបញ្ចាំនោះមិនបានប្រគល់ដីឲ្យម្ចាស់បំណុលទេ, កូនបំណុលត្រូវតែសងប្រាក់គេទាំងដើមទាំងចុងដូចដែលមាននិយាយក្នុងកិច្ចសន្យា, ទើបអាចលោះដោះខ្លួនឲ្យរួចពីបំណុលបាន ។

ក្នុងករណីដែលបញ្ចាំគ្មានប្រគល់វត្ថុ, ម្ចាស់បំណុលត្រូវតែប្តឹងតុលាការ ក្នុងរយៈវេលាដូចមានសំដែងក្នុងមាត្រា ១៣៥០ ខាងលើនេះដើម្បីនឹងទារប្រាក់បំណុលនោះដែរបើមិនប្តឹងទេម្ចាស់បំណុលនេះក៏នឹងត្រូវផ្តស់សិទ្ធដូចគ្នា ។

នាកាលរយៈវេលាទាំងឡាយនោះកន្លងផុតទៅ, បន្ទុកដែលផ្ទុកលើអចលវត្ថុរបស់កូនបំណុលក៏ត្រូវលប់ចោលតាមល័ក្ខខណ្ឌដូចមានសំដែងក្នុងមាត្រាខាងលើនេះដូចគ្នា ។

**មាត្រា ១៣៥២** ៖ ទោះជាយ៉ាងណាក៏ដោយ, ក៏នម្ចាស់បំណុលមិនត្រូវឡើងជាកម្មសិទ្ធិករនៃអចលវត្ថុបញ្ចាំនោះពេញច្បាប់ឡើយ ។

ខ សន្យាឯណា, ដែលផ្ទុយនឹងបទបញ្ញត្តិនេះ, ត្រូវទុកជាមោឃៈនិងអាសារឥត ការ ។

**មាត្រា ១៣៥៣** ៖ កិច្ចសន្យានៃការបញ្ចាំគ្រាន់តែបើកឲ្យម្ចាស់បំណុលមានសិទ្ធិត្រឹមតែប្ដឹងឲ្យដកកម្មសិទ្ធិ នៃអចលវត្ថុនោះយកមកលក់សងខ្លួនដែលជាអ្នកមានឯកសិទ្ធិ និង បុរិមាមុនម្ចាស់បំណុលដទៃទៀតតែប៉ុណ្ណោះ ។

ប្រសិនបើ, ក្នុងរយៈពេលដែលអចលវត្ថុនោះនៅជាប់ក្នុងកិច្ចសន្យាបញ្ចាំហើយ, អ្នកទទួលបញ្ចាំទិញដីដែលនៅនឹងដៃខ្លួន, ឬមិននៅនឹងដៃខ្លួនទេ, កិច្ចសន្យាលក់នោះត្រូវធ្វើតាមរូបមន្តដូចមានរំឭកមកក្នុងមាត្រា ១៣៤៥ វគ្គទី២ នៃក្រមនេះទើបបាន ។

**មាត្រា ១៣៥៤** ៖ អ្នកទទួលបញ្ចាំត្រូវប្រើប្រាស់នូវអចលវត្ថុនោះដោយយកចិត្តទុកដាក់ដូចគ្នានឹងផលុភោគគីដែរគឺថាត្រូវទុកខ្លួនស្មើមេបាដ៏ប្រពៃនៃគ្រួសារ ។ ម្ចាស់បំណុលត្រូវថែទាំនឹងរក្សានូវអចលវត្ថុនោះគង់ល្អ, បើវត្ថុនោះខូចខាតព្រោះអំពើរបស់ខ្លួន ឬក៏ព្រោះកំហុសរបស់ខ្លួន, ខ្លួននឹងត្រូវមានទោសឲ្យសងតម្លៃដែលខូចខាតនោះដោយកាត់ប្រាក់ក្នុងបំណុលខ្លួនបាន ។

**មាត្រា ១៣៥៥** ៖ នៅពេល ដែលផុតកិច្ចសន្យា ដោយសារកូនបំណុលសងប្រាក់អស់ហើយ ឬក៏ដោយសារខ័យសក្កិក្តី, អ្នកទទួលបញ្ចាំត្រូវទុកបង្វិលទៅកូនបំណុលវិញនូវអចលវត្ថុ ឬតម្លៃអចលវត្ថុនោះប្រសិនបើវាអន្តរាយព្រោះកំហុសរបស់ខ្លួន ។

**មាត្រា ១៣៥៦** ៖ នាកាលដែលកំណត់ក្នុងកិច្ចសន្យានោះត្រូវផុត ហើយកូនបំណុលមកសុំលោះវត្ថុគេវិញ, តែអ្នកទទួលបញ្ចាំមិនព្រមឲ្យលោះ, អ្នកនេះត្រូវជំពាក់ផល និងផលទុននៃកូនបំណុលវិញតាំងពីថ្ងៃដែលគេសុំលោះមក ។

**មាត្រា ១៣៥៧** ៖ ក៏ប៉ុន្តែបើកិច្ចសន្យានោះមិនបានចែងឲ្យច្បាស់លាស់ពីថ្ងៃកំណត់សងទេ, ម្ចាស់បំណុលនោះតែមានសិទ្ធិយកផល និងផលចម្រូត, ទោះជាប់នៅដើមក្តី, ទោះបានបេះ, ប្រលះ, ច្រូតកាត់, ទុកដាក់ហើយក្តី, ដែលជាផល កើតមកពីការយកចិត្តទុកដាក់របស់ខ្លួន, ពីថ្លៃដៃរបស់ខ្លួននិងប្រាក់កាសរបស់ខ្លួនចេញចាយទៅ ។

**មាត្រា ១៣៥៨** ៖ ការប្រាក់ត្រូវលែងមានតាំងពីថ្ងៃដែលកូនបំណុលសុំសងប្រាក់ វិញ។

ការស្នើសុំសងនេះត្រូវប្រាប់ឲ្យច្បាស់ថាសុំសងប៉ុន្មានហើយការស្នើនោះត្រូវកត់ក្នុងលិខិតមួយដែលមេឃុំត្រូវចុះហត្ថលេខាខ្លួនជាមួយនឹងកូនបំណុលនិងសាក្សីពីរនាក់ផង ។

បើកូនបំណុលចង់សងក្នុងកណ្ដាលឆ្នាំមុនរដូវចម្រូត, កូនបំណុលនេះត្រូវសងការប្រាក់ក្នុងឆ្នាំនោះ ហើយការនោះត្រូវយកតាមអត្រាដែលមានសំដែងហើយក្នុងក្រមនេះ ។

**មាត្រា ១៣៥៩** ៖ ការបង់ពន្ធត្រូវទុកជាបន្ទុកលើកូនបំណុលប្រសិនបើកិច្ចសន្យានោះមិនបានប្ដេជ្ញាថាដូចម្ដេចទេ ។

**មាត្រា ១៣៦០** ៖ កាលបើកំដឹងបានសង បំណុលដែលបញ្ចាំអចលវត្ថុហើយ, ម្ចាស់បំណុលមិនអាចនឹងឃាត់អចលវត្ថុនោះទុកតទៀតដោយអាងហេតុថាកូនបំណុលនៅជំពាក់បំណុលមួយទៀតបានឡើយ ទោះបំណុលក្រោយនោះដល់កំណត់ត្រូវទារក្ដី, ប្រសិនបើគ្មានកិច្ចសន្យាបញ្ចាំមួយជាថ្មីទៀតនិយាយថាបញ្ចាំដីដដែលនេះ និងបានធ្វើតាមរូបមន្តនៃកិច្ចសន្យាមុនទេ ។

**មាត្រា ១៣៦១** ៖ កូនបំណុលអាចយកសិទ្ធិខាងលើនេះទៅប្រើប្រាស់លើទាយាទ ឬលើសិទ្ធិវន្ត នៃម្ចាស់បំណុលបាន ។

**មាត្រា ១៣៦២** ៖ សិទ្ធិខាងលើនេះក៏ជារបស់ទាយាទនៃកូនបំណុល ឬសិទ្ធិវន្តនៃកូនបំណុលព្រមទាំងសមាជិកនៃគ្រួសារដែលអាចស្រដីថា ខ្លួនជាសហកម្មសិទ្ធិនៃវត្ថុបញ្ចាំនោះដែរ ។

## ចំពូកទី ៣
## ហ៊ីប៉ូតែក

**មាត្រា ១៣៦៣** ៖ ហ៊ីប៉ូតែក ជាប្រាតិភោគប្រត្យ័ក្ស ដែលបើកឲ្យម្ចាស់បំណុលប្ដឹង, នៅវេលដែលដល់កំណត់សងហើយ, សុំឲ្យលក់អចលវត្ថុនោះ, ទោះ

នៅលើដែនរណាក្តី, ដើម្បីយកប្រាក់សងខ្លួនជាអ្នកមានឯកសិទ្ធិ និងបុរិមាជាង ម្ចាស់បំណុលឯទៀតដោយគ្មានដកអចលវត្ថុនោះពីកម្មសិទ្ធិករទេ ។

**មាត្រា ១៣៦៤** ៖ មានតែអចលវត្ថុអ៊ីម៉្មាទ្រីគុឡាស្បុងទេទើបអាចដាក់ ហ៊ីប៉ូតែកបាន ។

**មាត្រា ១៣៦៥** ៖ (ក្រ ៩១០ ន.ស ៤.១១.៥៤) ហ៊ីប៉ូតែកជាកិច្ចសន្យាដែល ត្រូវប្រតិបត្តិតាមល័ក្ខខណ្ឌនៃច្បាប់បារាំង ដែលស្តីពីធ្វើបែបណាដែលទុកថាត្រឹម ត្រូវគឺថាត្រូវធ្វើនៅសារការីបើមិនដូច្នោះទេត្រូវទុកជាមោឃៈជាដាច់ខាត ។

# សារធាននៃក្រមរដ្ឋប្បវេណី

## មាតិកា ប្រាវ៣

## អំពីច្បាប់ទាំងឡាយនិងអនុភាពនៃច្បាប់មាត្រា ១ ដល់១៩

### គន្ថី ទី១

### អំពី បុគ្គល


មាតិកា ទី ១ - អំពីសិទ្ធិស៊ីវិល ២០- ៧៣

ចំពូក ១ - អំពីសញ្ជាតិ ២១ - ២៧

- ១ - ស្ទួន អំពីសញ្ជាតូបនីយកម្ម

- ២ - អំពីអត្រានុកូលដ្ឋាន (ភាពស៊ីវិល) ២៨ - ៤៨

ផ្នែកទី ១ - អំពីសញ្ញាប័ត្រកំណើត ៤៩ - ៥៤

- ២ - អំពីមរណភាពសញ្ញាប័ត្រ ៥៥ - ៥៩

- ៣ - អំពីអាពាហ៍ពិពាហ៍សញ្ញាប័ត្រ ៦០ - ៧០

- ៤ - អំពីបទបញ្ញត្តិពិសេស ៧១ - ៧៣

មាតិកា ទី ២ - អំពីលំនៅស្ថាន ៧៤ - ៨៦

- ៣ - អំពីបាត់ខ្លួន ឬអវត្តមាន ៨៧ - ១០៥

- ៤ - អំពីគ្រួសារ ១០៦ - ៣៥៧

ចំពូក ១ - អំពីកំជាប់ពាក្យ ១០៦ - ១១៣

- ២ -អំពីអាពាហ៍ពិពាហ៍ ១១៤ - ២០២

ផ្នែកទី ១ - អំពីល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីរៀប

អាពាហ៍ពិពាហ៍ ១១៤ - ១៤៧
- ២ - អំពីបណ្ដឹងទាស់ ១៤៨- ១៧៨
- ៣ - អំពីមោឃភាព ១៧៩ - ១៨៦
- ៤ - អំពីករណីកិច្ចនៃប្ដីប្រពន្ធ ១៨៧ - ២០២
ចំពូក ៣ - អំពីលែងគ្នា ២០៣ - ២៥៩
ផ្នែកទី ១ - អំពីបទបញ្ញត្តិទូទៅ ២០៣ - ២១១
- ២ - អំពីនីតិវិធីនៃការលែងគ្នា ២១២ - ២៤២
- ៣ - អំពីអនុភាពនៃការលែងគ្នា ២៤៣ - ២៥៩
ចំពូក ៤ - អំពីបុត្តភាព ២៦០ - ៣១៤
ផ្នែកទី ១ - អំពីបុត្តភាពនៃកូនមានខាន់ស្លា ២៦៤ - ២៧៨
- ២ - អំពីបុត្តភាពនៃកូនឥតខាន់ស្លា ២៧៩ - ២៨៨
- ៣ - អំពីធម្មានុរូបកម្មនៃកូនឥតខាន់ស្លា ២៨៩ - ២៩៦
- ៤ -អំពីការស្វែងរកបុត្តភាពឥតខាន់ស្លា ២៩៧ - ៣១៤
ចំពូក ៥ - អំពីសុំកូន ៣១៥ - ៣៣៤
ចំពូក ៦ - អំពីអំណាចមេបា ៣៣៥ - ៣៥៧
ផ្នែកទី ១ - អំពីសិទ្ធិឃុំឃាំង ៣៤១ - ៣៤៨
- ២ - អំពីសិទ្ធិដាក់ទណ្ឌកម្ម ៣៤៩ - ៣៥០
- ៣ - អំពីសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ ៣៥១ - ៣៥៧
មាតិកា ទី ៥ - អំពីអសមត្ថភាព ៣៥៨ - ៤៧៦

ចំពូក ១ - អំពីអនីតិភាព ៣៥៨ - ៤២៨

ផ្នែក ទី ១ - អំពីអំណាចព្យាបាលពីកំណើត ៣៦៦ - ៣៧០

- ២ - អំពីការប្រគល់អំណាចព្យាបាលតាមឪពុកម្ដាយរើសឲ្យ ៣៧២ - ៣៧៤

- ៣ - អំពីការប្រគល់អំណាចព្យាបាលតាមច្បាប់រើសឲ្យកូន មានខាន់ស្លា ៣៧៥ - ៣៧៨

- ៤ - អំពីការប្រគល់អណាចព្យាបាលតាមក្រុមប្រឹក្សាញាតិរើសឲ្យ ៣៧៩ - ៣៨៤

- ៥ - អំពីអំណាចព្យាបាលលើកូនឥតខាន់ស្លា ៣៨៥ - ៣៨៨

- ៦ - អំពីអំណាចព្យាបាលលើក្មេងដែលគេបោះបង់ ៣៨៩ - ៣៩១

- ៧ - អំពីហេតុដែលគប្បីឲ្យរួចអំពីការទទួលអំណាចព្យាបាល ៣៩២ - ៣៩៩

- ៨ - អំពីល័ក្ខខណ្ឌនៃសមត្ថភាពដើម្បីទទួលអំណាចព្យាបាល ៤០០ - ៤០៦

ផ្នែក ទី៩ - អំពីកាតព្វកិច្ច និងសិទ្ធិអាណាព្យាបាល ៤០៧ - ៤២៨

ចំពូក ២ - អំពីអត្តាធីនភាព ៤២៩ - ៤៤៦

- ៣ - អំពីអំណាចព្យាបាលលើជនគំហាត ៤៤៧ - ៤៧៦

ផ្នែកទី ១ - អំពីគំហាត់ស៊ីវិល ៤៤៩ - ៤៦៧

- ២ - អំពីគំហាត់ព្រហ្មទណ្ឌ ៤៦៨ - ៤៧៣

- ៣ - អំពីមុខការហិតូបត្ថម្ភក់លើមនុស្ស
ខ្វះខ្ចាយលើមនុស្សខ្សោយសតិលើមនុស្សពិការ
និងលើមនុស្សស្រវឹងខ្ជួប ៤៧៤ - ៤៧៦

មាតិកា ទី ៦ - អំពីសិទ្ធិ និងកាតព្វកិច្ចទាំងឡាយលើបេតិបភណ្ឌ
ក្នុងគ្រួសារ - ៤៧៧

ចំពូក ទី ១ - អំពីអាហារកាតព្វកិច្ច ៤៧៨ - ៤៨៥

- ២ - អំពីបទបញ្ញត្តិស្ដីពីសន្តតិកម្ម ៤៨៦ - ៤៩២

- ៣ - អំពីសន្តតិកម្មឥតបណ្ដាំ - ៤៩៣

ផ្នែក ទី ១ - អំពីលំដាប់នៃការផ្ទេរសន្តតិកម្ម ៤៩៤ - ៥០៣

- ២ - អំពីសិទ្ធិនៃសហាពទ្ធដែលរស់នៅ ៥០៤ - ៥០៥

**កថាខណ្ឌទី ១** - អំពីសិទ្ធិប្រពន្ធខាន់ស្លាទី១ជាមេផ្ទះ ៥០៦ - ៥១៤

- ២ - អំពីសិទ្ធិប្រពន្ធដើមមានខាន់ស្លា
ឥតកូន ៥១៣ - ៥១៧

- ៣ - អំពីសិទ្ធិនៃប្រពន្ធចុងមានខាន់ស្លា ៥១៨ - ៥២២

ចំពូក ៤ - អំពីសន្តតិកម្មមានបណ្ដាំ ៥២៣ - ៥៧៧

ផ្នែកទី ១ - អំពីបទបញ្ញត្តិទូទៅ ៥២៣ - ៥៣០

- ២ - អំពីសមត្ថភាពនៃអ្នកផ្ដាំ ៥៣១ - ៥៣៥

- ៣ - អំពីភាគបំរុងនិងភាគទំនេរ ៥៣៦ - ៥៤១

- ៤ - សេចក្ដីកាត់កាល ៥៤២ - ៥៤៦

- ៥ - អំពីសមត្ថភាពដែលនឹងទទួលទ្រព្យបណ្ដាំ ៥៤៧ - ៥៥៣

- ៦ - អំពីទំនងនៃសំបុត្របណ្ដាំ ៥៥៤ - ៥៦១

- ៧ - អំពីបដិសេធនៃបណ្ដាំ ៥៦២ - ៥៦៩

- ៨ - អំពីអច្ច័យទាន ៥៧០ - ៥៧៧

ចំពូក ៥ - អំពីការកាន់យកនូវមត៌ក ៥៧៨ - ៦២៦

ផ្នែកទី ១ - អំពីវិធានការដែលត្រូវចាត់ឲ្យរក្សាទុកនូវ

បេតិកភណ្ឌ ៥៧៨ - ៥៨២

- ២ - អំពីការព្រមនិងមិនព្រមទទួលយកមត៌ក ៥៨៣ - ៥៩២

- ៣ - អំពីការជំរះនិងការចែកមត៌ក ៥៩៣ - ៦២៦

## គន្ថីទី ២

## អំពីទ្រព្យ ៦២៧ - ៧៨៨

មាតិកា ទី១ - បទបញ្ញត្តិទូទៅនិងអំពីការវែកញែកនូវទ្រព្យ ៦២៨ - ៦៤៣

- ២ - អំពីកម្មសិទ្ធិ ៦៤៤ - ៧៨៨

ចំពូកទី១ - អំពីសិទ្ធិដំណោះ ៦៤៧ - ៦៦៤

ផ្នែកទី ១ - អំពីសិទ្ធិដំណោះដែលកើតអំពីវត្ថុ ៦៤៧ - ៦៤៨

- ២ - អំពីសិទ្ធិដំណោះលើអ្វីដែលជាប់និងដែលនាំ

ផ្សំគ្នានឹងវត្ថុ ៦៤៩ - ៦៦៤

**កថាខណ្ឌទី** ១ - អំពីសិទ្ធិដំណោះដែលដុះជាប់នឹងអចលវត្ថុ ៦៥០ - ៦៦២

- ២ - អំពីសិទ្ធិដំណុះដែលដុះជាប់នឹងចលវត្ថុ ៦៦៣ -៦៦៤
ចំពូក ទី ២ - អំពីសហកម្មសិទ្ធិ ៦៦៥ - ៦៧៣
- ៣ - អំពីអឌ្ឍសិទ្ធិភាព ៦៧៤ - ៦៨៤
ផ្នែកទី ១ - អំពីជញ្ជាំងអឌ្ឍសិទ្ធិ ៦៧៥ - ៦៨១
- ២ - អំពីស្នាមភ្លោះរបងភ្លឺអឌ្ឍសិទ្ធិ ៦៨២ - ៦៨៤
ចំពូក ទី ៤ - អំពីទ្រព្យវត្ត ៦៨៥ - ៦៨៧
- ៥ - អំពីលទ្ធកម្មនូវកម្មសិទ្ធិ និងអំពីការផ្ទេរ
នូវកម្មសិទ្ធិ ៦៨៨ - ៧០៧
ផ្នែកទី ១ - អំពីលទ្ធកម្ម និងការផ្ទេរនូវកម្មសិទ្ធិអចលវត្ថុ និងសិទ្ធិ
ប្រត្យ័ក្សអចលវត្ថុ ៦៨៩ - ៦៩២
- ២ - ព្រះរាជក្រមលេខ ២៦៤ ន.ស ២០-២-៥៨
- ៣ - អំពីលទ្ធកម្មនិងអំពីការផ្ទេរនូវកម្មសិទ្ធិចលវត្ថុ ៦៩៣ - ៧០៧
មាតិកា ទី ៣ - អំពីពាមានវត្ថុ ឬភោគៈ ៧០៨ - ៧២៥
- ៤ - អំពីអវយវភេទនៃកម្មសិទ្ធដែលមិនមែនជា
ប្រាតិភោគប្រត្យ័ក្ស ៧២៦ - ៧៨៨
ចំពូកទី ១ - អំពីផលុភោគ ៧២៧- ៧៥៤
ផ្នែកទី ១ - អំពីសិទ្ធិផលុភោគី ៧២៩ - ៧៣៧
- ២ - អំពីកាតព្វកិច្ចនៃផលុភោគី ៧៣៨ - ៧៤៨
- ៣ - ផលុភោគត្រូវចប់ត្រឹមណា ៧៤៩ - ៧៥៤

ចំពូក ទី ២ - អំពីសិទ្ធិប្រើប្រាស់ និងអាស្រ័យនៅ　　៧៥៥ - ៧៥៩

- ៣ - អំពីសេវភាព　　៧៦០ - ៧៨៨

ផ្នែកទី ១ - អំពីសេវភាពធម្មជាតិ　　៧៦២ - ៧៦៤

- ២ - អំពីសេវភាពរបស់ច្បាប់　　៧៦៥ - ៧៧៨

**កថាខណ្ឌទី ១** - អំពីសេវភាពរបស់ច្បាប់ បំរើសាធារណ ប្រយោជន៍　　- ៧៦៦

- ២ - អំពីសេវភាពរបស់ច្បាប់បំរើប្រយោជន៍ ឯកជន　　៧៦៧ - ៧៧៨

ផ្នែកទី ៣ - សេវភាពដែលមនុស្សបង្កើត　　៧៧៩ - ៧៨៨

កថាខណ្ឌទី១ - អំពីសេវភាពទាំងឡាយកើតឡើងយ៉ាង ដូចម្តេច　　៧៨០ - ៧៨១

- ២ - អំពីល័ក្ខខណ្ឌដែលត្រូវប្រើប្រាស់សេវភាព ទាំងឡាយ　　៧៨២ - ៧៨៧

- ៣ - អំពីសេវភាពរលត់ទៅវិញដោយរបៀបណា　　-៧៨៨


## គន្ថីទី ៣

## អំពីកាតព្វកិច្ច


មាតិកាទី ១ - អំពីបទបញ្ញត្តិទូទៅ　　៧៨៩ - ៩៣៥

ចំពូក ទី ១ - ប្រភពនៃកាតព្វកិច្ចទាំងឡាយ　　៧៩០ - ៨៣៤

ផ្នែកទី ១ - អំពីកាតព្វកិច្ចដោយប្តេជ្ញា　　៧៩១ - ៨១១

កថាខ័ណ្ឌទី១ - អំពីសុពលភាពនៃសេចក្តីប្តេជ្ញាទាំងឡាយ ៧៩៣ - ៨០៥

កថាខណ្ឌទី ២ - អានុភាពនិងការបកស្រាយនៃសេចក្តីប្តេជ្ញា ៨០៦ - ៨១១

ផ្នែកទី ២ - កាតព្វកិច្ចកើតអំពីធ្វើឲ្យមានព្យសនកម្ម ៨១២ - ៨១៨

- ៣ - កាតព្វកិច្ចកើតអំពីចំរើនឥតហេតុ ៨១៩ - ៨២៦

កថាខណ្ឌទី ១ - អំពីការសងប្រាក់ដែលគ្មានជំពាក់ ៨១៩ - ៨២៤

- ២ - អំពីការគ្រប់គ្រងដោយឈឺឆ្អាល ៨២៤ - ៨២៦

ផ្នែកទី ៤ - អំពីកាតព្វកិច្ចកើតអំពីច្បាប់ ៨២៧ - ៨៣៤

ចំពូក ២ - អំពីងអានុភាពនៃកាតព្វកិច្ច ៨៣៥ - ៨៥៩

ផ្នែកទី ១ - អំពីសេចក្តីទូទៅ ៨៣៥ - ៨៤៣

- ២ - អំពីសិទ្ធិនៃម្ចាស់បំណុល ៨៤៤ - ៨៥៩

ចំពូក ទី ៣ - អំពីបែបយ៉ាងនៃកាតព្វកិច្ច ៨៦០ - ៨៨៦

ផ្នែកទី ១ - អំពីកាតព្វកិច្ចមានល័ក្ខខណ្ឌ ៨៦០ - ៨៦៤

- ២ - អំពីកាតព្វកិច្ចមានកំណត់កាល ៨៦៥ - ៨៦៧

- ៣ - អំពីកាតព្វកិច្ចអនិយ័ត ៨៦៨ - ៨៧១

- ៤ - អំពីកាតព្វកិច្ចដោយសាមគ្គីភាព ៨៧២ - ៨៨៤

កថាខណ្ឌទី ១ - អំពីសាមគ្គីភាពរវាងម្ចាស់បំណុល ៨៧៣ - ៨៧៧

- ២ - អំពីសាមគ្គីរវាងកូនបំណុល ៨៧៨ - ៨៨៤

ផ្នែកទី ៥ - អំពីសាមគ្គីភាពអវិភាគ័យ ៨៨៥ - ៨៨៦

ចំពូក ទី ៤ - អំពីការរលត់នៃកាតព្វកិច្ច ៨៨៧ - ៩៣៥

ផ្នែកទី ១ - អំពីការប្រតិបត្តិនូវកាតព្វកិច្ច ៨៨៨ - ៩០៦
- ២ - អំពីកាតព្វកិច្ចដែលមិនអាចប្រតិបត្តិកើត - ៩០៧
ផ្នែកទី ៣ - អំពីផាត់វត្ថុដទៃឲ្យជាសំណង ៩០៨ - ៩០៩
- ៤ - អំពីការលើកកាតព្វកិច្ចចោលដោយចេតនា ៩១០ - ៩១២
- ៥ - អំពីនវកម្ម ៩១៣ - ៩១៩
- ៦ - អំពីការទូទាត់ ៩២០ - ៩២៥
- ៧ - អំពីព្យាកុលភាព ៩២៦ - ៩២៧
- ៨ - អំពីអាជ្ញាយុកាល ៩២៨ - ៩៣៥
មាតិកា ទី ២ - អំពីបន្ទាល់នៃកាតព្វកិច្ច ៩៣៦ - ១០១៦
ចំពូក ទី ១ - អំពីបន្ទាល់ដោយប័ណ្ណ ៩៣៩ - ៩៨៨
ផ្នែកទី ១ - អំពីលិខិតបញ្ជាក់ ៩៤៤ - ៩៦៨
- ២ - អំពីលិខិតឯកជន ៩៦៩ - ៩៨៧
- ៣ - អំពីសៀវភៅជំនួញ - ៩៨៨
ចំពូក ទី ២ - អំពីបន្ទាល់ដោយសាក្សី ៩៨៩ - ៩៩៧
ចំពូក ទី ៣ - អំពីបែបផ្សេងៗទៀតនៃបន្ទាល់កាតព្វកិច្ច ៩៩៨ - ១០១៦
ផ្នែកទី ១ - អំពីចម្លើយសារភាព ៩៩៨ - ១០០២
- ២ - អំពីសបថ ១០០៣ - ១០០៧
- ៣ - អំពីការពិនិត្យដល់ទីកន្លែងនិងអំពីកោសល
វិច្ឆ័យ ១០០៨ - ១០១៦

មាតិកា ទី ៣ - អំពីកិច្ចសន្យាដែលតែងធ្វើជាហូរហែរ ១០១៧ - ១៣១០

ចំពូក ទី ១ - អំពីការលក់ ១០១៧ - ១០៧៩

ផ្នែកទី ១ - អំពីបទបញ្ញត្តិទូទៅ ១០១៧ - ១០២៤

- ២ - អំពីកាតព្វកិច្ចរបស់អ្នកលក់ ១០២៥ - ១០៦៨

កថាខ័ណ្ឌ ទី១ - អំពីការដែលអ្នកលក់ថែរក្សាវត្ថុទុក ១០២៦ - ១០២៩

- ២ - អំពីការប្រគល់ ១០៣០ - ១០៣៧

- ៣ - អំពីការផ្ទេរនូវកម្មសិទ្ធិ ១០៣៨ - ១០៤០

- ៤ - អំពីការធានាចំពោះវិការៈនៃវត្ថុ ១០៤១ - ១០៥០

- ៥ - អំពីការរ៉ាប់រងចំពោះការរំខាន និងចំពោះការ

ដកហូត ១០៥១ - ១០៦៨

ផ្នែកទី ៣ - អំពីកាតព្វកិច្ចនៃអ្នកទិញ ១០៦៩ - ១០៧៩

ចំពូក ទី ២ - អំពីការលក់បញ្ចាំ (ឬការលក់លោះវិញ) ១០៨០ - ១០៩៤

- ២ - ស្ទួន- អំពីកាតិការភេទនៃការលក់ (ព្រះរាជប្រកាស

១០៥. ៦៦. ៣៩)

- ៣ - អំពីការដូរ ១០៩៥ - ១០៩៨

- ៤ - អំពីសន្យាជួល ១០៩៩ - ១១៩២

ផ្នែក ទី ១ - អំពីការជួលវត្ថុ ១១០២ - ១១៤៤

កថាខ័ណ្ឌ ទី១ - អំពីការជួលអចលវត្ថុ ១១០៣ - ១១៣៩

- ២ - អំពីការជួលចលវត្ថុ ១១៤០ - ១១៤៤

ផ្នែកទី ២ - អំពីការជួលការងារ ១១៤៥ - ១១៧៦
- ៣ - អំពីការជួលទុន ឬចងការ ១១៧៧ - ១១៩២
ចំពូក ទី ៥ - អំពីការខ្ចី ១១៩៣ - ១២១១
ផ្នែកទី ១ - អំពីការឲ្យខ្ចី វត្ថុប្រើ ១១៩៨ - ១២០៥
ចំពូក ទី ៦ - អំពីកិច្ចសន្យាសំខាន់ៗនៃការដឹកនាំ ១២១២- ១២៣០
- ៧ - អំពីកិច្ចសន្យាសហគ្រាស ១២៣១ - ១២៤៥
- ៨ - អំពីបញ្ញើ ១២៤៦ - ១២៥៧
- ៩ - អំពីវិសុណ្ឌាបនិក ១២៥៨ - ១២៦៧
- ១០ - អំពីអាណត្តិ ១២៦៨ - ១២៨៦
- ១១ - អំពីក្រុមហ៊ុន ១២៨៧ - ១២៩៤
- ១២ - អំពីប្រទានកម្ម ឬការឲ្យ ១២៩៥ - ១៣១០
ផ្នែកទី ១ - អំណោយ, ជំនូនបុបណ្ណាការ - ១២៩៧
- ២ - អំពីប្រទានកម្មផ្សេងៗទៀត ១២៩៨ - ១៣១០
មាតិកា ទី ៤ - អំពីកិច្ចសន្យាធានា ១៣១១ - ១៣៦៥
ចំពូក ទី ១ - អំពីធានាដោយបុគ្គល ១៣១៤ - ១៣២៧
- ២ - អំពីការបញ្ចាំ ១៣២៨ - ១៣៦២
ផ្នែកទី ១ - អំពីការបញ្ចាំចលវត្ថុ ១៣៣០ - ១៣៤៣
- ២ - អំពីការបញ្ចាំអចលវត្ថុ ១៣៤៤ - ១៣៦២
ចំពូក ទី ៣ - ហ៊ីប៉ូតែក ១៣៦៣- ១៣៦៥

# សន្ទានុក្រម

## ក, ខ, គ

**កតិកាភេទ** ( rescission ) កិរិយាបដិសេធ កិច្ចសន្យា ណាមួយចោល ដោយមកពីកិច្ចសន្យានោះមានវិការៈ ដល់ឬសគល់នៃការព្រមព្រៀងគ្នា ។ ក្នុងទីនេះកតិកាភេទ បាននៃថា បដិសេធន៍ កិច្ចសន្យាលក់ចោល ដោយមកពីវត្ថុណាមួយថោកជាងពាក់កណ្តាលថ្លៃ នៃថ្លៃមែនទែន ។

**ការជំរះមត៌ក** ( liquidation des successions ) កិរិយាធ្វើបញ្ជីទ្រព្យសម្បត្តិរបស់ខ្មោចឲ្យដឹងថាវានៅសល់ប៉ុន្មាន បាត់ប៉ុន្មានដើម្បីនឹងចែកគ្នារវាងទាយាទ និងទាយាទ ។

**កាត់កាល់** ( exhereder ) បដិសេធជនណាម្នាក់ ឬ ច្រើននាក់មិនឲ្យមានសិទ្ធិទទួលមត៌កនៃខ្មោច ។

**កាយវិកលកម្ម** ( multiliation ) ការធ្វើឲ្យបាត់បង់ ឬឲ្យពិការនូវអវៈយវៈណាមួយនៃកាយ ។

**ការទូទាត់** ( compensation ) ការយកចំនេញមកបំពេញការខាត ។ ក្នុងច្បាប់ ជនពីនាក់មានជាប់កាតព្វកិច្ចគ្នាទៅវិញទៅមក ហើយកាត់កងគ្នា មិនឲ្យជំពាក់គ្នាទៅវិញទៅមក ។ ឧ. ឈ្មោះ ក ជំពាក់តុងទីន ឈ្មោះ ខ ២ ម៉ឺនរៀលក៏

ប៉ុន្តែឈ្មោះមួយ ត្រូវនៅជំពាក់ការសងផ្ទះឱ្យឈ្មោះ ក ដែរ ។ លុះពីរនាក់នេះ គិតឃើញថា បំណុលខ្លួនល្មមកាត់កងគ្នាបាន ក៏សុខចិត្តព្រមទូទាត់គ្នាមិនឱ្យជំពាក់គ្នាទៅវិញទៅមក ។

**ការ្យ** ( Ouvrage ) = ផលអ្វីទាំងពួង ដែលកើតមកពីស្នាដៃជាង ឬ ពីស្នាដៃសិល្បករ លទ ។ ឧ. តុ ទូ ជាការ្យរបស់ជាង ឯប្រលោមលោកជាការ្យរបស់អ្នកនិពន្ធ ។

**កើយ** ( Balcon ) រានហាលតូចគ្មានសរសរទ្រពីក្រោមទេតែមានបង្កាន់ដៃព័ទ្ធជុំវិញ ។

**កោសលវិច្ឆ័យ** ( Expertise ) សេចក្តីវាយការណ៍របស់អ្នកជំនាញការដែលតុលាការ ឬ ចៅក្រមចាត់ឱ្យធ្វើ ។

**កំជាប់ព្រលឹង** ( Indemniser ) ឱ្យសំណងចិត្ត ឬ សងសោហ៊ុយដែលខូចខាត ។

**កំដឹង ឬកូនបំណុល** ( Debiteur ) ជនអ្នកជំពាក់ប្រាក់ ឬ ជំពាក់កាតព្វកិច្ចគេ ។ បូរាណប្រើពាក្យកំដឹងនេះ ជាមួយនឹងពាក្យកំដរ ។ ឧ. អ្នកឯងជាកំដឹង ឬ ជាកំដរគេ ? ។

**កំណត់ដៃ** ( Extait ) សេចក្តីស្រង់ ឬលិខិតដែលចម្លងយកតែសេចក្តីសំខាន់ពីអត្ថបទ ឬ ពីលិខិតណាមួយ ។ ឧ. កំណត់ដៃបញ្ជីជាតិ ។

**កំពែង** ( Cloture ) គូ ស្នាមភ្លោះ របង ភ្លឺស្រែ ។

**ក្រាន** ( Foyer ) សម័យបូរាណកន្លែងដែលគេដុតភ្លើងសម្រាប់អាំង ឬសម្រាប់ចំអិនអាហារនៃគ្រួសារសម័យឥឡូវនេះកន្លែងជាទីនៃគ្រួសារ ។

**ខ័យសក្តិ** ( Forelusion ) ការអស់ទៅនៃសិទ្ធិប្តឹងផ្តល់ ដល់តុលាការដោយហេតុថារយៈពេលដែលច្បាប់ឲ្យអំណាចប្តឹងបាននោះកន្លងផុតអស់ទៅ ។

**ខ្ទាត់** ( Frais de justice ) ប្រាក់ប្រដាប់ក្តី ។

**គណនី** ( Comples ) ការវាយតម្លៃនៃចំនួនអ្វីមួយ ។ បញ្ជីដែលកត់បំណុល ឬ ដែលកត់សំណង ។

**គំហាត់ ( ជន-- )** Interdit កិរិយាឃាត់ មិនឲ្យធ្វើអ្វីមួយ ។ ជនគំហាត់គឺជនអ្នកមានសតិប្រាជ្ញាទន់ខ្សោយ ល្ងីល្ងើ ឬមានទោសខាងអាជ្ញា ដែលច្បាប់អាជ្ញា ឬច្បាប់ស៊ីវិលឃាត់មិនឲ្យមានសេរីភាពក្នុងការគ្រប់គ្រងសម្បត្តិទ្រព្យខ្លួន ។

## ច, ឆ, ជ

**ចាត់តាំង** ( Designer ) ជ្រើសរើសជនណាម្នាក់ ហើយបញ្ជាឲ្យកាន់មុខការ ឬ មុខងារណាមួយ ។

**ឆន្ទានុសិទ្ធិ** ( Pouvoir discretionaire ) អំណាចដែលប្រគល់ដល់ចៅក្រមឲ្យរើសយកមធ្យោបាយណាមួយតាមចិត្តខ្លួនមកដោះស្រាយបញ្ហាណាមួយ ។

**ជនតា** ( Gerneration ) ពួកជន ដែលកើតមួយជំនាន់ៗ ។

**ជីវព្រឹត្តិ** ( Substance ) អាហារ ម្ហូបចំណី សម្លៀកបំពាក់ ។

## ដ

**ដំណុះ ( សិទ្ធិ--- )** Droit d"accession ដំណុះ= អ្វីៗដែលដុះដែលកើតពីវត្ថុអ្វីមួយ ។ សិទ្ធិដំណុះ= សិទ្ធិលើអ្វីទាំងពួងដែលដុះ ឬដែលកើតពីវត្ថុ ឬអំពីសត្វដែលជាទ្រព្យរបស់ខ្លួន ។ ឧ. ម្ចាស់ដីមានសិទ្ធិត្រូវបានដើមឈើ ដែលដុះក្នុងដីរបស់ខ្លួនម្ចាស់មេគោត្រូវបានកូនគោដែលកើតអំពីមេគោខ្លួន ។ សិទ្ធិរបស់ម្ចាស់ដី, ម្ចាស់គោនោះហៅថា សិទ្ធិដំណុះ ។

## ត,ថ,ទ,ធ,ន

**តក្កកម្ម** ( Invention ) កិរិយាបង្កើតវត្ថុមួយថ្មី មុនអ្នកទាំងពួង ។ អ្នកដែលបង្កើតម៉ាស៊ីនដេរមុនគេឈ្មោះ ធី ម៉ុន្នីអេ ដូច្នេះម៉ាស៊ីនដេរជាតក្កកម្មរបស់ធី ម៉ុន្នីអេ ។

**តតិយជន** ( Tier, Tierce ) ជនទីបី ឬភាគទីបីក្នុងរឿង ។ អ្នកដទៃ ឬ អ្នកក្រៅ ។ ឧ. អ្នកលក់ និងអ្នកទិញ ជាភាគីទី១ , ទី២ក្នុងការលក់វត្ថុណាមួយ, ឯអ្នកដទៃ ដែលចូលមកក្នុងការលក់នេះដែរហៅថាតតិយជន ។

**តាវកាលិក** ( Prestation ) វត្ថុជាទីតាំង នៃកាតព្វកិច្ចណាមួយ ។ ឧ. ស្រូវដែលជនម្នាក់ ខ្ចីពីជនម្នាក់ទៀតហៅ តាវកាលិកនៃការខ្ចី ។

**តិថី** ( Quantum ) ចំនួន ថ្ងៃ ឬខែ ឬឆ្នាំ ដែលវិលមកជួបគ្នាវិញ ។ ឧ. ពីថ្ងៃ៧រោច ខែចែត្រ មកដល់ ថ្ងៃ៧រោច ខែពិសាខ ហៅថាមួយខែ , ចំនួនថ្ងៃពី ៧ រោច ខែចែត្រ មក៧រោច ខែពិសាខ ហៅថាមួយតិថី ។

**តែងតាំង** ( Nommer ) ឲ្យមុខការ ឲ្យគុណភាព ។ ឧ. ឈ្មោះ ក បាន តែងតាំង ឈ្មោះ ខ ជាទាយាទរបស់ខ្លួន ។

**ផ្តាច់សញ្ជាតិ** ( Decheance de la nationalite ) លែង ឲ្យបាន សញ្ជាតិ ដែលបានហើយតទៅទៀត, ដកហូតយកសញ្ជាតិមកវិញ ។

**ទណ្ឌិត** ( Condemne ) ជនដែលតុលាការបានដាក់ទណ្ឌកម្មរួច ហើយ ។ ជនដែលកំពុងរងទណ្ឌកម្មរបស់តុលាការ ។

**ទាយាទ** ( Heritier ) អ្នកដែលច្បាប់តម្រូវឲ្យទទួលមត៌កពីជនណា ម្នាក់ ។ ឧ. កូនជាទាយាទរបស់ឪពុកម្ដាយ , ជីតាជីដូន ជាទាយាទ របស់ចៅ ដែលឥតគិតបច្ឆាញាតិជាតំណវង្ស ។

**ទាសភាព** ( Esclavage ) ភាពជាខ្ញុំបម្រើគេ ។

**ទាស់មុខស្នន់** ( Inceste ) យកញាតិឯង ដែលច្បាប់ហាមមកធ្វើជាប្ដី ប្រពន្ធ ។ ឧ. មា យកក្មួយធ្វើជាប្រពន្ធ ហៅថាទាស់មុខស្នន់ ។

**ទិដ្ឋាការ** ( Visa ) ហត្ថលេខា, ត្រាដែលបានចុះ បានបោះលើលិខិតណា មួយដើម្បីឲ្យលិខិតនោះមានតម្លៃពេញលក្ខណៈច្បាប់ ឬ ដើម្បីបញ្ជាក់ថាម្ចាស់ លិខិតបានបង់ពន្ធរួចហើយ ។

**ទុរាចា** ( Inconduite ) ការប្រព្រឹត្តិតែអំពើអាក្រក់, អបាយមុខ ។

**ធនលាភ** (Rente) ផលដែលផ្ដល់មកឲ្យរាល់ឆ្នាំ ដូចជាការប្រាក់ឈ្នួលដី ឈ្នួលផ្ទះជាដើម ។

**ធម្មានុរូប** ( Legitime ) ដែលមានគុណភាពជាអ្វីមួយតាមច្បាប់ ។ ចៅហ្វាយស្រុកជាអាជ្ញាធរធម្មានុរូប ។ កូនដែលកើតពីឪពុកម្ដាយមានខាន់ស្លា ហៅថាកូនធម្មានុរូប ឬកូនមានខាន់ស្លា ។

**ធម្មានុរូបកម្ម** ( Legitimation ) ការធ្វើជនគ្មានគុណភាពតាមច្បាប់ ឲ្យជាជនមានគុណភាពបរិបូណ៌តាមច្បាប់ ។ ការធ្វើកូនឥតខាន់ស្លាឲ្យជាកូនមានខាន់ស្លា ហៅថាធម្មានុរូបកម្ម ។

**នវកម្ម** ( Novation ) ការបង្កើតកាតព្វកិច្ចមួយថ្មី ដើម្បីយកទៅជំនួសកាតព្វកិច្ចចាស់ ។ ឧ. ការយកស្រែស្ពែងទៅដាក់បញ្ចាំជំនួសស្រែទួលដែលបញ្ចាំពីថ្ងៃមុនហៅថា នវកម្ម ។

**និទ្ទេស** ( Mention ) សេចក្ដីដែលចុះដោយសង្ខេបនៅលើរឹមទំព័រឬនៅចុងទំព័រនៃលិខិតណាមួយ ។

**និរាករ** ( Abroger ) លុបចោល, លែងឲ្យប្រើច្បាប់នោះតទៅទៀត ។

**នីតិបុគ្គល** ( Personne morale ) ក្រុមនៃមនុស្សដែលច្បាប់ទទួលស្គាល់ថាជាបុគ្គលដែរតែដទៃអំពីសមាជិកនៃខ្លួន ។ ឧ. ពុទ្ធិកសមាគមជានីតិបុគ្គល , ក្រុមហ៊ុនធ្វើស្ករក៏ជានីតិបុគ្គលដែរ ។

**នីតិភាព** ( Majorite ) អាយុដែលច្បាប់បើកឲ្យមានសិទ្ធិពេញបរិបូណ៌ ។ ឧ. នៅប្រទេសកម្ពុជាអាយុដែលត្រូវទុកជាអនីតិភាពគឺម្ភៃមួយឆ្នាំ ។

**នីតិវិធី** ( Procedure ) វិធីដែលតុលាការប្រើប្រាស់ ដើម្បីចាត់ចែងរឿងក្ដីតាំងពីដើមរហូតដល់ចប់ ។

**នីតិសម្បទា** ( Habilite ) សមត្ថភាព ដែលច្បាប់បើកឲ្យជនម្នាក់ៗ មានយ៉ាងគ្រប់គ្រាន់ ដើម្បីនឹងធ្វើកិច្ចការអ្វីមួយ ។ ឧ. ស្នងការប៉ូលិស (កុម្មិស្សែរ) មាននីតិសម្បទា នឹងធ្វើកំណត់ហេតុ អំពីបទល្មើសជាលហុ ដែលកើតមានក្នុងតម្បន់របស់ខ្លួន ។ ឧ. ជនអភ័ព្វមិនមាននីតិសម្បទានឹងទទួលមត៌កពីឪពុកម្ដាយឡើយ ។

**ប, ផ, ព, ភ, ម**

**បច្ឆាញាតិ ឬបច្ឆាជន** ( Descendants ) ជន ឬពួកជន ដែលកើតក្រោយជនមួយពួកទៀត ។ ឧ. កូន ជាបច្ឆាជនរបស់ឪពុកម្ដាយ ។

**បញ្ជីការ អិម្មាទ្រីគុឡាស្យុង** ( Registre Immatriculation ) សៀវភៅបញ្ជីរបស់ក្រសួងសុរិយោដីសម្រាប់កត់ត្រាដីកម្មសិទ្ធិ ។

**ប័ណ្ណ** ( Titre ) លិខិតដែលមានរូបមន្តយថាភូត (ដែលមានរូបភាព និងទម្រង់ត្រឹមត្រូវតាមច្បាប់ សម្រាប់បញ្ជាក់អំពីសិទ្ធិណាមួយ ។ ឧ. ដែលអ្នកផងហៅថាសន្លឹកផែនទី -- CI នោះជាប័ណ្ណនៃកម្មសិទ្ធិ ។

**បណ្ណសារដ្ឋាន** ( Archive ) ទីសម្រាប់តម្កល់លិខិតផ្សេងៗ ដែលមានសារៈសំខាន់ដូចបញ្ជីអត្រានុកូលដ្ឋានជាដើម ។

**បរិវត្ត** (រូបមន្ត---) Formule executoire រូបមន្តដែលមានសេចក្ដីថាឲ្យយកទៅសម្រេចបាន ។

**បាលិត** ( Pupille ) កូនកំព្រាជាអនីតិជនដែលឋិតនៅក្រោមអាណាព្យាបាលនៃជនណាម្នាក់ ។

**បិតុភាព** ( Paternite ) ក្រសែញាតិ ដែលទាក់ទងពីឪពុកទៅកូន ។

**បុត្តភាព** ( Filiation ) ក្រសែញាតិដែលទាក់ទងពីឪពុកម្ដាយទៅកូនបង្កើតរបស់ខ្លួន ។

**បុព្វញាតិ** ( Ascendants ) ពួកជនដែលកើតមុនជន មួយពួកទៀត ។ ឧ. ឪពុក ម្ដាយ ជីដូន ជីតា លÉ ជាបុព្វញាតិរបស់កូន ចៅ ចៅទួត ល...។

**បុរមា** ( Preference ) សេចក្ដីរាប់អាន ជននេះច្រើនជាងជននោះ ។ សិទ្ធិដែលបើកឲ្យជនណាម្នាក់បានអ្វីមួយមុនជនឯទៀត ។

**បេតិកភណ្ឌ** ( Patrimoine ) ទ្រព្យដែលជនម្នាក់ៗមាន និងបំណុលដែលជនម្នាក់ៗជំពាក់គេ ។ ទាំងទ្រព្យ ទាំងបំណុល របស់ជនម្នាក់ ហៅថាបេតិកភណ្ឌ ។

**ប្រកាសន:** ( Publicite ) កិរិយា ប្រកាសឲ្យសាធារណៈជនបានដឹងឮ ដោយវាចា ឬ ដោយលិខិតជាលាយលក្ខអក្សរ ។

**ប្រតិសកម្ម** ( retroactivite ) ការដែលមានអនុភាពបកទៅអតីតកាលវិញ ។

**ប្រធាន** ( Principal ) ដែលធំ ដែលសំខាន់ជាងគេ ដែលជាមេលើគេ ។

**ប្រវត្តិកាល** ( Peroide ) រដូវ ពេល វេលាដែលប្រព្រឹត្តិទៅក្នុងមួយរយៈ។ ពាក្យសមញ្ញច្រើននិយាយថាសម័យ ។ ឧ. សម័យដែលខ្មែរចម្រើនរុងរឿង ឬប្រវត្តិកាលនៃខ្មែររុងរឿង ។

**ប្រាតិភោគប្រត្យ័ក្ស** ( Surele reelle ) ការយកទ្រព្យទៅធានាបំណុល ។ ពាក្យបូរាណ ហៅថាកំជាប់ដោយវត្ថុ ។ ឧ. ការបញ្ចាំស្រែ ជាប្រាតិភោគប្រត្យ័ក្ស អចលនវត្ថុ ។ ការបញ្ចាំខ្សែមាសជាប្រាតិភោគប្រត្យ័ក្សចលនវត្ថុ ។

**ផលចម្រូត** ( Recolte ) ផលដែលច្រូត បេះ ប្រលេះ ដក ពីដីមក ។

**ផលទុន** ( Revenue ) ផល ឬចំនេញដែលកើតមកពីប្រាក់ទុន ឬ ប្រាក់ទុន ឬ ពីមូលនិធិដែលគេយកទៅប្រកបមុខរបរណាមួយ ។

**ផលធម្មជាតិ** ( Fruit naturel ) ផលិតផល ដែលកើតអំពីដីធ្លី ឬ កូនសត្វស្រុក ដែលកើតពីមេបាវាមក ។

**ផលស៊ីវីល** ( Fruit civil ) ប្រាក់ដែលកើតពីវត្ថុ ឬ ពីប្រាក់ដូចជាការប្រាក់ ឬ ឈ្នួលផ្ទះជាដើម ។

**ផលុបភោគ** ( Usufruit ) សិទ្ធិ បរិភោគ និងប្រើប្រាស់នូវផល និងផលទុនដែលកើតមកពីទ្រព្យជាកម្មសិទ្ធិអ្នកដទៃ ។

ឧ. ឈ្មោះ “ក” បានឲ្យស្រែមួយកន្លែង ជាកម្មសិទ្ធិរបស់ខ្លួនទៅឈ្មោះ “ខ” ធ្វើយកផល ចិញ្ចឹមជីវិត អស់មួយជីវិតក្តី អស់កាលមានកំណត់ក្តី ឥតយកឈ្នួលទេ ប៉ុន្តែដីនោះនៅជាដី របស់ឈ្មោះ “ក” ដដែល ។ សិទ្ធិដែល “ក” បើកឲ្យ “ខ” បរិភោគផលដីរបស់ខ្លួននោះ ហៅថា ផលុបភោគ ។ “ខ” គឺជាផលុបភោគី ហើយ “ក” ជាកម្មសិទ្ធិករ ។

**ផលុបភោគី** ( Usufruitier ) អ្នកបាន នូវផលុបភោគ អ្នកស៊ីផល ។

**ព្យសនកម្ម** ( Prejudice ) ការខូចខាត ឬសេចក្តីវិនាសអន្តរាយដល់រូបកាយក្តី ដល់សម្ភារៈក្តី ដល់ទឹកចិត្តក្តី ដែលបណ្តាលមកពីអំពើអ្នកដទៃ ។

**ព្យាកុលភាព** ( Confusion ) ភាពច្រឡំប្រឡូកគ្នា ។ ក្នុងទីនេះព្យាកុលភាពបានន័យថាមនុស្សម្នាក់ជាកូនបំណុលផងជាម្ចាស់បំណុលផងនៃជនតែម្នាក់ ។

**ព្រឹត្តិការណ៍** ( Evenement ) អ្វីៗ ដែលកើតមានឡើង ឬ ដែលប្រព្រឹត្តទៅ ។ ឧ. សង្គ្រាម រវាងអារ៉ាប់ និង អ៊ីស្រាអែលនាបច្ចុប្បន្ននេះជាព្រឹត្តិការណ៍មួយគួរអោយចង់ដឹង ។

**ភាគី** ( Partie ) គូក្តី គូសញ្ញា ជនម្ខាងៗ នៃកិច្ចសន្យា ។

**ភោគៈ** ( Possession ) សិទ្ធិដែលជនម្នាក់ៗ មានលើទ្រព្យណាមួយជាបណ្តោះអាសន្ន មិនទាន់ស៊ប់ជារបស់ខ្លួនមែនទែនទេ ។

“ភោគៈ” ជាពាក្យផ្ទុយនឹង “កម្មសិទ្ធិ” ដែលជាសិទ្ធិពេញបរិបូរណ៍របស់ជនម្នាក់ៗ លើទ្រព្យណាមួយ ។ ឧ. ដីផែនទី ជាដីកម្មសិទ្ធិ ឯដីគ្មានផែនទីគឺដីដែលមានតែចុងសន្លឹកជាភោគៈ ។

**មជ្ឈមណ្ឌល** ( Centre ) ទីផ្ចាកណ្តាល ។ ទីកន្លែង ដែលជាប្រធាននៃកិច្ចការទាំងពួង ។

**មធ្យោបាយ** ( Moyen ) អ្វីៗដែលជាគ្រឿងសម្រាប់យកទៅដោះស្រាយកិច្ចការ ឬ បញ្ហាណាមួយ ។

**មាតិកភណ្ឌ** ( Matrimonial ) អ្វីៗ ឬទ្រព្យ ដែលទាក់ទងក្នុងពេលអាពាហ៍ពិពាហ៍ ។

**វិសាលភាពនៃអាណត្តិ** ( Etendue mandat ) វិសាលភាព = ភាពទូលំទូលាយ ។ វិសាលភាព នៃអាណត្តិ = អំណាចនៃអាណត្តិ ។

**វិហិង្សា** ( Violence ) សេចក្តីឃោឃៅ ។

**ស, ហ**

**សញ្ជាតូបនីយកម្ម** ( Naturalisation ) ការធ្វើ ឲ្យជនបរទេសបាននូវសញ្ជាតិនៃប្រទេសដែលជននោះនៅ ។ ការសុំចូលជាតិ ។

**សទិសានុញ្ញាតិ** ( Homologation ) សេចក្តីយល់ព្រម របស់អាជ្ញាធររដ្ឋបាល ឬអាជ្ញាធរតុលាការ ចំពោះលិខិតណាមួយដែលត្រូវធ្វើតាមផ្លូវច្បាប់ ។

**សន្តតិកម្ម** ( Succession ) ការបញ្ជូនតាមផ្លូវច្បាប់ នូវទ្រព្យរបស់អ្នកស្លាប់ឲ្យទៅអ្នករស់ ។ មត៌ក ឬទ្រព្យរបស់ខ្មោចដែលត្រូវបានទៅទាយាទ ។

**សមគ្គសង្វាស** ( Union ) ការរួមរស់នៅរបស់ប្តីប្រពន្ធ ។

**សមត្ថកិច្ច** ( Competence ) សិទ្ធរបស់តុលាការ ដែលមានដើម្បីជំនុំជំរះរឿងក្តីណាមួយ ។

**សម្បត្តិសាធារណ នៃសមូហភាពរាជការ** ( Domaine public des collectivite Administratives ) ទ្រព្យដែលត្រូវរក្សា ឲ្យគង់រូប តាមធម្មជាតិរបស់វាដើម្បីទុកឲ្យជនអ្នករួមសង្គមប្រើប្រាស់ជាអង្វែងទៅដូចជាថ្នល់ ស្ពាន ល..

ទ្រព្យទាំងអស់នេះ គង់នៅជាសាធារណប្រយោជន៍ដរាបណាអ្នកផងនឹងលក់ និង ដូរមិនបានជាដាច់ខាតដរាបនោះ ។

**សម្បត្តិឯកជន នៃសមូហភាព** (Domaine prive des collectivites ) ទ្រព្យរបស់សង្គមណាមួយ ដែលមិនសម្រាប់ឲ្យជន ក្នុងសង្គមនោះ ប្រើប្រាស់ជាសាធារណទូទៅទេ ជាសម្បត្តិ ដែលសង្គមអាចលក់ដូរ ជួល ពាត់ឲ្យទៅអ្នកដទៃយកទៅធ្វើជាទ្រព្យរបស់ខ្លួនបាន ។ ដូចជាដី ក្រុងភ្នំពេញ ដែលជនជាតិខ្មែរម្នាក់ៗ អាចជួល ឬ ទិញពីរាជការក្រុងមកសង់ផ្ទះនៅបាន ។

**សម្បទាន** ( Concession ) ទ្រព្យដែលគេទិញ ឬ សុំដាច់ពីរដ្ឋមកធ្វើជាទ្រព្យរបស់គេ ។

**សមាមាត្រ** ( Proportion ) ការ ឬរបស់អ្វីមួយ ដែលសម ដែលល្មមនឹងការ ឬ របស់មួយទៀត ។ ឧ. ទណ្ឌកម្មដែលតុលាការបានផ្តន្ទានេះមានសមា-មាត្រ នឹងអំពើដែលជននោះបានប្រព្រឹត្តិហើយគឺថាសមរម្យនឹងអំពើនោះហើយ ។

**សមូហភាព** ( Collectivite ) ជនទាំងឡាយ ដែលមករួមគ្នា ជាក្រុម ឬ ជាសម្ពន្ធមួយ ។ មនុស្សទាំងអស់ ក្នុងឃុំ ក្នុងស្រុក ឬ ក្នុងក្រុងណាមួយ ហៅថា សមូហភាព ។

**សវនាការ** ( Audience ) ពេល ឬកន្លែងដែល តុលាការ ជំនុំជំរះក្តី ។ បុរាណ ពីដើម ហៅថាក្រឡាក្រម ។

**សហកម្មសិទ្ធិ** ( Co- propriete ) កម្មសិទ្ធិតែមួយជារបស់ជនច្រើននាក់ ។ ឧ. ជនច្រើននាក់រួបរួមគ្នាទិញរថយន្តមួយ ។ រថយន្តនោះជាសហកម្មសិទ្ធិរបស់ជនទាំងឡាយដែលទិញនោះ ។

**សហកម្មសិទ្ធិករ** ( Co- proprietaire ) អ្នកដែលមានសហកម្មសិទ្ធិ ។

**សហគមន៍** ( Communaute ) អ្វីៗដែលជនទាំងឡាយយកមករួមគ្នា ។

**សហចារី** ( Co-auteur ) អ្នកដែលចូលរួម ក្នុងការប្រព្រឹត្តិ នូវអំពើណាមួយជាអ្នកដៃដល់ ។

**សហទាយាទ** ( Co-heritier ) អ្នកដែលត្រូវចូលរួមក្នុងការចែកមត៌កណាមួយ ។

**សហព័ទ្ធ** ( Conjoint ) ប្តី ឬប្រពន្ធ , ឬទាំងប្តី ឬទាំងប្រពន្ធ ។

**សារទុក្ខ** (បណ្តឹង--) Pourvoi បណ្តឹងដែលប្តឹង ដល់សាលាវិនិច្ឆ័យដោយមិនសុខចិត្តនឹងសាលក្រម ឬ សាលដីការណាមួយ ។

**សារជាតិ** ( Substance ) សម្ភារៈគ្រប់យ៉ាង , អ្វីដែលឆ្ងាញ់ពិសារ , ដែលមានរស់ជាតិ ។

**សាលដីការ** ( Arret ) សេចក្តីសម្រេច របស់តុលាការ ជាន់ខ្ពស់ មានសាលាឧទ្ធរណ៍ និងសាលាវិនិច្ឆ័យជាដើម ។

**សិទ្ធិប្រទាន** (procuratuion) អំណាចដែលជនម្នាក់ ឲ្យទៅជនម្នាក់ទៀតឲ្យយកទៅប្រើប្រាស់ក្នុងនាមខ្លួន និងជំនួសខ្លួន ។

**សុពលភាព** ( validite) គុណភាពនៃអ្វីៗ ដែលនៅខ្លាំង, នៅមាំ, នៅមានតម្លៃថាជារបស់ត្រឹមត្រូវ ។

**សិទ្ធិវន្ត** (ayant-droit) អ្នកមានសិទ្ធិលើវត្ថុណាមួយ ។ ឧ. កាលណាអ្នកចង់ប៉ោកេ មានគ្រោះថ្នាក់ខ្លាំងដល់ស្លាប់ជាដើមសហព័ទ្ធនិងកូនទាំងឡាយដែលនៅក្នុងបន្ទុក នៃអ្នកនោះអាចទារតាវកលិកពីក្រុមប៉ោកេព្រោះខ្លួនមានគុណភាពជាសិទ្ធិ ។

**សិលាជាតិ** (carrier) កន្លែង ជាទីកើតនៃថ្ម, កន្លែងដែលគេជីកយកថ្ម ។

**សិល្បករ** (artisan) អ្នកធ្វើការអ្នកបង្កើតផលដោយដៃដើម្បីជាប្រយោជន៍ខ្លួនដោយធ្វើតែម្នាក់ឯងឬក៏មានប្រព័ន្ធ, កូនក្នុងគ្រួសារជួយធ្វើផង ។

**ស្ម ឬស្មបន្ទាល់** (prevue) អ្វីដែលជាទីតាំង ឬដែលចង្អុលបង្ហាញនូវការពិត, នូវសច្ចធម៌នៃវត្ថុណាមួយ ។ ឧ. សាក្សី, លិខិតឯកជន, លិខិតបញ្ជាក់ ទាំងអស់នេះជាស្មបន្ទាល់នៃកាតព្វកិច្ច ។

**សេនានីក្នុងកងទ័ព** ( officier de l"arm"e) ទាហាន ដែលមានបណ្ដាសក្ដិធំ តាំងពីអនុសេនីឯកឡើងទៅ ។

**សេវភាព** (servitude) បន្ទុកដែលផ្ទុកលើអចលវត្ថុម្យ៉ាងដែលហៅថាអចលវត្ថុ បម្រើដើម្បីជាប្រយោជន៍ដល់អចលវត្ថុម្យ៉ាងទៀតដែលហៅថាអចលវត្ថុប្រើ ។ ឧ. ស្រែក្រោមមានសេវភាពខាងទទួលទឹកពីស្រែលើ ។ ស្រែក្រោម ហៅថា ស្រែកបម្រើហើយស្រែលើហៅថាស្រែប្រើ ។

**សោធន** (pension) ប្រាក់ដែលគេឲ្យដល់ជនណាម្នាក់ដើម្បីឲ្យជននោះយកទៅចាយវាយក្នុងការចិញ្ចឹមជីវិត ។

**សោធន អាហារណីយ** (pension alimeniaire) សោធនដែលបើកឲ្យគ្រួសារមានប្រពន្ធកូនជាដើមដើម្បីយកទៅចិញ្ចឹមជីវិត ។

**សំណងចិត្ត** (indeminit") ប្រាក់ដែលឲ្យដើម្បីលប់លាងនូវព្យសនកម្មណាមួយ ។

**ស្ថាពរ** (d"finintif) ដែលសម្រេចរួចស្រេចអស់ហើយ, ឥតយកមកជំនុំជំរះ ឬ សម្រេចសេចក្ដីទៀតទេ ។

**ស្លាល័ក្ស** (scellé) ស្លាកធ្វើពីក្រដាស ឬធ្វើពីកំណាត់សំពត់មានបោះត្រា ដែលចៅក្រម ឬស្នងការប៉ូលីសយកទៅបិទ ដោយកាកល័ក្សនៅទ្វាផ្ទះ, ទ្វារទូជាដើមដើម្បីទុកជាបំរាមកុំឲ្យបើក ។

**ហត្ថលេខី** (signataire) អ្នកចុះហត្ថលេខា, អ្នកស៊ីញ៉េ ។

**ហិតូបត្ថម្ភកៈ** (curateur) ជនដែលច្បាប់ ចាត់ឲ្យឃុំគ្រងទ្រព្យរបស់អនីតិជន ដែលបានអត្តាធិនភាព ឬ របស់ជនល្ងីល្ងើជាដើម ។

**អ**

**អក្ខរាវិរុទ្ធ** (orthographé) កិរិយា នូវពាក្យ នៃភាសាណាមួយឲ្យបានត្រឹមត្រូវ ។

**អច្ច័យទាន** (legs) សំបុត្របណ្តាំដែលផ្តាំឲ្យចែកទ្រព្យមត៌កណាមួយទៅជនណាម្នាក់ ឬ ច្រើននាក់។

**អឌ្ឍសិទ្ធិ** (mitoyen) ដែលមានសិទ្ធិពាក់កណ្តាលម្នាក់, ដែលជារបស់ជនពីរនាក់និងជាព្រំនៃកម្មសិទ្ធិ នៃជនទាំងពីរនាក់នោះផង ។ ឧ. ជញ្ជាំង អឌ្ឍសិទ្ធិ គឺជញ្ជាំងរបស់ជនពីរនាក់ដែលមានផ្ទះជាប់គ្នា ។

**អឌ្ឍសិទ្ធិភាព** (mitoyenneté) ភាពដែលជាអឌ្ឍសិទ្ធិ ឧ. អឌ្ឍសិទ្ធិភាពនៃជញ្ជាំង ។

**អត្តសញ្ញាណ** (identit") សញ្ញាទាំងអស់នៃជនម្នាក់ៗ ដែលជាគ្រឿងសម្គាល់កុំឲ្យភាន់ច្រឡំ និងជនម្នាក់ទៀត ។

**អត្តាធិនភាព** (emancipation) ការបើកឲ្យក្មេងដែលនៅក្នុងអនីតិជននៅឡើយគ្រប់គ្រងខ្លួន និងទ្រព្យសម្បត្តិខ្លួនដោយខ្លួនឯង ។

**អត្ថគាហក** (b"n"ficiaire) អ្នកដែលបានចំណេញ ឬ បានកំរៃពីវត្ថុណាមួយ, ពីគុណប្រយោជន៍អ្វីមួយ ឬ ពីឯកសិទ្ធិណាមួយ ។

**អត្ថិភាព** (existence) ភាពដែលមាន ។ ឧ. អត្ថិភាព នៃព្រះអាទិទេព ។ ឧ. អស់អត្ថិភាព = អស់ជីវិត ។ រឿបរនៅ ឧ. អត្ថិភាពនៃកសិករ ។

**អធិលាភ** (la plus-value) កាកើនតម្លៃនៃទ្រព្យណាមួយ លើសពីតម្លៃមុន ។ តាមទ្រឹស្តីខ្លះ, អធិលាពគឺផលទាំងប៉ុន្មានដែលនាយទុនបានយកពីផលិតករមកដោយទុកឲ្យផលិតករតែប្រាក់ឈ្នួលបន្តិចបន្តួចល្មមតែរស់ប៉ុណ្ណោះ ។ តាមទ្រឹស្តី, នាយទុននិយម, ប្រាក់ថ្លៃផលិតដែលសល់ពីកាត់ប្រាក់ឈ្នួលផលិតករមកហៅថា អធិលាភ ។

**អនិយ័ត** ( alternative) មិនប្រាកដ ។ កាតព្វកិច្ចអនិយ័ត(មើលមាត្រា ៦៨៦) ឧ. ដើម្បីឲ្យកាតព្វកិច្ចរបស់ខ្ញុំមួយរលត់, ខ្ញុំត្រូវឲ្យសេះគេ ប្រាំ ឬ ឲ្យប្រាក់គេ ១000៛ ។ ការសងនេះមិនប្រាកដ ជាសងសេះ ឬប្រាក់ទេ ស្រេចតែលើខ្ញុំជា

កូនបំណុលរើសសងគេចុះ ។ កាតព្វកិច្ច ដូចបាននាំឧទាហរណ៍មកនេះហៅថា កាតព្វកិច្ចអនិយ័ត ។

**អនីតិភាព** (miuorit") ភាពនៃបុគ្គល អ្នកមានវ័យក្មេង ដែលច្បាប់ចាត់ទុកថាជាមនុស្សមានសមត្ថភាព មិនទាន់គ្រប់គ្រាន់ នឹងទទួលខុសត្រូវក្នុងអំពើដែលខ្លួនបានប្រព្រឹត្តនោះទេ ។

**អភិរក្ស សុរិយោដី** (របប-)

**អវត្តមាន** (absence) ការមិននៅ, មិនឃើញមុខ ឬបាត់ខ្លួនពីទីលំនៅអស់ពេលជាច្រើនឆ្នាំ ។

**អវយវភេទ** (d"menmbrement) ការបាក់បែកអវយវៈ។ក្នុងច្បាប់, អវយវភេទបានន័យថា ការផ្ទេរសិទ្ធិខ្លះរបស់ខ្លួនលើកម្មសិទ្ធិណាមួយឲ្យទៅអ្នកដទៃ ។ (មើលមាត្រា ៧២៩ និងតទៅ)

**អវិភាគភាព** (indivisibilit") ភាពដែលចែកគ្នា មិនបាប ។ ឧ. ផ្ទះមួយជាមត៌ករបស់កូនប្រាំនាក់ ។ បើកូនទាំងប្រាំនាក់ ពុះផ្ទះនោះចែកគ្នាផ្ទះនោះនឹងអន្តរាយជាមិនខាន ។ ដូច្នេះផ្ទះនោះជាមត៌កអវិភាគភាព ។

**អសមត្ថភាព** (incapacit") ដែលគ្មានសមត្ថភាព ជនអសមត្ថភាពគឺជនដែលគ្មានសមត្ថភាពនឹងរស់នៅដោយឥតអាណាព្យាបាលបាន, នឹងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនដោយខ្លួនឯងកើតដូចជាអនីតិជនជាដើម ។

**អាសារ-កម្មសិទ្ធិ** (un-propri"t") កម្មសិទ្ធិដែលឥតឲ្យផលដល់ម្ចាស់កម្មសិទ្ធិទេដោយហេតុថាម្ចាស់កម្មសិទ្ធិនោះឲ្យសិទ្ធិខ្លួននៅអ្នកដទៃស៊ីផលនៃកម្មសិទ្ធិនោះទាំងអស់ ។

**អាយ៍វត្ថុ** ( chose pr"cieuse) វត្ថុដែលមានតម្លៃច្រើន ។

**អាជ្ញាធរ** ( autorit") អ្នកទ្រទ្រង់អំណាច, អ្នករាជការ, ដែលកាន់អំណាច ។

**អាជ្ញាយុកាល** ( prescribtion) មធ្យោបាយម្យ៉ាងសម្រាប់ដោះខ្លួនឲ្យផុតពីកាតព្វកិច្ចណាមួយកាលណាបើម្ចាស់កាតព្វកិច្ចនោះបណ្ដែតបណ្ដោយឲ្យជំពាក់យូរពេកមិនតឹងទារមើលមាត្រា ៩២៨ ។

**អាហារសោធន** ( pension alimentaire) ប្រាក់ដែលជនម្នាក់ត្រូវឲ្យទៅជនម្នាក់ទៀតដើម្បីចិញ្ចឹមជីវិត ។

**ឯកសិទ្ធិ** ( privilege) អំណាចដែលត្រូវបានទៅជនណាម្នាក់ប្រើជាងជនដទៃទៀត ។

**ឧបាសកម្ម** (subrogation) ឧបាទេស ឬ ផ្ទេរអំណាចខ្លួនជាម្ចាស់បំណុលឲ្យទៅជនម្នាក់ទៀតកាន់ប្រើអំណាចនោះជួសខ្លួន ។

**ឯការធិភាព** (monopole) សិទ្ធិធ្វើ ឬ លក់របស់អ្វី ណាមួយជាមុខតែម្នាក់ឯង អ្នកផងនឹងធ្វើលក់ផងដែរមិនបាន ។

**ឱកាសទាន** (exequatur) ការឲ្យឱកាស ឬ បើកដៃឲ្យធ្វើអ្វីមួយបទបញ្ជា ឬ សេចក្ដីអនុញ្ញាត្តិឲ្យប្រតិបត្តិកិច្ចការអ្វីមួយ ។